សៀវភៅ
មគ្គុទេសក៍ណែនាំ
ជារូបភាព

# មគ្គុទេសក៍មូស្លីមថ្មី

ក្បួនច្បាប់ក្នុងឥស្លាមដែលងាយស្រួល ហើយនិងសេចក្តីបំភ្លឺជាលក្ខណៈច្បាប់ឥស្លាម
យ៉ាងសំខាន់បំផុតសម្រាប់អ្នកមូស្លីមថ្មីនៅក្នុងទិដ្ឋភាពនៃការរស់នៅទាំងមូល ។

លោក ហ្វាហាទ សាឡិម ពិន ហ៊ូម៉ាម

NEW MUSLIM GUIDE



# មគ្គុទេសក៍មូស្លីមថ្មី

## ក្បួនច្បាប់ឥស្លាមដែលងាយស្រួល ហើយនិងសេចក្តីបំភ្លឺជា
## លក្ខណៈច្បាប់ឥស្លាមយ៉ាងសំខាន់បំផុតសម្រាប់អ្នក
## មូស្លីមថ្មីនៅក្នុងទិដ្ឋភាពនៃការរស់នៅទាំងមូល។

លោក ហ្វាហាទ សាឡិម ពិន ហ៊ូម៉ាម

**បោះពុម្ពលើកទី១**

1441/2019
រក្សាសិទ្ធិក្នុងការបោះពុម្ព ការបកប្រែ និងការផ្សព្វផ្សាយ
តាមអេឡិកត្រូនិកទាំងអស់
ជូនក្រុមហ៊ុន អាត់ដាលីល អាល់មូអាសៀរ

K . S . A
ទូរស័ព្ទលេខ: +966114486000
ទូរសារ: +966114482181

بسم الله الرحمن الرحيم

| និពន្ធ | លោក ហ្វាហាទ សាឡិម ពិន ហ៊ូម៉ាម |
|---|---|
| អ្នកបកប្រែ | កូប សាក់រ៉នី, កូប អារី, សាន់ ហ្វាឌេល |
| អ្នកត្រួតពិនិត្យ | ម៉ាត់ លី, ម៉ាន វណ្ណា, សាហ្វអះ ទុលឡោះ, ម៉ាន់សួរ អាប់ឌុលឡោះ, ឆោម ភក្តី |
| រចនា | ក្រុមហ៊ុន មគ្គុទ្ទេសក៍សហសម័យ |
| ថតចំលង | គេហទំព័រនិងស្ទូឌីយោឯកទេសនៅជុំវិញពិភពលោក |
| ផ្សព្វផ្សាយ និងចែកផ្សាយ | ក្រុមហ៊ុន មគ្គុទ្ទេសក៍សហសម័យ |
| ផ្សព្វផ្សាយតាមអេឡិចត្រូនិក | ក្រុមហ៊ុន មគ្គុទ្ទេសក៍សហសម័យ |

# សេចក្តីផ្តើមរបស់អ្នកផ្សព្វផ្សាយ

ពិតប្រាកដណាស់ សាសនាឥស្លាម គឺជាសាសនាមួយដែលរីកសុសសាយឆាប់រហ័សជាងគេនៅលើសាកលលោក ដោយចំនួនអ្នកដែលចូលកាន់សាសនាឥស្លាមមានការកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ នោះគឺដោយសារតែឥស្លាម គឺជាសាសនាដ៏អមតៈរបស់អល់ឡោះដែលសមស្របទៅនិងប្រាជ្ញាចិត្តគំនិត វិញ្ញាណ និងធម្មជាតិរបស់មនុស្ស រួមជាមួយនឹងការខិតខំប្រឹងប្រែងដ៏ធំធេង និងប្រកបដោយពរជ័យរបស់បណ្តាមជ្ឈមណ្ឌលឥស្លាម និងបណ្តាឃោសនិកដែលជំនាញលើការអំពាវនាវអ្នកដែលមិនមែនកាន់សាសនាឥស្លាមនៅគ្រប់ទីកន្លែងលើពិភពលោក និងតាមរយៈមធ្យោបាយទំនើបៗជាច្រើន និងចំណេះដឹងសហសម័យ។ ប៉ុន្តែភាគច្រើននៃការប្រឹងប្រែងប្រកបដោយពរជ័យទាំងនោះ គឺឈរលើមូលដ្ឋាននៃការបង្ហាញមនុស្សលោកឲ្យចូលកាន់សាសនាឥស្លាម ប៉ុន្តែមិនបានផ្តល់នូវមគ្គុទេសក៍ និងទិសដៅច្បាស់លាស់សម្រាប់អ្នកដែលចូលឥស្លាម ហើយនិងអ្នកមូស្លីមថ្មីដើម្បីចាប់ដៃរបស់ពួកគេនៅលើមាគ៌ានៃការចង្អុលបង្ហាញដែលចាប់ផ្តើមដោយធ្វើសាក្សីទទួលស្គាល់អល់ឡោះជាម្ចាស់ដោយការពោលពាក្យសក្ខីកម្ម( ស្ហាហាហ្ទះ )នោះឡើយ។ លើសពីនេះ នៅមានរឿងជាច្រើនទៀតនៅចំពោះមុខដែលពួកគេត្រូវរៀនសូត្រ ជឿតាម និងអនុវត្តតាមនៅក្នុងគ្រប់បរិបទនៃជីវិតរស់នៅដើម្បីសម្រេចបានការចង្អុលបង្ហាញនៅក្នុងឆាកជីវិតរបស់ពួកគេ។

ហើយ "ទីរសាម៉ាអ៊ុលគូទុប" មានកិត្តិយសសូមជូនសៀវភៅ "មគ្គុទេសក៍អ្នកមូស្លីមថ្មី" ដែលនឹងបង្ហាញដល់អ្នកអាននូវការណែនាំ ក៏ដូចជាមេរៀនថ្មីៗអំពីសាសនាឥស្លាមដើម្បីជាការសិក្សា និងឈ្វេងយល់បន្ថែមអំពីសាសនាដ៏ល្អផូរផង់នេះ។ ហើយសៀវភៅនេះ ក៏ផ្តល់ជូនអ្នកអានផងដែរនូវមូលដ្ឋានគ្រឹះដែលយើងបានប្រមូលដកស្រង់ចេញពីគេហទំព័រ អ៊ីនធើណិត បណ្តាញសង្គម ឃ្លីបវីឌីអូអប់រំ និងកម្មវិធីទូរស័ព្ទនានា ដែលទាំងអស់នេះបានប្រមូលផ្តុំក្នុងការបម្រើដល់អ្នកអាន ពិសេសអ្នកមូស្លីមថ្មីដែលសំដៅទៅរកសាសនាអល់ឡោះនៅក្នុងគ្រប់ច្រកល្ហកនៃផែនដី។

យើងសុំពីអល់ឡោះប្រទានចិត្តស្មោះ និងភាពល្អប្រសើរទាំងក្នុងពាក្យសំដី និងការអនុវត្ត។



អ្នកផ្សព្វផ្សាយ

# មាតិកានៃសៀវភៅនេះ

## អារម្ភកថា




| មាតិកា | ទំព័រ |
|---|---|
| គុណប្រយោជន៍ដ៏ធំបំផុតនៃជីវិត | 24 |
| តើយើងត្រូវថ្លែងអំណរគុណចំពោះព្រះអល់ឡោះយ៉ាងដូចម្ដេច ? | 25 |
| គោលបំណងនៃជីវិតរបស់យើង | 25 |
| ឥស្លាមជាសាសនាសាកល | 26 |
| ក្នុងសាសនាឥស្លាមមិនមានអ្នកសំរបសំរួលរវាងព្រះជាម្ចាស់នឹងខ្ញុំរបស់ទ្រង់ឡើយ | 27 |
| ឥស្លាមគឺជាសាសនានៃជីវិត | 29 |
| ការស្ថាបនា | 29 |
| ការចូលរួមក្នុងសង្គម | 29 |
| ឥស្លាមជាសាសនានៃវិជ្ជា | 29 |
| ត្រូវសិក្សាស្វែងយល់ពីបទដ្ឋានឬច្បាប់ឥស្លាម | 30 |
| បទបញ្ញត្តិឥស្លាម | 31 |

| មាតិកា | ទំព័រ |
|---|---|
| គោលគ្រឹះឥស្លាមទាំងប្រាំ | 31 |
| តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បីដឹងពីបទដ្ឋានសាសនាឥស្លាម ? | 33 |
| ឥស្លាមជាសាសនាដែលមានលក្ខណៈអព្យាក្រឹត | 34 |
| សាសនាឥស្លាមគ្របដណ្ដប់គ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត | 35 |
| សូមមើលគំរូពិតរបស់ឥស្លាមពុំមែនដោយទង្វើរបស់ជនមូស្លីមខ្លះនោះទេ | 36 |
| សារៈសំខាន់ទាំងប្រាំ | 37 |
| សាសនា | 37 |
| ខ្លួនប្រាណ | 38 |
| ប្រាជ្ញា | 38 |
| ពូជអម្បូរ | 39 |
| ទ្រព្យសម្បត្តិ | 39 |

# 1 គោលជំនឿរបស់អ្នក




| មាតិកា | ទំព័រ |
|---|---|
| ពាក្យសច្ចាទាំងពីរ អត្ថន័យ និងភាពចាំបាច់របស់វា | 42 |
| ខ្ញុំសូមសច្ចាថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះ ហើយខ្ញុំសូមសច្ចាទៀតថា មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ | 42 |
| ហេតុអ្វីត្រូវពោលថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះ ? | 42 |
| អត្ថន័យនៃពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះ | 42 |
| គោលគ្រឹះនៃពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ គឺមានតែអល់ឡោះ | 43 |
| ការសច្ចាថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ | 44 |
| ការស្គាល់ព្យាការីមូហាំម៉ាត់ ( សូមពរជ័យ និងសន្តិភាពកើតមានដល់លោក ) | 44 |
| កំណើតរបស់ព្យាការីមូហាំម៉ាត់ | 44 |
| ជីវិត និងការធំពេលពេញវ័យរបស់ព្យាការីមូហាំម៉ាត់ | 44 |
| ការតែងតាំងព្យាការីមូហាំម៉ាត់ជាអ្នកនាំសារ | 45 |
| ការចាប់ផ្ដើមផ្សព្វផ្សាយរបស់ព្យាការីមូហាំម៉ាត់ | 45 |
| ការភៀសខ្លួនរបស់លោក | 46 |
| ការពង្រីកសាសនាឥស្លាមរបស់លោក | 46 |

| មាតិកា | ទំព័រ |
|---|---|
| មរណភាពរបស់ព្យាការីមូហាំម៉ាត់ | 47 |
| អត្ថន័យនៃពាក្យសច្ចាថា មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ | 48 |
| តើជំនឿខ្ញុំថា ព្យាការីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះត្រូវមានអ្វីខ្លះ ? | 48 |
| ជំនឿចំពោះដំណឹងទាំងឡាយដែលអ្នកនាំសារបានប្រាប់ក្នុងគ្រប់វិស័យទាំងអស់ដូចជា | 48 |
| ការប្រតិបត្តិតាមបទបញ្ញត្តិ និងការជៀសវាងពីបម្រាមរបស់អ្នកនាំសារដូចជា | 48 |
| យើងត្រូវគោរពសក្ការៈចំពោះអល់ឡោះស្របតាមច្បាប់របស់អ្នកនាំសារ ហើយច្បាប់នោះមាន | 49 |
| គោលជំនឿទាំងប្រាំមួយ | 51 |
| អត្ថន័យនៃជំនឿចំពោះព្រះអល់ឡោះ | 51 |
| ជំនឿថា ព្រះអល់ឡោះមានពិត | 51 |
| និស្ស័យដែលព្រះអល់ឡោះផ្ដល់ពីកំណើត | 51 |
| ភស្តុតាងដែលបញ្ជាក់ថាព្រះអល់ឡោះមានពិត វាច្បាស់ជាងការរំឭកប្រាប់ និងការគណនា ដូចជា | 51 |
| ជំនឿចំពោះភាពជាម្ចាស់របស់អល់ឡោះ | 52 |
| ពួកអារ៉ាប់ដែលគោរពពហុទេពនៅសម័យអ្នកនាំសារ ពួកគេមានជំនឿចំពោះភាពជាព្រះជាម្ចាស់របស់ព្រះអល់ឡោះ | 54 |
| ជំនឿចំពោះភាពជាព្រះជាម្ចាស់របស់អល់ឡោះធ្វើឲ្យចិត្តស្ងប់ ស្កប់ស្កល់ | 54 |
| ជំនឿចំពោះភាពជាព្រះដែលត្រូវគេគោរពសក្ការៈរបស់ព្រះអល់ឡោះ | 55 |

| មាតិកា | ទំព័រ |
|---|---|
| សារៈសំខាន់នៃជំនឿចំពោះភាពជាព្រះ ដែលត្រូវគោរពសក្ការៈរបស់ព្រះអល់ឡោះ | 56 |
| **តើការគោរពសក្ការៈមានន័យដូចម្ដេច?** | 57 |
| ការគោរពសក្ការៈប្រព្រឹត្តទៅលើគ្រប់វិស័យរស់នៅរបស់មនុស្សលោក | 57 |
| ការគោរពសក្ការៈគឺជាគតិបណ្ឌិតនៃការបង្កើត (ជិន និងមនុស្សលោក) | 58 |
| លក្ខខណ្ឌនៃការគោរពសក្ការៈ | 59 |
| **ពហុទេពនិយម(ស៊ីរិក)** | 60 |
| ពហុទេពនិយមមានពីរប្រភេទៈពហុទេពនិយមកម្រិតធ្ងន់ និងពហុទេពនិយមកម្រិតស្រាល | 61 |
| **តើការស្នើសុំចំពោះមនុស្សលោកជាទង្វើពហុទេពនិយមដែរឬទេ?** | 61 |
| **ជំនឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់អល់ឡោះ** | 63 |
| អំពីព្រះនាមខ្លះៗរបស់អល់ឡោះ | 63 |
| ផលប្រយោជន៍នៃជំនឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់អល់ឡោះ | 64 |
| លំដាប់ខ្ពស់បំផុតនៃជំនឿ | 64 |
| អំពីផលប្រយោជន៍នៃជំនឿចំពោះអល់ឡោះ | 65 |
| **ជំនឿចំពោះម៉ាឡាអ៊ីកាត់(ពួកទេវតា)** | 66 |
| អត្ថន័យនៃជំនឿចំពោះម៉ាឡាអ៊ីកាត់ (ពួកទេវតា) | 66 |
| ជំនឿចំពោះម៉ាឡាអ៊ីកាត់(ពួកទេវតា) មានអ្វីខ្លះ? | 66 |
| ផលប្រយោជន៍នៃជំនឿចំពោះម៉ាឡាអ៊ីកាត់ (ពួកទេវតា) | 67 |

| មាតិកា | ទំព័រ |
|---|---|
| **ជំនឿចំពោះព្រះគម្ពីរ** | 68 |
| អត្ថន័យនៃជំនឿចំពោះព្រះគម្ពីរ | 68 |
| តើជំនឿចំពោះព្រះគម្ពីរមានអ្វីខ្លះ? | 68 |
| លក្ខណៈពិសេសនៃគម្ពីរគួរអាន | 69 |
| អ្វីជាកាតព្វកិច្ចលើយើងចំពោះគម្ពីរអាល់គួរអានដ៏ប្រពៃនេះ? | 70 |
| អ្វីជាគោលជំហររបស់យើងចំពោះអ្វីដែលមាននៅក្នុងព្រះគម្ពីរមុនៗ? | 71 |
| ផលប្រយោជន៍នៃជំនឿចំពោះគម្ពីរ | 72 |
| **ជំនឿចំពោះពួកអ្នកនាំសារ** | 73 |
| តម្រូវការរបស់មនុស្សចំពោះសាររបស់ព្រះជាម្ចាស់ | 73 |
| គោលគ្រឹះមួយនៃគោលគ្រឹះនៃជំនឿ | 73 |
| អត្ថន័យនៃជំនឿចំពោះពួកអ្នកនាំសារ | 74 |
| តើជំនឿចំពោះអ្នកនាំសារមានអ្វីខ្លះ? | 74 |
| អំពីលក្ខណៈសម្បត្តិរបស់អ្នកនាំសារ | 75 |
| សញ្ញា និងអច្ឆរិយភាពរបស់អ្នកនាំសារ | 76 |
| ជំនឿរបស់អ្នកមូស្លីមចំពោះព្យាការីអ៊ីសា ឬយេស៊ូ | 76 |
| ជំនឿចំពោះមូហាំម៉ាត់ជាព្យាការី និងជាអ្នកនាំសាររបស់ព្រះ | 78 |
| លក្ខណៈពិសេសនៃសាររបស់ព្យាការីមូហាំម៉ាត់ | 79 |
| ផលប្រយោជន៍នៃជំនឿចំពោះអ្នកនាំសារ | 80 |
| **ជំនឿចំពោះថ្ងៃបរលោក** | 81 |
| អត្ថន័យនៃជំនឿចំពោះថ្ងៃបរលោក | 81 |

| មាតិកា | ទំព័រ |
|---|---|
| តើជំនឿចំពោះថ្ងៃបរលោកមានអ្វីខ្លះ? | 82 |
| អំពីភស្តុតាងនៃគម្ពីរគួរអានបញ្ជាក់ថា មនុស្សក្នុងផ្នូរទាំងអស់រស់ឡើងវិញគឺ | 82 |
| ផលប្រយោជន៍នៃជំនឿចំពោះថ្ងៃបរលោក | 85 |
| ជំនឿចំពោះព្រះលិខិត | 86 |

| មាតិកា | ទំព័រ |
|---|---|
| អត្ថន័យនៃជំនឿចំពោះព្រះលិខិត | 86 |
| តើជំនឿចំពោះព្រះលិខិតមានអ្វីខ្លះ? | 86 |
| មនុស្សលោកមានសិទ្ធិជ្រើសរើស មានលទ្ធភាព និងចេតនាខ្លួនឯង | 87 |
| យកលេសនឹងព្រះលិខិត | 88 |
| ផលប្រយោជន៍នៃជំនឿលើព្រះលិខិត | 88 |


## 2 ជំពូកទី២ អនាម័យរបស់អ្នក




| មាតិកា | ទំព័រ |
|---|---|
| និយមន័យនៃពាក្យ ការជម្រះសម្អាត | 92 |
| តើអ្វីជាការសម្អាតដែលគេទាមទារចង់បានសម្រាប់សឡាត(ថ្វាយបង្គំ)? | 92 |
| ការជម្រះសម្អាតពីប្រការកខ្វក់ | 93 |
| ប្រការដែលកខ្វក់នោះគឺ | 93 |
| ការជម្រះសម្អាតពីប្រការកខ្វក់(ណាជីស) | 93 |
| សុជីវធម៌ក្នុងការបន្ទោបង់ និងការសម្អាត | 94 |
| អាល់ហាហ្ទាស(ភាពកខ្វក់ផ្នែកបញ្ញត្តិច្បាប់) | 95 |

| មាតិកា | ទំព័រ |
|---|---|
| ហាហ្ទាសតូច និងការយកទឹកជម្រះកាយ (យកទឹកវូហ្ឌុ) | 95 |
| តើខ្ញុំយកទឹកជម្រះកាយយ៉ាងដូចម្តេច? | 96 |
| តើខ្ញុំយកទឹកជម្រះកាយ និងជម្រះសម្អាតហាហ្ទាសតូចយ៉ាងដូចម្តេច? | 96 |
| ហាហ្ទាសធំ និងការងូតទឹក | 98 |
| តើអ្នកមូស្លីមត្រូវជម្រះសម្អាតពីជូនុប និងហាហ្ទាសធំយ៉ាងដូចម្តេច? | 99 |
| ការជូតលើស្រោមជើង: | 99 |
| បុគ្គលដែលគ្មានលទ្ធភាពប្រើប្រាស់ទឹក: | 99 |

# 3 ការសឡាតរបស់អ្នក




| មាតិកា | ទំព័រ |
| --- | --- |
| ការសឡាត(ថ្វាយបង្គំ) | 102 |
| ឋានៈ និងគុណសម្បត្តិនៃការសឡាត | 102 |
| ផលបុណ្យនៃការសឡាត | 103 |
| ជនណាខ្លះដែលចាំបាច់ត្រូវសឡាត? | 104 |
| តើអ្វីទៅជាលក្ខខណ្ឌដែលចាំបាច់ត្រូវមានវាមុនពេលសឡាត? | 105 |
| ជ្រះស្អាតអំពីហាហ្វាស និងប្រការកខ្វក់ទាំងឡាយ | 105 |
| បិទបាំងអារ៉ាត់(កេរខ្មាស) | 105 |
| តម្រង់មុខទៅទិសគិបឡាត់ | 106 |
| ចូលដល់ពេលវេលាសឡាត | 106 |
| ការសឡាតដែលជាកាតព្វកិច្ចទាំងប្រាំពេល និងពេលវេលារបស់វា | 107 |
| កន្លែងសឡាត | 108 |
| របៀបនៃការសឡាត | 111 |
| តើអ្នកមិនបានទន្ទេញ អាល់ហ្វាទីហះ និងហ្សីកៀរក្នុងសឡាត ត្រូវធ្វើដូចម្ដេច? | 112 |
| តើខ្ញុំត្រូវសឡាតដូចម្ដេច?(ការឈរ ការឱនរូកុ ការស៊ូជោទ) | 118 |
| តើខ្ញុំត្រូវសឡាតដូចម្ដេច? (រ៉ក្អាត់ទីពីរ អាត់តាសាសហ៊ុទ ឲ្យសាឡាម) | 120 |
| គោលគ្រឹះនៃសឡាត(រូកុនសឡាត) និងកាតព្វកិច្ច(ប្រការវ៉ាជិប)របស់វា | 122 |
| ប្រការដែលនាំឱ្យខូចសឡាត | 124 |
| ប្រការដែលមិនគប្បីធ្វើពេលសឡាត | 124 |

| មាតិកា | ទំព័រ |
| --- | --- |
| តើអ្វីទៅជាការសឡាតស៊ូណិត? | 125 |
| ពេលវេលាដែលគេហាមឃាត់មិនឱ្យសឡាតស៊ូណិត | 126 |
| សឡាតជើម៉ាអះ(សឡាតរួមគ្នា) | 127 |
| តើត្រូវបំពេញដូចម្ដេចនូវអ្វីដែលគេបានខកខានជាមួយអ៊ីម៉ាំ? | 128 |
| តើនឹងអ្វីទៅដែលបញ្ជាក់ថា បានទាន់មួយរ៉ក្អាត់(ជាមួយអ៊ីម៉ាំ)? | 128 |
| ការប្រកាសហៅឱ្យមកសឡាត(អាហ្សាន) | 129 |
| របៀបអាហ្សាន និង អ៊ីក៏ម៉ាត់ | 129 |
| អាហ្សាន | 129 |
| អ៊ីក៏ម៉ាត់ | 130 |
| ការសូត្រតាមក្រោយអ្នកអាហ្សាន | 130 |
| វិធីសាស្ត្រដែលធ្វើឱ្យមានចិត្តនឹងនរក្នុងពេលសឡាត | 131 |
| ត្រូវមានឆន្ទៈក្នុងការសឡាត និងការត្រៀមខ្លួនសម្រាប់វា | 131 |
| ចេញឱ្យឆ្ងាយពីប្រការដែលនាំឱ្យរំខាន | 131 |
| ភាពនឹងនរក្នុងពេលសឡាត | 132 |
| បង្ហាញពីភាពខ្ពង់ខ្ពស់របស់អ្នកដែលយើងនឹងឈរចំពោះមុខ | 132 |
| ត្រូវត្រិះរិះពិចារណាអំពីអាយ៉ាត់ដែលបានសូត្រ នឹងហ្សីកៀរផ្សេងទៀតនៅក្នុងសឡាត ហើយបង្កើតសកម្មភាពជាមួយវា | 132 |
| សឡាតជុមអាត់(ថ្វាយបង្គំថ្ងៃសុក្រ) | 133 |

| មាតិកា | ទំព័រ |
| --- | --- |
| តើអ្នកណាខ្លះដែលចាំបាច់ត្រូវចូលរួមសឡាតជុមអាត់? | 133 |
| របៀប និងច្បាប់ដែលទាក់ទងនឹងសឡាតជុមអាត់ | 134 |
| តើអ្នកណាដែលគេអធ្យាស្រ័យឱ្យក្នុងការមិនបានមកសឡាតជុមអាត់? | 134 |

| មាតិកា | ទំព័រ |
| --- | --- |
| តើពេលវេលាធ្វើការជាមូលហេតុអាចបោះបង់សឡាតជុមអាត់បានដែរឬអត់? | 135 |
| សឡាតសម្រាប់អ្នកជំងឺ | 136 |
| សឡាតសម្រាប់អ្នកធ្វើដំណើរ | 137 |


# 4 ការបួសរបស់អ្នក




| មាតិកា | ទំព័រ |
| --- | --- |
| ការបួសខែរ៉ម៉ាហ្វន | 140 |
| អត្ថន័យនៃការបួស | 140 |
| ឧត្តមភាពនៃខែរ៉ម៉ាហ្វន | 140 |
| គោលបំណងនៃការបួស | 141 |
| គុណប្រយោជន៍នៃការបួស | 142 |
| ប្រការដែលបណ្តាលឲ្យខូចបួស | 143 |
| អ្នកដែលអល់ឡោះអនុញ្ញាតឲ្យផ្អាកបួសបាន | 144 |
| អ្នកជំងឺ | 144 |
| អ្នកអសមត្ថភាពក្នុងការបួស | 144 |
| អ្នកដំណើរ | 144 |
| ស្ត្រីមានរដូវ និងមានឈាមពេលសំរាល | 144 |
| ស្ត្រីមានផ្ទៃពោះ | 144 |

| មាតិកា | ទំព័រ |
| --- | --- |
| តើច្បាប់កំណត់បែបណាចំពោះអ្នកដែលមិនបួសក្នុងខែរ៉ម៉ាហ្វន? | 145 |
| ការបួសស៊ូណ្ណិត(ការបួសដែលមិនមែនជាកាតព្វកិច្ច) | 145 |
| ការបួសថ្ងៃអាស៊ូរ៉ា (عَاشُوْرَاءُ) | 145 |
| ការបួសថ្ងៃអារ៉ហ្វ (عَرَفَةُ) | 145 |
| ការបួសប្រាំមួយថ្ងៃនៃខែស្ហាវ៉ាល់ (شَوَالُ) | 145 |
| ថ្ងៃបុណ្យស្រាយបួស(រ៉យ៉ាហ្វិតរ៉ោះ) | 146 |
| ថ្ងៃបុណ្យ(រ៉យ៉ា)នៅក្នុងសាសនាឥស្លាម | 146 |
| ថ្ងៃបុណ្យ(រ៉យ៉ា)របស់ជនមូស្លីម | 146 |
| ថ្ងៃបុណ្យស្រាយបួស(រ៉យ៉ាហ្វិតរ៉ោះ) | 146 |
| តើច្បាប់តម្រូវឲ្យធ្វើអ្វីខ្លះនាថ្ងៃបុណ្យ? | 147 |

# 5 ហ្សាកាត់របស់អ្នក




| មាតិកា | ទំព័រ |
|---|---|
| ការបរិច្ចាគហ្សាកាត់ | 152 |
| តើទ្រព្យសម្បត្តិអ្វីដែលចាំបាច់ត្រូវបរិច្ចាគហ្សាកាត់? | 153 |
| មាស និង ប្រាក់ ដែលមិនសម្រាប់ប្រើគ្រឿងអលង្ការ | 153 |
| ទ្រព្យសម្បត្តិ និង លុំហូរសាច់ប្រាក់ដែលមានជារូបិយប័ណ្ណខុសគ្នា | 153 |
| ពាណិជ្ជកម្ម | 154 |

| មាតិកា | ទំព័រ |
|---|---|
| ដំណាំដែលដុះចេញពីដីនៃគ្រាប់ធញ្ញជាតិនិងដំណាំផ្លែឈើ អល់ឡោះបានមានបន្ទូលថា: | 154 |
| ទ្រព្យសម្បត្តិដែលជាសត្វ មានសត្វគោ សត្វអូដ្ឋ និងសត្វពពែតែប៉ុណ្ណោះ | 154 |
| តើហ្សាកាត់ត្រូវបរិច្ចាគទៅឲ្យអ្នកណា? | 155 |
| អ្នកដែលត្រូវទទួលហ្សាកាត់មានដូចខាងក្រោម: | 155 |


# 6 ការធ្វើធម្មយាត្រាហាជ្ជីរបស់អ្នក




| មាតិកា | ទំព័រ |
|---|---|
| ធម្មយាត្រាហាជ្ជី | 158 |
| អត្ថន័យនៃការធ្វើធម្មយាត្រាហាជ្ជី | 160 |
| ស្ថានភាពអ្នកមូស្លីមដែលមានលទ្ធភាពដើម្បីធ្វើធម្មយាត្រាហាជ្ជី | 161 |
| លក្ខខណ្ឌមានម៉ះរិម | 162 |
| គុណប្រយោជន៍នៃការធ្វើធម្មយាត្រាហាជ្ជី | 162 |
| គោលបំណងនៃការធ្វើធម្មយាត្រាហាជ្ជី | 163 |
| ការធ្វើអ៊ុំរ៉ោះ | 165 |
| ថ្ងៃបុណ្យអាល់អាដហា (ថ្ងៃរ៉យាហាជ្ជី) | 166 |

| មាតិកា | ទំព័រ |
|---|---|
| តើច្បាប់បង្គាប់ប្រើអ្វីខ្លះនៅក្នុងថ្ងៃបុណ្យអាល់អាដហា? | 166 |
| លក្ខខណ្ឌសម្រាប់សត្វដែលយកទៅសម្លេះ មានដូចជា | 167 |
| តើត្រូវធ្វើដូចម្ដេចជាមួយនឹងអាល់អោឌហ៊ីយ៉ះ(សត្វសម្រាប់សម្លេះក្នុងថ្ងៃបុណ្យរ៉យាហាជ្ជី)? | 167 |
| ការទស្សនកិច្ចទីក្រុង ម៉ាទីណះ | 168 |
| តើទីកន្លែងណាដែលច្បាប់កំណត់ឱ្យទៅទស្សនាវានៅក្នុងទីក្រុងម៉ាទីណះ? | 168 |

# 7 ប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក




| មាតិកា | ទំព័រ |
|---|---|
| មូលដ្ឋាននៃប្រតិបត្តិការនានាគឺត្រូវបានអនុញ្ញាត (ហាឡាល់) | 172 |
| ប្រការហាមឃាត់ដោយសារខ្លួនរបស់វាផ្ទាល់ | 172 |
| ប្រការហាមឃាត់ដោយសារវិធីរកវា | 172 |
| ការប្រាក់ | 173 |
| ការប្រាក់ក្នុងបំណុល | 173 |
| ការប្រាក់ក្នុងប្រាក់កម្ចី | 173 |
| ច្បាប់ឥស្លាមស្តីពីការប្រាក់ | 174 |
| ទណ្ឌកម្មនៃការប្រាក់ | 174 |
| ហានិភ័យរបស់ការប្រាក់ទៅលើបុគ្គលនិងសង្គម | 175 |
| ភាពមិនច្បាស់លាស់និងការមិនដឹងច្បាស់ | 175 |
| ភាពអយុត្តិធម៌ និងការយកទ្រព្យសម្បត្តិរបស់មនុស្សដោយមិនត្រឹមត្រូវ | 175 |
| ល្បែងស៊ីសង | 175 |
| ផលប៉ះពាល់នៃល្បែងស៊ីសងទៅលើបុគ្គលនិងសង្គម | 175 |
| ក្រមសីលធម៌ដែលឥស្លាមបានសង្កត់ធ្ងន់នៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុគឺ៖ | 176 |
| ទំនុកចិត្ត | 177 |
| ភាពទៀងត្រង់ | 177 |
| ភាពច្បាស់លាស់ | 177 |
| ភាពអយុត្តិធម៌ និងការយកទ្រព្យសម្បត្តិអ្នកដទៃដោយមិនត្រឹមត្រូវ | 178 |
| ការបង្ខិតបង្ខំ | 178 |

| មាតិកា | ទំព័រ |
|---|---|
| ការបោកប្រាស់ និងលួចបន្លំមនុស្ស | 178 |
| លេងសើចលើច្បាប់ | 178 |
| សំណូក | 179 |
| តើច្បាប់ចែងដូចម្តេចចំពោះបុគ្គលដែលបានចូលឥស្លាម ហើយមុនគាត់ចូលឥស្លាម គាត់បានយកទ្រព្យសម្បត្តិអ្នកដទៃដោយមិនត្រឹមត្រូវ? | 179 |
| ល្បែងស៊ីសង | 180 |
| តើល្បែងស៊ីសងជាអ្វី? | 180 |
| ច្បាប់របស់វា | 180 |
| ល្បែងស៊ីសងបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គម | 180 |
| ប្រភេទនៃល្បែងស៊ីសង | 181 |
| សុជីវធម៌ដែលឥស្លាមបានសង្កត់ធ្ងន់ក្នុងការទំនាក់ទំនងប្រតិបត្តិការហិរញ្ញវត្ថុ | 182 |
| ស្មោះត្រង់ | 182 |
| សេចក្តីទៀងត្រង់ | 183 |
| ជំនាញ និងធ្វើការល្អ | 183 |

## 8 ចំណីអាហាររបស់អ្នក និងភេសជ្ជៈរបស់អ្នក




| មាតិកា | ទំព័រ |
| --- | --- |
| ធាតុដើមនៃអាហារ និងភេសជ្ជៈ | 186 |
| ដំណាំ និងផល្លានុផល | 186 |
| សុរា និង ជាតិអាល់កុល | 187 |
| ការថែរក្សាសតិសម្បជញ្ញៈ | 187 |
| ច្បាប់អ៊ីស្លាមទាក់ទងនឹងសុរា | 187 |
| គ្រឿងញៀន | 188 |
| អាហារសមុទ្រ | 188 |
| សត្វនៅលើដី | 189 |

| មាតិកា | ទំព័រ |
| --- | --- |
| តើសត្វអ្វីខ្លះដែលគេអនុញ្ញាតឱ្យបរិភោគ? | 189 |
| ប្រភេទសត្វដែលគេអនុគ្រោះ | 190 |
| ការសម្លេះសត្វតាមក្បួនច្បាប់ឥស្លាម | 190 |
| ប្រភេទសាច់ដែលបម្រើនៅក្នុងភោជនីយដ្ឋាន និងហាង | 190 |
| ការប្រមាញ់តាមក្បួនច្បាប់ឥស្លាម | 191 |
| សីលធម៌នៃការទទួលទានអាហារ និងភេសជ្ជៈ | 192 |


## 9 សម្លៀកបំពាក់របស់អ្នក




| មាតិកា | ទំព័រ |
| --- | --- |
| សម្លៀកបំពាក់នៅក្នុងសាសនាឥស្លាម | 196 |
| សម្លៀកបំពាក់សម្រេចបាននូវសេចក្តីត្រូវការជាច្រើន | 196 |

| មាតិកា | ទំព័រ |
| --- | --- |
| ធាតុដើមនៃសម្លៀកបំពាក់ | 197 |
| សម្លៀកបំពាក់ដែលគេហាមឃាត់ | 198 |

# 10 គ្រួសាររបស់អ្នក




| មាតិកា | ទំព័រ |
| --- | --- |
| ឋានៈគ្រួសារនៅក្នុងសាសនាឥស្លាម | 202 |
| ឋានៈស្ត្រីនៅក្នុងសាសនាឥស្លាម | 204 |
| ស្ត្រីត្រូវបានឥស្លាមយកចិត្តទុកដាក់ថែទាំចំពោះពួកនាង | 204 |
| ម្ដាយ | 204 |
| កូនស្រី | 205 |
| ប្រពន្ធ | 205 |
| គ្មានជម្លោះទេរវាងភេទទាំងពីរ | 205 |
| ប្រភេទស្ត្រីចំពោះបុរស | 206 |
| ស្ត្រីជាប្រពន្ធរបស់គាត់: | 206 |
| ស្ត្រីដែលជាម៉ុះរ៉ម(មិនអនុញ្ញាតឱ្យរៀបការជាមួយបាន)របស់គាត់ | 206 |
| ស្ត្រីអាចូព្យាការីយ៉ះ(ស្ត្រីដែលអាចរៀបការជាមួយបាន) | 209 |
| វិធីសាស្ត្រទំនាក់ទំនងរវាងបុរស និងស្ត្រីអាចូព្យាការីយ៉ះ(ស្ត្រីដែលអាចរៀបការជាមួយបាន) | 210 |
| ដាក់ក្រសែភ្នែកចុះពីការសម្លឹងមើល | 210 |
| ការទំនាក់ទំនងដោយសីលធម៌ និងសុជីវធម៌ | 210 |
| ហាមឃាត់ពីការនៅកន្លែងស្ងាត់ៗ | 210 |
| ហ៊ីហ្សាប(អ្វីដែលយកមកបិទបាំងរាងកាយដែលច្បាប់បានបង្គាប់ប្រើ ) | 211 |

| មាតិកា | ទំព័រ |
| --- | --- |
| ព្រំដែននៃការពាក់ហ៊ីហ្សាប | 211 |
| វិធីសាស្ត្រពាក់ហ៊ីហ្សាប | 211 |
| ការរៀបអាពាហ៍ពិពាហ៍នៅក្នុងសាសនាឥស្លាម | 212 |
| លក្ខខណ្ឌសាសនាឥស្លាមចំពោះប្រពន្ធ | 212 |
| លក្ខខណ្ឌសាសនាឥស្លាមចំពោះប្ដី | 213 |
| សិទ្ធិរបស់ប្ដីប្រពន្ធ | 214 |
| សិទ្ធិរបស់ប្រពន្ធ | 214 |
| ផ្គត់ផ្គង់និងលំនៅដ្ឋាន | 214 |
| រស់នៅដោយមានសុភមង្គល | 215 |
| អត់ធ្មត់និងការអត់ឱន | 215 |
| ផ្ដល់ការស្នាក់នៅ | 216 |
| ការពារនាងពីព្រោះនាងជាកិត្តិយសនិងភាពថ្លៃថ្នូររបស់គាត់ | 216 |
| មិនត្រូវបញ្ចេញរឿងសម្ងាត់រវាងប្ដីប្រពន្ធឡើយ | 216 |
| មិនត្រូវរំលោភបំពានទៅលើស្ត្រីឡើយ | 216 |
| ការបង្រៀន និងផ្ដល់ដំបូន្មានដល់នាង | 217 |
| ការប្រកាន់ខ្ជាប់នូវលក្ខខណ្ឌរបស់ប្រពន្ធ | 217 |
| សិទ្ធិរបស់ប្ដី | 218 |
| ចាំបាច់ត្រូវគោរពដោយសមរម្យ | 218 |

| មាតិកា | ទំព័រ |
|---|---|
| ផ្តល់លទ្ធភាពឱ្យប្តីដើម្បីទទួលបានភាពរីករាយ | 218 |
| ស្ត្រីមិនត្រូវអនុញ្ញាតឱ្យអ្នកដែលប្តីមិនចូលចិត្តចូលក្នុងផ្ទះឡើយ | 218 |
| ស្ត្រីមិនអាចចេញពីផ្ទះទៅលើកលែងតែមានការអនុញ្ញាតពីប្តីរបស់នាង | 218 |
| ការបម្រើរបស់ប្រពន្ធចំពោះប្តី | 218 |
| **ការលែងលះ** | 219 |
| **សិទ្ធិរបស់ឪពុកម្តាយ** | 220 |

| មាតិកា | ទំព័រ |
|---|---|
| ប្រការគ្រោះថ្នាក់ពីភាពអកតញ្ញូចំពោះឪពុកម្តាយ និងធ្វើអាក្រក់ទៅលើគាត់ | 220 |
| ការគោរពតាមគាត់ទាំងពីរក្រៅពីប្រការដែលប្រឆាំងចំពោះអល់ឡោះ | 221 |
| ការធ្វើល្អជាមួយលោកទាំងពីរ ជាពិសេសក្នុងពេលលោកទាំងពីរចាស់ជរា | 221 |
| ឪពុកម្តាយជាអ្នកគ្មានជំនឿ | 221 |
| **សិទ្ធិរបស់កូនៗ** | 222 |

# 11 សីលធម៌របស់អ្នកនៅក្នុងសាសនាឥស្លាម




| មាតិកា | ទំព័រ |
|---|---|
| ឋានៈរបស់សីលធម៌ក្នុងសាសនាឥស្លាម | 226 |
| វាគឺជាផ្នែកមួយនៃគោលបំណងសំខាន់បំផុតនៃការតែងតាំងព្យាការីមកដល់មនុស្ស | 226 |
| សីលធម៌ជាផ្នែកមួយយ៉ាងជិតស្និទ្ធនៃជំនឿ និងការជឿជាក់ | 226 |
| សីលធម៌មានទំនាក់ទំនងជាមួយនឹងការគោរពបូជាគ្រប់ប្រភេទ | 226 |
| គុណសម្បត្តិដ៏អស្ចារ្យ និងផលបុណ្យយ៉ាងធំធេងដែលអល់ឡោះបានរៀបចំសម្រាប់អ្នកដែលមានសីលធម៌ល្អ | 227 |
| លក្ខណៈពិសេសនៃសីលធម៌ល្អក្នុងសាសនាឥស្លាម | 228 |
| សីលធម៌ល្អគឺមិនមែនសម្រាប់តែប្រភេទមនុស្សមួយចំនួននោះទេ | 228 |
| សីលធម៌ល្អគឺមិនមែនសម្រាប់តែមនុស្សនោះទេ | 229 |
| សីលធម៌ល្អមានគ្រប់វិស័យទាំងអស់នៃជីវិត | 230 |

| មាតិកា | ទំព័រ |
|---|---|
| គ្រួសារ | 230 |
| ពាណិជ្ជកម្ម | 230 |
| ឧស្សាហកម្ម | 230 |
| សីលធម៌ល្អមានគ្រប់ករណីទាំងអស់ | 231 |
| អំពីសីលធម៌ឥស្លាមក្នុងពេលធ្វើសង្គ្រាម | 231 |
| រូបភាពក្នុងសម័យកាលព្យាការីរស់នៅ | 232 |
| ការឱនលំទោន | 232 |
| ការអាណិតស្រឡាញ់ | 233 |
| ការអាណិតស្រឡាញ់របស់លោកទៅចំពោះកូនក្មេង | 233 |
| ការអាណិតស្រឡាញ់របស់លោកទៅចំពោះស្ត្រី | 234 |
| ការអាណិតស្រឡាញ់របស់លោកជាមួយនឹងអ្នកទន់ខ្សោយ | 235 |
| យុត្តិធម៌ | 236 |
| សេចក្តីសប្បុរស និងចិត្តទូលាយ | 237 |

# 12 ជីវិតថ្មីរបស់អ្នក




| មាតិកា | ទំព័រ |
|---|---|
| តើធ្វើដូចម្ដេចដើម្បីចូលសាសនាឥស្លាម ? | 240 |
| ការងូតទឹកសម្រាប់អ្នកចូលឥស្លាមថ្មី | 240 |
| ការទទួលសារភាពកំហុស | 241 |
| តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីឱ្យការទទួលសារភាពកំហុសបានត្រឹមត្រូវ ? | 241 |
| ត្រូវបញ្ឈប់ការប្រព្រឹត្តអំពើបាបកម្ម | 241 |
| ការសោកស្ដាយចំពោះការប្រព្រឹត្តអំពើបាបកម្មដែលកន្លងផុតទៅ | 241 |
| ការប្ដេជ្ញាចិត្តមិនវិលត្រឡប់ទៅប្រព្រឹត្តវាទៀត | 241 |
| ផែនការដើម្បីសម្រេចការប្ដេជ្ញាចិត្ត | 241 |
| តើមានអ្វីកើតឡើងបន្ទាប់ពីការទទួលសារភាពកំហុស ? | 242 |
| រសជាតិនៃជំនឿ | 242 |
| ការថ្លែងអំណរគុណទៅចំពោះគុណូបការៈនៃការចង្អុលបង្ហាញនិងការទទួលសារភាពកំហុស | 243 |
| ប្រកាន់ខ្ជាប់នឹងសាសនា ហើយអត់ធ្មត់នឹងប្រការលំបាកក្នុងវា | 243 |
| ឧស្សាហ៍ព្យាយាមក្នុងការអំពាវនាវមនុស្សទៅរកឥស្លាមដោយគតិបណ្ឌិតនិងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អ | 244 |

| មាតិកា | ទំព័រ |
|---|---|
| ការអំពាវនាវទៅកាន់សាសនាឥស្លាម | 244 |
| គុណសម្បត្តិនៃការអំពាវនាវទៅរកអល់ឡោះ | 244 |
| របៀបអំពាវនាវដែលត្រឹមត្រូវ | 245 |
| ការចេះដឹងច្បាស់លាស់ និងចំណេះដឹង | 245 |
| អំពាវនាវដោយគតិបណ្ឌិត | 246 |
| ការអំពាវនាវក្រុមគ្រួសារ | 247 |
| ការចូលឥស្លាមរបស់កូនក្មេង | 248 |
| តើនៅពេលណាទើបយើងអាចកាត់ក្ដីថាកុមារៗដែលគ្មានជំនឿជាអ្នកមានជំនឿវិញនៅក្នុងលោកិយនេះ ? | 248 |
| តើគេអនុញ្ញាតក្នុងការផ្លាស់ប្ដូរឈ្មោះបន្ទាប់ពីចូលសាសនាឥស្លាមដែរឬទេ ? | 250 |
| ចាំបាច់ត្រូវផ្លាស់ប្ដូរឈ្មោះក្នុងករណីដែលមានដូចខាងក្រោមនេះ | 250 |
| ប្រការដែលគប្បីក្នុងការផ្លាស់ប្ដូរឈ្មោះ | 251 |
| លក្ខណៈនៃភាពស្អាតស្អំ ( ស៊ូណានុលហ្វីតរ៉ោះ ) | 252 |
| តើលក្ខណៈនៃភាពស្អាតស្អំ( ស៊ូណានុលហ្វីតរ៉ោះ )មានអត្ថន័យដូចម្ដេច ? | 252 |

# សេចក្តីផ្តើមនៃសៀវភៅ

សូមអបអរសាទរចំពោះអ្នក ដោយអល់ឡោះធ្វើឲ្យងាយស្រួល និងបានទទួលភាពសំបូរសប្បាយទៅលើអ្នកដោយបានការចង្អុលបង្ហាញ ហើយបានចាកចេញផុតអំពីសភាពងងឹតទៅរកពន្លឺភ្លឺស្វាង និងប្រកាន់សាសនាឥស្លាមដ៏ធំធេងនេះ។

ហើយសូមអបអរសាទរអ្នកចំពោះសេចក្តីក្លាហាននោះ និងវត្ថុបំណងស្វែងរកការពិតដែលធ្វើឲ្យអ្នកសម្រេចចិត្តយ៉ាងសំខាន់ក្នុងឆាកជីវិតរបស់អ្នកដោយបានចូលកាន់សាសនាដ៏ធំធេងនេះ។

ហើយអ្នកណាបានទិញឧបករណ៍ ឬបានចូលរួមក្នុងក្លិបណាមួយ ឬក្រុមណាមួយ ឬអង្គការណាមួយដែលចាប់អារម្មណ៍ក្នុងការអានហើយនិងស្គាល់អ្វីដែលវាត្រូវទទួលបានហើយអ្វីដែលជាកាតព្វកិច្ចលើវាឲ្យធ្វើ ហើយធ្វើយ៉ាងណាដំណោះស្រាយជាមួយស្ថានការថ្មី។

ចុះយ៉ាងម៉េចដែរចំពោះអ្នកដែលអល់ឡោះបានប្រទានពរជ័យ ដោយបានចាកចេញផុតអំពីភាពងងឹតស្លុងទៅកាន់ពន្លឺភ្លឺស្វាង ហើយបានជួយជ្រោមជ្រែងបានទទួលការបង្ហាញផ្លូវ និងបានទទួលកាន់សាសនាឥស្លាម។ ដូច្នេះគ្មានសង្ស័យឡើយថា ប្រាកដណាស់សេចក្តីប្រាថ្នាដ៏ធំបំផុតដើម្បីយល់ដឹងក្បួនច្បាប់សាសនារបស់គេដើម្បីគោរពសក្ការៈទៅចំពោះអល់ឡោះដោយឈរលើការយល់ដឹងទូលំទូលាយនិងមានចំនេះដឹងហើយអាចប្រឈមនឹងការប្រែប្រួលជុំវិញខ្លួនវាទាំងអស់ស្របទៅតាមក្បួនច្បាប់ឥស្លាមដែលពោរពេញដោយការអត់ឱន។

ហើយជាការផ្តល់ដំណឹងល្អសម្រាប់អ្នកនៅពេលដែលអ្នកបានរៀនសូត្រដែលថា ព័ត៌មានទាំងនេះដែលអ្នកកំពុងរៀន វាគឺជាកេរមរតកនៃបណ្តាព្យាការី និងបណ្តាអ្នកនាំសារទាំងឡាយ ព្រោះថាប្រាកដណាស់ បណ្តាព្យាការីទាំងអស់មិនបានបន្សល់ទុកកេរមរតកទ្រព្យសម្បត្តិអ្វីហើយនិងរបស់របរអ្វីឡើយ គឺមានតែបន្សល់ទុកចំណេះដឹងសាសនាប៉ុណ្ណោះ។ ដូច្នេះជនណាហើយបានរៀនសូត្រចំណេះដឹងសាសនា ប្រាកដជាគេបានទទួលលាភដ៏ធំធេងហើយ និងគុណសម្បត្តិដ៏សន្ធឹកសន្ធាប់នៃកេរមរតកពួកព្យាការី។(អាពូទើវូទ : ៨៨)

ហើយមគ្គុទេសន៍ដែលត្រូវបានធ្វើជារូបភាពនេះ វានឹងផ្តល់ឲ្យអ្នក(សម្រាប់អ្នកកាន់សាសនាឥស្លាមថ្មី) ជាជំហានទី១ និងជាកម្រិតមូលដ្ឋានក្នុងការយល់ដឹងសាសនាដ៏ធំធេងនេះដែលជាការប្រទានមួយធំបំផុតសម្រាប់មនុស្សលោក នៅគ្រប់ទិដ្ឋភាពទាំងអស់នៃឆាកជីវិតដែលអ្នកកំពុងរស់នៅ និងដែលអ្នកកំពុងត្រូវការចំពោះវា។ ដូច្នេះដែរ មគ្គុទ្ទេសន៍នេះ វានឹងឆ្លើយតបទៅលើសំណួរបន្ទាន់ជាច្រើនរបស់អ្នក ហើយវាជួយគាំទ្រអ្នកក្នុងការប្រឈមនឹងការពិតដែលនៅជុំវិញខ្លួនអ្នក ដោយតាមរចនាបទច្បាស់លាស់ងាយស្រួល ហើយនិងទទួលបានព័ត៌មានជាក់លាក់ និងត្រឹមត្រូវបានចងក្រងឡើងដោយអនុលោមទៅតាមព្រះគម្ពីរគួរអាន និងស៊ុណ្ណះ(លំអាន)របស់ព្យាការីមូហាំម៉ាត់ ហើយដោយសារសៀវភៅជាមគ្គុទ្ទេសន៍ដ៏ពិស្តារដែលគួឲ្យចាប់អារម្មណ៍សម្រាប់អាននេះ វាក៏ជាឯកសារយោងដែលអ្នកអាចត្រលប់ទៅរកព័ត៌មានពិស្តាររបស់វាយ៉ាងងាយស្រួលបំផុតរៀងរាល់ពេលដែលអ្នកប្រឈមនឹងបញ្ហា ឬក៏អ្នកត្រូវការយល់ដឹងអំពីក្បួនច្បាប់របស់អល់ឡោះនៅក្នុងរឿងអ្វីមួយ។

យើងសុំបួងសួងចំពោះព្រះអល់ឡោះជាម្ចាស់ឲ្យអ្នកកាន់តែបន្ថែមនូវការធ្វើឲ្យងាយស្រួល និងបានបំភ្លឺក្នុងចិត្ត ហើយបានស្ងប់ចិត្តស្ថិតស្ថេរ នៅលើការគោរពតាមអល់ឡោះ និងសាសនារបស់ទ្រង់ ហើយវាធ្វើឲ្យអ្នកទទួលបាននូវពរជ័យ និងភាពរីកចម្រើនគ្រប់ទិសទី ហើយសុំឲ្យទ្រង់ប្រមូលផ្តុំពួកយើងទាំងអស់គ្នានៅក្នុងទីកន្លែងស្នាក់នៅដ៏ថ្លៃថ្នូរ ដែលទ្រង់ប្រទានឲ្យនៅជាមួយពួកព្យាការីៗនិងពួកអ្នកសាងកុសលទាំងឡាយផងចុះ។





# អារម្ភកថា



## មាតិកានៃអារម្ភកថា


គុណប្រយោជន៍ដ៏ធំបំផុតនៃជីវិត

គោលបំណងនៃជីវិតរបស់យើង

ឥស្លាមជាសាសនាសាកល

ក្នុងសាសនាឥស្លាមមិនមានអ្នកសម្របសម្រួលរវាងព្រះជាម្ចាស់ និងខ្ញុំរបស់ទ្រង់ឡើយ

ឥស្លាមគឺជាសាសនានៃជីវិត

ត្រូវសិក្សាស្វែងយល់ពីបទដ្ឋាន ឬច្បាប់ឥស្លាម

បទបញ្ញត្តិឥស្លាម

តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីដឹងពីច្បាប់សាសនា( ឥស្លាម ) ?

ឥស្លាមជាសាសនានៃភាពអព្យាក្រឹត

សាសនាឥស្លាមគ្របដណ្តប់គ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត

សូមមើលគំរូពិតរបស់ឥស្លាមពុំមែនដោយទង្វើរបស់មូស្លីមខ្លះនោះទេ

សារៈសំខាន់ទាំងប្រាំ

## > គុណប្រយោជន៍ដ៏ធំបំផុតនៃជីវិត

ព្រះអល់ឡោះជាម្ចាស់ទ្រង់មានព្រះគុណមកលើមនុស្សលោកយ៉ាងច្រើនដោយមិនអាចគណនាបានឡើយ។ទ្រង់បានផ្តល់ឲ្យមនុស្សនូវការមើលឃើញ និងការស្តាប់លឺ ខណៈដែលមនុស្សដទៃទៀតជាច្រើនមិនបានទទួលវាឡើយ។ លើសពីនេះទៀត ទ្រង់បានផ្តល់ដល់មនុស្សលោកនូវគំនិត និងប្រាជ្ញាឈ្លាសវៃ និងសុខភាពមាំមួន ព្រមទាំងទ្រព្យសម្បត្តិជាច្រើនទៀតផង។ ព្រះអល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយប្រសិនបើពួកអ្នករាប់ព្រះគុណរបស់ទ្រង់នោះ គឺពួកអ្នកមិនអាចរាប់វាអស់ឡើយ”។ (គម្ពីរគួរអាន ១៦:១៨)

ប៉ុន្តែព្រះគុណទាំងនេះ នឹងសាបសូន្យទៅវិញនៅពេលចុងបញ្ចប់នៃជីវិតរបស់យើងបានមក ដល់ហើយមានតែព្រះគុណមួយគត់ដែលធ្វើឲ្យយើងមានសុភមង្គល និងសុខដុមរមនាទាំង លោកិយ និងថ្ងៃបរលោក នោះគឺព្រះគុណរបស់ ទ្រង់ដែលបានបង្ហាញផ្លូវឲ្យយើងបានស្គាល់ សាសនាឥស្លាម ។ នេះជាព្រះគុណមួយដ៏ធំធេងបំផុតដែលទ្រង់បានប្រទានមកលើបណ្តាខ្ញុំរបស់ទ្រង់។

ហេតុដូចនេះហើយទើបទ្រង់បានភ្ជាប់ ព្រះគុណនេះទៅចំពោះទ្រង់ ជាការលើកតម្កើងចំពោះវា។ ព្រះអល់ឡោះបានមានបន្ទូលថាៈ “ថ្ងៃនេះយើងបានបំពេញសាសនារបស់ពួកអ្នកឲ្យពួកអ្នក និងបានបង្គ្រប់ព្រះគុណរបស់យើង ឲ្យពួកអ្នក ហើយយើងបានជ្រើសរើសសាសនាឥស្លាមជាសាសនារបស់ពួកអ្នក”។ ( គម្ពីរគួរអាន ៣:៣)

ពិតជាព្រះគុណដ៏ធំធេងណាស់ចំពោះមនុស្សការដែលទ្រង់បានបញ្ចៀសរូបគេចេញពីផ្លូវងងឹតហើយបានបង្ហាញផ្លូវឲ្យគេស្គាល់សាសនាដែលទ្រង់យល់ព្រម ដើម្បីជាការបំពេញនូវគោលបំណង និងតួនាទីដែលគេត្រូវបានបង្កើតសម្រាប់តួនាទីនោះ វាគឺជាការគោរពសក្ការៈទៅចំពោះអល់ឡោះ នៅពេលនោះពួកគេពិតជាទទួលបាននូវសុភមង្គលក្នុងលោកិយនេះ និងការតបស្នងយ៉ាងធំធេងបំផុតនៅថ្ងៃបរលោក។



> សាសនាឥស្លាម គឺជាការប្រសិទ្ធិពរធំបំផុតនៅក្នុងលោកិយ

ជាការប្រសើរបំផុតសម្រាប់យើងទាំងអស់គ្នាដែលទ្រង់ បានជ្រើសរើសយើងដើម្បីឲ្យយើងក្លាយទៅជាពលរដ្ឋមួយដ៏ល្អប្រសើរបំផុតសម្រាប់ឲ្យយើងគាំពារនូវពាក្យថា គ្មានទេម្ចាស់ដែលគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ ដែលវា គឺជាពាក្យដែលអល់ឡោះបានបញ្ជូនមកលើបណ្តាអ្នកនាំសាររបស់ទ្រង់ទាំងឡាយ។

នៅពេលដែលមានក្រុមឆោតល្ងង់មួយក្រុមដែលពួកគេមានអំនួតថា ឥស្លាមត្រូវអរគុណ ដល់ពួកគេ ព្រោះពួកគេបានចូលកាន់សាសនាឥស្លាម ផ្ទុយទៅវិញ អ្នកដែលគេត្រូវថ្លែង អំណរគុណនោះគឺ ព្រះ អ ល់ ឡោះ តែ មួ យ គ ត់ ព្រោះទ្រង់ជាម្ចាស់ដែលបានបង្ហាញផ្លូវដល់ពួកគេ រហូតពួកគេបានស្គាល់សាសនាដ៏ពិតមួយនេះ។

ព្រះអល់ឡោះមានបន្ទូលថាៈ “ពួកគេបានចាត់ទុកថា ការចូលសាសនាឥស្លាមរបស់ពួកគេផ្តល់ផលប្រយោជន៍ដល់អ្នក( ព្យាការីមូហាំម៉ាត់ )។ ចូរអ្នកពោលថាៈ អ្នកកុំចាត់ទុកការចូលសាសនាឥស្លាមរបស់ពួកអ្នក ផ្តល់ផលប្រយោជន៍ដល់ខ្ញុំឲ្យសោះ។ ផ្ទុយទៅវិញ អល់ឡោះទេដែលប្រទានព្រះគុណរបស់ទ្រង់ដល់ពួកអ្នកដោយទ្រង់បានចង្អុលបង្ហាញពួកអ្នកទៅរកភាពមានជំនឿ ប្រសិនបើពួកអ្នក ជាអ្នកនិយាយពិតនោះ”។ (គម្ពីរគួរអាន ៤៩:១៧)

ព្រះគុណរបស់អល់ឡោះដែលទ្រង់បានផ្ដល់មកលើយើងគឺច្រើនបំផុត តែព្រះគុណមួយគត់ដែលទ្រង់រំឭកពីគុណសម្បត្តិរបស់ទ្រង់នោះ គឺការដែលទ្រង់បានបង្ហាញផ្លូវឲ្យយើងបានស្គាល់ឥស្លាម និងគោរពសក្ការៈចំពោះទ្រង់តែមួយគត់នោះ។ ហេតុនេះ ចាំបាច់ត្រូវថ្លែងអំណរអរគុណដល់ព្រះជាម្ចាស់ដើម្បីឲ្យព្រះគុណរបស់ទ្រង់ស្ថិតនៅជាមួយយើងជារៀងរហូត។ ទ្រង់មានព្រះបន្ទូលថាៈ “ប្រាកដណាស់ ប្រសិនបើពួកអ្នកដឹងគុណ( ដល់ព្រះគុណរបស់យើង )យើងពិតជានឹងបន្ថែមការប្រោសប្រទានដល់ពួកអ្នកទៀត”។

តើយើងត្រូវអរគុណចំពោះព្រះអល់ឡោះយ៉ាងដូចម្ដេច?

ការអរគុណទៅចំពោះអល់ឡោះតាមរយៈប្រការពីរដូចខាងក្រោមៈ

1. ត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវសាសនាឥស្លាម ហើយត្រូវមានការអត់ធ្មត់ចំពោះឧបសគ្គទាំងឡាយ។
2. ផ្សព្វផ្សាយសាសនាឥស្លាមដល់អ្នកដទៃដោយស្របតាមគម្ពីរគួរអាននិងសុណ្ណៈ ( លំអានរបស់ព្យាការី )ជាមួយនឹងការអត់ធ្មត់។

## > គោលបំណងនៃជីវិតរបស់យើង

មនុស្សជាច្រើនមានការងឿងឆ្ងល់នូវចម្លើយមួយដ៏សំខាន់ក្នុងជីវិតរបស់យើង

តើហេតុអ្វីបានជាយើងមានវត្តមាននៅទីនេះ?

តើអ្វីទៅជាគោលបំណងនៃជីវិតរបស់យើង?

ជាការពិតណាស់ គម្ពីរគួរអានបានកំណត់គោលបំណងយ៉ាងច្បាស់លាស់លើការមានវត្តមានរបស់មនុស្សនៅក្នុងលោកនេះដោយគ្មានការស្រពិចស្រពិលឡើយ។ ព្រះអល់ឡោះទ្រង់មានបន្ទូលថា៖ "ហើយយើងមិនបានបង្កើតជិន(អមនុស្ស) និងមនុស្ស ក្រៅពីឲ្យពួកគេគោរពសក្ការៈមកចំពោះយើងឡើយ។(គម្ពីរគួរអាន ៥១:៥៦)។ ដូច្នេះ ការគោរពសក្ការៈទៅចំពោះព្រះជាម្ចាស់ជាគោលបំណងនៃវត្តមានរបស់យើងនៅលើផែនដីនេះ ហើយក្រៅពីនោះគឺគ្រាន់តែជាមធ្យោបាយប៉ុណ្ណោះ។

ក៏ប៉ុន្តែការគោរពសក្ការៈក្នុងឥស្លាមមិនមានន័យថា ត្រូវលះបង់ចោលការសោយសុខ និងភាពសប្បាយរីករាយនោះទេ។ ផ្ទុយទៅវិញ ការគោរពសក្ការៈនោះ រួមបញ្ចូលទាំងការសឡាត( ថ្វាយបង្គំ) ការបួស ការបរិច្ចាគហ្សាកាត់ រាល់ពាក្យសំដី និងទង្វើរបស់គេ ដូចជាការឆ្នៃប្រឌិតថ្មី និងការទំនាក់ទំនងជាដើម រហូតដល់សូម្បីតែការលេងកម្សាន្តសប្បាយ( ក៏ជាការគោរពសក្ការៈទៅចំពោះអល់ឡោះជាម្ចាស់ដែរ) ដរាបណាគេមាននៀត( ការតាំងចិត្ត )ដោយចិត្តស្មោះបរិសុទ្ធ និងជ្រះថ្លាចំពោះទ្រង់។ ព្យាការីមូហាំម៉ាត់ លោកបានមានប្រសាសន៍ថាៈ "ការរួមដំណេករបស់ពួកអ្នកជាមួយភរិយារបស់ពួកអ្នក គឺជាការបិច្ចាគទានមួយ"។ (មូស្លីមៈ១០០៦) គឺមានន័យថា ជនមូស្លីមនឹងទទួលផលបុណ្យពីម្ចាស់របស់គេ សូម្បីតែការសប្បាយរីករាយរបស់ពួកគេជាមួយភរិយារបស់ពួកគេក៏ដោយ។

ហើយតាមរយៈការនៀតរបស់គេនោះ កិច្ចការទាំងនោះ គឺនឹងក្លាយជាការគោរពសក្ការៈទៅចំពោះអល់ឡោះជាម្ចាស់ ខណៈដែលវាគឺជាតម្រូវការរបស់ជីវិត និងជាភាពពិតប្រាកដនៃជីវិត។ ជាការពិតអ្នកមូស្លីមគឺតែងតែប្រព្រឹត្តនូវគ្រប់ប្រភេទនៃការគោរពសក្ការៈទៅចំពោះអល់ឡោះ ដូចព្រះអល់ឡោះបានមានព្រះបន្ទូលថា៖ "ចូរអ្នក( ព្យាការីមូហាំម៉ាត់ )ពោលថា ពិតប្រាកដណាស់ ការសឡាតរបស់ខ្ញុំ និងការបូជាសត្វរបស់ខ្ញុំ និងការរស់នៅរបស់ខ្ញុំ ហើយនិងសេចក្ដីស្លាប់របស់ខ្ញុំ គឺសម្រាប់អល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពលោកទាំងអស់"។ ( គម្ពីរគួរអាន ៦:១៦២ )

## > ឥស្លាមជាសាសនាសាកល

ឥស្លាមជាសាសនាដែលនាំមកនូវសេចក្តីមេត្តាករុណានិងការចង្អុលបង្ហាញសម្រាប់មនុស្សជាតិលើលោកទាំងមូល ទោះជាពួកគេមានវប្បធម៌ ឬប្រពៃណី និងទំនៀមទម្លាប់ខុសគ្នាយ៉ាងណាក៏ដោយ។ ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថាៈ "ហើយយើងមិនបានបញ្ជូនអ្នក(មូហាំម៉ាត់)ឡើយ លើកលែងតែដើម្បីផ្តល់ក្តីមេត្តាករុណាទៅចំពោះពិភពលោកប៉ុណ្ណោះ"។ (គម្ពីរគួរអាន ២១:១០៧)

ហេតុនេះហើយបានជាឥស្លាមគោរពរាល់វប្បធម៌និងប្រពៃណីរបស់ពួកគេ ហើយឥស្លាមមិនបានបង្ខំឲ្យអ្នកឥស្លាមណាម្នាក់ប្តូរប្រពៃណី ឬវប្បធម៌របស់ពួកគេឡើយ លើកលែងតែវប្បធម៌ ឬប្រពៃណីទាំងនោះផ្ទុយពីច្បាប់ ឬបទដ្ឋានឥស្លាម ហើយអ្វីដែលផ្ទុយពីឥស្លាម គឺត្រូវតែបោះបង់ចោល ពីព្រោះព្រះអល់ឡោះជាម្ចាស់ដែលដាក់បង្គាប់មកលើយើង ទ្រង់មហាដឹងជ្រួតជ្រាបលើអ្វីៗទាំងអស់ ហើយកាលណាយើងមានជំនឿលើទ្រង់ គឺយើងត្រូវតែទទួលយកបទបញ្ជារបស់ទ្រង់។

ហើយត្រូវដឹងដែរថាៈ រាល់ប្រពៃណីរបស់ជនមូស្លីមដែលមិនទាក់ទងនឹងឥស្លាមឬច្បាប់ឥស្លាមនោះគឺមិនចាំបាច់ត្រូវតែយកតម្រាប់តាមនោះទេ។

លើភពផែនដីទាំងមូលនេះ ជាកន្លែងគោរពសក្ការៈទៅចំពោះព្រះអល់ឡោះ

ឥស្លាមបានចាត់ទុកថា គ្រប់ទីកន្លែងនៅលើផែនដីនេះ គឺយើងអាចរស់នៅ និងអាចគោរពសក្ការៈទៅចំពោះអល់ឡោះបាន។ នៅក្នុងសាសនាឥស្លាម គឺមិនបានកំណត់ប្រទេស ឬកន្លែងណាមួយមកលើជនមូស្លីមដើម្បីធ្វើការគោរពសក្ការៈទៅចំពោះព្រះនោះឡើយ ផ្ទុយទៅវិញ អ្នកមូស្លីមអាចគោរពសក្ការៈទៅចំពោះព្រះជាម្ចាស់បានគ្រប់ទីកន្លែង។

ហើយជនមូស្លីមមិនចាំបាច់ធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយនោះទេ លើកលែងតែមានការហាមឃាត់មិនឲ្យពួកគេគោរពទៅចំពោះទ្រង់(នៅកន្លែងដែលគេរស់នៅនោះ)។ នៅពេលនោះ គេអាចធ្វើដំណើរចេញពីតំបន់នោះដើម្បីទៅរកកន្លែងដែលគេអាចគោរពសក្ការៈចំពោះព្រះអល់ឡោះបាន។ ព្រះអល់ឡោះទ្រង់មានបន្ទូលថាៈ “ឱបណ្តាខ្ញុំរបស់យើងដែលមានជំនឿ! ពិតប្រាកដណាស់ ផែនដីរបស់យើង គឺធំទូលាយ។ (ដូច្នេះ ចូរពួកអ្នកភៀសខ្លួនទៅកន្លែងដែលមានសុវត្ថិភាព) ហើយពួកអ្នកត្រូវគោរពសក្ការៈមកចំពោះយើងតែមួយគត់”។ (គម្ពីរគួរអាន ២៩: ៦)



## > ក្នុងសាសនាឥស្លាម មិនមានអ្នកសម្របសម្រួលរវាងព្រះជាម្ចាស់ និងខ្ញុំរបស់ទ្រង់ឡើយ

មានសាសនាជាច្រើនបានផ្តល់ឋានៈសក្តិក្នុងសាសនាទៅឲ្យបុគ្គលមួយចំនួនលើសពីអ្នកដទៃ ហើយរាល់ជំនឿ និងការគោរពសក្ការៈនានា គឺនៅលើការសម្រេច និងការយល់ព្រមរបស់ពួកគេប៉ុណ្ណោះ ហើយពួកគេជាអ្នកដែលលុបលាងកំហុស ហើយមានអ្នកខ្លះក្នុងចំណោមពួកគេបានអះអាងថា គេជាអ្នកដឹងពីប្រការអាថ៌កំបាំង ហើយការធ្វើអ្វីខុសពីដំបូន្មានពួកគេ នឹងបណ្តាលឲ្យមានការខាតបង់ទៀតផង។

រីឯឥស្លាមវិញ ជាសាសនាមួយដែលបានឲ្យតម្លៃទៅលើមនុស្សជាតិនិងលើកកិត្តិយសរបស់ពួកគេ ហើយឥស្លាមបានបដិសេធរាល់ការគោរពសក្ការៈណាមួយដែលមានការទំនាក់ទំនងនឹងបុគ្គលណាម្នាក់នោះ ទោះបីបុគ្គលនោះមានកុសល ឬឋានៈខ្ពង់ខ្ពស់យ៉ាងណាក៏ដោយ។

ការគោរពសក្ការៈរបស់មូស្លីមទៅចំពោះអល់ឡោះ គឺរវាងបុគ្គលនោះជាមួយនឹងទ្រង់ផ្ទាល់ ដោយមិនចាំបាច់ពឹងពាក់បុគ្គលណាម្នាក់ឡើយ ពីព្រោះទ្រង់ជាម្ចាស់ដែលស្ថិតនៅក្បែរយើងជានិច្ច ទ្រង់ឮនូវអ្វីដែលខ្ញុំរបស់ទ្រង់បួងសួងសុំ ទ្រង់ឃើញរាល់ការគោរពសក្ការៈខ្ញុំរបស់ទ្រង់ ហើយទ្រង់នឹងតបស្នងលើទង្វើទាំងនោះ។ គ្មានបុគ្គលណាម្នាក់មានសិទ្ធិលុបលាងកំហុសឲ្យអ្នកណាម្នាក់បានឡើយ។ ផ្ទុយទៅវិញ បុគ្គលណាសុំអភ័យទោសពីព្រះជាម្ចាស់ដោយចិត្តស្មោះស នោះទ្រង់នឹងអភ័យទោសឲ្យគេជាមិនខាន។



> ក្នុងសាសនាឥស្លាមមិនមានអ្នកសំរបសំរួលរវាងព្រះជាម្ចាស់នឹងខ្ញុំរបស់ទ្រង់ឡើយ

ហើយឥស្លាមជាសាសនាមួយដែលបានជម្រុញឲ្យជនមូស្លីមធ្វើការសញ្ជឹងគិតនិងពិចារណា ថែមទាំងបង្គាប់ឲ្យប្រកាន់ខ្ជាប់នូវការយកព្រះគម្ពីរគួរអាននិងពាក្យសម្ដីរបស់ព្យាការីមូហាំម៉ាត់ជាគោលក្នុងការកាត់សេចក្ដី រាល់ពេលដែលមានការខ្វែងគំនិតអ្វីមួយនោះ។

ហើយគ្មានបុគ្គលណាម្នាក់ដែលគេត្រូវស្ដាប់តាមទាំងស្រុងក្រៅពីព្យាការីមូហាំម៉ាត់នោះឡើយ ព្រោះរាល់ពាក្យសម្ដីរបស់គាត់ គឺជាការចង្អុលបង្ហាញរបស់ព្រះជាម្ចាស់។ ទ្រង់បានមានបន្ទូលថាៈ "ហើយគេ(មូហាំម៉ាត់)ក៏មិននិយាយតាមទំនើងចិត្តដែរ។ វា(ពាក្យសំដីដែលគេនិយាយ)គ្មានអ្វីក្រៅពីវ៉ាហ៊ី(សារពីអល់ឡោះ)ដែលត្រូវគេវ៉ាហ៊ីមកនោះឡើយ"។ (គម្ពីរគួរអាន ៥៣ៈ៣-៤)

នេះជាព្រះគុណដ៏ធំធេងបំផុតដែលទ្រង់បានប្រទានសាសនាឥស្លាមមកលើយើងទាំងអស់គ្នា ដែលជាសាសនាមួយសមស្របនឹងនិស្ស័យធម្មជាតិដែលមានពីកំណើតរបស់មនុស្ស។ លើសពីនេះទៅទៀត ឥស្លាមជាសាសនាដែលផ្ដល់តម្លៃឲ្យមនុស្សគ្រប់រូប និងឲ្យគេជាអ្នកម្ចាស់ការលើខ្លួនឯងផ្ទាល់ដោយមិនពឹងពាក់អ្នកដទៃក្រៅពីអល់ឡោះឡើយ។



## > ឥស្លាមគឺជាសាសនានៃជីវិត:

ឥស្លាម គឺជាសាសនាមួយដែលមានតុល្យភាព រវាងជីវិតលោកិយ និងថ្ងៃបរលោក។ ហេតុនេះ ឥស្លាមបានចាត់ទុកលោកិយនេះ ជាថ្នាលសម្រាប់សាងអំពើកុសល ហើយគេនឹងទទួលផ្លែផ្កានេះនៅថ្ងៃបរលោកជាមិនខានឡើយ។ ហើយរាល់អំពើកុសលត្រូវមានគំនិតសុទិដ្ឋិនិយមលើជីវិត និងត្រូវមានការប្រឹងប្រែងក្នុងជីវិត។ ភស្តុតាងដែលបញ្ជាក់នោះគឺ៖

### ការស្ថាបនា:

ព្រះអល់ឡោះជាម្ចាស់បានមានបន្ទូលថា: “ទ្រង់ជាអ្នកដែលចាប់ផ្តើមបង្កើតពួកអ្នកពីដី ហើយទ្រង់ក៏បានឲ្យពួកអ្នកតាំងទីលំនៅលើវា”។ (គម្ពីរគួរអាន ១១:៦១)

ជាកាពិតណាស់ ទ្រង់បាន បង្កើតយើងឲ្យមករស់នៅលើផែនដីនេះ ហើយទ្រង់ដាក់បង្គាប់មកលើយើងឲ្យចេះសាងសង់ ស្ថាបនា និងអភិវឌ្ឍន៍លើគ្រប់វិស័យដើម្បីប្រម្រើដល់មនុស្សជាតិ ហើយដែលវាមិនផ្ទុយនឹងគោលការណ៍នៃច្បាប់ឥស្លាមទេ។ ការពិត ទ្រង់បានចាត់ទុកការអភិវឌ្ឍន៍និងស្ថាបនាទាំងនោះ គឺជាការគោរពសក្ការៈទៅចំពោះទ្រង់ផងដែរ។ ហេតុនេះហើយ បានជាព្យាការីមូហាំម៉ាត់បានបញ្ជាក់ប្រាប់យើងថា ប្រសិនបើមានបុគ្គលមូស្លីមណាម្នាក់ចង់ដាំដើមឈើ តែនៅពេលនោះថ្ងៃបរលោកក៏បានមកដល់ គឺចាំបាច់លើរូបគេត្រូវតែដាំដើមឈើនោះ ប្រសិនបើគេមានពេលដើម្បីគេទទួលផលបុណ្យពីព្រះជាម្ចាស់។ (អាល់មុសណាត់:២៧១២)

### ការចូលរួមក្នុងសង្គម:

ឥស្លាមបានអំពាវនាវឲ្យមានការចូលរួមក្នុងសង្គម និងសហការគ្នាដើម្បីកសាងសង្គម ហើយឥស្លាមបានជម្រុញឲ្យប្រកាន់ខ្ជាប់នូវសីលធម៌ល្អចំពោះអ្នកជុំវិញ និងត្រូវផ្សាភ្ជាប់ទំនាក់ទំនងឲ្យបានរឹងមាំ ដូចព្យាការីមូហាំម៉ាត់បានបញ្ជាក់ថា ការរស់នៅតែឯងដោយមិនចូលរួមជាមួយអ្នកដទៃ មិនមែនជាមាគ៌ារបស់អ្នកអំពាវនាវធ្វើល្អឡើយ។ លោកក៏បានបញ្ជាក់ផងដែរថា អ្នកដែលរួមរស់ក្នុងសង្គម ហើយទ្រាំអត់ធ្មត់លើការធ្វើទុកបុកម្នេញ ឬកំហុសឆ្គងរបស់ពួកគេ គឺប្រសើរជាងអ្នករស់តែម្នាក់ឯងឃ្លាតឆ្ងាយពីសង្គម។ (អ៊ីពនូម៉ាហ្ជះ:៤០២២)

### ឥស្លាមជាសាសនានៃវិជ្ជា:

វាមិនមែនជារឿងចៃដន្យនោះទេ ពេលដែលពាក្យដំបូងនៃព្រះគម្ពីរគួរអានដែលបានបញ្ចុះមកលើព្យាការី គឺជាពាក្យ "អ៊ិករ៉ក់" ដែលមានន័យជាភាសាខ្មែរថា: "ចូរអ្នកអាន"។ តាមពិតសាសនាឥស្លាមបានបញ្ជាក់អំពីការគាំទ្រគ្រប់វិជ្ជាណាដែលមានប្រយោជន៍សម្រាប់មនុស្សជាតិ រហូតផ្លូវដែលអ្នកស្វែងរកវិជ្ជាដើរនោះក្លាយជាផ្លូវសម្រាប់គាត់ទៅឋានសួគ៌ទៀតផង ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា:

“បុគ្គលណាបានធ្វើដំណើរស្វែងរកចំណេះដឹងអល់ឡោះនោះ ទ្រង់នឹងសម្រួលផ្លូវឲ្យគេទៅរកឋានសួគ៌”។ (អ៊ីបនូហ៊ិបហ្ពានៈ៨៥)



>សាសនាឥស្លាមមិនដែលស្គាល់ការធ្វើសង្គ្រាមរវាងសាសនានិងវិទ្យាសាស្ត្រដូចនៅក្នុងសាសនាដទៃនោះឡើយ

នៅក្នុងសាសនាឥស្លាមមិនមានពាក្យថាប្រឆាំងនឹងចំណេះដឹងនោះទេ ផ្ទុយទៅវិញ ឥស្លាមជាសាសនាដែលគាំទ្រពេញទំហឹងលើរាល់ចំណេះវិជ្ជាដែលនាំផលប្រយោជន៍ដល់មនុស្សជាតិទៀតផង។

លើសពីនេះទៅទៀត ឥស្លាមបានលើកតម្កើងអ្នកដែលមានចំណេះដឹងឬអ្នកដែលផ្តល់ចំណេះរបស់ខ្លួនដល់អ្នកដទៃនូវការលើកតម្កើងមួយដ៏ខ្ពស់បំផុត ហើយព្យាការីមូហាំម៉ាត់បានបញ្ជាក់ថារាល់សត្វលោកលើផែនដីនេះបានធ្វើការបួងសួងចំពោះព្រះជាម្ចាស់ឲ្យអ្នកដែលបានផ្តល់ចំណេះដឹងដល់អ្នកដទៃទៀតផង។(អាត់តៀរមីហ្ស៊ីៈ២៦៨៥)

## > ត្រូវសិក្សាយល់ដឹងពីបទដ្ឋានច្បាប់ឥស្លាម៖

ជាការចាំបាច់បំផុតមកលើជនមូស្លីមគ្រប់គ្នាត្រូវសិក្សាពីច្បាប់ឥស្លាមដើម្បីយកមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃរបស់គេ ដូចជាការគោពសក្ការៈចំពោះអល់ឡោះ និងការទំនាក់ទំនង ដើម្បីជៀសវាងពីការគោរពសក្ការៈចំពោះព្រះដោយអវិជ្ជា។ អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថាៈ “បុគ្គលណាដែលព្រះអល់ឡោះជាម្ចាស់ចង់ឲ្យគេជាមនុស្សល្អ ទ្រង់នឹងផ្តល់ឲ្យគេនូវការយល់ដឹងពីសាសនារបស់គេ”។ (អាល់ពូខរីៈ៧១ មូស្លីមៈ១០៣៧)

ហេតុនេះអ្នកមូស្លីមត្រូវសិក្សារៀនសូត្រអ្វីដែលជាកាតព្វកិច្ចមកលើរូបគេដូចជា របៀបថ្វាយបង្គំ ការជម្រះសម្អាត និងអ្វីៗដែលទ្រង់ហាមឃាត់ ឬអនុញ្ញាត។ល។



## > បទបញ្ញត្តិឥស្លាម

បទបញ្ញត្តិឥស្លាមមានប្រាំប្រភេទ ហើយរាល់ទង្វើនិងពាក្យសំដីរបស់មនុស្សគឺមិនអាចចេញក្រៅពីបទបញ្ញតិទាំងប្រាំនេះឡើយ។

| | |
|---|---|
| វ៉ាជិប (កាតព្វកិច្ច) | មានន័យថា:អ្វីៗដែលអល់ឡោះបានដាក់បង្គាប់ ដោយទ្រង់នឹងផ្តល់ផលបុណ្យលើបុគ្គលណាដែលបានអនុវត្ត និងដាក់ទណ្ឌកម្មលើបុគ្គលណាដែលមិនអនុវត្តតាម ដូចជាការសឡាត(ថ្វាយបង្គំ)មួយថ្ងៃមួយយប់ប្រាំដង ការបួសខែរ៉ម៉ាហ្ទន។ល។ |
| ហារ៉ាំ (បម្រាម) | មានន័យថា: អ្វីៗដែលអល់ឡោះបានហាមឃាត់ ដោយទ្រង់នឹងផ្តល់ផលបុណ្យលើបុគ្គលណាដែលបោះបង់នូវការហាមឃាត់នោះ ហើយទ្រង់នឹងដាក់ទណ្ឌកម្មលើបុគ្គលណាដែលបំពានលើការហាមឃាត់នោះ ដូចជា ការផឹកគ្រឿងស្រវឹង ប្រព្រឹត្តអំពើអនីតិសង្វាស (ការរួមភេទមុនរៀបការ)ជាដើម...។ល។ |
| ស៊ុណ្ណិត (គប្បីធ្វើ) | មានន័យថា: អ្វីដែលអល់ឡោះជម្រុញឲ្យប្រព្រឹត្តិ ដោយទ្រង់នឹងផ្តល់ផលបុណ្យលើការប្រព្រឹត្តិនោះ តែទ្រង់ក៏មិនដាក់ទណ្ឌកម្មលើបុគ្គលណាដែលមិនអនុវត្ត ឬប្រព្រឹត្តិដែរ ដូចជា ការសម្តែងទឹកមុខញញឹមចំពោះមនុស្សជាតិ ការផ្តល់សាឡាម។ល។ |
| ម៉ាក្រោះ (ពុំគប្បីធ្វើ) | មានន័យថា: អ្វីដែលអល់ឡោះជម្រុញឲ្យបោះបង់ចោលមិនគួរប្រព្រឹត្តិ ដោយទ្រង់នឹងផ្តល់ផលបុណ្យលើបុគ្គលណាដែលបោះបង់ទង្វើទាំងនោះ តែទ្រង់ក៏មិនដាក់ទណ្ឌកម្មលើបុគ្គលណាដែលប្រព្រឹត្តិដែរ ដូចជាការលេងម្រាមដៃនៅពេលកំពុងសឡាត។ |
| មូហ្ពាហ (អនុញ្ញាត) | មានន័យថា: អ្វីដែលឥស្លាមមិនបានហាមឃាត់ ហើយក៏មិនបានបង្គាប់ដែរ ដូចជាការលក់ដូរ ការធ្វើដំណើរ ការនិយាយស្តី....។ល។ |

## > គោលគ្រឹះឥស្លាមទាំងប្រាំ

ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា: "គេបានស្ថាបនាឥស្លាមលើគោលគ្រឹះប្រាំប្រការ នោះគឺ៖ ការធ្វើសាក្សីថា គ្មានទេព្រះដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដក្រៅពីព្រះអល់ឡោះ ហើយធ្វើសាក្សីទៀតថា មូហាំម៉ាត់ជាអ្នកនាំសាររបស់ទ្រង់ ប្រតិបត្តិសឡាត(ថ្វាយបង្គំ)ប្រាំដងក្នុងមួយថ្ងៃមួយយប់ បរិច្ចាគហ្សាកាត់ បួសខែរ៉ម៉ាហ្ទន និងធ្វើធម្មយាត្រាហាជ្ជី"។ (អាល់ពូខរី:៨ មូស្លីម:១៦)

គោលគ្រឹះទាំងប្រាំនេះ គឺជាមូលដ្ឋានគ្រឹះដ៏ធំបំផុតក្នុងសាសនាឥស្លាម ហើយវាក៏ជាសសរទ្រូងនៃសាសនាឥស្លាមផងដែរ ដែលយើងនឹងធ្វើការបកស្រាយឱ្យបានក្បោះក្បាយនៅជំពូកខាងមុខ។

ជំពូកដំបូងគេនោះគឺ ជំនឿលើព្រះជាម្ចាស់តែមួយគត់។

បន្ទាប់មក ការប្រតិបត្តិសឡាត គឺជាការគោរពប្រណិប័តន៍មួយដ៏ធំបំផុតក្នុងសាសនាឥស្លាម។ ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា: "សសរទ្រូងរបស់ឥស្លាម គឺការប្រតិបត្តិសឡាត"។ (អាត់តៀរមីហ្សី:២៧៤៩)

ក៏ប៉ុន្តែការសឡាត មានលក្ខខណ្ឌដើម្បីអនុវត្តវាបានត្រឹមត្រូវ គឺត្រូវមានភាពជ្រះស្អាត។ ហេតុនេះហើយទើបការបកស្រាយបន្ទាប់ពីជំពូក គោលជំនឿរបស់អ្នក គឺជំពូក ការជ្រះស្អាតរបស់អ្នក(តហារ៉ោះ)។ បន្ទាប់មកទើបចូលដល់ជំពូក ការសឡាតរបស់អ្នក និង ជំពូកបន្តបន្ទាប់មកទៀត។

1

ធ្វើសាក្សីថា
គ្មានទេព្រះដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដក្រៅពីព្រះអល់ឡោះ ហើយធ្វើសាក្សីថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់ទ្រង់

2

ការប្រតិបត្តិសឡាត

3

ការបរិច្ចាគ(ហ្សាកាត់)

4

ការបួសខែរ៉ម៉ាហ្ទន

5

ការធ្វើធម្មយាត្រាហាជ្ជី

| គោលគ្រឹះឥស្លាមទាំងប្រាំ | |
|---|---|
| 1 | ធ្វើសាក្សីថា គ្មានទេព្រះដែលត្រូវគេគោរពសក្ការៈយ៉ាងពិតប្រាកដក្រៅពីព្រះអល់ឡោះ ហើយធ្វើសាក្សីថា មូហាំម៉ាត់ជាអ្នកនាំសាររបស់ទ្រង់ |
| 2 | ការប្រតិបត្តិសឡាត |
| 3 | ការបរិច្ចាគទាន(ហ្សាកាត់) |
| 4 | ការបួសខែរ៉ម៉ាហ្ទន |
| 5 | ការធ្វើធម្មយាត្រាហាជ្ជី |

## > តើខ្ញុំត្រូវធ្វើដូចម្ដេចដើម្បីដឹងពីបទដ្ឋានសាសនាឥស្លាម?

ប្រសិនបើបុគ្គលណាម្នាក់មានជំងឺហើយគេត្រូវការព្យាបាលជំងឺនោះ គេនឹងស្វែងរកគ្រូពេទ្យជំនាញម្នាក់ ពោលគឺគេនឹងមិនធ្វេសប្រហែសក្នុង ការ ស្វែង រក វេជ្ជបណ្ឌិត ដើម្បី មក ធ្វើ ការព្យាបាលឡើយ ពីព្រោះអាយុជីវិតរបស់គេពិតជាមានតម្លៃណាស់។

ក៏ប៉ុន្តែសាសនារបស់មនុស្សយើងគឺមានតម្លៃថ្លៃជាងអ្វីៗទាំងអស់។ ហេតុនេះគេត្រូវតែស៊ូដើម្បីយល់ដឹងពីសាសនារបស់គេ គឺគេត្រូវសិក្សានិងសួរអ្នកចេះដឹងឥស្លាមលើចំណុចណាដែលគាត់មិនដឹង ឬមិនយល់នោះ។

វាជាជំហានមួយដ៏ត្រឹមត្រូវបំផុតដែលអ្នកបានអានសៀវភៅមួយក្បាលនេះ ដូចព្រះជាម្ចាស់ទ្រង់បានមានបន្ទូលថា: “ហេតុនេះចូរពួកអ្នកសួរអ្នកដែលមានចំណេះដឹង ប្រសិនបើពួកអ្នកមិនបានដឹងនោះ”។(អាន់ណះល៍ ៤៣)

ហេតុនេះ អ្នកអាចស្វែងយល់អំពីឥស្លាមតាមការ សាក សួរ ទៅ កាន់ អ្នក ប្រាជ្ញ ឥស្លាម ឬស្ថាប័នឥស្លាមដែលនៅក្បែរអ្នក ហើយអ្នកក៏អាចស្វែងយល់អំពីឥស្លាមតាមរយៈគេហទំព័រខាងក្រោមនេះបានផងដែរ៖

www.islamicfinder.org

អ្នកក៏គួរតែស្វែងរកគេហទំព័រណា ដែលគួរជាទីទុកចិត្តក្នុងការពន្យល់បកស្រាយអំពីច្បាប់សាសនាឥស្លាម ដូចជា:

www.newmuslimguide.com

www.guide-muslim.com



> សម្រាប់អ្នកដែលបានចូលកាន់សាសនាឥស្លាមថ្មីថ្មោង គួរតែទាក់ទងជាមួយមជ្ឈមណ្ឌលឥស្លាមទាំងឡាយដែលនៅជិតជាងគេ ហើយអានសៀវភៅ និងមើលគេហទំព័រអិនធើណិតដែលគេអាចទុកចិត្តបាន។

## > ឥស្លាមជាសាសនាដែលមានលក្ខណៈអព្យាក្រឹត

ឥស្លាមជាសាសនាដែលមានលក្ខណៈអព្យាក្រឹតដោយមិនបានធ្វេសប្រហែស ហើយក៏មិននិយមជ្រុលលើចំណុចមួយណាឡើយ ដូចដែលយើងបានឃើញជាក់ស្តែងក្នុងបទដ្ឋានរបស់ឥស្លាម ឬក្នុងការគោរពសក្ការៈផ្សេងៗរបស់ឥស្លាមនោះឯង។

ហើយអ្វីដែលបញ្ជាក់ថា ឥស្លាមជាសាសនាមានលក្ខណៈអព្យាក្រឹតនោះគឺ ព្រះជាម្ចាស់បានបង្គាប់អ្នកនាំសាររបស់ទ្រង់ និងបណ្តាអ្នកមានជំនឿទាំងអស់ឲ្យរក្សា និងប្រកាន់ខ្ជាប់នូវពីរចំណុច៖

**១** ប្រកាន់ខ្ជាប់នូវគោលជំហររឹងមាំ និងទៀងត្រង់ចំពោះសាសនានេះ ហើយត្រូវឲ្យតម្លៃ និងលើកតម្កើងលើនិមិត្តសញ្ញាសាសនានេះ។

**២** ហាមដាច់ខាត់មិនឲ្យមានការបំពាន ឬប្រព្រឹត្តអ្វីមួយហួសខ្នាតក្នុងសាសនាឥស្លាម។

ព្រះអល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថាៈ “ដូច្នេះចូរអ្នក( ព្យាការីមូហាំម៉ាត់ )ប្រកាន់ខ្ជាប់នូវគោលជំហរឲ្យរឹងប៉ឹង ដូចអ្វីដែលអល់ឡោះទ្រង់បានបញ្ជាចំពោះអ្នក និងអ្នកដែលបានសារភាពកំហុសចំពោះអល់ឡោះ ហើយចូរពួកអ្នកកុំបំពានឲ្យសោះ។ ពិតប្រាកដណាស់ ទ្រង់ជាអ្នកឃើញទាំងអស់នូវអ្វីដែលពួកអ្នកប្រព្រឹត្ត”។( គម្ពីរគួរអាន ១១:១១២ )

ពោលគឺ ចូរអ្នកអនុវត្តតាមបទបញ្ជារបស់ទ្រង់ឲ្យបានត្រឹមត្រូវ ហើយចូរអ្នកកុំបំពាន ឬធ្វើអ្វីមួយដែលហួសពីបទបញ្ជារបស់ទ្រង់នោះ។

នៅពេលដែលព្យាការីមូហាំម៉ាត់កំពុងបង្រៀនមិត្តភក្តិរបស់គាត់ គឺគាត់តែងតែដាស់រំឭកពួកគេមិនឲ្យប្រព្រឹត្តបំពានក្នុងសាសនាឥស្លាម ពីព្រោះវាជាមូលហេតុមួយដែលបង្កឲ្យមានវិនាសកម្មដល់ពួកជំនាន់មុន។ ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថាៈ “ចូរពួកអ្នកប្រុងប្រយ័ត្នកុំឲ្យមានការបំពានក្នុងសាសនារបស់អ្នក ពីព្រោះដោយសារតែការបំពាននេះហើយដែលធ្វើឲ្យពួកជំនាន់មុនពួកអ្នកទទួលនូវវិនាសកម្មនោះ”។( អ៊ីពនូម៉ាយ៉ះ ៣០២៩ )



ព្យាការីបានមានប្រសាសន៍ទៀតថាៈ “ចូរពួកអ្នកគោរពប្រណិប័តន៍ចំពោះទ្រង់តាមលទ្ធភាពរបស់ពួកអ្នក”។ ( អាល់ពូខរី ១១០០ )

ហើយពិតប្រាកដណាស់ ព្យាការីមូហាំម៉ាត់បានបញ្ជាក់ថា អល់ឡោះបានចាត់តាំងគាត់មកនេះ មិនមែនដើម្បីដាក់កម្រិតតឹងតែងមកលើមនុស្សជាតិឡើយ ដូចដែលគាត់បញ្ជាក់ប្រាប់ថាៈ “ពិតប្រាកដ ព្រះជាម្ចាស់មិនបានបញ្ជូនខ្ញុំមកដើម្បីនាំមកនូវច្បាប់ដែលតឹងតែងលើសពីលទ្ធភាពរបស់មនុស្សជាតិឡើយ ផ្ទុយទៅវិញ ទ្រង់បានបញ្ជូនខ្ញុំមក គឺដើម្បីអប់រំពួកអ្នក និងសម្រួលដល់ពួកអ្នក”។ ( មូស្លីម ១៤៧៨ )

## > សាសនាឥស្លាមគ្របដណ្តប់គ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត

សាសនាឥស្លាមមិនមែនជាតម្រូវការផ្នែកអារម្មណ៍ដែលមូស្លីមប្រណិប័តន៍ក្នុងវិហារដោយការបួងសួង និងសឡាត(ថ្វាយបង្គំ)តែប៉ុណ្ណោះទេ។

វាមិនមែនត្រឹមតែជាទស្សនៈ និងជំនឿដែលបរិស័ទគោរពតែប៉ុណ្ណោះទេ។

ហើយឥស្លាមមិនមែនត្រឹមតែបណ្តុំនៃប្រព័ន្ធសេដ្ឋកិច្ចប៉ុណ្ណោះទេ។ ឥស្លាមមិនមែនត្រឹមតែជាវិធាន និងទ្រឹស្តីដើម្បីកសាងសង្គមប៉ុណ្ណោះទេ។

ហើយឥស្លាមក៏មិនមែនត្រឹមតែបណ្តុំនៃសីលធម៌ក្នុងការទំនាក់ទំនងជាមួយអ្នកដទៃប៉ុណ្ណោះនោះដែរ។

ក៏ប៉ុន្តែសាសនាឥស្លាម គឺជាមាគ៌ាដ៏ពេញលេញមួយសម្រាប់គ្រប់គ្រងជីវិតទាំងមូលដោយគ្មានការខ្វះខាតជ្រុងណាមួយឡើយ។

ដូចព្រះជាម្ចាស់ទ្រង់បានមានបន្ទូលថាៈ “ថ្ងៃនេះយើងបានបំពេញសាសនារបស់ពួកអ្នកឲ្យពួកអ្នក និងបានបង្គ្រប់ព្រះគុណរបស់យើងឲ្យពួកអ្នក ហើយយើងបានជ្រើសរើសសាសនាឥស្លាមជាសាសនារបស់ពួកអ្នក”។(គម្ពីគួរអាន ៥ៈ៣)

មានថ្ងៃមួយ មានអ្នកគ្មានជំនឿម្នាក់បានសើចចំអកឲ្យលោកសាល់ម៉ានអាល់ហ្វារីស៊ីដែលជាមិត្តភក្តិរបស់ព្យាការីមូហាំម៉ាត់ ដោយគេបាននិយាយថាៈ មិត្តរបស់អ្នក(មូហាំម៉ាត់)បង្រៀនអ្នកគ្រប់បែបយ៉ាងមែនទេ សូម្បីតែរឿងបន្ទោបង់នោះឬ?! លោកសាល់ម៉ានបានតបវិញថា ពិតមែនហើយគាត់បង្រៀនពួកខ្ញុំគ្រប់បែបយ៉ាង។ បន្ទាប់មក លោកសាល់ម៉ានបានរៀបរាប់អំពីច្បាប់ឥស្លាមជាមួយនឹងសុជីវធម៌ដែលឥស្លាមតម្រូវឲ្យធ្វើក្នុងពេលបន្ទោបង់។ (មូស្លីមៈ២៦២)



> សាសនាឥស្លាម គឺជាមាគ៌ាដ៏ទូលំទូលាយសម្រាប់គ្រប់ទិដ្ឋភាពនៃជីវិតរស់នៅ

## > សូមមើលគំរូពិតរបស់ឥស្លាមពុំមែនដោយនធ្វើរបស់មូស្លីមខ្លះនោះទេ៖

ប្រសិនបើអ្នកបានជួបនឹងគ្រូពេទ្យ ឬគ្រូបង្រៀនណាម្នាក់ដែលមិនប្រកាន់នូវក្រមសីលធម៌ល្អ ឬប្រើសំដីមិនពីរោះនោះ អ្នកនឹងនៅតែមិនបដិសេធអំពីសារៈសំខាន់នៃចំណេះដឹង ឬវិជ្ជាទាំងនោះឡើយ។

ហើយអ្នកពិតជាធ្វើការបកស្រាយថា គ្រូពេទ្យ ឬគ្រូបង្រៀនោះមិនបានកាន់ខ្ជាប់នូវចំណេះដឹង ឬវិជ្ជាជីវៈដែលខ្លួនបានដឹងនោះឡើយ។

ក៏ដូច្នោះដែរ ប្រសិនបើអ្នកបានឃើញជនមូស្លីមមួយចំនួនដែលប្រព្រឹត្តអំពើអសីលធម៌នោះ វាមិនមែនបង្ហាញពីធាតុពិតរបស់សាសនាឥស្លាមឡើយ ផ្ទុយទៅវិញ វាគ្រាន់តែជាអត្តចរិតមិនល្អរបស់គាត់ដោយគ្មានការទាក់ទងនឹងសាសនាឥស្លាមឡើយ ដូចអ្វីដែលបានកើតឡើងលើលោកគ្រូពេទ្យ ឬគ្រូបង្រៀននោះឯង ហើយយើងមិនអាចចោទថា វិជ្ជាពេទ្យ ជាវិជ្ជាមិនល្អនោះទេ។



## > សារៈសំខាន់ទាំងប្រាំ

វាគឺជាគុណប្រយោជន៍ដ៏ធំធេងដែលមនុស្សជាតិមានតម្រូវការជាចាំបាច់ ដើម្បីរស់រានក្នុងភាពថ្លៃថ្នូរ។ គ្រប់ច្បាប់នៃសាសនាទាំងឡាយ តែងតែផ្តល់ឱវាទឲ្យថែរក្សាវា និងឲ្យជៀសវាងនូវប្រការណាដែលនាំឲ្យប្រព្រឹត្តផ្ទុយពីវា។

សាសនាឥស្លាមបាននាំមកនូវការជម្រុញឲ្យថែរក្សាសារសំខាន់ទាំងប្រាំនេះ ដើម្បីឲ្យជីវិតរស់នៅក្នុងលោកនេះប្រកបដោយសុវត្ថិភាព និងមានអារម្មណ៍នឹងនរក្នុងការបំពេញភារកិច្ចសម្រាប់លោកិយ និងបរលោក។

សង្គមឥស្លាមរស់នៅជាប្រជាជាតិតែមួយ មានការសាមគ្គីរឹងមាំប្រៀបដូចជាសំណង់មួយដែលផ្សារភ្ជាប់គ្នា និងហាក់បីដូចជាខ្លួនតែមួយ ដែលនៅពេលណាមានការឈឺចាប់អ្វីមួយនៅត្រង់ណានោះ សារពាង្គកាយទាំងមូលនឹងមានអារម្មណ៍ឈឺដូចគ្នា។ ហើយការថែរក្សានូវសារៈសំខាន់ទាំងប្រាំនេះ អាចធ្វើទៅបាន គឺអាស្រ័យលើប្រការពីរយ៉ាង:



> អល់ឡោះជាម្ចាស់បានបង្គាប់ឲ្យការពារអាយុជីវិតរបស់មនុស្ស ទោះជាបង្កឲ្យល្មើសអ្វីមួយនៃប្រការដែលត្រូវបានហាមឃាត់ក៏ដោយ។

1 ការជ្រោមជ្រែង និង ការថែរក្សា

2 ការការពារវាអំពីភាពខ្វះចន្លោះ។

### 1 សាសនា

វាជាវត្ថុបំណងដ៏ឧត្តុង្គឧត្តមដែលព្រះអល់ឡោះទ្រង់បានបង្កើតមនុស្សជាតិ និងបានបញ្ជូនបណ្តាអ្នកនាំសារទាំងឡាយមកដើម្បីផ្តល់ និងថែរក្សាវា ដូចទ្រង់បានមានបន្ទូលថា: “ហើយជាការពិតណាស់ រាល់ប្រជាជាតិនីមួយៗយើងបានតែងតាំងអ្នកនាំសារម្នាក់ដោយគេបង្គាប់ពួកគេឲ្យគោរពសក្ការៈចំពោះអល់ឡោះ និងជៀសវាងនូវការគោរពពហុទេពនិយមផ្សេងពីអល់ឡោះ”។ (គម្ពីរគួរអាន ១៦:៣៦)

សាសនាឥស្លាមបានយកចិត្តទុកដាក់ក្នុងការថែរក្សាសាសនា និងការពារមិនឲ្យមានអ្វីប៉ះពាល់ដល់ភាពស្អាតស្អំរបស់វាឡើយ។

## 2 ខ្លួនប្រាណ

ព្រះអល់ឡោះទ្រង់បានបង្គាប់ឲ្យមនុស្សលោកថែរក្សាខ្លួនប្រាណនិងអាយុជីវិត ទោះបីជាការថែរក្សានោះ ជាហេតុបណ្តាលឲ្យធ្វើអំពើដែលច្បាប់ហាមឃាត់ខ្លះក៏ដោយ ព្រោះថាក្នុងករណីនេះ ត្រូវបានច្បាប់លើកលែងនូវទោសកំហុស ដូចទ្រង់បានមានបន្ទូលថា: “ហេតុនេះ ជនណាហើយដែលត្រូវគេបង្ខំឲ្យទទួលទានអាហារដែលគេហាមឃាត់ដោយអចេតនា និងមិនលើសពីតម្រូវការចាំបាច់នោះ គឺគ្មានទោសពៃរ៍អ្វីទៅលើគេឡើយ។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រឡាញ់”។ (គម្ពីរគួរអាន២:១៧៣)

ហើយទ្រង់ក៏បានហាមឃាត់មិនឲ្យធ្វើអត្តឃាត ឬធ្វើរាល់ទង្វើទាំងឡាយណាដែលនាំឲ្យគ្រោះថ្នាក់ដល់ជីវិតនោះឡើយ ដូចដែលទ្រង់បានមានបន្ទូលថា: “ហើយចូរពួកអ្នកកុំបណ្តោយខ្លួនរបស់ពួកអ្នកឲ្យធ្លាក់ចូលទៅក្នុងភាពវិនាសអន្តរាយ”។ (គម្ពីរគួរអាន ២:១៩៥)

ហើយទ្រង់បានដាក់ច្បាប់និងទណ្ឌកម្មលើបទឧក្រិដ្ឋដើម្បីការពារកុំឲ្យមានការឈ្លានពានទៅលើអ្នកដទៃដោយមិនបានបែងចែកសាសនា ឬជាតិសាសន៍អ្វីឡើយ។ អល់ឡោះទ្រង់ក៏បានមានបន្ទូលទៀតថា: “ឱបណ្តាអ្នកដែលមានជំនឿ! គេបានដាក់កាតព្វកិច្ចលើពួកអ្នកឲ្យមានសមភាពក្នុងការវិនិច្ឆ័យទោសក្នុងរឿងឃាតកម្ម”។ (គម្ពីរគួរអាន ២:១៧៨)

## 3 ប្រាជ្ញា

សាសនាឥស្លាមបានធ្វើការហាមឃាត់គ្រប់អ្វីៗទាំងអស់ដែលនាំឲ្យប៉ះពាល់ដល់ប្រាជ្ញាស្មារតី ព្រោះថាប្រាជ្ញាវាជាការប្រទានដ៏ធំធេងមួយរបស់ព្រះអល់ឡោះជាម្ចាស់មកឲ្យពួកយើង។ ដោយសារប្រាជ្ញា ធ្វើឲ្យមនុស្សរស់ក្នុងភាពថ្លៃថ្នូរ និងខុសប្លែកពីសត្វលោកដទៃ ហើយវាក៏ជាមូលដ្ឋានគ្រឹះដែលត្រូវបានសួរនាំ និងជំនុំជម្រះ ទាំងក្នុងលោកិយនេះ និងបរលោកផងដែរ។

ហេតុដូចនេះហើយទើបអល់ឡោះជាម្ចាស់ទ្រង់បានដាក់បម្រាមចំពោះគ្រឿងស្រវឹង និងគ្រឿងញៀនគ្រប់ប្រភេទ ហើយថែមទាំងចាត់ទុករបស់អស់ទាំងនោះ ថាជាប្រការកខ្វក់ ស្ថិតក្នុងចំណោមទង្វើរបស់ព្រាយបិសាច ដូចដែលទ្រង់បានមានបន្ទូលថា: “ឱបណ្តាអ្នកមានជំនឿ! ពិតប្រាកដណាស់ សុរា ល្បែងស៊ីសង ការគោរពបូជារូបបដិមា និងជឿព្រួញទស្សន៍ទាយវាសនា គឺជាអំពើដ៏កខ្វក់នៃទង្វើរបស់ស្ហៃតន(ព្រាយបិសាច)។ ហេតុនេះ ចូរពួកអ្នកជៀសវាងឲ្យឆ្ងាយពីវា សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ”។ (គម្ពីរគួរអាន ៥:៩០)

### 4 ពូជអម្បូរ

ការយកចិត្តទុកដាក់របស់សាសនាឥស្លាមចំពោះការថែរក្សាពូជអម្បូរ និងការបង្កើតគ្រួសារដែលអប់រំយុវជនឲ្យចេះស្រឡាញ់អំពើល្អ វាស្តែងឡើងយ៉ាងច្បាស់នៅក្នុងច្បាប់ជាច្រើន មានដូចជាៈ

- ឥស្លាមបានជម្រុញឲ្យរៀបអាពាហ៍ពិពាហ៍ និងជម្រុញឲ្យផ្តល់ភាពងាយស្រួល ហើយហាមមិនឲ្យចំណាយថវិការច្រើនហួសហេតុឡើយ។ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថាៈ “ហើយចូរពួកអ្នករៀបអាពាហ៍ពិពាហ៍ឲ្យអ្នកដែលនៅលីវក្នុងចំណោមពួកអ្នក”។ (គម្ពីរគួរអាន ២៤:៣២)
- ឥស្លាមបានហាមឃាត់រាល់ចំណងទាក់ទងគ្នាដែលខុសពីប្រពៃណី និងបានលុបបំបាត់មធ្យោបាយណាដែលនាំឲ្យមានទំនាក់ទំនងខុសច្បាប់។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ហើយចូរពួកអ្នកកុំទៅក្បែរប្រការហ្ស៊ីណា(អនីតិសង្វាស)ឲ្យសោះ។ ពិតប្រាកដណាស់ វាគឺជាអំពើអសីលធម៌ និងជាមាគ៌ាមួយដ៏អាក្រក់បំផុត”។ (គម្ពីរគួរអាន ១៧:៣២)
- សាសនាឥស្លាមហាមឃាត់មិនឲ្យបរិហាកេរ្តិ៍ ឬចោទប្រកាន់ទៅលើអ្នកដទៃ ហើយឥស្លាមបានចាត់ទុកទង្វើទាំងនេះ ជាអំពើបាបមួយដ៏ធំបំផុត ហើយគេនឹងទទួលទោសតាមច្បាប់របស់ឥស្លាមនៅក្នុងលោកិយ ហើយនឹងទទួលនូវទណ្ឌកម្មចំពោះទង្វើបែបនេះនាថ្ងៃបរលោកថែមទៀត។
- ឥស្លាមបានប្រើឲ្យរក្សាសេចក្តីថ្លៃថ្នូរ ទាំងបុរស និងស្ត្រី ហើយឥស្លាមបានចាត់ទុកថាបុគ្គលណាដែលត្រូវគេសម្លាប់ព្រោះតែការពារកិត្តិយសរបស់គេនោះ គឺជាការស្លាប់ក្នុងផ្លូវអល់ឡោះ។ (សូមមើលទំព័រ ២០២)

### 5 ទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិ គឺមានសារៈសំខាន់ណាស់ក្នុងសាសនាឥស្លាម។ ហេតុនេះហើយបានជាសាសនាឥស្លាមជម្រុញឲ្យបង្កើតការងារដើម្បីរកចំណូល ដូចជាការជួញដូរ និងការងារផ្សេងៗដទៃទៀត។

ហើយឥស្លាមបានហាមឃាត់មិនឲ្យប្រព្រឹត្តអំពើឆបោកឬយករបស់អ្នកដទៃដោយមិនស្របច្បាប់នោះទេ។ (សូមមើលទំព័រ ១៧២ )



> ការរក្សាការពារកិត្តិយស និងរក្សាការពារពូជអម្បូរ គឺជាគោលបំណងដ៏ធំបំផុតនៃការបង្កើតឲ្យមានច្បាប់ក្នុងសាសនាឥស្លាម។



# គោលជំនឿរបស់អ្នក



# 1

សារទាំងឡាយរបស់បណ្តាព្យាការីទាំងអស់បានឯកភាពគ្នាសម្រាប់ក្រុមរបស់ពួកគេលើការគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ គ្មានការគោរពសក្ការៈចំពោះអ្នកផ្សេងរួមជាមួយទ្រង់ឡើយ ហើយប្រឆាំងនឹងអ្វីដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ។ នេះគឺជាអត្ថន័យពិតនៃពាក្យ "គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតក្រៅពីអល់ឡោះ ហើយមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះ"។ វាជាពាក្យដែលបុគ្គលម្នាក់ៗចូលសាសនារបស់អល់ឡោះ(សាសនាឥស្លាម)ត្រូវពោលវា។

## មាតិកាជំពូក

### ពាក្យសច្ចាទាំងពីរ អត្ថន័យ និងកាតព្វកិច្ចរបស់វា

- ហេតុអ្វីគ្មានព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិត លើកលែងតែអល់ឡោះ?
- អត្ថន័យនៃពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតលើកលែងតែអល់ឡោះ
- គោលគ្រឹះនៃពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតលើកលែងតែអល់ឡោះ

### ការសច្ចាថា មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ

- ការស្គាល់ព្យាការីមូហាំម៉ាត់(សូមពរជ័យនិងសន្តិភាពកើតមានដល់លោក)
- អត្ថន័យនៃពាក្យសច្ចាថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ

### គោលជំនឿទាំងប្រាំមួយ

### អ្វីដែលហៅថាការគោរពសក្ការៈ?

### ស្ទីនិយម(ពហុទេពនិយម)

### ជឿចំពោះព្រះនាមអល់ឡោះ និងលក្ខណៈសម្បត្តិរបស់ទ្រង់

### ជឿចំពោះពួកទេវតា

### ជឿចំពោះបណ្តាព្រះគម្ពីរ

### ជឿចំពោះបណ្តាអ្នកនាំសារ

### ជឿចំពោះថ្ងៃបរលោក

### ជឿចំពោះការកំណត់ព្រះលិខិត

## > ពាក្យសច្ចាធាំជ័ពីរ អត្ថន័យ និងភាពចាំបាច់របស់វា

### ខ្ញុំសូមសច្ចាថាគ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិត លើកលែងតែអល់ឡោះ ហើយខ្ញុំសូមសច្ចាទៀតថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ

### ហេតុអ្វីត្រូវពោលថា គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិត លើកលែងតែអល់ឡោះ ?

- ពីព្រោះវាជាកាតព្វកិច្ចដំបូងគេរបស់អ្នកមូស្លីម ។ ជនណាចង់ចូលសាសនាឥស្លាម ជននោះត្រូវតែជឿ និងពោលវា ។
- ពីព្រោះជនណាដែលពោលដោយភាពជឿជាក់នឹងវា ព្រមទាំងចិត្តស្មោះចំពោះអល់ឡោះនោះ វាគឺជាហេតុនាំឲ្យរូបគេរួចផុតពីភ្លើងនរក ។ ព្យាការីមូហាំម៉ាត់( សូមពរជ័យនិងសន្តិភាពកើតមានដល់លោក ) បានមានប្រសាសន៍ថា: “អល់ឡោះហាមឃាត់ភ្លើងនរកចំពោះជនណាដែលពោលថា: គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិត លើកលែងតែអល់ឡោះ ដោយចិត្តស្មោះសចំពោះទ្រង់” ។ (អាល់ពូខរី:៤១៥ )
- ពីព្រោះជនណាហើយបានស្លាប់ដោយបានពោល និងមានជំនឿចំពោះពាក្យនេះ រូបគេនឹងស្ថិតនៅជាមួយបណ្តាអ្នកចូលឋានសួគ៌ ។ ព្យាការីមូហាំម៉ាត់( សូមពរជ័យនិងសន្តិភាពកើតមានដល់លោក ) បានមានប្រសាសន៍ថា: “ជនណាស្លាប់ ហើយគេដឹងថា: គ្មានទេព្រះជាម្ចាស់ក្រៅពីអល់ឡោះនោះ គេនឹងបានចូលឋានសួគ៌” ។ (អះម៉ាត់:៤៦៤ )
- ដូច្នេះ ភាពចាំបាច់នៃការយល់ដឹងពីពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ គឺជាកាតព្វកិច្ចដ៏ឧត្តម និងមានសារៈសំខាន់បំផុត ។

### អត្ថន័យនៃពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈពិតប្រាកដ លើកលែងតែអល់ឡោះ

មានន័យថា គ្មានព្រះជាម្ចាស់ណាដែលគេត្រូវគោរពសក្ការៈដ៏ពិតប្រាកដ មានតែអល់ឡោះមួយអង្គគត់ដែលត្រូវគោរពសក្ការៈ ។ ជាការបដិសេធភាពជាព្រះណាដែលក្រៅពីអល់ឡោះ និងទទួលយកអល់ឡោះតែមួយគត់គ្មានអ្នកចូលរួមជាមួយទ្រង់ឡើយ ។



ព្រះមានន័យថា អ្នកដែលត្រូវគោរពសក្ការៈ ។ ជនណាគោរពសក្ការៈអ្វីមួយក្រៅពីអល់ឡោះ ជននោះពិតជាបានយកអ្នកផ្សេងធ្វើជាព្រះ ។ ទាំងអស់នោះមិនមែនជាព្រះពិតនោះទេ មានតែព្រះមួយគត់ ទ្រង់ជាម្ចាស់ និងជាអ្នកបង្កើត ។

អល់ឡោះទ្រង់ប្រកបដោយភាពស្អាតស្អំ ជាព្រះសក្តិសមនូវការគោរពសក្ការៈតែមួយគត់ដោយគ្មានអ្នកផ្សេងក្រៅពីទ្រង់ឡើយ ។ ទ្រង់ជាទីគោរពសក្ការៈនៃចិត្តទាំងឡាយដោយក្តីគោរពស្រឡាញ់ ការលើកតម្កើង ការបន្ទាបខ្លួន ការឱនលំទោន ការកោតខ្លាច ការជឿទុកចិត្ត និងការបួងសួងសុំចំពោះទ្រង់ ។ ដូច្នេះគេមិនត្រូវបួងសួង មិនត្រូវជឿទុកចិត្ត មិនថ្វាយបង្គំ និងមិនត្រូវសំឡេះសត្វទេ

លើកលែងតែចំពោះអល់ឡោះប៉ុណ្ណោះ។ ម្យ៉ាងទៀត ចាំបាច់ត្រូវតែគោរពសក្ការៈដោយចិត្តស្មោះស ចំពោះទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថា: “ហើយគេមិនបានបង្គាប់ប្រើពួកគេឲ្យធ្វើអ្វី ក្រៅពីឲ្យពួកគេគោរពសក្ការៈចំពោះអល់ឡោះ ដោយចិត្តស្មោះសចំពោះទ្រង់ឡើយ”។ (គម្ពីរគួរអាន ៩៨:៥) ជនណាហើយគោរពសក្ការៈដោយចិត្តស្មោះសចំពោះអល់ឡោះ សម្រាប់អ្នកនោះ គឺបានសម្រេចនូវពាក្យថា គ្មានទេព្រះជាម្ចាស់ក្រៅពីអល់ឡោះ ហើយគេនឹងទទួលបាននូវសេចក្ដីសុខសុភមង្គលសម្បូរសប្បាយរីករាយ ជីវិតល្អប្រសើរថ្លៃថ្លា។ សម្រាប់ដួងចិត្តមិនអាចមានភាពកក់ក្ដៅស្កប់ស្កល់ស្ងប់ចិត្តបានឡើយ លុះត្រាតែប្រតិបត្តិការគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់។ អល់ឡោះទ្រង់បានមានបន្ទូលថា: “អ្នកណាដែលបានសាងអំពើល្អក្នុងចំណោមបុរស ឬស្ត្រី ហើយគេជាអ្នកមានជំនឿ គឺយើងពិតជានឹងធ្វើឲ្យគេមានជីវិតរស់នៅដ៏ល្អប្រសើរ”។ (គម្ពីរគួរអាន ១៦:៩៧)

## គោលគ្រឹះនៃពាក្យ គ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិត លើកលែងតែអល់ឡោះ

ពាក្យដ៏ឧត្តមនេះមានគោលគ្រឹះពីរដែលត្រូវយល់ដឹងឲ្យបានច្បាស់ចំពោះអត្ថន័យ និងភាពចាំបាច់របស់វា។

**1**

គោលគ្រឹះទី១៖ គ្មានទេព្រះជាម្ចាស់ គឺជាការបដិសេធចំពោះការគោរពសក្ការៈអ្វីទាំងឡាយក្រៅពីអល់ឡោះ បំបាត់អំពើពហុទេពនិយម និងចាំបាច់ត្រូវប្រឆាំងនឹងអ្វីៗដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ ទោះនោះជាមនុស្ស សត្វ រូបបដិមា ផ្កាយ ឬជាអ្វីក៏ដោយ។

**2**

គោលគ្រឹះទី២៖ លើកលែងតែអល់ឡោះ គឺជាការទទួលស្គាល់ការគោរពសក្ការៈសម្រាប់អល់ឡោះតែមួយគត់ ហើយប្រតិបត្តិចំពោះទ្រង់តែមួយអង្គគត់នូវគ្រប់ប្រភេទនៃការគោរពសក្ការៈទាំងអស់ ដូចជាការថ្វាយបង្គំ ការបួងសួងសុំ ការជឿទុកចិត្ត ។ល។

ហើយរាល់ការគោរពសក្ការៈគ្រប់ប្រភេទទាំងអស់ថ្វាយជូនចំពោះអល់ឡោះតែមួយគត់ដោយគ្មានការគោរពសក្ការៈចំពោះអ្នកផ្សេងរួមជាមួយទ្រង់ឡើយ។ ហើយអ្នកដែលថ្វាយការគោរពសក្ការៈជូនអ្នកដទៃក្រៅពីទ្រង់ គេពិតជាបានប្រព្រឹត្តអំពើពហុទេពនិយមចំពោះទ្រង់។

អល់ឡោះទ្រង់មានបន្ទូលថា: “ជនណាហើយដែលគោរពសក្ការៈម្ចាស់ផ្សេងរួមជាមួយអល់ឡោះដែលគ្មានភស្តុតាងបញ្ជាក់សម្រាប់គេចំពោះការគោរពនោះ ពិតណាស់ការជំនុំជម្រះ(ទង្វើអាក្រក់របស់គេ គឺស្ថិតនៅលើម្ចាស់របស់គេ។ ពិតណាស់ ពួកដែលប្រឆាំងនោះ ពុំជោគជ័យឡើយ”។ (គម្ពីរគួរអាន ២៣:១១៧)។ អត្ថន័យនៃពាក្យ គ្មានព្រះជាម្ចាស់ក្រៅពីអល់ឡោះ និងគោលគ្រឹះរបស់វាមានបញ្ជាក់ដោយបន្ទូលរបស់អល់ឡោះថា: “ហេតុនេះ អ្នកដែលប្រឆាំងនឹងតហ្គ៊ូត(អ្វីៗដែលគេគោរសក្ការៈក្រៅពីអល់ឡោះ) ហើយមានជំនឿចំពោះអល់ឡោះនោះ អ្នកនោះប្រាកដជាបានប្រកាន់ខ្ជាប់នឹងខ្សែដ៏រឹងមាំ(សាសនាឥស្លាម)" ។ បន្ទូលរបស់ទ្រង់: “អ្នកដែលប្រឆាំងនឹងតហ្គ៊ូត(អ្វីៗដែលគេគោរពសក្ការៈក្រៅពីអល់ឡោះ)" គឺជាអត្ថន័យនៃគោលគ្រឹះទីមួយ (គ្មានទេព្រះជាម្ចាស់)។ បន្ទូលរបស់ទ្រង់:“ហើយមានជំនឿលើអល់ឡោះ" គឺជាអត្ថន័យនៃគោលគ្រឹះទីពីរ (លើកលែងតែអល់ឡោះ)។

# > ការសច្ចាថា មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ

## ការស្គាល់ព្យាការីមូហាំម៉ាត់( សូមពរជ័យនិងសន្តិភាពកើតមានដល់លោក )គាត់



### 1 កំណើតរបស់ព្យាការីមូហាំម៉ាត់

គាត់បានប្រសូត្រនៅទីក្រុងម៉ាក្កះក្នុងឆ្នាំ ៥៧០គ.ស ដោយកំព្រាឪពុក។ បន្ទាប់មក ម្ដាយរបស់គាត់ក៏បានបាត់បង់ជីវិតទៀត ក្នុងវ័យកុមារ។ ក្រោយមក គាត់ត្រូវបាន ជីតារបស់គាត់ គឺអាប់ទុលមុត្តាឡឹបជាអ្នក មើលថែបន្ត។ បន្ទាប់មកទៀត ឪពុកមា របស់គាត់ គឺអាពូតាឡិបបានមើលថែគាត់ បន្ត រហូតដល់ធំពេញវ័យ។



### 2 ជីវិត និងការធំពេញវ័យរបស់ព្យាការីមូហាំម៉ាត់

គាត់រស់នៅក្នុងកុលសម្ព័ន្ធរបស់គាត់ឈ្មោះ គូរ៉ស្ហ(Quraysh)រយៈពេល៤០ឆ្នាំ មុននឹង ទទួលតំណែងជាព្យាការី( ពីឆ្នាំ៥៧០គ.ស ដល់ ឆ្នាំ៦១០គ.ស )។ គាត់ជាបុគ្គលគំរូសម្រាប់ មនុស្សលោកទាំងមូលឲ្យយកតម្រាប់តាមភាព ខ្ជាប់ខ្ជួន និងភាពល្អប្រសើររបស់គាត់ ដែលពួក គេបានដាក់ងារដ៏ល្បីល្បាញមួយដល់គាត់គឺអ្នក ទៀងត្រង់។ ព្យាការីមូហាំម៉ាត់បានធ្វើជាអ្នក ឃ្វាលសត្វ ក្រោយមក ធ្វើជាអ្នកជំនួញ។

មុននឹងអ្នកនាំសារមូហាំម៉ាត់ទទួលសាសនា ឥស្លាម គាត់ស្ថិតនៅលើសាសនាដ៏ត្រឹមត្រូវតែត លម្អៀង។ គាត់គោរពសក្ការៈចំពោះអល់ឡោះ ជាម្ចាស់លើមាគ៌ាសាសនាព្យាការីអ៊ីព្រហ៊ីម ដោយបដិសេធការគោរពសក្ការៈទេវរូប និង ការប្រតិបត្តិជំនឿទេវរូប។

### ឈ្មោះរបស់ព្យាការីមូហាំម៉ាត់

មូហាំម៉ាត់ កូនអាប់ទុលឡោះ កូនអាប់ទុលមុត្តាឡឹប កូនហាស៊ិម ជាកុលសម្ព័ន្ធគូរ៉ស្ហ ដែលជាអម្បូរអារ៉ាប់ដែលល្អជាងគេ។

### ព្យាការីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះទៅកាន់មនុស្សលោកទាំងអស់

អល់ឡោះទ្រង់បានបញ្ជូនព្យាការីមូហាំម៉ាត់ទៅកាន់មនុស្សលោកទាំងអស់ គ្រប់ជាតិសាសន៍ និងពូជអម្បូរ ហើយទ្រង់បានដាក់កាតព្វកិច្ចលើមនុស្សលោកទាំងអស់ឲ្យប្រតិបត្តិតាមព្យាការី។ អល់ឡោះទ្រង់បានមានបន្ទូលថា: “ចូរអ្នក( ព្យាការីមូហាំម៉ាត់ )ពោលថា :ឱមនុស្សលោកទាំងឡាយ! ពិតណាស់ ខ្ញុំគឺជាអ្នកនាំសាររបស់អល់ឡោះមកកាន់ពួកអ្នកទាំងអស់គ្នា”។ ( គម្ពីគួរអាន ៧:១៥៨ )។



## 3 ការតែងតាំងព្យាការីមូហាំម៉ាត់ជាអ្នកនាំសារ

នៅពេលអ្នកនាំសារមានវ័យ៤០ឆ្នាំ គាត់បានធ្វើការត្រិះរិះពិចារណា និងគោរពសក្ការៈ ចំពោះអល់ឡោះនៅក្នុងរូងភ្នំមួយឈ្មោះថារូងភ្នំហ៊ីរ៉ក នៅភ្នំ អាន់នួរ(ជាភ្នំមួយនៃបណ្តាភ្នំដែលស្ថិតនៅជិតទីក្រុងម៉ាក្កះ)។ អល់ឡោះបានប្រទានវ៉ាហ៊ី(ព្រះរាជសារ) ហើយគម្ពីរគួរអានក៏បានចាប់ផ្តើមបញ្ចុះចាប់ពីពេលនោះមក។ ហើយអ្វីដែលបញ្ចុះមកមុនគេបង្អស់អំពីគម្ពីរគួរអាននោះគឺ:

(اقْرَأْ بِاسْمِ رَبِّكَ الَّذِي خَلَقَ)

មានន័យថា: «ចូរអ្នកសូត្រ» ជាប្រកាសឲ្យដឹងថា ការតែងតាំងជាអ្នកនាំសារនេះ គឺជាការចាប់ផ្តើមយុគសម័យថ្មីដែលពោរពេញដោយចំណេះវិជ្ជា ការអាន ពន្លឺរស្មី និងការចង្អុលបង្ហាញសម្រាប់មនុស្សលោក។ បន្ទាប់មក គម្ពីរគួរអានត្រូវបានបញ្ចុះមកកាន់ព្យាការីមូហាំម៉ាត់ជាបន្តបន្ទាប់អស់រយៈកាល២៣ឆ្នាំ។

## 4 ការចាប់ផ្តើមផ្សព្វផ្សាយរបស់ព្យាការីមូហាំម៉ាត់

អ្នកនាំសារបានចាប់ផ្តើមផ្សព្វផ្សាយសាសនារបស់អល់ឡោះដោយសម្ងាត់រយៈពេល៣ឆ្នាំ។ ក្រោយមក គាត់បានលាតត្រដាងការផ្សព្វផ្សាយនិងបើកចំហក្នុងរយៈពេល១០ឆ្នាំ។ ព្យាការីមូហាំម៉ាត់ និងសហការីរបស់គាត់បានទទួលរងការធ្វើទុក្ខបុកម្នេញ និងការរំលោភបំពានពីសំណាក់កុលសម្ព័ន្ធគូរ៉ស្ហក្នុងរយៈពេលនេះ។ គាត់ក៏បានអំពាវនាវដល់កុលសម្ព័ន្ធផ្សេងៗទៀតដែលបានមកធ្វើពិធីបុណ្យហាជ្ជនៅទីក្រុងម៉ាក្កះឲ្យទទួលយកសាសនាឥស្លាម ហើយពលរដ្ឋក្រុងម៉ាទីណះក៏បានទទួលយកសាសនាឥស្លាម។ ហេតុនេះហើយ ទើបអ្នកឥស្លាមចាប់ផ្តើមភៀសខ្លួនទៅកាន់ក្រុងម៉ាទីណះជាបន្តបន្ទាប់។

### គម្ពីរគួរអានបានបញ្ចុះមកកាន់ព្យាការីមូហាំម៉ាត់

គម្ពីរគួរអានបានបញ្ចុះមកកាន់ព្យាការីមូហាំម៉ាត់ ជាគម្ពីរដ៏ឧត្តុង្គឧត្តមជាទីបំផុត ពីព្រោះគម្ពីរនេះមិនមានប្រការខុសឆ្គងទាំងឡាយកើតដល់វាឡើយ។

### មូហាំម៉ាត់ជាព្យាការី និងជាអ្នកនាំសារចុងក្រោយបង្អស់

អល់ឡោះបានបញ្ជូនព្យាការីមូហាំម៉ាត់ ជាព្យាការីចុងក្រោយបង្អស់ ដោយគ្មានព្យាការីណាបន្ទាប់ពីគាត់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: "ក៏ប៉ុន្តែគាត់(មូហាំម៉ាត់)ជាអ្នកនាំសាររបស់អល់ឡោះ និងជាព្យាការីចុងក្រោយបង្អស់"។ (គម្ពីរគួរអាន ៣៣:៤០)។




## 5 ការភៀសខ្លួនរបស់គាត់

អ្នកនាំសារបានភៀសខ្លួនទៅកាន់ក្រុងម៉ាទីណះ ដែលកាលពីមុន គេឲ្យឈ្មោះក្រុងនេះថា យើសរិប នៅឆ្នាំ៦២២គ.ស ដែលពេលនោះគាត់មានអាយុ ៥៣ឆ្នាំ។ការភៀសខ្លួនរបស់គាត់ គឺបន្ទាប់ពីមេដឹកនាំគូរ៉ុស្ហដែលប្រឆាំងនឹងការផ្សព្វផ្សាយរបស់គាត់បានប៉ុនប៉ង និងព្យាយាមធ្វើឃាតគាត់។ គាត់បានរស់នៅនិងផ្សព្វផ្សាយសាសនាឥស្លាមនៅក្រុងម៉ាទីណះ អស់រយៈពេល១០ឆ្នាំ។ គាត់បានបង្គាប់ប្រើមនុស្សឲ្យសឡាត(ថ្វាយបង្គំព្រះ) ដកហ្សាកាត់ និងប្រតិបត្តិតាមច្បាប់ឥស្លាមផ្សេងៗទៀត។




## 6 ការពង្រីកសាសនាឥស្លាមរបស់គាត់

អ្នកនាំសារបានស្ថាបនាមជ្ឈមណ្ឌលអរិយធម៌ឥស្លាមនៅក្រុងម៉ាទីណះ ក្រោយការភៀសខ្លួនរបស់គាត់ នៅចន្លោះឆ្នាំ(៦២២-៦៣២គ.ស)។ គាត់បានបោះយុថ្កាពង្រឹងគោលអត្តសញ្ញាណសង្គមឥស្លាម ដោយបានលុបបំបាត់ការរើសអើង និងកុលសម្ព័ន្ធនិយម ហើយបានផ្សព្វផ្សាយចំណេះដឹង ពង្រឹងគោលការណ៍យុត្តិធម៌ ភាពត្រឹមត្រូវ ភាតរភាព សាមគ្គីភាព និងប្រព័ន្ធវិន័យ។ មានកុលសម្ព័ន្ធខ្លះបានព្យាយាមបញ្ចប់ជីវិតសាសនាឥស្លាម ដែលជាហេតុនាំឲ្យកើតមានចម្បាំងនិងព្រឹត្តិការណ៍មួយចំនួន ប៉ុន្តែអល់ឡោះបានជួយសាសនា និងអ្នកនាំសាររបស់ទ្រង់។ ក្រោយមក មនុស្សលោកបានចូលសាសនាឥស្លាមជាបន្តបន្ទាប់។ ប្រជាជននៅក្រុងម៉ាក្កះ ក៏ដូចជាប្រជាជននៅតាមទីក្រុងផ្សេងៗទៀត ព្រមទាំងកុលសម្ព័ន្ធជាច្រើននៅឧបទ្វីបអារ៉ាប់បានចូលសាសនាឥស្លាមដោយស្ម័គ្រចិត្ត និងពេញចិត្តជាទីបំផុតចំពោះសាសនាដ៏ឧត្តុង្គឧត្តមនេះ។



## 7 មរណភាពរបស់ព្យាការីមូហាំម៉ាត់

នៅក្នុងខែសហ្វើរ(ខែទី២) ឆ្នាំទី១១នៃមូហាំម៉ាត់សករាជ ក្រោយពីព្យាការីមូហាំម៉ាត់បានផ្សព្វផ្សាយសារ និងបានបំពេញនូវទំនួលខុសត្រូវរបស់លោក ហើយអល់ឡោះទ្រង់បានប្រទានពរជ័យដល់មនុស្សលោកដោយឲ្យសាសនាមានភាពពេញពេញបរិបូណ៌ហើយនោះ ព្យាការីក៏កើតជំងឺគ្រុនក្តៅ និងឈឺធ្ងន់ ហើយលោកក៏បានលាចាកលោកនេះទៅនៅថ្ងៃច័ន្ទ ខែរ៉ពីអុលអាវ៉ាល់(ខែទី៣) ឆ្នាំទី១១ នៃមូហាំម៉ាត់សករាជត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ៦៣២ នៃគ.ស នៅអាយុ៦៣ឆ្នាំ។ សពរបស់គាត់ត្រូវបានបញ្ចុះនៅផ្ទះរបស់ អាអ៊ីស្ហះ ស្ថិតនៅក្បែរម៉ាស្ជិតព្យាការី។

## អត្ថន័យនៃពាក្យសច្ចាថា មូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ

ពាក្យ ឬឃ្លានេះមានន័យថា ជំនឿចំពោះរាល់ដំណឹងរបស់គាត់ ប្រតិបត្តិតាមបទបញ្ញត្តិ និងជៀសវាងបម្រាមរបស់គាត់។ យើងត្រូវគោរពសក្ការៈចំពោះអល់ឡោះស្របតាមច្បាប់របស់អ្នកនាំសារ និងអ្វីដែលគាត់បានបង្រៀនយើង។

## តើជំនឿថា ព្យាការីមូហាំម៉ាត់ជាអ្នកនាំសាររបស់អល់ឡោះត្រូវមានអ្វីខ្លះ?

### 1 ជឿចំពោះដំណឹងទាំងឡាយដែលអ្នកនាំសារបានប្រាប់ក្នុងគ្រប់វិស័យទាំងអស់ដូចជា ៖

- រឿងអាថ៌កំបាំង ថ្ងៃបរលោក ឋានសួគ៌ បរមសុខក្នុងឋានសួគ៌ ឋាននរក និងទណ្ឌកម្មក្នុងឋាននរក។
- ព្រឹត្តិការណ៍ដែលកើតឡើងនៅថ្ងៃបរលោក សញ្ញាៗនៃថ្ងៃបរលោក និងអ្វីៗដែលនឹងកើតឡើងនៅសម័យចុងក្រោយ(មុនថ្ងៃបរលោក)
- ដំណឹង ពត៌មានមនុស្សនៅសម័យកាលមុនៗ និងអ្វីដែលបានកើតឡើងរវាងបណ្តាព្យាការី និងក្រុមរបស់គាត់។



>ចាំបាច់លើអ្នកមុស្លិមជឿជាក់ចំពោះអ្វីដែលត្រូវបានបង្ហាញនៃសុណ្ណះ(មាគ៌ា)របស់រ៉ស៊ូលុលឡោះ សល់ឡល់ឡោហ៊ូអាឡាយហ៊ីវ៉ាសាល់ឡាំ

### 2 ប្រតិបត្តិតាមបទបញ្ញត្តិ និងការជៀសវាងពីបម្រាមរបស់អ្នកនាំសារដូចជា

- ប្រតិបត្តិតាមអ្វីៗដែលអ្នកនាំសារបានបង្គាប់បញ្ជាចំពោះយើង និងភាពជឿជាក់របស់យើង គឺជឿថាគាត់មិននិយាយតាមទំនើងចិត្តឡើយ ក៏ប៉ុន្តែពាក្យសំដីរបស់គាត់ គឺជាវ៉ាហ៊ី(ព្រះរាជសារ)ពីអល់ឡោះ។ អល់ឡោះទ្រង់បានមានបន្ទូលថា: “អ្នកណាហើយប្រតិបត្តិតាមអ្នកនាំសារ(ព្យាការីមូហាំម៉ាត់)នោះ គឺគេពិតជាបានប្រតិបត្តិតាមអល់ឡោះ”។ (គម្ពីរគួរអាន ៤:៨០)។
- ជៀសវាងពីបម្រាមដែលគាត់បានហាមឃាត់ ដូចជា ចរិតមិនល្អ និងអាកប្បកិរិយាអាក្រក់។ ហើយយើងជឿជាក់ថា ការហាមប្រាមចំពោះពួកយើងពីបម្រាមទាំងនោះ គឺជាហេតុផលដែលអល់ឡោះទ្រង់ប្រាថ្នា និងដើម្បីផលប្រយោជន៍យើង គ្រាន់តែជួនកាលយើងមិនអាចដឹងពីវាតែប៉ុណ្ណោះ។
- យើងជឿជាក់ច្បាស់ថា ការប្រតិបត្តិតាមបទបញ្ញត្តិ និងការចៀសវាងបម្រាមរបស់អ្នកនាំសារ គឺនាំមកនូវភាពល្អប្រសើរ និងសេចក្តីសុខនៅក្នុងលោកិយនេះ និងនៅបរលោក។ អល់ឡោះទ្រង់ជាម្ចាស់បានមានបន្ទូលថា: “ហើយចូរពួកអ្នកប្រតិបត្តិតាមអល់ឡោះ និងអ្នកនាំសារ(ព្យាការីមូហាំម៉ាត់)ដើម្បីឲ្យពួកអ្នកទទួលបានការអាណិតស្រឡាញ់”។
(គម្ពីរគួរអាន ៣:១៣២)។
- ជំនឿរបស់យើងគឺ ជនណាល្មើសនឹងបទបញ្ញត្តិរបស់ព្យាការី គឺជននោះសក្តិសមនឹងត្រូវទទួលទណ្ឌកម្មយ៉ាងឈឺចាប់។ អល់ឡោះទ្រង់បានមានបន្ទូលថា: “ដូច្នេះចូរឲ្យពួកដែលប្រឆាំងនឹងបទបញ្ជារបស់គាត់(ព្យាការីមូហាំម៉ាត់) ប្រុងប្រយ័ត្នចំពោះគ្រោះអាសន្ននឹងធ្លាក់លើពួកគេ ឬទណ្ឌកម្មយ៉ាងឈឺចាប់ធ្លាក់លើពួកគេ”។
( គម្ពីរគួរអាន ២៤:៦៣)។

## 3 យើងត្រូវគោរពសក្ការៈចំពោះអល់ឡោះ ស្របតាមច្បាប់របស់អ្នកនាំសារ ហើយច្បាប់នោះមានមាត្រាជាច្រើនដែលចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ រួមមាន:

- ការយកតម្រាប់តាមអ្នកនាំសារ: តាមមាគ៌ា ការចង្អុលបង្ហាញ និងជីវិតរស់នៅរបស់អ្នកនាំសារ រួមមានពាក្យសំដី ទង្វើ ការយល់ស្រប និងការទទួលស្គាល់របស់អ្នកនាំសារ គឺជាតម្រាប់សម្រាប់រាល់ភារកិច្ចជីវិតរស់នៅរបស់ពួកយើង។ ហើយខ្ញុំរបស់ព្រះកាន់តែជិតស្និទ្ធចំពោះទ្រង់ និងឋានៈរបស់គេក៏កាន់តែខ្ពស់ដែរ នៅរាល់ពេលដែលគេយកតម្រាប់តាមមាគ៌ា និងការចង្អុលបង្ហាញរបស់អ្នកនាំសារ។ អល់ឡោះទ្រង់មានបន្ទូលថា: “ចូរអ្នកពោលថា ប្រសិនបើពួកអ្នកស្រឡាញ់អល់ឡោះ ចូរពួកអ្នកប្រតិបត្តិតាមខ្ញុំ នោះអល់ឡោះពិតជាស្រឡាញ់ពួកអ្នក និងអភ័យទោសឲ្យពួកអ្នកនូវបាបកម្មទាំងឡាយរបស់ពួកអ្នក។ ហើយអល់ឡោះមហាអភ័យទោសមហាអាណិតស្រឡាញ់”។

  (គម្ពីរគួរអានពា:៣១)។

- ច្បាប់សាសនាដ៏ពេញលេញ:

  អ្នកនាំសារបានផ្សព្វផ្សាយសាសនា និងច្បាប់សាសនាដ៏ពេញលេញគ្មានការខ្វះខាត។ ដូច្នេះមិនអនុញ្ញាតឡើយចំពោះអ្នកណាម្នាក់បង្កើតការគោរពសក្ការៈរបៀបថ្មី ដែលអ្នកនាំសារមិនបានដាក់ច្បាប់ការគោរពសក្ការៈនោះសម្រាប់ពួកយើងទេនោះ។.

- ច្បាប់របស់អល់ឡោះគឺមានប្រសិទ្ធភាពសម្រាប់គ្រប់សម័យកាល និងគ្រប់ទីកន្លែង:

  ក្រឹត្យក្រមវិន័យ និងច្បាប់សាសនាដែលមានចែងក្នុងគម្ពីររបស់អល់ឡោះ(គម្ពីរគួរអាន) និងក្នុងស៊ុណ្ណះ(មាគ៌ាអ្នកនាំសារ)គឺមានប្រសិទ្ធិភាពសម្រាប់គ្រប់សម័យកាល និងគ្រប់ទីកន្លែង។ គ្មានអ្នកណាម្នាក់ដឹងពីផលប្រយោជន៍របស់មនុស្សលោកជាងម្ចាស់ដែលបានបង្កើតពួកគេអំពីភាពទទេសូន្យនោះឡើយ។

- ស្របតាមមាគ៌ា(អ្នកនាំសារ): ការទទួលយកការគោរពសក្ការៈចាំបាច់ត្រូវតែនៀត(តាំងចិត្ត)ដោយស្មោះត្រង់ចំពោះអល់ឡោះ និងស្របតាមច្បាប់(មាគ៌ា)អ្នកនាំសារ។ អល់ឡោះទ្រង់បានមានបន្ទូលថា: “ដូច្នេះ ជនណាដែលសង្ឃឹមថានឹងបានជួបម្ចាស់របស់គេ ចូរឲ្យគេសាងអំពើល្អ ហើយកុំឲ្យគេយកអ្នកណាម្នាក់ធ្វើជាដៃគូក្នុងការគោរពសក្ការៈចំពោះម្ចាស់របស់គេឲ្យសោះ”។ (គម្ពីរគួរអាន១៨:១១០)

  "អំពើល្អ" មានន័យថា ធ្វើបានត្រឹមត្រូវ និងស្របតាមមាគ៌ារបស់ព្យាការី។



>ចិត្តបរិសុទ្ធជ្រះថ្លានិងចិត្តស្ងប់ដោយការគោរពទៅចំពោះព្រះអល់ឡោះតែមួយគត់

• ការហាមឃាត់ចំពោះការបង្កើតថ្មីក្នុងសាសនា ៖ ជនណាបង្កើតទង្វើអ្វីមួយ និងការគោរពសក្ការៈដែលមិនមែនជាមាគ៌ាព្យាការី ហើយគេចង់គោរពសក្ការៈចំពោះអល់ឡោះរួមនឹងការបង្កើតថ្មីនោះ ដូចជាបង្កើតសឡាត(ការថ្វាយបង្គំ)ថ្មីខុសពីមាគ៌ាសាសនា ដូច្នេះវាពិតជាល្មើសនឹងបទបញ្ញត្តិរបស់គាត់(អ្នកនាំសារ)។ គេមិនទទួលយកទង្វើនោះឡើយ ហើយថែមទាំងទទួលនូវបាបកម្មដោយសារទង្វើនោះថែមទៀតផង។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ដូច្នេះ ចូរឲ្យពួកដែលប្រឆាំងនឹងបទបញ្ជារបស់គេ(ព្យាការី) ប្រុងប្រយ័ត្នចំពោះគ្រោះអាសន្ននឹងធ្លាក់លើពួកគេ ឬទណ្ឌកម្មយ៉ាងឈឺចាប់ធ្លាក់លើពួកគេ”។ (គម្ពីរគួរអាន ២៤:៦៣)។ អ្នកនាំសារមានប្រសាសន៍ថាៈ “អ្នកណាបង្កើតថ្មីក្នុងកិច្ចការ(សាសនា)របស់យើងដែលមិនមែនមកពីវា(កិច្ចការសាសនា)ទេនោះ ប្រាកដណាស់វាត្រូវបានគេច្រានចោល(មិនទទួលយក)”។(ពូខរីៈ២៥៥០និងមូស្លីម១៧១៨)។



# > គោលជំនឿទាំង៦ប្រាំមួយ

## អត្ថន័យនៃជំនឿចំពោះអល់ឡោះ

គឺជំនឿដ៏ច្បាស់លាស់ថា អល់ឡោះមានពិត ទទួលស្គាល់ទ្រង់ជាព្រះជាម្ចាស់ និងជាព្រះដែលត្រូវគេគោរពសក្ការៈតែមួយគត់ ទ្រង់មានព្រះនាម និងព្រះលក្ខណៈដ៏វិសេសវិសាល។

យើងនឹងបកស្រាយអំពីប្រការទាំងបួនយ៉ាងលម្អិត ដូចតទៅនេះ៖

## 1 ជំនឿថា អល់ឡោះមានពិត

### និស្ស័យដែលអល់ឡោះផ្ដល់ពីកំណើត

ការទទួលស្គាល់ថាអល់ឡោះមានពិត គឺជានិស្ស័យពីកំណើតមិនចាំបាច់ត្រូវការភស្តុតាងក៏បានដែរ។ ហេតុនេះ មនុស្សភាគច្រើនដែលកាន់សាសនា និងលទ្ធិផ្សេងៗគ្នា តែងតែទទួលស្គាល់ថាមានព្រះជាម្ចាស់(អល់ឡោះ)។

រីឯពួកយើងក៏មានអារម្មណ៍ក្នុងជម្រៅបេះដូងរបស់យើងថា ទ្រង់ពិតជាមានពិត យើងត្រូវការពឹងអាស្រ័យចំពោះទ្រង់នៅពេលមានការលំបាកខ្លាំង និងពេលមានគ្រោះអាសន្ន ដោយនិស្ស័យពីកំណើតរបស់យើងដែលមានជំនឿសភាវៈធម្មជាតិនៃការប្រកាន់សាសនាដែលអល់ឡោះបានផ្ដុំឡើងក្នុងខ្លួនប្រាណមនុស្សគ្រប់ៗរូបទោះបីជាមនុស្សលោកខ្លះព្យាយាមលុបបំបាត់ និងបំភ្លេចវាក៏ដោយ។

ហើយពួកយើងធ្លាប់បានឮបានឃើញអំពីការឆ្លើយតបនឹងពួកអ្នកបួងសួងសុំ ការប្រទានចំពោះពួកអ្នកដែលបានសុំ ហើយឆ្លើយតបនឹងពួកអ្នកដែលមានគ្រោះអាសន្ន វាគឺជាការចង្អុលបង្ហាញឲ្យឃើញយ៉ាងច្បាស់លាស់ថាអល់ឡោះមានពិត។

### ភស្តុតាងដែលបញ្ជាក់ថាអល់ឡោះមានពិត វាច្បាស់ជាងការរំឭកប្រាប់ និងការគណនា ដូចជា

- បុគ្គលគ្រប់រូបដឹងយ៉ាងច្បាស់ថា រាល់ហេតុទាំងអស់ត្រូវមានអ្នកបង្កហេតុ ហើយម៉ាខ្លូក(អ្វីគ្រប់យ៉ាងដែលព្រះបានបង្កើត)ដ៏ច្រើនលើសលប់ដែលយើងបានឃើញគ្រប់ពេលវេលា ចាំបាច់ត្រូវតែមានព្រះជាម្ចាស់បង្កើតវា ទ្រង់នោះគឺព្រះអល់ឡោះ ពីព្រោះថា វាមិនអាចទៅរួចនោះទេដែលថា អ្វីដែលកើតឡើងដោយគ្មានព្រះជាម្ចាស់បង្កើតវា ក៏ដូចគ្នាដែរមិនអាចទេអ្វីដែលកើតឡើងឯកឯងនោះ។ ព្រោះអ្វីក៏ដោយមិនអាចបង្កើតខ្លួនឯងឡើយ។ អល់ឡោះទ្រង់បានមានបន្ទូលថា: "តើពួកគេត្រូវបានគេបង្កើត



ខ្លួនមនុស្សផ្ទាល់ គឺជាភស្តុតាងដ៏ធំបំផុតដែលបញ្ជាក់លើវត្តមានរបស់អល់ឡោះសម្រាប់អ្នកដែលធ្វើការត្រិះរិះពិចារណា និងដាក់ភ្នែកមើលទៅកាន់អ្វីដែលអល់ឡោះបានប្រទានឲ្យចំពោះពរជ័យប្រាជ្ញា និងសុក្រឹតភាពនៃវិញ្ញាណទាំងប្រាំ និងសណ្ដាប់ធ្នាប់នៃសភាវៈទាំងឡាយ និងភាពឥតខ្ចោះរបស់វាដូចជាអល់ឡោះបានមានព្រះបន្ទូលថា៖ ហើយចំពោះខ្លួនរបស់អ្នកផ្ទាល់ក៏ដូច្នោះដែរ តើពួកអ្នកមិនបានមើលឃើញទេឬ?

ដោយគ្មានអ្នកបង្កើត ឬមួយពួកគេជាអ្នកដែលបង្កើតខ្លួនឯង?”។ (គម្ពីរគួរអាន ៥២:៣៥)។ អត្ថន័យនៅក្នុងវាក្យខណ្ឌនេះគឺ ប្រាកដណាស់ ពួកគេមិនអាចកើតដោយគ្មានព្រះជាម្ចាស់បង្កើតនោះទេ ហើយពួកគេក៏មិនបានបង្កើតខ្លួនឯងបានដែរ។ ដូច្នេះ ចាំបាច់ត្រូវតែមានព្រះជាម្ចាស់បង្កើតពួកគេ ទ្រង់នោះគឺព្រះអល់ឡោះជាម្ចាស់។

- ពិតណាស់ ក្រឹត្យក្រមនៃប្រព័ន្ធចក្រវាឡ មានមេឃ ផែនដី ផ្កាយទាំងឡាយ និងរុក្ខជាតិ។ល។ ចង្អុលបង្ហាញយ៉ាងច្បាស់លាស់ថា សម្រាប់ចក្រវាលនេះ គឺមានព្រះជាម្ចាស់តែមួយគត់ ទ្រង់នោះគឺព្រះអល់ឡោះ។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ជាការបង្កើតរបស់អល់ឡោះដែលទ្រង់បានបង្កើតអ្វីៗគ្រប់យ៉ាងល្អឥតខ្ចោះ”។ ( គម្ពីរគួរអាន ២៧:៨៨)។

បណ្តាភព និងបណ្តាផ្កាយទាំងឡាយ ជាឧទាហរណ៍ វាធ្វើចលនាជាប្រព័ន្ធដ៏ល្អ សុក្រឹតឥតខ្ចោះ គ្មានខុសពីគន្លងវាឡើយ។ គ្រប់ភពទាំងអស់ធ្វើចលនាក្នុងគន្លងរបស់វាគ្មានការខុសឆ្គង ឬហួសពីគន្លងរបស់វាឡើយ។

អល់ឡោះទ្រង់មានបន្ទូលថាៈ “ព្រះអាទិត្យមិនអាចធ្វើចលនាទាន់ព្រះចន្ទឡើយ។ រីឯពេលយប់ក៏មិនអាចមកដល់មុនពេលថ្ងៃបានដែរ។ ហើយអ្វីៗទាំងអស់ត្រូវធ្វើដំណើរតាមគន្លងរបស់វារៀងៗខ្លួន”។ (គម្ពីរគួរអាន ៣៦:៤០)។

## 2 ជំនឿចំពោះភាពជាព្រះជាម្ចាស់នៃការបង្កើតរបស់អល់ឡោះ

### អត្ថន័យនៃជំនឿចំពោះភាពជាម្ចាស់នៃការបង្កើតរបស់អល់ឡោះ

គឺជាការទទួលស្គាល់ និងការជឿជាក់យ៉ាងច្បាស់លាស់ចំពោះអល់ឡោះជាម្ចាស់ថា ទ្រង់ជាអ្នកគ្រប់គ្រង ជាអ្នកបង្កើត ជាអ្នកប្រទានលាភសក្ការៈចំពោះអ្វីៗទាំងអស់។ ទ្រង់ជាអ្នកប្រោសឲ្យមានជីវិត ជាអ្នកឲ្យជីវិតស្លាប់ ជាអ្នកប្រទានផលល្អ ជាអ្នកប្រទានគ្រោះ ហើយរាល់កិច្ចការទាំងអស់គឺជាកម្មសិទ្ធិរបស់ទ្រង់។ ព្រះហស្ថ(ដៃ) របស់ទ្រង់ពោរពេញដោយសេចក្តីល្អប្រសើរ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។ កិច្ចការទាំងអស់នេះ គ្មានអ្នកណាចូលរួមជាមួយទ្រង់ឡើយ។



ដូច្នេះ ការទទួលស្គាល់អល់ឡោះតែមួយគត់ចំពោះរាល់ទង្វើរបស់ទ្រង់គឺត្រូវជឿថា

ពិតណាស់ អល់ឡោះតែមួយគត់ ទ្រង់បង្កើតចក្រវាលទាំងមូល គ្មានអ្នកបង្កើតផ្សេងក្រៅពីទ្រង់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: “អល់ឡោះគឺជាអ្នកដែលបានបង្កើតរាល់អ្វីៗទាំងអស់”។ (គម្ពីរគួរអាន ៣៩: ៦២)។

រីឯការបង្កើត ការច្នៃប្រឌិតរបស់មនុស្សលោកវិញ គឺជាការកែប្រែពីលក្ខណៈមួយ ទៅលក្ខណៈមួយផ្សេងទៀត ឬក៏ជាការប្រមូលផ្តុំ ឬផ្គុំ និងផ្សេងៗទៀត ដោយវាពុំមែនជាការបង្កើតពិតប្រាកដនោះឡើយ មិនមែនជាការបង្កើតពីភាពគ្មាន ហើយក៏មិនមែនជាការបង្កើតឱ្យរស់ក្រោយពេលស្លាប់ដែរ។

ពិតណាស់ ទ្រង់គឺជាអ្នកប្រទានលាភសក្ការៈដល់ម៉ាខ្លូក(អ្វីទាំងអស់ដែលព្រះអល់ឡោះបានបង្កើត) ទាំងអស់ ដោយគ្មានអ្នកណាផ្តល់លាភសក្ការៈក្រៅពីទ្រង់ឡើយ។ អល់ឡោះទ្រង់បានមានបន្ទូលថា: “គ្មានសត្វលោកណាមួយដែលរស់នៅលើផែនដីលើកលែងតែអល់ឡោះផ្តល់លាភសក្ការៈដល់ពួកគេ”។ (គម្ពីរគួរអាន១១: ៦)។

ហើយពិតណាស់ ទ្រង់គឺជាស្តេចគ្រប់គ្រងរាល់អ្វីៗគ្រប់យ៉ាង ហើយគ្មានអ្នកគ្រប់គ្រងដ៏ពិតក្រៅពីទ្រង់ឡើយ។អល់ឡោះទ្រង់មានបន្ទូលថា: “ការគ្រប់គ្រងមេឃជាច្រើននិងផែនដី ព្រមទាំងអ្វីៗដែលមាននៅក្នុងវាទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ”។ ( គម្ពីរគួរអាន ៥:១២០)។

ហើយទ្រង់គឺជាអ្នកចាត់ចែងអ្វីៗទាំងអស់គ្មានអ្នកចាត់ចែងណាក្រៅពីអល់ឡោះឡើយ។ អល់ឡោះទ្រង់បានមានបន្ទូលថា:“ទ្រង់ចាត់ចែងកិច្ចការពីលើមេឃមកកាន់ផែនដី”។(គម្ពីគួរអាន ៣២:៥)។

រីឯការចាត់ចែងរបស់មនុស្សលោកចំពោះកិច្ចការជីវិតរស់នៅ និងការរៀបចំកិច្ចការរបស់ពួកគេមានភាពស្មុគស្មាញ និងមានដែនកំណត់ត្រឹមតែអ្វីៗដែលនៅក្នុងកណ្តាប់ដៃរបស់គេ អ្វីៗដែលគេគ្រប់គ្រង និងមានលទ្ធភាពប៉ុណ្ណោះ។ ជួនកាលការចាត់ចែងរបស់គេទទួលបានផល ហើយជួនកាលបរាជ័យ។ ក៏ប៉ុន្តែការចាត់ចែងរបស់ទ្រង់ជាអ្នកបង្កើតវិញ គឺមានភាពពេញលេញគ្មានចន្លោះប្រហោងត្រង់ណាឡើយ។ ម៉្យាងទៀតវាប្រព្រឹត្តទៅយ៉ាងរលូនគ្មានអ្វីរាំងនិងគ្មានការប្រឈមមុខអ្វីឡើយ។ អល់ឡោះទ្រង់បានមានបន្ទូលថា: “ចូរដឹងថា ការបង្កើត និងការគ្រប់គ្រងគឺជាកម្មសិទ្ធិរបស់ទ្រង់។ អល់ឡោះដ៏មហាឧត្តុង្គឧត្តម ជាម្ចាស់គ្រប់គ្រងពិភពទាំងអស់”។ (គម្ពីគួរអាន ៧:៥៤)។



គ្មានសត្វលោកណាមួយដែលដើរហើរនៅលើផែនដីនេះ លើកលែងតែអល់ឡោះជាអ្នកផ្តល់លាភសក្ការៈឲ្យពួកគេ។

## ពួកអារ៉ាប់ដែលគោរពពហុទេពនៅសម័យអ្នកនាំសារ ពួកគេមានជំនឿចំពោះភាពជាព្រះនៃការបង្កើតរបស់ព្រះអល់ឡោះ

ពួកអ្នកប្រឆាំងនៅសម័យអ្នកនាំសារបានទទួលស្គាល់ថា អល់ឡោះទ្រង់ពិតជាអ្នកបង្កើត ជាអ្នកគ្រប់គ្រង និងជាអ្នកចាត់ចែង ប៉ុន្តែជំនឿនេះមិនអាចធ្វើឱ្យពួកគេចូលសាសនាឥស្លាមបានទេ បើគ្រាន់តែទទួលស្គាល់ប៉ុណ្ណឹងនោះ។ អល់ឡោះទ្រង់មានបន្ទូលថា: "ហើយប្រសិនបើអ្នក(ព្យាការីមូហាំម៉ាត់)សួរពួកគេ(ពួកពហុទេពនិយម)ថា: តើអ្នកណាដែលបានបង្កើតមេឃជាច្រើនជាន់ និងផែនដី? ពួកគេពិតជានឹងឆ្លើយថា: គឺព្រះអល់ឡោះជាម្ចាស់"។ (គម្ពីគួរអាន ៣១:២៥)។

ពីព្រោះអ្នកដែលបានទទួលស្គាល់ថា អល់ឡោះជាម្ចាស់គ្រប់គ្រងពិភពទាំងអស់ មានន័យថា ទ្រង់គឺជាអ្នកបង្កើត គ្រប់គ្រង និងមើលថែរក្សាពួកគេដោយពរជ័យរបស់ទ្រង់ ចាំបាច់ណាស់គេត្រូវតែគោរពសក្ការៈចំពោះទ្រង់តែមួយគត់ដោយមិនគោរពសក្ការៈអ្នកដទៃឡើយ។

តើសមហេតុផលយ៉ាងដូចម្តេចដែលមនុស្សទទួលស្គាល់ថា អល់ឡោះជាអ្នកបង្កើតគ្រប់អ្វីៗទាំងអស់ និងជាអ្នកចាត់ចែងចក្រវាល ទ្រង់ជាអ្នកឲ្យមានជីវិត និងឲ្យស្លាប់ ហើយគេបែរជាថ្វាយអ្វីមួយនៃការគោរពសក្ការៈជូនចំពោះអ្នកផ្សេងក្រៅពីទ្រង់ទៅវិញនោះ?! នេះជាទង្វើដ៏អយុត្តិធម៌បំផុត និងជាអំពើបាបដ៏ធ្ងន់ធ្ងរបំផុត។ ដូច្នេះហើយទើបព្យាការីលុកម៉ានបានពោលទៅកាន់កូនរបស់គាត់ដោយទូន្មាន និងណែនាំថា: "ឱកូនសម្លាញ់! ចូរកូនកុំធ្វើពហុទេពនិយមចំពោះអល់ឡោះឲ្យសោះ។ ពិតណាស់ អំពើពហុទេពនិយម គឺជាបាបកម្មមួយដ៏ធំ"។ (គម្ពីគួរអាន ៣១: ១៣)។

ហើយនៅពេលគេសួរអ្នកនាំសារថា: បាបកម្មអ្វីដែលធំជាងគេចំពោះអល់ឡោះ? គាត់បានឆ្លើយថា: "គឺការដែលអ្នកប្រព្រឹត្តិ(គោរពសក្ការៈ)ទៅចំពោះអ្នកផ្សេងដូច(គោរពសក្ការៈ)ចំពោះអល់ឡោះខណៈដែលទ្រង់បានបង្កើតអ្នក"។ (អាល់ពូខរី:៤២០៧ និងមូស្លីម:៨៦)។

## ជំនឿចំពោះភាពជាម្ចាស់របស់អល់ឡោះធ្វើឲ្យចិត្តស្ងប់ស្ងប់ស្ងល់

កាលណាខ្ញុំ(របស់អល់ឡោះ)ដឹងយ៉ាងច្បាស់ថា គ្មានអ្នកណាម្នាក់នៃម៉ាខ្លូកអាចគេចចេញពីព្រះលិខិត(បានកំណត់)របស់អល់ឡោះ ពីព្រោះអល់ឡោះទ្រង់គ្រប់គ្រងចាត់ចែងពួកគេតាមការសព្វព្រះទ័យស្របតាមគតិបណ្ឌិតរបស់ទ្រង់ដែលទ្រង់ជាអ្នកបង្កើតពួកគេទាំងអស់។ អ្វីៗក៏ដោយក្រៅពីអល់ឡោះគឺត្រូវបានគេបង្កើតឡើងមានលក្ខណៈខ្វះខាតត្រូវការទ្រង់ដែលជាអ្នកបង្កើតគេ។ គ្រប់ភារកិច្ចទាំងអស់នៅក្នុងកណ្តាប់ដៃរបស់ទ្រង់ គ្មានអ្នកបង្កើត គ្មានអ្នកប្រទានលាភសក្ការៈ និងគ្មានអ្នកចាត់ចែងចក្រវាលក្រៅពីទ្រង់តែមួយគត់នោះទេ សូម្បីតែគ្រាប់ធញ្ញជាតិមួយគ្រាប់ក៏មិនប្រែប្រួលបានដែរ លុះត្រាតែមានការអនុញ្ញាតពីទ្រង់ ហើយគ្រាប់ធញ្ញជាតិមួយគ្រាប់ផ្សេងទៀត



>ការជឿជាក់ចំពោះភាពជាព្រះជាម្ចាស់នៃការបង្កើតរបស់អល់ឡោះ ធ្វើអោយមានចិត្តស្ងប់

មិនប្រែប្រួល ក៏តាមបទបញ្ជារបស់ទ្រង់ដែរ។ ហេតុដូច្នេះ ទើបតម្រូវឲ្យចិត្តមនុស្សលោកផ្សាភ្ជាប់នឹងអល់ឡោះ បួងសួងសុំ ត្រូវការ និងពឹងពាក់ចំពោះទ្រង់តែមួយគត់នូវគ្រប់កិច្ចការជីវិតរបស់គេ។ ការសំដៅឆ្ពោះទៅមុខ ការខ្ជាប់ខ្ជួនក្នុងការប្រឈមនឹងឧបសគ្គជីវិត ប្រកបដោយភាពស្កប់ស្កល់ រឹងប៉ឹង និងមានភាពនឹងនរយ៉ាងពេញលេញ ពីព្រោះជានិច្ចកាល គេតែងតែប្រើប្រាស់គ្រប់មធ្យោបាយ និងបួងសួងសុំចំពោះអល់ឡោះ ដើម្បីសម្រេចតាមប្រាថ្នាចង់បានក្នុងកិច្ចការជីវិត។ គេប្រតិបត្តិតាមភារកិច្ចរបស់គេ នៅពេលនោះ ខ្លួនគេនឹងស្កប់ស្កល់មិនសម្លឹងមើល(ចង់បាន)អ្វីៗដែលនៅក្នុងកណ្តាប់ដៃអ្នកដទៃឡើយ។ តាមពិត កិច្ចការទាំងអស់នៅក្នុងកណ្តាប់ដៃរបស់អល់ឡោះតែមួយគត់ ទ្រង់បង្កើតអ្វីដែលទ្រង់ប្រាថ្នា និងជ្រើសរើស។

## 3 ជំនឿចំពោះភាពជាព្រះដែលត្រូវគេគោរពសក្ការៈរបស់អល់ឡោះ

### អត្ថន័យនៃជំនឿចំពោះភាពជាព្រះដែលត្រូវគេគោរពសក្ការៈរបស់អល់ឡោះ?

គឺជាការជឿជាក់យ៉ាងដាច់ខាតថា អល់ឡោះតែមួយគត់ដែលសក្តិសមនឹងទទួលការគោរពសក្ការៈគ្រប់ប្រភេទទាំងអស់ ទាំងការគោរពសក្ការៈផ្នែកខាងក្រៅ និងផ្នែកខាងក្នុង(ផ្លូវចិត្ត)។ ដូច្នេះ យើងត្រូវប្រតិបត្តិការគោរពសក្ការៈទាំងអស់ចំពោះទ្រង់តែមួយគត់ដូចជា ការបួងសួងសុំ កោតខ្លាច ជឿទុកចិត្ត សុំជំនួយ សទ្បាត(ការថ្វាយបង្គំ) បរិច្ចាគហ្សាកាត់ និងកាន់អំណត់បួស ហើយគ្មានអ្នកណាត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: "ហើយព្រះជាម្ចាស់របស់ពួកអ្នកគឺជាព្រះជាម្ចាស់តែមួយគត់។ គ្មានព្រះជាម្ចាស់ណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ដែលមហាសប្បុរស មហាអាណិតស្រឡាញ់នោះឡើយ"។ (គម្ពីរគួរអាន ២:១៦៣)។



>ការទទួលស្គាល់អល់ឡោះតែមួយគត់ជាព្រះដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ ហើយការគោរពសក្ការៈទៅចំពោះទ្រង់ គឺជាធាតុពិតនៃអត្ថន័យនៃពាក្យ គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈពិតប្រាកដ លើកលែងតែអល់ឡោះ។

ទ្រង់បានប្រាប់ថា ព្រះជាម្ចាស់គឺជាព្រះតែមួយ មានន័យថា ត្រូវគេគោរពសក្ការៈតែមួយគត់។ ដូច្នេះ មិនអនុញ្ញាតឲ្យយកព្រះជាម្ចាស់ផ្សេងគោរពសក្ការៈក្រៅពីទ្រង់ជាដាច់ខាត។

## សារៈសំខាន់នៃជំនឿចំពោះភាពជាម្ចាស់ដែលត្រូវគោរពសក្ការៈរបស់អល់ឡោះ

សារៈសំខាន់នៃជំនឿចំពោះភាពជាព្រះដែលត្រូវគោរពសក្ការៈរបស់អល់ឡោះ ស្តែងឡើងក្នុងផ្នែកជាច្រើនដូចជា ៖

1. ពិតណាស់ វាគឺជាគោលបំណងនៃការបង្កើតជិន(អមនុស្ស) និងមនុស្ស ពីព្រោះ គេមិនបានបង្កើតពួកគេនោះឡើយ លើកលែងតែដើម្បីឲ្យពួកគេគោរពសក្ការៈចំពោះទ្រង់តែមួយគត់ដោយគ្មានការគោរពសក្ការៈចំពោះអ្នកផ្សេងរួមជាមួយទ្រង់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងមិនបានបង្កើតជិននិងមនុស្សលោក ក្រៅពីឲ្យពួកគេគោរពសក្ការៈ មកចំពោះយើងនោះឡើយ”។ (គម្ពីរគួរអាន ៥១:៥៦)។
2. ជាការពិត គោលបំណងនៃការបញ្ជូនបណ្តាអ្នកនាំសារ និងការបញ្ចុះបណ្តាព្រះគម្ពីរទាំងឡាយពីលើមេឃនោះ គឺការទទួលស្គាល់ថា អល់ឡោះជាអ្នកដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ ហើយប្រឆាំងចំពោះអ្វីៗដែលគេគោរពសក្ការៈក្រៅពីទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយជាការពិតណាស់ រាល់ប្រជាជាតិនីមួយៗយើងបានតែងតាំងអ្នកនាំសារម្នាក់ ដោយបង្គាប់ពួកគេឲ្យគោរពសក្ការៈចំពោះអល់ឡោះ និងជៀសវាងពីតហ្គូត(អ្វីៗដែលគេគោរពសក្ការៈផ្សេងក្រៅពីអល់ឡោះ)”។ (គម្ពីរគួរអាន ១៦: ៣៦)
3. ពិតណាស់ វាជាកាតព្វកិច្ចដំបូងបង្អស់មកលើមនុស្សលោក ដូចអ្វីដែលព្យាការីបានផ្តាំផ្ញើចំពោះមូអាស្ស ពិនហ្ជាហ្គាល់ ពេលដែលព្យាការីបញ្ជូនគាត់ទៅកាន់ប្រទេសយេមែន ដោយលោកបានមានប្រសាសន៍ថាៈ “ពិតណាស់ អ្នកនឹងទៅជួបក្រុមមួយនៃពួកអះលីគីតាប(ពួកដែលអល់ឡោះផ្តល់គម្ពីរឲ្យ គឺពួកជ្វីហ្វ និងពួកគ្រឹស្ទាន)។ ដូច្នេះ អ្វីដែលអ្នកត្រូវតែអំពាវនាវពួកគេដំបូងបង្អស់នោះ គឺការសច្ចាថាគ្មានទេព្រះជាម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ ក្រៅពីអល់ឡោះឡើយ”។ (អាល់ពូខរីៈ១៣៨៩ និងមូស្លីមៈ១៩)។ ពោលគឺអ្នកត្រូវអំពាវនាវពួកគេឲ្យធ្វើការគោរពសក្ការៈទៅចំពោះអល់ឡោះតែមួយគត់។
4. ពិតណាស់ ជំនឿចំពោះភាពជាព្រះនៃការគោរពសក្ការៈ គឺជាអត្ថន័យពិតនៃពាក្យ គ្មានទេព្រះជាម្ចាស់ក្រៅពីអល់ឡោះ។ ព្រះមានន័យថា អ្នកដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ ដោយគ្មានអ្នកដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ ហើយយើងមិន ថ្វាយប្រការណាមួយនៃការគោរពសក្ការៈគ្រប់ប្រភេទទាំងអស់ជូនអ្នកផ្សេងក្រៅពីទ្រង់ឡើយ។
5. ពិតណាស់ ជំនឿចំពោះភាពជាព្រះដែលត្រូវតែគេគោរពសក្ការៈរបស់អល់ឡោះនោះ គឺជាលទ្ធផលសមហេតុផលនៃជំនឿថា អល់ឡោះជាអ្នកបង្កើត ជាអ្នកគ្រប់គ្រង និងជាអ្នកចាត់ចែង។



# > តើការគោរពសក្ការៈមានន័យដូចម្តេច?

ការគោរពសក្ការៈ គឺជានាមមួយដែលគ្រប់ដណ្តប់លើប្រការទាំងឡាយណាដែលអល់ឡោះទ្រង់ស្រឡាញ់ យល់ព្រម ហើយវាមានទាំងវាចា និងទង្វើដែលទ្រង់បញ្ញត្តិ និងតម្រូវឲ្យមនុស្សប្រតិបត្តិវា ទោះវាជាការប្រតិបត្តិផ្នែកខាងក្រៅដូចជា ការសឡាត(ការថ្វាយបង្គំ) ការបរិច្ចាគហ្សាកាត់(ការបង់ទ្រព្យសម្បត្តិតាមច្បាប់ឥស្លាម) ការធ្វើបុណ្យហាជ្ជ(នៅក្រុងម៉ាក្កះ) ឬជាការប្រតិបត្តិផ្នែកខាងក្នុងដូចជា ការស្រឡាញ់អល់ឡោះ ការស្រឡាញ់អ្នកនាំសាររបស់ទ្រង់ ការកោតខ្លាចចំពោះទ្រង់ ការជឿទុកចិត្តលើទ្រង់ ការសុំជំនួយពីទ្រង់។ល។

## ការគោរពសក្ការៈប្រព្រឹត្តទៅលើគ្រប់វិស័យរស់នៅរបស់មនុស្សលោក

ការគោរពសក្ការៈគឺគ្របដណ្តប់លើរាល់សកម្មភាពរបស់អ្នកមានជំនឿកាលណាគេមាននៀត(តាំងចិត្ត)នៃសកម្មភាពនោះដើម្បីគោរពសក្ការៈចំពោះអល់ឡោះ។ ការគោរពសក្ការៈក្នុងសាសនាឥស្លាមពុំមែនត្រឹមតែជាអត្តសញ្ញាណសាសនាដូចជា ការសឡាត(ការថ្វាយបង្គំ) ការកាន់អំណត់បួស... ដូចដែលគេស្គាល់នោះទេ ផ្ទុយទៅវិញ រាល់សកម្មភាពទាំងឡាយណាដែលមានផលប្រយោជន៍ដោយមានការនៀត(តាំងចិត្ត)ដែលល្អត្រឹមត្រូវ សកម្មភាពនោះ ក៏ក្លាយជាការគោរពសក្ការៈដែលទទួលបានផលបុណ្យដែរ។ ប្រសិនបើអ្នកឥស្លាមបរិភោគ ឬទទួលទាន ឬសម្រាន្តដោយប្រាថ្នាចង់ឲ្យរាងកាយមាំមួនដើម្បីប្រតិបត្តិចំពោះអល់ឡោះ ប្រាកដណាស់ គេពិតជាទទួលបានផលបុណ្យ។ ហេតុដូច្នេះ ទាមទារឲ្យអ្នកឥស្លាមប្រើប្រាស់ជីវិតរបស់ពួកគេទាំងអស់ថ្វាយជូនព្រះអល់ឡោះ។ គេបរិភោគអាហារចង់ឲ្យរាងកាយមាំមួនដើម្បីប្រតិបត្តិចំពោះអល់ឡោះ នោះការបរិភោគអាហារដោយគេប្រាថ្នាដូច្នោះ គេក៏បានផលបុណ្យនៃការគោរពសក្ការៈផងដែរ។ គេរៀបការដើម្បីរក្សាខ្លួនពីបម្រាម(របស់អល់ឡោះ) នោះអាពាហ៍ពិពាហ៍របស់គេក៏បានផលបុណ្យនៃការគោរពសក្ការៈផងដែរ។



> ទង្វើទាំងអស់ដែលអមជាមួយការនៀត(ប៉ុនប៉ង)ល្អត្រឹមត្រូវ គេចាត់ទុកថាជាការគោរពសក្ការៈ ដែលនឹងត្រូវបានតបស្នងទៅលើបុគ្គលដែលបានសាងវា

ដូចគ្នាដែរ ការប្រាថ្នាល្អត្រឹមត្រូវក្នុងជំនួញ មុខងារ តួនាទី និងប្រាក់ចំណូល(ល្អត្រឹមត្រូវ)របស់គេនោះ ក៏បានផលបុណ្យនៃការគោរពសក្ការៈផងដែរ។ ការទទួលបានចំណេះដឹង សញ្ញាបត្រ ការសិក្សាស្រាវជ្រាវស្វែងរកចំណេះដឹង ការច្នៃប្រឌិត(ផលិតផល) ទាំងអស់នោះគេក៏នឹងទទួលបានផលបុណ្យនៃការគោរពសក្ការៈផងដែរ។ ការមើលថែរក្សារបស់ភរិយាចំពោះស្វាមី កូនៗ ផ្ទះសំបែងរបស់នាង នោះនាងនឹងទទួលបានផលបុណ្យនៃការគោរពសក្ការៈផងដែរ។ ដូច្នេះ គ្រប់វិស័យរស់នៅ គ្រប់សកម្មភាព និងកិច្ចការដែលមានផលប្រយោជន៍ដល់មនុស្សលោក តែងទទួលបានផលបុណ្យនៃការគោរពសក្ការៈជានិច្ច កាលណាអ្វីៗទាំងអស់នោះប្រកបដោយការនៀត(តាំងចិត្ត)ល្អ និងស្អាតស្អំ។

## ការគោរពសក្ការៈគឺជាគោលបំណងនៃការបង្កើត ជិន(អមនុស្ស) និងមនុស្សលោក

អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងមិនបានបង្កើតជិន(អមនុស្ស) និងមនុស្សលោក ក្រៅពីឲ្យពួកគេគោរពសក្ការៈចំពោះយើងឡើយ។ យើងមិនត្រូវការលាភសក្ការៈពីពួកគេ ហើយយើងក៏មិនត្រូវការឲ្យពួកគេផ្ដល់អាហារដល់យើងដែរ។ ពិតណាស់អល់ឡោះជាអ្នកផ្ដល់លាភសក្ការៈដែលមានអានុភាពខ្លាំងក្លាជាទីបំផុត”។ (គម្ពីរគួរអាន ៥១:៥៦-៥៨)។ អល់ឡោះបានប្រាប់ថា ពិតណាស់ បុព្វហេតុនៃការបង្កើតជិន(អមនុស្ស) និងមនុស្សលោក គឺដើម្បីឲ្យពួកគេប្រតិបត្តិ គោរពសក្ការៈចំពោះអល់ឡោះ ពុំមែនមានន័យថា ទ្រង់ត្រូវការការគោរពសក្ការៈរបស់ពួកគេនោះទេ តែតាមពិត គឺពួកគេទេដែលត្រូវការការគោរពសក្ការៈចំពោះទ្រង់នោះ ពីព្រោះពួកគេក្រទុរគត និងត្រូវការទ្រង់។

ប្រសិនបើមនុស្សលោកព្រងើយកន្តើយពីបំណងប្រាថ្នា(ការគោរពសក្ការៈ)នេះ និងងប់ងុលក្នុងភាពត្រេកត្រអាលលើលោកិយ ដោយគ្មានការភ្ញាក់រឭកចំពោះគតិបណ្ឌិតរបស់ព្រះជាម្ចាស់នៃការមានវត្តមានរបស់គេ(នៅលើលោកិយ)នេះទេនោះ គឺគេនឹងក្លាយជាម៉ាខ្លូកមួយដែលគ្មានលក្ខណៈល្អប្រសើរជាងម៉ាខ្លូកដទៃទៀតលើភពផែនដីនេះឡើយ។ សត្វពាហនៈស៊ីចំណី ផឹកទឹក ហើយមិនខ្វល់ខ្វាយនឹងអ្វីឡើយ ដោយសារពួកវាពុំត្រូវគេនាំមកជំនុំជម្រះ(កាត់សេចក្ដី)នៅថ្ងៃបរលោកឡើយ ខុសពីមនុស្សលោកដែលពួកគេត្រូវគេជំនុំជម្រះ(កាត់សេចក្ដី)។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “រីឯពួកដែលប្រឆាំងវិញ ពួកគេសោយសុខ(នៅក្នុងលោកិយ) និងស៊ីចុកដូចជាសត្វពាហនៈស៊ីដូច្នោះដែរ។ ហើយនរកគឺជាកន្លែងជ្រកកោនសម្រាប់ពួកគេ”។ (គម្ពីរគួរអាន ៤៧:១២) មនុស្សលោកប្រព្រឹត្តដូចសត្វពាហនៈទាំងសកម្មភាព និងទំនើងចិត្ត ក៏ប៉ុន្តែពួកគេ(មនុស្សលោក) នឹងទទួលការតបស្នងវិញរាល់អ្វីដែលពួកគេបានសាង ពីព្រោះពួកគេមានសតិបញ្ញាយល់ដឹងខុសត្រូវ សខ្មៅ ខុសពីសត្វពាហនៈដែលគ្មានសតិបញ្ញា យល់ដឹងខុសត្រូវ សខ្មៅអ្វីឡើយ។

### គោលគ្រឹះនៃការគោរពសក្ការៈ

ពិតណាស់ ការគោរពសក្ការៈដែលអល់ឡោះទ្រង់បង្គាប់នោះ ផ្អែកលើគោលការណ៍សំខាន់ៗពីរ៖

ទីមួយៈ ការបន្ទាបខ្លួន និងកោតខ្លាចដ៏ពេញលេញ

ទីពីរៈ ការស្រលាញ់ និងពេញចិត្ត

ការគោរពសក្ការៈដែលអល់ឡោះដាក់កាតព្វកិច្ចលើខ្ញុំរបស់ទ្រង់ត្រូវតែបន្ទាបខ្លួន ប្រណិប័តន៍ និងកោតខ្លាចដ៏ពេញលេញចំពោះទ្រង់ ជាមួយនឹងសេចក្ដីស្រឡាញ់ពេញចិត្ត ប្រាថ្នា ចូលចិត្ត និងសេចក្ដីសង្ឃឹមដ៏ខ្ពង់ខ្ពស់បំផុតចំពោះទ្រង់។

យោងតាមការបកស្រាយខាងលើបញ្ជាក់ថា សេចក្ដីស្រឡាញ់ចូលចិត្តដែលគ្មានការកោតខ្លាច និងបន្ទាបខ្លួនទេនោះ ដូចជាការស្រឡាញ់ចូលចិត្តចំណីអាហារ ទ្រព្យសម្បត្តិ ពុំមែនជាការគោរពសក្ការៈនោះទេ។ ក៏ដូចគ្នានោះដែរ ការកោតខ្លាច



> លក្ខខណ្ឌលើភាពត្រឹមត្រូវនៃការគោរពសក្ការៈ គឺត្រូវមានចិត្តបរិសុទ្ធ ជ្រះថ្លាចំពោះអល់ឡោះ និងធ្វើតាមអ្នកនាំសាររបស់ទ្រង់ក្នុងការគោរពសក្ការៈនោះ

ដោយគ្មានការស្រឡាញ់ចូលចិត្ត ដូចជា សេចក្ដីភ័យខ្លាចពីសត្វសាហាវ និងអ្នកកាន់អំណាចរំលោភបំពាន គេមិនបានចាត់ទុកជាការគោរពសក្ការៈនោះទេ។ កាលណាការកោតខ្លាច និងការស្រឡាញ់ពេញចិត្តកើតឡើងព្រមគ្នាក្នុងការប្រតិបត្តិអ្វីមួយនោះ ពិតណាស់ការប្រតិបត្តិនោះក្លាយជាការគោរពសក្ការៈ។ ការគោរពសក្ការៈគឺសម្រាប់អល់ឡោះតែមួយគត់គ្មានអ្នកណាផ្សេងក្រៅពីទ្រង់ឡើយ។

## លក្ខខណ្ឌនៃការគោរពសក្ការៈ

ដើម្បីឲ្យការគោរពសក្ការៈមានភាពត្រឹមត្រូវ និងគេទទួលយកនោះ ត្រូវមានពីរលក្ខខណ្ឌ៖

**1**

លក្ខខណ្ឌទី១:
ការគោរពសក្ការៈដោយស្មោះសជូនចំពោះអល់ឡោះតែមួយគត់ ដោយគ្មានការគោរពសក្ការៈចំពោះអ្នកផ្សេងរួមជាមួយទ្រង់ឡើយ។

**2**

លក្ខខណ្ឌទី២:
កាគោរពសក្ការៈនោះត្រឹមត្រូវតាមមាគ៌ាអ្នកនាំសាររបស់ទ្រង់។

អល់ឡោះទ្រង់មានបន្ទូលថា: “ការពិតមិនមែនដូច្នោះទេ (អ្នកដែលបានចូលឋានសួគ៌នោះ) គឺអ្នកដែលបានប្រគល់ខ្លួនប្រាណរបស់គេចំពោះអល់ឡោះដោយប្រតិបត្តិកុសលធម៌។ ដូច្នេះ សម្រាប់អ្នកនោះនឹងទទួលបានផលបុណ្យពីម្ចាស់របស់គេ ហើយពួកគេគ្មានការភ័យខ្លាច និងព្រួយបារម្ភអ្វីឡើយ”។ (គម្ពីរគួរអាន ២:១១២)។

ឃ្លា “ប្រគល់ខ្លួនប្រាណរបស់គេចំពោះអល់ឡោះ” ន័យរបស់វាគឺសម្រេចបាននូវជំនឿឯកទេពនិយម(ជំនឿលើអល់ឡោះតែមួយគត់) ដោយការគោរពសក្ការៈរបស់គេស្មោះសជូនចំពោះអល់ឡោះ។ ឃ្លា “ដោយប្រតិបត្តិកុសលធម៌” ន័យរបស់វាគឺប្រតិបត្តិតាមច្បាប់អល់ឡោះ និងមាគ៌ាអ្នកនាំសាររបស់ទ្រង់។

ការប្រតិបត្តិតាមមាគ៌ាអ្នកនាំសារគឺសម្រាប់តែការគោរពសក្ការៈតែប៉ុណ្ណោះដូចជាសឡាត (ការថ្វាយបង្គំ) ការកាន់អំណត់បួស ការហ្ស៊ីកៀរ(រំលឹក)ចំពោះអល់ឡោះ ។ល។ រីឯអ្វីដែលនៅក្រៅរង្វង់នៃការគោរពសក្ការៈដូចជា ទំនៀមទម្លាប់ និងសកម្មភាពដែលបុគ្គលនៀត(តាំងចិត្ត)ចង់បានផលបុណ្យពីអល់ឡោះ ដូចជាការធ្វើលំហាត់ប្រាណដោយនៀត(តាំងចិត្ត)ចង់ឲ្យរាងកាយរឹងមាំដើម្បីប្រតិបត្តិតាមអល់ឡោះ ការប្រកបអាជីពជំនួញ(ដែលត្រឹមត្រូវ)ដើម្បីយកកម្រៃចិញ្ចឹមគ្រួសារ និងកូនចៅ គេមិនទាមទារឲ្យតាមមាគ៌ាអ្នកនាំសារនោះទេ តែគេក៏មិនអនុញ្ញាតឲ្យប្រព្រឹត្តបទល្មើសនឹងបម្រាម(ក្នុងសាសនា)ដែរ។



## > ស៊ីរិក(ពហុទេពនិយម)

- ពហុទេពនិយម គឺផ្ទុយពីជំនឿភាពជាព្រះតែមួយគត់របស់អល់ឡោះ(ឯកទេពនិយម)។ បើសិនជាជំនឿលើភាពជាព្រះតែមួយរបស់អល់ឡោះ និងការគោរពសក្ការៈចំពោះទ្រង់តែមួយគត់ជាកាតព្វកិច្ចដ៏សំខាន់ និងធំចម្បងជាទីបំផុតនោះ ដូច្នេះ ពហុទេពនិយមចំពោះអល់ឡោះក៏ជាបទល្មើសដ៏ធំធេងបំផុតដែរ។ វាគឺជាបាបកម្មតែមួយគត់ដែលទ្រង់មិនលើកលែងទោសជាដាច់ខាត លុះត្រាតែរូបគេតាវហ្ពាត់(សារភាពកំហុស)ចំពោះទ្រង់។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ពិតណាស់ អល់ឡោះមិនអភ័យទោសឲ្យអ្នកដែលធ្វើពហុទេពនិយមចំពោះទ្រង់នោះឡើយ តែទ្រង់នឹងអភ័យទោសឲ្យចំពោះបាបកម្មផ្សេងពីនោះសម្រាប់ជនណាដែលទ្រង់មានចេតនា”។ (គម្ពីរគួរអាន ៤:៤៨) នៅពេលគេសួរអ្នកនាំសារអំពីបាបកម្មអ្វីដែលធំជាងគេចំពោះអល់ឡោះ? គាត់ឆ្លើយថាៈ “នោះគឺការដែលអ្នកធ្វើស្ហ៊ីរិក(ពហុទេពនិយម)ចំពោះអល់ឡោះ ទាំងដែលទ្រង់ជាអ្នកបង្កើតអ្នក”។ (អាល់ពូខរីៈ៤២០៧ និងមូស្លីមៈ៨៦)។

- ពហុទេពនិយមធ្វើឲ្យអំពើល្អទាំងឡាយបាត់បង់រលាយសាបសូន្យ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ប្រសិនបើពួកគេ(បណ្ដាព្យាការី)បានធ្វើពហុទេពនិយមនោះ អ្វីដែលពួកគេធ្លាប់បានសាងពិតជាបាត់បង់ពីពួកគេជាមិនខាន”។ (គម្ពីរគួរអាន ៦:៨៨)។

  អ្នកដែលប្រព្រឹត្តពហុទេពនិយមត្រូវតែចូលក្នុងនរកដើម្បីហាន់ណាំជារៀងរហូត។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ពិតណាស់ ជនណាហើយដែលធ្វើស្ហ៊ីរិក(ពហុទេពនិយម)ចំពោះអល់ឡោះនោះ អល់ឡោះពិតជាបានហាមឃាត់រូបគេពីឋានសួគ៌ ហើយកន្លែងស្នាក់នៅរបស់គេគឺឋាននរក”។ (គម្ពីរគួរអាន ៥:៧២)។

### ពហុទេពនិយមមានពីរប្រភេទៈ គឺពហុទេពនិយមកម្រិតធ្ងន់ ឬស្ហ៊ីរិកធំ និងពហុទេពនិយមកម្រិតស្រាល ឬស្ហ៊ីរិកតូច

1 ពហុទេពនិយមកម្រិតធ្ងន់ គឺខ្ញុំ(របស់អល់ឡោះ)ធ្វើការគោរពសក្ការៈណាមួយចំពោះអ្នកផ្សេងក្រៅពីអល់ឡោះមិនថាតាមរយៈពាក្យសំដី និងទង្វើទាំងឡាយណាដែលអល់ឡោះទ្រង់សព្វព្រះទ័យ។ ហើយការគោរពសក្ការៈចំពោះទ្រង់តែមួយគត់នោះ គឺជាការមានជំនឿចំពោះឯកទេពនិយម(ភាពជាព្រះជាម្ចាស់តែមួយរបស់ទ្រង់) ហើយការគោរពសក្ការៈចំពោះអ្នកផ្សេងក្រៅពីទ្រង់នោះ គឺជាពហុទេពនិយមកម្រិតធ្ងន់ចេញពីសាសនា(ឥស្លាម)។

ពហុទេពនិយមកម្រិតធ្ងន់មានដូចជា ការបួងសួងសុំទៅកាន់អ្នកផ្សេងក្រៅពីអល់ឡោះ ការសុំទៅកាន់អ្នកផ្សេងក្រៅពីទ្រង់ឲ្យជាសះស្បើយពីជំងឺ ឲ្យទទួលបានលាភសក្ការៈសម្បូរហូរហៀរ ការជឿទុកចិត្ត ឬស៊ូជោត(ក្រាបគោរព)ចំពោះអ្នកផ្សេងក្រៅពីទ្រង់ ។ល។

អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ហើយម្ចាស់របស់អ្នកបានមានបន្ទូលថា ចូរពួកអ្នកបួងសួងសុំចំពោះយើងចុះ យើងនឹងទទួលយកការបួងសួងសុំរបស់ពួកអ្នក”។ (គម្ពីរគួរអាន ៤០:៦០)

អល់ឡោះទ្រង់មានបន្ទូលទៀតថាៈ “ហើយចូរពួកអ្នកប្រគល់ការទុកចិត្តចំពោះអល់ឡោះចុះ ប្រសិនបើពួកអ្នកជាអ្នកមានជំនឿ”។ (គម្ពីរគួអាន ៥:២៣)។

អល់ឡោះទ្រង់ក៏បានមានបន្ទូលដែរថាៈ “ដូច្នេះ ចូរពួកអ្នកស៊ូជោត(ក្រាបគោរព) និងគោរពសក្ការៈចំពោះអល់ឡោះចុះ”។ (គម្ពីរគួរអាន ៥៣:៦២)។

ដូច្នេះ អ្នកណាថ្វាយការគោរពសក្ការៈចំពោះអ្នកផ្សេងក្រៅពីអល់ឡោះ គឺគេជាអ្នកធ្វើពហុទេពនិយមកម្រិតធ្ងន់ ចេញពីសាសនា(ឥស្លាម)។

2 ពហុទេពនិយមកំរិតស្រាល គឺរាល់ពាក្យសំដី ឬទង្វើដែលជាមធ្យោបាយ និងជាផ្លូវនាំឲ្យធ្លាក់ទៅក្នុងពហុទេពនិយមកំរិតធ្ងន់។

ឧទាហរណ៍: ទង្វើដែលចង់បង្ហាញឲ្យគេឃើញ ដូចជាបុគ្គលម្នាក់ជួនកាលគេសឡាត(ថ្វាយបង្គំ)ប្រើរយៈពេលយូរដើម្បីចង់បង្ហាញឲ្យមនុស្សឃើញ ឬជួនកាលគេបន្លឺសម្លេងសូត្រគម្ពីរគួរអាន ឬហ្សីកៀរ(រំលឹកចំពោះអល់ឡោះ) ដើម្បីចង់ឲ្យមនុស្សឮ និងកោតសរសើរគេ(ធ្វើដោយមិនស្មោះត្រង់)។ អ្នកនាំសារមានប្រសាសន៍ថា: “អ្វីដែលខ្ញុំបារម្ភជាងគេទៅលើពួកអ្នកនោះគឺពហុទេពនិយមកម្រិតស្រាល។ពួកគេសួរថា: ឱអ្នកនាំសារអ្វីជាពហុទេពនិយមកំរិតស្រាលនោះ គាត់ឆ្លើយថា: ការចង់បង្ហាញឲ្យគេឃើញ(នូវទង្វើ)របស់ខ្លួន”។ (អ៊ីម៉ាំអះម៉ាត់:២៣៦៣០)។.

តែប្រសិនបើជនណាម្នាក់គ្មានចេតនាគោរពសក្ការៈចំពោះព្រះក្រៅពីដើម្បី(បង្ហាញ)មនុស្សលោក(ចង់ឲ្យគេឃើញ) ដូចជាគេសឡាត ឬកាន់អំណត់បួសដើម្បី(បង្ហាញ)មនុស្សលោកពិតណាស់ទង្វើនោះគឺជាទង្វើរបស់ពួកមូណាហ្វិក (ពុតត្បុត) ហើយវាគឺជាពហុទេពនិយមកម្រិតធ្ងន់ចេញពីសាសនាឥស្លាម។

## តើការស្នើសុំចំពោះមនុស្សលោកជាពហុទេពនិយមដែរឬទេ?

សាសនាឥស្លាមបានរំដោះមនុស្សឲ្យមានសិទ្ធិសេរីភាពពីអបិយជំនឿ និងជំនឿអូមអាម ហើយរំដោះខ្លួនគេអំពីការគោរពប្រណិប័តន៍អ្នកផ្សេងក្រៅពីអល់ឡោះ។

ដូច្នេះ មិនអនុញ្ញាតឡើយ ការសុំ ការគោរពប្រណិប័តន៍ និងការបន្ទាបខ្លួនចំពោះសាកសព ឬការៈគ្មានជីវិតជាដាច់ខាត ហើយវាគឺជាអបិយជំនឿ និងជាពហុទេពនិយម។

រីឯការសុំពីអ្នកនៅរស់ និងមានវត្តមាននូវអ្វីដែលគេមានលទ្ធភាព ដូចជាសុំជំនួយ ឬការសង្គ្រោះពីការលង់ទឹក ឬការស្នើសុំអ្នកផ្សេងឲ្យសុំពីអល់ឡោះ(នូវតម្រូវការរបស់គេ)នោះ វាត្រូវបានគេអនុញ្ញាត។



>ការស្នើសុំពីមនុស្សដែលនៅរស់ចំពោះអ្វីដែលគេមានលទ្ធភាពគឺជាប្រភេទមួយនៃទំនាក់ទំនងជាមួយមនុស្សនិងការសេពគប់រវាងពួកគេប្រចាំថ្ងៃដែលត្រូវបានអនុញ្ញាត

តើអាចស្នើសុំពីភាវៈគ្មានជីវិត ឬអ្នកដែលបានស្លាប់បានដែរឬទេ ?

បាទ

នេះគឺជាពហុទេពនិយម( កម្រិតធ្ងន់ )ផ្ទុយពីសាសនាឥស្លាម
និងជំនឿ( ដ៏ត្រឹមត្រូវ ) ពីព្រោះអ្នកដែលស្លាប់ និងភាវៈគ្មានជីវិត
គ្មានសមត្ថភាពស្តាប់ឮ និងផ្តល់តាមការសុំរបស់គេឡើយ ។
ការបួងសួងសុំ គឺជាការគោរពសក្ការៈ ហើយការថ្វាយ ការគោរព
សក្ការៈចំពោះអ្នកណាផ្សេងក្រៅពីអល់ឡោះគឺជាពហុទេពនិយម ។
អំពើពហុទេពនិយមរបស់ជនជាតិអារ៉ាប់នៅសម័យអ្នកនាំសារគឺ ការ
សុំរបស់ពួកគេចំពោះភាវៈគ្មានជីវិត និងអ្នកដែលបានស្លាប់ទៅហើយ ។

ទេ

ការស្នើសុំពីអ្នកនៅរស់ដែលស្តាប់លឺពាក្យសំដី និងការស្នើរបស់អ្នក ។
តើគេមានសមត្ថភាពអាចឆ្លើយតបនឹងការស្នើសុំរបស់អ្នកដែរឬទេ ? ដូចជា ស្នើសុំពីគេឲ្យ
ជួយអ្នកនូវអ្វីៗដែលគេមាន និងមានសមត្ថភាព ?

បាទ

គឺជាការស្នើសុំធម្មតាដែលគេអនុញ្ញាត គ្មានបញ្ហាអ្វីឡើយ
វាគឺជាផ្នែកមួយអំពីការទំនាក់ទំនងរវាងមនុស្សលោកប្រចាំថ្ងៃ ។

ទេ

ពិតប្រាកដការស្នើសុំពីអ្នកនៅរស់នូវអ្វីដែលគេគ្មានសមត្ថភាព ហើយពុំមែនជា
កម្មសិទ្ធិរបស់គេដូចជា អ្នកដែលគ្មានកូនសុំពីអ្នកនៅរស់ឱ្យផ្តល់កូនចៅល្អដល់គេ
ការធ្វើដូច្នេះគឺជាពហុទេពនិយមកម្រិតធ្ងន់ ផ្ទុយពីសាសនាឥស្លាម
ពីព្រោះវាគឺជាការសុំពីអ្នកផ្សេងក្រៅពីអល់ឡោះ ។

## > ជំនឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់អល់ឡោះ

គឺជាជំនឿចំពោះអ្វីៗដែលអល់ឡោះបានបញ្ជាក់អំពីទ្រង់ដោយព្រះអង្គផ្ទាល់ក្នុងគម្ពីររបស់ទ្រង់ ឬមាគ៌ារបស់អ្នកនាំសារ នៃព្រះនាម និងលក្ខណៈសម្បត្តិទាំងឡាយដែលសក្តិសមនឹងទ្រង់។

សម្រាប់អល់ឡោះ គឺមានព្រះនាម និងលក្ខណៈសម្បត្តិដ៏ល្អប្រពៃ និងពេញលក្ខណៈ គ្មានអ្នកណាដូចទ្រង់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ "គ្មានអ្វីប្រដូចនឹងទ្រង់ឡើយ។ ហើយទ្រង់មហាឮ មហាឃើញ"។ (គម្ពីរគួរអាន ៤២ៈ ១១)។ អល់ឡោះទ្រង់ស្អាតស្អំពីការប្រដូចព្រះនាម និងលក្ខណៈសម្បត្តិទាំងឡាយរបស់ទ្រង់ នឹងអ្នកណាម្នាក់នៃម៉ាខ្លូករបស់ទ្រង់។

### អំពីព្រះនាមខ្លះៗរបស់អល់ឡោះ

អល់ឡោះបានមានបន្ទូលថា: "ទ្រង់ជាម្ចាស់មហាសប្បុរស មហាអាណិតស្រឡាញ់"។ ( គម្ពីរគួរអាន ១ៈ ៣)។

អល់ឡោះបានមានបន្ទូលថា: "ហើយទ្រង់មហាឮ មហាឃើញ"។ (គម្ពីរគួរអាន ៤២:១១)។

អល់ឡោះបានមានបន្ទូលទៀតថា: "ហើយទ្រង់មហាខ្លាំងពូកែមហាគតិបណ្ឌិត"។ (គម្ពីគួរអាន ៣១ៈ ៩)។

អល់ឡោះក៏បានមានបន្ទូលដែរថា: "អល់ឡោះតែមួយគត់ គ្មានម្ចាស់ណាដែលត្រូវគេគោរពសក្ការៈ ដ៏ពិតប្រាកដផ្សេងពីទ្រង់ ដែលមានជីវិតអមតៈគ្រប់គ្រងលើអ្វីគ្រប់យ៉ាងឡើយ"។ (គម្ពីរគួរអាន ២:២៥៥)។

អល់ឡោះបានមានបន្ទូលថា: "ការសរសើរ គឺសម្រាប់អល់ឡោះដែលជាម្ចាស់នៃសកលលោកទាំងមូល "។ (គម្ពីរគួរអាន ១ៈ ២)



## ផលប្រយោជន៍នៃជំនឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់អល់ឡោះ

1 ស្គាល់អល់ឡោះ៖ ជនណាជឿចំពោះព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់ ធ្វើឲ្យគេស្គាល់ទ្រង់កាន់តែច្បាស់ ជំនឿរបស់គេចំពោះទ្រង់ក៏កាន់តែខ្លាំង ជំនឿឯកទេពរបស់គេចំពោះទ្រង់កាន់តែរឹងមាំ ជាការពិតសម្រាប់អ្នកដែលស្គាល់ព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់ ចិត្តគំនិតរបស់គេពោរពេញដោយការលើកតម្កើង ការស្រឡាញ់ និងប្រណិប័តន៍ចំពោះទ្រង់។

2 ការកោតសរសើរស្ញប់ស្ញែងចំពោះអល់ឡោះ ដោយព្រះនាមដ៏ល្អប្រសើរជាទីបំផុតរបស់ទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ឱបណ្ដាអ្នកដែលមានជំនឿ! ចូរពួកអ្នករំឭកចំពោះអល់ឡោះឲ្យបានច្រើន”។ (គម្ពីរគួរអាន ៣៣:៤១)។

3 ការសុំទូអាចំពោះអល់ឡោះដោយព្រះនាម និងលក្ខណៈសម្បត្តិរបស់ទ្រង់។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយបណ្ដាព្រះនាមដ៏ល្អប្រពៃជាកម្មសិទ្ធិរបស់អល់ឡោះ។ ដូច្នេះចូរពួកអ្នកបួងសួងសុំទ្រង់តាមរយៈព្រះនាមទាំងនោះចុះ”។ (គម្ពីរគួរអាន ៧:១៨០) ឧទាហរណ៍ដូចជាគេពោលថាៈ ឱព្រះមហាប្រទានលាភសក្ការៈ! សូមទ្រង់ប្រទានលាភសក្ការៈចំពោះខ្ញុំផង។ ឱព្រះមហាទទួលយកការសារភាពកំហុស! សូមទ្រង់ទទួលយកការសារភាពកំហុសរបស់ខ្ញុំផងចុះ។ ឱព្រះមហាអាណិតស្រឡាញ់! សូមទ្រង់អាណិតស្រឡាញ់ចំពោះខ្ញុំផងចុះ។

## លំដាប់ខ្ពស់បំផុតនៃជំនឿ

ជំនឿ គឺមានលំដាប់ថ្នាក់របស់វា។ ជំនឿរបស់អ្នកឥស្លាម មានការថយចុះតាមការព្រងើយ និងបទល្មើសរបស់គេ ហើយជំនឿរបស់គេកើនឡើងនៅរាល់ពេលដែលការប្រតិបត្តិ ការគោរពសក្ការៈ និងការកោតខ្លាចចំពោះអល់ឡោះ។

ហើយកម្រិតខ្ពស់បំផុតនៃជំនឿគឺអ្វីដែលច្បាប់បានឲ្យឈ្មោះថាៈ”អាល់អៀហសាន"។ ព្យាការីមូហាំម៉ាត់បានឲ្យនិយមន័យរបស់វាថាៈ “អ្នកត្រូវគោរពសក្ការៈចំពោះអល់ឡោះដូចអ្នកឃើញទ្រង់។ ប្រសិនបើអ្នកមិនបានឃើញទ្រង់ តែប្រាកដណាស់ទ្រង់ពិតជាឃើញអ្នក”។ (អាល់ពូខរីៈ៥០/ មូស្លីមៈ៨)។

អ្នកត្រូវនឹកឃើញថា រាល់ពេលអ្នកឈរ អង្គុយ ពេលអ្នកម៉ឹងម៉ាត់ ម៉ត់ចត់ ពេលអ្នកលេងសើច និងរាល់ស្ថានភាពរបស់អ្នកទាំងអស់ អល់ឡោះពិតជាដឹង និងឃើញអ្នក។ ដូច្នេះ ចូរអ្នកកុំល្មើសចំពោះទ្រង់ឲ្យសោះ អ្នកត្រូវដឹងថាទ្រង់ឃើញអ្នកជានិច្ច។ ចូរអ្នកកុំឲ្យសេចក្ដីភ័យខ្លាច អស់សង្ឃឹមគ្រប់គ្រងអ្នកឲ្យសោះ។ អ្នកត្រូវដឹងថាព្រះទ្រង់នៅជាមួយអ្នកជានិច្ច។ តើអ្នកអាចមានអារម្មណ៍ឯកោបានយ៉ាងដូចម្ដេចទៅ បើអ្នកបួងសួងសុំ និងសឡាត (ថ្វាយបង្គំ) ចំពោះទ្រង់គ្រប់ពេលនោះ? តើអ្នកឱ្យចិត្តរបស់អ្នកអូសទាញអ្នកឱ្យប្រព្រឹត្តបទល្មើសចំពោះទ្រង់ដូចម្ដេចទៅ បើអ្នកជឿជាក់ច្បាស់ថាទ្រង់ដឹងទាំងរឿងអាថ៌កំបាំង និងរឿងលាតត្រដាងរបស់អ្នកនោះ? ប្រសិនបើអ្នកភ្លាត់ ឬច្រឡំធ្វើខុសដោយអចេតនា អ្នកត្រូវត្រឡប់ទៅចំពោះទ្រង់ដោយការសារភាពកំហុស និងសុំអភ័យទោសពីទ្រង់ នោះទ្រង់នឹងទទួលយកការសារភាពកំហុស និងការសុំអភ័យទោសរបស់អ្នក។





## ក្នុងចំណោមផលប្រយោជន៍នៃជំនឿចំពោះអល់ឡោះ

1 ជាការពិតណាស់ អល់ឡោះការពារអ្នកដែលមានជំនឿ(ចំពោះអល់ឡោះ)ពីរាល់ប្រការដែលគេមិនពេញចិត្ត ទ្រង់ឲ្យគេជៀសផុតអំពីគ្រោះលំបាក ហើយទ្រង់ថែរក្សាគេពីឧបាយកលសត្រូវ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ប្រាកដណាស់ អល់ឡោះនឹងការពារបណ្តាអ្នកដែលមានជំនឿ(ពីឧបាយកលរបស់ពួកដែលគ្មានជំនឿ)”។ (គម្ពីរគួរអាន ២២:៣៨)។

2 ពិតប្រាកដជំនឿ(ចំពោះអល់ឡោះ)ជាហេតុនាំឲ្យជីវិតដ៏ល្អប្រសើរ មានសេចក្តីសុខ និងភាពសប្បាយរីករាយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “អ្នកណាដែលបានសាងអំពើល្អក្នុងចំណោមបុរសឬស្ត្រី ហើយគេជាអ្នកមានជំនឿទៀតនោះគឺយើងពិតជានឹងធ្វើឲ្យគេមានជីវិតរស់នៅដ៏ល្អប្រសើរ”។ (គម្ពីរគួរអាន ១៦:៩៧)។

3 ជំនឿ(ចំពោះអល់ឡោះ)ធ្វើឲ្យជីវិតជ្រះស្អាតពីជំនឿមិនត្រឹមត្រូវ។ជនណាមានជំនឿចំពោះអល់ឡោះ ពិតប្រាកដណាស់ គេពិតជាពឹងអាស្រ័យកិច្ចការរបស់គេទៅលើទ្រង់តែមួយគត់។ ទ្រង់ជាម្ចាស់នៃសាកលលោកទាំងមូល ទ្រង់ជាព្រះពិតគ្មានព្រះផ្សេងឡើយ។ ដូច្នេះគេមិនត្រូវខ្លាចម៉ាខ្លូកណាឡើយ គេមិនត្រូវពឹងលើមនុស្សលោកណាម្នាក់ឡើយ។បន្ទាប់មកគេរំដោះខ្លួនឱ្យរួចផុតពីអបិយជំនឿ និងជំនឿផ្តេសផ្តាស។

4 ឥទ្ធិពលដ៏ធំធេងនៃជំនឿ(ចំពោះអល់ឡោះ) គឺទទួលបានការយល់ព្រមពីទ្រង់ឲ្យចូលឋានសួគ៌ ដោយភាពជោគជ័យ និងបានពរជ័យជារៀងរហូត ព្រមទាំងទទួលបានក្តីអាណិតស្រឡាញ់ដ៏ពេញលេញអំពីទ្រង់។

## > ជំនឿចំពោះម៉ាឡាអ៊ីកាត់(ពួកទេវតា)

### អត្ថន័យនៃជំនឿចំពោះម៉ាឡាអ៊ីកាត់(ពួកទេវតា)

គឺជាការជឿជាក់យ៉ាងដាច់ខាតថា មានម៉ាឡាអ៊ីកាត់(ពួកទេវតា) ហើយពួកគេគឺជាម៉ាខ្លូកមួយអាថ៌កំបាំង។ ពួកគេពុំមែនជាម៉ាខ្លូកប្រភេទមនុស្ស និងជិន(អមនុស្ស)ទេ។ ពួកគេមានភាពឧត្តុង្គឧត្តមកោតខ្លាច គោរពសក្ការៈចំពោះអល់ឡោះដ៏ពិតប្រាកដ ពួកគេអនុវត្តតាមបទបញ្ជារបស់ទ្រង់ជានិច្ចដោយមិនល្មើសនឹងទ្រង់ឡើយ។

អល់ឡោះទ្រង់មានបន្ទូលថាៈ "ផ្ទុយទៅវិញពួកគេ(ម៉ាឡាអ៊ីកាត់)គឺជាខ្ញុំរបស់អល់ឡោះដែលត្រូវគេលើកតម្កើង។ ពួកគេមិនហ៊ានផ្ដើមសម្ដីមុនទ្រង់ឡើយ ហើយពួកគេប្រតិបត្តិតាមការបញ្ជារបស់ទ្រង់"។ (គម្ពីរគួរអាន ២១:២៦-២៧)។

ជំនឿចំពោះម៉ាឡាអ៊ីកាត់(ពួកទេវតា)គឺជាគោលគ្រឹះមួយក្នុងចំណោមគោលគ្រឹះជំនឿទាំងប្រាំមួយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ "អ្នកនាំសារ(ព្យាការីមូហាំម៉ាត់)មានជំនឿលើអ្វីៗដែលម្ចាស់របស់គេបានបញ្ចុះមកឲ្យគេ ហើយបណ្ដាអ្នកមានជំនឿក៏ដូចគ្នាដែរ។ ពួកគេទាំងអស់មានជំនឿលើអល់ឡោះ និងបណ្ដាម៉ាឡាអ៊ីកាត់របស់ទ្រង់ និងបណ្ដាគម្ពីររបស់ទ្រង់ ហើយនិងបណ្ដាអ្នកនាំសាររបស់ទ្រង់"។ (គម្ពីរគួរអាន ២:២៨៥)។ អ្នកនាំសារមានប្រសាសន៍ថាៈ "អ្នកត្រូវជឿចំពោះអល់ឡោះ ម៉ាឡាអ៊ីកាត់(ពួកទេវតា) គម្ពីរៗបណ្ដាអ្នកនាំសាររបស់ទ្រង់ ថ្ងៃបរលោក ហើយអ្នកត្រូវជឿចំពោះព្រះលិខិតល្អ និងអាក្រក់"។ (មូស្លីមៈ៨)។

### ជំនឿចំពោះម៉ាឡាអ៊ីកាត់(ពួកទេវតា)មានអ្វីខ្លះ?

1. ជឿថាពួកគេមាន។ ដូច្នេះត្រូវជឿថា ពួកគេជាម៉ាខ្លូករបស់អល់ឡោះដែលមានយ៉ាងពិតប្រាកដ។ ទ្រង់បង្កើតពួកគេពីពន្លឺ។ ទ្រង់ធ្វើឲ្យពួកគេគោរពសក្ការៈ និងប្រតិបត្តិតាមទ្រង់។
2. ជឿចំពោះឈ្មោះរបស់ពួកគេដែលយើងបានស្គាល់ដូចជាៈ ជីព្រីល និងជឿជាលក្ខណៈរួមចំពោះឈ្មោះណាដែលយើងមិនបានស្គាល់។
3. ជឿនូវអ្វីៗដែលយើងបានដឹងនៃលក្ខណៈសម្បត្តិរបស់ពួកគេដូចជា៖

• ពួកគេឋិតនៅក្នុងពិភពអាថ៌កំបាំង តួនាទីពួកគេគឺគោរពសក្ការៈចំពោះអល់ឡោះ។ ពួកគេគ្មានលក្ខណៈសម្បត្តិជាព្រះ ឬម្ចាស់នោះទេ។ ផ្ទុយទៅវិញ ពួកគេគឺជាខ្ញុំរបស់អល់ឡោះ ប្រតិបត្តិតាមទ្រង់យ៉ាងខ្ជាប់ខ្ជួន។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ពួកគេមិនជំទាស់នឹងអល់ឡោះនូវអ្វីដែលទ្រង់បានបញ្ជាដល់ពួកគេទេ ហើយពួកគេធ្វើនូវអ្វីដែលអល់ឡោះបញ្ជា"។ (គម្ពីរគួរអាន៦៦:៦)។

• ប្រាកដណាស់ព្រះបង្កើតពួកគេពីពន្លឺ។ អ្នកនាំសារមូហាំម៉ាត់លោកបានមានប្រសាសន៍ថាៈ "គេបានបង្កើតម៉ាឡាអ៊ីកាត់(ពួកទេវតា)ពីពន្លឺ"។ (មូស្លីមៈ២៩៩៦)

• ពួកគេមានស្លាប។ ពិតណាស់ អល់ឡោះបានប្រាប់ថាទ្រង់បានបង្កើតពួកគេមានចំនួនស្លាបខុសៗគ្នា។ អល់ឡោះទ្រង់មានបន្ទូលថាៈ "រាល់ការសរសើរគឺសម្រាប់អល់ឡោះដែលជាអ្នកបង្កើតមេឃជាច្រើនជាន់និងផែនដី ដែលជាអ្នកបង្កើតម៉ាឡាអ៊ីកាត់ជាអ្នកនាំសារដែលមានស្លាបជាច្រើន មានពីរ មានបី និងមានបួន។ ទ្រង់បន្ថែមក្នុងការបង្កើតនូវអ្វីដែលទ្រង់មានចេតនា។ ប្រាកដណាស់អល់ឡោះមានអានុភាពលើអ្វីៗទាំងអស់"។ (គម្ពីរគួរអាន ៣៥:១)

4 ជឿចំពោះអ្វីដែលយើងបានដឹងពីតួនាទីរបស់ពួកគេ ដែលពួកគេបានអនុវត្តតាមបទបញ្ជារបស់អល់ឡោះដូចជាៈ

- អ្នកដែលមានតួនាទីទទួលវ៉ាហ៊ី(សារ)ពីអល់ឡោះទៅកាន់បណ្ដាអ្នកនាំសារគឺ ជីព្រីល។
- អ្នកដែលមានតួនាទីដកហូតជីវិត គឺម៉ាឡាកុលម៉ោត។
- អ្នកដែលមានតួនាទីថែរក្សានិងកត់ត្រាអំពើល្អ និងអំពើអាក្រក់របស់ខ្ញុំរបស់អល់ឡោះគឺ អាល់គីរ៉ម អាល់កាទីពូន។

## ផលប្រយោជន៍នៃជំនឿចំពោះម៉ាឡាអ៊ីកាត់

ជំនឿចំពោះម៉ាឡាអ៊ីកាត់មានផលប្រយោជន៍ដ៏ធំធេងសម្រាប់ជីវិតអ្នកដែលមានជំនឿ ដូចជាៈ

1 ដឹងពីឧត្ដមភាព មហិទ្ធិឫទ្ធិ និងអានុភាពដ៏អស្ចារ្យរបស់អល់ឡោះ។ ប្រាកដណាស់ ភាពធំធេងរបស់ម៉ាខ្លូកបញ្ជាក់ឲ្យឃើញពីភាពធំធេងរបស់អល់ឡោះដែលធ្វើឲ្យអ្នកមានជំនឿកោតស្ញប់ស្ញែង និងលើកតម្កើងទ្រង់កាន់តែខ្លាំងឡើងថែមទៀត ដោយទ្រង់បានបង្កើតពីពន្លឺនូវម៉ាឡាអ៊ីកាត់ដែលមានស្លាប។

2 ការប្រកាន់ខ្ជាប់នឹងការប្រតិបត្តិតាមអល់ឡោះ។ ជនណាជឿថា ម៉ាឡាអ៊ីកាត់កំពុងកត់ត្រាទង្វើទាំងអស់របស់គេ ដូច្នេះគេចាំបាច់ត្រូវកោតខ្លាចអល់ឡោះ ហើយមិនប្រព្រឹត្តបទល្មើសចំពោះទ្រង់ទាំងការបើកចំហ និងអាថ៌កំបាំង។

3 ការអត់ធ្មត់លើការប្រតិបត្តិតាមអល់ឡោះនិងការមានអារម្មណ៍កក់ក្ដៅ និងស្ងប់ស្ងាត់ នៅពេលអ្នកមានជំនឿដឹងច្បាស់ថា នៅជាមួយគេក្នុងចក្រវាលដ៏ធំធេងនេះមាន ម៉ាឡាអ៊ីកាត់រាប់ពាន់ដែលកំពុងប្រតិបត្តិតាមអល់ឡោះយ៉ាងល្អឥតខ្ចោះ និងពេញលក្ខណៈបំផុត។

4 ការថ្លែងអំណរគុណអល់ឡោះចំពោះការថែរក្សាចំពោះមនុស្សលោក ដោយទ្រង់បាន បង្កើតម៉ាឡាអ៊ីកាត់ជាអ្នកជួយថែរក្សា ការពារពួកគេ។



> អ្នកនាំសាមូហាំម៉ាត់បានប្រាប់ថា មេឃាធ្ងន់ដោយសារអ្នកដែលនៅលើមេឃ។ ពិតណាស់ គ្មានសល់ផ្ទៃមេឃមួយចំអាមណាឡើយ លើកលែងតែមានម៉ាឡាអ៊ីកាត់មួយនៅឈរ ឬអោនរូកុ ឬអោនក្រាបស៊ូជូទ។

# > ជំនឿចំពោះព្រះគម្ពីរ

## អត្ថន័យនៃជំនឿចំពោះព្រះគម្ពីរ

ការជឿជាក់យ៉ាងដាច់ខាតថា អល់ឡោះបានបញ្ចុះព្រះគម្ពីរមកលើបណ្តាអ្នកនាំសាររបស់ទ្រង់ទៅកាន់បណ្តាខ្ញុំរបស់ទ្រង់(មនុស្សលោក)។

ជំនឿចំពោះព្រះគម្ពីរ គឺជាគោលគ្រឹះមួយក្នុងចំណោមគោលគ្រឹះជំនឿ(ទាំងប្រាំមួយ)។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកជឿលើអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់ និង(មានជំនឿចំពោះ)ព្រះគម្ពីរដែលទ្រង់បានបញ្ចុះមកលើអ្នកនាំសាររបស់ទ្រង់ ហើយនិងបណ្តាព្រះគម្ពីរដែលទ្រង់បានបញ្ចុះពីមុនៗមក”។ (គម្ពីរគួរអាន ៤ៈ ១៣៦)

អល់ឡោះទ្រង់បានប្រើឲ្យជឿចំពោះអ្នកនាំសារ និងព្រះគម្ពីរដែលទ្រង់បានបញ្ចុះមកលើអ្នកនាំសាររបស់ទ្រង់ គឺគម្ពីរគួរអាន។ ក៏ដូចគ្នាដែរ ទ្រង់បានប្រើឲ្យជឿចំពោះបណ្តាព្រះគម្ពីរដែលបានបញ្ចុះមុនគម្ពីរគួរអានដែរ។

អ្នកនាំសារមានប្រសាសន៍អំពីជំនឿថាៈ “អ្នកត្រូវជឿចំពោះអល់ឡោះ ម៉ាឡាអ៊ីកាត់(ពួកទេវតា)របស់ទ្រង់ គម្ពីររបស់ទ្រង់ អ្នកនាំសាររបស់ទ្រង់ ថ្ងៃបរលោក និងអ្នកត្រូវជឿចំពោះព្រះលិខិតល្អ និងអាក្រក់”។ (មូស្លីមៈ៨)



>គម្ពីរគួរអានដ៏ថ្លៃថ្លើង ត្រូវបានសរសេរចប់ជាស្ថាពរ ដោយយោងទៅតាមការត្រួតពិនិត្យយ៉ាងល្អិតល្អន់បំផុត និងផ្ទៀងផ្ទាត់យ៉ាងល្អឥតខ្ចោះជាទីបំផុត។

### តើជំនឿចំពោះព្រះគម្ពីរមានអ្វីខ្លះ?

1. ត្រូវជឿថា ការបញ្ចុះព្រះគម្ពីរ គឺមកពីអល់ឡោះយ៉ាងពិតប្រាកដ។
2. ត្រូវជឿថា ព្រះគម្ពីរគឺជាពាក្យបន្ទូលរបស់ព្រះអល់ឡោះ។
3. ត្រូវជឿចំពោះឈ្មោះគម្ពីរដែលទ្រង់បានដាក់ឈ្មោះវាដូចជា គម្ពីរគួរអាន(ដែលទ្រង់បានបញ្ចុះមកលើព្យាការីមូហាំម៉ាត់) គម្ពីរតាវរ៉ត(គម្ពីរតូរ៉ា ដែលត្រូវបានបញ្ចុះមកលើព្យាការីមូសា) និងគម្ពីរអ៊ីនជីល ដែលត្រូវបានបញ្ចុះមកលើព្យាការីអ៊ីសា។
4. ត្រូវជឿចំពោះដំណឹងត្រឹមត្រូវដែលមកពីព្រះគម្ពីរទាំងនោះ។

## លក្ខណៈពិសេសនៃគម្ពីរគួរអាន

ពិតណាស់ គម្ពីរគួរអាន គឺជាពាក្យបន្ទូលរបស់អល់ឡោះដែលបានបញ្ចុះមកលើព្យាការីរបស់យើងមូហាំម៉ាត់ ( សូមពរជ័យនិងសន្តិភាពកើតមានដល់លោក ) ។ ដូច្នេះអ្នកមានជំនឿត្រូវតែលើកតម្កើងគម្ពីរនេះ ហើយខិតខំប្រឹងប្រែងអនុវត្តតាមច្បាប់របស់វា សូត្រវា និងត្រិះរិះពិចារណាចំពោះអត្ថន័យរបស់វា ។

គ្រប់គ្រាន់ហើយសម្រាប់ពួកយើងដែលមានគម្ពីរគួរអានជាត្រីវិស័យរបស់យើងនៅលើលោកិយ និងជាមូលហេតុនៃភាពជោគជ័យរបស់យើងនៅថ្ងៃបរលោក ។

គម្ពីរគួរអានមានលក្ខណៈពិសេសជាងគម្ពីរមុនៗដែលបានបញ្ចុះពីលើមេឃដូចជា៖

1 គម្ពីរគួរអានរួមមានសេចក្ដីសង្ខេបនៃច្បាប់របស់ព្រះជាម្ចាស់ ។ ការបញ្ចុះគម្ពីរគួរអានមកនេះ គឺដើម្បីគាំទ្រ និងបញ្ជាក់ពីសច្ចភាពដែលមាននៅក្នុងគម្ពីរមុនៗនៃបទបញ្ញាឲ្យគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ ។

អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងបានបញ្ចុះគម្ពីរគួរអានឲ្យអ្នកយ៉ាងពិតប្រាកដដើម្បីបញ្ជាក់ពីសច្ចភាពដែលមាននៅក្នុងគម្ពីរមុនៗ និងបញ្ជាក់ពីភាពត្រឹមត្រូវគម្ពីរទាំងនោះ” ។ ( គម្ពីរគួអាន៥:៤៨ )

"បញ្ជាក់ពីសច្ចភាពដែលមាននៅក្នុងគម្ពីរមុនៗ"

អត្ថន័យរបស់វាគឺ ស្របគ្នាជាមួយនឹងអ្វីៗដែលមាននៅក្នុងគម្ពីរមុនៗទាំងគោលជំនឿ និងដំណឹងផ្សេង ។

"បញ្ជាក់ពីភាពត្រឹមត្រូវគម្ពីរទាំងនោះ"

អត្ថន័យរបស់វាគឺ ជាសេចក្ដីទុកចិត្ត និងជាសាក្សីទៅលើគម្ពីរមុនៗ ។

2 ចាំបាច់លើមនុស្សទាំងអស់ដែលមានអម្បូរជនជាតិ និងភាសាផ្សេងៗគ្នាត្រូវតែប្រកាន់ខ្ជាប់ និងប្រតិបត្តិតាមការចង្អុលបង្ហាញរបស់គម្ពីរគួរអាន ទោះបីជាពួកគេកើតនៅសម័យកាលក្រោយការបញ្ចុះគម្ពីរគួរអានក៏ដោយ ។ ខុសពីគម្ពីរមុនៗដែលសម្រាប់តែក្រុមមួយជាក់លាក់ និងសម័យកាលមួយជាក់លាក់ ។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ហើយគម្ពីរគួរអាននេះ គេបានបញ្ចុះមកឲ្យខ្ញុំដើម្បីដាស់តឿនដល់ពួកអ្នក និងអ្នកដែលគម្ពីរគួរអានបានទៅដល់” ។ ( គម្ពីរគួរអាន ៦:១៩ )

3 អល់ឡោះទ្រង់បានធានាថែរក្សាគម្ពីរនេះ ហេតុនេះ គ្មានអ្នកណាអាចកែប្រែ និងផ្លាស់ប្ដូរវាបានឡើយ ។

អល់ឡោះទ្រង់មានបន្ទូលថាៈ “ពិតណាស់ យើងបានបញ្ចុះគម្ពីរគួរអាន ហើយពិតប្រាកដណាស់យើងជាអ្នកថែរក្សាវា” ។ ( គម្ពីរគួរអាន ១៥:៩ )

ដូច្នេះរាល់ដំណឹងរបស់វាទាំងអស់គឺសុទ្ធតែត្រឹមត្រូវ ចាំបាច់ត្រូវតែជឿតាម ។



## អ្វីជាកាតព្វកិច្ចរបស់យើងចំពោះគម្ពីរគួរអានដ៏ប្រពៃនេះ ?

- ចាំបាច់លើយើងត្រូវតែស្រលាញ់ពេញចិត្ត គោរពលើកតម្កើងចំពោះគម្ពីរគួរអាន ព្រោះវាជាពាក្យបន្ទូលរបស់ព្រះជាម្ចាស់ដែលជាពាក្យពិត និងបវរមហាប្រសើរ ។
- ចាំបាច់លើយើងត្រូវតែសូត្រ សិក្សាស្វែងយល់នូវវាក្យខណ្ឌ និងជំពូកទាំងឡាយរបស់វា ដើម្បីត្រិះរិះពិចារណាចំពោះដំបូន្មាន ដំណឹង និងរឿងរ៉ាវជំនាន់មុន ហើយយើងត្រូវយកមកផ្ទះបញ្ចាំងនឹងជីវិតរបស់យើង ដើម្បីឲ្យយើងដឹងច្បាស់រវាងប្រការពិត និងប្រការមិនពិត ។
- ចាំបាច់លើយើងត្រូវតែអនុវត្តតាមច្បាប់ ប្រតិបត្តិតាមបទបញ្ញា និងសីលធម៌ ហើយទុកវាជាមាគ៌ានៃជីវិតរបស់យើង ។

នៅពេលគេសួរអាអ៊ីស្ហះ(ភរិយារបស់ព្យាការី)ពីអត្តចរិតរបស់ព្យាការី គាត់(អាអ៊ីស្ហះ) បានឆ្លើយថាៈ “អត្តចរិតរបស់គាត់(ព្យាការីមូហាំម៉ាត់)គឺ គម្ពីរគួរអាន”។ (អះម៉ាត់ៈ២៤៦០១ និងមូស្លីមៈ៧៤៦)

អត្ថន័យហាទីស្ហខាងលើគឺថា អ្នកនាំសារក្នុងការស់នៅរបស់គាត់ គ្រប់កិច្ចការ គឺជាការអនុវត្តជាក់ស្ដែងសម្រាប់ច្បាប់គម្ពីរគួរអាន។ ព្យាការីមូហាំម៉ាត់បានសម្រេចយ៉ាងពេញលក្ខណៈក្នុងការអនុវត្តតាមការចង្អុលបង្ហាញនៃគម្ពីរគួរអាន ហើយគាត់ជាគំរូដ៏ល្អប្រសើរសម្រាប់យើងគ្រប់ៗគ្នា។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ជាការពិតណាស់ ពួកអ្នកមានអ្នកនាំសាររបស់អល់ឡោះ(ព្យាការីមូហាំម៉ាត់)ជាគំរូដ៏ល្អ សម្រាប់ជនណាដែលសង្ឃឹមថានឹងបានជួបអល់ឡោះនិងថ្ងៃបរលោកហើយនឹងបានរំឭកចំពោះអល់ឡោះយ៉ាងច្រើន”។ (គម្ពីរគួរអាន ៣៣ៈ២១)



## អ្វីជាគោលជំហររបស់យើងចំពោះអ្វីដែលមាននៅក្នុងបណ្តាព្រះគម្ពីរមុនៗ?

អ្នកមូស្លីមជឿថាគម្ពីរតាវ៉ែត(គម្ពីរតូរ៉ា)ដែលគេបានបញ្ចុះមកលើព្យាការីមូសា(ម៉ូសេ) និងគម្ពីរអ៊ីនជីល ដែលគេបានបញ្ចុះមកលើព្យាការីអ៊ីសា(យេស៊ូគ្រីស្ទ) គឺជាការពិតមកពីអល់ឡោះ។ ព្រះគម្ពីរទាំងពីរនេះ ពោរពេញដោយក្រឹត្យក្រមច្បាប់ ដំបូន្មាន និងដំណឹងដែលមានសេចក្តីចង្អុលបង្ហាញ និងជាពន្លឺសម្រាប់មនុស្សលោកក្នុងជីវិតរស់នៅប្រចាំថ្ងៃ និងបរមសុខនៅថ្ងៃបរលោក។

ក៏ប៉ុន្តែអល់ឡោះជាម្ចាស់ទ្រង់បានប្រាប់នៅក្នុងគម្ពីរគួរអានថា ពួកដែលទទួលបានគម្ពីរទាំងពីរនេះ គឺពួកជ្វីហ្វ និងពួកគ្រឹស្ទាន បានកែប្រែគម្ពីររបស់ពួកគេ។ ពួកគេបានបន្ថែម និងបន្ថយនូវអ្វីដែលមាននៅក្នុងគម្ពីរទាំងពីរនេះ។ ដូច្នេះ ទើបក្នុងគម្ពីរទាំងពីរនេះបានបាត់បង់នូវខ្លឹមសារដើមដែលអល់ឡោះទ្រង់បានបញ្ចុះមក។

គម្ពីរតាវ៉ែត(គម្ពីរតូរ៉ា)ដែលមាននាពេលបច្ចុប្បន្ននេះ គឺមិនមែនជាគម្ពីរតាវ៉ែតដែលគេបានបញ្ចុះមកលើព្យាការីមូសា(ម៉ូសេ)ទេ ពីព្រោះពួកជ្វីហ្វបានកែប្រែ និងផ្លាស់ប្តូរបាត់អស់ទៅហើយ។ ពួកគេបានលេងសើចជាមួយក្រឹត្យក្រមច្បាប់ជាច្រើនរបស់វា។ អល់ឡោះទ្រង់មានបន្ទូលថាៈ “នៅក្នុងចំណោមពួកជ្វីហ្វ មានអ្នកខ្លះកែប្រែបន្ទូលរបស់អល់ឡោះឲ្យខុសពីកន្លែងរបស់វា”។ (គម្ពីរគួរអាន ៤:៤៦)

ក៏ដូចគ្នាដែរគម្ពីរអ៊ីនជីល ដែលមាននាបច្ចុប្បន្ននេះ គឺមិនមែនជាគម្ពីរអ៊ីនជីល(គម្ពីរប៊ីប)ដែលគេបានបញ្ចុះមកលើព្យាការីអ៊ីសា(យេស៊ូគ្រីស្ទ)នោះទេ។ ប្រាកដណាស់ ពួកគ្រឹស្ទានបានកែប្រែ និងផ្លាស់ប្តូរក្រឹត្យក្រមច្បាប់ជាច្រើនរបស់វា។ អល់ឡោះទ្រង់មានបន្ទូលពីពួកគ្រឹស្ទានថាៈ “ហើយប្រាកដណាស់ នៅក្នុងចំណោមពួកគេ គឺមានក្រុមមួយដែលកែប្រែ និងផ្លាស់ប្តូរគម្ពីរ(តាវ៉ែត) ដើម្បីឲ្យពួកអ្នកស្មានថា វាមកពីគម្ពីរនេះ តែតាមពិតវាមិនមែនមកពីគម្ពីរទេ។ ហើយពួកគេនិយាយថាៈ វាមកពីអល់ឡោះ តែតាមការពិតវាមិនមែនមកពីអល់ឡោះទេ។ ហើយពួកគេកំពុងតែនិយាយកុហកទៅលើអល់ឡោះ ខណៈដែលពួកគេដឹងហើយនោះ”។ (គម្ពីរគួរអាន ៣: ៧៨)

“ហើយយើងបានយកកិច្ចសន្យាពីពួកដែលបាននិយាយថាៈ ពិតប្រាកដណាស់ ពួកយើងជាគ្រិស្តសាសនិក តែពួកគេបានភ្លេច(បោះបង់ចោល)មួយចំណែកពីអ្វីដែលគេបានរំលឹកពួកគេពីវា។ ហើយយើង បានធ្វើឱ្យពួកគេក្លាយជាសត្រូវនឹងគ្នា និងស្អប់ខ្ពើមគ្នារហូតដល់ថ្ងៃ បរលោក។ ហើយអល់ឡោះនឹងប្រាប់ពួកគេឱ្យដឹងនូវអ្វីដែលពួកគេបានប្រព្រឹត្តកន្លងមក”។ (គម្ពីរគួរអាន៥:១៤)

ហេតុនេះ ទើបយើងសង្កេតឃើញថាបច្ចុប្បន្ន អ្វីដែលគេហៅថាគម្ពីរពិសិដ្ឋដែលមាន នៅក្នុងដៃអ្នកដែលបានទទួលព្រះគម្ពីរ(ពួកជ្វីហ្វ និងពួកគ្រឹស្ទាន)គឺគម្ពីរតាវ៉ែត និងគម្ពីរអ៊ីនជីល(គម្ពីរប៊ីប)ដែលពោរពេញដោយ




> សាសនិកឥស្លាមជឿជាក់ថា ពិតប្រាកដណាស់គម្ពីរតូរ៉ា(តាវ៉ែត) និងគម្ពីរអ៊ិញ្ជីល ទាំងពីរនេះត្រូវបានបញ្ចុះមកពីអល់ឡោះ ប៉ុន្តែគម្ពីទាំងពីរនេះត្រូវបានបញ្ចូលនូវការកែប្រែនិងផ្លាស់ប្តូរជាច្រើន ហើយយើងមិនត្រូវជឿជាក់ចំពោះវាឡើយ លើកលែងតែអ្វីដែលសមស្របនឹងគម្ពីរគួរអាននឹងសុណ្ណះប៉ុណ្ណោះ។

ជំនឿមិនត្រឹមត្រូវ ដំណឹងមិនពិត និងការប្រឌិតរឿងកុហកជាច្រើន។ យើងមិនអាចជឿដំណឹងដែលនៅក្នុងគម្ពីទាំងពីរនេះបានទេលុះត្រាតែអ្វីដែលគម្ពីរគួរអាននិងស៊ុណ្ណះ(លំអានរបស់ព្យាការី) បានបញ្ជាក់ថាជាការពិតទើបយើងអាចជឿបាន។ ហើយយើងនឹងមិនត្រូវជឿនូវអ្វីដែលគម្ពីរគួរអាន និងស៊ុណ្ណះបានបដិសេធចោលឡើយ។

ក្រៅពីនេះ យើងត្រូវនៅស្ងៀមមិននិយាយពីអ្វីផ្សេងទៀតដែលនៅសល់ ដោយយើងមិនជឿ ហើយក៏មិនបដិសេធដែរ។.

ជាមួយគ្នានេះដែរ ជនមូស្លីមត្រូវគោរពព្រះគម្ពីរទាំងនោះដោយមិនត្រូវមើលស្រាល និងបន្តុះបង្អាប់ឡើយ ពីព្រោះនៅក្នុងគម្ពីរទាំងនោះមានផ្នែកខ្លះជាពាក្យបន្ទូលរបស់អល់ឡោះនៅគង់វង្សមិនបានកែប្រែឡើយ។

## ផលប្រយោជន៍នៃជំនឿចំពោះព្រះគម្ពីរ

ជំនឿចំពោះព្រះគម្ពីរមានផលប្រយោជន៍ជាច្រើនដូចជា



1 យល់ដឹងពីការថែរក្សារបស់អល់ឡោះចំពោះខ្ញុំបម្រើទាំងឡាយ និងក្ដីមេត្តាករុណារបស់ទ្រង់ដ៏ពេញលេញ ដោយទ្រង់បានបញ្ជូនទៅកាន់ក្រុមមនុស្សនីមួយៗនូវគម្ពីរមួយច្បាប់ ដើម្បីចង្អុលបង្ហាញផ្លូវដល់ពួកគេ និងសម្រេចនូវសុភមង្គលសម្រាប់ពួកគេនៅក្នុងលោកិយនេះ និងនៅបរលោក។

2 យល់ដឹងពីគតិបណ្ឌិតរបស់អល់ឡោះដែលមាននៅក្នុងច្បាប់របស់ទ្រង់ ដោយទ្រង់ដាក់ច្បាប់សម្រាប់ក្រុមមនុស្សនីមួយៗតាមអ្វីដែលសមស្របនឹងស្ថានភាពរបស់ពួកគេ និងល្អប្រសើរសម្រាប់បុគ្គលិកលក្ខណៈរបស់ពួកគេ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “រាល់ប្រជាជាតិនីមួយៗក្នុងចំណោមពួកអ្នកយើងបានបង្កើតច្បាប់ និងមាគ៌ាយ៉ាងច្បាស់លាស់” ។(គម្ពីរគួរអាន៥ៈ ៤៨)

3 ថ្លែងអំណរគុណចំពោះពរជ័យរបស់អល់ឡោះក្នុងការបញ្ចុះគម្ពីរទាំងនេះ។ ដោយគម្ពីរទាំងនេះជាពន្លឺ និងជាការចង្អុលបង្ហាញផ្លូវនៅលើលោកិយនេះ និងនៅថ្ងៃបរលោក។ ដូច្នេះ ចាំបាច់ត្រូវតែថ្លែងអំណរគុណអល់ឡោះចំពោះពរជ័យដ៏ធំធេងនេះ។

# > ជំនឿចំពោះបណ្ដាអ្នកនាំសារទាំងឡាយ

## តម្រូវការរបស់មនុស្សចំពោះសារ(របស់ព្រះជាម្ចាស់)



ចាំបាច់សម្រាប់មនុស្សត្រូវមានសាររបស់ព្រះជាម្ចាស់ បញ្ជាក់ប្រាប់ពីក្រឹត្យក្រមច្បាប់សម្រាប់ពួកគេ និងចង្អុលបង្ហាញពួកគេទៅរកភាពត្រឹមត្រូវ។ សារ(របស់អល់ឡោះ) គឺជាវិញ្ញាណ ជីវិត និងជាពន្លឺរបស់ពិភពលោក។ តើពិភពលោកមានភាពល្អប្រសើរដែរឬទេ បើគ្មានវិញ្ញាណ ជីវិត និងពន្លឺទេនោះ?

ដូច្នេះហើយទើបអល់ឡោះទ្រង់ដាក់ឈ្មោះសាររបស់ទ្រង់ថាវិញ្ញាណ។ កាលបើគ្មានវិញ្ញាណ ជីវិតក៏បាត់បង់ដែរ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយដូច្នោះដែរ យើងបានបញ្ចុះវិញ្ញាណ (គម្ពីរគួរអាន)ឲ្យអ្នកតាមបទបញ្ជារបស់យើង ដោយអ្នកមិនធ្លាប់បានដឹងថាអ្វីជាគម្ពីរ ហើយអ្នកក៏មិនដឹងថាអ្វីជាជំនឿដែរ។ ក៏ប៉ុន្តែយើងបានបង្កើតវា (គម្ពីរគួរអាន) ជាពន្លឺមួយដែលយើងនឹងចង្អុលបង្ហាញតាមរយៈវាចំពោះអ្នកណាដែលយើងមានចេតនា ក្នុងចំណោមខ្ញុំរបស់យើង”។ (គម្ពីរគួរអាន៤២: ៥២)

ដោយសារ ដ្បិតតែប្រាជ្ញាស្គាល់ល្អ អាក្រក់ជាលក្ខណៈទូទៅក៏ដោយ តែវាមិនអាចស្គាល់ល្អិតល្អន់ និងគ្រប់ជ្រុងជ្រោយឡើយ ហើយការប្រតិបត្តិការគោរពសក្ការៈ និងរបៀបរបស់វាមិនអាចប្រព្រឹត្តទៅបានឡើយ លុះត្រាតែតាមរយៈវ៉ាហ៊ី និងសារ(របស់ព្រះអល់ឡោះ)។

ដូច្នេះ គ្មានផ្លូវនាំទៅរកសុភមង្គល និងភាពជោគជ័យនៅក្នុងលោកទាំងពីរបានឡើយ លុះត្រាតែតាមរយៈបណ្ដាអ្នកនាំសារ ហើយគ្មានផ្លូវអាចស្គាល់ល្អ អាក្រក់ដោយច្បាស់លាស់បានដែរ លុះត្រាតែតាមមាគ៌ារបស់ពួកគេ។ ជនណាងាកចេញពីសារ(របស់អល់ឡោះ) ជននោះនឹងជួបឧបសគ្គ ច្របូកច្របល់ ព្រួយបារម្ភ និងការវង្វេងអពមង្គលតាមទំហំនៃបទល្មើស និងការងាកចេញរបស់គេពីសារ(របស់ព្រះអល់ឡោះ)។

## ជាគោលគ្រឹះមួយនៃគោលគ្រឹះជំនឿ

ជំនឿចំពោះអ្នកនាំសារ គឺជាគោលគ្រឹះមួយក្នុងចំណោមគោលគ្រឹះជំនឿទាំងប្រាំមួយ។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ“អ្នកនាំសារ(ព្យាការីមូហាំម៉ាត់)មានជំនឿលើអ្វីៗដែលម្ចាស់របស់គេបានបញ្ចុះមកឲ្យគេ ហើយបណ្ដាអ្នកមានជំនឿក៏ដូច្នោះដែរ។ ពួកគេទាំងអស់មានជំនឿលើអល់ឡោះ និងបណ្ដាម៉ាឡាអ៊ីកាត់របស់ទ្រង់ និងបណ្ដាគម្ពីររបស់ទ្រង់ ហើយនឹងបណ្ដាអ្នកនាំសាររបស់ទ្រង់។ (ពួកគេបាននិយាយថា) ពួកយើងមិនបែងចែកអ្នកនាំសារណាម្នាក់ក្នុងចំណោមអ្នកនាំសារទាំងឡាយរបស់អល់ឡោះឡើយ”។ (គម្ពីរគួរអាន ២:២៨៥)។ វាក្យខណ្ឌនេះបានចង្អុលបង្ហាញពីភាពចាំបាច់នៃជំនឿចំពោះបណ្ដាអ្នកនាំសារទាំងអស់ដោយគ្មានការបែងចែក។ ដូច្នេះ យើងមិនត្រូវជឿចំពោះអ្នកនាំសារខ្លះ ហើយបដិសេធចំពោះអ្នកនាំសារខ្លះទៀត ដូចទង្វើរបស់ពួកជ្វីហ្វ និងពួកគ្រីស្ទានឡើយ។

អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ពីជំនឿថាៈ “អ្នកត្រូវជឿចំពោះអល់ឡោះ ម៉ាឡាអ៊ីកាត់របស់ទ្រង់ បណ្ដាព្រះគម្ពីររបស់ទ្រង់ បណ្ដាអ្នកនាំសាររបស់ទ្រង់ (មានជំនឿចំពោះ)ថ្ងៃបរលោក និងត្រូវជឿចំពោះព្រះលិខិតល្អ ឬអាក្រក់”។ (មូស្លីមៈ៨)

## អត្ថន័យនៃជំនឿចំពោះបណ្ដាអ្នកនាំសារ

គឺជាការជឿជាក់យ៉ាងច្បាស់ថា អល់ឡោះទ្រង់បានបញ្ជូនទៅកាន់រាល់ៗប្រជាជាតិនីមួយៗនូវអ្នកនាំសារពីក្នុងចំណោមពួកគេ ដើម្បីអំពាវនាវពួកគេឲ្យគោរពសក្ការៈចំពោះទ្រង់តែមួយគត់ដោយគ្មានពហុទេពនិយមចំពោះទ្រង់។ ហើយបណ្ដាអ្នកនាំសារទាំងអស់ជាអ្នកប្រកាន់សច្ចធម៌ គេជឿទុកចិត្តថាជាអ្នកប្រកាន់សច្ចធម៌ កោតខ្លាច(ចំពោះអល់ឡោះ) និងទៀងត្រង់។ ពួកគេបានផ្ដល់នូវអ្វីដែលអល់ឡោះបញ្ជូនមកឲ្យពួកគេដោយឥតលាក់លៀម ផ្លាស់ប្ដូរ និងបន្ថែមបន្ថយតាមទំនើងចិត្តរបស់ពួកគេសូម្បីតែមួយពាក្យ ឬមួយអក្សរក៏គ្មានដែរ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ដូច្នេះ តួនាទីរបស់បណ្ដាអ្នកនាំសារគ្មានអ្វីក្រៅពីការផ្សព្វផ្សាយសារយ៉ាងច្បាស់លាស់នោះឡើយ”។ (គម្ពីរគួរអាន ១៦:៣៥)

## តើជំនឿចំពោះបណ្ដាអ្នកនាំសារមានអ្វីខ្លះ?

1. ជំនឿថា សាររបស់ពួកគេគឺជាការពិតមកពីអល់ឡោះ ហើយសារទាំងអស់នោះគឺអំពាវនាវទៅរកការគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ដោយគ្មានពហុទេពនិយមចំពោះទ្រង់ឡើយ។ ដូចអល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយជាការពិតណាស់ រាល់ប្រជាជាតិនីមួយៗយើងបានតែងតាំងអ្នកនាំសារម្នាក់ ដោយបង្គាប់ពួកគេឲ្យគោរពសក្ការៈចំពោះអល់ឡោះ និងចៀសវាងពី តហ្គ៊ូត(អ្វីដែលគេគោរពសក្ការៈផ្សេងក្រៅពីអល់ឡោះ)”។ (គម្ពីរគួរអាន ១៦:៣៦)។ រីឯក្រឹត្យក្រមច្បាប់ព្យាការីនីមួយៗក្នុងមែកធាងនៃច្បាប់ដូចជាហាឡាល់(អ្វីដែលច្បាប់អនុញ្ញាត) និងហារ៉ាំ(អ្វីដែលច្បាប់ហាមឃាត់)អាចមានចំណុចខុសៗគ្នា អាស្រ័យលើប្រជាជាតិនីមួយៗ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “រាល់ៗប្រជាជាតិក្នុងចំណោមពួកអ្នក យើងបានបង្កើតជាច្បាប់និងមាគ៌ាយ៉ាងច្បាស់លាស់”។ (គម្ពីរគួរអាន ៥:៤៨)

2. ជំនឿចំពោះបណ្ដាព្យាការី និងអ្នកនាំសារទាំងអស់គឺ យើងត្រូវជឿចំពោះអ្នកនាំសារទាំងឡាយណាដែលអល់ឡោះបានប្រសិទ្ធនាមឈ្មោះរបស់ពួកគេដូចជាៈ ព្យាការីមូហាំម៉ាត់ អ៊ីព្រហ៊ីម(អាប្រាហាម) មូសា(ម៉ូសេ) អ៊ីសា(យេស៊ូគ្រីស្ទ) ណួហ(ណូអេ)ជាដើម។ ហើយព្យាការីនិងអ្នកនាំសារទាំងឡាយដែលយើងមិនបានស្គាល់ឈ្មោះ យើងត្រូវជឿចំពោះពួកគេជាទូទៅ។ ជនណាបដិសេធព្យាការី ឬអ្នកនាំសារណាម្នាក់ក្នុងចំណោមបណ្ដាព្យាការី និងអ្នកនាំសារនោះ ជននោះពិតជាបានបដិសេធពួកគេទាំងអស់គ្នា។

3. ការជឿយ៉ាងពិតប្រាកដនូវអ្វីដែលត្រឹមត្រូវនៃដំណឹង និងអច្ឆរិយភាព(ភាពអស្ចារ្យដែលអល់ឡោះទ្រង់ប្រទានឲ្យ)ពួកអ្នកនាំសារ ដែលមានចែងក្នុងគម្ពីរគួរអាន និងស៊ុណ្ណះ(មាគ៌ារបស់ព្យាការីមូហាំម៉ាត់) ដូចជាព្រឹត្តិការណ៍សមុទ្រញែកជាពីររបស់ព្យាការីមូសាជាដើម។

4. ការអនុវត្តតាមក្រឹត្យក្រមច្បាប់អ្នកនាំសារដែលគេបញ្ជូនមកកាន់ពួកយើង។ គាត់ជាអ្នកនាំសារដែលល្អប្រសើរជាងគេបំផុតក្នុងចំណោមបណ្ដាអ្នកនាំសារទាំងអស់ និងជាអ្នកនាំសារចុងក្រោយបង្អស់ នោះគឺព្យាការីមូហាំម៉ាត់(សូមសន្តិភាពកើតមានដល់លោក)។

## អំពីលក្ខណៈសម្បត្តិនៃអ្នកនាំសារ

1 ពិតណាស់ ពួកគេគឺជាមនុស្សលោក ហើយចំណុចខុសគ្នារវាងពួកគេនឹងមនុស្សលោកផ្សេងទៀតនោះ គឺអល់ឡោះទ្រង់បានជ្រើសរើសពួកគេដោយផ្តល់វ៉ាហ៊ី និងសារ(របស់ទ្រង់)។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងមិនបានបញ្ជូនអ្នកណាម្នាក់មុនអ្នក(ព្យាការីមូហាំម៉ាត់) ក្រៅពីបុរសៗដែលយើងផ្តល់វ៉ាហ៊ីដល់ពួកគេនោះឡើយ”។ (គម្ពីរគួរអាន ២១:៧)

ដូច្នេះ សម្រាប់ពួកគេគឺគ្មានលក្ខណៈពិសេសជាព្រះជាម្ចាស់នោះទេ។ ក៏ប៉ុន្តែពួកគេគឺជាមនុស្សលោកដែលមានលក្ខណៈរូបសម្បត្តិពេញលេញនិងចរិយាសម្បត្តិដ៏ឧត្តុង្គឧត្តម។ពួកគេមានពូជអម្បូរល្អជាងគេ មានប្រាជ្ញាឈ្លាសវៃ ការនិយាយស្តីពាក្យពេចន៍មានវោហារ ដែលធ្វើឲ្យពួកគេមានសមត្ថភាពអាចទទួលភារកិច្ចនាំសារ(របស់អល់ឡោះ) និងប្រតិបត្តិតួនាទីជាព្យាការី។

ពិតណាស់ អល់ឡោះបានបង្កើតអ្នកនាំសារពីក្នុងចំណោមមនុស្សលោកដើម្បីជាគំរូដល់ពួកគេ (ពីព្រោះអ្នកនាំសារជាមនុស្ស)។ដូច្នេះ ការប្រតិបត្តិតាម និងការយកគំរូតាមអ្នកនាំសារ គឺស្ថិតក្នុងកម្រិតនិងលទ្ធភាពដែលមនុស្សលោកអាចធ្វើបាន ។

2 អល់ឡោះទ្រង់បានជ្រើសរើសពួកគេដោយផ្តល់សារ និងវ៉ាហ៊ី(របស់ទ្រង់)ខុសពីមនុស្សលោកដទៃទៀត។អល់ឡោះទ្រង់មានបន្ទូលថាៈ “ចូរអ្នក(ព្យាការីមូហាំម៉ាត់) ពោលថាៈ តាមពិតខ្ញុំជាមនុស្សលោកដូចពួកអ្នកដែរ គ្រាន់តែគេបានផ្តល់វ៉ាហ៊ីមកឲ្យខ្ញុំថាៈ ម្ចាស់របស់ពួកអ្នកគឺជាម្ចាស់តែមួយគត់”។ (គម្ពីរគួរអាន ១៨:១១០)

ការទទួលតំណែងជាព្យាការី និងជាអ្នកនាំសាររបស់អល់ឡោះពុំមែនរកបានតាមរយៈការហាត់ពត់ភាពបរិសុទ្ធនៃវិញ្ញាណ ឬដោយប្រាជ្ញាឈ្លាសវៃ ឬដោយគំនិតតក្កភាពនោះទេ តែការពិត គឺជាការជ្រើសរើសរបស់ព្រះជាម្ចាស់ អល់ឡោះបានជ្រើសរើសអ្នកនាំសារពីបណ្តាមនុស្សលោកទាំងឡាយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “អល់ឡោះដឹងបំផុតអ្នកណាដែលទ្រង់នឹងផ្តល់សាររបស់ទ្រង់”។ (គម្ពីរគួរអាន ៦:១២៤)។

3 ពួកគេគឺប្រាសចាកពីកំហុសឆ្គងនូវអ្វីដែលពួកគេនាំមកពីអល់ឡោះ គ្មានការភាន់ច្រឡំក្នុងការផ្សព្វផ្សាយ និងមិនខុសឆ្គងក្នុងការប្រតិបត្តិតាមអ្វីដែលអល់ឡោះបានបញ្ចុះវ៉ាហ៊ីមកកាន់ពួកគេឡើយ។

4 សច្ចភាព ឬភាពស្មោះត្រង់៖ បណ្តាអ្នកនាំសារទាំងអស់ជាអ្នកប្រកាន់សច្ចធម៌ទាំងពាក្យសំដី និងទង្វើរបស់ពួកគេ។អល់ឡោះទ្រង់មានបន្ទូលថាៈ “នេះគឺជាអ្វីដែលម្ចាស់មហាសប្បុរសបានសន្យា និងអ្វីដែលអ្នកនាំសារដ៏ស្មោះត្រង់បានបញ្ជាក់ប្រាប់”។ (គម្ពីរគួរអាន ៣៦:៥២)

5 ការអត់ធ្មត់៖ ពួកគេបានអំពាវនាវ(មនុស្សលោក)ទៅរកសាសនាអល់ឡោះដោយប្រាប់ដំណឹងល្អ និងដាស់តឿនពីរឿងអាក្រក់។ពួកគេបានទទួលរងនូវការធ្វើទុកបុកម្នេញនិងការលំបាកសព្វបែបយ៉ាង។ ពួកគេបានអត់ធ្មត់ និងស៊ូទ្រាំក្នុងការលើកតម្កើងសាសនាអល់ឡោះ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ដូច្នេះចូរអ្នក(ព្យាការីមូហាំម៉ាត់) អត់ធ្មត់ដូចបណ្តាអ្នកដែលមានឆន្ទៈមោះមុតក្នុងចំណោមអ្នកនាំសារទាំងឡាយបានអត់ធ្មត់ចុះ”។ (គម្ពីរគួរអាន៤៦:៣៥)

## សញ្ញា និងអច្ឆរិយភាពរបស់អ្នកនាំសារ

អល់ឡោះបានគាំទ្រអ្នកនាំសារឲ្យមានភាពរឹងមាំដោយភស្តុតាង និងការចង្អុលបង្ហាញជាច្រើនបញ្ជាក់ពីសច្ចភាព និងភាពជាព្យាការីរបស់ពួកគេ។ ដូច្នេះ ការផ្តល់ចំពោះពួកគេនូវអច្ឆរិយភាព និងសញ្ញាច្បាស់លាស់ ដែលមនុស្សលោកគ្មានសមត្ថភាពធ្វើបាននោះ គឺដើម្បីបញ្ជាក់ពីសច្ចភាព និងភាពជាព្យាការីរបស់ពួកគេ។

អច្ឆរិយភាព គឺជាភាពអស្ចារ្យខុសពីធម្មតាដែលអល់ឡោះបានផ្តល់ចំពោះព្យាការី និងអ្នកនាំសារ ហើយមនុស្សលោកដទៃទៀតមិនអាចធ្វើដូចពួកគេឡើយ។

អច្ឆរិយភាពទាំងនោះមានដូចជា:

- ការប្រែឈើដំបងឲ្យទៅជាសត្វពស់
- ព្យាការីអ៊ីសា(យេស៊ូគ្រឹស្ទ)អាចប្រាប់ទៅកាន់ក្រុមរបស់គាត់នូវចំណីដែលពួកគេនឹងបរិភោគ និងចំណីអាហារដែលពួកគេត្រូវត្រៀមទុកក្នុងផ្ទះរបស់ពួកគេ។
- ព្រះចន្ទបែកជាពីរចំណែក ជាភស្តុតាងសម្រាប់ព្យាការីមូហាំម៉ាត់។

## ជំនឿរបស់ជនមូស្លីមចំពោះព្យាការីអ៊ីសា ឬព្រះយេស៊ូ

1. គាត់គឺជាអ្នកនាំសារដ៏ឧត្តុង្គឧត្តមនិងខ្ពង់ខ្ពស់ ជាអ្នកនាំសារម្នាក់ក្នុងចំណោមបណ្តាអ្នកនាំសារទាំងឡាយ ហើយគាត់ គឺជាអ្នកនាំសារម្នាក់ក្នុងចំណោមអ្នកនាំសារដែលមានឆន្ទៈមោះមុត គឺព្យាការីមូហាំម៉ាត់ អ៊ីព្រហ៊ីម(អាប្រាហាម) ណួហ(ណូអេ) មូសា(ម៉ូសេ) និងព្យាការីអ៊ីសា(យេស៊ូគ្រឹស្ទ)។ ពួកគាត់ត្រូវបានអល់ឡោះរំឭកក្នុងព្រះបន្ទូលរបស់ទ្រង់ថា: "ហើយ(ចូរចងចាំ) នៅពេលដែលយើងបានទទួលយកពីបណ្តាព្យាការីនូវកិច្ចសន្យារបស់ពួកគេ និងពីអ្នក(ព្យាការីមូហាំម៉ាត់) និងណួហ អ៊ីព្រហ៊ីម និងមូសា ហើយនិងអ៊ីសាកូនម៉ារយ៉ាំ(យេស៊ូគ្រឹស្ទបុត្រនាងម៉ារី)។ ហើយយើងបានទទួលយកកិច្ចសន្យាមួយដ៏មុឹងម៉ាត់ពីពួកគេ"។ (គម្ពីរគួរអាន ៣៣:៧)

2. ពិតណាស់ព្យាការីអ៊ីសា គឺជាមនុស្សម្នាក់នៃកូនចៅព្យាការីអាដាំ(អាដាំ)។ អល់ឡោះបានលើកតម្កើង និងបញ្ជូនគាត់មកកាន់អម្បូរអ៊ីស្រាអែល ហើយទ្រង់បានផ្តល់អច្ឆរិយភាពដល់គាត់ តែគាត់គ្មានលក្ខណៈពិសេសជាព្រះជាម្ចាស់ឡើយ។ អល់ឡោះទ្រង់មានបន្ទូលថា: "គេ(ព្យាការីអ៊ីសា) គ្រាន់តែជាខ្ញុំបម្រើម្នាក់ដែលយើងបានប្រទាននៀកម៉ាត់(អ្វីដែលអល់ឡោះប្រទានឲ្យ) ដល់គេប៉ុណ្ណោះហើយយើងបានយកគេធ្វើជាសញ្ញាសម្រាប់អំបូរអ៊ីស្រាអែល"។ (គម្ពីរគួរអាន៤៣:៥៩)។ ហើយគាត់ក៏មិនបានបញ្ជាក្រុមរបស់គាត់ឲ្យយកគាត់ និងមាតារបស់គាត់ធ្វើជាព្រះក្រៅពីអល់ឡោះដែរ តែការពិតគាត់បានពោលនូវអ្វីដែលអល់ឡោះបានបញ្ជាគាត់: "ចូរពួកអ្នកគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់របស់ខ្ញុំ និងជាម្ចាស់របស់ពួកអ្នក"។ (គម្ពីរគួរអាន ៥:១១៧)

3. ពិតណាស់ព្យាការីអ៊ីសា(យេស៊ូគ្រឹស្ទ) គឺជាបុត្ររបស់ម៉ារយ៉ាំ(នាងម៉ារី)ដែលជាស្ត្រីដ៏ល្អគ្រប់លក្ខណ៍ ជាអ្នកប្រតិបត្តិ គោរពសក្ការៈចំពោះព្រះជាម្ចាស់ ស្អាតស្អំ ព្រហ្មចារីយ៍បរិសុទ្ធ។ គាត់ពរពោះព្យាការីអ៊ីសាដោយឥតមានឪពុកនោះទេ តែដោយមហិទ្ធិឫទ្ធិរបស់អល់ឡោះ ទ្រង់បង្កើតគាត់ដោយអច្ឆរិយភាពដ៏អស្ចារ្យ ដូចទ្រង់បានបង្កើតព្យាការីអាដាំដោយគ្មានឪពុកម្តាយនោះដែរ។ អល់ឡោះទ្រង់មានបន្ទូលថា: "ពិតណាស់ការប្រៀបធៀប(ការបង្កើត)អ៊ីសាសម្រាប់អល់ឡោះ ដូចជា(ការបង្កើត)អាដាំដែរ គឺទ្រង់បានបង្កើតគាត់ពីដី បន្ទាប់មកទ្រង់បានមានបន្ទូលទៅកាន់គាត់ថា: ចូរកើតចុះ វាក៏កើតឡើងភ្លាម"។ (គម្ពីរគួរអាន ៣: ៥៩)

4 ពិតណាស់ គ្មានទេក្នុងចន្លោះរយៈពេលរវាងគាត់ និងព្យាការីមូហាំម៉ាត់ នូវអ្នកនាំសារផ្សេងទៀតនោះ។ គាត់បានប្រាប់ដំណឹងល្អពីមូហាំម៉ាត់ដូចអល់ឡោះទ្រង់មានបន្ទូលថា: “ហើយ(ចូរចងចាំ)នៅពេលដែលអ៊ីសាកូនម៉ារយ៉ាំបានពោលថា: ឱអម្បូរអ៊ីស្រាអែលើ! ពិតណាស់ ខ្ញុំជាអ្នកនាំសាររបស់អល់ឡោះមកកាន់ពួកអ្នក ដោយបញ្ជាក់ពីសច្ចភាពដែលមានមុនខ្ញុំនៅក្នុងគម្ពីរតាវ៉រ៉ត(គម្ពីរតូរ៉ា) និងផ្ដល់ដំណឹងរីករាយដល់ពួកអ្នកនូវអ្នកនាំសារម្នាក់ដែលនឹងមកដល់បន្ទាប់ពីខ្ញុំដែលគេមានឈ្មោះថា អះម៉ាត់ (ព្យាការីមូហាំម៉ាត់)។ ប៉ុន្តែនៅពេលដែលគាត់បានមកកាន់ពួកគេជាមួយនឹងភស្តុតាងដ៏ច្បាស់លាស់ជាច្រើននោះ ពួកគេបែរជានិយាយថា: នេះជាមន្តអាគមយ៉ាងច្បាស់លាស់”។ (គម្ពីគួរអាន ៦១:៦)

5 យើងជឿចំពោះអច្ឆរិយភាពដែលអល់ឡោះបានផ្ដល់ចំពោះគាត់ដូចជា ការព្យាបាលជំងឺឃ្លង់ខ្វាក់ឲ្យជាសះស្បើយ ការប្រោសជីវិតមនុស្សស្លាប់ឲ្យរស់ឡើងវិញ និងការប្រាប់នូវអ្វីដែលមនុស្សលោកបរិភោគ និងអ្វីដែលត្រៀមទុកក្នុងផ្ទះសំបែងពួកគេ។ ទាំងអស់នេះ គឺដោយការអនុញ្ញាតពីអល់ឡោះប៉ុណ្ណោះ។ ទ្រង់បង្កើតអច្ឆរិយភាពទាំងអស់នេះ គឺជាភស្តុតាងយ៉ាងច្បាស់លាស់បញ្ជាក់ពីភាពពិតថា គាត់ជាព្យាការី និងជាអ្នកនាំសារ។

6 ជនណាម្នាក់នៃមនុស្សលោកមិនទាន់មានជំនឿពេញលេញនោះទេ លុះត្រាតែគេជឿថា ព្យាការីអ៊ីសា(យេស៊ូគ្រីស្ទ) គឺជាខ្ញុំបម្រើរបស់អល់ឡោះ និងជាអ្នកនាំសាររបស់ទ្រង់ ហើយគាត់ប្រាសចាកនិងស្អាតស្អំពីការចោទប្រកាន់របស់ពួកជ្វីហ្វពីលក្ខណៈអាក្រក់ និងមិនពិត(ដែលចោទថា គាត់ជាកូនឥតខាន់ស្លា) ដែលអល់ឡោះបានផ្ដល់ភាពជ្រះស្អាតពីការចោទប្រកាន់ទាំងនោះ។ ក៏ដូច្នោះដែរ ពួកយើងក៏ឃ្លាតឆ្ងាយពីជំនឿរបស់ពួកគ្រឹស្ទាន)ដែលវង្វេងមិនយល់ពីការពិតរបស់ព្យាការីអ៊ីសាកូននាងម៉ារយ៉ាំ(នាងម៉ារី) ដោយពួកគេបានយកគាត់ និងមាតារបស់គាត់ធ្វើជាព្រះផ្សេងក្រៅពីអល់ឡោះ។ ហើយអ្នកខ្លះក្នុងចំណោមពួកគេនិយាយថា គាត់ជាបុត្ររបស់អល់ឡោះ ខ្លះទៀតថា គាត់ជាព្រះមួយនៃព្រះទាំងបី(ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ)។ អល់ឡោះជាម្ចាស់មហាស្អាតស្អំពី(ការចោទប្រកាន់) ហួសហេតុ ហើយវាជាអំពើបាបដ៏ធ្ងន់ធ្ងរ។

គាត់មិនត្រូវបានគេសម្លាប់ និងឆ្កាងនោះទេ។ ផ្ទុយទៅវិញ អល់ឡោះជាម្ចាស់បានលើកគាត់ទៅលើមេឃនៅពេលដែលពួកជ្វីហ្វចង់សម្លាប់គាត់ ហើយទ្រង់ធ្វើឲ្យអ្នកផ្សេងប្រែមុខមាត់ និងរូបរាងដូចគាត់។ ម្ល៉ោះហើយពួកគេក៏សម្លាប់ ហើយចងឆ្កាងបុគ្គលនោះ ដោយពួកគេគិតស្មានថា ម្នាក់នោះគឺជាព្យាការីអ៊ីសា(យេស៊ូគ្រីស្ទ)។ អល់ឡោះទ្រង់បានមានបន្ទូលថា: “ដោយសារតែពាក្យសំដីរបស់ពួកគេថា ពួកយើងបានសម្លាប់ម៉ាសៀហអ៊ីសាកូនម៉ារយ៉ាំដែលជាអ្នកនាំសាររបស់អល់ឡោះ ហើយពួកគេមិនបានសម្លាប់គាត់ និងមិនបានចងឆ្កាងគាត់ឡើយ តែទ្រង់បានបំភាន់ពួកគេដោយឱ្យបុរសម្នាក់ដូចអ៊ីសា។ ពិតណាស់ ពួកដែលបានខ្វែងយោបល់គ្នាក្នុងរឿងនេះ ស្ថិតក្នុងភាពសង្ស័យពីវា។ ពួកគេគ្មានចំណេះដឹងអ្វីក្នុងរឿងនេះ ក្រៅពីការស្មាននោះឡើយ។ ហើយពួកគេក៏ពុំបានសម្លាប់គាត់(អ៊ីសា)យ៉ាងពិតប្រាកដនោះដែរ។ ផ្ទុយទៅវិញ អល់ឡោះបានលើកគាត់(ព្យាការីអ៊ីសា)ទៅកាន់ទ្រង់។ ហើយអល់ឡោះមហាខ្លាំងពូកែមហាគតិបណ្ឌិត។ គ្មាននរណាម្នាក់ក្នុងចំណោមពួកដែលគេផ្ដល់គម្ពីរឲ្យ (ពួកជ្វីហ្វ និងពួកគ្រឹស្ទាន) មានជំនឿឡើយ លុះត្រាតែពួកគេមានជំនឿចំពោះអ៊ីសាក្រោយពេលគាត់ចុះពីលើមេឃមុននឹងការស្លាប់របស់គាត់ ហើយនៅថ្ងៃបរលោកគាត់នឹងធ្វើសាក្សីលើពួកគេ”។ (គម្ពីរគួរអាន ៤:១៥៧ -១៥៩)

ពិតប្រាកដទ្រង់មហាបរិសុទ្ធបានថែរក្សា និងលើកគាត់ទៅកាន់ទ្រង់នៅលើមេឃ ហើយគាត់នឹងចុះមកលើផែនដីវិញនៅដំណាក់កាលចុងក្រោយ។ គាត់នឹងកាត់សេចក្ដីតាមច្បាប់ព្យាការីមូហាំម៉ាត់។ បន្ទាប់មកគាត់នឹងទទួលមរណភាព ហើយគេបញ្ចុះសពគាត់នៅលើផែនដី ហើយគេឲ្យគាត់រស់ឡើងវិញនៅលើផែនដីនេះផងដែរ ដូចអម្បូរអាហ៊ាំ(មនុស្សលោក)ដទៃទៀតគ្រប់ៗគ្នា យោងតាមបន្ទូលរបស់អល់ឡោះថា៖ “អំពីដីនេះហើយដែលយើងបានបង្កើតពួកអ្នក ហើយយើងនឹងធ្វើឲ្យពួកអ្នកត្រឡប់ទៅជាដីវិញ(ស្លាប់) ហើយ(នៅថ្ងៃបរលោក) យើងនឹងបញ្ចេញពួកអ្នកពីវាម្ដងទៀត(រស់ឡើងវិញ)”។ (គម្ពីរគួរអាន ២០:៥៥)

## ជំនឿចំពោះមូហាំម៉ាត់ជាព្យាការី និងជាអ្នកនាំសារ

- យើងជឿថា មូហាំម៉ាត់គឺជាខ្ញុំបម្រើ និងជាអ្នកនាំសាររបស់អល់ឡោះ។ គាត់គឺជាចៅហ្វាយនៃមនុស្សលោកទាំងមូល តាំងពីជំនាន់មុន និងជំនាន់ក្រោយ ហើយគាត់គឺជាព្យាការីចុងក្រោយបង្អស់ដោយគ្មានព្យាការីណាក្រោយគាត់ឡើយ។ គាត់បានផ្សព្វផ្សាយសារ ប្រតិបត្តិតួនាទី ចង្អុលបង្ហាញផ្លូវដល់ប្រជាជាតិរបស់គាត់ ហើយគាត់បានតស៊ូពុះពារក្នុងមាគ៌ារបស់អល់ឡោះយ៉ាងពិតប្រាកដ។
- យើងជឿនូវអ្វីដែលគាត់ប្រាប់ ប្រតិបត្តិតាមនូវអ្វីដែលគាត់បញ្ជា ជៀសឆ្ងាយពីអ្វីដែលគាត់ហាមឃាត់ គោរពសក្ការៈចំពោះអល់ឡោះឲ្យស្របតាមមាគ៌ារបស់គាត់ និងយកគំរូតាមគាត់ដោយគ្មានអ្នកផ្សេង។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ "ជាការពិតណាស់ ពួកអ្នកមានអ្នកនាំសាររបស់អល់ឡោះ (ព្យាការីមូហាំម៉ាត់)ជាគំរូដ៏ល្អសម្រាប់អ្នកដែលសង្ឃឹមថានឹងបានជួបអល់ឡោះ និងថ្ងៃបរលោក និងបានរំឭកចំពោះអល់ឡោះយ៉ាងច្រើន"។ (គម្ពីរគួរអាន ៣៣:២១)
- យើងត្រូវតែផ្តល់សេចក្តីស្រឡាញ់ចំពោះគាត់ជាងស្រឡាញ់ឪពុកម្តាយ កូនចៅ និងមនុស្សលោកទាំងអស់។ អ្នកនាំសារបានមានប្រសាសន៍ថាៈ "អ្នកណាម្នាក់ក្នុងចំណោមពួកអ្នកមិនទាន់មានជំនឿពេញលេញនៅឡើយទេ ទាល់តែគេស្រឡាញ់យើងខ្លាំងជាងឪពុកម្តាយ កូនចៅរបស់គេ និងមនុស្សលោកទាំងអស់"។ (ពូខរីៈ១៥ មូស្លីមៈ៤៤)

  ហើយការស្រឡាញ់ដ៏ពិតប្រាកដនោះ គឺតម្រូវឲ្យប្រតិបត្តិតាមមាគ៌ារបស់គាត់ និងយកតម្រាប់តាមសកម្មភាពរបស់គាត់។ ហើយសុភមង្គលដ៏ពិតប្រាកដ និងការស្វែងរកមាគ៌ាដែលត្រឹមត្រូវមិនទាន់អាចសម្រេចបានទេ លុះត្រាតែប្រតិបត្តិតាមគាត់។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ហើយប្រសិនបើពួកអ្នកគោរពប្រតិបត្តិតាមគេ(ព្យាការីមូហាំម៉ាត់)នោះ ពួកអ្នកនឹងទទួលបានការចង្អុលបង្ហាញជាមិនខាន។ ហើយកាតព្វកិច្ចរបស់អ្នកនាំសារ គ្មានអ្វីក្រៅពីការផ្តល់សារដ៏ច្បាស់លាស់នោះឡើយ"។ (គម្ពីរគួរអាន២៤:៥៤)



- ចាំបាច់លើយើងត្រូវតែទទួលយកនូវអ្វីដែលព្យាការីមូហាំម៉ាត់បាននាំមក ប្រកាន់ខ្ជាប់នឹងមាគ៌ារបស់គាត់ ហើយយើងត្រូវតែឲ្យតម្លៃការចង្អុលបង្ហាញរបស់គាត់ជាទីគោរពដ៏ខ្ពង់ខ្ពស់។អល់ឡោះទ្រង់មានបន្ទូលថាៈ "សូមស្បថចំពោះម្ចាស់របស់អ្នក! ពួកគេគ្មានជំនឿទេ លុះត្រាតែពួកគេសុំឲ្យអ្នក(ព្យាការីមូហាំម៉ាត់)កាត់សេចក្តីនូវអ្វីដែលពួកគេបានឈ្លោះទាស់ទែងគ្នាបន្ទាប់មក ពួកគេគ្មានការចង្អៀតចង្អល់ក្នុងចិត្តនូវអ្វីដែលអ្នកបានកាត់សេចក្តីឡើយ ហើយទទួលយកវាដោយពេញចិត្ត"។ (គម្ពីរគួរអាន ៤:៦៥)
- ចាំបាច់លើយើងត្រូវតែប្រុងប្រយ័ត្នពីការប្រឆាំងនឹងបទបញ្ជារបស់គាត់ ពីព្រោះការប្រឆាំងនឹងបទបញ្ជារបស់គាត់ជាហេតុនាំឲ្យកើតមានគ្រោះអាសន្ន ការវង្វេង និងទណ្ឌកម្មយ៉ាងឈឺចាប់។

អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថាៈ “ដូច្នេះ ចូរឲ្យពួកដែលប្រឆាំងនឹងបទបញ្ជារបស់គាត់ (ព្យាការីមូហាំម៉ាត់) ប្រុងប្រយ័ត្នចំពោះគ្រោះអាសន្ននឹងធ្លាក់មកលើពួកគេ ឬទណ្ឌកម្មយ៉ាងឈឺចាប់ធ្លាក់មកលើពួកគេ”។ (គម្ពីរគួរអាន ២៤: ៦៣)

## លក្ខណៈពិសេសនៃសាររបស់ព្យាការីមូហាំម៉ាត់

សាររបស់ព្យាការីមូហាំម៉ាត់មានលក្ខណៈពិសេសជាងសារពីមុនៗដោយលក្ខណៈពិសេសមួយចំនួនដូចតទៅ៖

- សាររបស់ព្យាការីមូហាំម៉ាត់ ជាសារចុងក្រោយបង្អស់។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ព្យាការីមូហាំម៉ាត់មិនមែនជាឪពុករបស់អ្នកណាម្នាក់ក្នុងចំណោមបុរសរបស់ពួកអ្នកឡើយ ក៏ប៉ុន្តែគាត់ជាអ្នកនាំសាររបស់អល់ឡោះ និងជាព្យាការីចុងក្រោយបង្អស់”។ (គម្ពីរគួរអាន ៣៣:៤០)
- សាររបស់ព្យាការីមូហាំម៉ាត់លុបចោលនូវសារមុនៗ។ ដូច្នេះ អល់ឡោះមិនទទួលយកទេអ្នកណាម្នាក់កាន់សាសនាផ្សេងក្រោយពីបានបញ្ជូនព្យាការីមូហាំម៉ាត់មកហើយនោះលុះត្រាតែអ្នកនោះប្រតិបត្តិតាមព្យាការីមូហាំម៉ាត់(កាន់សាសនាឥស្លាម)។ ហើយក៏គ្មានអ្នកណាម្នាក់ឈានដល់ពរជ័យនៃឋានសួគ៌បានដែរ លុះត្រាតែតាមរយៈមាគ៌ាគាត់។ គាត់គឺជាអ្នកនាំសារដែលល្អប្រសើរជាងគេ ប្រជាជាតិរបស់គាត់ជាប្រជាជាតិដែលល្អជាងប្រជាជាតិដទៃទៀតទាំងអស់ ហើយច្បាប់របស់គាត់ មានលក្ខណៈពេញលេញជាងច្បាប់ផ្សេងៗទៀត។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ហើយអ្នកណាស្វែងរកសាសនាផ្សេងក្រៅពីសាសនាឥស្លាមនោះ អល់ឡោះនឹងមិនទទួលយក(ទង្វើល្អ) ពីគេឡើយ។ ហើយនៅថ្ងៃបរលោក គេនឹងស្ថិតនៅក្នុងចំណោមពួកដែលខាតបង់”។ (គម្ពីរគួរអាន ៣:៨៥)

  ហើយអ្នកនាំសារបានមានប្រសាសន៍ថាៈ “ស្បថចំពោះអ្នកដែលជីវិតរបស់មូហាំម៉ាត់នៅក្នុងដៃរបស់ទ្រង់! ជនណាក៏ដោយនៃប្រជាជាតិនេះដែលគេបានលឺពីខ្ញុំ មិនថាគេជាពួកយ៉ាហ៊ូឌី ឬជាពួកគ្រឹស្ទានក្តីក្រោយមក គេបានស្លាប់ដោយមិនបានជឿចំពោះសារដែលយើងបាននាំមកទេនោះ គឺគេគ្មានអ្វីក្រៅពីស្ថិតក្នុងចំណោមពួកអ្នកឋាននរកនោះឡើយ”។ (មូស្លីមៈ១៥៣ អះម៉ាត់ៈ៨៦០៩)
- សាររបស់ព្យាការីមូហាំម៉ាត់ជាសារទូទៅនាំទៅកាន់ក្រុមជិន(អមនុស្ស) និងមនុស្សលោក។ អល់ឡោះទ្រង់មានបន្ទូលលើកឡើងអំពីពាក្យសំដីរបស់ពួកជិនថាៈ “ឱក្រុមរបស់ពួកយើង(ជិន)! ចូរពួកអ្នកឆ្លើយតបចំពោះអ្នកអំពាវនាវរបស់អល់ឡោះ(ព្យាការីមូហាំម៉ាត់) និងមានជំនឿចំពោះគេចុះ”។ (គម្ពីរគួរអាន ៤៦: ៣១)

  អល់ឡោះទ្រង់បានមានបន្ទូលដែរថាៈ “ហើយយើងមិនបានបញ្ជូនអ្នក(ព្យាការីមូហាំម៉ាត់) លើកលែងតែទៅកាន់មនុស្សលោកទូទៅ ដើម្បីផ្តល់ដំណឹងរីករាយ និងដាស់តឿនឱ្យប្រុងប្រយ័ត្នពីទណ្ឌកម្ម”។ (គម្ពីគួរអាន៣៤:២៨)

  ហើយអ្នកនាំសារបានមានប្រសាសន៍ថាៈ គេផ្តល់ភាពល្អប្រសើរដល់ខ្ញុំជាងបណ្តាព្យាការីដទៃទៀតនូវប្រាំមួយប្រការៈ ១) គេផ្តល់ឲ្យខ្ញុំនូវពាក្យសំដីខ្លីខ្លឹម ២) គេឲ្យខ្ញុំឈ្នះ(សត្រូវ) ដោយភាពភ័យខ្លាច(ក្នុងចិត្តសត្រូវ) ៣)គេអនុញ្ញាតសម្រាប់ខ្ញុំនូវទ្រព្យជ័យភណ្ឌ ៤)គេចាត់ទុកដីជាវត្ថុសម្អាត និងជាម៉ាស្ជិទ(សទ្បាត)សម្រាប់ខ្ញុំ ៥) គេបញ្ជូនខ្ញុំទៅកាន់មនុស្សលោកទាំងអស់ ៦) គេបញ្ចប់ការបញ្ជូនបណ្តាព្យាការីចុងក្រោយត្រឹមខ្ញុំ”។ (អាលប៊ូខរីៈ២៨១៥ មូស្លីមៈ៥២៣)

## ផលប្រយោជន៍នៃជំនឿចំពោះបណ្តាអ្នកនាំសារ

សម្រាប់ជំនឿចំពោះអ្នកនាំសារមានផលប្រយោជន៍យ៉ាងច្រើនដូចជា៖

1 យល់ដឹងពីក្តីអាណិតស្រឡាញ់ និងការថែរក្សារបស់អល់ឡោះចំពោះខ្ញុំរបស់ទ្រង់ ដោយទ្រង់បានបញ្ជូនអ្នកនាំសារទៅកាន់ពួកគេដើម្បីចង្អុលបង្ហាញផ្លូវដ៏ត្រឹមត្រូវ និងបញ្ជាក់ប្រាប់ពួកគេនូវរបៀបគោរពសក្ការៈចំពោះទ្រង់ ពីព្រោះប្រាជ្ញារបស់មនុស្សលោកមិនអាចដឹងដោយឯកឯងបានទេចំពោះរឿងទាំងនេះ។ អល់ឡោះទ្រង់មានបន្ទូលពីព្យាការីមូហាំម៉ាត់ថាៈ “ហើយយើងមិនបានបញ្ជូនអ្នក(ព្យាការីមូហាំម៉ាត់)ឡើយ លើកលែងតែដើម្បីផ្តល់ក្តីមេត្តាករុណាចំពោះពិភពលោកទាំងមូល”។ (គម្ពីរគួរអាន ២១:១០៧)

2 ថ្លែងអំណរគុណអល់ឡោះចំពោះពរជ័យដ៏ធំធេងនេះ។

3 ស្រឡាញ់ លើកតម្កើង និងកោតសរសើរបណ្តាអ្នកនាំសារឱ្យបានសក្តិសមនឹងកិត្តិយសពួកគេ ពីព្រោះពួកគេបានប្រតិបត្តិការគោរពសក្ការៈចំពោះអល់ឡោះ ផ្សព្វផ្សាយសាររបស់ទ្រង់ និងដាស់តឿនខ្ញុំបម្រើរបស់ទ្រង់។

4 ការប្រតិបត្តិតាមសារដែលអ្នកនាំសារបាននាំមកពីអល់ឡោះនោះ គឺការគោរពសក្ការៈចំពោះអល់ឡោះតែមួយគត់ដោយគ្មានពហុទេពនិយមចំពោះទ្រង់ និងការអនុវត្តតាមសារ។ ដូច្នេះ វានឹងសម្រេចបានសម្រាប់អ្នកមានជំនឿនូវសេចក្តីល្អប្រសើរ ការចង្អុលបង្ហាញផ្លូវ និងសុភមង្គលក្នុងជីវិតរបស់ពួកគេក្នុងលោកទាំងពីរ(លោកិយ និងបរលោក)។

អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ជនណាដែលបានដើរតាមការចង្អុលបង្ហាញរបស់យើងនោះ គឺគេមិនវង្វេង(នៅក្នុងលោកិយ) និងមិនលំបាកឡើយ(នៅថ្ងៃបរលោក)។ តែបើអ្នកណាហើយបានងាកចេញពីការដាស់តឿន(គម្ពីរគួរអាន)របស់យើង ពិតណាស់សម្រាប់គេគឺការរស់នៅយ៉ាងលំបាកវេទនា(ទោះបីជារូបភាពខាងក្រៅរបស់គេជាអ្នកមាន ឬមានឋានៈខ្ពង់ខ្ពស់ក៏ដោយ)”។ (គម្ពីរគួរអាន២០:១២៣- ១២៤)



> វិហារ អាល់អឹកស សម្រាប់ជនមូស្លីម គឺមានឋានៈដ៏ខ្ពង់ខ្ពស់។ វាគឺជាវិហារតេស្លាមទីពីរដែលត្រូវបានសាងនៅលើផែនដីនេះ បន្ទាប់ពីវិហារ អាល់ហារ៉ាមនៅទីក្រុងនៅម៉ាក្កះ ហើយពិតណាស់ ព្យាការីមូហាំម៉ាត់ និងបណ្តាព្យាការីផ្សេងទៀតក៏បានសឡាត(ថ្វាយបង្គំ)នៅក្នុងវិហារអឹកសនេះផងដែរ។

# > ជំនឿចំពោះថ្ងៃបរលោក

## អត្ថន័យនៃជំនឿចំពោះថ្ងៃបរលោក

គឺជាការជឿជាក់យ៉ាងច្បាស់លាស់ថា អល់ឡោះនឹងធ្វើឲ្យអ្នកដែលនៅក្នុងផ្នូរទាំងអស់រស់ឡើងវិញ។ បន្ទាប់មក ទ្រង់នឹងជំនុំជម្រះពួកគេ និងតបស្នងចំពោះពួកគេតាមទង្វើរបស់ពួកគេ ដើម្បីឲ្យបណ្ដាអ្នកឋានសួគ៌ស្ថិតនៅទីកន្លែងរបស់ពួកគេ និងពួកឋាននរកស្ថិតនៅទីកន្លែងរបស់ពួកគេ។

ជំនឿចំពោះថ្ងៃបរលោកជាគោលគ្រឹះមួយក្នុងចំណោមគោលគ្រឹះជំនឿទាំងប្រាំមួយ។ ដូច្នេះ ជំនឿរបស់គេមិនត្រឹមត្រូវទេ លុះត្រាតែមានជំនឿចំពោះថ្ងៃបរលោក។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ប៉ុន្តែអំពើល្អនោះគឺ អ្នកណាដែលមានជំនឿលើអល់ឡោះ និងថ្ងៃបរលោក”។ (គម្ពីរគួរអាន ២:១៧៧)

## ហេតុអ្វីបានជាគម្ពីរគួរអានបញ្ជាក់យ៉ាងច្បាស់ពីជំនឿចំពោះថ្ងៃបរលោក?

គម្ពីរគួរអានបានបញ្ជាក់យ៉ាងច្បាស់ពីជំនឿចំពោះថ្ងៃបរលោក និងបានក្រើនរំឭកអំពីថ្ងៃបរលោកជារឿយៗ ហើយបញ្ជាក់យ៉ាងច្បាស់លាស់ថា វានឹងកើតឡើង ដោយប្រើសំនួនភាសាអារ៉ាប់ផ្សេងៗគ្នា។ គម្ពីរគួរអានក៏បានផ្សាភ្ជាប់ជំនឿចំពោះថ្ងៃបរលោក និងជំនឿចំពោះអល់ឡោះនៅកន្លែងជាច្រើនក្នុងគម្ពីរនេះ។

ពីព្រោះជំនឿចំពោះថ្ងៃបរលោក ជាហេតុផលនាំឲ្យជឿចំពោះអល់ឡោះ និងភាពយុត្តិធម៌របស់ទ្រង់ដែលមហាបរិសុទ្ធ។ ដើម្បីបញ្ជាក់ពីរឿងនេះគឺ៖

អល់ឡោះមិនទទួលស្គាល់អំពើអយុត្តិធម៌ ហើយមិនទុកពួកអ្នកបំពានឲ្យរួចខ្លួន មិនទុកឲ្យជនរងគ្រោះដោយគ្មានភាពយុត្តិធម៌ និងមិនបោះបង់អ្នកសាងទង្វើកុសលដោយគ្មានផលបុណ្យតបស្នងនោះដែរ ហើយទ្រង់នឹងផ្ដល់ឲ្យគ្រប់គ្នាទទួលបានសិទ្ធិរបស់ខ្លួន។ យើងឃើញហើយថា ជីវិតនៅលើលោកិយមានអ្នកដែលរស់នៅប្រព្រឹត្តអំពើអយុត្តិធម៌ ស្លាប់ទៅក្នុងនាមជាអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ ហើយមិនទាន់បានទទួលការដាក់ទោស។ រីឯខ្លះទៀតរស់នៅជាជនរងគ្រោះស្លាប់ដោយអយុត្តិធម៌ មិនទាន់ទទួលបានសិទ្ធិរបស់ខ្លួននៅឡើយ។ បើដូច្នោះមែន តើពាក្យថាអល់ឡោះមិនទទួលយកអំពើអយុត្តិធម៌ មានន័យដូចម្ដេចដែរ? អត្ថន័យរបស់វាគឺ ត្រូវតែមានជីវិតម្ដងទៀតបន្ទាប់ពីជីវិតដែលយើងកំពុងរស់នៅ(លើលោកិយ) ត្រូវតែមានពេលវេលាផ្សេងទៀតដែលគេនឹងតបស្នងអ្នកសាងអំពើកុសល និងធ្វើទណ្ឌកម្មអ្នកសាងអំពើអកុសល ហើយគ្រប់ៗគ្នាដែលមានសិទ្ធិនឹងទទួលបានសិទ្ធិរបស់ខ្លួនវិញ។



> សាសនាឥស្លាមអប់រំមនុស្សទៅរកការឃ្លាតឆ្ងាយអំពីភ្លើងនរក ដោយធ្វើល្អទៅចំពោះអ្នកដទៃ ទោះជារឿងនោះដោយការបរិច្ចាគមួយចំហៀងផ្លែល្មើក៏ដោយ។

## តើជំនឿចំពោះថ្ងៃបរលោកមានអ្វីខ្លះ ?

ជំនឿរបស់អ្នកមូស្លីមចំពោះថ្ងៃបរលោកមានប៉ុន្មានប្រការដូចជា៖

1 ជំនឿចំពោះការពង្រស់ឡើងវិញ និងការប្រមូលផ្ដុំមនុស្សទាំងអស់៖ វាគឺជាការធ្វើឲ្យអ្នកស្លាប់នៅក្នុងផ្នូរទាំងអស់រស់ឡើងវិញ វិញ្ញាណរបស់ពួកគេត្រឡប់ទៅរកខ្លួនប្រាណពួកគេវិញ។ មនុស្សលោកទាំងអស់ក្រោកឡើងទៅកាន់ម្ចាស់នៃសាកលលោកទាំងមូល។ បន្ទាប់មក គេប្រមូលផ្ដុំពួកគេនៅទីកន្លែងតែមួយ។ ពួកគេគ្មានស្បែកជើង និងគ្មានសម្លៀកបំពាក់ ដូចដែលគេបានបង្កើតពួកគេចេញពីផ្ទៃម្ដាយរបស់ពួកគេកាលពីដំបូងនោះដែរ។

ជំនឿថា អ្នកដែលនៅក្នុងផ្នូរទាំងអស់រស់ឡើងវិញ គឺជាអ្វីដែលគម្ពីរគួរអាន មាគ៌ាព្យាការីមូហាំម៉ាត់ សតិបញ្ញា និងនិស្ស័យពីកំណើតបានបញ្ជាក់ជាភស្តុតាង។ ហើយយើងជឿយ៉ាងច្បាស់ថា អល់ឡោះនឹងធ្វើឲ្យអ្នកដែលនៅក្នុងផ្នូរទាំងអស់រស់ឡើងវិញ វិញ្ញាណទាំងឡាយនឹងត្រឡប់ទៅរកខ្លួនប្រាណពួកគេវិញ មនុស្សលោកទាំងអស់ក៏ក្រោកឡើងទៅកាន់ម្ចាស់នៃសាកលលោកទាំងមូល។

អល់ឡោះទ្រង់មានបន្ទូលថាៈ "បន្ទាប់មកពួកអ្នកពិតជាស្លាប់(ក្រោយពេលដល់អាយុត្រូវស្លាប់)។ បន្ទាប់មក ពួកអ្នកពិតជានឹងត្រូវគេពង្រស់ឲ្យរស់ឡើងវិញនៅថ្ងៃបរលោក"។ (គម្ពីរគួរអាន ២៣:១៥-១៦)

បណ្ដាគម្ពីរទាំងអស់ដែលគេបញ្ចុះពីលើមេឃបានឯកភាពគ្នាចំពោះរឿងនេះ ព្រោះវាជាការចាំបាច់បំផុតនៃគតិបណ្ឌិតគឺៈ ចាំបាច់ណាស់អល់ឡោះត្រូវតែបង្កើតសម្រាប់មាខ្លូកទាំងអស់នូវការវិលត្រឡប់(មានជីវិតសាជាថ្មី) ដើម្បីតបស្នងពួកគេនូវរាល់អ្វីដែលទ្រង់តម្រូវឲ្យពួកគេប្រតិបត្តិតាមរយៈបណ្ដាអ្នកនាំសាររបស់ទ្រង់។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ "តើពួកអ្នកគិតថា យើងបានបង្កើតពួកអ្នកគ្រាន់តែជាការលេងសើច ហើយពួកអ្នកពិតជាមិនត្រូវវិលត្រឡប់មកជួបយើងវិញ(ដើម្បីជំនុំជម្រះ)នោះឬ?"។ (គម្ពីរគួរអាន ២៣:១១៥)

### ក្នុងចំណោមភស្តុតាងនៃគម្ពីរគួរអានដែលបញ្ជាក់ថា មនុស្សក្នុងផ្នូរទាំងអស់រស់ឡើងវិញគឺ

- ពិតណាស់អល់ឡោះបង្កើតមនុស្សលោកតាំងពីដំបូង។ អ្នកដែលមានអានុភាពបង្កើតមនុស្សលោកពីដំបូងបាន ពិតណាស់ នឹងមានសមត្ថភាពបង្កើតមនុស្សលោកសាជាថ្មីម្ដងទៀត។ អល់ឡោះទ្រង់មានបន្ទូលថាៈ "ហើយទ្រង់ជាអ្នកចាប់ផ្ដើមបង្កើតមនុស្សលោក បន្ទាប់មកទ្រង់នឹងបង្កើតវាសាជាថ្មីម្ដងទៀត(នៅថ្ងៃបរលោក)"។ (គម្ពីរគួរអាន ៣០:២៧)

អល់ឡោះទ្រង់មានបន្ទូលបញ្ជាឲ្យឆ្លើយតបនឹងពួកដែលបដិសេធនឹងការធ្វើឲ្យឆ្អឹងរស់ឡើងវិញ ខណៈដែលវាបានពុកផុយហើយនោះថាៈ "ចូរអ្នក(ព្យាការីមូហាំម៉ាត់) ពោលថាៈ អ្នកដែលធ្វើឲ្យវារស់ឡើងវិញនោះ គឺអ្នកដែលបានបង្កើតវាពីដំបូងនោះហើយ។ ទ្រង់ដឹងបំផុតនូវអ្វីដែលទ្រង់បានបង្កើត"។ (គម្ពីរគួរអាន ៣៦:៧៩)

- ពិតប្រាកដ ដីដែលស្ងួតហួតហែង គ្មានរុក្ខជាតិពណ៌បៃតង នៅពេលភ្លៀងធ្លាក់ វាក៏មានជីវិត



មានពណ៌បៃតង រស់(ដុះ)ឡើងវិញនូវរុក្ខជាតិគ្រប់បែបយ៉ាងយ៉ាងស្រស់បំព្រង។ អ្នកដែលមានអានុភាពអាចធ្វើឲ្យវារស់(រុក្ខជាតិដុះ)ឡើងវិញក្រោយពីវាបានស្លាប់(គ្មានរុក្ខជាតិដុះ)នោះ ទ្រង់ពិតជាមានអានុភាពធ្វើឲ្យអ្នកស្លាប់រស់ឡើងវិញ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងបានបញ្ចុះទឹកភ្លៀងដែលមានពរជ័យពីលើមេឃ រួចយើងបានបណ្ដុះចេញពីវានូវចម្ការដំណាំជាច្រើន និងប្រភេទធញ្ញជាតិដែលអាចច្រូតកាត់(ប្រមូលផល)បាន និងដើមល្មើខ្ពស់ស្កឹមស្កៃដែលមានធ្លាយផ្លែស្អែកស្កះជាជួរ ជាលាភសក្ការៈសម្រាប់ខ្ញុំរបស់អល់ឡោះ។ ហើយយើងបានធ្វើឲ្យដីដែលស្លាប់(គ្មានជីជាតិ)មានជីវិត(មានជីជាតិ)ឡើងវិញដោយសារវា(ទឹកភ្លៀង)។ ដូច្នោះដែរ យើងធ្វើឲ្យពួកអ្នករស់ឡើងវិញ(នៅថ្ងៃបរលោក)”។ (គម្ពីរគួរអាន ៥០:៩-១១)

- រាល់អ្នកដែលមានសតិបញ្ញាដឹងថា អ្នកដែលមានសមត្ថភាព ឬអានុភាពលើកិច្ចការដ៏ធំធេងនោះ ពិតណាស់ចំពោះកិច្ចការតូចតាចវិញនោះ វាងាយស្រួលជាទីបំផុត។ អល់ឡោះទ្រង់បង្កើតមេឃ ដី និងចក្រវាលជាកិច្ចការដ៏ធំធេង និងវិសាលភាពរបស់វា ហើយភាពអស្ចារ្យនៃទ្រង់ទ្រាយរបស់វា ទ្រង់ពិតជាមានអានុភាពអាចធ្វើឲ្យឆ្អឹងដែលពុកផុយទៅហើយនោះរស់ឡើងវិញ។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “តើអ្នកដែលបង្កើតមេឃជាច្រើនជាន់ និងផែនដីមិនមែនជាអ្នកដែលមានសមត្ថភាពបង្កើតឲ្យដូចពួកគេទេឬ? ផ្ទុយទៅវិញ ទ្រង់ជាអ្នកមានអានុភាពបង្កើត ទ្រង់មហាដឹង”។ (គម្ពីរគួអាន ៣៦:៨១)

**2** ជំនឿចំពោះការជំនុំជម្រះ និងជញ្ជីង(ថ្លឹងទង្វើរបស់មនុស្សលោក)គឺ៖ អល់ឡោះនឹងជំនុំជម្រះទង្វើដែលគេបានប្រព្រឹត្តក្នុងជីវិតនៅលោកិយនេះ។ ជនណាដែលឋិតក្នុងចំណោមអ្នកដែលគោរពសក្ការៈអល់ឡោះតែមួយគត់ ហើយប្រតិបត្តិតាមទ្រង់ និងអ្នកនាំសាររបស់ទ្រង់នោះ ការជំនុំជម្រះសម្រាប់គេគឺងាយស្រួល ហើយជនណាស្ថិតក្នុងចំណោមអ្នកដែលពហុទេពនិយម និងប្រព្រឹត្តបាបកម្ម ជាការពិតណាស់ការជំនុំជម្រះសម្រាប់គេ គឺពិបាកជាទីបំផុត។

គេនឹងថ្លឹងទង្វើនៅលើជញ្ជីងដ៏ធំមួយ គេក៏ដាក់អំពើកុសលនៅផ្នែកម្ខាងនៃជញ្ជីង និងអំពើអកុសលនៅផ្នែកម្ខាងទៀតនៃជញ្ជីង។ អ្នកណាដែលភ្នែកជញ្ជីងអំពើកុសលរបស់គេធ្ងន់ជាងអំពើអកុសល គេនឹងស្ថិតនៅក្នុងចំណោមអ្នកឋានសួគ៌ ហើយអ្នកណាដែលភ្នែកជញ្ជីងអំពើអកុសលរបស់គេធ្ងន់ជាងអំពើកុសល គេនឹងស្ថិតនៅក្នុងចំណោមអ្នកឋាននរក។ ម្ចាស់របស់អ្នកទ្រង់មិនបានបំពានលើអ្នកណាម្នាក់ឡើយ។

អល់ឡោះទ្រង់មានបន្ទូលថាៈ “ហើយយើងនឹងដាក់ជញ្ជីងយុត្តិធម៌នៅថ្ងៃបរលោក។ ដូច្នេះ ជីវិតគ្រប់រូបនឹងមិនត្រូវគេបំបាត់អ្វី(ទង្វើរបស់គេ)បន្តិចឡើយ ហើយសូម្បីវាមានទម្ងន់ប៉ុនគ្រាប់ស្ពៃ ក៏យើងនាំវា(អំពើល្អនិងអំពើអាក្រក់)មក(ជំនុំជម្រះ)ដែរ។គ្រប់គ្រាន់ហើយយើងជាអ្នកជំនុំជម្រះ”។(គម្ពីរគួរអាន ២១:៤៧)

**3** ឋានសួគ៌និងឋាននរក៖ឋានសួគ៌គឺជាទីកន្លែងមានពរជ័យជាអមតៈ។អល់ឡោះទ្រង់បានរៀបចំវាសម្រាប់អ្នកដែលកោតខ្លាចទ្រង់ គោរពប្រតិបត្តិតាមទ្រង់ និងអ្នកនាំសាររបស់ទ្រង់។ នៅក្នុងឋានសួគ៌ មានពរជ័យសព្វបែបយ៉ាងដែលឋិតថេរជារៀងរហូត មានអ្វីៗទាំងអស់តាមចំណង់ចំណូលចិត្ត រីករាយជាទីបំផុតដោយអ្វីៗដែលខ្លួនពេញចិត្តគឺមានទាំងអស់។

អល់ឡោះទ្រង់មានបន្ទូលទាក់ទាញខ្ញុំរបស់ទ្រង់ដើម្បីប្រសរាន់ទៅកាន់ការគោរពប្រតិបត្តិតាម និងទៅកាន់ឋានសួគ៌ដ៏ធំល្វឹងល្វើយដែលទំហំរបស់វា ដូចទំហំមេឃជាច្រើនជាន់និងផែនដីថាៈ “ហើយចូរពួកអ្នកប្រញាប់ប្រញាល់ទៅរកការអភ័យទោស និងទៅរកឋានសួគ៌ដែលទំហំរបស់វាដូចទំហំមេឃជាច្រើនជាន់និងផែនដីដែលគេបានរៀបចំវាសម្រាប់បណ្ដាអ្នកដែលកោតខ្លាច”។(គម្ពីរគួរអាន៣ៈ១៣៣)

រីឯឋាននរកវិញ ជាទីកន្លែងទណ្ឌកម្មជារៀងរហូតគ្មានទីបញ្ចប់។ អល់ឡោះទ្រង់បានរៀបចំវាសម្រាប់អ្នកប្រឆាំង ដែលប្រឆាំងចំពោះអល់ឡោះ និងល្មើសចំពោះអ្នកនាំសាររបស់ទ្រង់។ នៅក្នុងឋាននរក មាន

ទណ្ឌកម្ម និងការឈឺផ្សាជាទីបំផុតដែលជារឿងនឹកស្មានមិនដល់។ អល់ឡោះទ្រង់បានមានបន្ទូលជាការព្រមានខ្ញុំរបស់ទ្រង់អំពីឋាននរកដែលទ្រង់បានរៀបចំវាសម្រាប់ពួកប្រឆាំងថាៈ “ដូច្នេះ ចូរពួកអ្នកខ្លាចភ្លើងនរក ដែលគ្រឿងបញ្ឆេះរបស់វាគឺមនុស្សនិងដុំថ្មដែលគេបានរៀបចំសម្រាប់ពួកដែលប្រឆាំង”។ (គម្ពីរគួរអាន ២:២៤)

ឱអល់ឡោះជាម្ចាស់! ពិតណាស់ពួកយើងសុំពីទ្រង់នូវឋានសួគ៌ និងអ្វីដែលនាំឲ្យខិតជិតឋានសួគ៌ទាំងពាក្យសំដី និងទង្វើ។ យើងក៏សុំពីទ្រង់ឲ្យចៀសផុតពីឋាននរក និងពីអ្វីដែលនាំឲ្យខិតជិតឋាននរកទាំងពាក្យសំដី និងទង្វើ។

4 ទណ្ឌកម្ម និងពរជ័យនៅក្នុងផ្នូរ ៖ យើងជឿថាការស្លាប់គឺជាការពិត។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ចូរអ្នក(ព្យាការីមូហាំម៉ាត់)ពោលថាៈ ម៉ាឡាអ៊ីកាត់យកជីវិតមនុស្សដែលត្រូវគេបញ្ជូនទៅកាន់ពួកអ្នក នឹងយកជីវិតពួកអ្នក។ បន្ទាប់មក ពួកអ្នកនឹងត្រូវវិលត្រឡប់ទៅកាន់ម្ចាស់របស់ពួកអ្នកវិញ”។ (គម្ពីគួរអាន ៣២:១១)

វាគឺជារឿងឃើញច្បាស់ផ្ទាល់នឹងភ្នែកគ្មានការសង្ស័យឡើយ។ យើងជឿថា រាល់អ្នកដែលស្លាប់ ឬត្រូវគេសម្លាប់ ឬដោយមូលហេតុអ្វីក៏ដោយ វាគឺជាទីបញ្ចប់នៃជីវិតរបស់គេ។ ជាការពិតណាស់ វាគឺជាពេលកំណត់របស់គេដែលមកដល់គ្មានការផ្លាស់ប្តូរអ្វីឡើយ។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ដូច្នេះ នៅពេលដែលការកំណត់ជីវិតរបស់ពួកគេបានមកដល់ ពួកគេមិនអាចសុំពន្យារពេល ឬសុំមុនពេលកំណត់បានឡើយ សូម្បីមួយវិនាទីក៏ដោយ”។ (គម្ពីគួរអាន ៧:៣៤)

- អ្នកណាដែលបានស្លាប់ ពិតប្រាកដថ្ងៃបរលោករបស់គេបានមកដល់គេហើយ ហើយគេក៏ផ្លាស់ទៅកាន់ទីកន្លែងបរលោក។
- មានហាទីស្ហជាច្រើនពីអ្នកនាំសារបញ្ជាក់ពីទណ្ឌកម្មនៅក្នុងផ្នូរចំពោះពួកប្រឆាំង ពួកដែលល្មើស ហើយពរជ័យជាច្រើនសម្រាប់អ្នកមានជំនឿ និងអ្នកសាងអំពើកុសល។ ហើយយើងជឿលើរឿងដូច្នោះ ដោយយើងមិនបាច់លម្អិតចំពោះលក្ខណៈរបស់វាឡើយ ពីព្រោះគំនិតបញ្ញាគ្មានលទ្ធភាពអាចដឹងលក្ខណៈ និងភាពពិតរបស់វាបានឡើយ ដោយសារវាស្ថិតក្នុងភាពអាថ៌កំបាំង ដូចជាឋានសួគ៌ និងឋាននរកដែរ គឺវាមិនបាននៅក្នុងដែនដែលយើងអាចមើលឃើញ។ លទ្ធភាពគំនិតបញ្ញាអាចវាស់វែងដោយការប្រៀបធៀបទៅនឹងប៉ាន់ប្រមាណ សន្និដ្ឋាន និងការវិនិច្ឆ័យតាមអ្វីដែលគេដឹងថាមានភាពស្រដៀងគ្នា និងទៅតាមការស្ទង់ថ្លឹងថ្លែងវានៅក្នុងដែនលោកិយដែលអាចមើលឃើញ។
- ក៏ដូចគ្នាដែរស្ថានភាពនៅក្នុងផ្នូរ ជារឿងអាថ៌កំបាំងដែលឥន្ទ្រីយារម្មណ៍មិនអាចដឹងបានឡើយ។ ហើយប្រសិនបើឥន្ទ្រីយារម្មណ៍អាចដឹងមែននោះ ជំនឿចំពោះរឿងអាថ៌កំបាំងគ្មានប្រយោជន៍អ្វីឡើយ ហើយគតិបណ្ឌិតនៃការដាក់បន្ទុក(កាតព្វកិច្ច)លើមនុស្សលោកក៏ពុំមានផងដែរ ហើយនៅពេលនោះដែរ មនុស្សលោកនិងបញ្ឈប់ការបញ្ចុះសព។ អ្នកនាំសារបានមានប្រសាសន៍ថាៈ “ប្រសិនបើពួកអ្នកមិនត្រូវបានបញ្ចុះសពគ្នីគ្នាទេនោះ យើងនឹងសុំអល់ឡោះឱ្យពួកអ្នកស្តាប់ឮនូវអ្វីដែលយើងបានឮនៃទណ្ឌកម្មនៅក្នុងផ្នូរ”។ (មូស្លីមៈ២៨៦៨ ណាសាអ៊ីៈ២០៥៨)។ ហេតុនេះ ដោយសារតែគតិបណ្ឌិតនេះគ្មានទាក់ទងជាមួយនឹងសត្វពាហនៈទេនោះ សត្វពាហនៈបានស្តាប់ឮ និងអាចដឹងពីទណ្ឌកម្មនៅក្នុងផ្នូរ។

## ផលប្រយោជន៍នៃជំនឿចំពោះថ្ងៃបរលោក

1 ជំនឿចំពោះថ្ងៃបរលោកមានឥទ្ធិពលជាទីបំផុតក្នុងការចង្អុលបង្ហាញមនុស្សលោកឲ្យប្រកាន់ខ្ជាប់នឹងទង្វើកុសល និងការកោតខ្លាចចំពោះអល់ឡោះ ហើយជៀសវាងពីភាពអាត្មានិយម និងការសាងទង្វើកុសលដើម្បីចង់បង្ហាញឲ្យគេឃើញ។ នេះហើយជាហេតុនាំឲ្យមានការផ្សារភ្ជាប់រវាងជំនឿចំពោះថ្ងៃបរលោក និងទង្វើកុសលនៅកន្លែងជាច្រើនក្នុងគម្ពីរគួរអាន ដូចអល់ឡោះទ្រង់បានមានបន្ទូលថា៖ "ការពិតអ្នកដែលកសាង ឬថែទាំវិហាររបស់អល់ឡោះនោះ គឺមានតែអ្នកមានជំនឿលើអល់ឡោះ និងថ្ងៃបរលោកប៉ុណ្ណោះ"។ (គម្ពីរគួរអាន ៩:១៨)។ អល់ឡោះទ្រង់បានមានបន្ទូលទៀតថា៖ "ហើយបណ្ដាអ្នកដែលមានជំនឿនឹងថ្ងៃបរលោក គឺពួកគេមានជំនឿនឹងវា(គម្ពីរគួរអាន) ហើយពួកគេថែរក្សាសឡាតគ្រប់ពេលវេលា"។ (គម្ពីរគួរអាន ៦: ៩២)

2 ការដាស់តឿនចំពោះអ្នកដែលធ្វេសប្រហែស ងប់ងុលនឹងកិច្ចការជីវិត និងការត្រេកត្រអាលនៅក្នុងលោកិយដែលពួកគេមិនយកចិត្តទុកដាក់ពីការប្រកួតប្រជែងគ្នាក្នុងការប្រតិបត្តិ(សាងទង្វើកុសល) និងមិនយកចិត្តទុកដាក់ពីការឆ្លៀតពេលវេលាដើម្បីបញ្ជិតខ្លួនចំពោះអល់ឡោះដោយការប្រតិបត្តិឱ្យយល់ជីវិតឲ្យពិត និងរយៈពេលដ៏ខើចខ្លីនៃជីវិត ហើយថ្ងៃបរលោកគឺជាទីកន្លែងឋិតថេរនិងអមតៈ។ ខណៈដែលអល់ឡោះទ្រង់កោតសរសើរលើអ្នកនាំសារក្នុគម្ពីរគួរអាន និងរំឭកទង្វើរបស់ពួកគេ ទ្រង់សរសើរពួកគេជាមួយនឹងមូលហេតុដែលជម្រុញពួកគេឱ្យសាងទង្វើល្អនិងកុសលធម៌ ទ្រង់មានបន្ទូលថា៖ "ពិតណាស់ យើងបានជ្រើសរើសពួកគេជាពិសេសដោយយើងធ្វើឲ្យការរំឭកចំពោះថ្ងៃបរលោកឋិតក្នុងដួងចិត្តពួកគេ"។(គម្ពីរគួរអាន ៣៨:៤៦) ។បានសេចក្ដីថាមូលហេតុនៃទង្វើល្អនោះ គឺដោយសារពួកគេមានលក្ខណៈពិសេសក្នុងការនឹករឭកចំពោះថ្ងៃបរ-លោក។ ដូច្នេះ ការរឭកនេះជំរុញឲ្យពួកគេសាងអំពើល្អ និងកិច្ចការទាំងនោះ ។ហើយនៅពេលដែលអ្នកមូស្លីមខ្ជិលច្រអូសព្រងើយកន្តើយពីការប្រតិបត្តិតាមបទបញ្ជារបស់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់នោះ ទ្រង់ក៏មានបន្ទូលដាស់តឿនពួកគេថា៖ "តើពួកអ្នកពេញចិត្តនឹងការរស់នៅក្នុងលោកិយជាងបរលោកឬ? ប៉ុន្តែសុភមង្គលនៃការរស់នៅក្នុងលោកិយមិនអាចប្រៀបនឹងថ្ងៃបរលោកបានទេ លើកលែងតែបន្តិចបន្តួចប៉ុណ្ណោះ"។ (គម្ពីរគួរអាន ៩:៣៨)។ នៅពេលដែលមនុស្សលោកជឿចំពោះថ្ងៃបរលោក គេពិតជាដឹងច្បាស់ថា គ្រប់ពរជ័យទាំងអស់នៅលើលោកិយមិនអាចប្រៀបផ្ទឹមនឹងពរជ័យនៅថ្ងៃបរលោកបានឡើយ។ម្យ៉ាងទៀត សេចក្ដីសុខក្នុងលោកិយមិនអាចប្រៀបនឹងការជ្រលក់ចូលម្ដងក្នុងទណ្ឌកម្មនៅបរលោកនោះទេ។ គ្រប់ទណ្ឌកម្ម(ការលំបាក)នៅលើលោកិយ(ក្នុងការគោរពតាមមាគ៌ារបស់អល់ឡោះ)មិនអាចប្រៀបផ្ទឹមទៅនឹងទណ្ឌកម្មនៅថ្ងៃបរលោកបានឡើយ។ ម្យ៉ាងវិញទៀត ទុក្ខលំបាកក្នុងលោកិយក៏មិនអាចប្រៀបនឹងការជ្រលក់ម្ដងចូលក្នុងបរមសុខនៅបរលោកនោះដែរ។

3 ភាពស្កប់ស្កល់៖ គឺមនុស្សលោកទទួលបានចំណែករបស់ខ្លួន។ បើសិនជាសម្បត្តិណាមួយនៃជីវិតរស់នៅរបស់គេលើលោកិយបានបាត់បង់នោះ គេពុំត្រូវអស់សង្ឃឹម ហើយពុំត្រូវធ្វើអត្តឃាតដោយសារការកើតទុក្ខនោះទេ។ ផ្ទុយទៅវិញ គេត្រូវតែព្យាយាមតស៊ូ ហើយជឿជាក់ថា អល់ឡោះមិនបំបាត់ផលបុណ្យពីអ្នកសាងទង្វើកុសលឡើយ។ ទោះបីជាត្រូវគេបំពាន ឬបោកប្រាស់ប៉ុនគ្រាប់ស្ពៃក៏ដោយ គឺទ្រង់នឹងផ្ដល់ឲ្យវិញនូវអ្វីដែលគេត្រូវការចាំបាច់បំផុតនៅថ្ងៃបរលោក។ តើគេកើតទុក្ខម្ដេចនឹងកើតបើគេដឹងថា ចំណែករបស់គេនឹងមកដល់គេវិញដោយគ្មានការសង្ស័យនៅក្នុងគ្រាដែលគ្រោះថ្នាក់បំផុតនោះ? តើគេព្រួយបារម្ភម្ដេចកើតបើគេដឹងថា អ្នកដែលកាត់ក្ដីរវាងគេនិងគូវិវាទរបស់គេ គឺទ្រង់ជាអ្នកកាត់ក្ដីដ៏យុត្តិធម៌បំផុតនោះ?

# > ជំនឿចំពោះព្រះលិខិត

## អត្ថន័យនៃជំនឿចំពោះព្រះលិខិត

គឺការជឿជាក់យ៉ាងដាច់ខាតថា រាល់រឿងល្អ និងរឿងអាក្រក់ វាគឺជាការកំណត់(នៅក្នុងព្រះលិខិត) របស់អល់ឡោះរួចជាស្រេច ហើយទ្រង់ធ្វើនូវអ្វីដែលទ្រង់ប្រាថ្នា។ អ្វីក៏ដោយមិនអាចកើតឡើងបានឡើយ លុះត្រាតែទ្រង់ប្រាថ្នាឲ្យវាកើតឡើង។ អ្វីក៏ដោយមិនអាចចេញផុតពីចេតនារបស់ទ្រង់បានឡើយ។ ហើយអ្វីក៏ដោយនៅក្នុងភព(ចក្រវាល)ទាំងអស់មិនអាចចេញផុតពីការកំណត់របស់ទ្រង់បានឡើយ។ គ្មានអ្វីអាចកើតឡើង លើកលែងតែតាមការរៀបចំរបស់ទ្រង់។ ជាមួយគ្នានេះ ទ្រង់បានដាក់បញ្ញា និងបម្រាមចំពោះខ្ញុំរបស់ទ្រង់ទាំងអស់ ហើយទ្រង់បើកសិទ្ធិឲ្យពួកគេជ្រើសរើសតាមចិត្តសម្រាប់រាល់ទង្វើរបស់ពួកគេ ដោយគ្មានការបង្ខិតបង្ខំឡើយ។ ផ្ទុយទៅវិញ ទង្វើរបស់ពួកគេកើតឡើងអាស្រ័យទៅតាមលទ្ធភាព និងចេតនារបស់ពួកគេផ្ទាល់ខ្លួន។ អល់ឡោះទ្រង់ជាអ្នកបង្កើតពួកគេ និងលទ្ធភាពរបស់ពួកគេ។ ទ្រង់ចង្អុលបង្ហាញជនណាដែលទ្រង់មានចេតនា ហើយទ្រង់ធ្វើឲ្យវង្វេងចំពោះជនណាដែលទ្រង់មានចេតនាដែរ ដោយគតិបណ្ឌិតរបស់ទ្រង់។ ទ្រង់មិនត្រូវគេសួរដេញដោលនូវអ្វីដែលទ្រង់ធ្វើឡើយ តែពួកគេទេដែលត្រូវគេ(អល់ឡោះ)សួរដេញដោលនោះ។

## តើជំនឿចំពោះព្រះលិខិតមានអ្វីខ្លះ?

ជំនឿចំពោះព្រះលិខិតមាន៤ប្រការៈ

- ជំនឿថា អល់ឡោះទ្រង់ដឹងនូវអ្វីគ្រប់យ៉ាងជាលក្ខណៈរួម និងពិស្ដារ។ ទ្រង់ដឹងចំពោះម៉ាខ្លូករបស់ទ្រង់ទាំងអស់ តាំងពីលាភសក្ការៈ ពេលវេលានៃការស្លាប់ ពាក្យសំដី និងទង្វើរបស់ពួកគេមុននឹងទ្រង់បង្កើតពួកគេ។ ទ្រង់ដឹងពីការកម្រើក និងការនៅស្ងៀមរបស់ពួកគេ។ ទ្រង់ដឹងពីប្រការអាថ៌កំបាំង និងការលាតត្រដាងរបស់ពួកគេ អ្នកណាដែលនៅក្នុងចំណោមពួកអ្នកឋានសួគ៌ និងអ្នកណាដែលនឹងស្ថិតក្នុងចំណោមពួកឋាននរក។ អល់ឡោះទ្រង់មានបន្ទូលថាៈ “ទ្រង់គឺអល់ឡោះជាម្ចាស់ ដែលគ្មានម្ចាស់ណាត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់ជាម្ចាស់ដែលដឹងនូវការអាថ៌កំបាំង និងការលាតត្រដាង”។ (គម្ពីរគួរអាន ៥៩:២២)
- ជំនឿថា ទ្រង់ពិតជាបានសរសេរនៅក្នុងគម្ពីរ "ឡាវហ៊ុលម៉ះហ្វ៊ូស" (សៀវភៅដែលកត់ត្រាអ្វីៗគ្រប់បែបយ៉ាងទាំងអស់)នូវអ្វីដែលទ្រង់បានដឹងរួចជាមុន។ ភស្តុតាងគឺពាក្យបន្ទូលរបស់ទ្រង់ថាៈ “គ្មានគ្រោះថ្នាក់ណាមួយបានធ្លាក់មកលើផែនដី ហើយក៏គ្មានគ្រោះថ្នាក់ណាមួយបានធ្លាក់ទៅលើពួកអ្នក លើកលែងតែបានកត់ត្រាទុកក្នុងគម្ពីរ(ឡាវហុលម៉ះហ្វ៊ូស) មុននឹងយើងបានបង្កើតវា”។ (គម្ពីរគួរអាន ៥៧:២២)

ហើយព្យាការីបានមានប្រសាសន៍ថាៈ “អល់ឡោះទ្រង់បានលិខិតកំណត់ចំពោះម៉ាខ្លូកទាំងអស់មុននឹងទ្រង់បង្កើតមេឃ និងផែនដីចំនួនប្រាំម៉ឺនឆ្នាំ”។ (មូស្លីមៈ២៦៥៣)

- ជំនឿថា ចេតនារបស់អល់ឡោះគឺត្រូវតែកើតឡើង គ្មានអ្វីអាចរារាំងបាន ហើយអានុភាពរបស់ទ្រង់គ្មានអ្វីអាចយកឈ្នះបានដែរ។ គ្រប់ហេតុការណ៍ទាំងអស់កើតឡើងអាស្រ័យទៅតាមចេតនា និងអានុភាពរបស់ទ្រង់។ អ្វីដែលទ្រង់មានចេតនា

> ជំនឿចំពោះព្រះលិខិតរបស់អល់ឡោះជាគោលគ្រឹះមួយក្នុងចំណោមគ្រឹះជំនឿ(ទាំងប្រាំមួយ) ដូចមាននៅក្នុងចម្លើយរបស់អ្នកនាំសារនៅពេលដែលទេវៈជីព្រីលសួរគាត់អំពីជំនឿ គាត់ឆ្លើយថាៈ “អ្នកត្រូវជឿចំពោះអល់ឡោះ បណ្ដាម៉ាឡាអ៊ីកាត់របស់ទ្រង់ បណ្ដាព្រះគម្ពីររបស់ទ្រង់ បណ្ដាអ្នកនាំសាររបស់ទ្រង់ ជឿចំពោះថ្ងៃបរលោក និជឿចំពោះព្រះលិខិតល្អ អាក្រក់”។ (មូស្លីមៈ៨)

គឺត្រូវតែកើតឡើង ហើយអ្វីដែលទ្រង់គ្មានចេតនា គឺមិនអាចកើតឡើងជាដាច់ខាត។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ហើយពួកអ្នកមិនអាចមានបំណងធ្វើអ្វីមួយបានឡើយ លើកលែងតែអល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពទាំងអស់មានចេតនាប៉ុណ្ណោះ”។ (គម្ពីរគួរអាន ៨១:២៩)

- ជំនឿថា អល់ឡោះជាអ្នកបង្កើតឲ្យមានអ្វីៗគ្រប់យ៉ាងទាំងអស់។ ទ្រង់ជាអ្នកបង្កើតតែមួយគត់។អ្វីដែលក្រៅពីទ្រង់គឺជាម៉ាខ្លូក(ការបង្កើត)របស់ទ្រង់។ទ្រង់មានអានុភាពលើអ្វីៗទាំងអស់។ អល់ឡោះទ្រង់បានមានបន្ទូលថាៈ “ហើយទ្រង់បានបង្កើតនូវរាល់អ្វីៗទាំងអស់។ បន្ទាប់មកទ្រង់បានកំណត់វាយ៉ាងសុក្រឹតឥតខ្ចោះ”។ (គម្ពីរគួរអាន ២៥:២)

## មនុស្សលោកមានសិទ្ធិជ្រើសរើស មានលទ្ធភាព និងចេតនាខ្លួនឯង

ជំនឿចំពោះព្រះលិខិត គឺមិនមែនបដិសេធចេតនារបស់មនុស្សក្នុងការធ្វើទង្វើអ្វីមួយតាមជម្រើសរបស់គេនោះទេ ហើយក៏មិនបដិសេធលទ្ធភាពនៃការជ្រើសរើសផងដែរ ពីព្រោះតាមច្បាប់ និងភាពជាក់ស្ដែងបានបញ្ជាក់យ៉ាងដូច្នោះ។

តាមច្បាប់ គឺអល់ឡោះទ្រង់មានបន្ទូលពីចេតនាថា៖ “នោះគឺជាថ្ងៃដែលនឹងកើតឡើងយ៉ាងពិតប្រាកដ។ ដូច្នេះ ជនណាហើយចង់(គេចផុតពីភាពលំបាកនៅថ្ងៃបរលោក)នោះ ចូរឲ្យគេជ្រើសរើសកន្លែងវិលត្រឡប់ទៅកាន់ម្ចាស់របស់គេចុះ”។ (គម្ពីរគួរអាន ៧៨:៣៩)

ហើយអល់ឡោះទ្រង់មានបន្ទូលពីលទ្ធភាពថា៖ “អល់ឡោះមិនដាក់បន្ទុកលើអ្នកណាម្នាក់ហួសពីលទ្ធភាពរបស់គេឡើយ។អ្នកណាបានសាងអំពើល្អ គឺទទួលបានផលល្អ ហើយអ្នកណាបានសាងអំពើអាក្រក់គឺទទួលបានផលអាក្រក់”។ (គម្ពីរគួរអាន ២:២៨៦)

រីឯភាពជាក់ស្ដែងវិញ គឺមនុស្សគ្រប់រូបមានចេតនា និងលទ្ធភាពប្រព្រឹត្ត ឬមិនប្រព្រឹត្ត (ទៅតាមចេតនា និងលទ្ធភាពរបស់គេ)។ គេអាចបែងចែករវាងអ្វីដែលកើតឡើងតាមចេតនារបស់គេ ដូចជាការដើរ និងអ្វីដែលកើតឡើងដោយគេគ្មានចេតនា ដូចជាសេចក្ដីភ័យខ្លាច ការដួលភ្លាមៗ។ក៏ប៉ុន្តែចេតនារបស់មនុស្សនិងលទ្ធភាពរបស់គេកើតឡើងទៅតាមចេតនារបស់អល់ឡោះ និងអានុភាពរបស់ទ្រង់ ដូចអល់ឡោះទ្រង់មានបន្ទូលថាៈ “សម្រាប់អ្នកណាដែលមានបំណងចង់ដើរលើមាគ៌ាដ៏ត្រឹមត្រូវក្នុងចំណោមពួកអ្នក ហើយពួកអ្នកមិនអាចមានបំណងធ្វើអ្វីមួយបានឡើយ លើកលែងតែអល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពទាំងអស់មានចេតនាប៉ុណ្ណោះ”។ (គម្ពីរគួរអាន ៨១:២៨-២៩)

ក្នុងវាក្យខណ្ឌនេះ គឺទ្រង់បញ្ជាក់ពីបំណង និងចេតនារបស់មនុស្ស បន្ទាប់មកទ្រង់បញ្ជាក់ទៀតថា បំណងនិងចេតនា(របស់មនុស្ស) គឺនៅក្នុងចេតនារបស់ទ្រង់ ពីព្រោះចក្រវាលទាំងមូលគឺជាកម្មសិទ្ធិរបស់អល់ឡោះ។ គ្មានអ្វីដែលនៅក្នុងកម្មសិទ្ធិរបស់ទ្រង់ដោយទ្រង់ពុំបានដឹង និងទ្រង់ពុំមានចេតនានោះទេ។




> ពិតប្រាកដណាស់ យើងបានចង្អុលបង្ហាញគេនូវមាគ៌ាដ៏ត្រឹមត្រូវ។ គេអាចជាអ្នកដឹងគុណ ឬជាអ្នករមិលគុណ។ (គម្ពីរគួរអាន ៧៦:៣)

## យកលេសនឹងព្រះលិខិត

ការដាក់បន្ទុក បទបញ្ជា និងបម្រាម គឺអាស្រ័យទៅតាមលទ្ធភាព និងការជ្រើសរើសរបស់មនុស្សដែលអាចអនុវត្តទៅបាន។ គេប្រទានផលបុណ្យចំពោះអ្នកធ្វើអំពើល្អ តាមការជ្រើសរើសរបស់គេនូវមាគ៌ាដែលមានការចង្អុលបង្ហាញ ហើយគេធ្វើទណ្ឌកម្មចំពោះអ្នកធ្វើអំពើអាក្រក់តាមការជ្រើសរើសរបស់គេនូវមាគ៌ាដែលវង្វេង។

អល់ឡោះទ្រង់មិនបានដាក់បន្ទុកលើយើងទេ លើកលែងតែអ្វីដែលពួកយើងមានលទ្ធភាព ហើយទ្រង់មិនទទួលយកពីអ្នកណាម្នាក់ដែលបោះបង់ការគោរពសក្ការៈចំពោះទ្រង់ដោយអាងលេសថា ជាព្រះលិខិតនោះទេ។

បន្ទាប់មកទៀតគឺមនុស្សលោកមុននឹងប្រព្រឹត្តបាបកម្ម គឺគេពុំបានដឹងទេ អ្វីជាចំណេះដឹង និងអ្វីជាការកំណត់របស់អល់ឡោះ? ហើយអល់ឡោះទ្រង់ប្រទានចំពោះគេនូវលទ្ធភាព និងការជ្រើសរើស។ ទ្រង់បានបំភ្លឺចំពោះគេនូវផ្លូវល្អ និងផ្លូវអាក្រក់។ ដូច្នេះ បើសិនជាគេប្រព្រឹត្តបាបកម្មនោះ គឺគេជាអ្នកជ្រើសរើសបាបកម្មដោយខ្លួនឯង គេសម្រេចចិត្តយកការប្រព្រឹត្តបាបកម្មជាជាងការប្រព្រឹត្តតាម(ការធ្វើអំពើល្អ)។ ដូច្នេះ គេត្រូវតែទទួលទណ្ឌកម្មចំពោះការប្រព្រឹត្តបាបកម្មរបស់គេដោយខ្លួនឯង។



> ប្រសិនបើមនុស្សម្នាក់បានបំពានទៅលើអ្នក ហើយបានយកទ្រព្យសម្បត្តិរបស់អ្នក និងបានប៉ះពាល់ឲ្យរបួសដល់អ្នក បន្ទាប់មក គេបានសុំអភ័យទោសពីអ្នកដោយប្រើលេសថា វាគឺជាវាសនាដែលត្រូវបានកំណត់រួច ប្រាកដជាអ្នកមិនអាចទទួលការសុំអធ្យាស្រ័យអំពីទង្វើដ៏ថោកទាបនេះនោះឡើយ ហើយប្រាកដជាអ្នកនឹងដាក់ទណ្ឌកម្មដល់ជននោះ ហើយដកយកអ្វីដែលជាកម្មសិទ្ធិរបស់អ្នកពីគេវិញហើយ ពីព្រោះគេបានធ្វើបែបនោះដោយការជ្រើសរើសរបស់គេនិងដោយចេតនារបស់គេផ្ទាល់។

### ផលប្រយោជន៍នៃជំនឿលើព្រះលិខិត

ផលប្រយោជន៍នៃជំនឿលើព្រះលិខិត គឺធំធេងណាស់នៅក្នុងជីវិតរបស់មនុស្សដូចជា៖

1 ព្រះលិខិត គឺជាកត្តាជម្រុញលើកទឹកចិត្តដ៏ធំបំផុត(ដល់មនុស្ស)ចំពោះការងារ ភាពសកម្មក្លៀវក្លា និងការខិតខំស្វែងរកនូវអ្វីដែលអល់ឡោះអនុញ្ញាតយល់ព្រមសម្រាប់ជីវិតរស់នៅលើលោកិយនេះ។

អ្នកមានជំនឿទាំងអស់ត្រូវបានគេបង្គាប់ឲ្យយកហេតុជាបច្ច័យជាមួយនឹងការជឿទុកចិត្តលើអល់ឡោះ ហើយត្រូវមានជំនឿថា មូលហេតុមិនបានផ្តល់ផលអ្វីឡើយ លុះត្រាតែមានការអនុញ្ញាតពីអល់ឡោះ ពីព្រោះទ្រង់គឺជាអ្នកបង្កើតមូលហេតុ និងលទ្ធផលទាំងឡាយ។

អ្នកនាំសារបានមានប្រសាសន៍ថាៈ “ចូរអ្នកខិតខំធ្វើអ្វីដែលផ្តល់ផលប្រយោជន៍ដល់អ្នក។ ចូរអ្នកសុំជំនួយពីអល់ឡោះ ហើយចូរអ្នកកុំខ្ជិលច្រអូស។ ប្រសិនបើមានអ្វីកើតឡើងចំពោះអ្នក ចូរអ្នកកុំពោលពាក្យថាៈ ប្រសិនបើខ្ញុំបានធ្វើដូច្នេះនឹងបានដូច្នេះ ប្រសិនបើខ្ញុំដូច្នោះនឹងបានដូច្នោះ ក៏ប៉ុន្តែអ្នកត្រូវពោលថាៈ អល់ឡោះបានដាក់កំណត់រួចជាស្រេច ហើយអ្វីៗដែលទ្រង់មានចេតនា វានឹងកើតឡើង។ ពិតណាស់(ពាក្យថា) ”ប្រសិនបើ” គឺវាបើកផ្លូវឲ្យសកម្មភាពរបស់បិសាចស្ហៃតន(ញុះញង់មនុស្សលោក)”។ (មូស្លីមៈ២៦៦៤)

2 មនុស្សលោកត្រូវដឹងពីលទ្ធភាពខ្លួនឯង គេមិនត្រូវមានអំនួត ក្រអឺតក្រទម ពីព្រោះគេគ្មានលទ្ធភាពដឹងនូវអ្វីដែល(ព្រះលិខិត)បានកំណត់រួចជាស្រេច ហើយនៅពេលអនាគតគេ ក៏គេពុំបានដឹងនូវអ្វីដែលនឹងកើតឡើងដែរ។ ដូច្នេះ មនុស្សលោកត្រូវតែទទួលស្គាល់នូវការអសមត្ថភាពរបស់ខ្លួន និងភាពខ្វះខាតរបស់គេ និងត្រូវការម្ចាស់របស់គេជារៀងរហូត។

កាលណាមនុស្សលោកទទួលបានប្រការល្អ គេមានអំនួត ត្រេកត្រអាល ហើយកាលណាគេទទួលបានប្រការអាក្រក់និងគ្រោះថ្នាក់ គេខឹងច្រឡោត កើតទុក្ខព្រួយ។ គ្មានអ្វីអាចរក្សាមនុស្សលោកពីការមានអំនួតហួសហេតុនៅពេលដែលគេទទួលបានប្រការល្អ និងការកើតទុក្ខព្រួយនៅពេលដែលគេទទួលបានប្រការអាក្រក់បានឡើយ មានតែការមានជំនឿលើព្រះលិខិតនេះប៉ុណ្ណោះ។ ពិតណាស់ អ្វីៗដែលកើតឡើង គឺប្រព្រឹត្តទៅតាមព្រះលិខិតដែលបានកំណត់រួចជាស្រេច ហើយអល់ឡោះទ្រង់បានដឹងតាំងពីមុនមកហើយ។

3 ជំនឿលើព្រះលិខិតគឺវាបំបាត់អពមង្គលនៃការច្រណែនឈ្នានីស។ អ្នកមានជំនឿ គឺមិនច្រណែនឈ្នានីសនូវអ្វីៗដែលអល់ឡោះទ្រង់បានផ្តល់ចំពោះមនុស្សលោកនៃភាពល្អប្រសើរឡើយ ពីព្រោះទ្រង់ជាអ្នកដែលផ្តល់លាភសក្ការៈ និងកំណត់សម្រាប់ពួកគេរួចទៅហើយ។ អ្នកមានជំនឿក៏ដឹងទៀតថា នៅពេលដែលគេច្រណែនឈ្នានីសអ្នកដទៃនោះ គឺជាការប្រឆាំងនឹងព្រះលិខិតរបស់អល់ឡោះ និងការកំណត់របស់ទ្រង់។

4 ជំនឿលើព្រះលិខិត ជម្រុញចិត្តឲ្យមានភាពក្លាហានក្នុងការប្រឈមមុខនឹងឧបសគ្គ ហើយពង្រឹងឆន្ទៈ ពីព្រោះក្នុងចិត្តជឿជាក់យ៉ាងច្បាស់ថា ពេលកំណត់(នៃសេចក្តីស្លាប់) លាភសក្ការៈ គឺបានកំណត់រួចជាស្រេច ហើយគ្មានអ្វីកើតឡើងចំពោះមនុស្សក្រៅពីអ្វីដែលគេបានលិខិតកំណត់រួចជាស្រេចសម្រាប់គេនោះឡើយ។

5 ជំនឿលើព្រះលិខិត គឺវាបណ្តុះផ្នត់គំនិតអ្នកមានជំនឿនូវធាតុពិតជាច្រើននៃជំនឿ ធ្វើឲ្យគេជានិច្ចកាលតែងតែសុំជំនួយពីអល់ឡោះ ពឹងផ្អែក និងជឿទុកចិត្តលើទ្រង់ជាមួយនឹងការយកហេតុជាបច្ច័យ ហើយគេជានិច្ចកាល គេតែងតែត្រូវការទ្រង់ផងដែរ ដើម្បីសុំជំនួយឱ្យមានជំហររឹងមាំ។

6 ជំនឿលើព្រះលិខិតនាំឲ្យមានភាពស្កប់ស្កល់ក្នុងខ្លួន។ អ្នកមានជំនឿដឹងថា អ្វីដែលត្រូវកើតឡើងចំពោះរូបគេគឺវាមិនអាចទៅណាខុសពីគេបានទេ ហើយអ្វីដែលត្រូវកើតឡើងលើអ្នកដទៃក្រៅពីរូបគេនោះក៏មិនអាចកើតឡើងចំពោះរូបគេបាននោះដែរ។



# ជំពូក២ អនាម័យរបស់អ្នក



# 2

ព្រះអល់ឡោះជាម្ចាស់បានបង្គាប់ឲ្យជនមូស្លីមធ្វើការជម្រះសម្អាតចិត្តរបស់គេពីទង្វើស៊ីរិក(ពហុទេពនិយម)និងជំងឺផ្លូវចិត្តដូចជាការច្រណែនឈ្នានីស ក្រអឺតក្រទម និងការចងគំនុំនឹងគ្នា។ល។ ហើយធ្វើការជម្រះសម្អាតខ្លួនប្រាណរបស់គេពីភាពកខ្វក់។ ប្រសិនបើបុគ្គលណាបានធ្វើដូច្នោះ គេពិតជាទទួលបាននូវការអាណិតស្រលាញ់ពីព្រះជាម្ចាស់ជាមិនខាន ដូចទ្រង់បានមានបន្ទូលថាៈ ពិតណាស់ អល់ឡោះស្រលាញ់បណ្ដាអ្នកដែលសារភាពទោសកំហុស និងស្រលាញ់បណ្ដាអ្នកជ្រះស្អាត”។ (គម្ពីរគួរអាន ២:២២២)

## មាតិកាជំពូក

### និយមន័យនៃពាក្យ ការជម្រះសម្អាត

### ជម្រះសម្អាតពីភាពកខ្វក់

- ការសម្អាតភាពកខ្វក់
- សុជីវធម៌ក្នុងការបន្ទោបង់ និងការសម្អាត

### អាល់ហាហ្ទាស(ភាពកខ្វក់ផ្នែកបញ្ញត្តិច្បាប់)

- ហាហ្ទាសតូច និងការយកទឹកជម្រះកាយ(ទឹកវ៉ូហ្ទុ)

### តើខ្ញុំយកទឹកជម្រះកាយយ៉ាងដូចម្ដេច?

- ការបំបាត់ហាហ្ទាសតូច
- ហាហ្ទាសធំនិងការងូតទឹក
- តើអ្នកមូស្លីមសម្អាតខ្លួនពីជូនុប ឬហាហ្ទាសធំយ៉ាងដូចម្ដេច?
- អ្នកដែលគ្មានលទ្ធភាពប្រើប្រាស់ទឹក

# > និយមន័យនៃពាក្យ ការជម្រះសម្អាត

ន័យដើមរបស់ពាក្យ ការជម្រះសម្អាត(អាត់តហារ៉ោះ) គឺភាពស្អាតស្អំ អនាម័យ និងជ្រះថ្លា។

ពិតណាស់ អល់ឡោះទ្រង់បានបង្គាប់ប្រើលើជនមូស្លីមឲ្យធ្វើការជម្រះសម្អាតខ្លួនប្រាណ និងចិត្តរបស់គេ។ ហេតុនេះ គេត្រូវសម្អាតខ្លួនប្រាណរបស់គេពីរាល់ប្រការណាដែលកខ្វក់ និងសម្អាតចិត្តរបស់គេពីប្រការស៊ីរិក(ពហុទេពនិយម) និងការច្រណែនគុំគួនគ្នាទៅវិញទៅមក។ ប្រសិនបើបុគ្គលណាបានធ្វើដូច្នោះ គេពិតជាទទួលបានការអាណិតស្រលាញ់ពីអល់ឡោះជាម្ចាស់ ដូចដែលទ្រង់បានមានបន្ទូលថា ៖

"ពិតណាស់ អល់ឡោះស្រលាញ់បណ្ដាអ្នកដែលសារភាពទោសកំហុសនិងស្រលាញ់បណ្ដាអ្នកដែលជ្រះស្អាត"។ (គម្ពីរគួរអាន ២:២២២)

ហើយទ្រង់បានបង្គាប់ឲ្យធ្វើការជម្រះសម្អាតដើម្បីប្រតិបត្តិសឡាត(ថ្វាយបង្គំ) ពីព្រោះការសឡាត គឺជាការបួងសួងចំពោះទ្រង់។ ជាធម្មតាមនុស្សគ្រប់រូប នៅពេលទៅជួបស្ដេចឬប្រធានណាម្នាក់ គេពិតជាជ្រើសរើសសម្លៀកបំពាក់យ៉ាងល្អស្អាតជាមិនខាន។ ចុះយ៉ាងដូចម្ដេចវិញសម្រាប់អ្នកដែលទៅជួបនឹងម្ចាស់នៃស្ដេចទាំងឡាយ ជាម្ចាស់ដ៏មហាស្អាតស្អំបំផុតនោះ។

## តើអ្វីជាការសម្អាតដែលគេទាមទារចង់បានសម្រាប់សឡាត(ថ្វាយបង្គំ)?

នៅពេលណាដែលជនមូស្លីមចង់ប្រតិបត្តិសឡាត(ថ្វាយបង្គំ) ឬកាន់គម្ពីរគួរអាន ឬតវ៉ាហ្វ(ដើរប្រទក្សិណ)ជុំវិញកាក់ហ្ពះ គឺចាំបាច់ត្រូវធ្វើការជម្រះសម្អាត។ ចំពោះកន្លែងផ្សេងទៀតដែលទ្រង់ជម្រុញឲ្យធ្វើការជម្រះសម្អាតដែរនោះ ដូចជា ការសូត្រគម្ពីគួរអានដោយមិនកាន់គម្ពីរ ការបួងសួង និងនៅគេងជាដើម។

ដូច្នេះ ចាំបាច់លើជនមូស្លីមនៅពេលដែលគេចង់សឡាត(ថ្វាយបង្គំ) គេត្រូវជម្រះសម្អាតអំពីពីរប្រការៈ

1. ប្រការកខ្វក់
2. អាល់ហាហ្វាស



> អល់ឡោះបានបញ្ជារជនមូស្លីមឲ្យជម្រះសម្អាតចិត្តរបស់គេឲ្យជ្រះស្អាតអំពីប្រការស្ហ៊ីរិក និងអំពីជំងឺផ្លូវចិត្ត ហើយនិងសម្អាតផ្នែកខាងក្រៅរបស់គេឲ្យជ្រះស្អាតអំពីប្រការដែលត្រូវបានហាមឃាត់ និងប្រការដែលកខ្វក់ទាំងឡាយ។

# > ការជម្រះសម្អាតពីប្រការកខ្វក់

- ប្រការកខ្វក់ គឺវត្ថុរូបីទាំងឡាយដែលច្បាប់បានចែងថាវាកខ្វក់ ហើយបានបង្គាប់ប្រើឲ្យយើងជម្រះសម្អាតវា ដើម្បីធ្វើការគោរពសក្ការៈចំពោះទ្រង់។
- ជាគោលការណ៍ អ្វីៗគ្រប់យ៉ាងគឺត្រូវបានច្បាប់អនុញ្ញាត និងមានភាពជ្រះស្អាត ហើយភាពកខ្វក់ វាទើបតែកើតឡើងប៉ុណ្ណោះ។ ហេតុនេះប្រសិនបើយើងមានការមន្ទិលសង្ស័យចំពោះភាពស្អាតស្អំនៃសម្លៀកបំពាក់របស់យើង ហើយយើងមិនប្រាកដច្បាស់ថា វាមានភាពកខ្វក់ទេនោះ ជាគោលការណ៍ គឺវាជ្រះស្អាត។
- បើសិនជាយើងចង់ប្រតិបត្តិសឡាត(ថ្វាយបង្គំ) គឺចាំបាច់លើយើងត្រូវជម្រះសម្អាតខ្លួនប្រាណ និងសម្លៀកបំពាក់ ព្រមទាំងទីកន្លែងដែលយើងចង់សឡាត (ថ្វាយបង្គំ)។

## ប្រការដែលកខ្វក់នោះគឺៈ

| | |
|---|---|
| 1 | លាមក និងទឹកនោមរបស់មនុស្ស |
| 2 | ឈាម តែគេអនុគ្រោះចំពោះឈាមបន្តិចបន្តួច |
| 3 | លាមកស្ងួត និងទឹកនោមសត្វដែលគេហាមមិនឲ្យបរិភោគសាច់របស់វា (មើលទំព័រ១៨៩) |
| 4 | សត្វឆ្កែនិងជ្រូក |
| 5 | សាកសពសត្វ(រាល់សត្វងាប់ទាំងឡាយលើកលែងតែសត្វដែលគេអនុញ្ញាតឲ្យបរិភោគវានៅពេលគ្រេសទ្បេះវាតាមច្បាប់ឥស្លាម ចូរមើលទំព័រ១៩០)។ ចំណែកសាកសពមនុស្សនិងត្រី សត្វល្អិតគឺវាមានភាពជ្រះស្អាត។ |

## ការជម្រះសម្អាតពីប្រការកខ្វក់

ការលាងជម្រះភាពកខ្វក់ដែលប្រឡាក់លើខ្លួនប្រាណ សម្លៀកបំពាក់ ទីកន្លែង គឺយើងគ្រាន់តែលាងវាឱ្យបាត់សារជាតុកខ្វក់ពីរបស់ដែលប្រឡាក់នោះបានហើយ ទោះដោយប្រើវិធីណាក៏ដោយ ទោះដោយប្រើទឹក ឬអ្វីផ្សេងទៀត ពីព្រោះច្បាប់ប្រើឱ្យបំបាត់វា ហើយមិនបានដាក់លក្ខខណ្ឌឱ្យលាងជម្រះភាពកខ្វក់នោះចំនួនណាមួយជាក់លាក់ដែរ លើកលែងតែ ទឹកមាត់លាមក និងទឹកនោមសត្វឆ្កែប៉ុណ្ណោះដែលយើងត្រូវលាងវាចំនួនប្រាំពីរដង លើកទីមួយត្រូវប្រើទឹកលាយដី។ ចំណែកប្រការកខ្វក់ផ្សេងទៀត គឺយើងគ្រាន់តែលាងវាឲ្យបាត់សារជាតុកខ្វក់ប៉ុណ្ណោះ ហើយក្លិននិងពណ៌របស់វាគ្មានបញ្ហាអ្វីទេ ដូចព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ទៅកាន់នារីម្នាក់ដែលនាងបានលាងឈាមរដូវរបស់នាងថាៈ នាងគ្រាន់តែលាងឈាមបានហើយ ហើយស្នាមរបស់វាគឺគ្មានបញ្ហាអ្វីឡើយ។

(អាពូហ្ទាវូទៈ៣៦៥។)



> គ្រប់គ្រាន់ហើយក្នុងការបំបាត់ភាពកខ្វក់នោះ ឲ្យកចាត់ជាតួរបស់វាដោយរបស់បំបាត់ភាពកខ្វក់ណាមួយក៏បានដែរ។

## សុជីវធម៌ក្នុងការបន្ទោបង់និងការសម្អាត

- នៅពេលគេចូលបង្គន់ គប្បីត្រូវចាប់ផ្ដើមដោយជើងឆ្វេង រួចសូត្រថា:

(بسم الله، اللهم إني أعوذ بك من الخبث والخبائث)

(ពិសមិលឡះ អល់ឡហ៊ុមម៉ា អ៊ិននី អាអ៊ូហ្សុពីកា មីណាល់ឃុបហ្ស៊ី វ៉ាល់ខហ្ពាអ៊ិស)

"ក្នុងនាមអល់ឡោះ! ឱអល់ឡោះជាម្ចាស់! សូមទ្រង់បញ្ចៀសរូបខ្ញុំពីស្ទែតនឈ្មោលនិងស្ទែតនញីផងចុះ"។

- ហើយនៅពេលគេចេញពីបង្គន់វិញ គប្បីត្រូវចាប់ផ្ដើមដោយជើងស្ដាំ ហើយសូត្រថា

(غفرانك)

(ហ្គុហ្វរ៉ណាកា)

"សូមទ្រង់អភ័យទោសផងចុះ"។

- ចាំបាច់ត្រូវបិទបាំងខ្លួនប្រាណរបស់គេពីក្រសែភ្នែកមនុស្សនៅពេលកំពុងបន្ទោបង់។
- កុំបន្ទោបង់នៅទីកន្លែងណាដែលធ្វើឲ្យប៉ះពាល់ដល់មនុស្ស។
- ចូរកុំបន្ទោបង់ដាក់រន្ធដី ព្រោះវាអាចមានសត្វចង្រៃនៅក្នុងនោះដោយហេតុណាមួយ ដែលបណ្ដាលឲ្យប៉ះពាល់ដល់ខ្លួនឯងវិញ។
- ចាំបាច់លើជនមូស្លីមពុំត្រូវតម្រង់ទៅកាន់គិបឡាត់( ទិសតម្រង់ក្នុងពេលសឡាត ) ឬបែរខ្នងដាក់គិបឡាត់នោះទេ ទោះជានៅទីកន្លែងណាក៏ដោយ លើកលែងតែនៅក្នុងបន្ទប់ទឹកឬបង្គន់គឺគ្មានបញ្ហាទេ ព្រោះព្យាការីលោកបានមានប្រសាសន៍ថា: "ប្រសិនបើពួកអ្នកធ្វើការបន្ទោបង់ ចូរពួកអ្នកកុំតម្រង់ទៅកាន់គិបឡាត់ ឬបែរខ្នងដាក់វា"។ (អាល់ពូខរី:៣៨៦ មូស្លឹម:២៦៤)
- គេត្រូវប្រយ័ត្នពីការខ្ទាតប្រការកខ្វក់ទៅលើសម្លៀកបំពាក់របស់គេ ហើយចាំបាច់ត្រូវលាងវា ប្រសិនបើមានការប្រឡាក់នោះ។
- នៅពេលដែលគេបន្ទោបង់រួច គេត្រូវធ្វើរឿងពីរយ៉ាង:

| | |
|---|---|
| គឺគេត្រូវសម្អាតលាមកឬទឹកនោមពីខ្លួនរបស់គេដោយប្រើទឹក (អាល់អ៊ីសតិញហ្ជាក) | ឬក៏គេត្រូវសម្អាតដោយប្រើក្រណាត់បីដុំ ឬច្រើនជាងនេះ ឬដុំថ្ម ឬក្រដាសដែលអាចជម្រះសម្អាតខ្លួនគេពីប្រការកខ្វក់នោះបាន (អាល់អ៊ីសតិចមើរ)។ |

## > ហាហ្ទាស(ភាពកខ្វក់ផ្នែកបញ្ញត្តិច្បាប់)

- ហាហ្ទាស គឺជាលក្ខណៈអរូបីមួយដែលរារាំងមនុស្សមិនឲ្យប្រតិបត្តិសឡាតមុននឹងវាជ្រះស្អាត ហើយវាមិនមែនជាវត្ថុរូបីដូចរបស់កខ្វក់នោះទេ។
- ហើយហាហ្ទាស វានឹងជ្រះស្អាតនៅពេលដែលជនមូស្លីមយកទឹកជម្រះកាយ(វូហ្លុ) ឬក៏ងូតទឹកជម្រះសម្អាតខ្លួនប្រាណដោយទឹកស្អាត។ ទឹកស្អាត គឺជាទឹកដែលបរិសុទ្ធមិនលាយឡំជាមួយនឹងសារធាតុកខ្វក់ផ្សេងៗ។ បើសិនជាគេយកទឹកជម្រះកាយ(ទឹកវូហ្លុ)រួច គឺគេឋិតក្នុងសភាពដែលគេអាចប្រតិបត្តិសឡាត(ថ្វាយបង្គំ)បាន រហូតដល់គេមានហាហ្ទាស់សារជាថ្មី។

គេបែងចែកហាហ្ទាសជាពីរ៖

- ហាហ្ទាសដែលចាំបាច់លើគេត្រូវតែយកទឹកជម្រះកាយ(វូហ្លុ)ដើម្បីបំបាត់វាចេញពីខ្លួន ហើយគេឱ្យឈ្មោះថា (ហាហ្ទាសតូច)។
- ហាហ្ទាសដែលចាំបាច់លើគេត្រូវតែងូតទឹក និងស្រោចទឹកឱ្យសព្វខ្លួនប្រាណដើម្បីបំបាត់វាចេញពីខ្លួន ហើយគេឲ្យឈ្មោះថា(ហាហ្ទាសធំ)។

### ហាហ្ទាសតូច និងការយកទឹកជម្រះកាយ(ទឹកវូហ្លុ)

ភាពជ្រះស្អាត(ទឹកវូហ្លុ)របស់ជនមូស្លីមត្រូវបានខូចឬដាច់ ហើយចាំបាច់ត្រូវយកទឹកជម្រះកាយ ឬទឹកវូហ្លុសារជាថ្មីដើម្បីប្រតិបត្តិការថ្វាយបង្គំ(សឡាត) ប្រសិនបើមានករណីដូចខាងក្រោមនេះ

1 លាមក ទឹកនោម និងរាល់អ្វីៗដែលបានចេញពីទ្វារទាំងពីរ ដូចជាផោមជាដើម។ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា ៖ "ឬនរណាម្នាក់ក្នុងចំណោមពួកអ្នកបានបន្ទោបង់..."។ (គម្ពីរគួរអាន ៤:៤៣)។ ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ទាក់ទងនឹងអ្នកដែលមានការសង្ស័យថាខ្លួនមានហាហ្ទាសក្នុងពេលថ្វាយបង្គំ(សឡាត)ថា៖ "គេមិនត្រូវចាកចេញពីសឡាតឡើយ លុះត្រាតែគេបានឮសំឡេង ឬធុំក្លិន(ផោម)"។ (អាល់ពូខរីៈ១៧៥ មូស្លីមៈ៣៦១)

2 កាន់ប្រដាប់ភេទដោយផ្ទាល់ដៃដោយតណ្ហា៖ ព្យាការីមូហាំម៉ាត់មានប្រសាសន៍ថា ៖ "បុគ្គលណាកាន់ប្រដាប់ភេទរបស់គេ ចូរឱ្យគេយកទឹកជម្រះកាយ(យកវូហ្លុ)។ (អាពូហ្ទាវូទៈ១៨១)

3 បរិភោគសាច់អូដ្ឋ
មានគេសួរព្យាការីមូហាំម៉ាត់ថាៈ តើយើងត្រូវយកទឹកជម្រះកាយដែរឬទេក្រោយពីបរិភោគសាច់អូដ្ឋនោះ? គាត់បានតបថាៈ "បាទត្រូវតែយក"។

4 បាត់បង់សតិ ដោយការដេកលក់ ឬស្រវឹង ឬឆ្កួត។



>ក្នុងចំណោមប្រការដែលធ្វើឲ្យខូចទឹកវូហ្លុ គឺការបាត់បង់ស្មារតីដោយការដេកលក់ ឬឆ្កួត ឬស្រវឹង

# > តើខ្ញុំយកទឹកជម្រះកាយ(ទឹកវូហ្ទ)យ៉ាងដូចម្តេច?

ការយកទឹកជម្រះកាយ និងការជម្រះសម្អាត គឺជាទង្វើដ៏ល្អប្រសើរ និងថ្លៃថ្លាបំផុត។ ព្រះអល់ឡោះជាម្ចាស់ទ្រង់បានអភ័យទោសនិងលុបលាងកំហុសឆ្គងនៅពេលដែលខ្ញុំបម្រើរបស់ទ្រង់បានប្រតិបត្តិវាដោយចិត្តស្មោះបរិសុទ្ធ និងចង់បានផលបុណ្យពីព្រះជាម្ចាស់។ ពិតណាស់ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា: "នៅពេលដែលជនមូស្លីមយកទឹកជម្រះកាយ(ទឹកវូហ្ទ) ហើយគេបានលាងមុខរបស់គេនោះ រាល់កំហុសឆ្គងបានហូរចេញតាមមុខរបស់គេ។គេមើលឃើញផ្គាល់នឹងភ្នែកទាំងគូរបស់គេជាមួយនឹងទឹក។ហើយនៅពេលគេលាងដៃរបស់គេទាំងសងខាង រាល់កំហុសឆ្គងបានហូរចេញតាមដៃរបស់គេ។ កំហុសឆ្គងរលាស់ចេញពីដៃទាំងពីរជាមួយនឹងទឹក។ ហើយនៅពេលគេលាងជើងរបស់គេទាំងពីរ រាល់កំហុសឆ្គងបានហូរចេញតាមជើងទាំងពីររបស់គេ។ ជើងទាំងពីររបស់គេជាន់កំហុសឆ្គង់នោះជាមួយនឹងទឹក រហូតដល់គេបានជ្រះស្អាតពីទោសកំហុសរបស់គេ។ (មូស្លីម:២៤៤)

## តើខ្ញុំយកទឹកជម្រះកាយនិងជម្រះសម្អាតហាហ្ទាសតូចយ៉ាងដូចម្តេច?



នៅពេលដែលជនមូស្លីមចង់យកទឹកជម្រះកាយគឺគេត្រូវនៀត មានន័យថា គេត្រូវតាំងចិត្តបំបាត់ហាហ្ទាស ហើយនៀតគឺជាលក្ខខណ្ឌមួយក្នុងគ្រប់ការគោរពប្រណិបត្តិទាំងអស់។ ព្យាការីមូហាំម៉ាត់លោកបានមានប្រសាសន៍ថា: "រាល់ការគោរពប្រណិបត្តិទាំងអស់ត្រូវមានការនៀត"។ (អាល់ពូខរី:១ មូស្លីម:១៩០៧)។ បន្ទាប់មកគេ ត្រូវយកទឹកជម្រះកាយតាមលំដាប់លំដោយបន្តបន្ទាប់គ្នា គ្មានការឃ្លាតពីគ្នារយៈពេលយូរឡើយ។

**1**

គេត្រូវសូត្រថា( بسم الله )
(ពិសមិលឡះ)
"ក្នុងព្រះនាមអល់ឡោះ"



**2**

លាងប្រអប់ដៃនឹងទឹក ចំនួនបីដង



**3**

ខ្ពុរមាត់នឹងទឹកចំនួនបីដង។ មានន័យថា ដាក់ទឹកចូលក្នុងមាត់ ខ្ពុរវា បន្ទាប់មក ខ្ជាក់ចេញ។ គប្បីធ្វើដូចនេះចំនួនបីដង ហើយចំនួន១ដង គឺជាការចាំបាច់។



**4**

ត្រូវបឺតទឹកចូលក្នុងច្រមុះបន្ទាប់មកញើសចេញមកវិញដោយកម្លាំងខ្យល់ចេញពីច្រមុះ។ គប្បីបឺតទឹកឱ្យដល់ទីជម្រៅ លើកលែងតែវាបង្កផលប៉ះពាល់ដល់គេ ហើយគប្បីធ្វើបែបនេះដដែលៗចំនួនបីដង។



## 5

លាងមុខរបស់គេ គឺចាប់ផ្ដើមពីគល់ថ្ងាសខាងលើរហូតដល់ចង្កា និងពីត្រចៀកម្ខាង ដល់ត្រចៀកម្ខាងទៀត។ ត្រចៀកទាំងពីរ គេពុំរាប់ចូលក្នុងផ្ទៃមុខឡើយ។ គប្បីត្រូវលាងបីដង ហើយមួយដងយ៉ាងតិច។



## 6

លាងដៃទាំងពីររបស់គេ ដោយចាប់ផ្ដើមពីចុងម្រាមដៃរហូតដល់កែងដៃទាំងសងខាងរបស់គេ (ខាងស្ដាំបន្ទាប់មកខាងឆ្វេង)។ គេត្រូវលាងកែងដៃរបស់គេទាំងពីរផងដែរ ហើយគប្បីត្រូវលាងបីដង តែយ៉ាងតិចឲ្យបានមួយដង។



## 7

ជូតក្បាលរបស់គេ ដោយយកដៃរបស់គេទាំងពីរជ្រលក់ទឹក បន្ទាប់មកចាប់ផ្ដើមជូតពីខាងមុខរហូតដល់ខាងក្រោយ រួចទាញពីក្រោយមកមុខវិញ ហើយត្រូវធ្វើដូចនេះតែមួយដងប៉ុណ្ណោះ។



## 8

ជូតត្រចៀកទាំងសងខាងរបស់គេ ដោយលូកម្រាមដៃចង្អុលទាំងពីរក្នុងត្រចៀក បន្ទាប់ពីជូតក្បាលរួច និងយកមេដៃទាំងពីរជូតពីលើខ្នងត្រចៀក។



## 9

លាងជើងទាំងពីររបស់គេរហូតដល់ភ្នែកគោល។ ត្រូវលាងបីដង(លាងខាងស្ដាំ បន្ទាប់មកខាងឆ្វេង) ឬយ៉ាងតិចមួយដង។ ប្រសិនបើគេពាក់ស្រោមជើង គេអាចជូតពីលើស្រោមជើងបានតាមលក្ខខណ្ឌរបស់វា។ (សូមមើលទំព័រទី៩៩)



## ហាហ្ញាសធំ និងការងូតទឹក

### ប្រការៗដែលចាំបាច់ត្រូវងូតទឹក:

ជាប្រការទាំងឡាយណាដែលនៅពេលដែលអ្នកមូស្លីមបានប្រព្រឹត្តវា គឺចាំបាច់លើរូបគេត្រូវងូតទឹក មុននឹងប្រតិបត្តិការថ្វាយបង្គំ និងដើរប្រទក្សិណជុំវិញកាក់ហ្ពះ ហើយមុននឹងមុជទឹក គេឱ្យឈ្មោះថា ហាហ្ញាសធំ។

ប្រការទាំងនោះដូចជា:

1. ចេញទឹកកាមដោយចេតនាតាមវិធីណាក៏ដោយ និងគ្រប់ស្ថានភាព ទាំងភ្ញាក់ដឹងខ្លួន ឬដេកលក់។ ទឹកកាម គឺជាទឹករំអិលពណ៌ស ខាប់ ដែលចេញនៅពេលដែលមានអារម្មណ៍ស្រួលដល់កំពូល។

2. ការរួមដំណេក៖ គឺជាការបញ្ចូលអង្គជាតិបុរសទៅក្នុងទ្វារមុខរបស់ស្ត្រី ទោះបីមិនចេញទឹកកាមក្តី គឺចាំបាច់លើរូបគេត្រូវងូតទឹក សូម្បីតែក្បាលអង្គជាតិបុរសលិចចូលបន្តិចក៏ដោយ(ក៏ចាំបាច់ត្រូវងូតទឹកដែរ)។ ព្រះអល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថាៈ (ហើយប្រសិនបើពួកអ្នកមានជូនុប(ហាហ្ញាសធំ)គឺចាំបាច់ពួកអ្នកត្រូវជម្រះសម្អាតខ្លួនប្រាណ(ដោយងូតទឹក)។ (គម្ពីរគួរអាន ៥:៦)

3. ចេញឈាមរដូវ និងឈាមនីហ្វាស(ឈាមបន្ទាប់ពីឆ្លងទន្លេ)

- ឈាមរដូវ គឺជាឈាមធម្មជាតិដែលស្ត្រីមកជារៀងរាល់ខែម្តងដែលមានរយៈពេលប្រាំពីរថ្ងៃ ឬតិចជាងនេះ ឬច្រើនជាងនេះ អាស្រ័យតាមសភាពលក្ខណៈធម្មជាតិរបស់ស្ត្រី។
- ឈាមនីហ្វាស គឺជាឈាមដែលចេញបន្ទាប់ពីឆ្លងទន្លេរួចដែលមានរយៈពេលជាច្រើនថ្ងៃ។

គេបានអនុគ្រោះចំពោះស្ត្រីដែលមានរដូវនិងឈាមនីហ្វាសក្នុងរយៈពេលដែលឈាមកំពុងមក មិនឲ្យប្រតិបត្តិការថ្វាយបង្គំ (សឡាត) និងបួស (តមអាហារ) តែត្រូវបួសសងវិញ។ ចំណែកឯការថ្វាយបង្គំវិញ គឺមិនតម្រូវឲ្យសងឡើយ បន្ទាប់ពីនាងជ្រះស្អាតនោះ។ គេមិនអនុញ្ញាតឲ្យប្តីរបស់នាងរួមដំណេកជាមួយនាងខណៈដែលនាងកំពុងមានរដូវ ឬនីហ្វាសនោះទេ តែគេអាចប្រលែងលេងជាមួយនាងបាន។ ហើយចាំបាច់លើរូបនាង ត្រូវងូតទឹកជម្រះខ្លួនបន្ទាប់ពីអស់រដូវ និងអស់ឈាមនីហ្វាសនេះ។


> គ្រប់គ្រាន់ហើយក្នុងការងូតទឹកវ៉ាជិប(ការងូតទឹកដែលចាំបាច់ត្រូវងូត) ដោយស្រោចស្រពទឹកលើខ្លួនប្រាណរបស់គេទាំងមូលឲ្យបានសព្វ។

អល់ឡោះទ្រង់បានមានបន្ទូលថា "ចូរពួកអ្នកជៀសវាងពីការរួមដំណេកជាមួយភរិយាក្នុងអំឡុងពេលមានរដូវ ហើយកុំទៅជិតពួកនាង(ដើម្បីរួមដំណេក)រហូតដល់ពួកនាងជ្រះស្អាត(អស់រដូវហើយងូតទឹកសម្អាត)ខ្លួនប្រាណសិន។ បើសិនជាពួកនាងជ្រះស្អាតហើយនោះ ពួកអ្នកអាចរួមដំណេកជាមួយពួកនាងនៅត្រង់កន្លែង(ទ្វារមុខ)ដែលអល់ឡោះបានអនុញ្ញាតឲ្យពួកអ្នក"។ (គម្ពីរគួរអាន ២:២២២)

## តើជនមូស្លីមត្រូវជម្រះសម្អាតពីជូនុប និងពីហាហ្ទាសធំយ៉ាងដូចម្តេច?

គ្រប់គ្រាន់ហើយសម្រាប់ជនមូស្លីមដោយការនៀត (តាំងចិត្ត)សម្អាតខ្លួនប្រាណរបស់គេ រួចចាក់ទឹកឱ្យបានសព្វពេញខ្លួនប្រាណ។

- ក៏ប៉ុន្តែដែលពេញលក្ខណៈបំផុត គឺសម្អាតដូចគេធ្វើបន្ទាប់ពីបន្ទោបង់រួច បន្ទាប់មកយកទឹកជម្រះកាយ (ទឹកវូហ្ទុ)។ បន្ទាប់មកទៀត គេត្រូវចាក់ទឹកលើខ្លួនប្រាណរបស់គេទាំងអស់ដែលនៅសល់។ ធ្វើបែបនេះ គេនឹងទទួលផលបុណ្យជាច្រើនពីអល់ឡោះ ហើយវាស្របនិងមាគ៌ារបស់ព្យាការីមូហាំម៉ាត់(សូមពរជ័យ និងសន្តិភាពកើតមានដល់លោក)ផងដែរ។
- ប្រសិនបើជនមូស្លីមបានងូតទឹកសម្អាតពីជូនុបរួចហើយនោះ គឺវាអាចជំនួសទឹកវូហ្ទុបាន ដោយគេមិនចាំបាច់យកទឹកវូហ្ទុទៀតនោះទេ។ ក៏ប៉ុន្តែជាការប្រសើរ គឺគប្បីងូតទឹកដែលរួមទាំងទឹកវូហ្ទុ។ម្យ៉ាងទៀត ធ្វើដូចនេះ វាក៏ជាមាគ៌ារបស់ព្យាការីមូហាំម៉ាត់ផងដែរ។

## ការជូតលើស្រោមជើងៈ

ដោយសារភាពងាយស្រួលរបស់សាសនាឥស្លាម ជនមូស្លីមអាចជូតលើស្រោមជើងឬស្បែកជើងរបស់គេដែលគេកំពុងពាក់ដោយដៃទទឹករបស់គេជំនួសការលាងទឹកបានក្នុងការយកទឹកជម្រះកាយ តែត្រូវមានលក្ខខណ្ឌមួយ គឺគាត់ត្រូវមានទឹកជម្រះកាយ (ទឹកវូហ្ទុ)ខណៈដែលគាត់ពាក់ស្រោមជើងឬស្បែកជើងនោះ ហើយវាមានរយៈពេល២៤ម៉ោងសម្រាប់អ្នកនៅផ្ទះ និង៧២ម៉ោងសម្រាប់អ្នកដំណើរ។

ចំណែកឯក្នុងការងូតទឹកជូនុបវិញ គឺចាំបាច់ត្រូវលាងជើងទាំងសងខាងក្នុងគ្រប់ស្ថានភាពទាំងអស់។



## បុគ្គលដែលគ្មានលទ្ធភាពប្រើប្រាស់ទឹក

ប្រសិនបើជនមូស្លីមមិនអាចប្រើប្រាស់ទឹកបានក្នុងការយកទឹកជម្រះកាយ(ទឹកវូហ្ទុ) ឬងូតទឹក ដោយសារមានជំងឺ ឬគ្មានទឹក ឬទឹកប្រើប្រាស់មិនគ្រប់គ្រាន់ គឺគេត្រូវប្រើដីសម្អាតរហូតទាល់តែមានទឹកឬអាចប្រើប្រាស់ទឹកវិញបាន។

របៀបសម្អាតដោយប្រើដីស្អាត(តាយ៉ាំមុម) គឺគេត្រូវយកដៃទាំងពីរប៉ះនឹងដីចំនួនមួយដង។ បន្ទាប់មក គេត្រូវជូតមុខរបស់គេ។ បន្ទាប់មកទៀត គេត្រូវជូតខ្នងដៃស្តាំរបស់គេដោយបាតដៃខាងឆ្វេង និងជូតខ្នងដៃខាងឆ្វេងដោយបាតដៃខាងស្តាំ។





# ការសឡាតរបស់អ្នក



# 3

ការសឡាត ឬការថ្វាយបង្គំ គឺជាសរសរទ្រូងរបស់សាសនាឥស្លាម ហើយវាជាតំណភ្ជាប់របស់ខ្ញុំបម្រើនិងព្រះជាម្ចាស់របស់គេ និងអ្នកគ្រប់គ្រងរបស់គេ។ ហេតុដូច្នោះហើយ ទើបការសឡាត ឬការថ្វាយបង្គំនេះ គឺជាការគោរពសក្ការៈដ៏ឧត្តុងឧត្តម និងជាកិច្ចការដ៏ល្អប្រពៃ ហើយពិតណាស់ ព្រះអល់ឡោះបានប្រើឱ្យជនមូស្លីមថែរក្សាទៅលើការសឡាតនេះ ក្នុងគ្រប់ស្ថានភាពរបស់គេទាំងអស់ មិនថាក្នុងពេលមិនធ្វើដំណើរ ឬធ្វើដំណើរ ពេលមានសុខភាព ឬពេលមានជំងឺនោះឡើយ។

## មាតិការជំពូក


ឋានៈ និងឧត្តមភាពនៃការសឡាត( ថ្វាយបង្គំ )

ផលបុណ្យនៃការសឡាត

ការសឡាតដែលគេដាក់កាតព្វកិច្ចទាំងប្រាំពេល និងពេល-វេលារបស់វា

ទីកន្លែងសឡាត

របៀបនៃការសឡាត

តើខ្ញុំត្រូវសឡាតយ៉ាងដូចម្តេច ?

គោលគ្រឹះ និងប្រការចាំបាច់នៃសឡាត

- ប្រការដែលនាំឱ្យខូចសឡាត
- ប្រការដែលមិនគប្បីធ្វើក្នុងពេលសឡាត

តើអ្វីទៅជាការសឡាតស៊ូណិត( ថ្វាយបង្គំស្ម័គ្រចិត្ត ?

ការសឡាតសឡាតជើម៉ាអះ( សឡាតរួមគ្នា )

អាហ្សាន( ការប្រកាសហៅឱ្យមកសឡាត )

ភាពស្ងប់ស្ងាត់ក្នុងពេលសឡាត

ការសឡាតជុមអាត់( សឡាតថ្ងៃសុក្រ )

ការសឡាតរបស់អ្នកធ្វើដំណើរ

ការសឡាតរបស់អ្នកជំងឺ

# ការសឡាត(ថ្វាយបង្គំ)

ជាតុដើមនៃពាក្យសឡាត គឺមានន័យថា ការបួង-សួង(ទូអា)។ វាជាការតភ្ជាប់រវាងខ្ញុំបម្រើ(មនុស្សលោក)នឹងម្ចាស់របស់គេ និងអ្នកដែលបង្កើតគេ(អល់ឡោះ)។ នៅក្នុងនោះដែរ រួមមានអត្ថន័យនៃភាពជាខ្ញុំបម្រើ និងការងាកទៅរកអល់ឡោះ និងសុំជំនួយពីទ្រង់ ហើយបួងសួងទៅចំពោះទ្រង់ សន្ទនាជាមួយទ្រង់ និងរលឹកដល់ទ្រង់ កែសម្រួលដោយខ្លួនឯងផ្ទាល់ និងនឹករលឹកអំពីជាតុពិតរបស់គេ និងជាតុពិតនៃលោកិយដែលគេកំពុងរស់នៅក្នុងវា ហើយទទួលបានអារម្មណ៍ដ៏អស្ចារ្យចំពោះម្ចាស់របស់គេ និងការអាណិតស្រលាញ់របស់ទ្រង់ចំពោះគេ។ហើយការសឡាតនេះនឹងជម្រុញរូបគេឱ្យឆ្ពោះទៅរកការប្រកាន់ខ្ជាប់នឹងច្បាប់របស់អល់ឡោះ និងចេញឆ្ងាយអំពីប្រការអយុត្តិធម៌ ប្រការអសីល-ធម៌និងអំពើទុច្ចរិតដូចអល់ឡោះបានមានបន្ទូលថា "ពិតប្រាកដណាស់សឡាតអាចហាមឃាត់អំពីការប្រព្រឹត្តអសីលធម៌ និងអំពើទុច្ចរិត"។ (គម្ពីរគួរអាន ២៩:៤៥)



## > ឋានៈនិងឧត្តមភាពរបស់សឡាត

សឡាត គឺជាការគោរពសក្ការៈដោយប្រើប្រាស់រាងកាយដ៏ឧត្តុងឧត្តម និងជាកិច្ចការដ៏ល្អប្រពៃបំផុត។ វាជាការគោរពសក្ការៈយ៉ាងទូលំទូលាយដែលរួមមានទាំងការប្រើប្រាស់ចិត្ត គំនិត និងអណ្តាត ហើយលក្ខណៈពិសេសរបស់សឡាត បានស្តែងឱ្យឃើញនៅក្នុងកិច្ចការជាច្រើន ដូចជា ៖

### សម្រាប់សឡាតគឺមានឋានៈដ៏ខ្ពង់ខ្ពស់បំផុត

1 វាជាគោលគ្រឹះទីពីរក្នុងចំណោមគោលគ្រឹះ(ទាំងប្រាំ)របស់សាសនាឥស្លាម ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា "គេបានស្ថាបនាសាសនាឥស្លាមលើប្រាំប្រការៈ ធ្វើសាក្សី ថាគ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិត គឺមានតែអល់ឡោះ ហើយព្យាការីមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់ទ្រង់ ហើយត្រូវបញ្ឈរសឡាត...."។ (អាល់ពូខរី:៨ មូស្លីម:១៦)។ ហើយគ្រឹះនៃសំណង់ គឺប្រភពដើមដែលគេពឹងផ្អែកលើវា ហើយមិនអាចឈរបានទេប្រសិនបើគ្មានវា។

2 ភស្តុតាងនៃច្បាប់បានចាត់ទុកភាពខុសគ្នារវាងអ្នកមូស្លីមនិងអ្នកគ្មានជំនឿគឺការបញ្ឈរសឡាត។ ដូចអ្នកនាំសារបានមានប្រសាសន៍ "ពិតណាស់ រនាំងរវាងអ្នកឥស្លាមនឹងស្ហ៊ីក និងការគ្មានជំនឿ គឺការបោះបង់ចោលការសឡាត"(មូស្លីម)។ ហើយលោកបានមានប្រសាសន៍ផងដែរថា៖

“កិច្ចសន្យារវាងពួកយើងនិងពួកគេ គឺការសឡាត។ ជនណាហើយដែលបោះបង់ចោលវាពិតណាស់ គេជាអ្នកគ្មានជំនឿ”។ (អាត់តៀរមីហ្ស៊ី ២៦២១ អាន់ណាសាអ៊ី:៤៦៣)

3 អល់ឡោះបានប្រើឱ្យថែរក្សាទៅលើវាគ្រប់កាលៈទេសៈទាំងអស់ មិនថាក្នុងពេលធ្វើដំណើរ ពេលមិនធ្វើដំណើរ ពេលមានសន្តិភាព ពេលមានសង្គ្រាម ពេលមានសុខភាពល្អ និងពេលមានជំងឺ ហើយប្រតិបត្តិវាទៅតាមលទ្ធភាពដែលគេអាចធ្វើបាន។ ដូចអល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នកថែរក្សាសឡាតទាំងប្រាំពេល”។ (គម្ពីរគួរអាន ២:២៣៨)។ ហើយទ្រង់បានពណ៌នាអំពីលក្ខណៈសម្បត្តិខ្ញុំបម្រើរបស់ទ្រង់ដែលមានជំនឿ ដោយទ្រង់បានមានបន្ទូលថា “និងបណ្ដាអ្នកដែលថែរក្សាការលើការប្រតិបត្តិសឡាតរបស់ពួកគេ”។(គម្ពីរគួរអាន ២៣:៩)

## ផលបុណ្យនៃសឡាត

មានការរាយការណ៍ជាច្រើនអំពីផលបុណ្យនៃសឡាត ទាំងភស្តុតាងនៅក្នុងគម្ពីរគួរអាន និងក្នុងប្រសាសន៍របស់ព្យាការី ដែលមានដូចជា:

1 ជម្រុះចោលនូវបាបកម្មទាំងឡាយ៖ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “ការសឡាតទាំងប្រាំពេល ពីជុមអាត់(ថ្ងៃសុក្រ)មួយ ទៅជុមអាត់មួយទៀត វាជម្រុះចោលនូវបាបកម្មដែលនៅចន្លោះនោះ លើកលែងតែបាបកម្មធំៗ”។ (មូស្លីមៈ២៣៣ អាត់តៀរមីហ្ស៊ី:២១៤)

2 វាជាពន្លឺបំភ្លឺសម្រាប់អ្នកមូស្លីមក្នុងជីវិតរបស់គេទាំងអស់ ជំរុញឱ្យគេប្រព្រឹត្តអំពើល្អ និងជៀសឆ្ងាយពីអំពើអាក្រក់ ដូចដែលអល់ឡោះបានមានបន្ទូលថា “ពិតប្រាកដណាស់ សឡាតហាមឃាត់អំពីការប្រព្រឹត្តិអសីលធម៌ និងអំពើទុច្ចរិត”។(គម្ពីរគួរអាន ២៩:៤៥)។ហើយអ្នកនាំសារបានមានប្រសាសន៍ថា “ការសឡាតគឺជាពន្លឺ”។ (មូស្លីមៈ២២៣)

3 វានឹងត្រូវបានគេជំនុំជម្រះដំបូងគេបង្អស់នៅថ្ងៃបរលោក។ ប្រសិនបើវាល្អត្រឹមត្រូវហើយគេទទួលយកនោះ ទង្វើកុសលផ្សេងទៀតក៏គេទទួលដែរ។ តែប្រសិនបើគេបដិសេធ(មិនទទួលយក)ទេនោះ ទង្វើផ្សេងទៀតដែលនៅសល់ ក៏គេមិនទទួលយកដែរ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “អ្វីដែលគេជំនុំជំរះដំបូងគេបង្អស់ទៅលើមនុស្សនៅថ្ងៃបរលោកនោះ គឺការសឡាត។ ប្រសិនបើវាល្អត្រឹមត្រូវនោះ ទង្វើផ្សេងទៀតក៏ល្អត្រឹមត្រូវដែរ។ ប្រសិនបើវាមិនល្អវិញនោះ ទង្វើផ្សេងទៀតក៏មិនល្អត្រឹមត្រូវដែរ”។



> អល់ឡោះជាម្ចាស់បានបង្គាប់ប្រើឲ្យថែរក្សាសឡាតនៅក្នុងគ្រប់ស្ថានភាពទាំងអស់ សូម្បីតែក្នុងពេលធ្វើសង្គ្រាមនិងពេលមានគ្រោះ



សទ្បាត ជាពេលវេលាដែលមានរសជាតិបំផុតសម្រាប់អ្នកមានជំនឿក្នុងខណៈពេលដែលគេសន្ទនាទៅចំពោះម្ចាស់របស់គេក្នុងពេលសទ្បាត ហើយគេទទួលបានសន្តិភាព ភាពស្ងប់ស្ងាត់ និងការអាណិតស្រលាញ់ពីអល់ឡោះ។

ហើយវាជារសជាតិដ៏ល្អប្រពៃបំផុតសម្រាប់ព្យាការីមូហាំម៉ាត់ ដូចដែលលោកបានមានប្រសាសន៍ថា "ខ្ញុំចាត់ទុកភាពសប្បាយរីករាយរបស់ខ្ញុំ គឺនៅក្នុងពេលសទ្បាត"។ (អាន់ណាសាអ៊ី៣៩៤០)

ហើយលោកបានមានប្រសាសន៍ទៅកាន់លោកពីទ្បាល ដែលជាអ្នកប្រកាសហៅមនុស្សឱ្យមកសទ្បាតថា "សូមឱ្យយើងមានភាពស្ងប់សុខដោយសារការសទ្បាតឱពីទ្បាល"។(អាពូទើវូទ៤៩៨៥)

ព្យាការីមូហាំម៉ាត់ នៅពេលដែលជួបរឿងពិបាកចិត្តលើរឿងអ្វីមួយ គឺលោកតែងតែទៅសទ្បាត"។ (អាពូទើវូទ ១៣១៩)

## ជនណាខ្លះដែលចាំបាច់ត្រូវសទ្បាត?

ការសទ្បាត គឺជាកាតព្វកិច្ចដែលចាំបាច់លើគ្រប់បុគ្គលមូស្លីមដែលមានសតិបញ្ញា គ្រប់អាយុ មិនមែនជាអ្នកមានឈាមរដូវ ឬឈាមនីហ្វាស (ឈាមបន្ទាប់ពីសម្រាលកូនរួច) ដោយគេមិនត្រូវសទ្បាតក្នុងពេលដែលនាងមានឈាមរដូវ ឬឈាមនីហ្វាសនោះទេ្បីយ ហើយក៏មិនចាំបាច់ត្រូវសទ្បាតសងវិញនូវអ្វីដែលបានកន្លងផុតក្រោយពីនាងបានជ្រះស្អាតបន្ទាប់ពីអស់ឈាមនោះដែរ។ (ចូរមើលទំព័រ ៩៨)

ហើយគេកំណត់ថាគ្រប់អាយុ នៅពេលដែលមានមួយក្នុងចំណោមសញ្ញាៗខាងក្រោមនេះ

| |
|---|
| មានអាយុ១៥ឆ្នាំ |
| ដុះរោមនៅកន្លែងប្រដាប់ភេទខាងមុខ ឬខាងក្រោយ |
| ចេញទឹកកាមក្នុងពេលគេង ឬពេលដឹងខ្លួន |
| មករដូវ ឬមានផ្ទៃពោះ |

## > តើអ្វីទៅជាលក្ខខណ្ឌដែលចាំចាច់ត្រូវមានមុនពេលសឡាត?

**1** ការជ្រះស្អាតអំពី ហាហ្វាស និងប្រការកខ្វក់: យើងបានបកស្រាយពីបញ្ហានេះយ៉ាងលម្អិតរួចមកហើយ( សូមមើលទំព័រ ៩៣ )

**2** បិទបាំងអារ៉ាត់( កេរខ្មាស )
គេដាក់លក្ខខណ្ឌចំពោះការបិទបាំងអារ៉ាត់ដោយសំលៀកបំពាក់ ដែលមិនបង្ហាញឱ្យឃើញនូវរាងកាយច្បាស់លាស់ដោយមូលហេតុ ខ្លី ឬស្តើងឡើយ។

ហើយអារ៉ាត់មានបីប្រភេទ ៖

ស្ត្រី: អារ៉ាត់របស់ស្ត្រីដែលពេញវ័យក្នុងពេលសឡាត: ខ្លួនប្រាណរបស់នាងទាំងមូល លើកលែងតែមុខ និង ប្រអប់ដៃទាំងពីររបស់នាង។

កូនក្មេង: កូនក្មេងតូចអារ៉ាត់របស់គេ: គឺកេរខ្មាសទាំងពីរ( មុខ ក្រោយ )ប៉ុណ្ណោះ។

បុរស: អារ៉ាត់របស់បុរសដែលពេញវ័យ: គឺពីផ្ចិតរហូតដល់ជង្គង់។

អុល់ឡោះបានមានបន្ទូលថា: “ឱកូនចៅអាហ្ទាំ! ចូរពួកអ្នកលម្អសំលៀកបំពាក់របស់ពួកអ្នកនៅរាល់ម៉ាស្ជិទ(ពេលសឡាត)”។(គួរ្អានគួរអាន ៧:៣១)។ ហើយការបិទបាំងអារ៉ាត់ គឺជាការលម្អដែលមានឋានៈតិចតួចបំផុត។ ហើយអត្ថន័យរបស់ពាក្យ "រាល់ម៉ាស្ជិត" គឺរាល់ពេលសឡាត។



> ចាំបាច់លើស្ត្រីមូស្លីមនៅក្នុងការសឡាតរបស់គេ គឺត្រូវបិទបាំងរាងកាយរបស់គេទាំងអស់ លើកលែងតែមុខ និងប្រអប់ដៃប៉ុណ្ណោះ។

## 3 តម្រង់មុខទៅទិសគិបឡាត់

អល់ឡោះបានមានបន្ទូលថា “ហើយគ្រប់កន្លែងដែលអ្នកចេញដំណើរ(ហើយអ្នកចង់សឡាត)ចូរអ្នកតម្រង់មុខរបស់អ្នកទៅកាន់ទិសម៉ាស្ជិទីលហារ៉ម(កាក់ហ្ពះ)”។(គម្ពីរគួរអាន ២:១៤៩)

- គិបឡាត់របស់ជនមូស្លីម គឺកាក់ហ្ពះដែលបានសាងដោយបិតានៃបណ្ដាព្យាការីទាំងឡាយ គឺព្យាការីអ៊ីព្រហ៊ីម ហើយបណ្ដាព្យាការីទាំងឡាយបានធ្វើបុណ្យហាជ្ជីនៅទីនោះ។ យើងទាំងអស់គ្នាក៏ដឹងដែរថា ពិតណាស់ កាក់ហ្ពះ វាគ្រាន់ជាដុំថ្មដែលមិនអាចបង្កគ្រោះថ្នាក់ និងមិនអាចផ្ដល់ផលប្រយោជន៍អ្វីឡើយ។ ក៏ប៉ុន្តែអល់ឡោះបានប្រើឱ្យយើងតម្រង់មុខទៅរកវាក្នុងពេលសឡាត ដើម្បីប្រមូលអ្នកមូស្លីមទាំងអស់ទៅរកទិសតែមួយ និងគោរពសក្ការៈទៅចំពោះអល់ឡោះនឹងទិសមួយនោះ។
- ជាកាតព្វកិច្ចលើអ្នកមូស្លីមត្រូវតម្រង់មុខទៅរកកាក់ហ្ពះប្រសិនបើគេមើលឃើញវានៅនឹងមុខរបស់គេ។ ចំណែកឯអ្នកដែលនៅឆ្ងាយនោះ គ្រប់គ្រាន់ហើយសម្រាប់រូបគេគ្រាន់តែតម្រង់មុខទៅកាន់ទិសម៉ាក្កះប៉ុណ្ណោះ។ ការងាកចេញបន្តិចក្នុងពេលតម្រង់មុខនោះ មិនមានបញ្ហាឡើយ។ ព្យាការីបានមានប្រសាសន៍ថា “ចន្លោះរវាងទិសខាងកើតនិងទិសខាងលិច គឺជាគិបឡាត់”។(អាត់ទៀរមីហ្ស៊ី៣៤២)
- ប្រសិនបើគ្មានសមត្ថភាពក្នុងការតម្រង់ទៅកាន់ទិសគិបឡាត់ ដោយសារជំងឺឬអ្វីផ្សេង លក្ខខណ្ឌមួយនេះត្រូវបានលើកលែង ដូចដែលកាតព្វកិច្ចទាំងឡាយត្រូវបានគេលើកលែងនៅពេលដែលគេអសមត្ថភាពដូច្នោះដែរ។អល់ឡោះបានមានបន្ទូលថា“ចូរពួកអ្នកកោតខ្លាចអល់ឡោះទៅតាមលទ្ធភាពរបស់ពួកអ្នក”។(គម្ពីរគួរអាន ៦៤:១៦)

## 4 ដល់ពេលវេលាសឡាត

វាគឺជាលក្ខខណ្ឌមួយដើម្បីឱ្យការសឡាតមានភាពត្រឹមត្រូវ ហើយសឡាតមិនត្រឹមត្រូវឡើយប្រសិនបើគេប្រតិបត្តិវាមុនពេលកំណត់ ហើយក៏ហាមឃាត់មិនឱ្យពន្យារពេលសឡាតនោះដែរ ដូចដែលអល់ឡោះជាម្ចាស់បានមានបន្ទូលថា “ពិតណាស់ សឡាតជាកាតព្វកិច្ចមួយទៅលើបណ្ដាអ្នកមានជំនឿ ដែលមានពេលកំណត់យ៉ាងច្បាស់លាស់”។(គម្ពីរគួរអាន ៤:១០៣)

ហើយគួរតែបញ្ជាក់នៅពេលដែលពេលវេលាបានមកដល់លើកិច្ចការដូចជា:

- ជាការល្អប្រសើរ ត្រូវប្រតិបត្តិសឡាតនៅពេលដំបូងរបស់វា
- ចាំបាច់ប្រតិបត្តិសឡាតក្នុងពេលវេលារបស់វា ហើយហាមឃាត់មិនឱ្យពន្យាពេលវេលារបស់វា ទោះដោយមូលហេតុអ្វីក៏ដោយ។
- ជនណាដែលខកខានសឡាតដោយសារគេងលក់ ឬភ្លេច ចាំបាច់លើគេត្រូវប្រញាប់ប្រញាល់ក្នុងការប្រតិបត្តិសឡាតឡើងវិញនៅពេលណាដែលគេនឹកឃើញ។



>អល់ឡោះជាម្ចាស់បានមានបន្ទូលថា៖ "ប្រាកដណាស់ សឡាត គឺជាកាតព្វមួយទៅលើបណ្ដាអ្នកមានជំនឿដែលមានពេលកំណត់ច្បាស់លាស់"។

## > សឡាតដែលជាកាតព្វកិច្ចទាំងប្រាំពេល និងពេលវេលារបស់វា

អល់ឡោះបានដាក់កាតព្វកិច្ចសឡាតលើជនមូស្លីមក្នុងមួយថ្ងៃមួយយប់ប្រាំពេល។ វាគឺជាសសរទ្រូងនៃសាសនា ហើយទ្រង់បានបញ្ជាក់យ៉ាងច្បាស់អំពីកាតព្វកិច្ចចាំបាច់ចំពោះវា ហើយបានកំណត់លើវានូវពេលវេលាយ៉ាងច្បាស់លាស់ដូចមាននៅខាងក្រោម ៖

សឡាតហ្វាជើរ ឬថ្វាយបង្គំពេលទៀបភ្លឺ: វាមានចំនួនពីររ៉ក្អាត់។ ពេលវេលារបស់វាចាប់ផ្ដើមពីសេតរុណរះ គឺការចាប់ផ្ដើមចេញពន្លឺដំបូងនៅជើងមេឃនៅទិសខាងកើត ហើយបញ្ចប់នៅពេលថ្ងៃរះ។





សឡាតហ្ស៊ូហោរ ឬថ្វាយបង្គំពេលថ្ងៃត្រង់: វាមានចំនួនបួនរ៉ក្អាត់ ហើយពេលវេលារបស់វា ចាប់ផ្ដើមពីថ្ងៃជ្រេ ហើយបញ្ចប់នៅពេលដែលស្រមោលនៃវត្ថុមួយមានប្រវែងស្មើនឹងប្រវែងដើមនៃវត្ថុនោះវិញ។

សឡាតអាសើរ ឬថ្វាយបង្គំពេលរសៀល: វាមានចំនួនបួនរ៉ក្អាត់ ហើយពេលវេលារបស់វា ចាប់ផ្ដើមបន្ទាប់ពីផុតពេលសឡាតហ្ស៊ូហោរ គឺនៅពេលដែលស្រមោលវត្ថុមួយមានប្រវែងស្មើនឹងខ្លួនវាវិញ ហើយបញ្ចប់នៅពេលថ្ងៃលិច។ ចាំបាច់លើជនមូស្លីមរួសរាន់ក្នុងការប្រតិបត្តិសឡាតមុនពេលពន្លឺថ្ងៃចុះខ្សោយនិងមានពណ៌លឿង។





សឡាតម៉ាហ្គ្រិប ឬថ្វាយបង្គំពេលថ្ងៃលិច: វាមានចំនួនបីរ៉ក្អាត់ ហើយពេលវេលារបស់វាចាប់ផ្ដើមបន្ទាប់ពីថ្ងៃលិច និងបាត់រូបរាងរបស់វាពីជើងមេឃ ហើយបញ្ចប់នៅពេលដែលបាត់ពន្លឺក្រហមដែលបង្ហាញចេញបន្ទាប់ពីថ្ងៃលិច។

សឡាតអ៊ីសា ឬថ្វាយបង្គំពេលយប់: វាមានចំនួនបួនរ៉ក្អាត់ ហើយពេលវេលារបស់វា ចាប់ផ្ដើមពីពេលបាត់ពន្លឺក្រហម(នៅទិសខាងលិច) ហើយបញ្ចប់នៅពាក់កណ្ដាលយប់។ គេអាចប្រតិបត្តិវានៅពេលសេតរុណរះបានក្នុងករណីចាំបាច់ណាមួយ។



ចំពោះជនមូស្លីមអាចពឹងផ្អែកលើប្រតិទិនទាំងឡាយដែលបញ្ជាក់ពីពេលវេលាសឡាត ហើយមិនចាំបាច់ពិនិត្យមើលការដល់ពេលវេលាសឡាតដោយខ្លួនឯងឡើយ

## > កន្លែងសឡាត



សាសនាឥស្លាមបានប្រើឱ្យប្រតិបត្តិសឡាតរួមគ្នាជាក្រុម(សឡាតជើម៉ាអះ) ហើយគប្បីត្រូវសឡាត(រួមគ្នានេះ)នៅក្នុងម៉ាស្ជិទដើម្បីឱ្យមានការជួបជុំសម្រាប់ជនមូស្លីម ក៏ដូចជាបង្កើនចំណងបងប្អូននិងសេចក្តីស្រលាញ់រវាងពួកគេ ហើយបានចាត់ទុកការប្រតិបត្តិសឡាតរួមគ្នានោះ គឺល្អប្រសើរជាងការប្រតិបត្តិសឡាតតែម្នាក់ឯងជាច្រើនកម្រិត ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “ការសឡាតរួមគ្នា(សឡាតជើម៉ាអះ) គឺល្អប្រសើរជាងការសឡាតម្នាក់ឯងចំនួន២៧កម្រិត”។(អាល់ពូខរីៈ៦១៩ មូស្លីមៈ៦៥០ អះម៉ាត់ៈ៥៩២១)

ក៏ប៉ុន្តែ ទោះបីជាសឡាតនៅទីកន្លែងណាក៏ដោយ ក៏ត្រឹមត្រូវដែរ។ នេះហើយជាក្តីមេត្តាករុណារបស់អល់ឡោះមកលើយើងទាំងអស់គ្នា ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “ហើយគេបានផ្តល់ដីឱ្យខ្ញុំគឺជាម៉ាស្ជិត ហើយវា(ដី)គឺមានភាពជ្រះស្អាត។ បុរសម្នាក់ណាក៏ដោយអំពីប្រជាជាតិរបស់ខ្ញុំនៅពេលដែលដល់ពេលសឡាត ចូរឱ្យគេសឡាតចុះ”។(អាល់ពូខរី ៣២៨ មូស្លីម ៥២១)

### លក្ខណៈនៃកន្លែងសឡាតៈ

ឥស្លាមបានដាក់លក្ខខណ្ឌចំពោះកន្លែងសឡាតគឺត្រូវឱ្យដីនោះមានភាពជ្រះស្អាត។ អល់ឡោះបានមានបន្ទូលថា “ហើយយើងបានបញ្ជារចំពោះអ៊ីព្រហ៊ីម និងអ៊ីស្មាអែលថា ចូរអ្នកទាំងពីរសម្អាតកាក់ហ្ពះរបស់យើងសម្រាប់បណ្តាអ្នកតវ៉ាហ្វ និងបណ្តាអ្នកអៀកទីកាហ្វ និងបណ្តាអ្នករូកុ ស៊ូជូត”។(គម្ពីរគួរអាន២ៈ១២៥)ហើយធាតុដើមរបស់ដីគឺជ្រះស្អាតហើយប្រការកខ្វក់កើតឡើងមកក្រោយ។ អ្វីដែលមិនបានដឹងថាមានប្រការកខ្វក់ទេនោះ គេកំណត់ថាវាមានភាពជ្រះស្អាត ហើយមិនគប្បីយកកម្រាល ឬក្រណាត់ដែលគេមិនសឡាតលើកលែងតែនៅលើវានោះឡើយ។

## ក្នុងនោះដែរ មានចំណុចជាច្រើនដែលចាំបាច់ត្រូវពិនិត្យនៅកន្លែងសឡាត ដូចជា ៖

1. កន្លែងសឡាតរបស់គេមិនត្រូវឱ្យមានការប៉ះពាល់ដល់មនុស្សឡើយ ដូចជាការសឡាតនៅលើផ្លូវដើរ កន្លែងដែលគេឆ្លងកាត់ និងកន្លែងដែលត្រូវបានគេហាមមិនឱ្យឈប់ដែលនាំឱ្យមានផលវិបាក និងកកស្ទះដល់មនុស្ស។ អ្នកនាំសារបានហាមឃាត់អំពីការរំលោភបំពាន និងបង្កគ្រោះថ្នាក់ ដោយលោកមានប្រសាសន៍ថា "ចូរកុំបង្កគ្រោះថ្នាក់ដល់ខ្លួនឯង ហើយកុំបង្កគ្រោះថ្នាក់ដល់អ្នកដទៃ"។ (អ៊ិពនូម៉ាហ្ជះ:២៣៤០ អះម៉ាត់:២៨៦៥)

2. កន្លែងសឡាតនោះ មិនត្រូវមានអ្វីដែលបង្កការរំខានដល់អ្នកសឡាតឡើយ ដូចជាមានរូបភាព ឬសម្លេងខ្លាំង និងសម្លេងតន្ត្រីជាដើម។

3. កន្លែងនោះមិនមែនជាកន្លែងបង្ហាញពីការគោរពសក្ការៈបែបលេងសើច និងការសើចចំអកឡើយ ដូចជាបុគ្គលម្នាក់សឡាតនៅកន្លែងផឹកស្រា ឬជ្រុលនិយម និងអ្វីផ្សេងពីនេះទៀត។ ហើយអល់ឡោះបានហាមឃាត់អំពីការជេរប្រមាថដល់ព្រះរបស់ពួកគ្មានជំនឿ ព្រោះវាជាហេតុនាំឱ្យពួកគេជេរប្រមាថដល់អល់ឡោះវិញទាំងបំពានដោយគ្មានចំណេះដឹង។ អល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នក(ជនមូស្លីម)កុំជេរប្រមាថចំពោះព្រះនានាដែលពួកគេបួងសួងផ្សេងពីអល់ឡោះឱ្យសោះ ព្រោះវាជាហេតុធ្វើឱ្យពួកគេជេរប្រមាថអល់ឡោះវិញទាំងបំពាន ដោយគ្មានចំណេះដឹង”។ (គម្ពីរគួរអាន ៦:១០៨)

4. កន្លែងនោះមិនមែនជាកន្លែងដែលរៀបចំសម្រាប់ប្រព្រឹត្តអំពើខុសឆ្គងនិងអល់ឡោះឡើយ ដូចជា ឱស្ថ និងក្លឹបរាត្រី ដែលគេមិនពេញចិត្តក្នុងការសឡាតនៅក្នុងវា។



## > កន្លែងសឡាត



**តើអ្នកអាចប្រតិបត្តិសឡាតរួមគ្នាក្នុងម៉ាស្ជិទបានដែរឬទេ?**

ទេ | បាទ

- **បាទ:** បញ្ជាក់លើបុរសនោះឱ្យប្រតិបត្តិសឡាតរួមគ្នា ហើយវាជាទង្វើដ៏អស្ចារ្យ និងអល់ឡោះស្រលាញ់បំផុត ហើយគេក៏អនុញ្ញាតផងដែរចំពោះស្ត្រី។

**ប្រសិនបើអ្នកមិនអាចប្រតិបត្តិវាក្នុងម៉ាស្ជិទ តើកន្លែងផ្សេងទៀតមានភាពកខ្វក់ដែរឬទេ?**

ទេ | បាទ

- **បាទ:** គេហាមឃាត់មិនឱ្យសឡាតកន្លែងដែលមានភាពកខ្វក់ឡើយ ហើយអល់ឡោះបានប្រើឱ្យយើងមានភាពជ្រះស្អាតក្នុងពេលសឡាត។

**ប្រសិនបើកន្លែងនោះមិនមានភាពកខ្វក់ តើការសឡាតនៅទីនោះមានផលប៉ះពាល់ដល់មនុស្សឬអត់ ដូចជានៅលើផ្លូវដើររបស់ពួកគេ?**

ទេ | បាទ

- **បាទ:** គេហាមឃាត់មិនឱ្យបំពានលើមនុស្ស និងផ្តល់ភាពលំបាកដល់ពួកគេឡើយ សូម្បីតែក្នុងពេលសឡាតក៏ដោយ។ ចាំបាច់លើអ្នក ត្រូវជ្រើសរើសកន្លែងផ្សេង។

**តើកន្លែងនោះមានអ្វីដែលនាំឱ្យអ្នកពិបាកក្នុងការសឡាតដែរឬទេ ដូចជាមានរូបភាព ឬសម្លេងលឺខ្លាំង?**

ទេ | បាទ

- **បាទ:** ចាំបាច់ចេញឱ្យឆ្ងាយពីអ្វីដែលនាំឱ្យប៉ះពាល់ដល់អ្នកសឡាត និងរំខានដល់ការសឡាត។
- **ទេ:** លក្ខណៈពិសេសរបស់ប្រជាជាតិនេះ និងក្តីអាណិតស្រលាញ់ពីអល់ឡោះលើពួកគេ គឺទ្រង់ចាត់ទុកការសឡាតនោះមានភាពត្រឹមត្រូវ ទោះបីជាគេសឡាតនៅទីកន្លែងណាក៏ដោយនៅលើផែនដីនេះ។

# > របៀបសឡាត

**1** នៀត ( ការប៉ង )

គឺជាលក្ខខណ្ឌមួយដើម្បីឱ្យការសឡាតមានភាពត្រឹមត្រូវមានន័យថា ជាការប៉ងដោយចិត្តរបស់គេគោរពសក្ការៈទៅចំពោះអល់ឡោះតាមរយៈការសឡាត ហើយគេត្រូវដឹងថា គេកំពុងសឡាតម៉ាហ្រ៊ិប ឬ សាឡាតអ៊ិសា ឧទាហរណ៍។ ហើយគេមិនបានកំណត់ឱ្យពោលនឹងមាត់ឡើយក្នុងការប៉ងនេះ ផ្ទុយទៅវិញ ការប៉ងដោយចិត្តនិងគំនិត វាជាអ្វីដែលគេត្រូវការ ហើយការពោលដោយមាត់ វាជាការខុសឆ្គង ពីព្រោះវាគ្មានភស្តុតាងពីព្យាការីនិងមិត្តភក្តិរបស់លោកឡើយ។



**2** ឈរឱ្យត្រង់ដើម្បីសឡាត ហើយសូត្រថា "អល់ឡោះហ៊ូអឹកពើរ" ដោយលើកដៃទាំងពីរបស់គេរហូតដល់ស្មាទាំងពីរ ឬខ្ពស់ជាងបន្តិច ហើយដាក់បាតដៃតម្រង់ទិសគិបឡាត់។

ហើយការតឹកពៀរមិនត្រឹមត្រូវទេលើកលែងតែសូត្រដោយពាក្យនេះ "អល់ឡោះហ៊ូអឹកពើរ"។ អត្ថន័យរបស់វាការលើកតម្កើង និងសេចក្តីរុងរឿងចំពោះអល់ឡោះ។ អល់ឡោះមហាធំធេងបំផុតលើគ្រប់អ្វីទាំងអស់ ខ្ពង់ខ្ពស់ជាងផែនដីនិងអ្វីដែលទាំងអស់នៅក្នុងវា អំពីការប៉ងប្រាថ្នា និងការសោយសុខ។ ចូរយើងបោះបង់ចោលរាល់ប្រការសប្បាយទាំងនោះ ហើយតម្រង់ឆ្ពោះទៅរកអល់ឡោះដែលមហាធំធេងនិងខ្ពង់ខ្ពស់ក្នុងពេលសឡាតដោយចិត្ត និងសតិរបស់យើងដោយភាពកោតខ្លាច។



**3** បន្ទាប់ពី តឹកពៀរ
ដាក់ដៃខាងស្តាំរបស់គាត់លើដៃខាងឆ្វេង ហើយដាក់លើដើមទ្រូង ហើយធ្វើដូច្នេះជានិច្ចក្នុងពេលឈរ។

**4** គប្បីសូត្រ ទូអាអ៊ីហ្វទីហ្វតះ

سبحانك اللهم وبحمدك، وتبارك اسمك،
وتعالى جدك، ولا إله غيرك

( ស៊ុបហាណាកល់ឡហ៊ុមម៉ា វ៉ាពីហាំទីកា វ៉ាតាហ្ព្ា វ៉ៃកាសម្ហូកា វ៉ាតាអាឡា ចាត់ទូកា វ៉ាឡើអ៊ីឡើហើ ហ្គ័យរូកា )។

**5** សូត្រ ( អាអ៊ូហ្សុពីលឡាហ៊ី មីណាស់ស្សៃត៏ នៀរ៉ជីម )។

(أعــوذ بالله من الشيطان الرجيم)

ហើយនេះជាការសូត្រ អ៊ីស្ទីអាហ្សះ ដែលមានន័យថា សុំការគេចចេញ និងថែរក្សាពីអល់ឡោះអំពីប្រការអាក្រក់របស់ស្ហែតន។

6 សូត្រ ( ពីសមិលឡើ ហៀរ៉ោះម៉ា នៀរ៉ហ៊ីម ) ។

(بسم الله الرحمن الرحيم)

ហ្គាស់ម៉ាឡុះ មានន័យថា ខ្ញុំចាប់ផ្តើមដោយការសុំជំនួយ និងពរជ័យនឹងនាមរបស់អល់ឡោះ។

7 សូត្រជំពូក អាល់ហ្វាទីហះ ហើយ អាល់ហ្វាទីហះ គឺជាជំពូក ដ៏ថ្កុំថ្កើងបំផុតនៅក្នុងគម្ពីររបស់អល់ឡោះ ( គម្ពីរគួរអាន ) ។

- ហើយពិតណាស់ អល់ឡោះបានផ្តល់ឱ្យអ្នកនាំសាររបស់ទ្រង់ដោយបញ្ជះវា ទ្រង់មានបន្ទូលថា "ហើយជាការពិតណាស់ យើងបានផ្តល់ឱ្យអ្នក ( ព្យាការីម៉ូហាំម៉ាត់ ) ប្រាំពីរឃ្លានៃអាល់ម៉ាសានី រួមជាមួយនិងគម្ពីរគួរអានដ៏ឧត្តុងឧត្តម" ។ ( គម្ពីរគួរអាន ១៥:៨៧ ) ហើយប្រាំពីរឃ្លានៃអាល់ម៉ាសានី វាជាជំពូក អាល់ហ្វាទីហះ។ គេឱ្យឈ្មោះវាបែបនេះព្រោះវាមានប្រាំពីរឃ្លា។
- ចាំបាច់លើជនមូស្លីមត្រូវសិក្សាពីវា ពីព្រោះការសូត្រវា គឺជាគោលគ្រឹះមួយនៃការសឡាត សម្រាប់អ្នកដែលសឡាតម្នាក់ឯង ឬជាអ្នកតាមអ៊ីម៉ាំ ( ម៉ាកមុំ ) ក្នុងពេលសឡាតដែលអ៊ីម៉ាំមិនសូត្រលឺ។

8 ក្រោយពីសូត្រហ្វាទីហះចប់ ឬពេលស្តាប់ការសូត្ររបស់អ៊ីម៉ាំចប់ គេបង្គាប់ប្រើឲ្យពោលពាក្យ "អាមីន" ដែលមានន័យថា ឱអល់ឡោះជាម្ចាស! សូមទ្រង់ទទួលយកផងចុះ។

9 បន្ទាប់ពីសូត្រហ្វាទីហះរួច ក្នុងពីររ៉ក្អាត់ដំបូង គប្បីសូត្រជំពូកផ្សេងទៀត ឬឃ្លាខ្លះៗនៃជំពូកផ្សេងទៀត។ ចំនែកឯរ៉ក្អាត់ទីបី និងទីបួន គឺសូត្រតែហ្វាទីហះប៉ុណ្ណោះ។

- សូត្រហ្វាទីហះ និងអ្វីដែលបន្ទាប់ពីវាដោយសម្លេងលឺៗក្នុងពេលសឡាតហ្វាជើរ និងពីររ៉ក្អាត់ដំបូងនៃសឡាតម៉ាហ្គ្រិប និង សឡាតអ៊ីសា ហើយសូត្រតិចៗនៅក្នុងសឡាតហ្ស៊ូហោរ និងអាសើរ។
- ចំណែកការហ្សិកៀរក្នុងសឡាត ( ក្រៅពីការសូត្រគួរអាន ) ត្រូវសូត្រតិចៗ។



ការសឡាតរបស់អ្នក

### ចំពោះអ្នកដែលមិនបានទន្ទេញជំពូក អាល់ហ្វាទីហះ និងហ្ស៊ីកៀរផ្សេងៗក្នុងសឡាត តើត្រូវធ្វើដូចម្តេច?

បុគ្គលណាដែលទើបចូលឥស្លាមថ្មី ហើយមិនបានទន្ទេញ អាល់ហ្វាទីហះ និងហ្ស៊ីកៀរផ្សេងៗ ក្នុងសឡាត ចាំបាច់លើគេត្រូវធ្វើដូចខាងក្រោម ៖

- គាត់ត្រូវខិតខំទន្ទេញហ្សីកៀរដែលចាំបាច់នៅក្នុងសឡាត ហើយសឡាតមិនត្រឹមត្រូវជាដាច់ខាត លើកលែងតែជាភាសាអារ៉ាប់ មានដូចជា:

  (អាល់ហ្វាទីហះ) និង (តឹកពៀរ) (ស៊ុបហាណា រ៉បពីយ៉ាល់ អាហ្សីម) និង (សើមីអល់ឡហ៊ូលីម៉ាន់ហាមីហ្ទះ) និង (រ៉បពើណាវ៉ាឡើ កាល់ហាំហ្ទ) និង (ស៊ុបហាណារ៉បពីយ៉ាល់អាក់ឡើ) និង (រ៉ប់ពៀកហ្វៀរលី) និងសូត្រពេល (អ៊ាត់តាសាសហ៊ុទ) និង (សឡាវ៉ាតលើព្យាការី) និង (អាស់សាឡាមូអាឡៃគុំ វ៉ារ៉ោះម៉ាតុលឡោះ)។

- ចាំបាច់លើជនមូស្លីមត្រូវសឡាត ទោះបីជាមិនទាន់ទន្ទេញចាំក៏ដោយ ដោយឱ្យគាត់រំលឹកនូវអ្វីដែលគាត់បានចាំដូចជាតាសហ្បៀហ និងតះមីទ និងតឹកពៀរក្នុងពេលលគាត់សឡាត ឬរំលឹកឃ្លាដែលគាត់បានទន្ទេញក្នុងពេលឈរសឡាត ដូចអល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នកកោតខ្លាចទៅចំពោះអល់ឡោះទៅតាមលទ្ធភាពដែលពួកអ្នកមាន”។ (គម្ពីរគួរអាន ៦៤:១៦)

- ចាំបាច់លើគាត់ក្នុងខណៈពេលនេះព្យាយាមឲ្យបានខ្លាំងក្នុងការចូលរួមសឡាតរួមគ្នា ដើម្បីអនុវត្តសឡាតរបស់គាត់ ពីព្រោះថា អ៊ីម៉ាំ ទទួលរ៉ាបរងទៅលើភាពខ្វះខាតរបស់ម៉ាក់ម៉ុំ។

### ស៊ូរោះ អាល់ហ្វាទីហះ មានអត្ថន័យដូចខាងក្រោម ៖

الْحَمْدُ لِلَّهِ رَبِّ الْعَالَمِينَ

រាល់ការសរសើរទាំងឡាយ គឺចំពោះអល់ឡោះដែលជាម្ចាស់គ្រប់គ្រងពិភពទាំងអស់។

الرَّحْمَنِ الرَّحِيمِ

ជាម្ចាស់មហាសប្បុរស មហាអាណិតស្រលាញ់។

مَالِكِ يَوْمِ الدِّينِ

ជាស្តេច(គ្រប់គ្រង)នៃថ្ងៃជំនុំជំរះ(បរលោក)។

إِيَّاكَ نَعْبُدُ وَإِيَّاكَ نَسْتَعِينُ

ចំពោះទ្រង់តែមួយគត់ដែលពួកយើងគោរពសក្ការៈ ហើយចំពោះទ្រង់តែមួយគត់ដែលពួកយើងសុំឱ្យជួយ។

اهدِنَا الصِّرَاطَ الْمُسْتَقِيمَ

សូមទ្រង់មេត្តាចង្អុលបង្ហាញដល់ពួកយើងនូវមាគាដ៏ត្រឹមត្រូវផងចុះ។

صِرَاطَ الَّذِينَ أَنْعَمْتَ عَلَيْهِمْ

គឺមាគ៌ារបស់បណ្តាអ្នកដែលទ្រង់បានប្រទាននៀកម៉ាត់ដល់ពួកគេ។

غَيْرِ الْمَغْضُوبِ عَلَيْهِمْ وَلاَ الضَّالِّينَ

ពុំមែនជា(មាគ៌ា)អ្នកដែលត្រូវគេខឹងសម្បា និង ពុំមែនជា(មាគ៌ា)ពួកដែលវង្វេងឡើយ។



10 បន្ទាប់មក តឹកពៀរដើម្បីរូកុ ដោយលើកដៃទាំងពីរ ដល់ស្មា ឬលើសបន្តិច ដាក់បាតដៃទាំងពីរ តម្រង់ទិសគិបឡាត់ ដូចដែរបានធ្វើវានៅពេល តឹកពៀរទីមួយ។

11 រូកុដោយដាក់ខ្នងរបស់គាត់តម្រង់ទិសគិបឡាត់ ហើយដាក់ខ្នង និងក្បាលរបស់គាត់ស្មើគ្នា ហើយដាក់ ដៃទាំងពីររបស់គាត់លើជង្គង់ទាំងពីររបស់គាត់ ហើយសូត្រថា

**(سبحان ربي العظيم)**

( ស៊ុបហា ណារ៉ប់ពីយ៉ាល់ អាហ្សីម )

គប្បីសូត្រវាឡើងវិញចំនួនបីដង។ ការចាំបាច់ គឺតែមួយដងប៉ុណ្ណោះ ហើយរូកុ ជាកន្លែងលើកតម្កើង និងសេចក្តីរុងរឿងចំពោះអល់ឡោះ។

**(سبحان ربي العظيم)**

មានន័យថា ភាពស្អាតស្អំចំពោះ អល់ឡោះដ៏ឧត្តុងឧត្តមនិងល្អពិសិដ្ឋ ចាកផុតពីភាពខ្វះខាត ហើយខ្ញុំសូត្រវានៅពេលដែលខ្ញុំរូកុ បន្ទាបខ្លួន អោនលំទោនចំពោះអល់ឡោះ។



12 ងើបពីរូកុ ហើយឈរត្រង់វិញ ដោយលើកដៃ ទាំងពីរឱ្យស្មើនឹងស្មាទាំងពីរ ហើយបាតដៃ របស់គាត់តម្រង់ទិសគិបឡាត់ ដូចដែលបានធ្វើ ហើយសូត្រ
**(سمع الله لمن حمده)**
( សាមីអល់ឡ ហ៊្វលីម៉ាន់ហាមីហ្ទុះ )

ប្រសិនបើជាអ៊ីម៉ាំ ឬអ្នកសឡាតម្នាក់ឯង។ បន្ទាប់មកសូត្រទាំងអស់គ្នា ថា (រ៉ប់ហ្ពាណា វ៉ាឡើកាល់ហាំទ៍ )

**(ربنـــا ولك الحمـــد)**

ហើយគប្បីសម្រាប់គាត់បន្ថែម ដោយសូត្រថា (ហាំហ្ទាន់ កាសីរ៉ាន់ ត័យយីហ្ពាន់ ម៉ូពើរ៉កាន់ហ្វីហ៊ី មីលអាស់សាម៉ាអ៊ី វ៉ាមីលអុលអើរហ្ទី វ៉ាមីលអាម៉ាស៊ិតា មីនស្សៃអ៊ីនហ្ពាក់ទូ )។

**حمداً كثيراً طيباً مباركاً فيه، ملءَ السماء وملء الأرض وملء ما شئت من شيء بعد**

13 បន្ទាប់មកតឹកពៀរហើយត្រូវអោនចុះទៅលើដី ដោយស៊ូជោតលើអវយវៈរបស់គាត់ទាំងប្រាំពីរ នោះគឺ ថ្ងាស់រួមនឹងច្រមុះ ដៃទាំងពីរ ជង្គង់ទាំងពីរ ជើងទាំងពីរ។ ហើយគប្បីលើគាត់ត្រូវញែកដៃទាំងពីរឱ្យឃ្លាតពីដងខ្លួនបន្តិច និងញែកពោះឱ្យឃ្លាតពីភ្លៅទាំងពីរ និងញែកភ្លៅទាំងពីរឱ្យឃ្លាតពីជើងទាំងពីរក្នុងពេលសឡាត ហើយលើកកំភួនដៃឱ្យផុតពីដី។



14 ហើយសូត្រក្នុងពេលស៊ូជោទថា ( ស៊ុបហាណា រ៉ប់ពីយ៉ាល់អាក់ឡា )

**(سبحان ربي الأعلى)**

ចាំបាច់ត្រូវសូត្រតែមួយដងប៉ុណ្ណោះ តែគប្បីសូត្រសាឡើងវិញចំនួនបីដង។

ស៊ូជោទជាកន្លែងបួងសួងដ៏ល្អបំផុតទៅចំពោះអល់ឡោះ ហើយគេបួងសួងនៅក្នុងវាបន្ទាប់ពីសូត្រអ្វីដែលជាកាតព្វកិច្ច នូវអ្វីដែលគាត់ត្រូវការអំពីប្រការល្អនៅក្នុងលោកិយ និងថ្ងៃបរលោក។ អ្នកនាំសារបានមានប្រសាសន៍ថា “គម្លាតជិតបំផុតរវាងខ្ញុំបម្រើនិងម្ចាស់របស់គេនោះ គឺក្នុងពេលស៊ូជោទ។ ហេតុនេះ ចូរពួកអ្នកបង្កើនការបួងសួងឲ្យបានច្រើន”។ (មូស្លីមៈ៤៨២)

**(سبحان ربي الأعلى)**

មានន័យថា ភាពល្អពិសិដ្ឋចំពោះអល់ឡោះដែលខ្ពង់ខ្ពស់លើភាពខ្លាំងពូកែរបស់ទ្រង់ និងឥទ្ធិពលរបស់ទ្រង់ ហើយភាពខ្ពង់ខ្ពស់លើមេឃទាំងអស់ ដោយឃ្លាតឆ្ងាយពីរាល់ភាពខ្វះខាត និងការអសមត្ថភាព។ នៅក្នុងនោះដែរ គឺផ្តល់ការប្រុងប្រយ័ត្នសម្រាប់អ្នកស៊ូជោទ ដោយការភ្ជាប់ខ្លួនទៅនិងដីដោយការអោនលំទោន នឹងស្ដាប់បង្គាប់ដើម្បីនឹករលឹកពីភាពខុសគ្នារវាងគាត់នឹងអ្នកបង្កើតគាត់ដ៏ខ្ពង់ខ្ពស់(ព្រះអល់ឡោះ) ហើយបន្ទាបខ្លួនទៅចំពោះម្ចាស់របស់គាត់ និងឱនលំទោនទៅចំពោះអ្នកគ្រប់គ្រងគាត់។

15 បន្ទាប់មកតឹកពៀរ ហើយងើបអង្គុយរវាង ស៊ូជោទទាំងពីរ។ គប្បីលើគាត់អង្គុយលើជើងខាងឆ្វេងរបស់គាត់ ហើយជើងស្ដាំដាក់សណ្ដូកត្រង់ ហើយដាក់ដៃទាំងពីរលើភ្លៅទាំងពីរបន្ទាប់ពីជង្គង់។

- ហើយរាល់ការអង្គុយក្នុងសឡាតទាំងអស់គប្បីត្រូវធ្វើតាមរបៀបនេះ ក្នុងពេលអង្គុយលើកលែងតែពេលអង្គុយ អាត់តាសាសហ៊ុទ។ ចុងក្រោយ គប្បីលើគាត់ដាក់ជើងស្ដាំសណ្ដូកត្រង់ដូចគ្នាដែរ ក៏ប៉ុន្តែដាក់ជើងឆ្វេងពីក្រោមវា ហើយអង្គុយនៅលើដី។
- បុគ្គលណាដែលមិនអាចអង្គុយក្នុងពេលសឡាតដូចបានរៀបរាប់ដូចជាអង្គុយអាត់តាសាសហ៊ូទដំបូង ឬអាត់សាសហ៊ូទចុងក្រោយ ដោយមានការឈឺចាប់ត្រង់ជង្គង់ ឬព្រោះតែគាត់មិនអាចធ្វើវាបាន គាត់អាចអង្គុយយ៉ាងណាក៏បាន ឱ្យតែមានភាពស្រដៀងនឹងវាទៅតាមភាពងាយស្រួលក្នុងការអង្គុយរបស់គាត់។



16 សូត្រក្នុងពេលអង្គុយរវាងស៊ូជោទទាំងពីរថា (រ៉ប់ពៀកហ្វៀរលី)



(ربي اغفر لي)

ហើយគប្បីលើគាត់ត្រូវសូត្រសារឡើងវិញចំនួនបីដង។

17 បន្ទាប់មកស៊ូជោទលើកទីពីរដូចការស៊ូជោទលើកទីមួយដែរ។

18 បន្ទាប់មក ងើបពីស៊ូជោទទីពីររហូតដល់ឈរត្រង់ ដោយសូត្រថា អល់ឡហ៊ូអឹកពើរ

(الله أكبر)

19 ហើយសឡាតនៅរ៉ក្អាត់ទីពីរដូចក្នុងរ៉ក្អាត់ទីមួយដែរ។

20 ក្រោយពីស៊ូជោទទីពីរ ក្នុងរ៉ក្អាត់ទីពីរហើយ ត្រូវអង្គុយអាត់តាសាសហ៊ុទទីមួយ ដោយសូត្រ (អាត់តាហ៊ីយ៉ា ទូលិលឡះ វ៉ាស់សឡាវ៉ាតូ វ៉ាត់ត័យយីហ្ពាត អាស់សាឡាមូ អាឡៃកា អៃយូហាន់ព្យាការីយូ វ៉ារ៉ោះម៉ាតុលឡហ៊ី វ៉ាហ្ពារ៉កាតុះ អាស់សាឡាមូអាឡៃណា វ៉ាអាឡា អ៊ីហ្ពាទីលឡើ ហ៊ីសស័លីហ៊ីន អាស្ហាហាទូ អាល់លើអ៊ីលើហើ អ៊ីលឡលឡោះ វ៉ាអាស់ហើទូ អាន់ណា មូហាំម៉ាហ្ទាន់ អាប់ទូហ៊ូ វ៉ារ៉ស៊ូលុះ)។

التحيات لله والصلوات والطيبات، السلام عليك أيها النبي ورحمة الله وبركاته، السلام علينا وعلى عباد الله الصالحين، أشهد أن لا إله إلا الله، وأشهد أن محمدا عبده ورسوله

21 បន្ទាប់មក ងើបឈរឡើងវិញដើម្បីបំពេញសឡាតដែលនៅសល់ ប្រសិនបើវាជាសឡាតដែលមានបី ឬបួនរ៉ក្អាត់ ដោយគ្រាន់តែគាត់សូត្រក្នុងរ៉ក្អាត់ទីបី និងទីបួនតែហ្វាតីហះប៉ុណ្ណោះ។

ចំណែកឯសឡាតពីររ៉ក្អាត់ ដូចជាសឡាតហ្វាជើរ គឺត្រូវអង្គុយអាត់តាសាសហ៊ុទចុងក្រោយ ដូចដែលមានបន្ទាប់នេះ។

22 បន្ទាប់មក ក្នុងរ៉ក្អាត់ចុងក្រោយបន្ទាប់ពីស៊ូជោទទីពីរ ត្រូវអង្គុយអាត់តាសាសហ៊ុទចុងក្រោយ ហើយរបៀបសូត្ររបស់វាគឺដូច អាត់តាសាសហ៊ុទដំបូងដែរ ដោយគ្រាន់តែថែមការសឡាវ៉ាតទៅលើព្យាការីប៉ុណ្ណោះ ហើយរបៀបសូត្រនោះគឺ (អល់ឡហ៊ុមម៉ា សល់លីអាឡា មូហាំម៉ាត់ វ៉ាអាឡាអាលីមូហាំម៉ាត់ កាម៉ាសល់ឡៃតាអាឡាអ៊ីបព្រហ៊ីម វ៉ាអាឡាអាលីអ៊ីបព្រហ៊ីម អ៊ីនណាកា ហាមីទុមម៉ាជីទ វ៉ាពើរិកអាឡាមូហាំម៉ាត់ វ៉ាអាឡាអាលីមូហាំម៉ាត់ កាម៉ាពើរិកតាអាឡាអ៊ីបព្រហ៊ីម វ៉ាអាឡា អាលីអ៊ីបព្រហ៊ីម អ៊ីនណាកា ហាមីទុមម៉ាជីទ)។

اللهم صل على محمد وعلى آل محمد كما صليت على إبراهيم وعلى آل إبراهيم إنك حميد مجيد، وبارك على محمد وعلى آل محمد كما باركت على إبراهيم وعلى آل إبراهيم إنك حميد مجيد

ហើយគប្បីលើគាត់ សូត្របន្ទាប់ពីនោះថា (អាអ៊ូហ៊្សពីលឡើហ៊ី មិនអាហ្សាបពី ជើហាន់ណាំ វ៉ាមិនអាហ្សាបពីល កប់រី វ៉ាមិន ហ្វីតណាតិល ម៉ះយ៉ា វ៉ាលម៉ាម៉ាត វ៉ាមិន ហ្វីតណាតិល ម៉ាស៊ីហ៊ីទ ហ្វាច់ហ្ជាល)។

(أعوذ بالله من عذاب جهنم، ومن عذاب القبر، ومن فتنة المحيا والممات، ومن فتنة المسيح الدجال)

ហើយបួងសួងសុំនូវអ្វីដែលគេចង់បាន។

23 បន្ទាប់មកងាកទៅទិសខាងស្តាំហើយសូត្រថា អាស់សាឡាមូ អាឡៃគុំ វ៉ារ៉ោះម៉ាតុលឡោះ។

(السلام عليكم ورحمة الله)

បន្ទាប់មកបែរទៅទិសខាងឆ្វេងរួចសូត្រដូចគ្នាដែរ។

តាមរយៈការឱ្យសាឡាមនេះ ការសឡាតរបស់ជនមូស្លីមត្រូវបានបញ្ចប់ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “ការហាមឃាត់របស់វាគឺបន្ទាប់ពីតឹកពៀរ ហើយការអនុញ្ញាតរបស់វា បន្ទាប់ពីឲ្យសាឡាម”។(អាពូទើវូទ:៦១ អាត់តៀរមីហ្ស៊ី:៣) មានន័យថាការចូលក្នុងសឡាតដោយការតឹកពៀរលើកដំបូង ហើយចេញពីសឡាតវិញ ដោយការឱ្យសាឡាម។

24 គប្បីលើជនមូស្លីមក្រោយពីឲ្យសាឡាមនៃសឡាតដែលជាកាតព្វកិច្ច ត្រូវសូត្រ:

១. (អាស់តោគហ្វៀរុលឡោះ) ចំនួនបីដង

(أستغفر الله)

២. ហើយសូត្រ (អល់ឡហ៊ូមម៉ាអាន់តាសសាឡាម វ៉ាមីនកាសសាឡាម តាពើរ៉កតាយ៉ាហ្សៀល ជើឡើលីវ៉ាល់អ៊ីក់រ៉ម)។

(اللهم أنت السلام ومنك السلام تباركت يا ذا الجلال والإكرام)

(អល់ឡហ៊ូមម៉ាឡើ ម៉ានីអា លីម៉ា អាកត័យតា វ៉ាលើមូកតីយ៉ា លីម៉ា ម៉ាណាក់តា វ៉ាឡើ យ៉ាន់ហ្វាអ៊ូ ហ្សៀលហ្ជាត់ទី មិនកើលហ្ជាត់ទូ)។

(اللهم لا مانع لما أعطيت ولا معطي لما منعت ولا ينفع ذا الجد منك الجد)

៣. បន្ទាប់មកសូត្រ ៖

(سبحان الله) (ស៊ុបហាណល់ឡោះ) ចំនួន៣៣ដង

(الحمد لله) (អាល់ហាំទូ លីលឡះ) ចំនួន៣៣ដង

(الله أكبر) (អល់ឡហ៊ូ អឹកពើរ) ចំនួន៣៣ដង

ហើយបំពេញឱ្យគ្រប់មួយរយដោយសូត្រថា

(ឡើអ៊ីឡើហ៊ី អ៊ីលលល់ឡោះ វ៉ះទើហ៊ូ ឡើស្ហារីកាឡះ ឡើហ៊ុលមុលគូ វ៉ាឡើហ៊ុលហាំទូ វ៉ាហ៊ូវ៉ា អាឡើ គុលលីសែអិ នកទៀរ)។

لا إله إلا الله وحده لا شريك له، له الملك وله الحمد وهو على كل شيء قدير



## > តើខ្ញុំត្រូវសឡាតយ៉ាងដូចម្តេច?(ការឈរ-ការរូកុ-ការស៊ូជោដ)

1

ឈរឱ្យត្រង់ ហើយសូត្រថា (អល់ឡោះហូអឹកពើរ) ហើយលើកដៃទាំងពីររបស់គាត់ដាក់ចន្លោះរវាងស្មាទាំងពីរ និងត្រចៀកទាំងពីរ។



2

ដាក់ដៃស្តាំរបស់គេលើដៃឆ្វេង ហើយដាក់លើដើមទ្រូង ហើយសូត្រជំពូកអាល់ហ្វាទីហះ និងសូត្រជាមួយវាផងដែរនូវអ្វីដែលអ្នកចេះអំពីគម្ពីរគួរអានក្នុងរ៉ក្អាត់ទី១ និងទី២។



3

តឹកពៀរដោយលើកដៃទាំងពីររបស់គេ បន្ទាប់មកបន្ទន់ខ្នងតម្រង់ទៅទិសគិបឡាត់ ហើយដាក់បាតដៃទាំងពីរលើជង្គង់ទាំងពីររបស់គាត់ ហើយសូត្រថា

(سبحان ربي العظيم)

(ស៊ុបហាណា រ៉បពីយ៉ាល់ អាហ្សុីម) ចំនួនបីដង





4 ងើបពីរូកុហើយឈរឱ្យត្រង់វិញដោយលើកដៃទាំងពីរឱ្យដូចពេលតឹកពៀរ ហើយសូត្រ

(سمع الله لمن حمده)

( សាមីអល់ឡហ៊ូ លីម៉ាន់ហាមីហ្ទុះ ) ប្រសិនបើជាអ៊ីម៉ាំ ឬសឡាតម្នាក់ឯង ។ បន្ទាប់មក សូត្រទាំងអស់គ្នា( ទាំងអ៊ីម៉ាំ ម៉ាក់មុម និងអ្នកសឡាតម្នាក់ឯង )ថា

(ربنـــا ولك الحمـــد)

( រ៉ប់ហ្ពាណា វ៉ាឡើកាល់ហាំទូ )

5 បន្ទាប់មក តឹកពៀរដោយមិនលើកដៃទាំងពីរ ហើយអោនចុះទៅស៊ូជោទ ហើយត្រូវស៊ូជោទលើអវយវៈរបស់គាត់ទាំងប្រាំពីរ នោះគឺថ្ងាស់រួមនឹងច្រមុះ ដៃទាំងពីរ ជង្គង់ទាំងពីរ ជើងទាំងពីរ។ ហើយសូត្រថា ( ស៊ុបហាណា រ៉ប់ពីយ៉ាល់ អាក់ឡើ ) ចំនួនបីដង

(سبحان ربي الأعلى)





6 បន្ទាប់មក អង្គុយចន្លោះស៊ូជោទទាំងពីរ ដោយជើងស្ដាំដាក់សណ្ដូកត្រង់ ហើយអង្គុយលើជើងខាងឆ្វេង ហើយដាក់ដៃទាំងពីរលើគល់ភ្លៅ ហើយសូត្រថា

(ربي اغفر لي)

(រ៉ប់ពៀកហ្វៀរលី ) ចំនួនបីដង

បន្ទាប់មកស៊ូជោទម្ដងទៀត ហើយត្រូវធ្វើដូចមុនដែរ។



ការសឡាតរបស់អ្នក

## > តើខ្ញុំត្រូវសឡាតដូចម្តេច? (រ៉ក្អាត់ទីពីរ-អាត់តាសាសហ៊ុទ-សាឡាំម)

7

ងើបអំពីស៊ូជោទ ហើយក្រោកឈរទឡើង ដើម្បីសឡាតរ៉ក្អាត់ទីពីរ ហើយប្រតិបត្តិវាដូច រ៉ក្អាត់ទីមួយដែរ (ការឈរ ការសូត្រ ការរូកុ ការងើបពីរូកុ និងការស៊ូជោទ)។



8

ក្រោយពីស៊ូជោទលើកទីពីរនៃរ៉ក្អាត់ទីពីរ គាត់ត្រូវអង្គុយ អាត់តាសាសហ៊ុទដំបូង ដូចការអង្គុយរវាងស៊ូជោទទាំងពីរដែរ ហើយសូត្រថា (អាត់តាហ៊ីយ៉ាទូ លីលឡាហ៊ិ វ៉ាស់សឡាវ៉ាទូ វ៉ាត់ត័យយីហ្ពាត អាស់សាឡាមូអាឡៃកា អៃយូហាន់ញាការីយូ វ៉ារ៉ោះម៉ាទុលឡហ៊ិ វ៉ាហ្ពារ៉កាតូះ អាស់សាឡាមូអាឡៃណា វ៉ាអាឡា អ៊ីហ្ពាទីលឡា ហ៊ីសសលីហ៊ីន អាស្ហហាទូ អាល់លើអ៊ុលើហា អ៊ីលលល់ឡោះ វ៉ាអាស្ហហាទូ អាន់ណា មូហាំម៉ាហ្ពាន់ អាប់ទូហ៊ូ វ៉ារ៉ស៊ូលុះ)។

**التحيات لله والصلوات والطيبات السلام عليك أيها النبي ورحمة الله وبركاته السلام علينا وعلى عباد الله الصالحين أشهد أن لا إله إلا الله وأشهد أن محمداً عبده ورسوله**

9

ប្រសិនបើវាជាសឡាតដែលមានបី ឬបួនរ៉ក្អាត់ គេត្រូវឈរទឡើងដើម្បីសឡាតរ៉ក្អាត់ទីបី ហើយប្រតិបត្តិវាដូចរ៉ក្អាត់ទីមួយនិងទីពីរដែរ ក៏ប៉ុន្តែមិនសូត្រជំពូកផ្សេងទេបន្ទាប់ពី អាល់ហ្វាទីហះ។ ចំណែកកាយវិការ និងការសូត្រផ្សេងៗទៀត ត្រូវធ្វើដូចមុន។



**10** នៅរ៉ក្អាត់ចុងក្រោយ គេត្រូវអង្គុយក្រោយពីស៊ូជោទ ហើយសូត្រអាត់តាសាសហ៊ូទដំបូង ។ បន្ទាប់មកសឡាវ៉ាតលើព្យាការី ហើយរបៀបសូត្រនោះគឺ (អល់ឡហ៊ុមម៉ាសល់លីអាឡើម្ហូហាំម៉ាត់ វ៉ាអាឡើអាលីមូហាំម៉ាត់ កើម៉ាសល់ឡៃតាអាឡើអ៊ីបព្រហ៊ីម វ៉ាអាឡើអាលីអ៊ីបព្រហ៊ីម អ៊ិនណាកាហាមីទុមម៉ាជីត វ៉ាពើរីកអាឡើមូហាំម៉ាត់ វ៉ាអាឡើអាលីមូហាំម៉ាត់ កាម៉ាហ្ពារីកតា អាឡើអ៊ីបព្រហ៊ីម វ៉ាអាឡើអាលីអ៊ីបព្រហ៊ីម អ៊ិនណាកាហាមីទុមម៉ាជីត) ។

**اللهم صل على محمد وعلى آل محمد كما صليت**
**على إبراهيم وعلى آل إبراهيم إنك حميد مجيد،**
**وبارك على محمد وعلى آل محمد كما باركت على**
**إبراهيم وعلى آل إبراهيم إنك حميد مجيد**





**11** បន្ទាប់មក ឱ្យសាឡាមដោយងាកមុខបែរទៅទិសខាងស្តាំ ហើយសូត្រថា (អាស់សាឡាមូ អាឡៃគុម វ៉ារ៉ោះម៉ាតុលឡោះ) ។

**(السلام عليكم ورحمة الله)**

បន្ទាប់មកបែរទៅទិសខាងឆ្វេង សូត្រថា (អាស់សាឡាមូ អាឡៃគុម វ៉ារ៉ោះម៉ាតុលឡោះ)

**(السلام عليكم ورحمة الله)**

## > គោលគ្រឹះ(រូកុន) និងប្រការចាំបាច់(វ៉ាជិប) នៃសឡាត

គោលគ្រឹះនៃសឡាត(រូកុនសឡាត): គឺចំណែកគោលរបស់សឡាត ដែលសឡាតនឹងត្រូវខូច ប្រសិនបើបោះបង់វាដោយចេតនា ឬអចេតនា។

វាមានដូចខាងក្រោមនេះ

តឹកពៀរ៉តុលអៀហរ៉ម(តឹកពៀរលើកតំបូងពេលផ្តើមសឡាត) ការឈរជាមួយនឹងលទ្ធភាព សូត្រហ្វាទីហះសម្រាប់អ្នកមិនមែនជាម៉ាក់មុំ ការរូកុ ការងើបពីរូកុ ការស៊ូជោទ អង្គុយរវាងស៊ូជោទទាំងពីរ ការសូត្រតាសាសហ៊ុទចុងក្រោយ និងការអង្គុយដើម្បីសូត្រ ភាពនឹងនរ និងការឱ្យសាឡាម។

កាតព្វកិច្ចនៃសឡាត(ប្រការវ៉ាជិបនៃសឡាត): វាគឺជាចំណែកដែលចាំបាច់ក្នុងសឡាត ហើយធ្វើឱ្យសឡាតខូច ប្រសិនបើបោះបង់វាដោយចេតនា ក៏ប៉ុន្តែប្រសិនបើភ្លេច ឬអចេតនានោះ គឺគេត្រូវបំពេញកន្លែងចន្លោះនោះដោយស៊ូជោទសះវី ដែលយើងនឹងពន្យល់នាពេលក្រោយ។

កាតព្វកិច្ចនៃសឡាតមានដូចខាងក្រោម

តឹកពៀរទាំងអស់ផ្សេងពីតឹកពៀរ៉តុលអៀហរ៉ម ការសូត្រ "ស៊ុបហាណារ៉បពីយ៉ាលអាហ្សីម" ចំនួនមួយដង ការសូត្រ "សាមីអល់ឡហ៊ូ លីម៉ាន់ហាមីហ្ទះ" សម្រាប់អ្នកសឡាតម្នាក់ឯង និងអ៊ីមុាំ ការសូត្រ "រ៉ប់ហ្ពាណា វ៉ាឡៅកាល់ហាំទូ" សម្រាប់ទាំងអស់គ្នា(អ៊ីមុាំ ម៉ាក់មុម និងអ្នកសឡាតម្នាក់ឯង) ការសូត្រ "ស៊ុបហាណា រ៉ប់ពីយ៉ាលអាក់ឡៅ" ចំនួនមួយដងក្នុងពេលស៊ូជោទ ការសូត្រ "រ៉ប់ពៀកហ្វៀរលី" ចំនួនមួយដងក្នុងពេលអង្គុយរវាងស៊ូជោទទាំងពីរ ការសូត្រតាសាសហ៊ុទដំបូង។ កាតព្វកិច្ចទាំងនេះ ប្រសិនបើភ្លេចដោយអចេតនា ចាំបាច់ត្រូវស៊ូជោទសះវី។

ប្រការគួរគប្បីធ្វើនៅក្នុងសឡាត(ប្រការស៊ូណិត): រាល់អ្វីៗដែលមិនមែនជាគោលគ្រឹះនៃសឡាត និងកាតព្វកិច្ចនៃសឡាត អំពីពាក្យសំដី និងកាយវិកា វាជាប្រការគួរគប្បីធ្វើ(ប្រការស៊ូណិត) ដែលជួយបំពេញសឡាត គប្បីត្រូវថែរក្សាវា។ ក៏ប៉ុន្តែ សឡាតមិនខូចទេប្រសិនបើបោះបង់វានោះ។



>ឋានៈរបស់អ្នកដែលសឡាតកើនខ្ពស់ឡើងហើយត្រូវបានបន្ថែមការតបស្នងឲ្យវាតាមកម្រិតនៃភាពស្មឹងស្មាធរបស់គេទៅចំពោះអល់ឡោះ ហើយនិងឃ្លាតឆ្ងាយអំពីប្រការដែលនាំឲ្យខាននៅក្នុងសឡាត។

## ស៊ូដោទសះរី

វាជាការស៊ូដោទចំនួនពីរដងដែលអស់ឡោះបានដាក់វាដើម្បីបំពេញភាពកង្វះខាត និងការខ្វះចន្លោះក្នុងពេលសឡាត។

តើត្រូវអនុវត្តវានៅពេលណា ?

គេត្រូវអនុវត្តស៊ូដោទសះរីក្នុងករណីដូចខាងក្រោម:

1. ប្រសិនបើគេបានថែមក្នុងសឡាត រ៉ូកុ ឬស៊ូដោទ ឬឈរ ឬអង្គុយ ដោយមូលហេតុភ្លេច ឬខុស គេត្រូវស៊ូដោទសះរី។

2. ប្រសិនបើបាត់បង់អ្វីមួយអំពីគោលគ្រឹះ(រ៉ូកុន) ចាំបាច់ឱ្យគាត់ត្រឡប់ទៅបំពេញគោលគ្រឹះនោះ ហើយត្រូវស៊ូដោទសះរី នៅចុងក្រោយនៃសឡាតរបស់គាត់។

3. ប្រសិនបើបោះបង់កាតព្វកិច្ច(រ៉ូកុន)មួយក្នុងចំណោមកាតព្វកិច្ចនៃសឡាតដូចជាតាសាសហ៊ុទដំបូង ដោយធ្វេសប្រហែស និងភ្លេច ពិតណាស់គាត់ ត្រូវស៊ូដោទសះរី។

4. ប្រសិនបើមានការសង្ស័យក្នុងចំនួនរ៉ក្អាត់ ពិតណាស់ គាត់ត្រូវជ្រើសរើសលើការជឿជាក់ ហើយវាគឺចំនួនតិច(ជ្រើសរើសយករ៉ក្អាត់ដែលតិច) ហើយត្រូវស៊ូដោទសះរី។

របៀបស៊ូដោទសះរី: ស៊ូដោទចំនួនពីរដង ដោយអង្គុយរវាងវាទាំងពីរ ដូចជាក្នុងការស៊ូដោទនិងអង្គុយរវាងស៊ូដោទទាំងពីរក្នុងពេលសឡាតដែរ។

ពេលស៊ូដោទ: សម្រាប់ស៊ូដោទសះរីមានពីរពេល ហើយអាចប្រតិបត្តិក្នុងពេលមួយណាក៏បាន:

- មុនពេលឱ្យសាឡាម និងក្រោយតាសាសហ៊ុទចុងក្រោយ៖ គាត់ត្រូវស៊ូដោទ បន្ទាប់មកឱ្យសាឡាម។
- ក្រោយពេលឱ្យសាឡាមពីសឡាត៖ គាត់ត្រូវស៊ូដោទសះរីពីរដង បន្ទាប់មកឱ្យសាឡាមម្តងទៀត។



> គេមិនពេញចិត្ត(ម៉ាក្រុះ)ក្នុងការពើសលេងលើមុខឬដៃនៅពេលកំពុងសឡាត

## ប្រការដែលនាំឱ្យខូចសឡាត

1. សឡាតនឹងត្រូវខូចដោយការបោះបង់គោលគ្រឹះណាមួយ ឬលក្ខខណ្ឌណាមួយនៃការសឡាត ខណៈដែលគេមានលទ្ធភាពអាចធ្វើវា ទោះដោយចេតនា ឬអចេតនាក៏ដោយ។
2. សឡាតនឹងត្រូវខូចដោយការបោះបង់កាតព្វកិច្ចមួយនៃកាតព្វកិច្ចសឡាតដោយចេតនា។
3. សឡាតនឹងត្រូវខូចដោយការនិយាយដោយចេតនា។
4. សឡាតនឹងត្រូវខូច ដោយការសើចចេញសំលេង។
5. សឡាតនឹងត្រូវខូចដោយកាយវិការច្រើនជាប់ៗគ្នាដោយគ្មានការចាំបាច់។

## ប្រការដែលមិនគប្បីធ្វើពេលសឡាត

វាជាទង្វើដែលនាំឱ្យខាតផលបុណ្យនៃសឡាត និងនាំឱ្យបាត់បង់ភាពនឹងនរ និងភាពស្ងឹងស្ងាធ ហើយវាមានដូចខាងក្រោមនេះ:

1. មិនគប្បីងាកមុខនៅក្នុងសឡាត ពីព្រោះព្យាការីត្រូវបានគេសួរអំពីការងាកនៅក្នុងសឡាត? លោកបានឆ្លើយថា “វាគឺជាការកញ្ឆក់មួយ ដែលស្ហៃតននឆក់យកសឡាតរបស់មនុស្ស”។ (អាល់ពូខរីៈ៧១៨)។
2. មិនគប្បីកកេះរុះរើដៃនិងមុខលេង និងដាក់ដៃប្រត់ចង្កេះ និងស្រាក់ម្រាមដៃចូលគ្នាហើយកាច់វាឡើយ។
3. មិនគប្បីក្នុងពេលកំពុងសឡាត តែចិត្តរបស់គាត់គិតពីអ្វីផ្សេង ដោយតម្រូវការទៅបន្ទប់ទឹក ឬតម្រូវការចំណីអាហារ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “គ្មានទេការសឡាតនៅពេលគេលើកអាហារមកដល់ ហើយក៏ដូចគ្នាដែរ នៅពេលគាត់ខំទប់ទុក្ខសត្វទាំងពីរ”។ (មូស្លឹមៈ៥៦០)

# > តើអ្វីទៅជាការសឡាតស៊ូណាត(ថ្វាយបង្គំស្ម័គ្រចិត្ត)?

ចាំបាច់លើជនមូស្លីមក្នុងមួយថ្ងៃមួយយប់ត្រូវសឡាតតែប្រាំពេលប៉ុណ្ណោះ។ ហើយជាមួយគ្នាដែរ ច្បាប់បានជម្រុញដល់ជនមូស្លីមលើការសឡាតស៊ូណាត ព្រោះវាគឺជាមូលហេតុដែលនាំឲ្យអល់ឡោះកាន់តែស្រលាញ់ខ្ញុំបម្រើរបស់ទ្រង់ និងបំពេញរាល់កង្វះខាតនៃសឡាតដែលគេដាក់កាតព្វកិច្ច។

សឡាតស៊ូណាតមានច្រើនណាស់ ហើយដែលសំខាន់ជាងគេនោះគឺ

1 ស៊ូណាត់រ៉ាទិប(ស៊ូណាតអមសឡាតដែលជាកាតព្វកិច្ច): គេឱ្យឈ្មោះវាដូចនេះ ពីព្រោះវានៅជាប់ជាមួយនឹងសឡាតកាតព្វកិច្ច និងដោយសារអ្នកមូស្លីមមិនបោះបង់វាឡើយ។

ពិតណាស់ ព្យាការីបានមានប្រសាសន៍ថា "ជនមូស្លីមគ្រប់រូបដែលសឡាតដើម្បីអល់ឡោះរាល់ថ្ងៃចំនួន១២រ៉ក្កាត់ដោយស្ម័គ្រចិត្តក្រៅពីសឡាតដែលជាកាតព្វកិច្ចនោះ អល់ឡោះនឹងសង់ផ្ទះមួយសម្រាប់គាត់នៅក្នុងឋានសួគ៌"។ (មូស្លីមៈ៧២៨)

## សឡាតរ៉ាទិបវាមានដូចខាងក្រោម:

| | |
|---|---|
| 1 | ពីររ៉ក្កាត់មុនសឡាតហ្វាជើរ |
| 2 | បួនរ៉ក្កាត់មុនសឡាតហ៊្សូហោរ ដោយឱ្យសាឡាមរាល់ពីររ៉ក្កាត់ និងពីររ៉ក្កាត់ទៀត បន្ទាប់ពីសឡាតហ៊្សូហោរ។ |
| 3 | ពីររ៉ក្កាត់ក្រោយសឡាតម៉ាហ្គ្រិប |
| 4 | ពីររ៉ក្កាត់ក្រោយសឡាតអ៊ីស្ហា |

2 សឡាត វីតៀរ: គេឱ្យឈ្មោះវាដូចនេះ ពីព្រោះចំនួនរ៉ក្កាត់របស់វាគឺសេសគូរ ហើយវាជាសឡាតស៊ូណាតដ៏ល្អប្រពៃបំផុត។ ព្យាការីបានមានប្រសាសន៍ថា "ចូរពួកអ្នកសឡាតវីតៀរចុះ ឱពួកអ្នកគម្ពីរគួរអាន"។ (អាត់តៀរមីហ្ស៊ីៈ៤៥៣ អ៊ិពនូម៉ាហ្ជះៈ១១៧០)

ហើយពេលវេលាដែលល្អបំផុតសម្រាប់សឡាតវីតៀរនោះ គឺនៅចុងក្រោយនៃយប់ តែជនមូស្លីមអាចប្រតិបត្តិវាក្នុងពេលណាក៏បានដែរចាប់ពីសឡាតអ៊ីស្ហារួចរហូតដល់សេតរុណរះ។

ចំនួនតិចបំផុតនៃរ៉ក្កាត់វីតៀរគឺចំនួនមួយរ៉ក្កាត់ តែជាការប្រសើរ គឺមិនគួរសឡាតតិចជាងបីរ៉ក្កាត់ទេ ហើយគាត់អាចថែមទៅតាមអ្វីដែលគាត់ចង់។ អ្នកនាំសារវិញ លោកសឡាតចំនួន១១រ៉ក្កាត់។

ធាតុដើមនៃការសឡាតស៊ូណាត គឺចំនួនពីរៗរ៉ក្កាត់ ដោយសឡាតពីររ៉ក្កាត់ឱ្យសាឡាមម្ដងៗ។ ចំពោះសឡាតវីតៀរក៏ដូចគ្នាដែរ ក៏ប៉ុន្តែនៅពេលដែលគេចង់បញ្ចប់សឡាត គេត្រូវសឡាតមួយរ៉ក្កាត់នៅពេលចុងក្រោយ។ ក្រោយពេលដែលគាត់ងើបពីរូកុ មុនពេលស៊ូជោទ គេបង្គាប់ប្រើឲ្យសូត្រហ្ស៊ីកៀរដែលមានបញ្ជាក់ពីព្យាការី បន្ទាប់មកលើកដៃទាំងពីររបស់គាត់ប្តូងសួង(ទូអា)ទៅចំពោះអល់ឡោះនូវអ្វីដែលគាត់ចង់បាន ហើយគេឱ្យឈ្មោះវាថា "ទូអាគូនុត"។

## ពេលវេលាដែលគេហាមឃាត់មិនឱ្យសឡាតស៊ូណិត

គេអនុញ្ញាតឱ្យសឡាតស៊ូណិតគ្រប់ពេលវេលាទាំងអស់ លើកលែងតែពេលវេលាមួយចំនួនដែលឥស្លាមបានហាមឃាត់មិនឱ្យសឡាតនៅក្នុងពេលនោះ ពីព្រោះវាជាពេលរបស់ពួកគ្មានជំនឿគោរពសក្ការៈដែរ។ ដូច្នេះមិនត្រូវសឡាតក្នុងពេលនោះឡើយ លើកលែងតែសឡាតកាតព្វកិច្ចដែលគេបានខកខាន ឬសឡាតស៊ូណិតដែលមានមូលហេតុត្រឹមត្រូវដូចជា ស៊ូណិតតាហ៊ីយ៉ាតុលម៉ាស្ជិត (សឡាតពេលចូលម៉ាស្ជិត) ហើយវាទាក់ទងចំពោះតែសឡាតប៉ុណ្ណោះ។ ចំណែកឯការហ្ស៊ីកៀរ (រំលឹក)ទៅចំពោះអល់ឡោះ និងការបួងសួង គឺអាចធ្វើនៅពេលណាក៏បាន។

ហើយពេលវេលាដែលគេហាមឃាត់មិនឲ្យសឡាតមានដូចខាងក្រោម៖

| | |
|---|---|
| 1 | ក្រោយពីសឡាតហ្វាជើរ រហូតដល់ថ្ងៃរះ និងរហូតដល់ថ្ងៃរយៈបានកម្ពស់មួយថ្នោលដែលគិតជាមធ្យម គឺបន្ទាប់ពីថ្ងៃរះប្រហែល ២០នាទី។ |
| 2 | នៅពេលដែលថ្ងៃនៅចំកណ្ដាលក្បាល រហូតដល់ថ្ងៃជ្រេ។<br>វាជាពេលវេលាដ៏ខ្លីមុនពេលចូលដល់ពេលសឡាតហ្ស៊ូហោរ។ |
| 3 | ក្រោយពីសឡាតអាសើរ រហូតដល់ថ្ងៃលិច។ |



> សឡាតស៊ូណិតត្រូវបានហាមឃាត់ក្រោយពីសឡាតអាសើរ រួចរហូតដល់ថ្ងៃលិច។

## > សឡាតជើម៉ាអះ(សឡាតរួមគ្នា)



អល់ឡោះជាម្ចាស់បានប្រើឱ្យបុរសៗសឡាតប្រាំពេលក្នុងលក្ខណៈរួមគ្នា(ជើម៉ាអះ)។ មានភស្តុតាងដែលបញ្ជាក់ពីផលបុណ្យដ៏ធំធេងនៃការសឡាតរួមគ្នានេះ។ អ្នកនាំសារបានមានប្រសសន៍ថា “ការសឡាតរួមគ្នា ល្អជាងការសឡាតម្នាក់ឯងចំនួន២៧កម្រិត”។ (អាល់ពូខរី:៦១៩ មូស្លីម:៦៥០)

ចំនួនតិចបំផុតនៃសឡាតរួមគ្នាៈ អ៊ីម៉ាំ(ម្នាក់) និងម៉ាក់មុំ(ម្នាក់)។ កាលណាមានគ្នាកាន់តែច្រើន គឺអល់ឡោះកាន់តែស្រលាញ់។

### អត្ថន័យនៃពាក្យ "ការតាមអ៊ីម៉ាំ"

ជាការភ្ជាប់គ្នារវាងអ្នកសឡាតជាម៉ាក់មុំជាមួយនឹងអ៊ីម៉ាំ ដោយត្រូវធ្វើតាមអ៊ីម៉ាំក្នុងពេលរូកុ ស៊ូជោទ និងស្តាប់ការសូត្ររបស់គាត់ ហើយមិនត្រូវធ្វើមុន ឬធ្វើអ្វីមួយខុសពីអ៊ីម៉ាំឡើយ ផ្ទុយទៅវិញ គឺធ្វើតាមបន្ទាប់ពីអ៊ីម៉ាំតែម្តង។

អ្នកនាំសារបានមានប្រសាសន៍ថា “ពិតណាស់ គេបានបង្កើតអ៊ីម៉ាំដើម្បីឱ្យ(ម៉ាក់មុម)អនុវត្តតាមគាត់។ ដូចនេះ នៅពេលដែលអ៊ីម៉ាំតឹកពៀរ ចូរពួកអ្នកតឹកពៀរ ហើយពួកអ្នកមិនត្រូវតឹកពៀរឡើយ លុះត្រាតែអ៊ីម៉ាំបានតឹកពៀរមុន។ ហើយនៅពេលដែលគាត់រូកុ ចូរពួកអ្នករូកុ ហើយពួកអ្នកមិនត្រូវរូកុឡើយ លុះត្រាតែគាត់រូកុមុន។ ហើយនៅពេលដែលគាត់សូត្រ "សាមីអល់ឡ ហ៊ូលីម៉ាន់ហាមីហ្ទះ" ចូរពួកអ្នកសូត្រថា "រ៉ប់ហ្ពាណា វ៉ាលើកាលហាំទូ"។ នៅពេលដែលគាត់ស៊ូជោទ ចូរពួកអ្នកស៊ូជោទ ហើយពួកអ្នកមិនត្រូវស៊ូជោទឡើយ លុះត្រាតែគាត់ស៊ូជោទមុន”។ (អាល់ពូខរី:៧០១ មូស្លីម:៤១៤ អាពូទើវូទ:៦០៣)

### តើអ្នកណាដែលគួរឱ្យធ្វើជាអ៊ីម៉ាំ?

អ្នកដែលគួឱ្យធ្វើអ៊ីម៉ាំ គឺអ្នកដែលបានទន្ទេញចាំគម្ពីរគួរអាន។ បន្ទាប់មក អ្នកដែលល្អបន្តបន្ទាប់ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “អ្នកដែលត្រូវធ្វើជាអ៊ីម៉ាំ(ដឹកនាំសឡាត)នៃក្រុមមួយ គឺអ្នកដែលសូត្រគម្ពីរគួរអានបានល្អប្រសើរជាងគេ។ ប្រសិនបើការសូត្ររបស់ពួកគេមានភាពស្មើគ្នា គឺអ្នកដែលយល់ដឹងច្រើនជាងគេពីស៊ុណ្ណះ(មាគ៌ារបស់ព្យាការី)”។ (មូស្លីម:៦៧៣)

### តើអ៊ីម៉ាំ និងម៉ាក់មុំត្រូវឈរនៅទីតាំងណា?

ចាំបាច់លើអ៊ីម៉ាំត្រូវឈរនៅខាងមុខ ហើយម៉ាក់មុំឈរជាជួរនៅខាងក្រោយអ៊ីម៉ាំ។ ត្រូវបំពេញជួរទីមួយមុន បន្ទាប់មកជួរបន្ទាប់ទៀត។ ប្រសិនបើម៉ាក់មុំមានតែម្នាក់ គឺត្រូវឈរនៅខាងស្តាំអ៊ីម៉ាំ។

## តើត្រូវបំពេញដូចម្ដេចនូវអ្វីដែលគេបានខកខានជាមួយអ៊ីម៉ាំ?

អ្នកដែលចូលសឡាតជាមួយអ៊ីម៉ាំក្រោយពីគាត់បានខកខាននូវចំណែកខ្លះនៃសឡាត គាត់ត្រូវតឹកពៀរសឡាតហើយចូលជាមួយអ៊ីម៉ាំរហូតដល់អ៊ីម៉ាំឱ្យសាឡាម បន្ទាប់មកបំពេញអ្វីដែលនៅសល់ពីសឡាតរបស់គាត់។ ត្រូវរាប់នូវអ្វីដែលគាត់ទាន់ជាមួយអ៊ីម៉ាំពីដើមសឡាតរបស់គាត់ ហើយនិងអ្វីដែលគាត់ធ្វើវាក្រោយពីនោះ នៅចុងក្រោយនៃសឡាតរបស់គាត់។

## តើអ្វីទៅដែលបញ្ជាក់ថា គាត់បានទាន់រ៉ក្អាត់(ជាមួយអ៊ីម៉ាំ?

យើងគណនាវាតាមចំនួនរ៉ក្អាត់នៃសឡាត។ ជនណាដែលទៅទាន់រូកុជាមួយអ៊ីម៉ាំ ពិតណាស់គាត់បានទាន់មួយរ៉ក្អាត់ពេញលេញ ប៉ុន្តែជនណាខកខានរូកុជាមួយអ៊ីម៉ាំ គឺមិនចាត់ទុកថាបានទាន់រ៉ក្អាត់នោះទេ ទោះជាគាត់បានធ្វើនូវអ្វីដែលនៅសល់អំពីកាយវិកា និងពាក្យសំដីនៅក្នុងរ៉ក្អាត់នោះក៏ដោយ ក៏គេមិនរាប់ជារ៉ក្អាត់ដែរ។

**ឧទាហរណ៍ក្នុងការបំពេញសឡាតសម្រាប់អ្នកដែលខកខានសឡាតដំបូងជាមួយអ៊ីម៉ាំ។**

ជនណាដែលទៅទាន់អ៊ីម៉ាំរ៉ក្អាត់ទីពីរនៃសឡាតហ្វាជើរ ចាំបាច់លើគាត់ក្រោយពីអ៊ីម៉ាំឱ្យសាឡាម គាត់ត្រូវក្រោកឈរឡើងដើម្បីបំពេញមួយរ៉ក្អាត់ទៀតដែលនៅសល់ ហើយមិនត្រូវឱ្យសាឡាមឡើយរហូតទាល់តែចប់។ ពីព្រោះសឡាតហ្វាជើរ គឺមានចំនួនពីររ៉ក្អាត់ ហើយគាត់មកទាន់តែមួយរ៉ក្អាត់ប៉ុណ្ណោះ។

ជនណាដែលទាន់ជាមួយអ៊ីម៉ាំក្នុងពេលរូកុរ៉ក្អាត់ទីបីនៃសឡាតហ្ស៊ូហោរ ពិតណាស់ គាត់បានទាន់ពីររ៉ក្អាត់ជាមួយអ៊ីម៉ាំ(សម្រាប់ម៉ាក់មុំ គឺពីររ៉ក្អាត់ដំបូងនៃសឡាតហ្ស៊ូហោរ)។ នៅពេលដែលអ៊ីម៉ាំឱ្យសាឡាម ចាំបាច់គាត់ឈរឡើង ហើយបំពេញអ្វីដែលនៅសល់វានោះគឺពីររ៉ក្អាត់ គឺរ៉ក្អាត់ទីបីនិងទីបួន ពីព្រោះសឡាតហ្ស៊ូហោរមានបួនរ៉ក្អាត់។

ជនណាហើយដែលមកទាន់អ៊ីម៉ាំនៅពេលតាសាសហ៊ុទចុងក្រោយនៃសឡាតម៉ាហ្រ៊ិប ចាំបាច់លើគាត់ ក្រោយពីអ៊ីម៉ាំបានឱ្យសាឡាមរួច ត្រូវឱ្យគាត់សឡាតបីរ៉ក្អាត់យ៉ាងពេញលេញ ពីព្រោះគាត់មកទាន់អ៊ីម៉ាំក្នុងពេលតាសាសហ៊ុទចុងក្រោយ ហើយការទាន់រ៉ក្អាត់ គឺទាល់តែទាន់រូកុជាមួយអ៊ីម៉ាំ។

## > ការប្រកាសហៅឱ្យមកសឡាត(អាហ្សាន)

អល់ឡោះបានដាក់ច្បាប់លើជនមូស្លីមឱ្យអាហ្សាន ដើម្បីហៅមនុស្សមកសឡាត និងប្រកាសប្រាប់ពួកគេពីការដល់ពេលសឡាត ហើយគេដាក់ច្បាប់ឱ្យអ៊ីក៏ម៉ះដើម្បីប្រកាសប្រាប់ពួកគេពីការចាប់ផ្តើមសឡាត។ ពិតណាស់ ជនមូស្លីមធ្លាប់បានជួបជុំគ្នាដើម្បីបំពេញកាតព្វកិច្ចសឡាតដោយមិនមាននរណាម្នាក់ប្រកាសហៅឡើយ។ នៅថ្ងៃមួយ ពួកគេក៏បានពិភាក្សាគ្នា ដោយពួកគេមួយចំនួនបាននិយាយថា: ពួកយើងគួរប្រើប្រាស់ជួង ដូចជាជួងរបស់ពួកគ្រឹស្ទាន(ដើម្បីប្រកាសហៅមនុស្សឲ្យមកសឡាត) មានអ្នកខ្លះទៀតនិយាយថា: គួរផ្លុំត្រែដូចជាត្រែរបស់ពួកជ្វីហ្វ។ ពេលនោះ អ៊ូមើត ពិន អាល់ខត្តប បាននិយាយថា: "ទេ ត្រូវតែងតាំងបុរសម្នាក់ប្រកាសហៅឱ្យមកសឡាតវិញ" ។ ពេលនោះ អ្នកនាំសារក៏បានមានប្រសាសន៍ថា “ឱ ពីឡាល! ចូរក្រោកឈរឡើង ហើយប្រកាសហៅមនុស្សឱ្យមកសឡាត”។

(អាល់ពូខរី:៥៧៩ មូស្លីម:៣៧៧)

### របៀបអាហ្សាន និង អ៊ីក៏ម៉ះ

- ចំពោះការអាហ្សាន និងអ៊ីក៏ម៉ះ ចាំបាច់សម្រាប់តែការសឡាតជាក្រុម(ជើម៉ាអះ)ប៉ុណ្ណោះ ពុំមែនសម្រាប់បុគ្គលម្នាក់ៗនោះទេ។ ប្រសិនបើពួកគេបោះបង់ការអាហ្សាន និងអ៊ីក៏ម៉ះដោយចេតនានោះ សឡាតរបស់ពួកគេត្រឹមត្រូវ ប៉ុន្តែពួកគេទទួលបាប។
- ហើយច្បាប់បានកំណត់ឱ្យអាហ្សានដោយសម្លេងខ្លាំងហើយល្អ រហូតអាចឱ្យមនុស្សស្តាប់លឺ ដើម្បីឲ្យពួកគេមកសឡាត។
- ហើយពិតណាស់គេទទួលបានរបៀប អាហ្សាន និង កោះម៉ាត់ជាច្រើនលក្ខណៈដែលមានពីព្យាការីមូហាំម៉ាត់ ហើយដែលពេញនិយមជាងគេនោះមានដូចខាងក្រោម:

អាហ្សាន;

1. អល់ឡហ៊ូអឹកពើរ អល់ឡហ៊ូអឹកពើរ អល់ឡហ៊ូអឹកពើរ អល់ឡហ៊ូអឹកពើរ
2. អាស្ហហាទូ អាល់ឡើអ៊ីឡើហា អ៊ិលលល់ឡោះ អាស្ហហាទូ អាល់ឡើអ៊ីឡើហា អ៊ីលលល់ឡោះ
3. អាស្ហហាទូ អាន់ណា មូហាំម៉ាហ្មាន់ រ៉ស៊ូលុលឡោះ អាស្ហហាទូ អាន់ណា មូហាំម៉ាហ្មាន់ រ៉ស៊ូលុលឡោះ
4. ហៃយ៉ាអាឡើស សឡើហ។ ហៃយ៉ាអាឡើស សឡើហ
5. ហៃយ៉ាអាឡាល់ ហ្វាឡើហ។ ហៃយ៉ាអាឡាល់ ហ្វាឡើហ
6. អល់ឡហ៊ូអឹកពើរ អល់ឡហ៊ូអឹកពើរ
7. ឡើអ៊ីឡើហើ អ៊ិលលល់ឡោះ

អ៊ីកម៉ះ:

1. អល់ឡហ៊ូអឹកពើរ អល់ឡហ៊ូអឹកពើរ
2. អាស្ហហាទូ អាល់ឡើអ៊ីឡើហា អិលលល់ឡោះ
3. អាស្ហហាទូ អាន់ណា មូហាំម៉ាហ្ទាន់ រ៉ស៊ូលុលឡោះ
4. ហៃយ៉ាអាឡើស សឡើហ
5. ហៃយ៉ាអាឡាល់ ហ្វាឡើហ
6. កុទ្ធក៏ម៉ាទីស សឡើហ កុទ្ធក៏ម៉ាទីស សឡើហ
7. អល់ឡហ៊ូអឹកពើរ អល់ឡហ៊ូអឹកពើរ
8. ឡើអ៊ីឡើហើ អិលលល់ឡោះ

## ការសូត្រតាមក្រោយអ្នកអាហ្សាន:

គប្បីលើអ្នកដែលលឺអាហ្សាន ត្រូវសូត្រតាមក្រោយអ្នកអាហ្សាន ដោយសូត្រដូចអ្វីដែលអ្នកអាហ្សានបានសូត្រទាំងអស់ លើកលែងតែក្នុងពេលដែលអ្នកអាហ្សានសូត្រថា៖ "ហៃយ៉ាអាឡើស សឡើហ" ឬ"ហៃយ៉ាអាឡាល់ ហ្វាឡើហ" គាត់ត្រូវសូត្រថា "ឡើហារឡើ វ៉ាឡើ គូវ៉ាតា អិលឡើ ពីលឡើហ"

បន្ទាប់ពីគេអាហ្សានចប់ គាត់ត្រូវសូត្រថា (អល់ឡហ៊ុមម៉ា រ៉ប់ហ្ហាហា ហ្សីហ៊ុទហ្វាក់វ៉ាទិត តាមម៉ះ វ៉ាសស៏ឡើទិល កអ៊ីម៉ះ អាទី ម៉ូហាំម៉ាទើនីល វ៉ាស៊ីឡាទី វ៉ាល់ហ្វាទីឡះ វ៉ាប់អាស់ហ៊ូ ម៉ាក៏មុាំ ម៉ះម៉ូទើនីល ឡើហ្សី វ៉ាអាត់តះ)



>អល់ឡោះជាម្ចាស់នឹងតបស្នងដល់អ្នកមូស្លីមនូវរាល់ជំហានដែលគេឈានជើងដើរទៅកាន់ម៉ាស្ជិទ

## > ការមានចិត្តនឹងនរ ស្ងប់ស្ងាត់ក្នុងពេលសទ្បាត

ការមានចិត្តនឹងនរក្នុងពេលសទ្បាត វាជាធាតុពិតនៃសទ្បាត និងជាផ្នែកដ៏សំខាន់របស់វា។ មានន័យថា វត្តមានចិត្តរបស់ខ្ញុំលើដៃរបស់អល់ទ្បោះក្នុងពេលសទ្បាត ដោយការគោរព និង បន្ទាបខ្លួន ផ្តោតអារម្មណ៍លើអ្វីដែលខ្ញុំសូត្រនៃឃ្លាគម្ពីរគួរអាន ទូអា និង ហ្សីកៀរ។



> ពេលដែលបុគ្គលនោះជិតនឹងម្ចាស់របស់ពួកគេបំផុត គឺក្នុងពេលដែលគេកំពុងអោនក្រាបស៊ូជូទ

ហើយវាជាការគោរពសក្ការៈដ៏ល្អជាងគេ និងជាការប្រតិបត្តិដ៏ល្អប្រពៃ។ អល់ទ្បោះបានបញ្ជាក់យ៉ាងច្បាស់ក្នុងគម្ពីរបស់ទ្រង់ថា ពិតណាស់វាជាលក្ខណៈសម្បត្តិរបស់អ្នកមានជំនឿ ដូចជាអល់ទ្បោះបានមានបន្ទូលថា “បណ្តាអ្នកដែលមានជំនឿពិតជាទទួលបានជោគជ័យ គឺអ្នកដែលមានចិត្តនឹងនរក្នុងការប្រតិបត្តិសទ្បាតរបស់ពួកគេ”។ (គម្ពីរគួរអាន ២៣:១-២)

ជនណាដែលមានចិត្តនឹងនរក្នុងពេលសទ្បាតគេ និងទទួលបានរស់ជាតិនៃការគោរពសក្ការៈនិង ជំនឿ ដូច្នេះហើយអ្នកនាំសារបានមានប្រសាសន៍ថា “ខ្ញុំចាត់ទុកភាពសប្បាយរីករាយរបស់ខ្ញុំនៅក្នុងពេលសទ្បាត”។(អាន់ណាសើអ៊ី ៣៩៤០)

### វិធីសាស្ត្រដែលធ្វើឱ្យមានចិត្តនឹងនរក្នុងពេលសទ្បាត

មានវិធីសាស្ត្រជាច្រើនដែលជួយឱ្យមានចិត្តនឹងនរក្នុងពេលសទ្បាតដូចជាៈ

#### 1 ត្រូវមានឆន្ទៈក្នុងការសទ្បាត និងការត្រៀមខ្លួនសម្រាប់វា

ដោយការរួសរាន់ក្នុងការធ្វើដំណើរទៅសទ្បាតនៅម៉ាស្ជិតចំពោះបុរស និងប្រតិបត្តិសទ្បាតស៊ូណិតមុនសទ្បាត ហើយស្លៀកសំលៀកបំពាក់ដែលស្អាតសមរម្យ និងដើរទៅសទ្បាតដោយការគោរព និងស្ងប់ស្ងាត់។

#### 2 ចេញឱ្យឆ្ងាយពីប្រការដែលនាំឱ្យរំខាន

មិនត្រូវសទ្បាតទេប្រសិនបើនៅពីមុខគាត់មានរូបភាព និងអ្វីដែលរំខានដល់អ្នកសទ្បាត ឬគាត់លឺសម្លេងដែលរំខានដល់គាត់។ ហើយមិនត្រូវសទ្បាតទេប្រសិនបើគាត់ត្រូវការទៅបន្ទប់ទឹក ឬឃ្លាន ឬខណៈពេលដែលគេលើកអាហារមកដល់។ ទាំងអស់នេះជាការរំខានស្មារតីអ្នកសទ្បាតក្នុងពេលដែលគាត់កំពុងបំពេញកាតព្វកិច្ចដ៏ឧត្តុងឧត្តមដែលគាត់កំពុងប្រឈមមុខ នោះគឺការសទ្បាតរបស់គាត់ និងការសន្ទនាជាមួយម្ចាស់របស់គាត់។

## 3 ត្រូវមានលំនឹងក្នុងពេលសឡាត

ពិតណាស់ អ្នកនាំសារ គឺលោកមានភាពលំនឹងជានិច្ចក្នុងពេល រូកុ និងពេលស៊ូជោទរបស់គាត់ រហូតទាល់តែអវៈយវៈទាំងឡាយត្រឡប់ទៅកន្លែងរបស់វាវិញ ហើយលោកបានប្រើឱ្យអ្នកដែលសឡាតមិនបានល្អឱ្យមានភាពលំនឹងក្នុងកាយវិការរបស់គាត់រាល់ពេលសឡាត និងហាមឃាត់មិនឱ្យធ្វើលឿនឡើយ ដោយលោកបានប្រដូចការធ្វើបែបនេះទៅនឹងការចឹកចំនីរបស់សត្វក្អែក។

អ្នកនាំសារបានមានប្រសាសន៍ថា "មនុស្សដែលអាក្រក់បំផុត គឺចោរលួចដែលបានលួចសឡាតរបស់ខ្លួនឯង"។ ពួកគេបានសួរថា: ឱអ្នកនាំសារ! តើគេលួចសឡាតរបស់ខ្លួនឯងយ៉ាងដូចម្តេចទៅ? លោកឆ្លើយថា "គឺគេមិនបានបំពេញរូកុ និង ស៊ូជោទរបស់គេឲ្យបានពេញលេញឡើយ"។ (អះម៉ាត់ ២២៦៤២)។ ជនណាហើយដែលមិនមានភាពលំនឹងក្នុងសឡាតរបស់គេទេនោះ គេនឹងមិនទទួលបានចិត្តនឹងនរ ស្ងឹងស្ងាធឡើយ ពីព្រោះភាពលឿននឹងធ្វើឱ្យបាត់បង់ចិត្តនឹងនរ ហើយការលឿនដូចជាការចឹកចំណីរបស់សត្វក្អែក នាំឱ្យបាត់បង់ផលបុណ្យ។

## 4 នឹកឃើញពីភាពខ្ពង់ខ្ពស់របស់អ្នកដែលយើងកំពុងឈរចំពោះមុខ

តាមរយៈការរំលឹកពីភាពខ្ពង់ខ្ពស់របស់អ្នកបង្កើត(អល់ឡោះ) និងភាពឧត្តុងឧត្តមរបស់ទ្រង់ ហើយនិងភាពទន់ខ្សោយរបស់ខ្លួនឯង ហើយថាពិតណាស់ រូបគេកំពុងតែឈរនៅចំពោះមុខម្ចាស់របស់គេសន្ទនាជាមួយទ្រង់ បួងសួងទៅចំពោះទ្រង់ដោយការគោរពឱនលំទោន និងបន្ទាបខ្លួន ហើយរំលឹកនូវអ្វីដែលអល់ឡោះបានរៀបចំសម្រាប់អ្នកមានជំនឿនៅថ្ងៃបរលោកអំពីផលបុណ្យ នឹងអ្វីដែលអល់ឡោះបានរៀបចំសម្រាប់អ្នកប្រឆាំងអំពីទណ្ឌកម្ម ព្រមទាំងរំលឹកពីស្ថានភាពនៅពេលដែលជួបនឹងអល់ឡោះនៅថ្ងៃបរលោក។

ប្រសិនបើអ្នកមានជំនឿបាននឹកឃើញអ្វីទាំងនោះក្នុងពេលសឡាតរបស់គេ គេប្រៀបដូចជាអ្នកដែលអល់ឡោះបានប្រាប់ពីលក្ខណៈសម្បត្តិរបស់ពួកគេនៅក្នុងគម្ពីររបស់ទ្រង់ នៃអ្នកដែលជឿជាក់ថាពិតណាស់ ពួកគេនឹងជួបម្ចាស់របស់ពួកគេ។ អល់ឡោះបានមានបន្ទូលថា "ហើយពិតប្រាកដណាស់ វា(ការសឡាត)ពិតជាមានការលំបាកយ៉ាងខ្លាំង លើកលែងតែចំពោះបណ្តាអ្នកដែលឱនលំទោនកោតខ្លាចអល់ឡោះប៉ុណ្ណោះ គឺបណ្តាអ្នកដែលជឿជាក់ថា ពិតប្រាកដណាស់ ពួកគេនឹងជួបម្ចាស់របស់ពួកគេ ហើយពិតប្រាកដណាស់ ពួកគេនឹងត្រូវវិលត្រឡប់ទៅចំពោះទ្រង់វិញ"។ (គម្ពីរគួរអាន ២:៤៥-៤៦)

ប្រសិនបើអ្នកសឡាតបាននឹកឃើញថា ពិតណាស់អល់ឡោះបានលឺគាត់ ផ្តល់អ្វីៗដល់គាត់ ព្រមទាំងទទួលយកសំណើរបស់គាត់នោះ គាត់នឹងមានចិត្តនឹងនរទៅតាមកម្រិតនៃការនឹកឃើញរបស់គាត់។

## 5 ត្រូវត្រិះរិះពិចារណាអំពីឃ្លាគម្ពីរដែលបានសូត្រ នឹងហ្សីកៀរផ្សេងៗទៀតនៅក្នុងសឡាត ហើយបង្កើតសកម្មភាពជាមួយវា:

គម្ពីរគួរអានបានបញ្ចុះមកដើម្បីធ្វើការត្រិះរិះពិចារណា។ អល់ឡោះបានមានបន្ទូលថា "នេះជាគម្ពីរដ៏មានពរជ័យដែលយើងបានបញ្ចុះវាឱ្យអ្នកដើម្បីឱ្យពួកគេត្រិះរិះពិចារណាចំពោះបណ្តាវាក្យខណ្ឌរបស់វា ហើយក៏ដើម្បីបញ្ញាជនទាំងឡាយយកធ្វើជាមេរៀនផងដែរ"។ (គម្ពីរគួរអាន ៣៨:២៩)។ ហើយគេមិនអាចទទួលបានការត្រិះរិះពិចារណាទេលើកលែងតែមានចំណេះដឹង មានន័យថាគាត់អាចសូត្រឃ្លាគម្ពីរ ហ្សីកៀរ និងទូអាផ្សេងៗ ហើយគាត់អាចគិតពិចារណាក្នុងស្ថានភាពរបស់គាត់ និងការជាក់ស្តែងរបស់គាត់ អំពីអត្ថន័យនៃឃ្លាគម្ពីរ ហើយនិងហ្សីកៀរទាំងនោះ។ ពេលនោះ វានឹងធ្វើឱ្យមានចិត្តនឹងនរ ឱនលំទោន បន្ទាបខ្លួន និងរំជួលចិត្ត ជួនកាលអាចធ្វើឱ្យស្រក់ទឹកភ្នែកទៀតផង។ ហើយបើឃ្លាគម្ពីរណាមួយដែលគេបានលឺ តែគេគ្មានការរំជួលចិត្តអ្វីទេនោះ គឺប្រៀបដូចជាគេមិនបានលឺ និងមិនបានឃើញនោះដែរ ដូចដែលអល់ឡោះបានមានបន្ទូលថា "និងបណ្តាអ្នកដែលនៅពេលពួកគេត្រូវបានគេរំលឹកនូវអាយ៉ាត់ៗនៃម្ចាស់របស់ពួកគេ ពួកគេមិនបានធ្វើគ ធ្វើថ្លង់ចំពោះវាឡើយ។ (គម្ពីរគួរអាន ២៧:៧៣)

## > សឡាតជុមអាត់(ថ្វាយបង្គំថ្ងៃសុក្រ)

អល់ឡោះទ្រង់បានដាក់កាតព្វកិច្ចមួយនៅថ្ងៃសុក្រក្នុងពេលសឡាតហ្ស៊ូហោរ នូវការសឡាតមួយដែលជានិមិត្តសញ្ញារបស់ឥស្លាម។ ហើយបានបញ្ជាក់ពីកាតព្វកិច្ចនេះដោយប្រមូលផ្ដុំអ្នកមូស្លីមទាំងអស់ក្នុងមួយសប្ដាហ៍ម្ដង ហើយនាំគ្នាស្ដាប់នូវការអប់រំ និងការប្រៀនប្រដៅដែលលើកឡើងដោយអ៊ីម៉ាំជុមអាត់។ បន្ទាប់មកនាំគ្នាប្រតិបត្តិសឡាតជុមអាត់។



>ចាំបាច់លើអ្នកដែលសឡាតត្រូវយកចិត្តទុកដាក់ស្ដាប់ឃុតប្ហះជុមអាត់ ហើយមិនត្រូវឲ្យមានការរំខានដោយអ្វីមួយឡើយឡើយ

### ឧត្តមភាពនៃថ្ងៃជុមអាត់(ថ្ងៃសុក្រ)

ថ្ងៃជុមអាត់ជាថ្ងៃដែលល្អបំផុតក្នុងចំណោមថ្ងៃទាំងអស់ក្នុងមួយសប្ដាហ៍។ ពិតណាស់ អល់ឡោះបានជ្រើសរើសវាផ្សេងពីថ្ងៃដទៃ និងបានផ្ដល់ភាពវិសេសវិសាលដល់វាលើសពេលវេលាដទៃទៀតតាមរយៈលក្ខណៈពិសេសមួយចំនួនដូចជា:

- ពិតណាស់ អល់ឡោះបានជ្រើសរើសវាជាពិសេសសម្រាប់ប្រជាជាតិរបស់ព្យាការីមូហាំម៉ាត់ ខុសពីប្រជាជាតិដទៃ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា "អល់ឡោះបានធ្វើឱ្យអ្នកជំនាន់មុនយើងវង្វេងពីថ្ងៃសុក្រ។ សម្រាប់ពួកសាសន៍ជ្វីហ្វ គឺថ្ងៃសៅរ៍(ជាថ្ងៃជុមអាត់របស់ពួកគេ) ហើយសម្រាប់ពួកគ្រីស្ទាន គឺថ្ងៃអាទិត្យ (ជាថ្ងៃជុមអាត់របស់ពួកគេ)។ បន្ទាប់មក អល់ឡោះបាននាំពួកយើងមក ហើយចង្អុលបង្ហាញឱ្យយើងនូវថ្ងៃសុក្រ(ជាថ្ងៃជុមអាត់របស់ពួកយើង)"។ (មូស្លីម ៨៥៦)
- ពិតណាស់នៅក្នុងថ្ងៃជុមអាត់(ថ្ងៃសុក្រ) គេបានបង្កើតព្យាការីអាហ្ទាំ ហើយក្នុងថ្ងៃជុមអាត់នេះដែរ ជាថ្ងៃដែលថ្ងៃបរលោកនឹងកើតឡើង ដូចដែលអ្នកនាំសារមូហាំម៉ាត់លោកបានមានប្រសាសន៍ថា "ថ្ងៃដែលព្រះអាទិត្យរះល្អបំផុត គឺថ្ងៃសុក្រ។ នៅក្នុងវាគេបានបង្កើតអាហ្ទាំ និងក្នុងវា គេបញ្ចូលអាហ្ទាំទៅក្នុងឋានសួគ៌ ហើយក្នុងវានេះដែរ គេបានបញ្ចេញគាត់ពីក្នុងឋានសួគ៌មកវិញ ហើយថ្ងៃបរលោកក៏នឹងមិនកើតឡើងឡើយលើកលែងតែនៅក្នុងថ្ងៃសុក្រ"។ (មូស្លីម ៨៥៤)

### តើអ្នកណាខ្លះដែលចាំបាច់ត្រូវសឡាតជុមអាត់?

ចាំបាច់សឡាតជុមអាត់លើ:

1. បុរស : មិនចាំបាច់លើស្ត្រីឡើយ។
2. មានសតិ: មិនចាំបាច់លើមនុស្សឆ្កួត និងក្មេងដែលមិនទាន់ដឹងក្ដីឡើយ។.
3. អ្នករស់នៅក្នុងភូមិស្រុក: មិនចាំបាច់លើអ្នកដំណើរ និងអ្នកដែលរស់នៅជនបទដែលចេញឆ្ងាយពីទីក្រុង ឬភូមិស្រុកឡើយ។
4. មានសុខភាពល្អ: មិនចាំបាច់លើអ្នកជំងឺដែលមិនអាចធ្វើដំណើរទៅសឡាតជុមអាត់ឡើយ។

## របៀបរបប និងច្បាប់ដែលទាក់ទងនឹងសឡាតជុំអាត់

1. គប្បីលើជនមូស្លីមងូតទឹកមុនពេលទៅសឡាតជុំអាត់ ហើយរួសរាន់ក្នុងការទៅម៉ាស្ជិទ មុនពេលចាប់ផ្តើមឃុតហ្ពះ និងគប្បីស្លៀកសម្លៀកបំពាក់ដែលស្រស់ស្អាត។

2. ប្រមូលផ្តុំអ្នកមូស្លីមនៅក្នុងម៉ាស្ជិទ ហើយអ៊ីម៉ាំទៅខាងមុខ ហើយឡើងលើមីមពើរ(កន្លែងសូត្រឃុតហ្ពះ) តម្រង់មុខមកកាន់អ្នកសឡាត ហើយសូត្រពីរខុតហ្ពះ ដោយឈប់អង្គុយបន្តិចនៅចន្លោះរវាងឃុតហ្ពះទាំងពីរនោះ។ រំលឹកពួកគេឲ្យកោតខ្លាចចំពោះអល់ឡោះ ហើយផ្តល់នូវការណែនាំ ការបង្រៀន និងឃ្លាគម្ពីរគួរអាន។

3. ចាំបាច់លើអ្នកសឡាតត្រូវស្តាប់ឃុតហ្ពះ ហាមឃាត់លើពួកគេមិនឱ្យនិយាយ ឬរវល់ជាមួយនឹងអ្វីដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍អំពីការស្តាប់ឃុតហ្ពះនោះ សូម្បីតែការរុះរើកំរាលលេង ឬអេះដៃ និងសំលៀកបំពាក់លេង ឬលេងឈើ និងដីក៏ដោយ។

4. បន្ទាប់មកអ៊ីម៉ាំក៏ចុះពីលើមីមពើរ ហើយសឡាតជុំអាត់ ហើយសឡាតជាមួយពួកគេចំនួនពីររ៉ក្អាត់ ដោយសូត្រលឺៗក្នុងវាទាំងពីរ។

5. សឡាតជុំអាត់ត្រូវបានគេដាក់កាតព្វកិច្ចឲ្យសឡាតរួមគ្នា(ជើម៉ាអះ)។ ហេតុនេះជនណាដែលខកខានមិនបានសឡាតរួមគ្នា ឬមិនបានបំពេញវាដោយបញ្ហាណាមួយ គឺគេត្រូវសឡាតហ្ស៊ូហោរ និងមិនត្រឹមត្រូវទេបើគេសឡាតជុំអាត់នោះ។

6. ជនណាដែលយឺតយ៉ាវក្នុងការទៅសឡាតជុំអាត់ ហើយគេមិនបានទៅទាន់អ៊ីម៉ាំទេលើកលែងតែមួយចំណែកតិចតួចនៃរ៉ក្អាត់ចុងក្រោយ គឺគេត្រូវនៀតសឡាតហ្ស៊ូហោរ។

7. រាល់អ្នកដែលគេមិនដាក់កាតព្វកិច្ចឱ្យមកសឡាតជុំអាត់ដូចជាស្ត្រី និងអ្នកធ្វើដំណើរជាដើមនោះ ពិតណាស់ការសឡាតរបស់ពួកគេគឺត្រឹមត្រូវប្រសិនបើពួកគេសឡាតជុំអាត់រួមជាមួយអ្នកមូស្លីម ហើយពួកគេមិនចាំបាច់សឡាតហ្ស៊ូហោរទៀតនោះទេ។

## តើជនណាខ្លះដែលគេអនុគ្រោះឱ្យក្នុងការមិនបានមកសឡាតជុំអាត់នោះ?

ច្បាប់ឥស្លាមបានបញ្ជាក់យ៉ាងច្បាស់លើកាតព្វកិច្ចក្នុងការមកចូលរួមសឡាតជុំអាត់ចំពោះជនណាដែលកាតព្វកិច្ចលើពួកគេត្រូវមកចូលរួម ហើយបានព្រមានចំពោះជនណាដែលមិនបានចូលរួមសឡាតជុំអាត់ដោយសារតែការស្វែងរកទ្រព្យសម្បត្តិក្នុងលោកិយ។ អល់ឡោះបានមានបន្ទូលថា "ឱបណ្តាអ្នកដែលមានជំនឿ! នៅពេលមានគេអំពាវនាវពួកអ្នកឱ្យទៅសឡាតនៅថ្ងៃសុក្រ ចូរពួកអ្នករួសរាន់ទៅរកការរំលឹកចំពោះអល់ឡោះ ហើយចូរពួកអ្នកបោះបង់ចោលនូវការលក់ដូរ។ នោះគឺជាការប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង"។ (គម្ពីរគួរអាន ៦២:៩)

ហើយបានព្រមានចំពោះអ្នកដែលមិនបំពេញវាដោយគ្មានមូលហេតុស្របច្បាប់ដោយការបោះត្រាភ្ជិតលើដួងចិត្តរបស់គេ។ អ្នកនាំសារបានមានប្រសាសន៍ថា "ជនណាដែលបានបោះបង់សឡាតជុំអាត់បីដងដោយមិនយកចិត្តទុកដាក់ ហើយមិនមានមូលហេតុ)ស្របច្បាប់)នោះ អល់ឡោះនឹងបោះត្រាលើចិត្តរបស់គេ"។ (អាពូហ្ទាវូទៈ១០៥២ អះម៉ាត់ៈ១៥៤៩៨)។ អល់ឡោះនឹងបោះត្រាលើចិត្តរបស់គេ មានន័យថា បោះត្រាលើចិត្តរបស់គេ និងគ្របដណ្តប់លើរូបគេ ហើយធ្វើឱ្យរូបគេល្ងង់ខ្លៅ និងទន់ខ្សោយ ដូចជាចិត្តរបស់ពួកពុតត្បុត និងពួកប្រឆាំងដូច្នោះដែរ។

ការសឡាតរបស់អ្នក

មូលហេតុដែលគេអនុញ្ញាតឱ្យបោះបង់សឡាតជុមអាត់:
រាល់ៗអ្វីដែលកើតឡើងលើអ្នកនៃបញ្ហាធ្ងន់ធ្ងរដែលមិនប្រក្រតី ឬខ្លាចមានគ្រោះថ្នាក់ជាក់លាក់លើការរស់នៅរបស់អ្នក និងសុខភាពរបស់អ្នក ដូចជាមានជំងឺ ឬស្ថានភាពបន្ទាន់ជាដើម។

## តើពេលវេលាធ្វើការ ជាមូលហេតុអាចបោះបង់សឡាតជុមអាត់បានដែរឬទេ?

ធាតុដើមវា ការងារ និងការរវល់នឹងកិច្ចការអ្វីមួយជាប់ជាប្រចាំនោះ មិនមែនជាមូលហេតុសម្រាប់ជនមូស្លីម ក្នុងការបោះបង់សឡាតជុមអាត់នោះទេ។ អល់ឡោះបានប្រើឱ្យយើងបោះបង់កិច្ចការរបស់យើងដើម្បីបំពេញកាតព្វកិច្ចសឡាត ដោយទ្រង់បានមានបន្ទូលថា “ឱបណ្ដាអ្នកដែលមានជំនឿ! នៅពេលមានគេអំពាវនាវពួកអ្នកឱ្យទៅសឡាតនៅថ្ងៃជុមអាត់(ថ្ងៃសុក្រ) ចូរពួកអ្នករួសរាន់ទៅរកការរំលឹកចំពោះអល់ឡោះ ហើយចូរពួកអ្នកបោះបង់ចោលនូវការលក់ដូរ។ នោះគឺជាការប្រសើរបំផុតសម្រាប់ពួកអ្នក ប្រសិនបើពួកអ្នកបានដឹង”។ (គម្ពីរគួរអាន ៦២:៩) ។ ចាំបាច់លើជនមូស្លីមត្រូវជ្រើសរើសការងារណាដែលអាចឲ្យគេបំពេញកាតព្វកិច្ចដែលអល់ឡោះដាក់ឱ្យ សូម្បីតែប្រាក់ចំណូលតិចជាងកន្លែងផ្សេងក៏ដោយ។

អល់ឡោះបានមានបន្ទូលថា “ហើយជនណាដែលកោតខ្លាចអល់ឡោះ ទ្រង់នឹងធ្វើឱ្យគេមានច្រកចេញ។ហើយទ្រង់នឹងផ្ដល់លាភសក្ការៈដល់គេដោយគេនឹកស្មានមិនដល់។ហើយជនណាដែលប្រគល់ការទុកចិត្តលើអល់ឡោះ គឺទ្រង់ជាអ្នកផ្ដល់ភាពគ្រប់គ្រាន់ដល់គេ”។ (គម្ពីរគួរអាន ៦៥:២-៣)



> ចូរពោលចុះ(ឱមូហាំម៉ាត់)! អ្វីដែលអល់ឡោះមាន ល្អប្រសើរជាងការលេងសប្បាយនិងប្រសើរជាងជំនួញទៅទៀត។

### តើនៅពេលណាដែលការងារជាមូលហេតុដែលអាចឲ្យគេបោះបង់សឡាតជុមអាត់បាន ?

គេមិនចាត់ទុកការងារអចិន្ត្រៃយ៍ជាមូលហេតុក្នុងការបោះបង់សឡាតជុមអាត់ សម្រាប់អ្នកដែលមានកាតព្វកិច្ចលើគាត់ត្រូវចូលរួមសឡាតជុមអាត់នោះទេ លើកលែងតែពីរករណីប៉ុណ្ណោះ ៖

1 ការងារនោះ គឺជាការងារដែលផ្ដល់ផលប្រយោជន៍ធំធេង ហើយមិនអាចសម្រេចវាបានទេ លើកលែងតែគាត់នៅធ្វើការងារនោះ ហើយបោះបង់សឡាតជុមអាត់។ ហើយប្រសិនបើគាត់បោះបង់ការងារ វានឹងផ្ដល់គ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ហើយមិនមាននណារម្នាក់អាចជំនួសការងារគាត់បានឡើយ។

ឧទាហរណ៍

- គ្រូពេទ្យនៅក្នុងរថយន្តសង្គ្រោះបន្ទាន់ដែលចាំព្យាបាលករណីអ្នករងរបួសបន្ទាន់។
- អ្នកយាមនិងប៉ូលីសដែលការពារប្រជាជននិងទ្រព្យសម្បត្តិរបស់ពួកគេពីការលួចនិងសកម្មភាពបទល្មើសព្រហ្មទណ្ឌ។
- មនុស្សដែលកាន់តំណែងគ្រប់គ្រងនៅក្នុងក្រុមហ៊ុនធំ ឬផ្សេងពីនេះ ដែលតម្រូវឱ្យត្រួតពិនិត្យគ្រប់ពេលវេលា។

2 ប្រសិនបើការងារនោះ វាជាប្រភពដើមតែមួយគត់ក្នុងការទទួលបានប្រាក់ចំណូល ហើយវាមិនបានផ្ដល់ឱកាសឱ្យគាត់ក្នុងការមកចូលរួមសឡាតជុមអាត់ និងមិនមានការងារផ្សេងក្រៅពីវាឡើយដើម្បីគ្រប់គ្រងលើការចំណាយចាំបាច់ទៅលើម្ហូបអាហារ ទឹក និងប្រការចាំបាច់ផ្សេងទៀតសម្រាប់គ្រួសាររបស់គាត់។ ដូច្នេះគេអនុញ្ញាតឱ្យគាត់នៅបន្តបំពេញការងារ ហើយអាចបោះបង់សឡាតជុមអាត់ដោយសារតែភាពចាំបាច់នេះ រហូតដល់គាត់រកបានការងារផ្សេង ឬរហូតដល់គាត់ទទួលបានការចំណាយលើម្ហូបអាហារ ទឹក និងប្រការចាំបាច់ផ្សេងទៀតគ្រប់គ្រាន់សម្រាប់ខ្លួនគាត់ និងអ្នកដែលនៅក្រោមបន្ទុករបស់គាត់។

## > ការសឡាតរបស់អ្នកជំងឺ

សឡាត គឺជាកាតព្វកិច្ចលើជនមូស្លីមនៅគ្រប់កាលៈទេសៈទាំងអស់របស់គេដរាបណាគេនៅមានសតិ និងការយល់ដឹង។ ទោះជាយ៉ាងណាក៏ដោយ សាសនាឥស្លាមបានយកចិត្តទុកដាក់លើកិច្ចការដែលផ្ទុយពីកាលៈទេសៈ និងតម្រូវការរបស់ពួកគេ ហើយនៅក្នុងវានោះគឺអ្នកជំងឺ។

ដើម្បីឱ្យកាន់តែច្បាស់ គេនិយាយថា ៖

- អ្នកជំងឺអាចបោះបង់ការឈរសឡាត នៅពេលណាដែលគាត់មិនអាចឈរបាន ឬពេលឈរធ្វើឱ្យគាត់មានការពិបាក ឬយឺតយ៉ាវក្នុងការព្យាបាល ដូច្នេះគាត់អាចសឡាតអង្គុយបាន។ តែប្រសិនបើគាត់មិនអាចសឡាតដោយអង្គុយបាន ចូរឱ្យគាត់សឡាតដោយដេកផ្អៀង។ អ្នកនាំសារបានមានប្រសាសន៍ថា ៖ “ចូរអ្នកសឡាតដោយឈរ។ ប្រសិនបើគ្មានលទ្ធភាព ចូរ( សឡាតដោយ )អង្គុយ។ ប្រសិនបើគ្មានលទ្ធភាពទៀត ចូរសឡាតដោយដេកផ្អៀង”។ (អាល់ពូខរីៈ១០៦៦)
- ជនណាដែលគ្មានលទ្ធភាព រូកុ ឬស៊ូជោទ គាត់គ្រាន់តែឱនទៅមុខតាមលទ្ធភាពដែលគាត់អាចធ្វើបាន។
- ជនណាដែលពិបាកអង្គុយលើដី ចូរឱ្យគាត់អង្គុយលើកៅអី ឬអ្វីផ្សេង។
- ជនណាដែលមានការលំបាកក្នុងការយកទឹកសម្អាតកាយ( ទឹកវូហ្ទុ )រាល់ពេលសឡាតដោយសារជំងឺរបស់គាត់ គេអនុញ្ញាតឱ្យគាត់អាចផ្គុំសឡាតរវាងសឡាតស៊ូហោរ និងសឡាតអាសើរក្នុងពេលណាមួយនៃពេលវេលារបស់វាទាំងពីរ ហើយរវាងសឡាតម៉ាហ្គ្រិប និងសឡាតអ៊ីសាក្នុងពេលណានៃពេលវេលារបស់វាទាំងពីរ។
- ជនណាដែលមានការលំបាកក្នុងការប្រើប្រាស់ទឹកដោយសារជំងឺ គេអនុញ្ញាតឱ្យគាត់តាយ៉ាំមុំ( គឺការប្រើប្រាស់ដីស្អាតដើម្បីយកទឹកវូហ្ទុ )ដើម្បីប្រតិបត្តិសឡាត។

## > ការសឡាតរបស់អ្នកធ្វើដំណើរ

- ចំពោះអ្នកធ្វើដំណើរ ក្នុងពេលដែលកំពុងធ្វើដំណើរ ឬពេលស្នាក់នៅដោយកំណត់ពេលច្បាស់លាស់ដែលមានរយៈពេលតិចជាងបួនថ្ងៃនោះ  គេអនុញ្ញាតឱ្យគាត់អាចបង្រួមសឡាតដែលមានបួនរ៉ក្អាត់ឱ្យនៅសល់ពីររ៉ក្អាត់។ ដូចនេះ គេអាចសឡាតហ្ស៊ូហួរ អាសើរ និងអ៊ីសាចំនួនពីររ៉ក្អាត់ ជំនួសបួនរ៉ក្អាត់ លើកលែងតែពេលសឡាតជាមួយអ៊ីមុាំ ដោយគេប្រតិបត្តិតាមអ៊ីមុាំក្នុងសឡាតរបស់គាត់ ដោយត្រូវសឡាតបួនរ៉ក្អាត់ដូចអ៊ីមុាំដែរ។

- ច្បាប់អនុញ្ញាតឱ្យគាត់អាចបោះបង់សឡាតស៊ូណិតរ៉ាវាទិប លើកលែងតែសឡាតស៊ូណិតហ្វាជើរ និងសឡាតស៊ូណិតវីតៀរ(ដែលមិនគួរបោះបង់)។

- គេអនុញ្ញាតឱ្យគាត់អាចបង្រួមសឡាតរវាងសឡាតហ្ស៊ូហួរ និងសឡាតអាសើរ ហើយរវាងសឡាតម៉ាហ្រ៊ិប និងសឡាតអ៊ីសា ក្នុងពេលវេលាណាមួយនៃពេលវេលារបស់វាទាំងពីរ។ ទាំងនេះជាការបន្ធូរបន្ថយក្ដីមេត្តាករុណា(ពីអល់ឡោះ) និងកាត់បន្ថយការលំបាកក្នុងខណៈពេលធ្វើដំណើររបស់គេ។





# ការបួសរបស់អ្នក



# 4

ព្រះអល់ឡោះបានដាក់កាតព្វកិច្ចមកលើសាសនិកឥស្លាមនូវការបួសរយៈពេលមួយខែក្នុងមួយឆ្នាំ គឺខែរ៉ម៉ាហ្ទនដ៏ពិសិដ្ឋ ហើយទ្រង់បានចាត់ទុកការបួសនេះ គឺជាគោលគ្រឹះទីបួនក្នុងចំណោមបណ្ដាគោលគ្រឹះរបស់សាសនាឥស្លាមទាំងប្រាំ។ អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថាៈ “ឱបណ្ដាអ្នកដែលមានជំនឿទាំងឡាយ! ជាការពិតណាស់ គេ(អល់ឡោះ)បានដាក់កាតព្វកិច្ចមកលើពួកអ្នកទាំងអស់គ្នានូវការបួស ដូចដែលគេបានដាក់កាតព្វកិច្ចនេះទៅលើបណ្ដាប្រជាជាតិមុនពួកអ្នកដូចគ្នាដែរ សង្ឃឹមថាពួកអ្នកនឹងមានការកោតខ្លាច(ចំពោះអល់ឡោះ)”។ (គម្ពីរគួរអានៈ១៨៣)

## មាតិកានៃជំពូក


អត្ថន័យនៃការបួស
ឧត្តមភាពនៃខែរ៉ម៉ាហ្ទន
គោលបំណងនៃការបួស
គុណប្រយោជន៍នៃការបួសខែរ៉ម៉ាហ្ទន
ប្រការដែលបណ្ដាលឲ្យខូចបួស
អ្នកដែលច្បាប់អនុញ្ញាតឲ្យផ្អាកបួស

- អ្នកជំងឺ
- អ្នកអសមត្ថភាព
- អ្នកដំណើរ
- ស្ត្រីមានរដូវ និងស្ត្រីដែលនីហ្វាស
- ស្ត្រីកំពុងមានផ្ទៃពោះ និងស្ត្រីដែលបំបៅកូន

ការបួសស៊ូណិត (បួសដែលមិនមែនជាកាតព្វកិច្ច)
ពិធីបុណ្យស្រាយបួស(រ៉យ៉ាហ្វិតរ៉ោះ)

- តើច្បាប់ឥស្លាមបង្គាប់ប្រើឲ្យធ្វើអ្វីខ្លះនៅថ្ងៃបុណ្យ(រ៉យ៉ា)

# ការបួសខែរ៉ម៉ាហ្វូន

## អត្ថន័យនៃការបួស

ការបួសនៅក្នុងសាសនាឥស្លាម គឺជាការគោរពសក្ការៈទៅចំពោះព្រះអល់ឡោះជាម្ចាស់ដោយការតមអាហារ ការរួមភេទ និងប្រការផ្សេងៗទៀតដែលនាំឲ្យខូចបួស ចាប់ពីពេលសេតុណោះ (គឺពេលអាហ្សានហ្វាជើរ) រហូតដល់ថ្ងៃលិច(គឺពេលអាហ្សានម៉ាហ្គ្រិប)។

## > ឧត្តមភាពនៃខែរ៉ម៉ាហ្វូន

ខែរ៉ម៉ាហ្វូន គឺជាខែទី៩ នៃខែចន្ទគតិនៅក្នុងប្រតិទិនឥស្លាម។ វាគឺជាខែដែលល្អប្រសើរជាងគេបំផុតក្នុងចំណោមខែទាំង១២ ដែលអល់ឡោះបានផ្តល់នូវលក្ខណៈពិសេសជាច្រើននៅក្នុងខែនេះ ដែលមានដូចជា ៖

1. ជាខែដែលអល់ឡោះជ្រើសរើសសម្រាប់បញ្ចុះគម្ពីរដ៏វិសេស និងខ្ពង់ខ្ពស់ជាងគេបំផុត នោះគឺគម្ពីរគួរអានលការីម។ អល់ឡោះបានមានបន្ទូលថាៈ "ខែរ៉ម៉ាហ្វូន ជាខែដែលអល់ឡោះបានបញ្ចុះនូវគម្ពីរគួរអាន ដើម្បីណែនាំដល់មនុស្សលោក និងបង្ហាញពីមាគ៌ាដែលត្រឹមត្រូវ ព្រមទាំងវិនិច្ឆ័យរវាងខុសនិងត្រូវ។ ហេតុនេះ ជនណាហើយក្នុងចំណោមពួកអ្នក មានវត្តមាននៅក្នុងខែនេះ ចូរឱ្យគេបួស"។ (គម្ពីរគួរអាន ២:១៨៥)

2. អ្នកនាំសារបានមានប្រសាសន៍ថាៈ "នៅពេលដែលខែរ៉ម៉ាហ្វូនបានមកដល់ ទ្វារឋានសួគ៌ត្រូវបានបើក ទ្វារឋាននរកត្រូវបានបិទ ហើយពពួកបិសាច(ស្ហៃតន)ត្រូវបានគេចាប់ចង"។ (អាល់ពូខរីៈ៣១០៣ មូស្លីមៈ១០៧៩)។ អល់ឡោះបានប្រើឱ្យខ្ញុំបម្រើរបស់ទ្រង់រៀបចំទទួលវា ដោយការប្រតិបត្តិអំពើល្អ និងបោះបង់អំពើអាក្រក់។

3. ជាការពិត អ្នកដែលបានបួសក្នុងពេលថ្ងៃនៃខែរ៉ម៉ាហ្វូន និងបានសឡាតតារ៉ាវេះនៅពេលយប់នោះ រូបគាត់នឹងត្រូវបានគេ(អល់ឡោះ)លើកលែងទោសកំហុសរបស់គាត់ទាំងប៉ុន្មានដែលមានកន្លងមក។ព្យាការីមូហាំម៉ាត់លោកបានមានប្រសាសន៍ថាៈ"ជនណាហើយដែលបានបួសខែរ៉ម៉ាហ្វូន ដោយការមានជំនឿ និងរំពឹងផលបុណ្យអំពីអល់ឡោះនោះ គេនឹងអភ័យទោសឲ្យគាត់នូវបាបកម្មទាំងឡាយដែលគាត់បានសាងកន្លងមក"។ (អាល់ពូខរីៈ១៩១០ មូស្លីមៈ៧៦០) ព្យាការីមូហាំម៉ាត់ក៏បានមានប្រសាសន៍ផងដែរថាៈ "ជនណាដែលបានសឡាតស៊ូណិតពេលយប់នៃខែរ៉ម៉ាហ្វូន(ស៊ូណិតតារ៉ាវេះ)ដោយការមានជំនឿ និងរំពឹងផលបុណ្យអំពីអល់ឡោះនោះ គេនឹងអភ័យទោសឲ្យគាត់នូវបាបកម្មទាំងឡាយរបស់គាត់ដែលគាត់បានសាងកន្លងមក"។ (អាល់ពូខរីៈ១៩០៥ មូស្លីមៈ៧៥៩)

4. នៅក្នុងខែរ៉ម៉ាហ្វូន មានយប់មួយដ៏ពិសេសជាងគេគឺ យប់ឡៃឡាទុលក៏ទើរ ដែលអល់ឡោះបានបញ្ជាក់ប្រាប់នៅក្នុងគម្ពីរ(គួរអាន)របស់ទ្រង់ថា ការសាងទង្វើកុសលនៅក្នុងយប់នោះ គឺល្អប្រសើរជាងពេលផ្សេងៗទៀតទាំងអស់។ អល់ឡោះបានមានបន្ទូលថាៈ "យប់ឡៃឡាទុលក៏ទើរនោះ គឺល្អប្រសើរជាងមួយពាន់ខែ"។ (គម្ពីរគួរអាន ៩៧:៣)។ ហើយប្រសិនបើជនណាបានប្រតិបត្តិការគោរពសក្ការៈផ្សេងៗក្នុងយប់នោះ ដោយការមានជំនឿ និងរំពឹងផលបុណ្យអំពីអល់ឡោះនោះ គេនឹងអភ័យទោសឲ្យគាត់នូវបាបកម្មទាំងឡាយដែលគាត់បានសាងកន្លងមក"។ វាគឺជាយប់មួយដែលស្ថិតក្នុងចំណោមដប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្វូន ប៉ុន្តែពុំមាននរណាម្នាក់ដឹងពីពេលវេលារបស់វាជាក់លាក់នោះទេ។

# > គោលបំណងនៃការបួស

អល់ឡោះបានដាក់កាតព្វកិច្ចបួស ដោយសារបុព្វហេតុ និងអត្ថប្រយោជន៍ជាច្រើន ទាំងក្នុងលោកិយ និងថ្ងៃបរលោក ដូចជា ៖

## 1 ជាការបញ្ជាក់ឲ្យច្បាស់នូវការគោរពកោតខ្លាចអល់ឡោះ

ព្រោះថាការបួស គឺជាការគោរពសក្ការៈដែលមនុស្សលោកធ្វើវាដើម្បីបញ្ចិតខ្លួនគេទៅចំពោះម្ចាស់របស់គេ ដោយការបោះបង់(តម)នូវអ្វីដែលពួកគេពេញចិត្ត និងបញ្ឈប់នូវសេចក្តីស្រេកឃ្លានរបស់គេផ្សេងៗ ពោលគឺគេរៀបចំខ្លួនរបស់គេដោយការកោតខ្លាចទៅចំពោះអល់ឡោះនៅគ្រប់ពេលវេលា និងគ្រប់ទីកន្លែង ទាំងខាងក្នុង និងខាងក្រៅ។ ដូចនេះហើយ ទើបព្រះអល់ឡោះបានមានបន្ទូលថាៈ "ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ! ជាការពិតណាស់ គេ(អល់ឡោះ)បានដាក់កាតព្វកិច្ចមកលើពួកអ្នកទាំងអស់គ្នានូវការបួស ដូចដែលគេបានដាក់កាតព្វកិច្ចនេះមកលើបណ្តាប្រជាជាតិមុនពួកអ្នកដូចគ្នាដែរ សង្ឃឹមថាពួកអ្នកនឹងមានការកោតខ្លាច(អល់ឡោះ)"។(គម្ពីរគួរអាន ២ៈ១៨៣)

## 2 ការហ្វឹកហាត់ក្នុងការបោះបង់ប្រការខុសឆ្គង និងអំពើបាប

នៅពេលដែលអ្នកបួសគាត់បានតមអំពីប្រការដែលច្បាប់អនុញ្ញាតដើម្បីជាការគោរពទៅចំពោះអល់ឡោះជាម្ចាស់ គាត់ច្បាស់ជានឹងមានលក្ខណៈកាន់តែរឹងមាំក្នុងការហាមឃាត់ការស្រេកឃ្លានរបស់គាត់ក្នុងការធ្វើប្រការដែលច្បាប់ហាមឃាត់ និងឈរលើដែនកំណត់របស់អល់ឡោះ និងច្បាស់ជាមិនបន្តក្នុងការប្រព្រឹត្តអំពើអាក្រក់ទៀតនោះទេ។ អ្នកនាំសារបានមានប្រសាសន៍ថាៈ "បើជនណាមិនព្រមបោះបង់ចោលនូវការនិយាយអាក្រក់ និងអ្វីដែលអាក្រក់ គឺអល់ឡោះមិនត្រូវការការបោះបង់ចំណីអាហាររបស់គេនោះទេ"។ (អាល់ពូខរីៈ១៨០៤)។ ពោលគឺប្រសិនបើនរណាម្នាក់មិនព្រមបោះបង់ចោលនូវការកុហក ទាំងពាក្យសំដី និងកាយវិការទេនោះ គាត់មិនទាន់បានបំពេញនូវគោលបំណងនៃការបួសនោះទេ។

## 3 នឹកឃើញដល់អ្នកក្រីក្រ និង ជាការលួងចិត្តរបស់ពួកគេៈ

ជាការពិតនៅក្នុងការបួស វាជាបទពិសោធន៍ក្នុងការលួងចិត្តអ្នកក្រីក្រ អត់ឃ្លាន និងជាការធ្វើឲ្យនឹកឃើញដល់អ្នកទីទាល់ក្រដែលពួកគេកំពុងទទួលរងនូវការអត់ឃ្លាន និងហេវហត់ នៅពេលនោះមនុស្សច្បាស់ជានឹងនឹកឃើញបងប្អូនរបស់ខ្លួនដែលក្រីក្រ ថាតើពួកគេកំពុងទទួលនូវទុក្ខលំបាកយ៉ាងណាអំពីការស្រេកឃ្លាន ខណៈនោះវានឹងជំរុញឲ្យគេមានទឹកចិត្តកាន់តែខ្លាំងក្នុងការជួយដល់អ្នកទីទាល់ក្រ។



> សម្រាប់អ្នកដែលបួសមានការរីករាយពីរដងៈ
ទី១ សប្បាយរីករាយនៅពេលដែលគេស្រាយបួស
ទី២ សប្បាយរីករាយនៅពេលទៅជួបនឹងម្ចាស់របស់គេ

## > គុណប្រយោជន៍នៃការបួស

ការបួសមានគុណប្រយោជន៍ជាច្រើនដែលមានបញ្ជាក់ក្នុងច្បាប់ឥស្លាម ដែលមានដូចជា ៖

1 ជាការពិត អ្នកដែលបានបួសខែរ៉ម៉ាហ្ទន ប្រកបដោយការមានជំនឿចំពោះអល់ឡោះ គោរពតាមការបង្គាប់ប្រើរបស់ទ្រង់ ជឿជាក់ចំពោះគុណប្រយោជន៍នៃការបួសដែលមានបញ្ជាក់ ដោយរំពឹងចង់បានផលបុណ្យពីអល់ឡោះជាម្ចាស់នោះ ត្រូវបានគេលើកលែងទោសកំហុសរបស់គាត់កន្លងមក ដូចដែលអ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា: (ជនណាបានបួសខែរ៉ម៉ាហ្ទន ដោយការមានជំនឿ និងរំពឹងផលបុណ្យពីអល់ឡោះនោះ គេនឹងអភ័យទោសឲ្យគាត់នូវបាបកម្មទាំងឡាយដែលគាត់បានសាងកន្លងមក"។ (អាល់ពូខរី:១៩១០ មូស្លីម:៧៦០)

2 ជាការពិត អ្នកបួសនឹងសប្បាយរីករាយជាមួយនឹងអ្វីដែលគាត់ទទួលបាននៃផលបុណ្យ និងការសប្បាយរីករាយ នៅពេលជួបជាមួយអល់ឡោះជាម្ចាស់ ដោយសារតែការបួសរបស់គេ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា: "សម្រាប់អ្នកបួសមានការសប្បាយរីករាយពីរដង គឺការសប្បាយមួយនៅពេលដែលគាត់ស្រាយបួស ហើយការសប្បាយមួយទៀតនៅពេលដែលគាត់ជួបម្ចាស់របស់គាត់"។ (អាល់ពូខរី:១៨០៥ មូស្លីម:១១៥១)

3 ជាការពិតណាស់ នៅក្នុងឋានសួគ៌មានទ្វារមួយឈ្មោះថា អាល់រ៉យ្យ៉ាន(الرَّيَّانُ ) ។ មិនមាននរណាម្នាក់អាចចូលឋានសួគ៌តាមច្រកទ្វារនេះបានក្រៅពីអ្នកបួសឡើយ។ អ្នកនាំសារបានមានប្រសាសន៍ថា: "ជាការពិតណាស់ នៅក្នុងឋានសួគ៌មានទ្វារមួយឈ្មោះថា អាល់រ៉យ្យ៉ានសម្រាប់អ្នកបួសចូលនាថ្ងៃបរលោក។ គ្មាននរណាម្នាក់អាចចូលបានក្រៅពីពួកគេឡើយ។ នៅពេលនោះគេប្រកាសថា: ឯណាទៅអ្នកបួស? ខណៈនោះពួកគេក៏ក្រោកឡើង ហើយគ្មាននរណាម្នាក់ចូលបានក្រៅពីពួកគេឡើយ ហើយពេលពួកគេបានចូលអស់ ទ្វារក៏ត្រូវបានបិទ ដែលមិនអាចមាននរណាម្នាក់ចូលបានឡើយ"។

(អាល់ពូខរី:១៧៩៧ មូស្លីម:១១៥២)

4 ជាការពិត អល់ឡោះបានរំលឹកជាពិសេសចំពោះផលតបស្នងនៃការបួសថា ទ្រង់គឺជាអ្នកផ្តល់ផលបុណ្យដោយផ្ទាល់។ ជនណាដែលមានសំណាងបានទទួលការតបស្នងពីសំណាក់ម្ចាស់ដែលមហាសប្បុរសនោះ រូបគេច្បាស់ជាមិនមានអ្វីត្រូវព្រួយបារម្ភនូវអ្វីដែលអល់ឡោះបានរៀបចំសម្រាប់គេនោះទេ។ អ្នកនាំសារបានមានប្រសាសន៍ថា: "គ្រប់កិច្ចប្រណិប័តន៍ទាំងឡាយរបស់មនុស្សលោក គឺសម្រាប់ពួកគេលើកលែងតែការបួស គឺសម្រាប់យើង (អល់ឡោះ) ហើយយើងនឹងតបស្នងចំពោះកិច្ចប្រណិប័តន៍នេះដោយផ្ទាល់"។ (អាល់ពូខរី:១៨០៥ មូស្លីម:១១៥១)



> ខែរ៉ម៉ាទន គឺជាខែទី៩នៃខែចន្ទគតិនៅក្នុងប្រតិទិនឥស្លាម។

## > ប្រការដែលបណ្តាលឲ្យខូចបួស

វាគឺជាប្រការដែលអ្នកបួសត្រូវជៀសវាង ព្រោះថាវាបណ្តាលឲ្យខូចបួស ឬដាច់បួស។ ប្រការទាំងនោះមានដូចខាងក្រោម ៖

1 ការបរិភោគ: អល់ឡោះបានមានបន្ទូលថា: “ហើយចូរពួកអ្នកហូប និងផឹករហូតទាល់តែផ្ទៃមេឃមានពន្លឺពណ៌សចេញពីផ្ទៃមេឃពណ៌ខ្មៅងងឹតនៅពេលទៀបភ្លឺ។ បន្ទាប់មក ចូរពួកអ្នកបន្តការបួសរហូតដល់ពេលយប់។”។ (គម្ពីរគួរអាន ២:១៨៧)

បុគ្គលណាហើយដែលហូប និងផឹកដោយការភ្លេច ការបួសរបស់គាត់ត្រឹមត្រូវ ហើយគាត់មិនទទួលបាបកម្មឡើយ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា : “បុគ្គលណាដែលភ្លេចហើយរូបគាត់កំពុងបួស ដោយបានហូបអាហារ និងពិសារទឹកក្នុងពេលនោះ ចូរឱ្យគាត់បន្តបំពេញការបួសរបស់គាត់ចុះ។ ការពិត អល់ឡោះគឺជាអ្នកផ្តល់អាហារ និងទឹកនោះដល់គាត់”។ (អាល់ពូខរី:១៨៣១ មូស្លីម:១១៥៥)

2 ទង្វើទាំងឡាយដែលមានន័យស្មើនឹងការបរិភោគ ដែលមានដូចជា ៖

- គ្រឿងបំប៉នរាងកាយ និងថ្នាំកម្លាំង ដែលចូលទៅក្នុងខ្លួន ដើម្បីជួយបំពេញនូវសារជាតុអាហារដែលបាត់បង់ ដែលប្រៀបបាននឹងការបរិភោគដែរ។ ដូចនេះ ច្បាប់របស់វាដូចជាការបរិភោគដែរ។
- ការបញ្ចូលឈាមសម្រាប់អ្នកជំងឺ ព្រោះថាឈាមវាជាលទ្ធផលនៃការបរិភោគ។
- ការជក់: គ្រប់ប្រភេទទាំងអស់វាបណ្តាលឲ្យខូចបួស ព្រោះថាវានាំជាតិពុលទៅក្នុងខ្លួនតាមរយៈការហឺតផ្សែង។

3 ការរួមភេទ: គឺការបញ្ចូលប្រដាប់ភេទបុរសក្នុងប្រដាប់ភេទស្ត្រី បើទោះជាបានចេញទឹកកាម ឬអត់ក្តី។

4 ការបញ្ចេញទឹកកាមដោយចេតនា: ដោយការប្រឡែង ឬការបញ្ចេញទឹកកាមដោយប្រើដៃ។ល។

ចំណែកឯការចេញទឹកកាមដោយការយល់សប្តិ មិនបណ្តាលឲ្យខូចបួសទេ។

ចំពោះស្វាមីអាចថើបភរិយាគាត់បាន ប្រសិនបើគាត់អាចទប់ខ្លួនគាត់មិនឲ្យប្រព្រឹត្តនូវអ្វីដែលនាំឲ្យខូចបួសបាន។

5 ការក្អួតដោយចេតនា: ប្រសិនបើក្អួតដោយអចេតនា វាមិនជាបញ្ហាអ្វីទេ។ ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា: "ជនណាបានក្អួតដោយអចេតនាខណៈដែលគាត់កំពុងបួស គឺគ្មានបញ្ហាអ្វីឡើយ តែបើជនណាមានចេតនាធ្វើឲ្យក្អួតនោះ គឺគេត្រូវបួសសងវិញ"។ (អាត់តៀរមីហ្ស៊ី:៧២០ អាពូហ្ទាវូទ:២៣៨០)

6 មានឈាមរដូវ និងឈាមនីហ្វាស: នៅពេលណាដែលស្ត្រីមានឈាមរដូវ ឬឈាមនីហ្វាស (ឈាមពេលសំរាលកូន)នៅផ្នែកណាមួយនៃពេលថ្ងៃ ការបួសរបស់គាត់ត្រូវខូចហើយ ឬប្រសិនបើស្ត្រីម្នាក់មករដូវ ហើយបានអស់ឈាមរដូវបន្ទាប់ពីពេលហ្វាជើរនោះ ការបួសរបស់គាត់ក៏មិនត្រឹមត្រូវដែរ ហើយគាត់ត្រូវផ្អាកបួសនៅថ្ងៃនោះ ព្រោះប្រសាសន៍របស់ព្យាការីមូហាំម៉ាត់បានលើកឡើងថា: "តើមិនមែនទេឬ ពេលដែលស្ត្រីមករដូវ គឺគាត់មិនត្រូវសឡាត និងមិនត្រូវបួសនោះ"? (អាល់ពូខរី:១៨៥០)

ចំណែកឯឈាមដែលចេញពីស្ត្រីដោយមូលហេតុជំងឺ ដែលវាមិនមែនជាឈាមរដូវដែលមានចំនួនថ្ងៃច្បាស់លាស់រៀងរាល់ខែ ហើយក៏មិនមែនឈាមសំរាលកូនដែលកើតមានបន្ទាប់ពីសំរាលកូនទេនោះ គឺវាមិនបានរាំងគាត់អំពីការបួសឡើយ។

## > អ្នកដែលអល់ឡោះអនុញ្ញាតឲ្យផ្អាកបួសចាន

ជាការពិត អល់ឡោះជាម្ចាស់បានអនុញ្ញាតឲ្យក្រុមមនុស្សខ្លះអាចផ្អាកបួសក្នុងខែរ៉ម៉ាហ្ទនបានជាការបន្ធូរបន្ថយ ជាក្តីមេត្តាករុណា និងជាការផ្តល់ភាពងាយស្រួលដល់ពួកគេ។ អ្នកទាំងនោះមានដូចខាងក្រោម ៖

**1** អ្នកជំងឺ: ពេលគឺអ្នកជំងឺដែលមានបញ្ហាក្នុងការបួស ដែលបណ្តាលឲ្យគាត់មិនអាចបួសបាន គឺគាត់អាចផ្អាក ឬសំរាកពីការបួសបាន ហើយគាត់ត្រូវបួសសងវិញបន្ទាប់ពីរ៉ម៉ាហ្ទនរួច។

**2** អ្នកដែលអសមត្ថភាពក្នុងការបួស: ដោយសារតែភាពចាស់ជរា ឬជំងឺដែលមិនសង្ឃឹមថាអាចជាសះស្បើយបាន គឺគាត់ត្រូវបានអនុញ្ញាតឲ្យផ្អាកបួស តែត្រូវផ្តល់អាហារដល់អ្នកក្រម្នាក់ក្នុងមួយថ្ងៃ ដោយគាត់ត្រូវផ្តល់អាហារចំនួនប្រហែលមួយគីឡូកន្លះ អំពីចំណីអាហារដែលអ្នកស្រុកបរិភោគប្រចាំថ្ងៃ។

**3** អ្នកដំណើរ: អ្នកដំណើរខណៈដែលកំពុងធ្វើដំណើរ និងការស្នាក់នៅបណ្តោះអាសន្នក្នុងរយៈពេលតិចជាងបួនថ្ងៃ គាត់ត្រូវបានអនុញ្ញាតឲ្យផ្អាកបួសបាន តែគាត់ត្រូវបួសសងវិញបន្ទាប់ពីចប់ខែរ៉ម៉ាហ្ទន។ អល់ឡោះបានមានបន្ទូលថា: "ហើយជនណាមានជំងឺ ឬធ្វើដំណើរ(អាចផ្អាកបួសបាន) តែត្រូវបួសសងវិញនៅថ្ងៃផ្សេង(ចំនួនថ្ងៃដែលបានផ្អាកនោះ)។ អល់ឡោះចង់ឲ្យពួកអ្នកងាយស្រួល ទ្រង់មិនចង់ឲ្យពួកអ្នកលំបាកទេ"។ (គម្ពីរគួរអាន ២:១៨៥)

**4** ស្ត្រីមានឈាមរដូវ និងឈាមនីហ្វាស: ច្បាប់ឥស្លាមហាមដាច់ខាតចំពោះស្ត្រីមានរដូវ និងស្ត្រីមាននីហ្វាសអំពីការបួស ហើយបើទោះជាពួកគេបួស ក៏ការបួសរបស់ពួកគេមិនត្រឹមត្រូវដែរ ហើយពួកគាត់ត្រូវបួសសងវិញបន្ទាប់ពីខែរ៉ម៉ាហ្ទន។ (សូមមើលទំព័រ ៩៨)

**5** ស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន: ប្រសិនបើពួកគាត់ព្រួយបារម្ភខ្លាចមានបញ្ហាដល់ខ្លួន ឬក៏កូនៗរបស់ពួកគាត់នោះ គឺពួកគាត់អាចផ្អាកបួសបាន ហើយគាត់ត្រូវបួសសងវិញតាមចំនួនថ្ងៃដែលគាត់បានផ្អាកបួសនោះ។



## តើច្បាប់ឥស្លាមកំណត់បែបណាចំពោះអ្នកដែលស្រាយបួសក្នុងខែរ៉ម៉ាហ្ទន ?

បុគ្គលទាំងឡាយណាដែលស្រាយបួស ឬមិនបួសក្នុងខែរ៉ម៉ាហ្ទនដោយគ្មានមូលហេតុសមស្រប ទេនោះ ចាំបាច់លើរូបគេត្រូវទទួលសារភាពកំហុស(តាវហ្គាត់)ពីអល់ឡោះ ពីព្រោះរូបគេបានប្រព្រឹត្តនូវបាបកម្មដ៏ធំបំផុត ហើយវាជាការមិនគោរពនូវការបង្គាប់ប្រើរបស់ព្រះជាម្ចាស់ ហើយរូបគេត្រូវបួសសងវិញនូវថ្ងៃដែលគេបានស្រាយ ឬមិនបួសនោះតែប៉ុណ្ណោះ។ ក៏ប៉ុន្តែ ចំពោះអ្នកដែលស្រាយបួស(ដាច់បួស)ដោយសារតែការរួមរ័ក្ស គឺគេត្រូវបួសសងសម្រាប់ថ្ងៃដែលគេបានស្រាយនោះ រួមជាមួយនឹងការទទួលការពិន័យចំពោះទង្វើបាបរបស់គាត់ ដោយត្រូវដោះលែងខ្ញុំបម្រើ(ទាសករដាច់ថ្លៃ)ម្នាក់ ពោលគឺត្រូវទិញខ្ញុំបម្រើមូស្លីមម្នាក់ ហើយដោះលែងឲ្យមានសេរីភាព។ ជាការពិត សាសនាឥស្លាមបានបញ្ជាក់យ៉ាងច្បាស់អំពីសារសំខាន់នៃការដោះលែងមនុស្សឲ្យរួចផុតពីភាពជាខ្ញុំគេ(ទាសករដាច់ថ្លៃ) នៅគ្រប់ឱកាសទាំងអស់ដែលសមស្រប។ ប្រសិនបើរូបគេគ្មានលទ្ធភាពទេនោះ គឺត្រូវបួសរយៈពេលពីរខែបន្តបន្ទាប់គ្នា។ ហើយប្រសិនបើគ្មានលទ្ធភាពទៀតនោះ គឺរូបគេត្រូវផ្តល់អាហារដល់អ្នកទីទាល់ក្រចំនួន៦០នាក់។

## > ការបួសស៊ូណិត(ការបួសដែលមិនមែនជាកាតព្វកិច្ច)

អល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចបួសមួយខែក្នុងមួយឆ្នាំ ក៏ប៉ុន្តែ ទ្រង់ក៏ជម្រុញឲ្យបួសក្នុងថ្ងៃផ្សេងៗទៀតផងដែរសម្រាប់អ្នកដែលមានលទ្ធភាព ហើយចង់បានផលបុណ្យបន្ថែម។ ការបួសទាំងនោះ មានដូចខាងក្រោម ៖

1. ការបួសថ្ងៃអាស៊ូរ៉ា: រួមជាមួយការបួសមុនមួយថ្ងៃ និងក្រោយមួយថ្ងៃ។ អាស៊ូរ៉ាជាថ្ងៃទីដប់នៃខែមូហារ៉មែ (ខែទីមួយនៃប្រតិទិនឥស្លាម)។ វាគឺជាថ្ងៃដែលព្រះអល់ឡោះបានសង្គ្រោះព្យាការីមូសា(ម៉ូសេ) អំពីហ្វៀរអោន(ផារ៉ាអុង) ហើយទ្រង់បានធ្វើឱ្យផារ៉ាអុងនិងបក្សពួកលិចក្នុងសមុទ្រ។ ដូចនេះហើយទើបសាសនិកឥស្លាមបួសក្នុងថ្ងៃនេះដើម្បីជាការថ្លែងអំណរគុណទៅចំពោះអល់ឡោះដែលទ្រង់បានជួយព្យាការីមូសា(ម៉ូសេ)ឲ្យរួចពីសេចក្តីស្លាប់ និងជាការអនុវត្តតាមអ្នកនាំសាររបស់យើង(ព្យាការីមូហាំម៉ាត់) គ្រាដែលលោកបានបួសហើយបានមានប្រសាសន៍ថា "ចូរពួកអ្នកទាំងអស់គ្នាបួសមុនវា(ថ្ងៃអាស៊ូរ៉ា)មួយថ្ងៃ ឬក្រោយវាមួយថ្ងៃ"។ (អះម៉ាត់:២១៥៤)។ នៅពេលដែលមានគេសួរលោកអំពីការបួសនេះ លោកបានឆ្លើយថា "វាលុបលាងបាបកម្មដែលគេបានសាងក្នុងរយៈពេលមួយឆ្នាំដែលកន្លងទៅ"។ (មូស្លីម:១១៦២)
2. ការបួសថ្ងៃអារ៉ហ្វេះ: គឺជាថ្ងៃទី៩ នៃខែហ្ស៊ុលហ៊ិជ្ជះ(ខែទី១២ នៃប្រតិទិនឥស្លាម)។ វាជាថ្ងៃដែលក្រុមអ្នកធ្វើធម្មយាត្រាហាជ្ជីទាំងអស់ជួបជុំគ្នានៅកន្លែងវាលអារ៉ហ្វេះ។ ពួកគេធ្វើការបួងសួងនិងសំដែងនូវតម្រូវការរបស់ពួកគេទៅចំពោះទ្រង់ ហើយវាក៏ជាថ្ងៃដែលល្អជាងគេបំផុតក្នុងមួយឆ្នាំផងដែរ។ គេបង្គាប់ឲ្យអ្នកដែលមិនទៅធ្វើហាជ្ជីឲ្យបួសក្នុងថ្ងៃនោះ។ នៅពេលដែលគេសួរលោកអំពីការបួសលោកបានឆ្លើយថា: "វាលុបលាងបាបកម្មដែលបានកើតឡើងក្នុងរយៈពេលមួយឆ្នាំដែលកន្លងទៅ និងមួយឆ្នាំដែលនៅខាងមុខ"។ (មូស្លីម:១១៦២)
3. ការបួសប្រាំមួយថ្ងៃនៃខែស្ហាវ៉ាល់(ខែទីដប់នៃប្រតិទិនឥស្លាម)៖ អ្នកនាំសារមានប្រសាសន៍ថា: "អ្នកណាបានបួសខែរ៉ម៉ាហ្ទន ហើយបានបួស៦ថ្ងៃទៀតនៃខែស្ហាវ៉ាល់ គឺហាក់បីដូចជាគេបានបួសពេញមួយឆ្នាំ"។ (មូស្លីម:១១៦៤)

## > ថ្ងៃបុណ្យស្រាយបួស (រ៉យ៉ាហ្វិតរ៉ោះ)

ពិធីបុណ្យទានផ្សេងៗ វាជានិមិត្តសញ្ញានៃសាសនា។ នៅពេលដែលព្យាការីមូហាំម៉ាត់បានមកដល់ទីក្រុងម៉ាទីណះ លោកបានឃើញពួកអាន់សរ៍ (ពួកគេ គឺជាជនមូស្លីមដែលរស់នៅទីក្រុងម៉ាទីណះ) លេងកម្សាន្តសប្បាយចំនួនពីរថ្ងៃក្នុងមួយឆ្នាំ។ លោកបានសួរពួកគេថា "តើថ្ងៃទាំងពីរនេះជាថ្ងៃអ្វី"? ពួកគេបានឆ្លើយថា "ជាថ្ងៃដែលពួកយើងតែងតែលេងកម្សាន្តសប្បាយតាំងពីសម័យហ្ជើហ៊ីលីយ៉ះ (សម័យកាលមុនឥស្លាម)មកម្លេះ"។ លោកក៏បានបន្តថា “ជាការពិត អល់ឡោះបានប្តូរឲ្យពួកអ្នកនូវពីរថ្ងៃដែលល្អប្រសើរជាងនេះ គឺថ្ងៃបុណ្យ អាដហា(ថ្ងៃរ៉យ៉ាហាជ្ជី) និងថ្ងៃបុណ្យស្រាយបួស(ថ្ងៃរ៉យ៉ាហ្វិតរ៉ោះ"។(អាពូហ្ទាវូទ:១១៣៤)។លោកក៏បានមានប្រសាសន៍បញ្ជាក់ផងដែរថា ថ្ងៃបុណ្យ(រ៉យ៉ា) វាគឺជាអត្តសញ្ញាណរបស់សាសនា ដោយលោកបានមានប្រសាសន៍ថា: “ជាការពិតណាស់ គ្រប់ក្រុមនីមួយៗតែងតែមានថ្ងៃបុណ្យ ហើយនេះ គឺជាថ្ងៃបុណ្យរបស់ពួកយើង”។ (អាល់ពូខរី:៩០៩ មូស្លីម:៨៩២)

### ថ្ងៃបុណ្យនៅក្នុងសាសនាឥស្លាម:

ថ្ងៃបុណ្យ(ថ្ងៃបុណ្យ)នៅក្នុងសាសនាឥស្លាម គឺជាថ្ងៃដែលសំដែងនូវការសប្បាយរីករាយដោយគេបានបំពេញនូវកិច្ចប្រណិប័តន៍ ដើម្បីជាការថ្លែងអំណរគុណចំពោះអល់ឡោះជាម្ចាស់ដែលទ្រង់បានចង្អុលបង្ហាញនិងប្រទានពរជ័យសម្រាប់បំពេញនូវកិច្ចប្រណិប័តន៍(ការគោរពសក្ការៈ)ទាំងនោះ។ នៅក្នុងថ្ងៃនោះ ច្បាប់អនុញ្ញាតឲ្យបង្កើតភាពសប្បាយរីករាយដល់មនុស្សម្នាទាំងឡាយ ដោយស្លៀកសម្លៀកបំពាក់ស្អាតៗ ធ្វើល្អចំពោះអ្នកក្រីក្រ និងធ្វើនូវទង្វើផ្សេងៗទៀតដែលស្របតាមច្បាប់ឥស្លាម ដូចជាការរៀបចំកម្មវិធី និងសកម្មភាពផ្សេងៗដែលនាំមកនូវភាពសប្បាយរីករាយដល់គ្រប់គ្នា ហើយរំលឹកដាស់តឿនពួកគេឲ្យនឹកឃើញនូវការប្រោសប្រទានទាំងឡាយរបស់អល់ឡោះមកលើពួកគេ។

### ថ្ងៃបុណ្យរបស់សាសនិកឥស្លាម:

សម្រាប់សាសនិកឥស្លាមមានថ្ងៃបុណ្យពីរក្នុងមួយឆ្នាំ ដែលពួកគេតែងតែប្រារព្ធធ្វើវាជារៀងរាល់ឆ្នាំ ហើយច្បាប់មិនអនុញ្ញាតឲ្យកំណត់ថ្ងៃណាមួយធ្វើជាថ្ងៃបុណ្យផ្សេងពីថ្ងៃទាំងពីរនេះនោះទេ។ ថ្ងៃបុណ្យទាំងពីរនោះគឺ: ថ្ងៃបុណ្យស្រាយបួស(ថ្ងៃរ៉យ៉ាហ្វិតរ៉ោះ) ដែលគេប្រារព្ធធ្វើនៅថ្ងៃទីមួយនៃខែស្ហាវ៉ាល់(ខែទី១០នៃប្រតិទិនឥស្លាម) និងថ្ងៃបុណ្យ អាដហា(ថ្ងៃរ៉យ៉ាហាជ្ជី) ដែលគេប្រារព្ធធ្វើនៅថ្ងៃទីដប់ នៃខែហ្ស៊ុលហិជ្ជះ(ខែទី១២នៃប្រតិទិនឥស្លាម)។

### ថ្ងៃបុណ្យស្រាយបួស(ថ្ងៃរ៉យ៉ាហ្វិតរ៉ោះ)

ពិធីបុណ្យនេះត្រូវបានប្រារព្ធធ្វើនៅថ្ងៃទីមួយនៃខែស្ហាវ៉ាល់ ដែលជាខែទីដប់នៃប្រតិទិនឥស្លាម។ វាជាពិធីបុណ្យដែលធ្វើឡើងបន្ទាប់ពីបញ្ចប់យប់ចុងក្រោយនៃខែរ៉ម៉ាហ្ទន។ ហេតុនេះហើយទើបគេឲ្យឈ្មោះថាជា ថ្ងៃបុណ្យស្រាយបួស(ថ្ងៃរ៉យ៉ាហ្វិតរ៉ោះ )។ ម្យ៉ាងទៀត ដោយសារតែមនុស្សទាំងឡាយគោរពសក្ការៈចំពោះអល់ឡោះជាម្ចាស់ដោយការស្រាយបួស(មិនបួស)នៅក្នុងថ្ងៃនេះ ដូចដែលពួកគេបានគោរពសក្ការៈចំពោះទ្រង់ដោយការបួសក្នុងខែរ៉ម៉ាហ្ទនដូច្នោះដែរ ពោលគឺពួកគេប្រារព្ធពិធីបុណ្យនេះ ជាការថ្លែងអំណរគុណទៅចំពោះការប្រោសប្រទានរបស់អល់ឡោះដែលបានផ្តល់ភាពងាយស្រួលដល់ពួកគេបានបំពេញកាតព្វកិច្ចបួសខែរ៉ម៉ាហ្ទន។ អល់ឡោះបានមានបន្ទូលថា: “ហើយចូរពួកអ្នកបួសបង្គ្រប់ចំនួន(ថ្ងៃនៃខែរ៉ម៉ាហ្ទន)។ ហើយចូរពួកអ្នកលើកតម្កើងអល់ឡោះ(តឹកពៀរនៅថ្ងៃរ៉យ៉ាហ្វិតរ៉ោះ)ចំពោះអ្វីដែលទ្រង់បានចង្អុលបង្ហាញពួកអ្នក ហើយសង្ឃឹមថា ពួកអ្នកនឹងថ្លែងអំណរគុណ"។ (គម្ពីរគួរអាន ២:១៨៥)

## តើច្បាប់ឥស្លាមតម្រូវឲ្យធ្វើអ្វីខ្លះនាថ្ងៃបុណ្យ?

1 ការសឡាតថ្ងៃបុណ្យ(សឡាតរ៉យ៉ា) ជាការសឡាតដែលឥស្លាមជំរុញឲ្យប្រណិប័តន៍វា ហើយក៏ជម្រុញឱ្យចូលរួមទាំងប្រុស ទាំងស្រី និងក្មេងៗផងដែរ។ ពេលវេលារបស់វាគឺចាប់ផ្តើមពីព្រះអាទិត្យមានកំពស់មួយថ្នោលរហូតដល់ថ្ងៃជ្រេរ។ មានន័យថាអ្នកមើលឃើញកំពស់ថ្ងៃរះប្រហែលប្រវែងលំពែង វាគឺប្រហែលមួយម៉ែត្រជាង។

របៀបសឡាត: ចំពោះការសឡាតថ្ងៃបុណ្យ(សឡាតរ៉យ៉ា) គឺមានចំនួនពីររ៉ក្អាត់។ អ៊ីម៉ាំសូត្រលឺៗ ហើយសូត្រឃុតហ្ពះពីរបន្ទាប់ពីសឡាតរួច។ នៅក្នុងសឡាតថ្ងៃបុណ្យនេះ តម្រូវឲ្យបន្ថែម ការសូត្រតឹកពៀរនៅដើមរ៉ក្អាត់នីមួយៗ។ នៅរ៉ក្អាត់ទីមួយមុននឹងសូត្រហ្វាទីហះ ត្រូវសូត្រតឹកហ្បៀរចំនួន៦ដង ដោយមិនរាប់តឹកពៀរ៉ទុលអៀហរ៉ម(តឹកពៀរពេលផ្តើមសឡាត) ហើយនៅរ៉ក្អាត់ទីពីរត្រូវសូត្រតឹកពៀរចំនួន៥ដង ដោយមិនរាប់ការសូត្រតឹកពៀរពេលក្រោកពីស៊ូជោទទេ។

2 ការបរិច្ចាគហ្សាកាត់ហ្វីត្រោះ: ជាការពិតអល់ឡោះបានដាក់កាតព្វកិច្ចឲ្យបរិច្ចាគហ្សាកាត់ចំពោះអ្នកដែលមានអាហារសម្រាប់ផ្គត់ផ្គង់ជីវភាពរបស់គាត់គ្រប់សម្រាប់យប់នឹងថ្ងៃបុណ្យ គឺគាត់ត្រូវតែបរិច្ចាកចំនួនមួយសក អំពីចំណីអាហារនៅក្នុងស្រុកភូមិរបស់គាត់ ដូចជាអង្ករស្រូវសាលី ឬក៏ផ្លែល្មើ ទៅឲ្យអ្នកក្រីក្រនិងអ្នកដែលខ្វះខាត។ ធ្វើបែបនេះដើម្បីឲ្យថ្ងៃបុណ្យមានតែភាពសប្បាយរីករាយមិនមានអ្នកខ្វះខាតនោះទេ។



ពេលវេលាដែលត្រូវបរិច្ចាគហ្សាកាត់ហ្វីត្រោះ គឺចាប់ពីថ្ងៃលិចនាថ្ងៃចុងក្រោយនៃខែរ៉ម៉ាហ្ទន រហូតដល់ពេលសឡាតថ្ងៃបុណ្យ(ថ្ងៃរ៉យ៉ា)។ ច្បាប់ឥស្លាមក៏អនុញ្ញាតឲ្យបរិច្ចាគមុនថ្ងៃបុណ្យមួយយប់ ឬពីរយប់ផងដែរ។

ចំនួនដែលត្រូវចេញ: គឺចំនួន មួយសក អំពីចំណីអាហារអ្នកស្រុកភូមិដូចជា ស្រូវសាលី អង្ករ ផ្លែល្មើ ឬក៏អ្វីផ្សេងទៀតដែលជាអាហាររបស់អ្នកស្រុក។ "សក" គឺជារង្វាល់ ប៉ុន្តែបើយើងគិតជាទំនង់ វាងាយស្រួលជាងក្នុងការកំណត់តាមខ្នាតចំនួននាពេលបច្ចុប្បន្ន គឺវាស្មើនឹងទំងន់ប្រហែលជា៣គីឡូក្រាម។

ការបួសរបស់អ្នក

វាជាកាតព្វកិច្ចចំពោះខ្លួនគាត់និងអ្នកដែលគាត់មានកាតព្វកិច្ចត្រូវផ្គត់ផ្គង់ ដូចជា ប្រពន្ធ និងកូនៗរបស់គាត់។ ជាការប្រសើរ គួរបរិច្ចាគជំនួសឲ្យទារកដែលនៅក្នុងផ្ទៃម្ដាយ គឺទារកម្នាក់ស្មើនឹង មួយសកអំពីអាហាររបស់អ្នកស្រុក ពោលគឺទំនង់ប្រមាណជា៣គីឡូក្រាម។

ជាការពិត អ្នកនាំសារបានដាក់កាតព្វកិច្ចការបរិច្ចាគហ្សាកាត់នេះ "ជាការសម្អាតដល់អ្នកបួសអំពីកំហុសឆ្គង ហើយក៏ជាអាហារសម្រាប់អ្នកទីទាល់ក្រផងដែរ។ ដូចនេះ ប្រសិនបើជនណាបានបរិច្ចាគវាមុនពេលសឡាតថ្ងៃបុណ្យ វាគឺជាហ្សាកាត់ដែលត្រូវអល់ឡោះទទួលយក តែប្រសិនបើជនណាបានបរិច្ចាគវាបន្ទាប់ពីសឡាត វាគឺជាការបរិច្ចាគទាន(សហ្ទើកោះ)មួយប៉ុណ្ណោះ។ (អាពូហ្ទាវូទៈ១៦០៩)



3 ច្បាប់អនុញ្ញាតឲ្យបង្ហាញនូវភាពសប្បាយរីករាយនៅក្នុងគ្រួសារ ទាំងក្មេងចាស់ប្រុសស្រី ជាមួយនឹងអ្វីដែលច្បាប់អនុញ្ញាត ហើយស្លៀកសំលៀកបំពាក់ស្អាតៗ និងការគោរពសក្ការៈទៅចំពោះអល់ឡោះជាម្ចាស់ដោយការស្រាយបួស (មិនបួសក្នុងថ្ងៃបុណ្យនោះ) និងការទទួលទានអាហារនាថ្ងៃបុណ្យ។ ហេតុនេះទើបច្បាប់ហាមមិនឲ្យបួសក្នុងថ្ងៃបុណ្យនោះទេ។



4 គប្បីសូត្រតឹកពៀរទៅចំពោះអល់ឡោះនៅយប់ថ្ងៃបុណ្យ និងពេលចាកចេញទៅសឡាតថ្ងៃបុណ្យ(សឡាតរ៉យ៉ា) ហើយពេលសូត្រតឹកពៀរនេះត្រូវបញ្ចប់ដោយការសឡាតថ្ងៃបុណ្យ។ ការសូត្រតឹកពៀរ គឺជាការបង្ហាញនូវភាពសប្បាយរីករាយដែលបានបំពេញការបួសខែរ៉ម៉ាហ្ទនដ៏ពិសិដ្ឋ និងជាការថ្លែងអំណរគុណចំពោះការប្រោសប្រទាន និងការចង្អុលបង្ហាញរបស់ទ្រង់មកចំពោះពួកយើងគ្រប់គ្នាសម្រាប់ការបួសនេះ។ អល់ឡោះបានមានបន្ទូលថា "ហើយចូរពួកអ្នកបួសបង្គ្រប់ចំនួន(ថ្ងៃនៃខែរ៉ម៉ាហ្ទន)។ ហើយចូរពួកអ្នកលើកតម្កើងអល់ឡោះ(តឹកហ្បៀរនៅថ្ងៃរ៉យ៉ាហ្វិតរ៉ោះ)ចំពោះអ្វីដែលទ្រង់បានចង្អុលបង្ហាញ ហើយសង្ឃឹមថា ពួកអ្នកថ្លែងអំណរគុណ"។ (គម្ពីរគួរអាន ២:១៨៥)

របៀបនៃការសូត្រតឹកពៀរៈ

اَللّٰهُ أَكْبَرُ، اَللّٰهُ أَكْبَرُ، لاَ إِلَهَ إِلاَّ اللهُ، اَللّٰهُ أَكْبَرُ اللهُ أَكْبَرُ، وَلِلّٰهِ الْحَمْدُ

អល់ឡហ៊ូ អឹកពើរ អល់ឡហ៊ូ អឹកពើរ ឡើអ៊ីឡើហើ អ៊ិលលល់ឡោះ អល់ឡហ៊ូ អឹកពើរ អល់ឡហ៊ូ អឹកពើរ វ៉ាលីលឡើហ៊ិលហាំទ៍

ហើយសូត្រទៀតថាៈ

اَللّٰهُ أَكْبَرُ كَبِيْرًا، وَالْحَمْدُ لِلّٰهِ كَثِيْرًا، وَسُبْحَانَ اللهِ بُكْرَةً وَأَصِيْلاً

អល់ឡហ៊ូ អឹកពើរ កាពីរ៉ាវ វ៉ាល់ហាំទូ លីលឡើ ហ៊ីកាស៊ីរ៉ វ៉ាស៊ុបហា ណល់ឡហ៊ី ពុករ៉តៅ វ៉ាអាស៊ីឡើ

ច្បាប់បង្គាប់ប្រើឲ្យបុរសបន្លឺសំលេងសូត្រខ្លាំងៗ តែធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ និងរំខានដល់អ្នកដទៃ។ ចំណែកឯស្ត្រី គឺតម្រូវឲ្យសូត្រតិចៗ។



> អ្នកមូស្លីមបន្ទាប់ពីពួកគេបានចេញពីសឡាតថ្ងៃបុណ្យ(សឡាតរ៉យ៉ា)



# ហ្សាកាត់របស់អ្នក
# (ការបរិច្ចាគទ្រព្យ)



# 5

អល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចហ្សាកាត់ និងបានចាត់ទុកវាជាគោលគ្រឹះទីបីក្នុងចំណោមគោលគ្រឹះទាំងប្រាំរបស់សាសនាឥស្លាម ហើយទ្រង់ក៏បានព្រមានដោយការដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលមិនគោរពតាមច្បាប់នេះ។ ទ្រង់ក៏បានភ្ជាប់វាជាមួយនឹងភាពជាបងប្អូននៅក្នុងសាសនាឥស្លាមដោយការបោះបង់នូវការមិនគោរពច្បាប់នេះ ហើយព្រមបរិច្ចាគឡើងវិញ។ អល់ឡោះបានមានបន្ទូលថា “ប្រសិនបើពួកគេសារភាពកំហុស(មានជំនឿ) និងប្រតិបត្តិសឡាត ហើយនិងបរិច្ចាគហ្សាកាត់នោះ គឺពួកគេជាបងប្អូនរួមសាសនារបស់ពួកអ្នក”។ (គម្ពីរគួរអាន ៩:១១) ព្យាការីមូហាំម៉ាត់បានមានប្រសាសន៍ថា “សាសនាឥស្លាមត្រូវបានសាងសង់លើគ្រឹះ ៥ ......ក្នុងនោះលោកបានលើកឡើងថា "ការបញ្ឈរសឡាត និងការបរិច្ចាគហ្សាកាត់”។ (អាល់ពូខរី:៨ មូស្លីម:១៦)

## មាតិកានៃជំពូក

គោលបំណងនៃហ្សាកាត់ (ការបរិច្ចាគទ្រព្យ)

ទ្រព្យសម្បត្តិដែលត្រូវបរិច្ចាគហ្សាកាត់

- មាស និងប្រាក់
- ទ្រព្យសម្បត្តិ និងលំហូរសាច់ប្រាក់
- ទំនិញពាណិជ្ជកម្ម
- ដំណាំដែលដុះចេញពីដី
- សត្វពាហនៈ

តើត្រូវបរិច្ចាគហ្សាកាត់ទៅឲ្យក្រុមណាខ្លះ?

# ការបរិច្ចាគហ្សាកាត់

ហ្សាកាត់ គឺជាចំណែកដ៏តិចមួយអំពីទ្រព្យសម្បត្តិដែលអល់ឡោះ បានដាក់ជាកាតព្វកិច្ចលើជនមូស្លីម ដោយអ្នកមានត្រូវបរិច្ចាគដើម្បីជួយសម្រួលការលំបាក និងតម្រូវការរបស់អ្នកក្រក្រី និងគោលបំណងផ្សេងៗទៀត។

## គោលបំណងនៃការបរិច្ចាគហ្សាកាត់

អល់ឡោះបានដាក់កាតព្វកិច្ចហ្សាកាត់មកលើជនមូស្លីមក្នុងគោលបំណងធំៗជាច្រើន ដោយយើងសូមលើកមកបញ្ជាក់ខ្លះៗដូចខាងក្រោម ៖

1 ជាការពិត ការស្រឡាញ់ទ្រព្យសម្បត្តិ វាជាធម្មជាតិរបស់មនុស្សលោក គឺមនុស្សតែងព្យាយាមគ្រប់វិធីដើម្បីប្រមូលទ្រព្យសម្បត្តិ និងថែរក្សាវាទុក។ ហេតុដូចនេះហើយទើបច្បាប់បានដាក់កាតព្វកិច្ចឲ្យធ្វើការបរិច្ចាគហ្សាកាត់ ដើម្បីជាការសម្អាតខ្លួនប្រាណអំពីភាពកខ្វក់នៃភាពកំណាញ់ និងភាពលោភលន់ ហើយវាក៏ជាការលុបបំបាត់ការស្រឡាញ់ និងវិលវល់ក្នុងរឿងលោកិយផងដែរ។ អល់ឡោះបានមានបន្ទូលថា "ចូរអ្នកយកផ្នែកខ្លះនៃទ្រព្យសម្បត្តិរបស់ពួកគេ វាជាការបរិច្ចាគ (ហ្សាកាត់) ដែលវាជួយសម្អាតពួកគេ និងធ្វើឲ្យពួកគេបានប្រសើរ"។(គម្ពីរគួរអាន ៩:១០៣)

2 ការបរិច្ចាគហ្សាកាត់អាចសម្រេចបាននូវចំណុចគ្រឹះនៃទំនាក់ទំនង និងភាពស្និទ្ធស្នាល ព្រោះថាមនុស្សតែងមានការគោរពស្រឡាញ់ចំពោះអ្នកដែលបានធ្វើអំពើល្អមកចំពោះខ្លួន។ ហេតុនេះហើយទើបសមាជិកនៃសហគមន៍ឥស្លាមរស់នៅប្រកបដោយសេចក្តីស្រឡាញ់រាប់អាន និងសាមគ្គីភាពគ្នា ហាក់បីដូចជាសំណង់ដ៏រឹងមាំដែលផ្សាភ្ជាប់គ្នាយ៉ាងស្អិតរមួត ហើយមិនសូវកើតមានករណីចោរកម្ម ឬក៏ឆក់ប្លន់អ្វីទេ។

3 ភាពជាខ្ញុំបម្រើអល់ឡោះ និងការគោរពដ៏ពិតប្រាកដទៅចំពោះទ្រង់មានលក្ខណៈពេញលេញទៅបានអាស្រ័យការប្រគល់ខ្លួនយ៉ាងពេញលក្ខណៈទៅចំពោះអល់ឡោះដែលជាម្ចាស់នៃពិភពទាំងឡាយ ពោលគឺនៅពេលដែលអ្នកមានបរិច្ចាគទ្រព្យសម្បត្តិរបស់ពួកគេ នោះវាគឺជាការអនុវត្តនូវច្បាប់របស់អល់ឡោះ និងជាការបំពេញនូវការបង្គាប់ប្រើរបស់ទ្រង់។ ការបរិច្ចាគហ្សាកាត់នេះក៏ជាការថ្លែងអំណរគុណទៅចំពោះម្ចាស់ដែលបានប្រទានលាភសក្ការៈទាំងនេះផងដែរ។ អល់ឡោះបានមានបន្ទូលថាៈ "ប្រសិនបើពួកអ្នកថ្លែងអំណរគុណ យើងនឹងបន្ថែមដល់ពួកអ្នកទៀត"។ (គម្ពីរគួរអាន ១៤:៧)

4 តាមរយៈការបរិច្ចាគហ្សាកាត់ វានឹងផ្តល់កាន់តែច្បាស់នូវអត្ថន័យនៃការគាំពារសង្គមនិងរក្សាលំនឹងបានមួយកម្រិតក្នុងផ្នែកខ្លះនៃសង្គម ពោលគឺដោយការបរិច្ចាគហ្សាកាត់នេះទៅដល់អ្នកដែលត្រូវទទួល ដោយវាមិនធ្វើឱ្យទ្រព្យសម្បត្តិទាំងឡាយស្ថិតនៅតែក្នុងដៃមនុស្សមួយក្រុមណាមួយនៅក្នុងសង្គមនោះទេ។ អល់ឡោះបានមានបន្ទូលថាៈ "ដើម្បីកុំឱ្យទ្រព្យសម្បត្តិនោះស្ថិតក្នុងកណ្តាប់ដៃអ្នកមានណាម្នាក់ក្នុងចំណោមពួកអ្នក"។ (គម្ពីរគួរអាន ៥៩:៧)



>ការស្រឡាញ់ទ្រព្យសម្បត្តិ គឺជាលក្ខណៈធម្មជាតិនៅក្នុងចិត្តមនុស្ស ហើយប្រាកដណាស់ឥស្លាមបានអំពាវនាវឲ្យសម្អាតចិត្តនិងកុំឲ្យជំពាក់ចិត្តនឹងទ្រព្យសម្បត្តិ។

## តើទ្រព្យសម្បត្តិអ្វីដែលចាំបាច់ត្រូវបរិច្ចាគហ្សាកាត់?

ទ្រព្យសម្បត្តិដែលយើងមានសម្រាប់បម្រើឲ្យការរស់នៅមិនតម្រូវឲ្យបរិច្ចាគហ្សាកាត់ទេ ដូចជាផ្ទះជាដើម បើទោះជាវាមានតម្លៃថ្លៃយ៉ាងណាក៏ដោយ និងរថយន្តសម្រាប់ប្រើប្រាស់ បើទោះជាវាទំនើបហើយថ្លៃបែបណាក្តី។ក៏ដូចគ្នានេះដែរ សំលៀកបំពាក់និងគ្រឿងឧបភោគបរិភោគក៏មិនតម្រូវឲ្យបរិច្ចាគហ្សាកាត់ដែរ។

ជាការពិតអល់ឡោះបានដាក់កាតព្វកិច្ចបរិច្ចាគហ្សាកាត់ តែទៅលើប្រភេទទ្រព្យសម្បត្តិដែលមិនសម្រាប់ប្រើប្រាស់ ហើយវាមានការរីកលូតលាស់ ដូចជា ៖



1 មាស និងប្រាក់ ដែលមិនសម្រាប់ប្រើ និងគ្រឿងអលង្ការ

ទ្រព្យទាំងនេះនឹងមិនត្រូវបរិច្ចាគហ្សាកាត់នោះទេ លុះត្រាតែវាគ្រប់ចំនួនកំណត់ ( النِّصَاب ) ហើយត្រូវបានរក្សាទុករយៈពេលមួយឆ្នាំពេញ( ឆ្នាំចន្ទគតិ ) ដែលមានចំនួន ៣៥៤ ថ្ងៃ។ ចំនួននៃការកំណត់ត្រូវបរិច្ចាគហ្សាកាត់ក្នុងមាសនិងប្រាក់គឺ មាសស្មើនឹង ៨៥ ក្រាម រីឯប្រាក់ គឺស្មើនឹង ៥៩៥ ក្រាម។

ដូចនេះប្រសិនជនមូស្លីមណាម្នាក់គាត់មានគ្រប់ចំនួនដូចបានបញ្ជាក់ខាងលើ ហើយវាមានរយៈពេលមួយឆ្នាំ គឺគាត់ត្រូវបរិច្ចាគហ្សាកាត់ចំនួន ២.៥%។



2 ទ្រព្យសម្បត្តិ និងលំហូរសាច់ប្រាក់ ដែលមានជារូបិយប័ណ្ណខុសគ្នា បើទោះជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ផ្ទាល់ ឬក៏ជាសាច់ប្រាក់នៅក្នុងធនាគារក្តី

ការបរិច្ចាគហ្សាកាត់របស់វា គឺយោងទៅតាមចំនួនទ្រព្យសម្បត្តិទាំងនោះគិតជាតម្លៃមាស។ ដូចនេះ ប្រសិនបើវាមានចំនួនស្មើនឹងចំនួនកំណត់ដែលត្រូវបរិច្ចាគហ្សាកាត់របស់មាស ឬច្រើនជាងដែលមានទំងន់ប្រហែល៨៥ក្រាម នៅពេលវេលាដែលត្រូវបរិច្ចាគហ្សាកាត់ ហើយវាមានរយៈពេលមួយឆ្នាំស្ថិតនៅជាកម្មសិទ្ធិរបស់គាត់ គឺគាត់ត្រូវបរិច្ចាគហ្សាកាត់ចំនួន ២.៥%។

ឧទាហរណ៍ៈ តម្លៃមាសមានការប្រែប្រួល បើឧបមាថាតម្លៃមាសក្នុងមួយក្រាមនៅពេលត្រូវចេញហ្សាកាត់គឺស្មើនឹង២៥ដុល្លារ។ ដូចនេះចំនួនកំណត់ដែលត្រូវបរិច្ចាគហ្សាកាត់គឺដូចខាងក្រោម៖

២៥( តម្លៃមាសក្នុងមួយក្រាមដែលអាចមានការប្រែប្រួល ) x ៨៥ ( ចំនួនក្រាមដែលច្បាប់កំណត់ត្រូវបរិច្ចាគហ្សាកាត់គឺវាថេរ ) = ២១២៥ ដុល្លា
វាជាចំនួនកំណត់ដែលត្រូវបរិច្ចាគហ្សាកាត់នៃទ្រព្យសម្បត្តិ



3 ទំនិញពាណិជ្ជកម្ម

គឺសំដៅលើទ្រព្យសម្បត្តិ ឬសម្ភារដែលសម្រាប់ធ្វើពាណិជ្ជកម្ម ដូចជា អចលនទ្រព្យ អាគារ សំណង់ ឬទំនិញ ដូចជាគ្រឿងឧបភោគបរិភោគជាដើម។

របៀបបរិច្ចាគហ្សាកាត់: គាត់ត្រូវវាយតម្លៃសម្ភារ ឬទ្រព្យសម្បត្តិដែលគាត់ទុកសម្រាប់ធ្វើពាណិជ្ជកម្មទាំងអស់នៅពេលដែលវាមានរយៈពេលមួយឆ្នាំ ហើយការវាយតម្លៃគឺធ្វើទៅតាមតម្លៃទីផ្សារពេលដែលគាត់ចង់បរិច្ចាគហ្សាកាត់។ ប្រសិនបើចំនួនរបស់វាគ្រប់បរិមាណទ្រព្យសម្បត្តិដែលត្រូវបរិច្ចាគហ្សាកាត់ គឺត្រូវបរិច្ចាគហ្សាកាតចំនួន២.៥%។



4 ដំណាំដែលដុះចេញពីដីនៃគ្រាប់ធញ្ញជាតិនិងដំណាំផ្លែឈើ

អល់ឡោះបានមានបន្ទូលថា: “ឱបណ្ដាអ្នកមានជំនឿទាំងឡាយ! ចូរពួកអ្នកបរិច្ចាគពីរបស់ល្អៗនូវអ្វីដែលពួកអ្នកបានខំស្វែងរក និងអ្វីដែលយើងបានបញ្ចេញពីដីឲ្យពួកអ្នក”។ (គម្ពីរគួរអាន ២:២៦៧)

កាតព្វកិច្ចនេះត្រូវបានកំណត់តែទៅលើដំណាំមួយចំនួនតែប៉ុណ្ណោះ គឺមិនមែនគ្រប់ដំណាំទាំងអស់នោះទេ ហើយត្រូវមានបរិមាណគ្រប់ចំនួនដែលច្បាប់បានកំណត់ថា ត្រូវបរិច្ចាគហ្សាកាត់ទៀតផង។

ច្បាប់ក៏បានធ្វើការបែងចែកផងដែរ រវាងដំណាំដែលស្រោចស្រពដោយទឹកភ្លៀង ទឹកទន្លេ និងដំណាំដែលស្រោចស្រពដោយការចំណាយក្នុងការស្រោចស្រព។ ចំពោះចំនួនចាំបាច់ដែលត្រូវបរិច្ចាគហ្សាកាត់ គឺត្រូវពិនិត្យមើលលើស្ថានភាពរបស់មនុស្ស។



5 ទ្រព្យសម្បត្តិដែលជាសត្វពាហនៈ ដូចជាសត្វគោ សត្វអូដ្ឋ និងសត្វពពែតែប៉ុណ្ណោះដែលគេត្រូវបរិច្ចាគហ្សាកាត់ ប្រសិនបើសត្វទាំងនោះមិនត្រូវបានចំណាយក្នុងការផ្ដល់ចំណីឲ្យវា។

ប្រសិនបើម្ចាស់ជាអ្នកផ្គត់ផ្គង់ចំណាយក្នុងការផ្ដល់ចំណីអាហារឲ្យវាពេញមួយឆ្នាំ ឬស្ទើរតែពេញមួយឆ្នាំនោះ គឺមិនត្រូវបរិច្ចាគហ្សាកាត់ទេ។

ចំនួនកំណត់ដែលត្រូវបរិច្ចាគហ្សាកាត់ និងបរិមាណដែលត្រូវចេញហ្សាកាត់នោះ គឺមានបរិយាយលម្អិតនៅក្នុងសៀវភៅហ្វីកោះ(សៀវភៅសិក្សាក្បួនច្បាប់ឥស្លាម)។

## តើហ្សាកាត់ត្រូវបរិច្ចាគទៅឲ្យក្រុមណាខ្លះ?

សាសនាឥស្លាមបានកំណត់យ៉ាងច្បាស់នូវអ្នកដែលមានសិទ្ធទទួលហ្សាកាត់។ ជនមូស្លីមត្រូវបានអនុញ្ញាតឲ្យបរិច្ចាគហ្សាកាត់ទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់ក្នុងចំណោមអ្នកដែលច្បាប់បានកំណត់ថាអាចទទួលហ្សាកាត់បាន ឬក៏បរិច្ចាគឲ្យទៅមូលនិធិ និងអង្គការសប្បុរសធម៌នានា ដែលមានភារៈកិច្ចបែងចែកវាទៅដល់អ្នកដែលត្រូវទទួល ហើយជាការប្រសើរនោះគឺ ត្រូវបែងចែកនៅក្នុងប្រទេសរបស់ខ្លួន។

អ្នកដែលមានសិទ្ធិទទួលហ្សាកាត់មានដូចខាងក្រោម ៖

1 ទុគ៌តជន និងអ្នកទីទាល់ក្រ: គឺអ្នកដែលគ្មានលទ្ធភាពក្នុងការផ្គត់ផ្គង់តម្រូវការរស់នៅប្រចាំថ្ងៃរបស់ពួកគាត់បាន។

2 អ្នកធ្វើការក្នុងការប្រមូលហ្សាកាត់ និងធ្វើការបែងចែកវា។

3 អ្នកបម្រើដាច់ថ្លៃដែលសុំលោះខ្លួនពីចៅហ្វាយរបស់គាត់: ក្នុងករណីនេះ គឺត្រូវជួយគាត់ដោយផ្តល់ទ្រព្យហ្សាកាត់ដល់គាត់ដើម្បីគាត់បានក្លាយជាអ្នកដែលមានសេរីភាពដូចគេឯង។

4 អ្នកដែលជំពាក់បំណុលគេ ហើយមិនអាចសងរួច: បើទោះជាបំណុលនោះសម្រាប់បម្រើប្រយោជន៍សាធារណៈ និងជាអំពើល្អជួយដល់មនុស្សផងទាំងឡាយ ឬ ជាប្រយោជន៍ផ្ទាល់ខ្លួនសម្រាប់បុគ្គលគាត់តែឯងក្តី។

5 អ្នកតស៊ូក្នុងផ្លូវអល់ឡោះ: គឺជាអ្នកដែលធ្វើការតស៊ូដើម្បីការពារសាសនា និងប្រទេសជាតិរបស់ពួកគេ ហើយគ្រប់ការងារដែលជាការផ្សព្វផ្សាយសាសនាឥស្លាម។

6 អ្នកមូអាល់ឡាហ្វ: គឺជាអ្នកដែលទើបនឹងចូលឥស្លាមថ្មី ឬអ្នកមិនមែនឥស្លាមដែលគេសង្ឃឹមថាគាត់នឹងចូលឥស្លាម។ ក្រុមនេះមិនមែនមនុស្សគ្រប់គ្នាអាចឲ្យបាននោះទេ គឺត្រូវបានផ្តល់ឲ្យពីសំណាក់ថ្នាក់ដឹកនាំ ឬមូលនិធិសប្បុរសធម៌ដែលអាចកំណត់ប្រយោជន៍ក្នុងរឿងនេះ។ វាក៏ចូលក្នុងចំណុចនេះផងដែរ។

7 អ្នកដំណើរដាច់ស្បៀង: គឺជាអ្នកដំណើរដែលដាច់ស្បៀងខណៈពេលកំពុងធ្វើដំណើរ ទោះបីជាគាត់ជាអ្នកមានទ្រព្យសម្បត្តិច្រើននៅស្រុករបស់គាត់ក្តី។ អល់ឡោះបានមានបន្ទូលថា: "តាមពិត ការបរិច្ចាគហ្សាកាត់នោះ គឺសម្រាប់តែអ្នកក្រខ្សត់ អ្នកក្រីក្រ អ្នកប្រមូលហ្សាកាត់ អ្នកដែលទើបតែចូលសាសនាឥស្លាម អ្នកដែលចង់រំដោះខ្លួនពីទាសករគេ អ្នកជំពាក់បំណុលគេ អ្នកដែលតស៊ូក្នុងមាគ៌ាអល់ឡោះ និងអ្នកដែលធ្វើដំណើរដាច់ស្បៀងប៉ុណ្ណោះ"។ (គម្ពីរគួរអាន៩:៦០)



> ទុគ៌តជន គឺជាអ្នកដែលគ្មានអ្វីដើម្បីផ្គត់ផ្គង់ និងបំពេញសេចក្តីត្រូវការជាមូលដ្ឋានរបស់គាត់បានគ្រប់គ្រាន់។



# ការធ្វើធម្មយាត្រាហាជ្ជីរបស់អ្នក



# 6

ការធ្វើធម្មយាត្រាហាជ្ជីនៅទីក្រុងម៉ាក្កះ គឺជាគោលគ្រឹះទី៥ក្នុងចំណោមគោលគ្រឹះទាំងប្រាំនៃសាសនាឥស្លាម។ វាជាការគោរពសក្ការៈមួយដែលរួមបញ្ចូលនៅក្នុងនោះទាំងការគោរពសក្ការៈដោយរាងកាយ ចិត្ត និងទ្រព្យសម្បត្តិ។ ចំពោះអ្នកដែលមានលទ្ធភាពផ្នែករាងកាយ និងទ្រព្យសម្បត្តិ ចាំបាច់ត្រូវប្រតិបត្តិវាឲ្យបានមួយដងក្នុងមួយឆាកជីវិត។ អល់ឡោះបានមានបន្ទូលថា "អល់ឡោះបានដាក់កាតព្វកិច្ចលើមនុស្សលោកឱ្យធ្វើធម្មយាត្រាហាជ្ជីនៅផ្ទះរបស់អល់ឡោះ(ម៉ាក្កះ) ចំពោះអ្នកដែលមានលទ្ធភាពទៅដល់។ ហើយបើអ្នកណាបានបដិសេធ ពិតណាស់អល់ឡោះមិនត្រូវការអ្វីមួយពីពិភពទាំងអស់ឡើយ"។ (គម្ពីរគួរអាន ៣:៩៧)

## មាតិកាជំពូក


ឧត្តមភាពនៃទីក្រុងម៉ាក្កះ និងម៉ាស្ជិត អាល់ហារ៉ម

អត្ថន័យនៃការធ្វើធម្មយាត្រាហាជ្ជី

ស្ថានភាពជនមូស្លីមដែលមានលទ្ធភាពធ្វើធម្មយាត្រាហាជ្ជី

លក្ខខណ្ឌមានម៉ះរិម(អ្នកដែលគេមិនអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន)សម្រាប់ស្ត្រីទៅធ្វើធម្មយាត្រាហាជ្ជី

ឧត្តមភាពនៃការធ្វើធម្មយាត្រាហាជ្ជី

គោលបំណងនៃការធ្វើធម្មយាត្រាហាជ្ជី

ការធ្វើអ៊ុំរ៉ោះ

ថ្ងៃបុណ្យអាដហា(ថ្ងៃរ៉យ៉ាហាជ្ជី)ដ៏ពិសិដ្ឋ

- តើច្បាប់ឥស្លាមបង្គាប់ប្រើអ្វីខ្លះក្នុងថ្ងៃបុណ្យអាដហា?
- លក្ខខណ្ឌសត្វដែលត្រូវសម្លេះ
- តើត្រូវធ្វើដូចម្តេចចំពោះសត្វដែលសម្លេះ(គួរហ្គាន)?

ការទស្សនកិច្ចទីក្រុងម៉ាទីណះ អាន់ណាហ្គាវីយ៉ះ

# ការធ្វើដំណើរទៅកាន់ម៉ាក្កាហាជ្ជី

## ឧត្តមភាពនៃទីក្រុងម៉ាក្កះ និងម៉ាស្ជិត អាល់ហារ៉ម

ម៉ាស្ជិត អាល់ហារ៉ម មានទីតាំងស្ថិតនៅក្នុងទីក្រុងម៉ាក្កះភាគខាងលិចនៃឧបទ្វីបអារ៉ាប់ ហើយវាមានឧត្តមភាពជាច្រើននៅក្នុងសាសនាឥស្លាម ដែលមានដូចជា ៖

**1** មានកាក់ហ្ពះដ៏ពិសិដ្ឋនៅក្នុងវា

កាក់ហ្ពះគឺជាសំណង់មួយដែលមានរាងបួនជ្រុងនិងរាងគូប ដែលស្ថិតនៅចំណុចកណ្តាលម៉ាស្ជិតអាល់ហារ៉មនៃទីក្រុងម៉ាក្កះ។ វាគឺជាគិបឡាត់(ទិស)ដែលជនមូស្លីមតម្រង់មុខទៅរកនៅពេលពួកគេប្រតិបត្តិសឡាត និងការគោរពសក្ការៈមួយចំនួនទៀតដែលអល់ឡោះបានបញ្ជារប្រើ។ ពិតប្រាកដណាស់ ព្យាការីអ៊ីព្រហ៊ីម(អាប្រាហាម) និងកូនរបស់គាត់ព្យាការីអ៊ីស្មាអែលបានកសាងវាឡើងដោយការបញ្ជារប្រើពីអល់ឡោះ។ បន្ទាប់មកក៏មានការកសាងសារជាថ្មីជាច្រើនលើក។

អល់ឡោះបានមានបន្ទូលថាៈ “ហើយ(ចូរចងចាំ)នៅពេលដែលអ៊ីព្រហ៊ីម និងអ៊ីស្មាអែលបានតំឡើងគ្រឹះកាក់ហ្ពះ(ដោយបួងសួងសុំថា) ឱម្ចាស់របស់ពួកយើងខ្ញុំ! សូមទ្រង់មេត្តាទទួលយក(អំពើល្អនិងការបួងសួងសុំ)ពីយើងខ្ញុំផង។ ពិតប្រាកដណាស់ ទ្រង់មហាឮមហាដឹង”។ (គម្ពីរគួរអាន ២:១២៧)

ពិតណាស់ ព្យាការីមូហាំម៉ាត់បានចូលរួមជាមួយនឹងកុលសម្ព័ន្ធនានានៃទីក្រុងម៉ាក្កះក្នុងការដាក់ថ្មខ្មៅនៅកន្លែងដើមរបស់វាវិញនៅពេលដែលគេបានកសាងវាសារជាថ្មី។

**2** ពិតណាស់ វាជាម៉ាស្ជិតដំបូងគេបង្អស់នៅលើផែនដីនេះ

អាពូ ហ៊្សែរ បានសួរអ្នកនាំសារថា "ឱអ្នកនាំសារ! តើម៉ាស្ជិតមួយណាដែលមាននៅលើផែនដីនេះដំបូងគេបង្អស់? លោកបានឆ្លើយថា "គឺម៉ាស្ជិត អាល់ហារ៉ម"។ គាត់បាននិយាយទៀតថាៈ ខ្ញុំបានសួរទៀតថា “បន្ទាប់មក តើម៉ាស្ជិទណា”? លោកបានឆ្លើយថា "គឺម៉ាស្ជិតអឹកស៏(នៅក្រុងយេរូសាឡឹម)"។ ខ្ញុំក៏សួរទៀតថាៈ "រយៈពេលរវាងវាទាំងពីរប៉ុន្មានឆ្នាំដែរ" ? លោកបានឆ្លើយថា “៤០ឆ្នាំ។ បន្ទាប់មកកន្លែងណាក៏ដោយឱ្យតែដល់ពេលសឡាត ចូរអ្នកសឡាតចុះ ពិតណាស់ផលបុណ្យនឹងមាននៅក្នុងវា”។ (អាល់ពូខរីៈ៣១៨៦ មូស្លីមៈ៥២០)

**3** ផលបុណ្យនៃសឡាតកើនឡើងនៅក្នុងវា

ពិតណាស់អ្នកនាំសារបានមានប្រសាសន៍ថា “សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះ(ម៉ាស្ជិតម៉ាទីណះ)ម្តង គឺល្អប្រសើរជាងការសឡាតនៅម៉ាស្ជិតផ្សេងទៀតចំនួន១០០០សឡាតលើកលែងតែម៉ាស្ជិត អាល់ហារ៉ម ហើយសឡាតនៅម៉ាស្ជិត អាល់ហារ៉ម ម្តង គឺប្រសើរជាងការសឡាតនៅម៉ាស្ជិតផ្សេងទៀតចំនួន១០០ពាន់សឡាត”។ (អ៊ិពនូម៉ាហ្ជះៈ១៤០៦ អះម៉ាត់ ១៤៦៩៤)

**4** ពិតណាស់ វាជាទឹកដីដែលអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់បានហាមឃាត់

អល់ឡោះបានមានបន្ទូលថា “(ឱមូហាំម៉ាត់ ចូរអ្នកពោលទៅកាន់មនុស្សលោកថា) តាមពិតខ្ញុំត្រូវបានគេបង្គាប់ឱ្យគោរពសក្ការៈចំពោះម្ចាស់របស់ទឹកដី(ម៉ាក្កះ)នេះ ដែលទ្រង់បានហាមឃាត់នៅក្នុងនោះ។ ហើយអ្វីៗទាំងអស់ជាកម្មសិទ្ធិរបស់ទ្រង់។ ហើយខ្ញុំត្រូវបានគេ

បង្គាប់ឱ្យស្ថិតនៅក្នុងចំណោមអ្នកមូស្លីម"។ (គម្ពីរគួរអាន ២៧:៩១)
ម៉ាក្កះត្រូវបានអល់ឡោះហាមឃាត់លើមនុស្សមិនឱ្យបង្ហូរឈាមនៅក្នុងវា ឬប្រព្រឹត្តអំពើអយុត្តិធម៌ទៅលើនរណាម្នាក់ ឬប្រម៉ាញ់សត្វនៅក្នុងវា ឬកាត់អ្វីម្យ៉ាងពីដើមឈើ និងស្មៅនៅក្នុងវាឡើយ។
អ្នកនាំសារបានមានប្រសាសន៍ថា "ពិតប្រាកដណាស់ ម៉ាក្កះគឺអល់ឡោះជាអ្នកហាមឃាត់ មិនមែនមនុស្សជាអ្នកហាមឃាត់នោះទេ។ មិនអនុញ្ញាតឡើយចំពោះបុគ្គលណាម្នាក់ដែលមានជំនឿចំពោះអល់ឡោះ នឹងជឿចំពោះថ្ងៃបរលោក បង្ហូរឈាមនៅក្នុងវា ហើយក៏មិនឱ្យកាប់ដើមឈើនៅក្នុងវាដែរ"។ (អាល់ពូខរីៈ១០៤ មូស្លីមៈ១៣៥៤)

5 វាជាទឹកដីដែលអល់ឡោះ និងព្យាការីស្រឡាញ់ខ្លាំងបំផុត

មានមិត្តភក្តិរបស់ព្យាការីម្នាក់បាននិយាយថាៈ ខ្ញុំបានឃើញអ្នកនាំសារនៅលើសត្វអូដ្ឋរបស់គាត់ស្ថិតនៅតំបន់អាល់ហ៊ូហ្សរ៉ោះ(វាជាតំបន់មួយនៅម៉ាក្កះ) លោកបានមានប្រសាសន៍ថា "ខ្ញុំស្បថនឹងអល់ឡោះ! ពិតប្រាកដណាស់ អ្នកគឺជាទឹកដីរបស់អល់ឡោះដែលល្អប្រសើរ ហើយជាទឹកដីរបស់អល់ឡោះដែលអល់ឡោះស្រឡាញ់ជាងគេ។ ប្រសិនបើខ្ញុំមិនត្រូវបានគេឱ្យបង្ខំឲ្យចេញពីអ្នកទេនោះ ខ្ញុំនឹងមិនចាកចេញពីអ្នកជាដាច់ខាត"។ (អាត់តៀរមីហ្ស៊ីៈ៣៩២៥ អាន់ណាសាអ៊ីក្នុងគីតាបគុបរ៉ៈ៤២៥២)

6 អល់ឡោះបានដាក់កាតព្វកិច្ចធ្វើធម្មយាត្រាហាជ្ជីនៅកាក់ហ្ពះ សម្រាប់អ្នកដែលមានលទ្ធភាពទៅដល់។ ពិតណាស់ ព្យាការីអ៊ីព្រហ៊ីមបានប្រកាសអំពាវនាវមនុស្សឱ្យមកធ្វើធម្មយាត្រាហាជ្ជី។ មនុស្សបាននាំគ្នាទៅកាន់ទីនោះពីគ្រប់ទីកន្លែង ហើយបណ្តាព្យាការីក៏បានធ្វើធម្មយាត្រាហាជ្ជីនៅក្នុងទីនោះដែរ ដូចដែលអ្នកនាំសារបានប្រាប់។ អល់ឡោះបានប្រាប់អំពីការបញ្ជារប្រើរបស់ទ្រង់ទៅលើព្យាការីអ៊ីព្រហ៊ីមដោយទ្រង់បានមានបន្ទូលថា "ហើយចូរអ្នកប្រកាសអំពាវនាវដល់មនុស្សអំពីការធ្វើហាជ្ជី។ ពួកគេនឹងមកកាន់អ្នក(តាមការអំពាវនាវ)ដោយថ្មើរជើង។ ដោយជិះសត្វអូដ្ឋដែលពួកគេនឹងមកពីគ្រប់ច្រកល្ហកដ៏សែនឆ្ងាយ"។ (គម្ពីរគួរអាន ២២:២៧)





> ការតវ៉ាហ្វ(ដើរប្រទក្សិណ)ជុំវិញកាក់ហ្ពះប្រាំពីរជុំ គឺជាគោលគ្រឹះ(រ៉ូកុន)មួយនៃគោលគ្រឹះហាជ្ជី និងអ៊ុមរ៉ោះ

## > អត្ថន័យនៃការធ្វើធម្មយាត្រាហាជ្ជី

ការធ្វើធម្មយាត្រាហាជ្ជី គឺជាគោលបំណងទៅកាន់គេហដ្ឋានរបស់អល់ឡោះ(កាក់ហ្ពះ)ដើម្បីបំពេញកិច្ចធម្មយាត្រា។ វានោះគឺជាកាយវិការ និងពាក្យសំដីដែលមានលំនាំពីព្យាការីមូហាំម៉ាត់ ដូចជា ការកានតំណមអៀហ្រ៉ម ការដើរតវ៉ាហ្វ(ដើរជុំវិញ)កាក់ហ្ពះប្រាំពីរជុំ ការដើរសាអ៊ី(ដើរទៅមក) ប្រាំពីរជុំរវាងភ្នំសហ្វា និងភ្នំម៉ារវ៉ះ ការស្ថិតនៅតំបន់អារ៉ហ្វះ ការចោលគោលនៅតំបន់មីណា និងផ្សេងៗទៀត។

ហើយវាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់មនុស្ស ដូចជាការប្រកាសអំពីឯកទេពនិមចំពោះអល់ឡោះតែមួយគត់ ហើយអ្នកធ្វើហាជ្ជីនឹងទទួលបានការអភ័យទោសយ៉ាងធំធេងពីអល់ឡោះ និងការស្គាល់គ្នារវាងអ្នកមូស្លីម ព្រមទាំងការសិក្សាពីក្បួនច្បាប់សាសនាឥស្លាម និងផ្សេងៗទៀត។

ពេលវេលាធ្វើហាជ្ជីៈ កាតព្វកិច្ចធ្វើធម្មយាត្រាហាជ្ជីគឺនៅចន្លោះរវាងថ្ងៃទី៨ និងថ្ងៃទី១៣ខែហ្ស៊ុលហាជ្ជះដែលវាគឺជាខែទី១២នៃប្រតិទិនឥស្លាម។

តើការធ្វើធម្មយាត្រាហាជ្ជីជាកាតព្វកិច្ចលើជនណាខ្លះ?

លក្ខខណ្ឌដែលចាំបាច់ត្រូវធ្វើហាជ្ជីនោះគឺ ជាជនមូស្លីម មូកាល់ឡាហ្វ និងមានលទ្ធភាព។ (មូកាល់ឡាហ្វ មានន័យថា មានប្រាជ្ញាស្មារតី គ្រប់អាយុ)។

មានលទ្ធភាព គឺមានន័យថា៖

អាចធ្វើដំណើរមកដល់ម៉ាស្ជិត អាល់ហារ៉ម(ក្រុងម៉ាក្កះ)តាមផ្លូវដែលត្រឹមត្រូវ និងស្របច្បាប់ ហើយអាចប្រតិបត្តិហាជ្ជីដោយមិនបង្ករការលំបាកធ្ងន់ធ្ងរ បន្ថែមលើការលំបាកក្នុងការធ្វើដំណើរធម្មតា ជាមួយនិងសុវត្ថិភាពលើរាងកាយ និងទ្រព្យសម្បត្តិ។ ហើយចាំបាច់ត្រូវឱ្យទ្រព្យដែលចំណាយក្នុងការធ្វើហាជ្ជីជាទ្រព្យដែលសល់បន្ទាប់ពីគាត់បានចំណាយលើតម្រូវការទូទៅ និងការចំណាយលើអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់គាត់។

# >ស្ថានភាពអ្នកម៉ូស្លីមដែលមានលទ្ធភាពធ្វើហាជ្ជី

1. មានលទ្ធភាពធ្វើហាជ្ជីដោយខ្លួនឯងផ្ទាល់: មានន័យថា រូបគេមានលទ្ធភាពមកដល់កាក់ហ្ពះ ដោយខ្លួនឯងដោយមិនបង្ករការលំបាកច្រើនហួសប្រមាណលើសពីធម្មតា ហើយមានទ្រព្យសម្បត្តិគ្រប់គ្រាន់។ ដូចនេះ ចាំបាច់លើរូបគេត្រូវប្រតិបត្តិកាតព្វកិច្ចហាជ្ជីដោយខ្លួនឯង។

2. មានលទ្ធភាពផ្តល់ដោយអ្នកដទៃ: គឺអ្នកដែលគ្មានលទ្ធភាពធ្វើហាជ្ជីដោយខ្លួនឯងដោយសារមានជំងឺ ឬចាស់ជរា ក៏ប៉ុន្តែគាត់មានអ្នកអាចធ្វើហាជ្ជីជំនួសឱ្យបាន ហើយគាត់មានលទ្ធភាពផ្តល់ប្រាក់ដល់គេ(ជួលគេ)ដើម្បីគេធ្វើហាជ្ជីឱ្យគាត់។ ក្នុងករណីនេះ គាត់ចាំបាច់ត្រូវផ្តល់ប្រាក់ដល់អ្នកដែលធ្វើហាជ្ជីឱ្យគាត់នោះ(ជួលគេឲ្យធ្វើហាជ្ជីឲ្យ)។

3. អ្នកដែលគ្មានលទ្ធភាពធ្វើហាជ្ជីដោយខ្លួនឯងផ្ទាល់ ហើយក៏គ្មានលទ្ធភាពឱ្យអ្នកដទៃធ្វើជំនួស: ក្នុងករណីនេះមិនចាំបាច់លើគាត់ត្រូវធ្វើហាជ្ជីឡើយ ដរាបណាគាត់មិនមានលទ្ធភាព។ ឧទាហរណ៍ដូចជា បុគ្គលដែលមិនមានទ្រព្យសម្បត្តិនៅសល់បន្ទាប់ពីគាត់បានចំណាយលើតម្រូវការទូទៅ និងការចំណាយលើក្រុមគ្រួសាររបស់គាត់ ដែលមិនគ្រប់គ្រាន់សម្រាប់គាត់ដើម្បីប្រតិបត្តិហាជ្ជី។

ហើយក៏មិនចាំបាច់លើគាត់ប្រមូលទ្រព្យសម្បត្តិដើម្បីឱ្យមានលទ្ធភាពធ្វើហាជ្ជីដែរ ក៏ប៉ុន្តែនៅពេលណាដែលគាត់មានលទ្ធភាព ចាំបាច់លើគាត់ត្រូវធ្វើហាជ្ជី។

តើអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ និងមានលទ្ធភាពខាងរាងកាយក្នុងការធ្វើហាជ្ជីដែរឬទេ?

- មាន → ចាំបាច់អ្នកត្រូវធ្វើហាជ្ជីដោយខ្លួនឯង។
- ទេ ↓

តើអ្នកមានទ្រព្យសម្បត្តិគ្រប់គ្រាន់ ក៏ប៉ុន្តែអ្នកមិនមានលទ្ធភាពខាងរាងកាយដើម្បីធ្វើហាជ្ជីដោយមូលហេតុអ្នកមានជំងឺដែលគ្មានសង្ឃឹមនិងអាចជាសះស្បើយ ឬ អ្នកមានវ័យចាស់ជរាមែនទេ?

- បាទមាន → ចាំបាច់លើអ្នកផ្តល់ទ្រព្យសម្បត្តិឱ្យអ្នកដែលធ្វើហាជ្ជីជំនួសអ្នក។
- ទេ ↓

ប្រសិនបើអ្នកមិនមានទ្រព្យសម្បត្តិគ្រប់គ្រាន់សម្រាប់ធ្វើហាជ្ជីដែលសល់បន្ទាប់ពីបានចំណាយលើតម្រូវការទូទៅ និងការចំណាយលើក្រុមគ្រួសាររបស់អ្នកទេនោះ អ្នកមិនមានកាតព្វកិច្ចត្រូវធ្វើហាជ្ជីនោះទេ ហើយក៏មិនចាំបាច់លើអ្នកត្រូវប្រមូលទ្រព្យដើម្បីធ្វើហាជ្ជីដែរ។

## > លក្ខខណ្ឌមុាំរមសម្រាប់ស្ត្រីដែលធ្វើធម្មយាត្រាហាជ្ជី

គេដាក់លក្ខខណ្ឌលើស្ត្រីក្នុងការប្រតិបត្តិកាតព្វកិច្ចហាជ្ជីគឺត្រូវមានម៉ះរ៉ម(ប្តី ឬសាច់ញាតិដែលមិនអាចរៀបការជាមួយគ្នាបាន)។ ដូចនេះ មិនមែនជាកាតព្វកិច្ចលើស្ត្រីក្នុងការធ្វើហាជ្ជីនោះទេ លុះត្រាតែមាននរណាម្នាក់ក្នុងចំណោមម៉ះរ៉មគាត់អមដំណើរទៅធ្វើហាជ្ជីជាមួយគាត់ដែរ។ អ្នកដែលជាម៉ះរ៉មស្ត្រីនោះមានដូចជា ប្តីរបស់គាត់ ឬអ្នកដែលគាត់មិនអាចរៀបការជាមួយបានជារៀងរហូតដូចជា ឪពុក ជីតា កូនប្រុស ចៅប្រុសបង្កើត បងប្អូនប្រុសបង្កើត ក្មួយប្រុសបង្កើត ឪពុកមាខាងឪពុក និងឪពុកមារខាងម្តាយ។ (សូមមើលទំព័រ ២០៨)

ប្រសិនបើស្ត្រីទៅធ្វើហាជ្ជីដោយគ្មានម៉ះរ៉មដោយមធ្យោបាយត្រឹមត្រូវនិងមានសុវត្ថិភាពលើខ្លួនរបស់នាងនោះ ការធ្វើហាជ្ជីរបស់គាត់ត្រឹមត្រូវ និងទទួលបានផលបុណ្យ។

## > ឧត្តមភាពនៃការធ្វើធម្មយាត្រាហាជ្ជី

មានសេចក្តីរាយការណ៍ជាច្រើនដែលទាក់ទងនឹងឧត្តមភាព និងប្រការល្អៗនៃការធ្វើធម្មយាត្រាហាជ្ជី ក្នុងនោះមានដូចជា ៖

1. ពិតណាស់ វាស្ថិតក្នុងចំណោមទង្វើដ៏ល្អប្រពៃបំផុត។ នៅពេលមានគេសួរអ្នកនាំសារថា "តើទង្វើណាដែលល្អជាងគេ"? លោកបានឆ្លើយថា “គឺការជឿចំពោះអល់ឡោះ និងអ្នកនាំសាររបស់ទ្រង់”។ គេបានសួរទៀតថា: "តើបន្ទាប់មកគឺអ្វី"? លោកបានឆ្លើយថា “គឺការតស៊ូក្នុងមាគ៌ារបស់អល់ឡោះ”។ គេក៏បានសួរទៀតថា "តើបន្ទាប់មកទៀត គឺអ្វី"? លោកបានឆ្លើយថា “គឺការធ្វើធម្មយាត្រាហាជ្ជីដែលត្រូវគេទទួលយក”។ (អាល់ពូខរី:១៤៤៧ និងមូស្លីម:៨៣)
2. ជារង្វាន់ដ៏អស្ចារ្យសម្រាប់ទទួលបានការលើកលែងទោស(ពីអល់ឡោះ)៖ អ្នកនាំសារបានមានប្រសាសន៍ថា “បុគ្គលណាធ្វើធម្មយាត្រាហាជ្ជី ដោយមិនបានធ្វើនូវប្រការទាក់ទងនឹងការរួមភេទ និងមិនបានប្រព្រឹត្តនូវបាបកម្ម គាត់នឹងត្រឡប់មកវិញ(ដោយគ្មានបាបកម្មជាប់ខ្លួន) ដូចជាថ្ងៃដែលម្តាយគាត់ប្រសូត្រគាត់មក”។ (អាល់ពូខរី:១៤៤៩ មូស្លីម:១៣៥០) មានន័យថា គាត់ត្រឡប់មកវិញដោយគ្មានបាបកម្មជាប់ខ្លួនដូចជាគាត់ទើបតែប្រសូត្រដូច្នោះដែរ។
3. ជាឱកាសដ៏ធំធេងបំផុតសម្រាប់ទទួលបានការដោះលែងពីឋាននរកៈ អ្នកនាំសារលោកបានមានប្រសាសន៍ថា “គ្មានថ្ងៃណាមួយដែលអល់ឡោះដោះលែងមនុស្សពីឋាននរកច្រើនជាងថ្ងៃអារ៉ហ្វះ (ថ្ងៃទី៩នៃខែហ្ស៊ុលហិជ្ជះ)ឡើយ”។ (មូស្លីម:១៣៤៨)
4. ពិតណាស់ ការតបស្នងចំពោះការធ្វើហាជ្ជីនោះ គឺឋានសួគ៌ៈ អ្នកនាំសារបានមានប្រសាសន៍ថា “ការធ្វើធម្មយាត្រាហាជ្ជីដែលគេទទួលយកនោះ គ្មានអ្វីតបស្នងចំពោះវាក្រៅពីឋានសួគ៌ឡើយ” ។ (អាល់ពូខរី:១៦៨៣ មូស្លីម:១៣៤៩)

រាល់គុណប្រយោជន៍ទាំងនេះ និងអ្វីៗផ្សេងទៀតដែលទទួលបានពីការធ្វើធម្មយាត្រាហាជ្ជីនោះ គឺសម្រាប់តែអ្នកដែលជឿជាក់ និងមានចិត្តបរិសុទ្ធ និងជម្រះរាល់ប្រការដែលមិនគួរគប្បីធ្វើ ហើយនិងអនុវត្តតាមគន្លងរបស់ព្យាការីមូហាំម៉ាត់ដ៏ត្រឹមត្រូវប៉ុណ្ណោះ។

## > គោលបំណងនៃការធ្វើធម្មយាត្រាហាជ្ជី

ការធ្វើធម្មយាត្រាហាជ្ជីគឺមានគោលបំណង និងគោលដៅដ៏ធំធេង។ ដូច្នេះហើយបានជាអល់ឡោះបានមានបន្ទូលបន្ទាប់ពីគាត់បានរៀបរាប់ពីប្រការដែលជាកាតព្វកិច្ចលើអ្នកធ្វើហាជ្ជីអំពីការសម្លេះសត្វជំនូន ដែលអ្នកធ្វើហាជ្ជីសម្លេះវាដើម្បីគោរពសក្ការៈទៅចំពោះអល់ឡោះនៅក្នុងថ្ងៃណាហើរ(ថ្ងៃទី១០នៃខែហ្ស៊ុលហ៊ិជ្ជះ) ដោយទ្រង់បានមានបន្ទូលថា “ សាច់ និងឈាមរបស់វា(សត្វជំនូន)ទាំងអស់មិនអាចទៅដល់អល់ឡោះឡើយ ក៏ប៉ុន្តែការកោតខ្លាច(អល់ឡោះ)អំពីពួកអ្នកទេ ដែលអាចទៅដល់ទ្រង់នោះ”។ (គម្ពីរគួរអាន ២២:៣៧)។ អ្នកនាំសារបានមានប្រសាសន៍ថា “ការពិត គេប្រើឱ្យតវ៉ាហ្វ(ដើរជុំវិញ)កាក់ហ្ពះ និងដើរទៅមករវាងភ្នំសហ្វានិងភ្នំម៉ារវ៉ះ និងចោលគោល គឺដើម្បីបញ្ឈរការនឹករលឹកទៅចំពោះអល់ឡោះ”។ (អាពូហ្ទាវូទ:១៨៨៨)

ក្នុងចំណោមគោលដៅ និងគោលបំណងទាំងនេះមានដូចជា

### 1 បង្ហាញពីភាពឱនលំទោន និងភាពរាបសារទៅចំពោះអល់ឡោះ

ពីព្រោះថា អ្នកធ្វើហាជ្ជីបានបោះបង់ចោលទម្រង់នៃការស្រស់ស្អាតនិងការតុបតែង ដោយស្លៀកសម្លៀកបំពាក់អៀហរ៉ម ដើម្បីបង្ហាញពីភាពតោកយ៉ាករបស់គេទៅចំពោះម្ចាស់របស់គេ និងផ្តាច់ខ្លួនរបស់គេពីកិច្ចការលោកិយដែលនាំឱ្យរូបគេចាកឆ្ងាយពីចិត្តស្មោះត្រង់ទៅចំពោះម្ចាស់របស់គេ។ រូបគេបង្ហាញដូច្នោះ ដើម្បីទទួលបាននូវការអភ័យទោស និងការអាណិតស្រឡាញ់ពីម្ចាស់របស់ពួកគេ។ បន្ទាប់មក រូបគេស្ថិតនៅតំបន់អារ៉ហ្វះដោយភាពឱនលំទោន កោតសរសើរ និងថ្លែងអំណរគុណទៅចំពោះម្ចាស់របស់គេ នូវរាល់ឧបការៈគុណ និងការសណ្តោសប្រណីរបស់ទ្រង់ ព្រមទាំងសុំការអភ័យទោសនូវរាល់បាបកម្ម និងកំហុសឆ្គងរបស់គេ។

### 2 ថ្លែងអំណរគុណចំពោះឧបការៈគុណ

ការថ្លែងអំណរគុណក្នុងពេលប្រតិបត្តិកាតព្វកិច្ចហាជ្ជីមានពីរផ្នែក: ទីមួយ ថ្លែងអំណរគុណទៅលើការប្រទានទ្រព្យសម្បត្តិ និងទីពីរ ថ្លែងអំណរគុណលើសុវត្ថិភាពរាងកាយ ដែលទាំងពីរនេះ គឺជាការប្រោសប្រទានដ៏ធំធេងដែលមនុស្សទទួលបានលើលោកិយនេះ ជាពិសេសក្នុងពេលធ្វើហាជ្ជី គឺត្រូវថ្លែងអំណរគុណចំពោះឧបការៈគុណដ៏ធំធេងទាំងពីរនេះ ក្នុងខណៈពេលដែលមនុស្សខិតខំប្រឹងប្រែងនឹងខ្លួនរបស់គេ និងបរិច្ចាគទ្រពសម្បត្តិរបស់គេក្នុងការអនុវត្តតាម និងបញ្ជិតខ្លួនទៅចំពោះម្ចាស់របស់គេ។ ពិតណាស់ ការថ្លែងអំណរគុណចំពោះឧបការៈគុណ គឺជាកាតព្វកិច្ចដែលវិចារណ-ញ្ញាណទទួលស្គាល់ និងច្បាប់សាសនាបានដាក់ជាកាតព្វកិច្ច។



> ចាំបាច់លើអ្នកដែលចង់ធ្វើហាជ្ជីនិងអ៊ុំរ៉ោះ ត្រូវរៀនសូត្រអំពីច្បាប់ឥស្លាមដែលពាក់ព័ន្ធនឹងវា។

## 3 ការជួបជុំជនមូស្លីម

ជនមូស្លីមដែលរស់នៅបណ្ដាប្រទេសនានាជុំវិញពិភពលោកបានមកជួបជុំគ្នាក្នុងពេលធ្វើហាជ្ជី ហើយក៏បានស្គាល់គ្នាទៅវិញទៅមក និងបានបង្រួបបង្រួមចិត្តគ្នាទៅវិញទៅមក ហើយវាលុបបំបាត់ភាពខុសគ្នារវាងមនុស្ស ដូចជាភាពខុសគ្នារវាងអ្នកមានទ្រព្យសម្បត្តិ និងអ្នកក្រីក្រ ភេទ ពណ៌សម្បុរ ការនិយាយស្តី និងភាសា។ វាជាការប្រមូលអ្នកមូស្លីមក្នុងសន្និសីទដ៏អស្ចារ្យរបស់មនុស្សជាតិ ប្រមូលផ្ដុំពាក្យសំដីរបស់ពួកគេទៅលើអំពើល្អ និងការកោតខ្លាច និងលើការផ្ដែផ្ដាំគ្នាឱ្យប្រកាន់ខ្ជាប់នូវការពិត និងការផ្ដែផ្ដាំគ្នាឱ្យមានការអត់ធ្មត់។ វាជាគោលដៅដ៏ចម្បងដែលភ្ជាប់ទំនាក់ទំនងរវាងមូលហេតុនៃជីវិតទៅនឹងហេតុផលលើមេឃ។

## 4 រំលឹកអំពីថ្ងៃបរលោក

ធម្មយាត្រាហាជ្ជី គឺជាការរំលឹកដល់អ្នកមូស្លីមអំពីថ្ងៃបរលោក។ វារំលឹកដូចនេះ គឺនៅពេលដែលពួកគេបានបោះបង់សម្លៀកបំពាក់របស់ពួកគេ ហើយស្លៀកសម្លៀកបំពាក់អៀហរ៉ម និងស្ថិតនៅតំបន់អារ៉ហ្វះ ហើយបានឃើញមនុស្សជាច្រើន នៅក្នុងសម្លៀកបំពាក់តែមួយ ប្រៀបដូចជាសម្លៀកបំពាក់សាកសព។ នេះជាចំណុចមួយដែលរំឭកគេពីស្ថានភាពរបស់គេបន្ទាប់ពីគេស្លាប់ និងជម្រុញឱ្យពួកគេរៀបចំខ្លួនសម្រាប់វា និងខិតខំស្វែងរកផលបុណ្យមុនពេលជួបនឹងអល់ឡោះ។

## 5 បង្ហាញពីគោលជំនឿចំពោះអល់ឡោះតែមួយគត់ និងការគោរពសក្ការៈដោយពាក្យសំដី និងកាយវិការទៅចំពោះទ្រង់តែមួយគត់

អត្តសញ្ញាណរបស់អ្នកធ្វើធម្មយាត្រាហាជ្ជី គឺការសូត្រតាល់ពីយ៉ះ

(لبيك اللهم لبيك، لبيك لا شريك لك لبيك، إن الحمد والنعمة لك والملك، لا شريك لك)

( ឡាប់ពៃកល់ឡហ៊ុមម៉ាឡាប់ពៃក៍ ឡាប់ពៃកាឡើស្ហារីកាឡើកាឡាប់ពៃក៍ អ៊ិនណាល់ហាំទើ វ៉ាន់នៀកម៉ាតា ឡើការ៉ាល់មុលកា លើស្ហារីកាឡឹក )

ដូច្នេះហើយបានជាមិត្តភក្តិម្នាក់របស់ព្យាការីបានប្រាប់ពីរបៀបសូត្រតាលពីយ៉ះរបស់ព្យាការីថា "ចាប់ផ្ដើមនឹងគោលជំនឿ"។ (មូស្លីមៈ១២១៨)។ បង្ហាញពីគោលជំនឿឯកទេពនិយមដ៏ច្បាស់លាស់ក្នុងរាល់អត្តសញ្ញាណរបស់ហាជ្ជី កាយវិការវា និងពាក្យសម្ដី។



ការធ្វើបុណ្យហាជ្ជីរបស់អ្នក

# > ការធ្វើអ៊ុំរ៉ោះ

វាគឺជាការគោរពសក្ការៈចំពោះអល់ឡោះដោយការស្លៀកសំលៀកបំពាក់អៀហរ៉ម  ការតវ៉ាហ្វ (ដើរប្រទក្សិណ)ជុំវិញកាក់ហ្ពះប្រាំពីរជុំ និងដើរសាអុី(ដើរទៅដើរមក)រវាងភ្នំសហ្វា និងភ្នំម៉ារវ៉ះ ប្រាំពីរជុំ បន្ទាប់មកកោរសក់ ឬកាត់សក់។

ច្បាប់របស់វា: វាជាកាតព្វកិច្ចលើអ្នកដែលមានលទ្ធភាពមួយដងក្នុងមួយឆាកជីវិត ហើយគប្បីធ្វើវាច្រើនដង។

ពេលវេលារបស់វា: គេអាចប្រតិបត្តិវាមួយឆ្នាំពេញ ក៏ប៉ុន្តែនៅក្នុងខែរ៉ម៉ាហ្ទន ផលបុណ្យរបស់វាគឺទ្វេដង ដូចដែលអ្នកនាំសារលោកបានមានប្រសាសន៍ថា “ការធ្វើអ៊ុំរ៉ោះក្នុងខែរ៉ម៉ាហ្ទន ស្មើនឹងការធ្វើហាជ្ជី"។ (អាល់ពូខរី ១៧៦៤ មូស្លីម ១២៥៦)



> ចាំបាច់លើអ្នកដែលមានសមត្ថភាពក្នុងមួយជីវិតត្រូវធ្វើអ៊ុំរ៉ោះយ៉ាងតិចឲ្យបាន១ដង

# ថ្ងៃបុណ្យ អាល់អាជហា(ថ្ងៃរ៉យ៉ាហាជ្ជី)

វាជាបុណ្យទីពីរសម្រាប់ជនមូស្លីម ហើយគេប្រារព្ធវានៅក្នុងថ្ងៃទី១០នៃខែហ្ស៊ុលហិជ្ជះ(ខែទី១២នៃប្រតិទិនឥស្លាម)។ ហើយពិតណាស់ ចំពោះថ្ងៃនោះ គឺមានឧត្តមភាពជាច្រើនដូចជា ៖

1. វាស្ថិតក្នុងចំណោមថ្ងៃដែលល្អប្រសើរជាងគេក្នុងមួយឆ្នាំ: ពិតណាស់ បណ្ដាថ្ងៃដែលល្អជាងគេក្នុងមួយឆ្នាំគឺ១០ថ្ងៃដំបូងនៃខែហ្ស៊ុលហិជ្ជះ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “គ្មានថ្ងៃណាមួយដែលការសាងទង្វើកុសលនៅក្នុងថ្ងៃនោះអល់ឡោះស្រឡាញ់ជាងបណ្ដាថ្ងៃទាំងនេះទេ(១០ថ្ងៃខាងដើមនៃខែហ្ស៊ុលហិជ្ជះ)"។ ពួកគេបានសួរថា: "ឱអ្នកនាំសារ! តើសូម្បីតែការតស៊ូក្នុងផ្លូវអល់ឡោះក៏ដោយឬ"? លោកបានឆ្លើយថា “សូម្បីតែការតស៊ូក្នុងផ្លូវអល់ឡោះក៏ដោយ លើកលែងតែបុរសម្នាក់ចេញទៅដោយលះបង់ទាំងខ្លួនប្រាណនិងទ្រព្យសម្បត្តិរបស់គាត់ហើយគ្មានអ្វីត្រឡប់មកវិញ”។ (អាល់ពូខរី:៩២៦ អាត់តៀរមីហ្ស៊ី:៧៥៧)

2. ពិតណាស់វាជាថ្ងៃបុណ្យហាជ្ជីធំ: ហើយនៅក្នុងវានោះមានភារកិច្ចហាជ្ជីដ៏ថ្កុំថ្កើង ហើយសំខាន់ៗ និងខ្ពង់ខ្ពស់ ដូចជាការតវ៉ាហ្វជុំវិញកាក់ហ្ពះ សម្លេះសត្វជំនួន និងចោលគោលអាល់អាក៏ហ្ពះ(គោលធំជាងគេ)

## តើច្បាប់បង្គាប់ប្រើអ្វីខ្លះនៅក្នុងថ្ងៃបុណ្យអាល់អាជហា(ថ្ងៃរ៉យ៉ាហាជ្ជី)?

ច្បាប់បានកំណត់នៅក្នុងថ្ងៃបុណ្យអាល់អាជហា សម្រាប់អ្នកដែលមិនបានទៅធ្វើហាជ្ជីនោះ ដូចដែលបានកំណត់នៅក្នុងថ្ងៃបុណ្យស្រាយបួស(ថ្ងៃរ៉យ៉ាហ្វិត្រោះ)ដែរ លើកលែងតែកាតព្វកិច្ចបរិច្ចាគហ្សាកាត់ហ្វិត្រោះ ដែលសម្រាប់តែបុណ្យរ៉យ៉ាស្រាយបួសប៉ុណ្ណោះ។ (សូមមើលទំព័រ ១៤៦)

ហើយមានចំណុចពិសេសមួយនៅក្នុងថ្ងៃបុណ្យរ៉យ៉ាអាល់អាជហា គឺគប្បីត្រូវសម្លេះអ៊ុទហ៊ីយ៉ះ(គួរហ្ពាន) ដើម្បីបញ្ជិតខ្លួនទៅចំពោះអល់ឡោះជាម្ចាស់។

អាល់អ៊ុទហ៊ីយ៉ះ(សត្វសម្រាប់សំឡេះក្នុងថ្ងៃបុណ្យរ៉យ៉ាហាជ្ជី): គឺជាសត្វដែលគេយកមកសម្លេះដូចជា សត្វអូដ្ឋ ឬសត្វគោ ឬពពែដើម្បីបញ្ជិតខ្លួនចំពោះអល់ឡោះក្នុងថ្ងៃបុណ្យអាល់អាជហាចាប់ផ្ដើមបន្ទាប់ពីសឡាតថ្ងៃបុណ្យ(សឡាតរ៉យ៉ា)រួច រហូតដល់ថ្ងៃលិចនៃថ្ងៃទី១៣នៃខែហ្ស៊ុលហិជ្ជះ។ អល់ឡោះបានមានបន្ទូលថា “ដូច្នេះ ចូរអ្នកសឡាត និងសម្លេះសត្វដើម្បីម្ចាស់របស់អ្នកចុះ”។ (គម្ពីរគួរអាន ១០៨:២)។ ហើយគេបានបកស្រាយថា នោះគឺសឡាតថ្ងៃបុណ្យអាជហា(សឡាតរ៉យ៉ាហាជ្ជី) និងការសម្លេះអ៊ុទហ៊ីយ៉ះ។

ច្បាប់របស់អ៊ុទហ៊ីយ៉ះ: គឺជាស៊ូណិតមូអឹកកាត់(ជាប្រការគួរគប្បីធ្វើបំផុត) សម្រាប់អ្នកដែលមានលទ្ធភាព ហើយអ្នកមូស្លីមសម្លេះសត្វសម្រាប់ខ្លួនរបស់គេ និងក្រុមគ្រួសាររបស់គេ។

ច្បាប់កំណត់សម្រាប់អ្នកដែលចង់ធ្វើអ៊ុទហ៊ីយ៉ះ(គួរហ្ពាន) មិនឱ្យគេកាត់សក់ កាត់ក្រចក និងដកអ្វីម្យ៉ាងពីស្បែករបស់គេនោះទេ ចាប់ពីថ្ងៃដំបូងនៃខែហ្ស៊ុលហិជ្ជះ រហូតដល់ពេលសម្លេះសត្វរួច។

## លក្ខខណ្ឌសម្រាប់សត្វដែលយកទៅសម្លេះ មានដូចជា ៖

1 ចាំបាច់ត្រូវតែជាសត្វពាហនៈ គឺសត្វពពែ សត្វគោ ឬសត្វអូដ្ឋ។ ហើយមិនត្រឹមត្រូវទេបើសិនជាសម្លេះសត្វផ្សេងពីនេះ ឬសម្លេះបក្សីនោះ។

2 ហើយគ្រប់គ្រាន់សម្រាប់បុគ្គលម្នាក់ និងក្រុមគ្រួសាររបស់គាត់ ចៀមមួយក្បាល ឬពពែមួយក្បាល។ ហើយគេអនុញ្ញាតឱ្យចូលហ៊ុនជាមួយគ្នាប្រាំពីរចំណែកក្នុងសត្វគោមួយក្បាល ឬសត្វអូដ្ឋមួយក្បាល។

3 សត្វត្រូវតែមានសុវត្ថិភាពពីពិការភាពច្បាស់លាស់។ អ្នកនាំសារបានមានប្រសាសន៍ថា “មានបួន(ប្រភេទនៃសត្វ)ដែលគេមិនទទួលយកការសម្លេះរបស់វាឡើយ គឺសត្វដែលខ្វាក់ភ្នែកដែលភាពខ្វាក់របស់វាច្បាស់លាស់ សត្វដែលមានជំងឺ ដែលជំងឺរបស់វាច្បាស់លាស់ សត្វដែលខ្វិនដែលភាពខ្វិនរបស់វាច្បាស់លាស់និងសត្វដែលស្គមស្គាំងខ្លាំង”។(អាន់ណាសាអ៊ីៈ៤៣៧១ អាត់តៀរមីហ្ស៊ីៈ១៤៩៧)

## តើត្រូវធ្វើដូចម្តេចជាមួយនឹងអាល់អ៊ុទហ៊ីយះ (សត្វសម្រាប់សម្លេះក្នុងថ្ងៃបុណ្យអាដហា)?

- ហាមមិនឱ្យលក់អ្វីម៉្យាងពីអ៊ុទហ៊ីយះ ឬគួរហ្លានឡើយ។
- គប្បីបែងចែកសាច់របស់វាជាបីចំណែក មួយចំណែកសម្រាប់ហូបខ្លួនឯង មួយចំណែកសម្រាប់ផ្តល់ឱ្យគេ និងមួយចំណែកទៀតសម្រាប់បរិច្ចាគឱ្យអ្នកក្រីក្រ។
- គេអនុញ្ញាតឱ្យផ្តល់សិទ្ធិឱ្យនរណាម្នាក់ និងផ្តល់ប្រាក់ដល់អង្គការសប្បុរសធម៌ដែលអាចជឿទុកចិត្តបានដើម្បីឱ្យគេសម្លេះអ៊ុទហ៊ីយះ និងចែកឱ្យអ្នកដែលត្រូវការចាំបាច់។



> សាសនាឥស្លាមបានដាក់លក្ខខណ្ឌចំពោះសត្វដែលត្រូវធ្វើអ៊ុទហ៊ីយ៉ះ គឺសត្វនោះត្រូវមានសុវត្ថិភាពរួចផុតពីភាពខ្វះខាត

# ការទស្សនកិច្ចទីក្រុងម៉ាទីណះ

ម៉ាទីណះ គឺជាទីក្រុងដែលព្យាការីមូហាំម៉ាត់បានភៀសខ្លួន ឬធ្វើចំណាកស្រុកទៅកាន់វា នៅពេលដែលលោកបានចាកចេញពីទីក្រុងម៉ាក្កះ ដោយសារពួកប្រឆាំងបានធ្វើទុក្ខបុកម្នេញដល់លោក។

ហើយកិច្ចការដំបូងគេដែលព្យាការីបានធ្វើនៅទីនោះ គឺការសាងសង់ ម៉ាស្ជិតអាន់ណាហ្ពាវី ដែលវាបានក្លាយជាមជ្ឈមណ្ឌលផ្តល់នូវចំនេះដឹង ការអំពាវនាវ និងផ្សព្វផ្សាយប្រការល្អទៅដល់មនុស្សលោក។

ការទៅទស្សនកិច្ចម៉ាស្ជិតអាន់ណាហ្ពាវី គឺជាប្រការមួយដែលគួរគប្បីធ្វើបំផុត មិនថានៅក្នុងរដូវកាលធ្វើហាជ្ជី ឬមិនមែននោះទេ។

ហើយការទៅទស្សនកិច្ចនោះ គឺនោះមិនជាប់ពាក់ព័ន្ធនឹងការប្រតិបត្តិធម្មយាត្រាហាជ្ជីទេ ហើយក៏មិនមានពេលកំណត់ដែរ។

អ្នកនាំសារបានមានប្រសាសន៍ថា “គេមិនបានដាក់សម្ពាធឱ្យធ្វើដំណើរទៅទីណាទេ លើកលែងតែទៅកាន់ម៉ាស្ជិត(វិហាឥស្លាម)បីប៉ុណ្ណោះគឺ ម៉ាស្ជិត អាល់ហារ៉ម(នៅក្រុងម៉ាក្កះ) ម៉ាស្ជិតរបស់ខ្ញុំ(នៅក្រុងម៉ាទីណះ) និងម៉ាស្ជិត អាល់អឹកស៏(នៅក្រុងយេរូសាឡឹម)”។ (អាល់ពូខរីៈ១១៣៩ មូស្លីមៈ១៣៩៧ អាពូហ្ទាវូទៈ២០៣៣)

អ្នកនាំសារបានមានប្រសាសន៍ថា “ការសឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំម្តង គឺល្អប្រសើរជាងការសឡាតនៅកន្លែងផ្សេង១ពាន់ដង លើកលែងតែម៉ាស្ជិត អាល់ហារ៉ម”។ (អាល់ពូខរីៈ១១៣៣មូស្លីម១៣៩៤)

## តើទីកន្លែងណាដែលគេបង្គាប់ប្រើឱ្យទៅទស្សនាវានៅក្នុងទីក្រុងម៉ាទីណះនោះ?

គប្បីលើអ្នកដែលចង់ទៅទស្សនកិច្ចទីក្រុងម៉ាទីណះត្រូវតែមានគោលបំណងទៅទស្សនាម៉ាស្ជិទរបស់ព្យាការី(ម៉ាស្ជិតណាហ្ពាវី) និងប្រតិបត្តិសឡាតនៅក្នុងវា។ នៅពេលដែលគេមកដល់ម៉ាទីណះច្បាប់ឥស្លាមបានបង្គាប់ប្រើឱ្យទៅទស្សនាកន្លែងមួយចំនួនដូចជា ៖

1 សឡាតនៅក្នុងរ៉ាវហ្ទោះ(ឈ្មោះកន្លែងមួយនៅក្នុងម៉ាស្ជិតព្យាការី)ៈ វាជាកន្លែងដែលគេកំណត់មួយនៅផ្នែកខាងមុខនៃម៉ាស្ជិត ចន្លោះរវាងផ្ទះរបស់ព្យាការី និងមីមពើ(កន្លែងថ្លែងសុន្ទរកថា)របស់លោក។ ការសឡាតនៅទីនោះទទួលបានផលបុណ្យយ៉ាងច្រើន។ អ្នកនាំសារបានមានប្រសាសន៍ថា “នៅចន្លោះរវាងផ្ទះរបស់ខ្ញុំនិងមីមពើររបស់ខ្ញុំ វាគឺជាសួនច្បារ(រ៉ាវហ្ទោះ)មួយក្នុងចំណោមសួនច្បារនៃឋានសួគ៌”។ (អាល់ពូខរីៈ១១៣៧ មូស្លីមៈ១៣៩០)

2 ឱ្យសាឡាម(គារវកិច្ច)ទៅលើព្យាការីៈ ដើរទៅកន្លែងផ្នូររបស់ព្យាការី ហើយឈរនៅពីមុខផ្នូររបស់លោក តម្រង់មុខទៅកាន់ផ្នូរ ហើយគិបឡាត់នៅខាងក្រោយ ហើយពោលដោយសីលធម៌និងប្រើសំលេងតិចៗថាៈ “អាស់សាឡាមូអាឡៃកា យ៉ារ៉ស៊ូលុលឡោះ វ៉ារ៉ោះម៉ាតុលឡ៏ហ៊ិវ៉ាហ្ពារ៉កាតុស អាស្ហាហាទូ អាន់ណាកា កត់ហ្ពាល់ឡើហ្គតា រីសាឡះ វ៉ាអាត់ទៃតាល់ អាម៉ាណះវ៉ាណាសោះតាល់ អ៊ុមម៉ះ វ៉ាជើហាត់តា ហ្វីលឡើហ៊ិ ហុកក៏ជីហើទីស ហ្វាជើហ្សើកុលឡោះ អាន់អ៊ុមម៉ាទីកា អាហ្ញទ៏លូ ម៉ាជើហ្សើ ព្យាការីយ៉ាន់ អាន់អ៊ុមម៉ាទីស”។ ពិតណាស់ អ្នកនាំសារបានមានប្រសាសន៍ថា “ពេលមនុស្សគ្រប់រូបដែលគេបានឲ្យសាឡាមមកចំពោះខ្ញុំអល់ឡោះបង្វិលព្រលឹងរបស់ខ្ញុំមកវិញ ដើម្បីឲ្យខ្ញុំឆ្លើយតបចំពោះការឲ្យសាឡាមរបស់គេ”។ (អាពូហ្ទាវូទៈ២០៤១)

បន្ទាប់មកត្រូវបែរមុខទៅខាងស្តាំ ដើម្បីឲ្យសាឡាមទៅលើអាពូហ្គាកើរ ដែលជាមេដឹកនាំឥស្លាម(បន្ទាប់ពីព្យាការី) និងជាមិត្តភក្តិជំនិតរបស់លោកដែលល្អប្រពៃជាងគេ។ បន្ទាប់មកឈានទៅខាងស្តាំហើយឲ្យសាឡាមទៅលើអ៊ូមើរ ដែលជាមេដឹកនាំឥស្លាមទីពីរ និងក៏ជាមិត្តភក្តិជំនិតរបស់លោកដែលល្អប្រពៃផងដែរបន្ទាប់ពីអាពូហ្គាកើរ។ ទោះបីជាអ្នកនាំសារគឺជាមនុស្សដែលល្អប្រពៃបំផុតក៏ដោយ តែលោកគ្មានលទ្ធភាពផ្តល់ផលប្រយោជន៍ឬបង្ករគ្រោះថ្នាក់ដល់នរណាម្នាក់បានឡើយ។ ហេតុនេះមិនអនុញ្ញាតទេចំពោះការបួងសួង ឬសុំជំនួយពីលោក។ ផ្ទុយទៅវិញការបួងសួងនិងការគោរពសក្ការៈទាំងអស់គឺចំពោះអល់ឡោះតែមួយគត់ ដោយគ្មានអ្នកផ្សេង ឬអ្វីមួយចូលរួមជាមួយទ្រង់ឡើយ។

3 ការទៅទស្សនកិច្ចម៉ាស្ជិតគូហ្ពាក(វិហាឥស្លាមមួយនៅតំបន់គូហ្ពាក)៖ គឺជាម៉ាស្ជិតដែលគេកសាងឡើងដំបូងគេបង្អស់នៅក្នុងសាសនាឥស្លាមមុនពេលដែលព្យាការីសាងសង់ម៉ាស្ជិតរបស់លោក។ ហើយសម្រាប់អ្នកដែលទៅដល់ក្រុងម៉ាទីណះ គួរគប្បីទៅទស្សនាកិច្ចម៉ាស្ជិតគូហ្ពាកនេះផងដែរ។ ហើយពិតណាស់ អ្នកនាំសារតែងតែទៅទស្សនាវា ហើយលោកក៏បានមានប្រសាសន៍ផងដែរថា “បុគ្គលណាហើយដែលបានសម្អាតខ្លួននៅក្នុងផ្ទះរបស់គេបន្ទាប់មកគាត់ធ្វើដំណើរទៅម៉ាស្ជិតគូហ្ពាក ហើយបានសឡាតនៅទីនោះគឺរូបគេនឹងទទួលបានផលបុណ្យដូចជាការធ្វើអ៊ុំរ៉ោះ”។ (អ៊ិពនូម៉ាយ៉ះៈ១៤១២)។






# ប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក



# 7

សាសនាឥស្លាមបានដាក់បទបញ្ញត្តិនិងក្បួនច្បាប់ទាំងអស់ដោយគិតគូរអំពីមនុស្សនិងការពារសិទ្ធិទ្រព្យសម្បត្តិនិងវិជ្ជាជីវៈរបស់ពួកទោះបីបុគ្គលនោះជាអ្នកមានឬអ្នកក្រក៏ដោយ។ ហើយច្បាប់ទាំងនេះរួមចំណែកក្នុងការបង្រួបបង្រួមអភិវឌ្ឍន៍ និងលើកកំពស់សង្គមលើគ្រប់ផ្នែកនៃជីវិត។

## មាតិកាជំពូក

មូលដ្ឋាននៃប្រតិបត្តិការនានាគឺត្រូវបានអនុញ្ញាត(ហាឡាល់)

ប្រការហាមឃាត់ដោយសារខ្លួនរបស់វាផ្ទាល់

ប្រការហាមឃាត់ដោយសារវិធីរកវា

ការប្រាក់(រីបា)

- ការប្រាក់ក្នុងបំណុល
- ការប្រាក់ក្នុងប្រាក់កម្ចី
- ច្បាប់ឥស្លាមស្តីពីការប្រាក់
- ទណ្ឌកម្មនៃការប្រាក់

ហានិភ័យរបស់ប្រាក់ការទៅលើបុគ្គល និងសង្គម

ភាពមិនច្បាស់លាស់ និងការមិនដឹងច្បាស់

ភាពអយុត្តិធម៌ និងការយកទ្រព្យសម្បត្តិរបស់មនុស្សដោយមិនត្រឹមត្រូវ

ល្បែងស៊ីសង

- ផលប៉ះពាល់នៃល្បែងស៊ីសងទៅលើបុគ្គល និងសង្គម

ក្រមសីលធម៌ដែលឥស្លាមបានសង្កត់ធ្ងន់នៅក្នុងប្រតិបត្តិការហិរញ្ញវត្ថុគឺ ៖

- ទំនុកចិត្ត
- ភាពទៀងត្រង់
- ភាពច្បាស់លាស់

# ប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក



ការងារដែលគេអនុញ្ញាតទាំងអស់គឺជាការងារដែលថ្លៃថ្នូរ គ្មានភាពអាប់ឱននោះទេ។

អល់ឡោះបានប្រើឱ្យប្រឹងប្រែងដើម្បីស្វែងរកលាភសក្ការៈនៅលើផែនដី និងបានជំរុញលើកិច្ចការនេះ ហើយបានស្តែងចេញយ៉ាងច្បាស់នៅក្នុងប្រការជាច្រើនដូចជា៖

- ពិតប្រាកដណាស់ គេបានហាមឃាត់អំពីការសុំទានពីមនុស្ស ដរាបណាគេនៅមានលទ្ធភាពធ្វើការ និងស្វែងរកចំណូលពីការខិតខំប្រឹងប្រែងនិងទង្វើរបស់គាត់។ ហើយគេបានបញ្ជាក់ថា បុគ្គលដែលសុំទានពីមនុស្ស ខណៈដែលគាត់មានលទ្ធភាពធ្វើការនិងរកចំណូលនោះ វានឹងធ្វើឲ្យគាត់ខាតបង់ឋានៈរបស់គាត់នៅចំពោះអល់ឡោះ និងចំពោះមនុស្ស។ អ្នកនាំសារមានប្រសាសន៍ថា "អ្នកខ្លះនៃពួកអ្នកនៅសុំគេរហូតដល់ពេលជួបនឹងអល់ឡោះ នៅលើមុខរបស់គាត់គ្មានសាច់មួយដុំឡើយ"។ (អាល់ពូខរី ១៤០៥ មូស្លឹម ១០៤០)

អ្នកនាំសារបានមានប្រសាសន៍ថា "បុគ្គលណាមានតម្រូវការចាំបាច់អ្វីមួយ ហើយគាត់សុំវាអំពីមនុស្ស គេនឹងមិនអាចបំពេញតម្រូវការរបស់គាត់បានឡើយ។ ចំណែកបុគ្គលណាមានតម្រូវការចាំបាច់អ្វីមួយ ហើយគាត់សុំអំពីអល់ឡោះ អល់ឡោះស្ទើរតែនឹងផ្តល់ឲ្យគាត់នូវភាពមានបាន"។(អះម៉ាត់ ៣៨៦៩ អាពូទើវ៉ូទ ១៦៤៥)

- វិជ្ជាជីវៈទាំងអស់ដូចជា ឧស្សាហកម្ម សេវាកម្ម និងការវិនិយោគ ជាការងារថ្លៃថ្នូរ វាមិនថោកទាបនោះទេ ដរាបណាស្ថិតក្នុងដែនដែលគេអនុញ្ញាត។ ហើយបទបញ្ញត្តិឥស្លាមដែលបាននាំមកថាបណ្តាព្យាការីៗទាំងឡាយប្រកបការងារដូចវិជ្ជាជីវៈដែលគេអនុញ្ញាតរបស់ក្រុមពួកគាត់។ ដូចអ្នកនាំសារបានមានប្រសាសន៍ថា "គ្រប់ព្យាការីទាំងអស់ដែលអល់ឡោះបានចាត់តាំងសុទ្ធតែជាអ្នកគង្វាលចៀម"។(អាល់ពូខរី ២១៤៣) ព្យាការីហ្សាការីយ៉ាគឺជាជាងឈើ (មូស្លឹម ២៣៧៩) ហើយដូច្នោះដែរព្យាការីដទៃទៀតគាត់ប្រកបការងារទៅតាមវិជ្ជាជីវៈនោះ។

- ពិតណាស់សម្រាប់អ្នកដែលមានបំណងល្អពីការងាររបស់គាត់ ដោយគាត់ចង់ផ្គត់ផ្គង់ដល់ខ្លួនរបស់គាត់ និងក្រុមគ្រួសាររបស់គាត់ ការពារពួកគេពីការសុំអំពីមនុស្សនិងផ្តល់ផលប្រយោជន៍ដល់អ្នកដែលមានតម្រូវការទាំងឡាយ ពិតណាស់រូបគាត់នឹងទទួលបានផលបុណ្យពីការប្រកបការងារ និងការខិតខំប្រឹងប្រែងរបស់គាត់។

## ប្រភពដើមនៃប្រតិបត្តិការទាំងអស់ គឺត្រូវបានអនុញ្ញាត

ប្រភពដើមនៃប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់ដូចជាការលក់ ការទិញ និងការជួល និងផ្សេងពីនេះទៀតដែលមនុស្សធ្វើប្រតិបត្តិការនិងមានតំរូវការចំពោះវាគឺត្រូវបានអនុញ្ញាត លើកលែងតែអ្វីដែលគេបានដកចេញវិញនៃប្រការហាមឃាត់ដោយសារខ្លួនរបស់វាផ្ទាល់ឬដោយសារមធ្យោបាយរកវា។

## អ្វីដែលគេហាមឃាត់ដោយសារខ្លួនរបស់វាផ្ទាល់

វាជាប្រការហាមឃាត់ដែលអល់ឡោះបានដាក់បំរាមវាដោយសារខ្លួនរបស់វាផ្ទាល់ ហើយគេមិនអនុញ្ញាតឱ្យជួញវាឬលក់ដូរវាឬទិញវាឬជួលវា ឬធ្វើការក្នុងការផលិតវា និងចែកចាយទៅដល់មនុស្សទូទៅឡើយ។

ឧទាហរណ៍អំពីអ្វីដែលឥស្លាមហាមឃាត់ដោយសារតែខ្លួនរបស់វា ៖

- សត្វឆ្កែ និងសត្វជ្រូក
- សត្វដែលបានស្លាប់ ឬផ្នែកខ្លះអំពីវា
- សុរា និងគ្រឿងបរិភោគដែលមានជាតិអាល់កុល
- គ្រឿងញៀន និងរាល់អ្វីដែលនាំឱ្យខូចសុខភាព
- សម្ភារៈដែលគេប្រើដើម្បីផ្សព្វផ្សាយប្រការអាក្រក់ដល់មនុស្ស ដូចជាវីដេអូ វេបសាយ និងទស្សនាវដ្ដី អាសអាភាស។
- រូបសំណាក និងរាល់អ្វីដែលគេគោរពសក្ការៈផ្សេងពីអល់ឡោះ

### អ្វីដែលត្រូវបានហាមឃាត់ដោយសារមធ្យោបាយរកវា

វាគឺជាទ្រព្យសម្បត្តិដែលប្រភពដើមវាគេអនុញ្ញាត ប៉ុន្តែគេហាមឃាត់វាដោយសារមធ្យោបាយរកវាដែលនាំឱ្យបង្កគ្រោះថ្នាក់ដល់បុគ្គលនិងសង្គម។ ដូច្នេះគេហាមឃាត់វាដោយមូលហេតុនោះ។ បណ្ដាមូលហេតុដែលគេហាមឃាត់ក្នុងប្រតិបត្តិការវានោះគឺ:

ការប្រាក់ ភាពមិនប្រាកដប្រជា និងភាពមិនច្បាស់លាស់ ការបំពាន និងល្បែងស៊ីសង។ ហើយយើងនឹងលម្អិតអំពីវាដូចខាងក្រោម ៖

## > ការប្រាក់

ការប្រាក់ជាអ្វីដែលលើសដែលច្បាប់ហាមឃាត់ ដោយសារនៅក្នុងវាមានការបំពាន និងការបង្កគ្រោះថ្នាក់។

វាមានច្រើនប្រភេទ ប្រភេទដែលល្បីល្បាញ និងគេហាមឃាត់ខ្លាំងបំផុតនោះគឺ: ការប្រាក់ក្នុងប្រាក់កម្ចី និងបំណុល។ វាគឺជាការថែមពីលើប្រាក់ដើមដោយមិនមែនជាការលក់ ឬផ្លាស់ប្ដូរទំនិញរវាងពីរភាគី។ វាមានពីរប្រភេទ ៖



រាល់ប្រាក់កម្ចី ឬបំណុលដែលជាមូលហេតុផ្ដល់ផលដល់អ្នកដែលឱ្យគេខ្ចី វាគឺជាការប្រាក់។

### ■ ការប្រាក់ក្នុងបំណុល

វាជាការបន្ថែមលើបំណុលនៅពេលដែលដល់ពេលកំណត់ទូទាត់ ប្រសិនបើកូនបំណុលមិនមានលទ្ធភាពសង។

ឧទាហរណ៍របស់វា: សាអ៊ីទ បានខ្ចីលុយពី ខលីទ ១០០០ដុល្លា និងសន្យាសងវិញនៅខែក្រោយ។ នៅពេលដែលដាច់ខែហើយពេលវេលាត្រូវសងមកដល់សាអ៊ីទមិនមានលទ្ធភាពសង។ ពេលនោះ អ្នកដែលឱ្យគេខ្ចី បានដាក់លក្ខខណ្ឌថាបើទូទាត់គ្នាពេលនេះគឺមិនមានការបន្ថែមទេ តែបើចាំទូទាត់គ្នាខែក្រោយគឺ ១១០០ដុល្លា ហើយបើសិនជានៅតែគ្មានលទ្ធភាពទៀត ខែក្រោយមួយទៀតគឺ ១២០០ដុល្លា។

### ■ ការប្រាក់ក្នុងប្រាក់កម្ចី

វាមានន័យថាការខ្ចីប្រាក់មួយចំនួនពីបុរសម្នាក់ ឬពីធនាគាដោយលក្ខខ័ណ្ឌឱ្យប្រាក់បន្ថែមនៅពេលទូទាត់ ដោយឯកភាពគ្នាលើចំនួន៥%ក្នុងមួយឆ្នាំ ឬតិចជាង ឬច្រើនជាង។

ឧទាហរណ៍របស់វា: គេចង់ទិញផ្ទះដែលមានតម្លៃ(មួយរយពាន់) ហើយគេគ្មានប្រាក់គ្រប់គ្រាន់។ ហើយគេក៏ទៅធនាគារ ហើយខ្ចីប្រាក់(មួយរយពាន់)ដើម្បីទិញផ្ទះ ដោយលក្ខខ័ណ្ឌគេនឹងទូទាត់ទៅឱ្យធនាគារវិញចំនួនមួយរយហាសិបពាន់នៅលើការបង់រំលស់ប្រចាំខែរយៈពេលប្រាំឆ្នាំ។

ការប្រាក់គឺត្រូវបានហាមឃាត់ហើយវាជាបាបកម្មដ៏ធំដរាបណាប្រាក់កម្ចីទទួលបានផលប្រយោជន៍។ ទោះបីជាប្រាក់កម្ចីនោះផ្តល់ផលដល់ការវិនិយោគពាណិជ្ជកម្ម ឬឧស្សាហកម្ម ឬដើម្បីទិញតម្រូវការជាមូលដ្ឋានសំខាន់ដូចជាផ្ទះ ឬអាគារ ឬប្រើប្រាស់ដើម្បីបំពេញតម្រូវការ។

ចំណែកការទិញទំនិញដោយបង់រំលស់ក្នុងតម្លៃថ្លៃជាងតម្លៃបង់លុយភ្លាមនោះមិនចូលក្នុងការប្រាក់ឡើយ។

ឧទាហរណ៍: បុគ្គលម្នាក់ទិញឧបករណ៍មួយតំលៃ១០០០ដុល្លាឱ្យលុយភ្លាម ឬតំលៃ១២០០ដុល្លាដោយបង់រំលស់ប្រចាំខែរយៈពេលមួយឆ្នាំ ក្នុងមួយខែ ១០០ដុល្លារ បង់វាឱ្យម្ចាស់ហាងពីការដែលគាត់ទិញឧបករណ៍នោះ។

## ច្បាប់ទាក់ទងនឹងការប្រាក់

ភស្តុតាងពីអត្ថបទ គួរអាន និងហាឌីសរបស់ព្យាការី បានចង្អុលបង្ហាញយ៉ាងច្បាស់ថាការប្រាក់ត្រូវបានហាមឃាត់យ៉ាងតឹងរឹងក្នុងសាសនាឥស្លាម ហើយវាជាអំពើបាបកម្មដ៏ធំមួយ ដែលអល់ឡោះមិនបានសន្យាប្រកាសសង្គ្រាមលើបុគ្គលណាមួយនៃមនុស្សប្រឆាំងឡើយលើកលែងតែអ្នកស៊ីការប្រាក់ និងអ្នករួមចំណែក។ការប្រាក់ ត្រូវបានហាមឃាត់មិនមែនមានតែនៅក្នុងសាសនាឥស្លាមទេ តែថែមទាំងនៅក្នុងសាសនារបស់អល់ឡោះពីមុនទាំងអស់ ក៏ប៉ុន្តែវាត្រូវបានគេកែប្រែ និងប្រព្រឹត្តល្មើសដូចដែលគេបានធ្វើវាក្នុងច្បាប់ផ្សេងទៀត។ អល់ឡោះបានមានបន្ទូលបញ្ជាក់យ៉ាងច្បាស់ពីមូលហេតុនៃការផ្តន្ទាទោសដល់ក្រុម អះលីគីតាបថា "និងដោយសារតែពួកគេទទួលយកការប្រាក់ដែល អល់ឡោះបានហាមឃាត់ពួកគេអំពីវា"។(គម្ពីរគួរអាន ៤:១៦១)

## ការផ្តន្ទាទោសលើការស៊ីការប្រាក់

1. ១- អ្នកដែលបានចូលរួមប្រតិបត្តិការក្នុងការប្រាក់ គឺដូចជាអ្នកដែលបានបង្ហាញខ្លួនរបស់គាត់ដើម្បីធ្វើសង្គ្រាមជាមួយអល់ឡោះនិងអ្នកនាំសារ ហើយបានក្លាយជាសត្រូវជាមួយអល់ឡោះនិងអ្នកនាំសារ។ អល់ឡោះបានមានបន្ទូលថា "ហើយប្រសិនបើពួកអ្នកមិនព្រមបោះបង់ចោល (ការប្រាក់)ទេ ពួកអ្នកត្រូវដឹងថា នឹងមានសង្គ្រាមមកពីអល់ឡោះ និង អ្នកនាំសាររបស់ទ្រង់។ តែប្រសិនបើពួកអ្នកសារភាពកំហុសវិញសម្រាប់ពួកអ្នកគឺប្រាក់ដើមរបស់ពួកអ្នក។ (ការធ្វើដូច្នេះ) ពួកអ្នកមិនបំពានលើគេ ហើយគេក៏មិនបំពានលើពួកអ្នកដែរ"។(អាល់បាហ្គោរ៉ោះ ២៧៩ ) វាគឺជាសង្គ្រាមជាមួយនឹងផលប៉ះពាល់ផ្លូវចិត្តនិងរាងកាយ។ អ្វីដែលមនុស្សទទួលបានបច្ចុប្បន្នអំពីការព្រួយបារម្ភ ពិបាកចិត្ត ទុក្ខព្រួយ ទុក្ខលំបាក លើកលែងតែវាជាសញ្ញាមួយចំនួននៃសង្គ្រាមដែលអល់ឡោះបានប្រកាសលើពួកអ្នកដែលមិនគោរពតាមបទបញ្ជារបស់ទ្រង់ និងយកប្រាក់ការ ឬចូលរួមជាមួយគេ។ ចុះបើសង្គ្រាមនៅថ្ងៃបរលោកវិញតើវានឹងផ្តល់ផលប៉ះពាល់កំរិតណាទៅវិញ?

2. អ្នកដែលយកប្រាក់ការ និងអ្នកដែលចូលរួមជាមួយគ្នា ត្រូវបានគេដាក់បណ្តាសា និងច្រានចេញពីក្តីមេត្តាករុណារបស់អល់ឡោះ សម្រាប់គាត់និងអ្នកដែលចូលរួមជាមួយគាត់គឺដូចគ្នា។ ជើពៀរបាននិយាយថា "អ្នកនាំសារបានដាក់បណ្តាសាចំពោះអ្នកដែលស៊ីប្រាក់ការ និងអ្នកដែលឱ្យគេស៊ីវា និងអ្នកកត់ត្រា ព្រមទាំងសាក្សីទាំងពីរ" ហើយលោកមានប្រសាសន៍ថា "ពួកគេទាំងអស់នោះ គឺដូចគ្នា"។(មូស្លីម ១៥៩៨)

3. អ្នកដែលយកប្រាក់ការពួកគេនឹងត្រូវបានរស់ឡើងវិញនៅថ្ងៃបរលោកក្នុងរូបភាពដែលអាក្រក់បំផុតនិងទទួលរងពីជំងឺស្កន់ និងឆ្កួត។អល់ឡោះបានមានបន្ទូលថា "ពួកដែលស៊ីការប្រាក់នោះ ពួកគេមិនអាចក្រោកឈរ បានទេ(នៅថ្ងៃបរលោក) លើកលែងតែគេក្រោកឈរដូចអ្នកដែលស្ទៃតនចូលដែលធ្វើឱ្យគេឆ្កួតប៉ុណ្ណោះ"។ (គម្ពីរគួរអាន ២:២៧៥)

4. ទ្រព្យសម្បត្តិបានពីការប្រាក់ទោះជាវាច្រើន ប៉ុន្តែវាត្រូវបានគេលុបបំបាត់ចេញនូវភាពរីកចម្រើន វាមិនធ្វើឲ្យទទួលបានក្តីសុខ សុភមង្គល និងស្កប់ស្កល់ឡើយ។ អល់ឡោះបានមានបន្ទូលថា

"អល់ឡោះបំបាត់ភាពរីកចម្រើនចំពោះការប្រាក់។ ប៉ុន្តែទ្រង់បង្កើនផលចំពោះទ្រព្យបរិច្ចាគនានា"។ (គម្ពីរគួរអាន ២:២៧៦)

## ហានិភ័យរបស់ការប្រាក់ទៅលើបុគ្គល និងសង្គម

ពិតណាស់ ឥស្លាមបានសង្កត់ធ្ងន់លើការប្រាក់ ដោយសារវាផ្តល់ផលប៉ះពាល់ ឥទ្ធិពលអាក្រក់ និងការបំផ្លិចបំផ្លាញ ទាំងទៅលើបុគ្គលខ្លួនឯង និងសង្គមជាតិ។ ក្នុងចំណោមនោះមានដូចជា ៖

### 1 វាបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរក្នុងការចែកចាយទ្រព្យសម្បត្តិនិងពង្រីកនូវភាពគម្លាតឆ្ងាយរវាងអ្នកមាននិងអ្នកក្រ

ដោយសារការប្រាក់ផ្តោតលើទ្រព្យសម្បត្តិនៅក្នុងដៃរបស់បុគ្គលមួយចំនួនតូចក្នុងចំណោមបុគ្គលក្នុងសង្គមមួយ ហើយត្រូវបានហាមឃាត់សម្រាប់មនុស្សភាគច្រើន។ នេះគឺជាកង្វះខាតនៅក្នុងការចែកចាយទ្រព្យសម្បត្តិ ដែលជាហេតុបុគ្គលមួយធ្វើឲ្យសង្គមនោះឬមនុស្សមួយចំនួនតូចមានទ្រព្យសម្បត្តិស្តុកស្តម្ភ តែអ្នកដែលនៅសេសសល់គឺជាអ្នកនៀយហត់ អ្នកក្រីក្រ និងអ្នកខ្វះខាត។ នេះគឺជាបរិស្ថានមួយដែលវាល្អប្រសើរសម្រាប់ការរីករាលដាលនៃការចងគំនុំគ្នានិងឧក្រិដ្ឋកម្មក្នុងសង្គម។

### 2 ធ្វើឲ្យមានទម្លាប់ខ្ជះខ្ជាយ និងមិនចេះសន្សំសំចៃ។

ភាពងាយស្រួលនៃការទទួលបានប្រាក់កម្ចីជាមួយនឹងការប្រាក់នោះ បានលើកទឹកចិត្តមនុស្សជាច្រើនលើការខ្ជះខ្ជាយនិងកង្វះការសន្សំសំចៃព្រោះមានអ្នកដែលចាំឱ្យប្រាក់កម្ចីរាល់ពេលដែលត្រូវការ ហេតុនេះគាត់មិនសូវគិតគូរពីបច្ចុប្បន្ន និងអនាគតរបស់គាត់ឡើយ គឺគិតតែពីចំណាយបំពេញតម្រូវការរហូតធ្វើឲ្យមានបំណុលជុំទិស និងជីវិតប្រែជាចង្អៀត។ ហើយជីវិតសេសសល់របស់គាត់ត្រូវស្ថិតនៅក្នុងភាពលំបាកវេទនាដោយសារការរកែពុននូវបំណុលនិងកម្ចីទាំងនោះ។

### 3 ការប្រាក់ជាមូលហេតុរាំងអ្នកមានទាំងឡាយពីការវិនិយោគនៅក្នុងគម្រោងដែលមានប្រយោជន៍សំរាប់ប្រទេសជាតិ

ម្ចាស់ប្រាក់ទទួលបានពីប្រព័ន្ធការប្រាក់នូវឱកាសដើម្បីទទួលបានភាគរយមួយចំនួននៅក្នុងការប្រាក់នៃប្រាក់របស់គាត់ ហើយនេះអាចបង្វែរពួកគាត់ពីការវិនិយោគដើមទុនរបស់ខ្លួននៅក្នុងគម្រោងឧស្សាហកម្ម កសិកម្ម និងពាណិជ្ជកម្ម ទោះបីជាវាផ្តល់ផលប្រយោជន៍ក្នុងសង្គមក៏ដោយ តែវាមានកម្រិតនៃហានិភ័យខ្ពស់ និងទាមទារឱ្យមានការខិតខំប្រឹងប្រែងធ្វើការ។

### 4 ការប្រាក់ជាមូលហេតុក្នុងការលុបបំបាត់ភាពរីកចម្រើននៃទ្រព្យសម្បត្តិ និងនាំឱ្យមានវិបត្តិសេដ្ឋកិច្ច

រាល់វិបត្តិសេដ្ឋកិច្ច និងការក្ស័យធនធំៗរបស់សហគ្រាស ឬក៏បុគ្គលគឺដោយសារការចូលរួមក្នុងប្រព័ន្ធការប្រាក់ដែលគេហាមឃាត់។ វាគឺជាឥទ្ធិពលមួយនៃការបាត់បង់ភាពចំរុងចម្រើនដែលអល់ឡោះបានប្រាប់ ដែលផ្ទុយពីការបរិច្ចាគនិងអំពើល្អចំពោះមនុស្ស។ វាផ្តល់ភាពចំរុងចម្រើនដល់ទ្រព្យសម្បត្តិ និងបង្កើនវា។ អល់ឡោះបានមានបន្ទូលថា "អល់ឡោះបំបាត់ភាពរីកចម្រើនចំពោះការប្រាក់។ ប៉ុន្តែ ទ្រង់បង្កើនផលចំពោះទ្រព្យបរិច្ចាគនានា" ។(គម្ពីរគួរអាន ២:២៧៦)



> ប្រាក់ការជាមូលហេតុដែលនាំឲ្យរលាយទ្រព្យសម្បត្តិនិងបង្កឲ្យកើតមានការដួលរលំសេដ្ឋកិច្ច

## តើច្បាប់ចែងដូចម្ដេចចំពោះបុគ្គលម្នាក់ចូលឥស្លាម ហើយគាត់នៅជាប់ពាក់ព័ន្ធជាមួយកិច្ចសន្យាការប្រាក់ ?

ប្រសិនបើបុរសម្នាក់ចូលឥស្លាមហើយគាត់នៅជាប់ពាក់ព័ន្ធជាមួយកិច្ចសន្យាការប្រាក់ សម្រាប់គាត់មានពីរករណី ៖

១. ប្រសិនបើគាត់ជាអ្នកយកប្រាក់បន្ថែម(យកការប្រាក់)គាត់ត្រូវយកតែប្រាក់ដើមរបស់គាត់ ហើយមិនត្រូវយកអ្វីបន្ថែមឡើយដោយសារគាត់បានចូលឥស្លាម។ អល់ឡោះបានមានបន្ទូលថា ៖ "ប្រសិនបើពួកអ្នកសារភាពកំហុសសម្រាប់ពួកអ្នកគឺប្រាក់ដើមរបស់ពួកអ្នក។ (ការធ្វើដូច្នេះ) ពួកអ្នកមិនបំពានលើគេ ហើយគេក៏មិនបំពានលើពួកអ្នកដែរ"។ (គម្ពីរគួរអាន ២:២៧៩)

២. ប្រសិនបើគាត់ជាអ្នកបង់ប្រាក់បន្ថែម(អ្នកបង់ការប្រាក់) សម្រាប់គាត់មានពីរករណី ៖

- ប្រសិនបើគាត់មានសមត្ថភាពលុបកិច្ចសន្យា និងចេញអំពីវាដោយគ្មានគ្រោះថ្នាក់ធ្ងន់ធ្ងរ ចាំបាច់លើគាត់ត្រូវធ្វើដូចនោះ។
- តែបើសិនជាគាត់មិនអាចលុបកិច្ចសន្យាលើកលែងតែមានគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ ពិតណាស់ គាត់ត្រូវបំពេញកិច្ចសន្យា ហើយគាត់ត្រូវប្ដេជ្ញាចិត្តថាមិនត្រលប់ទៅធ្វើដូចនេះទៀតទេ។ អល់ឡោះបានមានបន្ទូលថា ៖ "ហើយអ្នកណា ដែលទទួលបាននូវការទូន្មានពីម្ចាស់របស់គេ ហើយគេបោះបង់ចោល(ឈប់យកការប្រាក់) ដូច្នេះ អ្វីដែលមានពីមុន(មុនការទូន្មានមកដល់)គឺជាកម្មសិទ្ធិរបស់គេ ហើយរឿងរ៉ាវរបស់គេគឺអាស្រ័យលើអល់ឡោះ។ រីឯអ្នកណាដែលបានត្រឡប់ទៅ(ស៊ីការប្រាក់)វិញ ពួកទាំងនោះជាពួកនរក។ ពួកគេស្ថិតក្នុងនោះជាអមតៈ"។(គម្ពីរគួរអាន ២:២៧៥)

តើអ្នកជាអ្នកឱ្យគេខ្ចីប្រាក់ និងយកប្រាក់បន្ថែម(យកប្រាក់ការ)ឬ?

ទេ

បាទ

ចាំបាច់លើអ្នកត្រូវយកតែប្រាក់ដើមរបស់អ្នកដោយមិនយកប្រាក់បន្ថែមឡើយ។

ប្រសិនបើអ្នកជាអ្នកបង់ប្រាក់បន្ថែម តើអ្នកអាចលុបកិច្ចសន្យាដោយគ្មានគ្រោះថ្នាក់ធ្ងន់ធ្ងរបានដែរឬទេ ?

ទេ

បាទ

ចាំបាច់លើអ្នកត្រូវតែលុបកិច្ចសន្យាប្រសិនបើអ្នកមានលទ្ធភាព ហើយគ្មានគ្រោះថ្នាក់លើអ្នក។

ប្រសិនបើអ្នកមិនអាចលុបកិច្ចសន្យា ឬបើលុបកិច្ចសន្យាវាជាមូលហេតុផ្ដល់គ្រោះថ្នាក់ធ្ងន់ធ្ងរ ពិតណាស់ អ្នកត្រូវបំពេញកិច្ចសន្យា ហើយអ្នកត្រូវប្ដេជ្ញាចិត្តថាមិនត្រលប់ទៅធ្វើដូចនេះទៀតទេនាពេលអនាគត។

# > ភាពមិនច្បាស់លាស់ និងការមិនដឹងច្បាស់

មានន័យថា រាល់កិច្ចព្រមព្រៀងទាំងអស់ដែលមានមូលដ្ឋានលើភាពមិនច្បាស់លាស់និងការមិនដឹងច្បាស់ ដែលជួនកាល វាជាមូលហេតុនាំឲ្យមានការខ្វែងគំនិត និងមានជម្លោះរវាងភាគីទាំងពីរ ឬជាការបំពានរបស់ភាគីម្ខាងលើភាគីម្ខាងទៀត។



ពិតណាស់ សាសនាឥស្លាមបានហាមឃាត់វាដើម្បីទប់ស្កាត់មធ្យោបាយនាំឱ្យមានជម្លោះ ឬការបោកប្រាស់ និងភាពអយុត្តិធម៌។ ហើយសូម្បីតែមនុស្សយល់ព្រមលើវាក៏គេមិនអនុញ្ញាតដែរ ពិតណាស់ព្យាការីបានហាមឃាត់អំពីការលក់ដូរទំនិញដែលមានលក្ខណៈមិនច្បាស់លាស់។ (មូស្លីម ១៥១៣)

## ឧទាហរណ៍ សម្រាប់ការលក់ដែលមិនមានលក្ខណៈច្បាស់លាស់ និងការមិនដឹងពីទំនិញ

1. លក់ផ្លែឈើមុនពេលលេចឡើងថាវាអាចប្រើការបាន និងសមស្របក្នុងការបេះវា។ ពិតណាស់អ្នកនាំសារបានហាមឃាត់អំពីវា ពីព្រោះវាអាចប្រឈមនឹងការខូចខាតមុនពេលប្រមូលផល។
2. ការបង់ប្រាក់មួយចំនួនដើម្បីទិញប្រអប់ដោយមិនបានដឹងថាអ្វីដែលមានក្នុងវា ថាតើវាអាចជារបស់ដែលមានតម្លៃថ្លៃ ឬក៏អ្វីដែលធម្មតា។ ហើយដូចគ្នាផងដែរ ការលក់អ្វីដែលមិនមែនជាកម្មសិទ្ធិរបស់ខ្លួន និងអ្វីដែលគេគ្មានលទ្ធភាពក្នុងការប្រគល់ឲ្យ។

## តើនៅពេលណាដែលភាពមិនច្បាស់លាស់ផ្តល់ផលប៉ះពាល់?

ការមិនច្បាស់លាស់និងការមិនដឹង មិនមានឥទ្ធិពលលើការហាមឃាត់នៃកិច្ចសន្យានោះទេ លើកលែងតែវាមិនច្បាស់ខ្លាំង និងក្នុងប្រការជាគោលនៃកិច្ចសន្យា មិនមែនក្នុងសាខារបស់វា។

ដូច្នេះ អ្នកមូស្លីមអាចទិញផ្ទះមួយ បើទោះបីជាគាត់មិនបានដឹងពីប្រភេទនៃសម្ភារៈសំណង់ដែលត្រូវបានប្រើក្នុងការសាងសង់ផ្ទះ និងប្រភេទនៃទឹកថ្នាំលាប និងអ្វីផ្សេងទៀត ពីព្រោះការមិនដឹងនេះគឺក្នុងកម្រិតតិចតួច។ លើសពីនេះវាស្ថិតនៅក្នុងសាខានៃកិច្ចសន្យា មិនមែនស្ថិតនៅលើប្រការគោលរបស់វានោះទេ។

# >ភាពអយុត្តិធម៌ និងការយកទ្រព្យសម្បត្តិរបស់អ្នកដទៃដោយមិនត្រឹមត្រូវ

ភាពអយុត្តិធម៌ ស្ថិតនៅក្នុងចំណោមទង្វើអាក្រក់បំផុតដែលឥស្លាមបានប្រើឱ្យមានការប្រុងប្រយ័ត្នអំពីវា។ អ្នកនាំសារបានមានប្រសាសន៍ថា ៖ "ទង្វើអយុត្តិធម៌ ធ្វើឱ្យមានភាពងងឹតនៅថ្ងៃបរលោក"។ (អាល់ពូខរីៈ២៣១៥ មូស្លីមៈ២៥៧៩)

ការយកទ្រព្យសម្បត្តិអ្នកដទៃដោយមិនត្រឹមត្រូវ សូម្បីតែតិចតួចក៏ដោយ វាជាអំពើបាប និងជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតដែលគេបានសន្យាចំពោះអ្នកដែលប្រព្រឹត្តវានូវទណ្ឌកម្មយ៉ាងខ្លាំងក្លាបំផុតនៅថ្ងៃបរលោក។ អ្នកនាំសារបានមានប្រសាសន៍ថា "ជនណារំលោភបំពានដីគេមួយចង្អាម គេនឹងយកដីនោះប្រាំពីរជាន់ដាក់រុំលើគាត់នៅថ្ងៃបរលោក"។ (អាល់ពូខរីៈ២៣២១ មូស្លីមៈ១៦១០)

## ឧទាហរណ៍ខ្លះៗនៃភាពអយុត្តិធម៌ក្នុងការប្រតិបត្តិការផ្សេងៗ

1 ការបង្ខិតបង្ខំៈ គេមិនអនុញ្ញាតឱ្យមានការបង្ខិតបង្ខំឡើយក្នុងការប្រតិបត្តិការផ្សេងៗ ទោះជាការបង្ខិតបង្ខំនិងគាបសង្កត់ប្រភេទណាក៏ដោយ។ ហើយកិច្ចសន្យាមិនមានភាពត្រឹមត្រូវឡើយ លើកលែងតែមានការយល់ព្រមពេញចិត្ត។ អ្នកនាំសារបានមានប្រសាសន៍ថា "តាមពិតការលក់ដូរត្រឹមត្រូវនោះគឺដោយមានការយល់ព្រមពេញចិត្ត។ (អិពនូម៉ាហ្ជះៈ២១៨៥)

2 ការបោកប្រាស់ និងលួចបន្លំមនុស្សៈ ដើម្បីយកទ្រព្យសម្បត្តិរបស់ពួកគេដោយមិនត្រឹមត្រូវ។ វាគឺជាអំពើបាបដ៏ធ្ងន់ធ្ងរ។ អ្នកនាំសារបានមានប្រសាសន៍ថា "ហើយជនណាបោកប្រាស់ពួកយើង មិនមែនជាក្រុមរបស់ពួកយើងទេ"។ (មូស្លីមៈ១០១)
ហើយមូលហេតុដែលព្យាការីបានមានប្រសាសន៍ដូចនេះ គឺពិតណាស់អ្នកនាំសារបានដើរកាត់អាហារមួយពំនូក លោកក៏បានលូកដៃចូលក្នុងអាហារនោះ ស្រាប់តែម្រាមដៃរបស់គាត់មានសំណើមទឹក។ លោកក៏សួរថាៈ ឱម្ចាស់អាហារ! តើនេះជាអ្វីទៅ? គាត់បានឆ្លើយថាៈ "ឱអ្នកនាំសារ! វាត្រូវទឹកភ្លៀង។ លោកក៏បានតបវិញថា "ហេតុអ្វីបានជាអ្នក មិនដាក់វានៅលើអាហារដើម្បីឱ្យគេមើលឃើញ?ជនណាដែលបោកប្រាស់យើង មិនមែន ជាក្រុមរបស់យើងនោះទេ"។ (អាត់តៀរមីហ្ស៊ីៈ១៣១៥)



>ការយកទ្រព្យសម្បត្តិអ្នកដទៃដោយអយុត្តិធម៌ទោះបីជាតិចតួចក៏ដោយគឺស្ថិតក្នុងចំណោមបាបកម្ម និងឧក្រិដ្ឋកម្មដ៏ធំបំផុត។

3 លេងសើចលើច្បាប់ ដើម្បីយកទ្រព្យសម្បត្តិដោយអយុត្តិធម៌មិនត្រឹមត្រូវ។ ពិតណាស់មនុស្សខ្លះមានភាពឆ្លាតវៃ និងប្រាជ្ញាដែលអាចយកទ្រព្យសម្បត្តិអ្នកដទៃបានតាមរយៈផ្លូវច្បាប់។ ក៏ប៉ុន្តែការកាត់ក្ដីរបស់ចៅក្រមមិនអាចកែប្រែប្រការមិនត្រឹមត្រូវទៅជាប្រការត្រឹមត្រូវនោះទេ។ អ្នកនាំសារបានមានប្រសាសន៍ថា "ការពិត ខ្ញុំក៏ជាមនុស្សដែរ ហើយពួកអ្នកបានប្ដឹងតវ៉ាគ្នាមកចំពោះខ្ញុំ។ ជួនកាល អ្នកខ្លះពូកែនិយាយបញ្ជាក់ហេតុផលជាងអ្នកខ្លះទៀត។ ហេតុនេះ ខ្ញុំក៏កាត់ក្ដីតាមអ្វីដែលខ្ញុំបានលឺ។ ជនណា

ដែលខ្ញុំបានសម្រេចក្ដីឱ្យគាត់នូវកម្មសិទ្ធិរបស់បងប្អូនគាត់(គាត់មិនត្រូវទទួលយកឡើយ)។ ការពិតខ្ញុំកាត់ក្ដីឱ្យគាត់គឺមួយចំណែកនៃភ្លើងនរក"។(អាល់ពូខរី:៦៧៤៨ មូស្លីម:១៧១៣)

4 សំណូក: វាគឺជាការបង់ប្រាក់របស់បុគ្គលម្នាក់ ឬការផ្ដល់សេវាកម្មដើម្បីទទួលបានទ្រព្យអ្វីមួយ ដែលមិនមែនជារបស់គាត់ ហើយវាជាប្រភេទនៃភាពអយុត្តិធម៌ដែលអាក្រក់បំផុត និងជាអំពើបាបធ្ងន់ធ្ងរបំផុត។ ពិតណាស់ អ្នកនាំសារបានដាក់បណ្ដាសារលើអ្នកឱ្យសំណូក និងអ្នកដែលយកសំណូក"។ (អាត់តៀរមីហ្ស៊ី:១៣៣៧)

នៅពេលដែលការសូកប៉ាន់បានរីករាលដាលនៅក្នុងសង្គម វានឹងបំផ្លាញប្រព័ន្ធនៃសង្គម និងប៉ះពាល់ដល់ការអភិវឌ្ឍ និងភាពរុងរឿងនៃសង្គមនោះ។

## តើច្បាប់ចែងដូចម្ដេចចំពោះបុគ្គលម្នាក់ដែលបានចូលឥស្លាម ហើយមុនគាត់ចូលឥស្លាម គាត់បានយកទ្រព្យសម្បត្តិគេដោយមិនត្រឹមត្រូវ?(ដោយខុសច្បាប់)?

បុគ្គលណាដែលបានចូលឥស្លាម ហើយគាត់មានទ្រព្យទុច្ចរិតដែលគាត់បានយកពីការបោកប្រាស់មនុស្សនិងរំលោភបំពានលើពួកគេដោយការលួច ឬកេងបន្លំ និងអ្វីផ្សេងទៀត ចាំបាច់លើគាត់ត្រូវត្រលប់វាទៅឱ្យម្ចាស់របស់វាវិញ ប្រសិនបើគាត់ស្គាល់ពួកគេ ហើយគាត់មានលទ្ធភាពក្នុងការប្រគល់វាឱ្យពួកគេដោយគ្មានគ្រោះថ្នាក់លើគាត់។

ទោះបីជាវាបានកើតឡើងមុនពេលចូលឥស្លាមក៏ដោយ ក៏ទ្រព្យដែលស្ថិតនៅក្នុងដៃរបស់គាត់នោះគឺទទួលបានដោយការបោកប្រាស់ និងរំលោភបំពាន។ ដូច្នេះចាំបាច់គាត់ត្រូវបង្វិលត្រលប់ទ្រព្យទាំងនោះវិញប្រសិនបើគាត់មានលទ្ធភាព។ អល់ឡោះបានមានបន្ទូលថា "ពិតប្រាកដណាស់ អល់ឡោះបញ្ជាពួកអ្នកឱ្យប្រគល់បញ្ញើទាំងឡាយទៅឱ្យម្ចាស់របស់គេវិញ"។ (គម្ពីរគួរអាន ៤:៥៨)

ប្រសិនបើគាត់បានខិតខំស្វែងរកម្ចាស់វាហើយ នៅតែមិនជួបម្ចាស់របស់វាទៀតនោះ ចូរបរិច្ចាគវាទៅលើប្រការដែលល្អ ឬផ្លូវសប្បុរស។



> អ្នកនាំសារបានដាក់បណ្ដាសាលើអ្នកឱ្យសំណូក និងអ្នកដែលយកសំណូក។

# > ល្បែងស៊ីសង

## តើល្បែងស៊ីសងជាអ្វី ?

ល្បែងស៊ីសង គឺជាការប្រកួតប្រជែង និងការលេងល្បែងដែលគេដាក់លក្ខខណ្ឌរវាងអ្នកលេងពីរនាក់ ឬអ្នកប្រកួតពីរនាក់ ដោយនរណាម្នាក់ឈ្នះនឹងទទួលបានប្រាក់ពីអ្នកដែលចាញ់។ អ្នកដែលចូលរួម គឺស្ថិតនៅរវាងការទទួលបានប្រាក់ពីម្នាក់ទៀត ឬក៏គាត់ចាញ់ដែលត្រូវគេយកប្រាក់ពីគាត់វិញ។



> ល្បែងស៊ីសង ធ្វើឲ្យអ្នកដែលលេងវាក្លាយទៅជាញៀន

## ច្បាប់របស់វា

ល្បែងស៊ីសង គឺត្រូវបានគេហាមឃាត់ ហើយមានសេចក្ដីរាយការណ៍ជាច្រើនដែលបញ្ជាក់ពីការហាមឃាត់យ៉ាងតឹងរឹងទាក់ទងនឹងល្បែងស៊ីសងនេះនៅក្នុងគម្ពីរគួរអាន និងប្រសាសន៍របស់ព្យាការី ដូចជា ៖

1. អល់ឡោះបានចាត់ទុកបាបកម្មរបស់ល្បែងស៊ីសង និងគ្រោះថ្នាក់របស់វា គឺធំធេងជាងផលប្រយោជន៍ដែលទទួលបានពីវា។ អល់ឡោះបានមានបន្ទូលថា “ពួកគេនឹងសួរអ្នក( ព្យាការីមូហាំម៉ាត់ )អំពីស្រា និងល្បែងស៊ីសង។ ចូរអ្នកឆ្លើយថាៈ វាទាំងពីរនេះគឺមានបាបកម្មធំ តែក៏មានផលប្រយោជន៍ខ្លះដល់មនុស្សលោកដែរ។ ប៉ុន្តែបាបកម្មរបស់វាទាំងពីរគឺធំធេងជាងផលប្រយោជន៍របស់វាទាំងពីរទៅទៀត”។ ( គម្ពីរគួរអាន ២:២១៩ )

2. អល់ឡោះបានចាត់ទុកការលេងល្បែងស៊ីសង ជាប្រការមិនស្អាតស្អំ ដោយសារគ្រោះថ្នាក់របស់វាបានប៉ះពាល់ដល់បុគ្គលនិងសង្គម និងប្រើឱ្យជៀសឆ្ងាយ។ ហើយវាជាមូលហេតុដែលនាំឲ្យក្លាយជាសត្រូវ និងការស្អប់ខ្ពើមគ្នា និងជាមូលហេតុបោះបង់ចោលការសឡាត និងរំលឹកចំពោះអល់ឡោះ។ អល់ឡោះបានមានបន្ទូលថា “ឱបណ្ដាអ្នកមានជំនឿ! ពិតប្រាកដណាស់ស្រា ល្បែងស៊ីសង ការគោរពបូជារូបបដិមា និងជៀគ្រូទស្សន៍ទាយវាសនា គឺជាអំពើជ៏កខ្វក់នៃទង្វើរបស់ស្ហៃតន។ ដូច្នេះ ចូរពួកអ្នកចៀសវាងឱ្យឆ្ងាយពីវា សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។ ពិតប្រាកដណាស់ ស្ហៃតនចង់ធ្វើឱ្យពួកអ្នកក្លាយជាសត្រូវ ស្អប់ខ្ពើមគ្នាតាមរយៈស្រា និងល្បែងស៊ីសង ហើយវារារាំងពួកអ្នកអំពីការរំលឹកទៅចំពោះអល់ឡោះ និងការសឡាត។ ហេតុនេះចូរពួកអ្នកឈប់ជាបន្ទាន់”។ ( គម្ពីរគួរអាន ៥:៩០-៩១ )

## ល្បែងស៊ីសងបង្កគ្រោះថ្នាក់ដល់បុគ្គល និងសង្គម

ល្បែងស៊ីសងបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ទាំងទៅលើបុគ្គល និងសង្គមជាតិ ដូចជា ៖

1 វាធ្វើឱ្យមនុស្សក្លាយជាសត្រូវ និងស្អប់ខ្ពើមគ្នា។ ពិតណាស់ អ្នកដែលលេងល្បែងស៊ីសងភាគច្រើននៃពួកគេ គឺជាមិត្តភក្តិនិងមនុស្សជាទីស្រឡាញ់ ប៉ុន្តែនៅពេលណាដែលមាននរណាម្នាក់ឈ្នះ ហើយយកប្រាក់ពួកគេ ច្បាស់ណាស់ពួកគេនឹងខឹងសម្បា និងមានការអន់ចិត្តលើគេ ហើយនាំឱ្យពួកគេក្លាយជាសត្រូវ និងឈ្នានីសគ្នា។ ហើយពួកគេបានធ្វើល្បិចដើម្បីឱ្យគេធ្លាក់ក្នុងគ្រោះថ្នាក់ ដោយសាររូបគេបានធ្វើឱ្យពួកគេធ្លាក់ក្នុងភាពខាតបង់។ ទាំងនេះជាភាពជាក់ស្ដែងដែលមនុស្សទាំងអស់បានដឹង ហើយវាបានបញ្ជាក់យ៉ាងពិតដោយបន្ទូលអល់ឡោះថា “ពិតប្រាកដណាស់ ស្ហៃតនចង់ធ្វើឱ្យពួកអ្នកក្លាយជាសត្រូវនិងស្អប់ខ្ពើមគ្នាតាមរយៈស្រា និងល្បែងស៊ីសង”។ ហើយវាបានរារាំងមនុស្សអំពីកាតព្វកិច្ចសឡាតនិងការរំលឹកចំពោះអល់ឡោះ។ ដូចដែលអល់ឡោះបានរៀបរាប់ពីល្បិចស្ហៃតនក្នុងការពង្វក់

មនុស្សឱ្យលេងល្បែងស៊ីសងថា “ហើយវារាំងពួកអ្នកអំពីការរំលឹកទៅចំពោះអល់ឡោះ និងការប្រតិបត្តិសឡាត"។ (គម្ពីរគួរអាន ៥:៩០-៩១)

2 ល្បែងស៊ីសងបំផ្លាញប្រាក់និងទ្រព្យសម្បត្តិ និងបណ្តាលឱ្យអ្នកលេងល្បែងទទួលរងការខាតបង់យ៉ាងធ្ងន់ធ្ងរ។

3 ការលេងល្បែងស៊ីសង វានឹងបណ្តាលឱ្យក្លាយទៅជាការញៀន។ នៅពេលដែលគេលេងឈ្នះ ភាពលោភលន់នឹងកើនឡើងក្នុងការបន្តលេងល្បែងស៊ីសងទៀត ហើយគេនៅតែទទួលបានផលពីប្រាក់ដែលគេហាមឃាត់។ តែប្រសិនបើគេចាញ់ រូបគេនៅតែសង្ឃឹមថានឹងលេងឈ្នះវិញ និងត្រលប់យកអ្វីដែលគេបានចាញ់នោះមកវិញ។ ទាំងពីរនេះ គឺជាឧបសគ្គចំពោះការងារ និងបង្កើតបានជាការវិនាសអន្តរាយដល់សង្គម។

## ប្រភេទនៃល្បែងស៊ីសង

រូបភាពនិងប្រភេទនៃល្បែងស៊ីសង ពីអតីតកាលនិងបច្ចុប្បន្ននេះ គឺមានច្រើនទម្រង់។ ក្នុងចំណោមប្រភេទរបស់វានាសម័យកាលបច្ចុប្បន្នមានដូចជា ៖

1. រាល់ល្បែងទាំងអស់ដែលគេដាក់លក្ខខណ្ឌថា អ្នកដែលឈ្នះត្រូវយកប្រាក់ពីអ្នកដែលចាញ់។ ឧទាហរណ៍: មនុស្សមួយក្រុមបានលេងបៀជាមួយគ្នា ហើយពួកគេម្នាក់ៗត្រូវដាក់ចំនួនដាក់លាក់មួយនៃប្រាក់ ដោយអ្នកឈ្នះ នឹងត្រូវទទួលបានប្រាក់ទាំងអស់នោះ។
2. ការភ្នាល់ថាក្រុមមួយណាមួយឬអ្នកលេងណាម្នាក់ឈ្នះឬអ្វីផ្សេងទៀត។ អ្នកដែលភ្នាល់គ្នានោះ បានដាក់លុយកាក់មួយចំនួន ហើយម្នាក់ៗបានភ្នាល់ថា ក្រុមរបស់គេ ឬអ្នកលេងរបស់គេនឹងឈ្នះ។ ប្រសិនបើក្រុមរបស់គេឈ្នះ គេនឹងទទួលបានលុយនោះ តែប្រសិនបើក្រុមរបស់គេចាញ់ គេនឹងត្រូវបាត់បង់លុយនោះ។
3. ការផ្សងសំណាងនិងការចាក់ឆ្នោត។ ឧទាហរណ៍ គេទិញកាតមួយក្នុងតម្លៃមួយដុល្លាដើម្បីចូលរួមក្នុងការផ្សងសំណាងដើម្បីឈ្នះរង្វាន់១០០០ដុល្លារនៅពេលដែលគេចាប់ឆ្នោតត្រូវ។
4. គ្រប់ប្រភេទនៃការលេងល្បែងស៊ីសងទាំងអស់ដែលដំណើរការដោយចលនាថាមពលអគ្គិសនី និងអេឡិចត្រូនិក ឬបណ្តាញអ៊ីនធឺណិតដែលនៅក្នុងនោះ អ្នកលេងវានោះត្រូវប្រឈមមុខនឹងភាពមិនច្បាស់លាស់ពីរ គឺការចំណេញ ឬខាតបង់។



> គ្រប់ប្រភេទនៃការលេងល្បែងស៊ីសងទាំងអស់ដែលដំណើរការដោយចលនា ថាមពលអគ្គិសនី និងអេឡិចត្រូនិក ឬដោយលក្ខណៈបែបណាក៏ដោយគឺត្រូវបានគេហាមឃាត់ដែរ ហើយវាជាអំពើបាបដ៏ធំ។

# សុជីវធម៌ដែលឥស្លាមបានសង្កត់ធ្ងន់ក្នុងទំនាក់ទំនងប្រតិបត្តិការហិរញ្ញវត្ថុ

ប្រតិបត្តិការហិរញ្ញវត្ថុរបស់អ្នក

ដូចដែលឥស្លាមបានបកស្រាយយ៉ាងច្បាស់ពីច្បាប់ទាក់ទងនឹងប្រតិបត្តិការហិរញ្ញវត្ថុនោះដែរ ឥស្លាមក៏បានសង្កត់ធ្ងន់ចំពោះអ្នកប្រតិបត្តិការនូវសុជីវធម៌ និងសីលធម៌មួយចំនួនដូចជា ៖



## ភាពស្មោះត្រង់

ភាពស្មោះត្រង់ក្នុងប្រតិបត្តិការពាណិជ្ជកម្មជាមួយអ្នកដទៃ សូម្បីតែគេជាអ្នកមូស្លីម ឬមិនមែនជាមូស្លីម។ វាជាសុជីវធម៌សំខាន់សម្រាប់អ្នកមូស្លីមដែលគោរពតាមច្បាប់អល់ឡោះ ហើយបង្ហាញពីការសង្កត់ធ្ងន់លើវានោះដូចខាងក្រោម ៖

- អល់ឡោះបានមានបន្ទូលថា "ពិតប្រាកដណាស់ អល់ឡោះបញ្ជាពួកអ្នកឱ្យប្រគល់បញ្ញើទាំងឡាយទៅឱ្យម្ចាស់របស់គេវិញ"។ (គម្ពីរគួរអាន ៤:៥៨)
- អ្នកនាំសារបានរាប់បញ្ចូលការបាត់បង់ភាពស្មោះត្រង់និងការក្បត់សន្យា ជាសញ្ញាសម្គាល់របស់ពួកពុតត្បុត(មូណាហ្វិក) ដោយលោកបានមានប្រសាសន៍ថា "សញ្ញាសម្គាល់អ្នកពុតត្បុតមានបីគឺ នៅពេលដែលគេនិយាយ គេកុហក នៅពេលសន្យា គេមិនបំពេញតាមការសន្យា នៅពេលគេទុកចិត្តគាត់បោកប្រាស់គេ"។ (អាល់ពូខរី:៣៣ មូស្លីម:៥៩)
- ភាពស្មោះត្រង់ គឺជាលក្ខណៈសម្បត្តិដ៏សំខាន់សម្រាប់អ្នកមានជំនឿ។ អល់ឡោះបានមានបន្ទូលថា "បណ្ដាអ្នកដែលមានជំនឿពិតជាទទួលបានជោគជ័យ"។ រហូតដល់បន្ទូលទ្រង់ថា " ហើយនិងបណ្ដាអ្នកដែលថែរក្សានូវភាពស្មោះត្រង់ និងការសន្យារបស់ពួកគេ"។ ( គម្ពីរគួរអាន ២៣:១-៨)
- ពិតណាស់ អ្នកនាំសារត្រូវបានគេឱ្យងារគាត់នៅម៉ាក្កះ មុនពេលអល់ឡោះតែងតាំងគាត់ជាអ្នកនាំសារថា "ជាអ្នកស្មោះត្រង់ សច្ចៈ" ពីព្រោះគាត់ជានិម្មិត្តរូបនៃភាពស្មោះត្រង់ក្នុងទំនាក់ទំនង និងប្រតិបត្តិការនានារបស់គាត់។

## សេចក្តីទៀងត្រង់

សេចក្តីទៀងត្រង់និងភាពច្បាស់លាស់ គឺជាលក្ខណៈពិសេសដ៏សំខាន់ដែលឥស្លាមបានសង្កត់ធ្ងន់ទៅលើវា



- អ្នកនាំសារលោកបានមានប្រសាសន៍ចំពោះអ្នកលក់និងអ្នកទិញថា "ប្រសិនបើគេទាំងពីរមានសេចក្តីទៀងត្រង់និងបញ្ជាក់ច្បាស់ គេនឹងផ្តល់ភាពចម្រុងចម្រើនដល់គេទាំងពីរក្នុងការលក់ទិញរបស់គេទាំងពីរនោះ។តែប្រសិនបើគេលាក់លាមនិងកុហកនោះ គេនិងបបាត់ភាពចំរុងចម្រើននៃការលក់ទិញរបស់គេទាំងពីរនោះ"។(អាល់ពូខរី:១៩៧៣មូស្លីម:១៥៣២)

■ អ្នកនាំសារបានមានប្រសាសន៍ថា "ចូរពួកអ្នកប្រកាន់នូវសេចក្តីទៀងត្រង់។ ពិតណាស់ សេចក្តីទៀងត្រង់នាំទៅដល់ទង្វើកុសល ហើយទង្វើកុសលនាំទៅកាន់ឋានសួគ៌។ ហើយបុគ្គលខ្លះនៅតែនិយាយទៀងត្រង់ រហូតដល់ត្រូវគេកត់ត្រានៅនឹងអល់ឡោះថា ជាមនុស្សទៀងត្រង់បំផុត"។ (មូស្លីម ២៦០៧)

■ ឥស្លាមបានចាត់ទុកអ្នកដែលស្បថកុហកដើម្បីលើកសសើរទំនិញរបស់ខ្លួនដើម្បីឲ្យលក់ដាច់នោះ គឺគាត់បានប្រព្រឹត្តអំពើបាបយ៉ាងធំធេង។ អ្នកនាំសារបានមានប្រសាសន៍ថា "មនុស្សបីក្រុមដែលអល់ឡោះមិនមានបន្ទូលទៅកាន់ពួកគេទេនៅថ្ងៃបរលោក ហើយមិនមើលពួកគេទេ និងមិនសម្អាតពួកគេឡើយ ហើយសម្រាប់ពួកគេគឺទណ្ឌកម្មដ៏ឈឺផ្សាបំផុត: ហើយក្នុងនោះ គឺអ្នកស្បថភូតកុហកដើម្បីលក់ទំនិញរបស់ខ្លួន"។(មូស្លីម ១០៦)


3

## ភាពច្បាស់លាស់ និងការបំពេញការងារឲ្យបានល្អ

ជាកាតព្វកិច្ចលើមូស្លីមគ្រប់រូបដែលជាអ្នកផលិតឬកម្មករ ត្រូវមានជំនាញច្បាស់លាស់ និងត្រូវបំពេញការងារឱ្យមានប្រសិទ្ធភាពល្អទៅតាមគោលការណ៍និងឯកសិទ្ធរបស់ខ្លួន ដែលគាត់មិនត្រូវបោះបង់ចោលវាឡើយ។

■ អល់ឡោះបានកត់ត្រាឲ្យធ្វើល្អចំពោះអ្វីៗគ្រប់យ៉ាង ហើយបានដាក់បទបញ្ជាឱ្យធ្វើល្អចំពោះគ្រប់វិស័យនៃជីវិត សូម្បីតែអ្វីចំពោះអ្វីដែលជួនកាលពេលមើលដំបូងហាក់មិនអាចធ្វើល្អ ឬច្បាស់លាស់បាន ដូចជាការប្រមាញ់ និងការសម្លេះសត្វជាដើម។ អ្នកនាំសារបានមានប្រសាសន៍ថា "ពិតណាស់ អល់ឡោះបានដាក់បទបញ្ជាឱ្យធ្វើល្អចំពោះអ្វីៗទាំងអស់។ ហេតុនេះ នៅពេលពួកអ្នកសម្លាប់សត្វ (ដែលបង្ករគ្រោះថ្នាក់)ចូរពួកអ្នកសម្លាប់ដោយល្អប្រសើរ ហើយនៅពេលពួកអ្នកសំឡេះសត្វ ចូរពួកអ្នកសំឡេះក្នុងលក្ខណៈល្អប្រសើរ។ ចូរឱ្យពួកអ្នកសំលៀងកាំបិតឱ្យមុត ហើយធ្វើយ៉ាងណាឱ្យសត្វនោះស្លាប់ដោយស្រួលបំផុត"។(មូស្លីម ១៩៥៥)

■ អ្នកនាំសារបានចូលរួមមរណទុក្ខនៃការស្លាប់របស់មនុស្សម្នាក់ លោកបានណែនាំសហការីរបស់លោកអំពីការជីកផ្នូរនិងការបញ្ចុះសពឱ្យបានល្អប្រសើរ បន្ទាប់មកលោកក៏ក្រឡេកមើលពួកគេ ហើយបានមានប្រសាសន៍ថា "ទាំងនេះ វាមិនបានផ្តលផលប្រយោជន៍ឬបង្ករគ្រោះថ្នាក់អ្វីដល់សពឡើយ ក៏ប៉ុន្តែអល់ឡោះទ្រង់ស្រលាញ់បុគ្គលណាហើយដែលធ្វើកិច្ចការអ្វីមួយ គឺធ្វើបានយ៉ាងល្អប្រសើរ"។(អាល់ហៃហាគី ក្នុង ស៊ូអាពូលអ៊ីម៉ាន ៥៣១៥) ក្នុងឃ្លាមួយទៀត "ពិតណាស់អល់ឡោះស្រលាញ់ចំពោះបុគ្គលណាម្នាក់ក្នុងចំណោមពួកអ្នក ដែលកាលណាគាត់ធ្វើកិច្ចការអ្វីមួយគាត់ធ្វើវាដោយល្អឥតខ្ចោះ"។(អាពូយ៉ាក់ឡើ ៤៣៨៦ ស៊ូអាពូលអ៊ីម៉ាន ៥៣១២)



# ចំណីអាហាររបស់អ្នក
# ឆង័កេសផ្ទះរបស់អ្នក



# 8

ចំពោះចំណីអាហារដែលហាឡាល់(ចំណីអាហារដែលច្បាប់ឥស្លាមអនុញ្ញាត) គឺមានមានតួនាទីយ៉ាងសំខាន់នៅក្នុងសាសនាឥស្លាម ហើយវាជាមូលហេតុដែលគេទទួលយកការប្តូងស្ទង់ និងផ្តល់ភាពចម្រុងចម្រើននៅក្នុងទ្រព្យសម្បត្តិ និងក្រុមគ្រួសារ។ ហើយអត្ថន័យនៃអាហារដែលហាឡាល់(អនុញ្ញាត) គឺរាល់អាហារដែលគេអនុញ្ញាតិ និងទទួលបានតាមមធ្យោបាយផ្លូវត្រឹមត្រូវ និងដោយទ្រព្យសម្បត្តិសុច្ចរិត ដោយគ្មានការកេងប្រវ័ញ្ច និងរំលោភបំពានលើសិទ្ធិអ្នកដទៃ។

## មាតិកាជំពូក

ធាតុដើមនៃអាហារ និងភេសជ្ជៈ

ដំណាំ និងផល្លានុផល

សុរា និងជាតិអាល់កុល

គ្រឿងញៀន

អាហារសមុទ្រ

សត្វរស់នៅលើដី

- ការសម្លេះតាមច្បាប់ឥស្លាម
- ច្បាប់ដែលទាក់ទងនឹងសាច់ក្នុងភោជនីយដ្ឋាននិងកន្លែងលក់ដូររបស់អ្នកគ្មានជំនឿ(អ្នកមិនមែនឥស្លាម)

ការប្រមាញ់សត្វតាមច្បាប់ឥស្លាម

សុជីវធម៌នៃចំណីអាហារ និងភេសជ្ជៈ

# ចំណីអាហាររបស់អ្នក និងភេសជ្ជៈរបស់អ្នក

## ធាតុដើមនៃអាហារ និងភេសជ្ជៈ

ធាតុដើមនៃចំណីអាហារ និង ភេសជ្ជៈទាំងអស់ គឺត្រូវបានគេអនុញ្ញាត និងហាឡាល់(អាចហូបបាយ) លើកលែងតែអាហារមួយចំនួនដែលត្រូវគេហាមឃាត់(ហារ៉ាំ) ដោយសារតែវាបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្សចំពោះសុខភាព សីលធម៌ និងសាសនារបស់គេ។ ហើយពិតណាស់ អល់ឡោះបានផ្តល់ឱ្យមនុស្សដោយបង្កើតសម្រាប់ពួកគេនូវរាល់អ្វីគ្រប់យ៉ាងដែលមាននៅលើភពផែនដីនេះ ដើម្បីឱ្យពួកគេទាញយកផលប្រយោជន៍អំពីវា លើកលែងតែអ្វីដែលអល់ឡោះបានហាមឃាត់(ហារ៉ាំ)លើពួកគេ។ អល់ឡោះបានមានបន្ទូលថា "ទ្រង់គឺជាអ្នកដែលបានបង្កើតអ្វីៗទាំងអស់នៅលើផែនដីនេះសម្រាប់ពួកអ្នក"។ (គម្ពីរគួរអាន ២:២៩)

## >ដំណាំ និងផលានុផល

គ្រប់រុក្ខជាតិដែលមនុស្សដាំដុះ ឬយកវាពីព្រៃរហោស្ថាន ព្រៃស្តុក និងវាលស្មៅ និងរុក្ខជាតិផ្សិតគ្រប់ប្រភេទទាំងអស់ គឺត្រូវបានគេអនុញ្ញាតឱ្យបរិភោគ លើកលែងតែអ្វីដែលនាំឱ្យគ្រោះថ្នាក់ដល់ខ្លួនប្រាណ និងសុខភាព ឬធ្វើឱ្យបាត់បង់សតិសម្បជញ្ញៈ ដូចជាសុរា ឬគ្រឿងញៀន។ ពិតណាស់ វាត្រូវបានគេហាមឃាត់ដោយសារវាមានគ្រោះថ្នាក់ និងធ្វើឲ្យបាត់បង់សតិសម្បជញ្ញៈ។



# > សុរា និងជាតិអាល់កុល

គឺរាល់ៗអ្វីដែលធ្វើឱ្យវង្វេងវង្វាន់សតិ មានន័យថាធ្វើឱ្យវាលាយឡំគ្នា ឬគ្រប់ដណ្ដប់វា ឬបិទបាំងវា ឬប៉ះពាល់ដល់វា។ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា "រាល់ៗអ្វីដែលធ្វើឱ្យស្រវឹងគឺជាសុរា ហើយរាល់សុរាទាំងអស់ គឺត្រូវបានហាមឃាត់"។ (មូស្លីម:២០០៣)។ ទោះបីជាវាត្រូវបានគេផលិតពីផ្លែឈើក៏ដោយ ដូចជា ទំពាំងបាយជូ ល្មើស្រកៀល ផ្លែទីន និងទំពាំងបាយជូក្រៀម ឬធ្វើអំពីគ្រាប់ធញ្ញជាតិ ដូចជាស្រូវសាលី ស្រូវ ពោត និងអង្ករ ឬធ្វើអំពីសារធាតុផ្អែម ដូចជា ទឹកឃ្មុំជាដើម។ ដូចនេះ រាល់អ្វីៗដែលធ្វើឱ្យបាត់បង់សតិ វាគឺជាស្រាដែលត្រូវបានគេហាមឃាត់ ទោះបីជាមានឈ្មោះអ្វី ឬមានលក្ខណៈបែបណាក៏ដោយ រហូតសូម្បីតែគេយកទៅលាយជាមួយទឹកផ្លែឈើធម្មជាតិ ឬបង្អែម ឬសូកូឡាក៏ដោយ។

## ការថែរក្សាសតិស្មារតី

ពិតប្រាកដណាស់ សាសនាដ៏ឧត្ដុងឧត្ដមនេះបាននាំមកដើម្បីបញ្ជាក់យ៉ាងច្បាស់ពីផលប្រយោជន៍របស់មនុស្សនៅក្នុងលោកិយរបស់ពួកគេ និងបរលោករបស់ពួកគេ។ ហើយពិសេសជាងនេះទៅទៀតគឺការថែរក្សាប្រការចាំបាច់ទាំងប្រាំគឺ សាសនា ខ្លួនប្រាណ សតិបញ្ញា ទ្រព្យសម្បត្តិ និងពូជអម្បូរ។

សតិបញ្ញា គឺជាមូលដ្ឋាននៃការទទួលខុសត្រូវផ្នែកច្បាប់ ហើយជាមូលហេតុចម្បងក្នុងការផ្ដល់កិត្តិយស និងជាការជ្រើសរើសរបស់ម្ចាស់ចំពោះមនុស្ស។ ហើយច្បាប់ឥស្លាមបានថែរក្សា និងការពារវាអំពីរាល់ប្រការទាំងអស់ដែលធ្វើឱ្យសតិបញ្ញាបាត់បង់ ឬចុះខ្សោយ។

## ច្បាប់ឥស្លាមទាក់ទងនឹងសុរា

សុរា គឺស្ថិតក្នុងចំណោមអំពើបាបដ៏ធំ និងខ្លាំងក្លាបំផុត ហើយការហាមឃាត់អំពីសុរា និងការផ្ដោតសំខាន់នៅក្នុងកិច្ចការរបស់វានោះ ត្រូវបានបញ្ជាក់ដោយគម្ពីរគួរអាន និងប្រសាសន៍របស់ព្យាការី ដែលក្នុងនោះរួមមានដូចជា ៖

- អល់ឡោះបានមានបន្ទូលថា "ឱបណ្ដាអ្នកមានជំនឿ! ពិតប្រាកដណាស់ សុរា ល្បែងស៊ីសង ការគោរពបូជារូបបដិមា និងជឿព្រួញទស្សន៍ទាយវាសនា គឺជាអំពើដ៏កខ្វក់នៃទង្វើរបស់ស្ហៃតន។ ដូច្នេះ ចូរពួកអ្នកជៀសវាងឱ្យឆ្ងាយពីវា ដើម្បីឱ្យពួកអ្នកទទួលបានជោគជ័យ"។ (គម្ពីរគួរអាន ៥:៩០)។ អល់ឡោះបានឱ្យលក្ខណៈរបស់វា ថាជាអំពើដ៏កខ្វក់ ហើយពិតណាស់វាជាទង្វើរបស់ស្ហៃតន ហើយក៏បានប្រើឱ្យពួកយើងចៀសវាងឱ្យឆ្ងាយពីវា ប្រសិនបើយើងចង់ទទួលបានជ័យជំនះ និងជោគជ័យ។
- អ្នកនាំសារបានមានប្រសាសន៍ថា "រាល់ៗអ្វីដែលធ្វើឱ្យស្រវឹងគឺជាសុរា ហើយរាល់ៗអ្វីដែលធ្វើឱ្យស្រវឹងគឺត្រូវបានហាមឃាត់(ហារ៉ាំ)។ ជនណាហើយដែលទទួលទានសុរានៅក្នុងលោកិយនេះ ហើយគេបានស្លាប់ក្នុងសភាពជាអ្នកញៀនសុរា នោះគេនឹងមិនបានទទួលទានសុរាឡើយនៅថ្ងៃបរលោក"។ (មូស្លីម:២០០៣)
- អ្នកនាំសារបានលើកឡើងពីភាពប្រឆាំងគ្នានៃការទទួលទានសុរា និងជំនឿ ហើយនិងការថយចុះរបស់ជំនឿថា "គ្មានបុគ្គលណាម្នាក់ទទួលទានសុរាក្នុងខណៈពេលដែលរូបគេជាអ្នកមានជំនឿនោះឡើយ"។ (អាល់ពូខរី:៥២៥៦ មូស្លីម:៥៧)
- សាសនាឥស្លាមបានបង្គាប់ឱ្យដាក់ទណ្ឌកម្មទៅលើអ្នកដែលទទួលទានសុរា។ ដូច្នេះ វាធ្វើឲ្យបាត់បង់សេចក្ដីថ្លៃថ្នូររបស់ពួកគេ និងការធ្លាក់ចុះនៃភាពជឿជាក់របស់ពួកគេនៅក្នុងសង្គម។

- គេបានរៀបចំនូវទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត សម្រាប់អ្នកដែលនៅតែបន្តក្នុងការសេពសុរា និងអ្វីដែលស្រដៀងនឹងវារហូតដល់ស្លាប់ ដោយគេមិនបានសារភាពកំហុស កែខ្លួន(មុនពេលស្លាប់)។ អ្នកនាំសារបានមានប្រសាសន៍ថា "ពិតណាស់ចំពោះអល់ឡោះ គឺមានការព្រមានមួយសម្រាប់អ្នកដែលទទួលទានសុរា គឺនឹងឱ្យពួកគេផឹក ទីណាតុលខ៏ហ្បាល"។ (មូស្លីម:២០០២)។ "ទីណាតុលខ៏ហ្បាល" គឺជាសារធាតុរាវរបស់អ្នកនៅឋាននរក សំដៅលើសារធាតុរាវដែលអាក្រក់ និងខ្ទុះដែលចេញពីរាងកាយអ្នកដែលបានវិនាសដោយភ្លើងនរក។
- ហើយគ្រប់បុគ្គលដែលចូលរួម ឬជ្រោមជ្រែងទៅលើការបរិភោគសុរា មិនថាជិត ឬឆ្ងាយ គឺចូលនៅក្នុងការព្រមាននេះទាំងអស់។ "ពិតណាស់ អ្នកនាំសារបានដាក់បណ្តាសារចំពោះបញ្ហាពាក់ព័ន្ធនឹងសុរាគឺមាន១០ គឺអ្នកដែលផលិតសុរា អ្នកដែលឱ្យគេផលិតឱ្យគាត់ អ្នកដែលផឹកវា អ្នកដែលដឹកជញ្ជូនវា អ្នកដែលគេជញ្ជូនឱ្យ អ្នកដែលចាក់ស្រាឲ្យគេផឹក អ្នកដែលលក់ស្រាអ្នកដែលទទួលប្រយោជន៍ពីតម្លៃស្រា អ្នកដើលទិញវា និងអ្នកដែលឲ្យគេទិញ"។ (អាត់តៀរមីហ្សី:១២៩៥)

## > គ្រឿងញៀន

ការប្រើប្រាស់គ្រឿងញៀន សូម្បីតែប្រភពដើមរបស់វាជារុក្ខជាតិ ឬផលិតផល ហើយសូម្បីតែការប្រើប្រាស់វាដោយការស្រូបហើយបញ្ចេញមកវិញ ឬការលេប ឬការចាក់ក៏ដោយ វាគឺជាអំពើបាប និងជាអំពើដ៏អាក្រក់បំផុត។ជាមួយគ្នាផងដែរ វាធ្វើឱ្យបាត់បង់សតិ ហើយវាបានបំផ្លាញប្រព័ន្ធសរសៃប្រសាទរបស់មនុស្ស ហើយធ្វើឱ្យអ្នកដែលប្រើប្រាស់វាមានជំងឺសសៃប្រសាទ និងវិកលចរិកនានា និងប្រហែលជាអាចនាំឱ្យរូបគេស្លាប់ផងដែរ។ អល់ឡោះដែលជាម្ចាស់ដ៏មហាអាណិតស្រលាញ់បំផុតទៅចំពោះខ្ញុំបម្រើរបស់ទ្រង់ បានមានបន្ទូថា "ហើយចូរពួកអ្នកកុំសម្លាប់ខ្លួនឯង(ឬសម្លាប់អ្នកដទៃ)ឱ្យសោះ។ ពិតណាស់ អល់ឡោះអាណិតស្រលាញ់បំផុតចំពោះពួកអ្នក"។ (គម្ពីរគួរអាន ៤:២៩)

## > អាហារសមុទ្រ

អាហារសមុទ្រមានន័យថា អ្វីដែលមិនអាចរស់នៅបានទេ លើកលែងតែនៅក្នុងទឹក ដោយវាមិនអាចរស់នៅលើគោកបានឡើយ។ ហើយពាក្យថាសមុទ្រនៅត្រង់នេះ គឺមានន័យថាកន្លែងដែលមានទឹកច្រើន ហើយរាប់បញ្ចូលទៅក្នុងនោះដែរមានដូចជា ទន្លេ បឹង និងអ្វីដែលផ្សេងពីវាដែលមានទឹកច្រើន។

ហើយអាហារសមុទ្រទាំងអស់នោះ មិនថាវាសត្វ ឬជារុក្ខជាតិ បានប្រមាញ់វា ឬជួបវាស្លាប់ក៏ដោយ ពិតណាស់ ការបរិភោគវា គឺត្រូវបានគេអនុញ្ញាត អនុគ្រោះ បើសិនជាវាមិនផ្តល់គ្រោះថ្នាក់ដល់សុខភាព។ អល់ឡោះបានមានបន្ទូលថា "គេ(អល់ឡោះ)បានអនុញ្ញាតឱ្យពួកអ្នកនេសាទសត្វសមុទ្ររស់ និងយកសត្វសមុទ្រស្លាប់មកធ្វើជាអាហារ"។ (គម្ពីរគួរអាន ៥:៩៦)។ ការនេសាទគឺការយកវាបានដោយវានៅមានជីវិត ហើយអាហារគឺអ្វីដែលយកពីសមុទ្រក្រោយពីវាបានស្លាប់។



## > សត្វនៅលើគោក

គេដាក់លក្ខខណ្ឌចំពោះការអនុញ្ញាតឱ្យបរិភោគសត្វនៅលើដីនឹងពីរលក្ខខណ្ឌ ៖

1. វាគឺជាសត្វដែលគេអនុញ្ញាតឱ្យបរិភោគ
2. វាត្រូវបានប្រមាញ់ ឬសម្លេះវាទៅតាមក្បួនច្បាប់ឥស្លាម

### តើសត្វអ្វីខ្លះដែលគេអនុញ្ញាតឱ្យបរិភោគ?

ជាតុដើម សត្វទាំងអស់គឺហាឡាល់(អនុញ្ញាតឲ្យបរិភោគ) លើកលែងតែអ្វីដែលមានភស្តុតាងចង្អុលបង្ហាញពីគួរអាន និងប្រសាសន៍របស់ព្យាការី លើការហាមឃាត់របស់វា។

ហើយសត្វដែលគេហាមឃាត់មានដូចខាងក្រោម ៖

1 សត្វជ្រូក: វាជាសត្វដែលគេហាមឃាត់ និងកខ្វក់មួយនៅក្នុងសាសនាឥស្លាម គឺគ្រប់ផ្នែកទាំងអស់របស់វា និងអវៈយវៈរបស់វា និងអ្វីដែលចេញពីវា ដូចដែលអល់ឡោះបានមានបន្ទូលថា "គេ(អល់ឡោះ)បានហាមឃាត់ចំពោះពួកអ្នក(បរិភោគ)សត្វស្លាប់ ឈាម សាច់ជ្រូក"។(គម្ពីរគួរអាន ៥:៣)។ ហើយអល់ឡោះបានមានបន្ទូលទៀតថា "ឬសាច់ជ្រូក ពីព្រោះវាជារបស់ដែលកខ្វក់"។ (គម្ពីរគួរអាន ៦:១៤៥)

2 រាល់សត្វសាហាវដែលមានចង្កូម: មានន័យថា រាល់សត្វទាំងអស់ដែលស៊ីសាច់ជាអាហារ ទោះបីពួកវាមានទំហំធំដូចជាសត្វតោ និងសត្វខ្លា ឬតូចដូចជាសត្វឆ្មា និងអ្វីដែលផ្សេងពីវាក៏ដោយ។ ហើយក៏ដូច្នោះដែរ ចំពោះសត្វឆ្កែ។

3 រាល់សត្វបក្សីដែលមានក្រញ៉ាំ: វាគឺរាល់បក្សីទាំងអស់ដែលស៊ីសាច់ជាអាហារ ដូចជាសត្វស្ទាំង សត្វឥន្ទ្រី សត្វទីទុយ និងអ្វីផ្សេងពីនេះទៀត។

4 សត្វល្អិត: រាល់សត្វល្អិតទាំងអស់នៅលើដីគឺគេមិនអនុញ្ញាតឱ្យបរិភោគវាឡើយ ពីព្រោះគេមិនអាចសម្លេះវាបានឡើយ លើកលែងតែកណ្តូបគឺគេអនុញ្ញាតឱ្យបរិភោគ ដូចអ្នកនាំសារបានមានប្រសាសន៍ថា "គេបានអនុញ្ញាតឲ្យពួកយើង(អាចបរិភោគ)នូវសត្វស្លាប់ពីរប្រភេទ (ដោយមិនចាំបាច់សម្លេះ) គឺត្រី និងកណ្តូប"។ (អ៊ិពនូម៉ាហ្ជះ:៣២១៨)

5 សត្វពស់ និងសត្វកណ្ដុរ: គេបានហាមឃាត់មិនឱ្យបរិភោគវាឡើយ ហើយបានប្រើឱ្យយើងសម្លាប់វា។ អ្នកនាំសារបានមានប្រសាសន៍ថា "ប្រាំប្រភេទនៃសត្វអាក្រក់ដែលគេអាចសម្លាប់ពួកវាបានទាំងនៅក្នុងពេលដែលគេអនុញ្ញាត ឬពេលគេមិនអនុញ្ញាត(ពេលកាន់តំណមអៀហរ៉ម) គឺសត្វពស់ សត្វក្អែក កណ្ដុរ ឆ្កែឆ្កួត និងសត្វខ្លែងខ្មៅ)។ (អាល់ពូខរី:៣១៣៦ មូស្លីម:១១៩៨)

6 សត្វលាស្រុក: វាគឺសត្វលាដែលគេប្រើប្រាស់វានៅក្នុងភូមិសម្រាប់ជិះ និងដឹកជញ្ជូនឥវ៉ាន់។

## ប្រភេទសត្វដែលគេអនុញ្ញាត( ឲ្យទទួលទាន )

អ្វីដែលអល់ឡោះបានអនុញ្ញាតឲ្យទទួលទានបាននៃសត្វទាំងនេះ ត្រូវបានបែងចែកចេញជាពីរ៖

- ប្រភេទសត្វដែលរស់នៅក្នុងព្រៃ ហើយរត់គេចពីមនុស្ស ហើយមិនអាចចាប់វាយកមកសម្លេះបានទេៈ គេអនុញ្ញាតឱ្យយើងប្រមាញ់វាទៅតាមក្បួនច្បាប់នៃការប្រមាញ់របស់ឥស្លាម។

- ប្រភេទមួយទៀត គឺសត្វចិញ្ចឹមដែលគេអាចចាប់វាបានៈ គេមិនអនុញ្ញាតទេ លើកលែងតែសម្លេះវាទៅតាមក្បួនច្បាប់ឥស្លាម។




អល់ឡោះជាម្ចាស់បានអនុញ្ញាតឲ្យយើងអាចទទួលទានចំណីអាហាររបស់ពួកអះលីគីតាប ( ពួកជ្វីហ្វ និងពួកគ្រឹស្ទាន )កាលណាពួកគេបានសម្លេះវាទៅតាមរបៀបលក្ខណៈឥស្លាម។

## ការសម្លេះសត្វតាមក្បួនច្បាប់ឥស្លាម

វាជាការសម្លេះសត្វដែលមានគ្រប់លក្ខខណ្ឌនៃច្បាប់ឥស្លាម។
លក្ខខណ្ឌនៃការសម្លេះសត្វតាមក្បួនច្បាប់ឥស្លាមមាន ៖

1. អ្នកសម្លេះ គឺជាអ្នកដែលគេអនុញ្ញាតឱ្យសម្លេះសត្វបាន ពោលគឺ ត្រូវតែជាជនមូស្លីម ឬ អះលីគីតាប ( ពួកជ្វីហ្វ និងពួកគ្រឹស្ទាន ) ដែលដឹងខុសត្រូវ និងមានគោលបំណងសម្លេះ។
2. ឧបករណ៍ដែលបានប្រើសម្រាប់សម្លេះសត្វត្រូវតែត្រឹមត្រូវ ដែលអាចធ្វើឱ្យហូរឈាម និងមុត ដូចជាកាំបិតជាដើម។ ហើយគេបានហាមឃាត់មិនឱ្យប្រើអ្វីដែលអាចសម្លាប់សត្វដោយដាក់សង្កត់ធ្ងន់ពីលើ និងវាយក្បាលរបស់សត្វ ឬដោយការជុតវា ដូចជាការឆក់ដោយអគ្គិសនីជាដើម។
3. រំលឹកនាមអល់ឡោះសូត្រថា بسم الله ( ពីសមិលឡះ ) នៅពេលដែលគេកំរើកដៃដើម្បីសម្លេះ។
4. កាត់ផ្តាច់អ្វីដែលចាំបាច់ក្នុងការសម្លេះ គឺបំពង់អាហារ បំពង់ក និងសរសៃឈាមពីរ (ដែលនៅអមបំពង់ក ) ហើយវាជាសសៃសំខាន់នៃបំពង់ក ឬកាត់បីនៅក្នុងចំណោមបួននេះ។

ប្រសិនបើលក្ខខណ្ឌទាំងនេះត្រូវបានបំពេញ សាច់សត្វដែលបានសម្លេះគឺត្រូវបានគេអនុញ្ញាតឲ្យបរិភោគបាន។ តែប្រសិនបើខ្វះលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ ពិតណាស់ សាច់សត្វដែលបានសម្លេះនោះ គឺមិនត្រូវបានគេអនុញ្ញាតឲ្យបរិភោគនោះទេ។

## ប្រភេទសាច់ដែលបម្រើការនៅក្នុងភោជនីយដ្ឋាន និងហាង

**1** សត្វដែលបានសម្លេះដោយអ្នកមិនមែនមូស្លីម ឬអះលីគីតាបៈ ដូចជាអ្នកកាន់ពុទ្ធសាសនា ហិណ្ឌូសាសនា និងអ្នកគ្មានសាសនានោះ គឺត្រូវបានគេហាមឃាត់។ ហើយក៏ចូលក្នុងចំណុចនេះផងដែរ អ្វីដែលមាននៅក្នុងភោជនីយដ្ឋាន ឬហាងនៅក្នុងប្រទេសដែលភាគច្រើននៃប្រជាជនរបស់គេមិនមែនជាសាសនិកឥស្លាម និងអះលីគីតាប។ ដូចនេះ ច្បាប់ឥស្លាមមិនអនុញ្ញាតឲ្យទទួលទានឡើយ លើកលែងតែមានការបញ្ជាក់ថា សាច់នោះគឺហាឡាល់ (អាចហូបបាន )។

**2** សត្វដែលបានសម្លេះដោយជនមូស្លីម ឬអះលីគីតាបដែលស្របទៅតាមក្បួនច្បាប់ឥស្លាមៈ គឺត្រូវបានអនុញ្ញាតដោយការឯកភាពទាំងអស់។

3 សត្វដែលបានសម្លេះដោយជនមូស្លីម ឬអះលីគីតាប តែមិនអនុវត្តទៅតាមក្បួនច្បាប់ឥស្លាមៈ ដូចជាការឆក់ដោយអគ្គិសនី និងធ្វើឱ្យលង់ទឹកជាដើម គឺត្រូវបានហាមឃាត់ជាដាច់ខាត់។

4 ការសម្លេះវាដោយអះលីគីតាប តែគេមិនបានដឹងពីស្ថានភាពនៃការសម្លេះរបស់គេ ដូចគ្នាដែរ អ្វីដែលមាននៅក្នុងភោជនីយដ្ឋាននិងហាងរបស់ពួកគេៈ ពិតណាស់ជាតុដើមវា ការសម្លេះរបស់ពួកគេដែលត្រឹមត្រូវនោះ គឺត្រូវបានអនុញ្ញាតឱ្យបរិភោគបាន ជាមួយនឹងការប្រុងប្រយ័ត្នលើការសូត្រ(ពីសមិលឡះ)ក្នុងពេលបរិភោគ។ តែជាការល្អបំផុតនោះ គឺស្វែងរកសាច់ដែលហាឡាល់ដែលគេអនុញ្ញាតច្បាស់លាស់។

## > ការប្រមាញ់តាមក្បួនច្បាប់ឥស្លាម

ការប្រមាញ់សត្វ គឺត្រូវបានអនុញ្ញាតចំពោះពាហនៈ និងបក្សីដែលគេអនុញ្ញាតឱ្យបរិភោគវាបាន តែគេមិនអាចចាប់វាយកមកសម្លេះបាន មានដូចជាប្រភេទសត្វស្លាបនៅជនបទ និងទីរហោស្ថានដែលមិនបរិភោគសាច់ជាអាហារ ហើយក៏ដូចគ្នាដែរសត្វក្តាន់ និងទន្សាយព្រៃ និងអ្វីផ្សេងទៀត។

លក្ខខណ្ឌក្នុងការបរបាញ់មានដូចខាងក្រោម ៖

1 អ្នកដែលបរបាញ់នោះ គឺជាអ្នកដែលមានប្រាជ្ញាស្មារតី មានបំណងក្នុងការបរបាញ់ ជាជនមូស្លីម ឬអះលីគីតាប ហើយការបរបាញ់មិនអនុញ្ញាតទេចំពោះអ្នកដែលគោរពបដិមា និងមនុស្សដែលវិកលចរិត។

2 សត្វដែលគេគ្មានលទ្ធភាពក្នុងការចាប់យកមកសម្លេះ ដោយសារការរត់គេចចេញឆ្ងាយទៅ។ ប្រសិនបើគេមានលទ្ធភាពក្នុងការចាប់វាយកមកសម្លេះ ដូចជាមាន់ ពពែ និងគោជាដើមនោះ គឺមិនអនុញ្ញាតឱ្យបរបាញ់វាឡើយ។

3 ឧបករណ៍ក្នុងការប្រមាញ់ចាំបាច់ត្រូវតែមុត ដូចជា ព្រួញ និងគ្រាប់កាំភ្លើង ឬអ្វីផ្សេងទៀត។ ចំណែកឯការប្រមាញ់ដោយឧបករណ៍ធ្ងន់ៗដូចជា ដុំថ្ម ឬអ្វីផ្សេងទៀត គឺមិនអនុញ្ញាតឱ្យបរិភោគសាច់វាឡើយ លើកលែងតែគេបានទៅទាន់សត្វនោះមុនពេលដែលវាស្លាប់ ហើយគេបានយកវាមកសម្លេះទាន់។



4 រំលឹកនាមអល់ឡោះដោយសូត្រថា "ពីសមិលឡះ" មុនពេលដែលបាញ់ឧបករណ៍នោះទៅ។

5 ប្រសិនជាគេបានទៅទាន់សត្វ ឬបក្សី ក្រោយពីបរបាញ់វា តែវាមិនទាន់ស្លាប់ទេនោះ ចាំបាច់លើគេត្រូវតែសម្លេះវា។

6 ហាមឃាត់មិនឱ្យបរបាញ់សត្វដោយគ្មានគោលបំណងដើម្បីបរិភោគជាដាច់ខាត់ ដូចជាអ្នកដែលបរបាញ់សត្វដើម្បីការកម្សាន្ត និងការសប្បាយ បន្ទាប់មកគេមិនបរិភោគអ្វីដែលគេបានបរបាញ់នោះទេ។

# > សីលធម៌នៃការទទួលទានអាហារ និងភេសជ្ជៈ

អល់ឡោះបានដាក់ច្បាប់ជាច្រើននៃសីលធម៌ក្នុងការទទួលទានអាហារ និងភេសជ្ជៈ ដើម្បីបញ្ជាក់យ៉ាងច្បាស់អំពីគោលដៅ និងគតិបណ្ឌិតរបស់ព្រះ ដូចជាការរំលឹកអំពីឧបការគុណដែលអល់ឡោះបានប្រទានឱ្យមនុស្ស និងជាការការពារអំពីជំងឺផ្សេងៗ ព្រមទាំងហាមឃាត់ពីការខ្ជះខ្ជាយជាដើម។ ខ្លះៗអំពីសុជីវធម៌ទាំងនេះមានដូចជា



1. ហាមឃាត់មិនឱ្យបរិភោគ និងទទួលទានទឹកនៅក្នុងវត្ថុប្រើប្រាស់ដែលធ្វើពីមាស និងប្រាក់ ឬស្រោបអំពីវាទាំងពីរ ពីព្រោះការធ្វើដូច្នេះ វាគឺជាការខ្ជះខ្ជាយ និងលើសព្រំដែន និងជាការបំបាក់ទឹកចិត្តអ្នកក្រីក្រ។ អ្នកនាំសារបានមានប្រសាសន៍ថា "ចូរពួកអ្នកកុំផឹកទឹកនៅក្នុងឧបករណ៍ធ្វើអំពីមាស និងប្រាក់ ហើយកុំទទួលអាហារនៅក្នុងថាសធ្វើអំពីវាទាំងពីរនេះ។ ពិតណាស់ វាគឺសម្រាប់ពួកគេ (ពួកគ្មានជំនឿ) នៅលើលោកិយ ហើយសម្រាប់ពួកអ្នក(អ្នកមានជំនឿ)នៅថ្ងៃបរលោក"។ (អាល់ពូខរី:៥១១០ មូស្លីម:២០៦៧)
2. លាងសម្អាតដៃទាំងពីរ មុននិងក្រោយពេលបរិភោគអាហារ។
3. សូត្រ "ពីសមិលឡះ" (بسم الله) មុនពេលចាប់ផ្ដើមទទួលទានអាហារ និងភេសជ្ជៈ ហើយអត្ថន័យរបស់វានោះគឺ ខ្ញុំសុំពរជ័យ និងសុំជំនួយនឹងនាមរបស់អល់ឡោះ។ ប្រសិនបើគេភ្លេច ហើយនឹកឃើញវិញពេលកំពុងបរិភោគនោះចូរសូត្រថា "ពីសមិលឡើហី អៅវាឡើហ៊ូ វ៉ាអាឃីរ៉ើហ៊ូ" (بسم الله أَوَّلَهُ وَآخِرَه) (ខ្ញុំចាប់ផ្ដើមនឹងនាមរបស់អល់ឡោះ និងបញ្ចប់នឹងនាមរបស់ទ្រង់)។

   ពិតណាស់ ព្យាការីបានឃើញក្មេងតូចម្នាក់ដែលមិនបានយល់ដឹងច្បាស់ពីសីលធម៌នៃការទទួលទានអាហារ គាត់ក៏បានបង្រៀនក្មេងនោះថា "ឱក្មេងប្រុស! ចូរអ្នកសូត្រពីសមិលឡះ បរិភោគអាហារនឹងដៃស្ដាំ និងបរិភោគអ្វីដែលនៅជិតអ្នក"។ (អាល់ពូខរី:៥០៦១ មូស្លីម:២០២២)
4. បរិភោគអាហារ និងផឹកដោយដៃស្ដាំៈ អ្នកនាំសារបានមានប្រសាសន៍ថា (ចូរពួកអ្នកកុំបរិភោគនឹងដៃឆ្វេង។ ពិតណាស់ស្វៃតនវាស៊ីអាហារនឹងដៃឆ្វេង"។ (មូស្លីម:២០១៩)
5. គប្បីលើគេមិនត្រូវផឹកទឹក ឬបរិភោគអាហារដោយឈរឡើយ
6. បរិភោគអាហារដែលនៅជិតខ្លួនរបស់គេ មិនត្រូវបរិភោគអំពីកន្លែងអ្នកដទៃទេ ពីព្រោះការបរិភោគអំពីកន្លែងអ្នកដទៃ វាគឺជាសីលធម៌អាក្រក់មួយ។ ពិតណាស់អ្នកនាំសារបានមានប្រសាសន៍ទៅកាន់ក្មេងប្រុសនោះថា "ចូរបរិភោគនូវអ្វីដែលនៅជិតអ្នក"។

7 គប្បីរើសចំណែកអាហារដែលធ្លាក់ ហើយជូតអ្វីដែលប្រលាក់ចេញ ហើយបរិភោគវា នៅពេលណាដែលយើងអាចយកចេញនូវប្រការមិនល្អ។ ការធ្វើដូចនេះ បញ្ជាក់អំពីការថែរក្សាលើឧបការគុណរបស់អល់ឡោះ និងអាហារដែលទ្រង់បានប្រទានឲ្យ។

8 ហាមមិនឱ្យបន្ទុះបង្អាប់ រិះគន់ ឬមើលងាយអាហារឡើយ តែគប្បីសរសើរវា ឬនៅស្ងៀម។ "ព្យាការីរបស់ពួកយើងមិនធ្លាប់បន្ទុះបង្អាប់ចំណីអាហារឡើយ។ ប្រសិនបើលោកចូលចិត្ត លោកទទួលទានវា តែប្រសិនបើលោកមិនពេញចិត្តលោកទុកវា"។ (អាល់ពូខរី:៥០៩៣ មូស្លីម:២០៦៤)

9 ជៀសវាងការបរិភោគច្រើនហួសហេតុ ព្រោះថាការធ្វើដូច្នេះ ជាទូទៅបណ្តាលអោយមានជំងឺនិងខ្ជិល។ ដែលល្អប្រសើរនោះ គឺគួរបរិភោគល្មមៗបានហើយ(មិនឆ្អែតពេក) ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា "កូនចៅអាហ្ទាំមិនបានបំពេញអ្វីមួយអាក្រក់ជាងការបំពេញពោះឡើយ។ គ្រប់គ្រាន់ហើយសំរាប់កូនចៅអាហ្ទាំនូវអាហារប៉ុន្មានម៉ាត់ដែលធ្វើអោយឆ្អឹងខ្នងរបស់គាត់ត្រង់នោះ។ ហើយប្រសិនបើចាំបាច់ដោយខានមិនបាននោះ គឺ(ត្រូវទទួលទាន)១/៣(នៃក្រពះ)សម្រាប់អាហារ ១/៣សម្រាប់ទឹក និង១/៣ទៀតសម្រាប់ការដកដង្ហើម"។ (អាត់តៀរមីហ្ស៊ី:២៣៨០ អ៊ិពនូម៉ាហ្ជះ:៣៣៤៩)

10 ស្ប្រូតនៅពេលបរិភោគរួច សូត្រថា "អាល់ហាំទូលិលឡះ" (الحمد لله) ថ្លែងអំណរទៅចំពោះអល់ឡោះលើគុណបុណ្យនេះ ដែលទ្រង់បានផ្តល់អាហារមកឲ្យគេបរិភោគ ខណៈដែលមនុស្សជាច្រើនមិនទទួលបានវា។ ហើយក៏អាចបន្ថែមពីលើនេះទៀតដោយសូត្រថា ៖

អាល់ហាំទូ លិលឡើហ៊ិលឡើហ្សី អាត់អាម៉ានី ហើហ្សើ វ៉ារ៉ហ្សើក៏នីហ៊ី មិនហ្គ័យរី ហាវលិន មិននីវ៉ាលើគូវ៉ះ

الحمد لله الذي أطعمني هذا ورزقنيه من غير حول مني ولا قوة

(រាល់ការសរសើទាំងឡាយគឺសម្រាប់ អល់ឡោះដែលបានឱ្យខ្ញុំបានទទួលទានអាហារនេះ និងបានផ្តល់លាភសក្ការៈនេះដល់ខ្ញុំ ដោយវាមិនមែនដោយសារការខំប្រឹងប្រែង ឬអានុភាពរបស់ខ្ញុំឡើយ)។



> អ្នកនាំសារមូហាំម៉ាត់បានមានប្រសាសន៍ថា "ប្រាកដណាស់ អល់ឡោះពេញចិត្តចំពោះខ្ញុំបម្រើរបស់ទ្រង់ដែលគេទទួលទានចំណីអាហារ ហើយគេបានថ្លែងអំណរគុណទៅចំពោះទ្រង់ ឬទទួលទានទឹកហើយ រួចគេបានថ្លែងអំណរគុណចំពោះទ្រង់"។ (រាយការណ៍ដោយមូស្លីម)



# សម្លៀកបំពាក់របស់អ្នក



# 9

សម្លៀកបំពាក់ គឺជាឧបការគុណមួយក្នុងចំណោមឧបការគុណទាំងឡាយដែលអល់ឡោះបានផ្តល់មកឱ្យមនុស្ស ដូចដែលអល់ឡោះបានមានបន្ទូលថា "ឱកូនចៅអាហ្ទាំ! យើងបានបញ្ចុះមកឱ្យពួកអ្នកនូវសម្លៀកបំពាក់ដែលអាចបិទបាំងរាងកាយរបស់ពួកអ្នក និងសម្លៀកបំពាក់សម្រាប់តែងលម្អខ្លួន។ តែសម្លៀកបំពាក់កោតខ្លាច (ធ្វើអ្វីដែលអល់ឡោះប្រើ និងជៀសវាងពីការហាមឃាត់) នោះ វាប្រសើរជាងអ្វីៗទាំងអស់។ ទាំងនោះ គឺស្ថិតក្នុងចំណោមភស្តុតាងរបស់អល់ឡោះ សង្ឃឹមថា ពួកគេនឹងចងចាំ"។ (គម្ពីរគួរអាន ៧:២៦)

## មាតិកាជំពូក

### សម្លៀកបំពាក់នៅក្នុងសាសនាឥស្លាម

### សម្លៀកបំពាក់ដែលគេហាមឃាត់ (ហារ៉ាំ)

- សម្លៀកបំពាក់ដែលលេចចេញអាវ៉ាត់
- សម្លៀកបំពាក់ដែលមានភាពស្រដៀងគ្នារវាងប្រុស និងស្រី
- សម្លៀកបំពាក់ដែលដូចនឹងសម្លៀកបំពាក់អ្នកគ្មានជំនឿ
- សម្លៀកបំពាក់ដែលធ្វើឱ្យមានភាពក្អេងក្អាង និងក្រអឺតក្រទម
- សម្លៀកបំពាក់ដែលមានសសៃសូត្រ ឬមាស
- សម្លៀកបំពាក់ដែលមានភាពខ្ជះខ្ជាយ និងហួសកម្រិត

# សម្លៀកបំពាក់នៅក្នុងសាសនាឥស្លាម

សម្លៀកបំពាក់របស់អ្នកមានជំនឿចាំបាច់ត្រូវតែស្រស់ស្អាត និងមានអនាម័យ ជាពិសេស ក្នុងពេលទំនាក់ទំនងជាមួយនឹងមនុស្ស និងក្នុងពេលប្រតិបត្តិសឡាត ដូចដែលអល់ឡោះបានមានបន្ទូលថា "ឱកូនចៅអាហ្ទាំ(មនុស្សលោក)! ចូរពួកអ្នកលម្អសម្លៀកបំពាក់របស់ពួកអ្នកនៅរាល់ម៉ាស្ជិទ(ពេលសឡាត"។ (គម្ពីរគួរអាន ៧:៣១)

ហើយពិតណាស់ អល់ឡោះបានបង្គាប់បម្រើដល់មនុស្សឱ្យសម្អាតសម្លៀកបំពាក់របស់ពួកគេ និងរាងកាយរបស់ពួកគេ ពីព្រោះធ្វើដូច្នោះវាជាផ្នែកមួយនៃការនឹករលឹកដល់ឧបការគុណដែលអល់ឡោះបានផ្ដល់ឱ្យ។ អល់ឡោះបានមានបន្ទូលថា "ចូរអ្នកពោលថា តើអ្នកណាបានហាមឃាត់ពួកអ្នកនូវសម្លៀកបំពាក់ស្អាត និងលាភសក្ការៈដែលល្អ ដែលអល់ឡោះបានផ្ដល់ឱ្យបណ្ដាខ្ញុំរបស់ទ្រង់នោះ? ចូរអ្នកពោលថា វាគឺសម្រាប់បណ្ដាអ្នកដែលមានជំនឿក្នុងការរស់នៅលើលោកីយនេះ ជាពិសេសគឺ(សម្រាប់ពួកគេ)នៅថ្ងៃបរលោក។ ដូច្នោះដែរ យើងបញ្ជាក់ភស្តុតាងជាច្រើន(ច្បាប់ឥស្លាម)យ៉ាងច្បាស់សម្រាប់ក្រុមដែលចេះដឹង)។ (គម្ពីរគួរអាន ៧:៣២)

## សម្លៀកបំពាក់សម្រេចបាននូវសេចក្ដីត្រូវការជាច្រើន

1. បិទបាំងផ្នែកសំខាន់ៗនៃរាងកាយរបស់មនុស្សពីការមើលឃើញរបស់អ្នកដទៃ នៅក្រោមអារម្មណ៍សុភាពស្អាតស្អំទៅចំពោះមនុស្ស។

2. ការពាររាងកាយរបស់មនុស្សអំពីភាពក្ដៅត្រជាក់ និងគ្រោះថ្នាក់។ ក្ដៅនិងត្រជាក់ គឺជាការផ្លាស់ប្ដូរនៃអាកាសធាតុ រីឯគ្រោះថ្នាក់ គឺជាការបំពានទៅលើរាងកាយរបស់មនុស្ស។ អល់ឡោះបានមានបន្ទូលអំពីលក្ខណៈរបស់សម្លៀកបំពាក់ថា "ហើយទ្រង់បានធ្វើឱ្យមានសម្លៀកបំពាក់សម្រាប់ពួកអ្នកដើម្បីការពារពួកអ្នកពីកម្ដៅ(ឬរងា)និងសម្លៀកបំពាក់(អាវក្រោះ)ដើម្បីការពារពួកអ្នកក្នុងពេលសង្គ្រាម។ ដូច្នោះហើយទ្រង់បំពេញឧបការ-គុណរបស់ទ្រង់ដល់ពួកអ្នក ដើម្បីឱ្យពួកអ្នកប្រគល់ខ្លួនទៅចំពោះទ្រង់"។ ( គម្ពីរគួរអាន ១៦:៨១)



> សម្លៀកបំពាក់សម្រេចបាននូវអត្ថប្រយោជន៍ដល់មនុស្សជាច្រើន

## > ជាតុដើមនៃសម្លៀកបំពាក់



> សាសនាឥស្លាមមិនបានកំណត់ប្រភេទនៃសម្លៀកបំពាក់ដោយឡែកពីគេឡើយ ហើយជាការល្អប្រសើរគឺត្រូវស្លៀកសម្លៀកបំពាក់ស្របទៅតាមសម្លៀកបំពាក់របស់ប្រជាជនដែលរស់នៅក្នុងប្រទេសដែលគេអនុញ្ញាត លើកលែងតែអ្វីដែលជាករណីលើកលែង។

ឥស្លាមជាសាសនាស្អាតស្អំ ហើយមិនបានកំណត់ច្បាប់សម្រាប់មនុស្សក្នុងកិច្ចការនៃជីវិតរស់នៅរបស់ពួកគេទេ លើកលែងតែអ្វីដែលសមស្របទៅនឹងភាពស្អាតស្អំ សន្តិភាព និងអារម្មណ៍អាចទទួលយកបាន និងទូទៅសមហេតុសមផល។

ជាតុដើមនៃសម្លៀកបំពាក់របស់អ្នកមូស្លីម និងការតុបតែងខ្លួនរបស់ពួកគេ គឺត្រូវបានអនុញ្ញាត ៖

សាសនាឥស្លាមមិនបានកំណត់សម្រាប់មនុស្សនូវប្រភេទនៃសម្លៀកបំពាក់ដោយឡែកពីគេឡើយ។ ប៉ុន្តែច្បាប់បានទទួលស្គាល់រាល់សម្លៀកបំពាក់ទាំងអស់ ដរាបណាវាស្ថិតនៅក្នុងចំណោមប្រការដែលគេត្រូវការ ដោយមិនមានការបំពាន និងលើសព្រំដែន។

អ្នកនាំសារលោកបានស្លៀកសម្លៀកបំពាក់ដែលមាននៅក្នុងសម័យកាលរបស់លោក ហើយលោកមិនបានប្រើឱ្យស្លៀកសម្លៀកបំពាក់ជាក់លាក់ណាមួយឡើយ ហើយលោកក៏មិនបានហាមឃាត់ការស្លៀកពាក់ជាក់លាក់ណាមួយដែរ ក៏ប៉ុន្តែ លោកបានហាមឃាត់នូវលក្ខណៈជាក់លាក់នៃសម្លៀកបំពាក់មួយចំនួន។ ជាតុដើមនៃការទំនាក់ទំនងមានដូចជាសម្លៀកបំពាក់ គឺគេអនុញ្ញាតដោយមិនមានការហាមឃាត់ឡើយ លើកលែងតែមានភស្តុតាងបញ្ជាក់។ គោលការណ៍នេះ គឺផ្ទុយអំពីការគោរពសក្ការៈ ដែលជាតុដើមរបស់វា គឺមិនត្រូវអនុវត្តឡើយ ហើយច្បាប់ឥស្លាមក៏មិនបានបង្គាប់ប្រើឲ្យធ្វើវានោះដែរ លើកលែងតែមានភស្តុតាងបញ្ជាក់។

អ្នកនាំសារបានមានប្រសាសន៍ថា "ចូរពួកអ្នកបរិភោគ ចូរពួកអ្នកបរិច្ចាគ និងចូរពួកអ្នកស្លៀកសម្លៀកបំពាក់ចុះ ដោយមិនត្រូវមានការខ្ជះខ្ជាយ និងកំណាញ់(ត្បិតត្បៀត)ឡើយ"។ (អាន់ណាសាអ៊ី:២៥៥៩)

## សម្លៀកបំពាក់ដែលគេហាមឃាត់

1 សម្លៀកបំពាក់ដែលលេចចេញអាវ៉ាត់(ផ្នែកនៃរាងកាយដែលចាំបាច់ត្រូវបិតបាំង): ចាំបាច់លើជនមូស្លីមត្រូវបិទបាំងអាវ៉ាត់របស់ពួកគេដោយសម្លៀកបំពាក់ ដូចដែលអល់ឡោះបានមានបន្ទូលថា "យើងបានបញ្ចុះមកឱ្យពួកអ្នកនូវសម្លៀកបំពាក់ដែលអាចបិទបាំងរាងកាយរបស់ពួកអ្នក"។ (គម្ពីរគួរអាន ៧:២៦)

ហើយសាសនាឥស្លាមបានកំណត់ខ្នាតក្នុងការបិទបាំងអាវ៉ាត់(ផ្នែកនៃរាងកាយដែលចាំបាច់ត្រូវបិតបាំង)សម្រាប់បុរសនិងស្ត្រី។ ចំពោះបុរស អាវ៉ាត់(ផ្នែកនៃរាងកាយដែលចាំបាច់ត្រូវបិតបាំង) របស់ពួកគេ គឺចាប់ពីផ្ចិតរបស់គេ រហូតដល់ជង្គង់របស់គេ។ ហើយចំណែកឯអាវ៉ាត់(ផ្នែកនៃរាងកាយដែលចាំបាច់ត្រូវបិតបាំង)របស់ស្ត្រីពេលនៅមុខបុរសដែលអាចរៀបការជាមួយបាន គឺរាងកាយទាំងមូលរបស់នាង លើកលែងតែមុខ និងបាតដៃទាំងពីរ។

ហើយមិនអនុញ្ញាតឱ្យបិទបាំងដោយសម្លៀកបំពាក់ដែលរឹបចង្អៀតដែលអាចកំណត់(មើលយល់) ផ្នែកៗនៃរាងកាយរបស់គេនោះទេ ហើយក៏មិនត្រូវស្តើងពេកដែលអាចចេញ(មើលឃើញ)ខ្លួនប្រាណខាងក្នុងនោះដែរ។ ជាការពិតណាស់ អល់ឡោះបានព្រមានដល់អ្នកដែលស្លៀកសម្លៀកបំពាក់ដែលអាចមើលឃើញអាវ៉ាត់របស់គេនោះ ដោយអ្នកនាំសារបានមានប្រសាសន៍ថា “ពីរក្រុមស្ថិតក្នុងចំណោមអ្នកដែលចូលឋាននរក” ហើយលោកបានរំលឹកថា "គឺស្ត្រីដែលស្លៀកពាក់ស្តើងចេញអៅព៉ោះ”)

2 សម្លៀកបំពាក់ដែលប្រដូចទៅនឹងភេទទាំងពីរៈ មានន័យថាគឺការប្រដូចខ្លួនបុរសទៅនឹងស្ត្រីដោយការស្លៀកសម្លៀកបំពាក់ដែលសម្រាប់តែស្ត្រីប៉ុណ្ណោះ។ ហើយក៏ដូចគ្នាផងដែរការប្រដូចស្ត្រីទៅនឹងបុរស។ ទង្វើបែបនេះគឺគេហាមឃាត់ហើយវាជាបាបកម្មមួយនៃបាបកម្មកម្រិតធ្ងន់។ ហើយគេរាប់បញ្ចូលទៅក្នុងវានោះដែរ គឺការប្រដូចរបស់ពួកគេនៅក្នុងការនិយាយស្តី ការដើរ និងកាយវិការ។ "ពិតណាស់ អ្នកនាំសារបានដាក់បណ្តាសារលើបុរសដែលស្លៀកសម្លៀកបំពាក់របស់ស្ត្រី និងស្ត្រីដែលស្លៀសម្លៀកបំពាក់បុរស"។ (អាពូហ្ទាវូទ:៤០៩៨)។ ក៏ដូច្នោះដែរ "អ្នកនាំសារបានដាក់បណ្តាសារលើបុរសដែលប្រដូចខ្លួនទៅនឹងស្ត្រី និងស្ត្រីដែលប្រដូចខ្លួនទៅនឹងបុរស"។ (អាល់ពូខរី:៥៥៤៦)។ ហើយបណ្តាសារមានន័យថា បណ្តេញចេញឲ្យឆ្ងាយអំពីការអាណិតស្រលាញ់របស់អល់ឡោះ។ ឥស្លាមចង់ឱ្យទម្លាប់របស់បុរស និងរូបរាងកាយរបស់ពួកគេមានភាពខុសប្លែកពីស្ត្រី ហើយសម្រាប់ស្ត្រីក៏ដូចគ្នាដែរ។ នោះហើយជាអ្វីដែលមានពីធម្មជាតិពីកំណើតដ៏ស្អាតស្អំ និងជាប្រការត្រឹមត្រូវសមហេតុសមផល។

3 សម្លៀកបំពាក់ដែលដូចនឹងអ្នកគ្មានជំនឿ ដោយវាជាសម្លៀកបំពាក់ជាក់លាក់របស់ពួកគេ ដូចជាសម្លៀកបំពាក់លោកសង្ឃ និងអាចារ្យ ការពាក់រូបឈើឆ្កាង និងអ្វីដែលជាសញ្ញាជាក់លាក់របស់សាសនាណាមួយ។ សម្លៀកបំពាក់ទាំងនោះត្រូវបានគេហាមមិនឱ្យពាក់វានោះទេ ដោយអ្នកនាំសារបានមានប្រសាសន៍ថា “ជនណាហើយដែលប្រដូចខ្លួនទៅនឹងក្រុមណាមួយ ពិតណាស់ រូបគេគឺជាផ្នែកមួយនៃក្រុមនោះ"។ (អាពូហ្ទាវូទ ៤០៣១)។ រួមបញ្ចូលទៅក្នុងការប្រដូចនោះផងដែរ គឺការស្លៀកសម្លៀកបំពាក់ដែលមាននិមិត្តសញ្ញាជាក់លាក់ពីសាសនាដទៃ ឬនិកាយដែលវង្វេង។ ការប្រដូចនេះជាភស្តុតាងបង្ហាញពីការអសីលធម៌ និងការមិនស្មោះត្រង់នឹងខ្លួនលើអ្វីដែលជាសិទ្ធិរបស់មនុស្ស។

ហើយមិនមែនជាការប្រដូចនោះទេ ប្រសិនបើអ្នកមូស្លីមស្លៀកសម្លៀកបំពាក់ដែលល្បីសុះសាយនៅក្នុងប្រទេសរបស់គាត់ សូម្បីតែភាគច្រើនមនុស្សគ្មានជំនឿស្លៀកពាក់វាក៏ដោយ។ ពិតណាស់ អ្នកនាំសារលោកបានស្លៀកសម្លៀកបំពាក់ដូចជាសម្លៀកបំពាក់អ្នកគ្មានជំនឿនៃក្រុមគូរ៉ៃស្ហដែរ លើកលែងតែអ្វីដែលមានភស្តុតាងបញ្ជាក់ពីការហាមឃាត់ចំពោះវា។

4 សម្លៀកបំពាក់ដែលធ្វើឱ្យមានភាពក្អេងក្អាង និងក្រអឺតក្រទមៈ ពិតណាស់ អ្នកនាំសារលោកបានមានប្រសាសន៍ថា “មិនបានចូលក្នុងឋានសួគ៌ឡើយ ជនណាហើយដែលមានភាពក្រអឺតក្រទមនៅក្នុងចិត្តរបស់វាសូម្បីតែទម្ងន់ប៉ុនល្អងធូលីក៏ដោយ”។ (មូស្លីម ៩១)

ដូចនេះហើយ ឥស្លាមបានហាមឃាត់អំពីការស្លៀកសារុង(ឬខោ)ហៀរផុតក្អែកគោលសម្រាប់បុរសដោយសារការធ្វើដូច្នោះជាមូលហេតុនាំឱ្យមានភាពក្អេងក្អាង និងក្រអឺតក្រទម។ អ្នកនាំសារលោកបានមានប្រសាសន៍ថា "ជនណាស្លៀកសារុង(ឬខោ)ហៀរកែងជើងដោយក្រអឺតក្រទមនោះ អល់ឡោះនឹងមិនមើលទៅកាន់គេឡើយនៅថ្ងៃបរលោក"។ (អាល់ពូខរីៈ៣៤៦៥ មូស្លីមៈ២០៨៥)

ហើយឥស្លាមហាមឃាត់ពីការសម្លៀកបំពាក់ដែលល្បីល្បាញ ពោលគឺសម្លៀកបំពាក់ដែលធ្វើឱ្យមនុស្សមានការចាប់អារម្មណ៍ខ្លាំងនៅពេលដែលបុគ្គលណាម្នាក់ស្លៀកវា ហើយពួកគេនឹងជជែកគ្នាអំពីវា និងធ្វើឱ្យអ្នកដែលស្លៀកវាមានភាពល្បីល្បាញ ដោយសារវាចម្លែក ឬមនុស្សស្អប់ខ្ពើមវាដោយមូលហេតុរូបរាង និងពណ៌របស់វាមិនធម្មតា ឬធ្វើឱ្យអ្នកដែលស្លៀកវាក្លាយជាអ្នកមានមោទនភាព និងក្អេងក្អាង។ អ្នកនាំសារបានមានប្រសាសន៍ថា “ជនណាហើយស្លៀកសម្លៀកបំពាក់ដែលល្បីល្បាញនៅក្នុងលោកិយនេះ អល់ឡោះនឹងឱ្យរូបគេស្លៀកសម្លៀកបំពាក់ដែលធ្វើឱ្យគេអាម៉ាស់នៅថ្ងៃបរលោក”។ (អះម៉ាត់ៈ៥៦៦៤ អ៊ិពនូម៉ាហ្ជះ ៣៦០៧)

5 សម្លៀកបំពាក់ដែលមានមាស ឬក៏មានសសៃសូត្រធម្មជាតិ ជាពិសេសសម្រាប់បុរស។ ពិតណាស់សាសនាឥស្លាមបានហាមឃាត់វាទាំងពីរមកលើបុរស ដូចដែលអ្នកនាំសារបានមានប្រសាសន៍អំពីមាស និងសូត្រថា “ពិតណាស់វាទាំងពីរនេះគឺត្រូវបានហាមឃាត់មកលើបុរសៗនៃប្រជាជាតិខ្ញុំ ហើយអនុញ្ញាតសម្រាប់ស្ត្រី”។ (អ៊ិពនូម៉ាហ្ជះៈ៣៥៩៥ អាពូហ្ទាវូទៈ៤០៥៧)

សូត្រដែលគេហាមឃាត់លើបុរសនោះ គឺសំដៅលើសូត្រធម្មជាតិដែលគេដកយកវាចេញពីដង្កូវនាង។

6 សម្លៀកបំពាក់ដែលមានភាពខ្ជះខ្ជាយ និងហួសកម្រិតៈ អ្នកនាំសារបានមានប្រសាសន៍ថា “ចូរពួកអ្នកបរិភោគ ចូរពួកអ្នកបរិច្ចាគ និងចូរពួកអ្នកស្លៀកសម្លៀកបំពាក់ចុះ ដោយមិនត្រូវមានការខ្ជះខ្ជាយ និងកំនាញ់(ត្បិតត្បៀត)នោះទេ”។ (អាន់ណាសាអ៊ីៈ២៥៥៩)

ហើយវាមានភាពខុសគ្នាអាស្រ័យលើការប្រែប្រួលស្ថានភាពរបស់អ្នកដែលស្លៀកពាក់វា។ សម្រាប់អ្នកមាន គេអាចទិញសម្លៀកបំពាក់ដែលអ្នកក្រមិនសាកសមនឹងទិញវា ដោយធៀបទៅនឹងទ្រព្យសម្បត្តិរបស់ពួកគេ ប្រាក់ចំណូលប្រចាំខែ និងការចំណាយនានា ព្រមទាំងសិទ្ធិដទៃទៀតដែលនៅក្រោមការគ្រប់គ្រងរបស់គេ។ សម្លៀកបំពាក់មួយវាអាចជាការខ្ជះខ្ជាយសម្រាប់អ្នកក្រ តែវាមិនមែនជាការខ្ជះខ្ជាយទេសម្រាប់អ្នកមាន។



> គេបានហាមឃាត់ការខ្ជះខ្ជាយនៅក្នុងសម្លៀកបំពាក់ ហើយវាខុសគ្នាទៅតាមប្រាក់ចំណូល និងអ្វីដែលនៅក្រោមការគ្រប់គ្រងរបស់គេ។



# គ្រួសាររបស់អ្នក



# 10

សាសនាឥស្លាមបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើស្ថេរភាព និងលំនឹងក្នុងគ្រួសារ ហើយនិងថែរក្សាវាអំពីប្រការដែលធ្វើឱ្យប៉ះពាល់ដល់វា និងបំផ្លាញសុភមង្គលរបស់វា ពីព្រោះសេចក្ដីល្អនៅក្នុងក្រុមគ្រួសារ និងសង្គម វានឹងជានាដល់សេចក្ដីល្អរបស់បុគ្គល និងសង្គមជាលក្ខណៈទូទៅ។

## មាតិកាជំពូក


ឋានៈគ្រួសារនៅក្នុងសាសនាឥស្លាម

ឋានៈស្ត្រីនៅក្នុងសាសនាឥស្លាម

- ស្ត្រីត្រូវបានឥស្លាមយកចិត្តទុកដាក់ថែទាំចំពោះពួកនាង
- គ្មានជម្លោះទេរវាងភេទទាំងពីរ
- ប្រភេទស្ត្រីចំពោះបុរស
- គោលការណ៍ទំនាក់ទំនងរវាងបុរសនិងស្ត្រីដែលអាចរៀបការជាមួយបាន
- ដែនកំណត់នៃហ៊ីហ្ជាប

អាពាហ៍ពិពាហ៍ក្នុងសាសនាឥស្លាម

សិទ្ធិរបស់ប្ដី និងប្រពន្ធ

ការយកប្រពន្ធច្រើន( ពហុពន្ធភាព )

ការលែងលះ

សិទ្ធិរបស់ឪពុក ម្ដាយ

សិទ្ធិរបស់កូនៗ

## > ឋានៈគ្រួសារនៅក្នុងសាសនាឥស្លាម

សាសនាឥស្លាមបានបង្ហាញពីការយកចិត្តទុកដាក់ចំពោះគ្រួសារ ដូចអ្វីដែលមាននៅខាងក្រោមនេះ៖

### 1 ឥស្លាមបានសង្កត់ធ្ងន់លើការចាប់ផ្តើមរៀបអាពាហ៍ពិពាហ៍ និងការបង្កើតគ្រួសារ ហើយបានចាត់ទុកវាជាកិច្ចការដ៏ឧត្តុងឧត្តម្ភ និងជាមាគ៌ារបស់បណ្តាអ្នកនាំសារទាំងឡាយ

ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា“ប៉ុន្តែខ្ញុំបួសហើយខ្ញុំស្រាយ ខ្ញុំប្រតិបត្តិសឡាតហើយខ្ញុំគេង ហើយខ្ញុំរៀបការជាមួយស្ត្រី។ បុគ្គលណាមិនពេញចិត្តនឹងមាគ៌ារបស់ខ្ញុំ បុគ្គលនោះមិនស្ថិតនៅក្នុងក្រុមរបស់ខ្ញុំឡើយ”។ (អាល់ពូខរីៈ៤៧៧៦ មូស្លីមៈ១៤០១)

- គម្ពីរគួរអានបានចាត់ទុកថា វាជាការប្រោសប្រទាន និងជាភស្តុតាងដ៏អស្ចារ្យដែលអល់ឡោះបានបង្កើតឱ្យមានការរួមរស់ ការស្រលាញ់គ្នា ការអាណិតអាសូរគ្នា និងការរស់នៅជាមួយគ្នារវាងស្វាមីនិងភរិយា។ អល់ឡោះបានមានបន្ទូលថា “ហើយក្នុងចំណោមភស្តុតាងរបស់ទ្រង់ គឺទ្រង់បានបង្កើតឱ្យពួកអ្នកនូវភរិយាចេញពីខ្លួនពួកអ្នក ដើម្បីឱ្យពួកអ្នកមានភាពកក់ក្តៅជាមួយនាង។ ហើយទ្រង់បានបង្កើតឱ្យមានការស្រលាញ់ និងការអាណិតអាសូររវាងពួកអ្នក”។ (គម្ពីរគួរអាន ៣០:២១)
- ឥស្លាមបានប្រើឱ្យផ្តល់ភាពងាយស្រួលក្នុងការរៀបអាពាហ៍ពិពាហ៍ និងជួយដល់អ្នកដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ដើម្បីទប់ស្កាត់តណ្ហារបស់ខ្លួនគេ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “បីក្រុម មានសិទ្ធិឱ្យអល់ឡោះជួយដល់ពួកគេ” ហើយនៅក្នុងចំណោមនោះគឺ “អ្នករៀបការដែលមានបំណងដើម្បីទប់ស្កាត់តណ្ហារបស់ខ្លួនកុំឱ្យប្រព្រឹត្តប្រការដែលច្បាប់ហាមឃាត់”។ (អាត់តៀរមីហ្ស៊ី ១៦៥៥)
- ឥស្លាមបានបង្គាប់ប្រើយុវជនឱ្យរៀបអាពាហ៍ពិពាហ៍នៅក្នុងពេលដែលពួកគេមានកំលាំងមាំមួន និងមានសមត្ថភាព ដែលជាហេតុធ្វើឱ្យពួកគេមានការរួមរស់ និងមានភាពនឹងនរ ហើយក៏ទទួលបានដំណោះស្រាយស្របច្បាប់ដើម្បីទប់ស្កាត់តណ្ហា និងចំណង់ផ្លូវភេទដ៏ខ្លាំងក្លារបស់ពួកគេ។

### 2 ឥស្លាមបានផ្តល់ការគោរពយ៉ាងពេញលេញចំពោះសមាជិកគ្រប់រូបក្នុងគ្រួសារ ទោះបីជាបុរស ឬស្ត្រីក៏ដោយ។

ឥស្លាមបានចាត់ទុកឪពុកម្តាយជាអ្នកទទួលខុសត្រូវខ្ពស់បំផុតក្នុងការអប់រំកូនៗរបស់ពួកគាត់។ អំពី អាប់ទុលឡោះ កូន អូមើរ គាត់បានលឺអ្នកនាំសារបានមានប្រសាសន៍ថា “ពួកអ្នកទាំងអស់គឺជាអ្នកមើលការខុសត្រូវ ហើយនឹងត្រូវទទួលខុសត្រូវលើអ្វីដែលរូបគេមើលការខុសត្រូវនោះ។ មេដឹកនាំ គឺជាអ្នកមើលការខុសត្រូវ ហើយត្រូវទទួលខុសត្រូវចំពោះអ្នកនៅក្រោមការគ្រប់គ្រងរបស់គាត់។ បុរស គឺជាអ្នកមើលការខុសត្រូវចំពោះគ្រួសាររបស់គេ ហើយនឹងត្រូវទទួលខុសត្រូវអ្នកនៅក្រោមការគ្រប់គ្រងរបស់គេ។ ស្ត្រី គឺជាអ្នកមើលការខុសត្រូវផ្ទះស្វាមីរបស់នាង ហើយត្រូវទទួលខុសត្រូវអ្នកនៅក្រោមការគ្រប់គ្រងរបស់នាង។ អ្នកបម្រើ គឺជាអ្នកមើលការខុសត្រូវចំពោះទ្រព្យសម្បត្តិចៅហ្វាយរបស់គាត់ ហើយត្រូវទទួលខុសត្រូវចំពោះអ្វីដែលគាត់មើលការខុសត្រូវនោះ”។ (អាល់ពូខរីៈ៨៥៣ មូស្លីមៈ១៨២៩)



> គម្ពីរគួរអានបានរាប់បញ្ចូលការរួមរស់ ការស្រលាញ់ និងការអាណិតអាសូររវាងប្តីប្រពន្ធជាឧបការគុណដ៏ធំធេងបំផុត។

គ្រួសាររបស់អ្នក

## 3 ឥស្លាមយកចិត្តទុកដាក់លើការបណ្ដុះគោលការណ៍នៃការគោរព និងលើកតម្កើនចំពោះឪពុកម្ដាយ មើលថែពួកគាត់ និងគោរពតាមបទបញ្ជារបស់ពួកគាត់រហូតដល់ពួកគាត់លាចាកលោកនេះទៅ។

ទោះបីជាកូនប្រុស ឬកូនស្រីស្ថិតក្នុងវ័យណាក៏ដោយ ក៏ចាំបាច់លើពួកគេត្រូវគោរព និងធ្វើល្អទៅចំពោះពួកគាត់ដែរ។ ពិតណាស់ អល់ឡោះបានភ្ជាប់ការធ្វើល្អចំពោះគាត់ទាំងពីរជាមួយនឹងការគោរពសក្ការៈទៅចំពោះទ្រង់ ហើយបានហាមឃាត់មិនឱ្យជ្រុលជ្រួសពាក្យសំដី ឬកាយវិការទៅលើគាត់ទាំងពីរឡើយ សូម្បីតែការប្រើប្រាស់ពាក្យសំដី ឬសម្លេងដែលបង្ហាញពីភាពធុញទ្រាន់ចំពោះគាត់ទាំងពីរក៏ដោយ។ អល់ឡោះបានមានបន្ទូលថា “ហើយម្ចាស់របស់អ្នកបានបញ្ជាថា ពួកអ្នកមិនត្រូវគោរពសក្ការៈ(ចំពោះអ្វី)ក្រៅពីទ្រង់ឡើយ ហើយចូរពួកអ្នកធ្វើល្អទៅចំពោះឪពុកម្ដាយ។ ប្រសិនបើម្នាក់នៃគាត់ទាំងពីរ ឬគាត់ទាំងពីរមានវ័យចាស់ជរារស់នៅជាមួយអ្នក ចូរអ្នកកុំនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសំដីមិនសមរម្យ ឬគំហកដាក់គាត់ទាំងពីរឱ្យសោះ។ តែអ្នកត្រូវនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសំដីណាដែលទន់ភ្លន់បំផុត”។ (គម្ពីរគួរអាន ១៧:២៣)

## 4 ឥស្លាមបង្គាប់ប្រើឱ្យថែរក្សាសិទ្ធិកូនប្រុស និងកូនស្រី ហើយចាំបាច់ត្រូវឱ្យមានភាពយុត្តិធម៌រវាងពួកគេក្នុងការផ្ដត់ផ្គង់ និងកិច្ចការផ្នែកខាងក្រៅ។

## 5 ជនមូស្លីមត្រូវបានគេដាក់កាតព្វកិច្ចឱ្យភ្ជាប់ទំនាក់ទំនងជាមួយសាច់ញាតិ មានន័យថា ភ្ជាប់ទំនាក់ទំនងជាមួយមនុស្ស និងធ្វើល្អជាមួយនឹងសាច់ញាតិរបស់គេទាំងខាងឪពុក និងខាងម្ដាយ។

ដូចជាបងប្អូនប្រុស និងបងប្អូនស្រីរបស់គេ មាមីងខាងឪពុករបស់គេ និងកូនៗរបស់ពួកគាត់ ហើយនិងមាមីងខាងម្ដាយរបស់គេ និងកូនៗរបស់ពួកគាត់ ហើយគេបានចាត់ទុកការធ្វើដូច្នោះជាការបញ្ចិតខ្លួន និងជាការគោរពប្រណិប័តន៍ដ៏ធំធេងបំផុត។ ហើយត្រូវមានការប្រុងប្រយ័ត្នអំពីការផ្ដាច់ទំនាក់ទំនងជាមួយញាតិសណ្ដានឬធ្វើប្រការអាក្រក់ទៅចំពោះពួកគេហើយគេចាត់ទុកទង្វើបែបនោះ ជាបាបកម្មយ៉ាងធំ។ អ្នកនាំសារបានមានប្រសាសន៍ថា “មិនចូលឋានសួគ៌ឡើយ អ្នកដែលកាត់ផ្ដាច់ចំណងសាច់សាលោហិតនោះ"។ (អាល់ពូខរី:៥៦៣៨ មូស្លីម ២៥៥៦)



> សាសនាឥស្លាមបានបណ្ដុះគោលការណ៍គោរព លើកតម្កើនចំពោះឪពុកម្ដាយ។

## > ឋានៈស្ត្រីនៅក្នុងសាសនាឥស្លាម

សាសនាឥស្លាមបានលើកតម្កើងស្ត្រី និងបានផ្តល់សិទ្ធិសេរីភាពដល់នាងរួចផុតពីភាពជាខ្ញុំបម្រើដាច់ថ្លៃរបស់បុរស។ ម្យ៉ាងទៀត ឥស្លាមក៏បានផ្តល់សេរីភាពដល់នាងរួចផុតពីការក្លាយជាទំនិញដ៏ថោកទាប ដែលគ្មានកិត្តិយសសម្រាប់នាង និងគ្មានការគោរព។

ក្នុងចំណោមឧទាហរណ៍នៃច្បាប់ទាក់ទងនិងការលើកតម្កើងស្ត្រីមានដូចជា ៖

- សាសនាឥស្លាមផ្តល់ឱ្យស្ត្រីនូវចំណែករបស់នាងនៃកេរមរតកក្នុងការបែងចែកដ៏យុត្តិធម៌ ថ្លៃថ្លា ដោយកន្លែងខ្លះមានភាពស្មើគ្នារវាងបុរសនិងស្ត្រី ហើយកន្លែងខ្លះទៀតក៏មានភាពខុសគ្នា អាស្រ័យទៅលើការជាប់សាច់ញាតិរបស់នាង(ខ្សែជិតឬឆ្ងាយ)និងការចំណាយចាយដែលជាបន្ទុកលើនាង
- បុរសនិងស្ត្រីមានភាពស្មើគ្នានៅក្នុងកិច្ចការជាច្រើនខុសៗគ្នា រួមទាំងការទំនាក់ទំនងពាក់ព័ន្ធជាមួយនឹងហិរញ្ញវត្ថុទាំងអស់ផងដែរ រហូតដល់អ្នកនាំសារបានមានប្រសាសន៍ថា “ស្ត្រី គឺជាបងប្អូនបង្កើតនឹងបុរស”។ (អាពូហ្ទាវូទ:២៣៦)
- ផ្តល់សេរីភាពដល់ស្ត្រីក្នុងការជ្រើសរើសស្វាមី ហើយដាក់កាតព្វកិច្ចលើនាងមួយផ្នែកធំនៃការទទួលខុសត្រូវក្នុងការអប់រំកូនៗ។អ្នកនាំសារបានមានប្រសាសន៍ថា“ស្ត្រីគឺជាអ្នកមើលការខុសត្រូវផ្ទះស្វាមីរបស់នាង ហើយត្រូវទទួលខុសត្រូវចំពោះអ្នកនៅក្រោមការគ្រប់គ្រងរបស់នាង”។ (អាល់ពូខរី:៨៥៣ មូស្លីម:១៨២៩)
- ថែរក្សាឈ្មោះរបស់នាងឱ្យនៅដូចដើម និងផ្តល់កិត្តិយសឱ្យនាងយកត្រកូលតាមឪពុករបស់នាង ដោយមិនមានការកែប្រែត្រកូលរបស់នាងឡើយបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច ផ្ទុយទៅវិញគឺបន្សល់ទុកឱ្យនាងយកត្រកូលតាមឪពុករបស់នាង និងក្រុមគ្រួសាររបស់នាងដដែល។
- គេបានដាក់កាតព្វកិច្ចទៅលើបុរសត្រូវថែរក្សា និងផ្តល់ការចំណាយចាយទៅឱ្យនាងដោយគ្មានការនិយាយរំលឹកគុណនោះឡើយ ប្រសិនបើនាងជាអ្នកដែលច្បាប់ឥស្លាមដាក់កាតព្វកិច្ចតម្រូវឱ្យផ្គត់ផ្គង់ការចំណាយចាយលើនាង ដូចជា ប្រពន្ធ ម្តាយ និងកូនស្រី។
- គេបានបញ្ជាក់យ៉ាងច្បាស់អំពីឧត្តមភាព និងអត្ថប្រយោជន៍នៃការមើលថែស្ត្រីដែលទន់ខ្សោយដែលគ្មាននរណាម្នាក់រស់នៅជាមួយគាត់ សូម្បីតែសាច់ញាតិណាម្នាក់ ហើយគេបានជម្រុញឱ្យខិតខំបម្រើគាត់ និងបានចាត់ទុកទង្វើនោះ ជាកិច្ចការល្អប្រពៃបំផុតចំពោះអល់ឡោះ។ អ្នកនាំសារបានមានប្រសាសន៍ថា “អ្នកថែរក្សាស្ត្រីមេម៉ាយ និងអ្នកក្រីក្រ ដូចជាអ្នកតស៊ូក្នុងផ្លូវអល់ឡោះ ហើយដូចជាអ្នកសឡាតរហូត ឬបួសរហូត”។ (អាល់ពូខរី:៥៦៦១ មូស្លីម:២៩៨២)

### ស្ត្រីដែលសាសនាឥស្លាមសង្កត់ធ្ងន់ចំពោះការយកចិត្តទុកដាក់ថែទាំចំពោះនាង

ម្តាយ: អំពី អាពូហ៊ូរ៉យរ៉ោះ គាត់បាននិយាយថា: មានបុរសម្នាក់បានមកជួបអ្នកនាំសារ ហើយសួរថា: "ឱអ្នកនាំសារ! តើអ្នកណាដែលខ្ញុំត្រូវធ្វើល្អចំពោះគាត់ជាងគេ"? លោកបានឆ្លើយថា "គឺម្តាយរបស់អ្នក"។ បុរសនោះបានសួរទៀតថា "បន្ទាប់មកតើអ្នកណា"? លោកបានឆ្លើយថា "គឺម្តាយរបស់អ្នក។ បុរសនោះក៏បានសួរទៀតថា "បន្ទាប់មក តើអ្នកណាទៀត" ?លោកបានឆ្លើយថា "គឺម្តាយរបស់អ្នក។ បុរសនោះក៏សួរទៀតថា "បន្ទាប់មក តើអ្នកណាទៀតទៅ"? លោកបានឆ្លើយថា "គឺឪពុករបស់អ្នក"។ (អាល់ពូខរី:៥៦២៦ មូស្លីម:២៥៤៨)

កូនស្រី: អំពី អ៊ុកហ្ពះ កូន អាមៀរ បាននិយាយថា: ខ្ញុំបានលឺអ្នកនាំសារបានមានប្រសាសន៍ថា “ជនណាហើយដែលមានកូនស្រីបីនាក់ ហើយគេបានអត់ធ្មត់ជាមួយពួកនាង ផ្តល់ចំណីអាហារដល់ពួកនាង ផ្តល់ទឹកផឹកដល់ពួកនាង ផ្តល់សម្លៀកបំពាក់ដល់ពួកនាង ការខិតខំប្រឹងប្រែងរបស់គាត់ វានឹងក្លាយជារនាំងការពារអំពីភ្លើងនរកនៅថ្ងៃបរលោក”។ (អ៊ីពនូម៉ាហ្ជះ:៣៦៦៩)

ប្រពន្ធ: អំពីលោកស្រី អាអ៊ីស្ហះ បាននិយាយថា: អ្នកនាំសារបានមានប្រសាសន៍ថា “អ្នកដែលល្អជាងគេក្នុងចំណោមពួកអ្នក គឺអ្នកដែលធ្វើល្អចំពោះគ្រួសាររបស់ពួកអ្នកជាងគេ ហើយខ្ញុំ គឺជាអ្នកដែលធ្វើល្អចំពោះគ្រួសាររបស់ខ្ញុំជាងគេ”។ (អាត់តៀរមីហ្ស៊ី:៣៨៩៥)

ទំនាក់ទំនងរវាងបុរស និងស្ត្រីក្នុងច្បាប់ឥស្លាម គឺជាទំនាក់ទំនងដ៏ពេញលេញមួយ ដែលជួយបំពេញកង្វះខាតរបស់ពួកគេទៅវិញទៅមកក្នុងការកសាងសង្គមឥស្លាម។

## គ្មានជម្លោះទេរវាងភេទទាំងពីរ

គំនិតនៃជម្លោះរវាងបុរសនិងស្ត្រីបានបញ្ចប់ ដោយការគ្រប់គ្រងរបស់បុរសលើស្ត្រី ដូចជានៅក្នុងសហគមន៍ល្ងង់ខ្លៅមួយចំនួន ឬការបះបោររបស់ស្ត្រី និងការចាកចេញរបស់នាងពីទេពកោសល្យ និងលក្ខណៈធម្មជាតិរបស់ពួកនាង ដែលគេបង្កើតវាសម្រាប់នាង ដូចជានៅក្នុងសង្គមដទៃទៀតដែលចេញឆ្ងាយពីច្បាប់របស់អល់ឡោះ។

ដូចនេះ បញ្ហាទាំងនោះនឹងមិនអាចកើតឡើងឡើយប្រសិនបើគេមិនចាកចេញឆ្ងាយពីច្បាប់របស់អល់ឡោះដែលប្រកបដោយគតិបណ្ឌិតទេនោះ ដោយអល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នកកុំទទូចចង់បានដូចអ្វីដែលអល់ឡោះបានប្រទានឱ្យអ្នកខ្លះក្នុងចំណោមពួកអ្នក។ សម្រាប់បុរស នឹងទទួលផលពីអ្វីដែលពួកគេបានសាង ហើយសម្រាប់ស្ត្រីក៏នឹងទទួលផលពីអ្វីដែលពួកនាងបានសាងដែរ។ ចូរពួកអ្នកសុំពីអល់ឡោះនូវការសន្ដោសប្រណីរបស់ទ្រង់”។ (គម្ពីរគួរអាន ៤:៣២)។ ដូច្នេះទាំងបុរសនិងស្ត្រី គឺមានលក្ខណៈពិសេស តួនាទី និងការគោរពរៀងៗខ្លួន ហើយម្នាក់ៗ ត្រូវខិតខំព្យាយាមដើម្បីទទួលបានការប្រោសប្រទាន និងការពេញចិត្តពីអល់ឡោះជាម្ចាស់។ ជាការពិតណាស់ច្បាប់ឥស្លាមមិនបាននាំមកនូវការកាត់សេចក្តី ឬវិនិច្ឆ័យសម្រាប់បុរស ឬសម្រាប់ស្ត្រីនោះទេ ក៏ប៉ុន្តែគឺបាននាំមកនូវការកាត់សេចក្តី ឬវិនិច្ឆ័យសម្រាប់មនុស្សជាតិ និងសង្គមឥស្លាម។

នៅក្នុងមាគ៌ានៃសាសនាឥស្លាម គឺគ្មានទេសមរភូមិ ឬជម្លោះរវាងភេទទាំងពីរ ហើយក៏មិនមែនមានន័យចំពោះការប្រកួតប្រជែងក្នុងកិច្ចការលោកិយនោះដែរ ហើយក៏មិនមែនការភ្លក់រសជាតិនៃយុទ្ធនាការលើស្ត្រី ឬយុទ្ធនាការលើបុរសដែរ ហើយការប៉ុនប៉ងដើម្បីធ្វើឱ្យប៉ះពាល់ដល់នរណាម្នាក់ និងគំនិតអវិជ្ជមានរបស់គេ និងការតាមដានកង្វះខាតរបស់គេ!

ទាំងអស់នោះ គឺជាផ្នែកមួយដែលមានការភ័ន្តច្រឡំនិងយល់ខុសមកលើសាសនាឥស្លាម ហើយក៏ជាការយល់ខុសអំពីតួនាទីពិតប្រាកដនៃភេទទាំងពីរនៅក្នុងផ្នែកផ្សេងទៀត។ ហើយចាំបាច់លើមនុស្សគ្រប់រូបត្រូវតែបួងសួងសុំពីអល់ឡោះដើម្បីទទួលបានការប្រោសប្រទានពីទ្រង់។

## ប្រភេទស្ត្រីចំពោះបុរស

ស្ត្រីចំពោះបុរសត្រូវបានបែងចែកជាច្រើនប្រភេទដូចជា ៖

### 1 ស្ត្រីម្នាក់នោះគឺជាប្រពន្ធរបស់គាត់

បុរសត្រូវបានអនុញ្ញាតឱ្យមើល និងទទួលភាពរីករាយពីប្រពន្ធរបស់គាត់ទៅតាមអ្វីដែលចង់បាន ហើយចំពោះស្ត្រីវិញក៏ត្រូវបានអនុញ្ញាតជាមួយនឹងប្តីរបស់នាងដូចគ្នានេះដែរ។ ពិតណាស់អល់ឡោះបានឱ្យឈ្មោះថា ប្តីគឺជាសម្លៀកបំពាក់របស់ប្រពន្ធ ហើយប្រពន្ធក៏ជាសម្លៀកបំពាក់របស់ប្តីដែរ។ វាប្រៀបដូចជារូបភាពដ៏អស្ចារ្យនៃការផ្សារភ្ជាប់រវាងផ្លូវកាយ ផ្លូវចិត្ត និងរាងកាយពួកគេទាំងពីរ។ អល់ឡោះបានមានបន្ទូលថា "ពួកនាង(ប្រពន្ធ)គឺជាសម្លៀកបំពាក់សម្រាប់ពួកអ្នក ហើយពួកអ្នក(ប្តី)គឺជាសម្លៀកបំពាក់សម្រាប់ពួកនាង"។ (គម្ពីរគួរអាន ២:១៨៧)។ (ចូរមើលទំព័រ ២១៤)

### 2 ស្ត្រីម្នាក់នោះគឺជាម៉ះរ៉មរបស់គាត់

ស្ត្រីដែលជាម៉ះរ៉មមានអត្ថន័យថា គឺស្ត្រីទាំងឡាយដែលច្បាប់ឥស្លាមហាមឃាត់ចំពោះបុរសមិនឱ្យរៀបការជាមួយនាងជារៀងរហូត។ ហើយស្ត្រីដែលជាម៉ះរ៉ម មានដូចជា ៖

| | |
|---|---|
| 1 | ម្តាយបង្កើត ឬជីដូនខាងឪពុកនិងខាងម្តាយ ដូចជាម្តាយរបស់ម្តាយ ឬម្តាយរបស់ឪពុក និងខ្សែទៅលើទៀត។ |
| 2 | កូនស្រីបង្កើត ឬកូនស្រីរបស់កូនប្រុស ឬកូនស្រីរបស់កូនស្រី(ចៅបង្កើត) និងខ្សែទៅខាងក្រោមហ្នឹងទៀត។ |
| 3 | បងប្អូនស្រីបង្កើត ឬបងប្អូនស្រីរួមឪពុក ឬបងប្អូនស្រីរួមម្តាយ |
| 4 | មីងខាងឪពុក គឺបងប្អូនស្រីបង្កើតរបស់ឪពុក ឬបងប្អូនស្រីរួមម្តាយឬរួមឪពុករបស់ឪពុក។ ហើយរាប់បញ្ចូលនៅក្នុងនោះដែរ គឺមីងខាងឪពុករបស់ឪពុក និងមីងខាងឪពុករបស់ម្តាយ។ |
| 5 | មីងខាងម្តាយ គឺបងប្អូនស្រីបង្កើតរបស់ម្តាយ ឬបងប្អូនស្រីរួមម្តាយឬរួមឪពុក របស់ម្តាយ។ ហើយរាប់បញ្ចូលនៅក្នុងនោះដែរមីងខាងម្តាយរបស់ឪពុក និងមីងខាងម្តាយរបស់ម្តាយ។ |
| 6 | កូនស្រីរបស់បងប្អូនប្រុសបង្កើត ឬខាងឪពុក ឬខាងម្តាយ(ក្មួយបង្កើត) និងខ្សែទៅខាងក្រោមទៀត ដូចជា កូនស្រីរបស់កូនបងប្អូនប្រុស(កូនរបស់ក្មួយបង្កើត) |
| 7 | កូនស្រីរបស់បងប្អូនស្រីបង្កើត ឬខាងឪពុក ឬខាងម្តាយ (ក្មួយបង្កើត) និងខ្សែទៅខាងក្រោមទៀត ដូចជា កូនស្រីរបស់កូនបងប្អូនស្រី (កូនរបស់ក្មួយបង្កើត) |
| 8 | ម្តាយរបស់ប្រពន្ធ(ម្តាយក្មេក) ទោះបីជាប្រពន្ធនោះនៅជាមួយគាត់ ឬលែងលះគ្នាហើយក៏ដោយ។ ម្តាយរបស់នាងគឺជាម៉ះរ៉មជារៀងរហូត ហើយក៏ដូច្នោះដែរជីដូនរបស់ប្រពន្ធ។ |
| 9 | កូនស្រីរបស់ប្រពន្ធដែលមិនមែនជាកូនរបស់គាត់(កូនចុង)។ |

| | |
|---|---|
| 10 | ប្រពន្ធរបស់កូន ( កូនប្រសារ ) និងអ្នកនៅក្រោមទៀត ដូចជាប្រពន្ធរបស់ចៅ ( ចៅប្រសារ ) |
| 11 | ប្រពន្ធរបស់ឪពុក ( ម្តាយចុង ) និងអ្នកនៅលើទៀត ដូចជាប្រពន្ធរបស់ជីតា ។ |
| 12 | ម្តាយដោយសារការបំបៅ ( ម៉ែដោះ ) ៖ គឺជាស្ត្រីដែលបំបៅដោះគាត់នៅក្នុងពេលពីរឆ្នាំដំបូងនៃការសម្រាលរបស់គោត់ដោយបំបៅឆ្អែតប្រាំដង ។ ពិតណាស់ឥស្លាមបានផ្តល់សិទ្ធិឱ្យស្ត្រីនោះដោយមូលហេតុការបំបៅរបស់គាត់ចំពោះក្មេងនោះ ។ |
| 13 | បងប្អូនស្រីអំពីការបំបៅ ( បងប្អូនរួមដោះ ) ៖ គឺកូនស្រីរបស់ស្ត្រីដែលបំបៅគាត់នៅពេលដែលគាត់នៅក្មេងដូចដែលបានរៀបរាប់ខាងលើ ។ ដូច្នោះដែរ រាល់សាច់ញាតិអំពីការបំបៅទាំងអស់ត្រូវបានគេហាមឃាត់ ដូចជាសាច់ញាតិនៃពូជអម្បូរដែរ ដូចជាមីងខាងឪពុក មីងខាងម្តាយ កូនស្រីបងប្អូនប្រុស កូនស្រីបងប្អូនស្រី អំពីការបំបៅដោះ ។ |






អ្នកដែលជាម៉ះរ៉មទាំងនេះ ត្រូវបានអនុញ្ញាតឲ្យដើរចេញក្រៅឆ្លងកាត់ខាងមុខបុរសនោះដោយអាចបញ្ចេញអាវ៉ាត់ដែលជាធម្មតាតែងតែលេចចេញនៅពីមុខសាច់ញាតិ ដូចជាការលេចចេញកំភួនដៃ ក និងសក់ ហើយនិងកន្លែងផ្សេងៗទៀតដែលមានលក្ខណៈស្រដៀងគ្នាក្នុងកម្រិតដែលមិនហួសហេតុ ឬហួសព្រំដែន។

## 3 ស្ត្រីនោះជាស្ត្រីអាច្ចណាពីយ៉ះ (ស្ត្រីដែលអាចរៀបការជាមួយបាន)

ស្ត្រីអាច្ចណាពីយ៉ះ គឺបណ្ដាស្ត្រីដែលមិនមែនម៉ះរ៉មរបស់គេ ទោះបីជានាងជាសាច់ញាតិរបស់គេក៏ដោយដូចជា កូនស្រីរបស់មាឬមីងខាងឪពុកគេ(ក្មួយជីដូនមួយ) ឬកូនស្រីរបស់មារឬមីងខាងម្ដាយគេ (ក្មួយជីដូនមួយ) ប្រពន្ធរបស់បងប្អូនប្រុសគេ(បងថ្លៃ) ឬសាច់ញាតិរបស់ក្រុមគ្រួសារ ឬមិនមែនជាសាច់ញាតិរបស់គេ និងមិនមានជាប់ទំនាក់ទំនងសាច់ញាតិជាមួយនាង ឬសាច់ញាតិក្រុមគ្រួសាររបស់នាងឡើយ។

ពិតណាស់ សាសនាឥស្លាមបានដាក់នូវគោលការណ៍ និងច្បាប់ដើម្បីវិនិច្ឆ័យលើការទំនាក់ទំនងរវាងជនមូស្លីមនិងស្ត្រីអាច្ចណាពីយ៉ះ(ស្ត្រីដែលអាចរៀបការជាមួយបាន) ក្នុងគោលបំណងការពារកិត្តិយសនិងបិទទ្វាររបស់ស្ហៃតនទៅចំពោះមនុស្ស។ ជាការពិតណាស់ ម្ចាស់ដែលបង្កើតមនុស្សទ្រង់ដឹងបំផុតនូវអ្វីដែលល្អប្រសើរសម្រាប់ពួកគេ។ អល់ឡោះបានមានបន្ទូលថា "តើម្ចាស់ដែលបានបង្កើត(អ្វីៗទាំងអស់)មិនបានដឹងទេឬ? ហើយទ្រង់គឺជាអ្នកដែលទន់ភ្លន់ ដឹងជ្រួតជ្រាបបំផុត"។ (គម្ពីរគួរអាន ៦៧:១៤)

> របាយការណ៍ និងស្ថិតិនៅតែនិយាយជារៀងរាល់ថ្ងៃអំពីករណីនៃការរំលោភសេពសន្ថវៈនិងទំនាក់ទំនងមានភាពខុសឆ្គងដែលច្បាប់ឥស្លាមហាមឃាត់នោះ គឺបានបំផ្លាញជាច្រើននៃក្រុមគ្រួសារនិងសហគមន៍ ដោយសារតែការឃ្លាតឆ្ងាយពីការអនុវត្តច្បាប់របស់អល់ឡោះ។



> ឥស្លាមបានដាក់ក្បួនច្បាប់ដើម្បីកំណត់ទំនាក់ទំនងរវាងបុរសនិងស្ត្រី។

## វិធីសាស្ត្រទំនាក់ទំនងរវាងបុរសនិងស្ត្រីអាច្ចណាពីយ៉ះ(ស្ត្រីដែលអាចរៀបការជាមួយបាន)

### 1 ដាក់ក្រសែភ្នែកចុះ(ពីការសម្លឹងមើល)

ចាំបាច់លើជនមូស្លីមមិនត្រូវមើលអាវ៉ាត់ ហើយមិនត្រូវមើលទៅកាន់អ្វីដែលនាំឱ្យមានតណ្ហានៅក្នុងខ្លួន និងមិនត្រូវមើលស្ត្រីក្នុងរយៈពេលវែងដោយគ្មានកិច្ចការចាំបាច់ឡើយ។

ពិតណាស់ អល់ឡោះបានបង្គាប់ប្រើឱ្យភេទទាំងពីរ(ទាំងប្រុស ទាំងស្រី)ដាក់ក្រសែភ្នែកចុះពីការសម្លឹងមើល ពីព្រោះវាជាមធ្យោបាយមួយរក្សាភាពបរិសុទ្ធ និងការពារកិត្តិយស។ ម្យ៉ាងទៀត ជាទូទៅការសម្លឹងមើលដោយគ្មានព្រំដែននោះ វាគឺផ្លូវមួយឆ្ពោះទៅកាន់អំពើបាប និងអំពើអាក្រក់។ អល់ឡោះបានមានបន្ទូលថា “ចូរអ្នក(ព្យាការីមូហាំម៉ាត់)ពោលទៅកាន់បណ្តាបុរសដែលមានជំនឿឱ្យពួកគេដាក់ក្រសែភ្នែករបស់ពួកគេចុះពីការសម្លឹងមើល(ស្ត្រី និងអ្វីដែលច្បាប់ឥស្លាមបានហាមឃាត់)ហើយឱ្យពួកគេថែរក្សានូវប្រដាប់ភេទរបស់ពួកគេ(អំពីប្រការហ្ស៊ីណា)។ នោះគឺជាប្រការស្អាតស្អំបំផុតសម្រាប់ពួកគេ។ ពិតប្រាកដណាស់ អល់ឡោះដឹងជ្រួតជ្រាបំផុតនូវអ្វីដែលពួកគេប្រព្រឹត្ត។ ចូរអ្នក(ព្យាការីមូហាំម៉ាត់)ពោលទៅកាន់បណ្តាស្ត្រីដែលមានជំនឿឱ្យពួកនាងដាក់ក្រសែភ្នែកចុះពីការសម្លឹងមើល(បុរសនិងអ្វីដែលច្បាប់ឥស្លាមហាមឃាត់) ហើយឱ្យពួកនាងថែរក្សាប្រដាប់ភេទរបស់ពួកនាង(អំពីប្រការហ្ស៊ីណា)។ (គម្ពីរគួរអាន ២៤:៣០-៣១)

ប្រសិនជាវាបានកើតឡើងដោយមនុស្សបានមើលឃើញដោយចៃដន្យ(អចេតនា) ចាំបាច់លើគេត្រូវតែបង្វែរក្រសែរភ្នែកគេចចេញអំពីប្រការដែលគេហាមឃាត់ ហើយការដាក់ក្រសែភ្នែកចុះពីការសម្លឹងមើលនោះ រួមបញ្ចូលទាំងអស់ ទាំងតាមប្រព័ន្ធផ្សព្វផ្សាយ និងអ៊ិនធឺណេត។ ហើយហាមឃាត់មិនឱ្យសម្លឹងមើលអ្វីដែលនាំឱ្យមានតណ្ហា ហើយជម្រុញឱ្យមានភាពត្រេកត្រអាល។

### 2 ទំនាក់ទំនងដោយសីលធម៌ និងសុជីវធម៌

គឺការនិយាយសន្ទនាជាមួយស្ត្រីអាច្ចណាពីយ៉ះ(ស្ត្រីដែលរៀបការជាមួយបាន) ហើយនិងទំនាក់ទំនងរវាងគេទាំងពីរដោយសីលធម៌ និងសុជីវធម៌ ជាមួយនឹងការជៀសឆ្ងាយអំពីអ្វីទាំងអស់ដែលនាំឱ្យកើតមាននូវភាពត្រេកត្រអាលដោយវិធីណាមួយក៏ដោយ។ អាស្រ័យហេតុនេះហើយទើប ៖

- អល់ឡោះបានហាមឃាត់ស្ត្រីចំពោះការនិយាយដោយស្រទន់ និងម្ទិកម្ទក់ជាមួយបុរសអាច្ចណាពី(បុរសដែលអាចរៀបការជាមួយបាន) និងដាក់បទបញ្ញាដោយបន្ទូលរបស់ទ្រង់យ៉ាងច្បាស់លាស់។ អល់ឡោះបានមានបន្ទូលថា "ចូរពួកនាងកុំប្រើពាក្យសំដីទន់ភ្លន់ម្ទិកម្ទក់(ជាមួយបុរសដែលមិនមែនជាស្វាមី)ឱ្យសោះ ដោយហេតុធ្វើឱ្យបុរសដែលមានជំងឺ(ចំណង់តណ្ហា)នៅក្នុងចិត្តរបស់គេមានអារម្មណ៍(ចំពោះពួកនាង)។ តែពួកនាងត្រូវនិយាយនូវពាក្យសំដីណាដែលល្អ”។ (គម្ពីរគួរអាន ៣៣:៣២)
- ហាមឃាត់អំពីការបញ្ចេញសកម្មភាពកាច់រាងក្នុងពេលដើរ និងការបង្ហាញនូវខ្លះៗអំពីការតុបតែងលម្អ។អល់ឡោះបានមានបន្ទូលថា “ដូច្នោះដែរកុំឱ្យពួកនាងដើរទន្រ្ទាំជើងបន្លឺសម្លេង ដើម្បីឱ្យគេដឹងនូវអ្វីដែលពួកនាងលាក់បាំងអំពីការតុបតែងរបស់ពួកនាងឱ្យសោះ”។ (គម្ពីរគួរអាន ២៤:៣១)

### 3 ហាមឃាត់ការនៅកន្លែងស្ងាត់

ការនៅកន្លែងស្ងាត់មានន័យថា ការនៅស្ងាត់តែពីរនាក់រវាងបុរសនិងស្ត្រីអាច្ចណាពីយ៉ះ នៅកន្លែងដែលគ្មាននរណាម្នាក់មើលឃើញពួកគេ។ ជាការពិតណាស់ សាសនាឥស្លាមបានហាមឃាត់ការនៅកន្លែងស្ងាត់តែពីរនាក់ ពីព្រោះវាជាកន្លែងដែលស្ហៃតនអាចជម្រុញពួកគេឲ្យប្រព្រឹត្តនូវរឿងដែលមិនគួរគប្បី។ អ្នកនាំសារបានមានប្រសាសន៍ថា “គ្មានទេបុរសម្នាក់នៅកន្លែងស្ងាត់(តែពីរនាក់)ជាមួយនឹងស្ត្រីម្នាក់ លើកលែងតែមានស្ហៃតនជាអ្នកទីបីនៃពួកគេទាំងពីរ”។ (អាត់តៀរមីហ្ស៊ី:២១៦៥)

## 4 ហ៊ីហ្សាប (អ្វីដែលយកមកបិទបាំងរាងកាយដែលច្បាប់បានបង្គាប់ប្រើ)

អល់ឡោះបានដាក់កាតព្វកិច្ចពាក់ហ៊ីហ្សាបចំពោះស្ត្រី ដោយមិនបានបង្គាប់ប្រើលើបុរសដោយសារតែស្ត្រីមានការស្តែងចេញនូវសម្រស់និងកត្តាទាក់ទាញច្រើន ដែលអាចធ្វើឱ្យមានចលាចល ឬភាពវឹកវរ(ហ្វិតណះ)ដល់បុរស ច្រើនជាងបុរសធ្វើឱ្យមានចលាចល ឬភាពវឹកវរដល់ស្ត្រី។

ពិតណាស់ អល់ឡោះបានបង្គាប់ប្រើលើស្ត្រីឲ្យពាក់ហ៊ីហ្សាប ដោយសារមូលហេតុជាច្រើនដូចជា៖

- ដើម្បីឲ្យស្ត្រីអាចអនុវត្តកិច្ចការរបស់នាងនៅក្នុងជីវិតរស់នៅ និងសង្គមក្នុងផ្នែកសិក្សានិងការងារដោយមានភាពល្អប្រសើរ ជាមួយនឹងការថែរក្សានូវសេចក្តីថ្លៃថ្នូរ និងភាពបរិសុទ្ធរបស់នាង។
- កាត់បន្ថយនិងបន្ធូរស្រាលដល់ឱកាសនៃការប្រព្រឹត្តកំហុស និងការរំលោភបំពានដើម្បីធានាដល់ការជ្រះស្អាតនៃសង្គមក្នុងផ្នែកមួយ និងមួយផ្នែកទៀតដើម្បីថែរក្សាសេចក្តីថ្លៃថ្នូររបស់ស្ត្រី។
- ជួយដល់បុរសក្នុងការសម្លឹងមើលទៅកាន់ស្ត្រីលើភាពបរិសុទ្ធ និងមានវិន័យ។ ហើយពួកគេធ្វើទំនាក់ទំនងជាមួយនាងដូចជាមនុស្សទទួលបានភាពរីករាយពីការរួមផ្សំវប្បធម៌និងចំណេះដឹង ពោលគឺនាងមិនមែនជាវត្ថុសម្រាប់បម្រើតណ្ហា និងជាឧបករណ៍សម្រាប់លេងសើចសប្បាយឡើយ។

### ព្រំដែននៃការពាក់ហ៊ីហ្សាប

អល់ឡោះបានដាក់កាតព្វកិច្ចលើស្ត្រីពេលនៅមុខបុរសអាចណាពី(បុរសដែលអាចរៀបការជាមួយបាន) គឺត្រូវបិទបាំងទាំងអស់ខ្លួនប្រាណរបស់នាងលើកលែងតែមុខនិងប្រអប់ដៃរបស់នាងប៉ុណ្ណោះ។ ដូចអល់ឡោះបានមានបន្ទូលថា “ហើយកុំឱ្យពួកនាងបង្ហាញសម្រស់របស់នាង លើកលែងតែអ្វីដែលស្តែងចេញជាធម្មតា”។ (គម្ពីរគួរអាន ២៤:៣១)។ អ្វីដែលស្តែងចេញជាធម្មតានោះគឺ មុខ និងប្រអប់ដៃ លើកលែងតែនៅពេលណាដែលជួបនឹងភាពវឹកវរ(ហ្វិតណះ)ណាមួយ ដោយសារតែការបង្ហាញមុខនិងប្រអប់ដៃ ដែលចាំបាច់ត្រូវបិទបាំងវាទាំងពីរនៅខណៈពេលនោះ។

### បទដ្ឋាននៃការពាក់ហ៊ីហ្សាប

អនុញ្ញាតចំពោះស្ត្រីអាចពាក់ហ៊ីហ្សាបទៅតាមអ្វីដែលនាងចង់ មិនថារូបរាង និងពណ៌អ្វីក៏បានទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ ៖

1. ហ៊ីជើបនោះត្រូវគ្រប់ដណ្តប់លើកន្លែងដែលចាំបាច់ត្រូវបិទបាំងវា
2. ត្រូវឱ្យមានទំហំធំទូលាយ និងមិនចង្អៀតដែលអាចកំណត់ផ្នែករាងកាយបាន។
3. មិនត្រូវឱ្យស្តើងពេក អាចមើលឃើញរាងកាយខ្លួនប្រាណនៅខាងក្នុង



> ការថែរក្សាលើការពាក់ហ៊ីហ្សាបសម្រាប់ស្ត្រី ដើម្បីឱ្យពួកនាងអាចបំពេញសកម្មភាពរបស់នាងក្នុងសង្គមនៅក្នុងរូបភាពបរិសុទ្ធបំផុតដែលមនុស្សជាតិអាចស្គាល់នាង។

## > អាពាហ៍ពិពាហ៍នៅក្នុងសាសនាឥស្លាម



> ការរៀបអាពាហ៍ពិពាហ៍ គឺជាទំនាក់ទំនងដ៏អស្ចារ្យដែលសាសនាឥស្លាមបានបញ្ជាក់លើវាយ៉ាងច្បាស់

ការរៀបអាពាហ៍ពិពាហ៍ គឺជាទំនាក់ទំនងដ៏អស្ចារ្យបំផុតដែលសាសនាឥស្លាមបានបញ្ជាក់យ៉ាងច្បាស់ចំពោះវា និងមានចំណងក្នុងវា ហើយនិងបានចាត់ទុកវាជាមាគ៌ារបស់បណ្ដាអ្នកនាំសារ។ (សូមមើលទំព័រ ២០២)

សាសនាឥស្លាមបានយកចិត្តទុកដាក់យ៉ាងលម្អិតនៅក្នុងច្បាប់នៃអាពាហ៍ពិពាហ៍ និងសីលធម៌របស់វា ព្រមទាំងសិទ្ធិប្ដីប្រពន្ធ នៅក្នុងគោលបំណងដើម្បីរក្សាទំនាក់ទំនងនេះឱ្យនៅបន្ត និងមានស្នេហភាព និងកសាងគ្រួសារមួយដែលទទួលបានជោគជ័យ ដែលជាកន្លែងដែលកុមាររីកដុះដាលដោយមានស្នេហភាពខ្លួនឯង និងស្ថិតនៅលើសាសនា និងឧត្តមភាពក្នុងផ្នែកទាំងអស់នៃជីវិត។

### ច្បាប់ទាំងនោះមានដូចខាងក្រោម

ឥស្លាមបានដាក់លក្ខខណ្ឌចាំបាច់សម្រាប់ប្ដីនិងប្រពន្ធក្នុងការរៀបអាពាហ៍ពិពាហ៍ឲ្យបានត្រឹមត្រូវដូចខាងក្រោម ៖

### លក្ខខណ្ឌសាសនាឥស្លាមចំពោះប្រពន្ធ

1. ស្ត្រីនោះ គឺជាជនមូស្លីម(កាន់សាសនាឥស្លាម) ឬជាអះលីគីតាប(មានន័យថា ជាអ្នកកាន់សាសនាយូដា ឬសាសនាគ្រឹស្ត)មានជំនឿនឹងសាសនារបស់នាង។ ក៏ប៉ុន្តែ ឥស្លាមបានជំរុញឲ្យជ្រើសរើសស្ត្រីមូស្លីមដែលប្រកាន់ខ្ជាប់នឹងសាសនា ពីព្រោះនាងនឹងក្លាយជាម្ដាយអប់រំកូនៗរបស់អ្នក ជួយដល់អ្នកលើសេចក្ដីល្អ និងភាពត្រឹមត្រូវ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “ចូរអ្នកជ្រើសយកស្ត្រីដែលមានសាសនា នោះអ្នកនឹងមានភាពសុខសាន្ត”។ (អាល់ពូខរី:៤៨០២ មូស្លីម:១៤៦៦)

2 ស្ត្រីនោះជាស្ត្រីដែលល្អបរិសុទ្ធ ហើយគេហាមឃាត់មិនឱ្យរៀបការជាមួយនឹងស្ត្រីដែលប្រព្រឹត្តអំពើមិនគប្បី និងអំពើហ្សីណានោះទេ ដូចដែលអល់ឡោះជាម្ចាស់បានមានបន្ទូលថា “ហើយ (គេអនុញ្ញាតឱ្យពួកអ្នករៀបអាពាហ៍ពិពាហ៍ផងដែរ)ជាមួយស្ត្រីបរិសុទ្ធក្នុងចំណោមស្ត្រីដែលមានជំនឿ និងស្ត្រីបរិសុទ្ធនៃពួកដែលគេផ្តល់គម្ពីរឱ្យ(ពួកអះលីគីតាប)មុនពួកអ្នក”។ (គម្ពីរគួរអាន ៥:៥)

3 ស្ត្រីនោះមិនមែនជាម៉ះរ៉មរបស់បុរសនោះ ដែលគេហាមឃាត់មិនឱ្យរៀបការជាមួយនឹងពួកនាងជាដាច់ខាត ដូចដែលបានបញ្ជាក់ពីមុន។ ហើយមិនត្រូវរួមគ្នាជាមួយប្តីតែមួយ រវាងស្ត្រីនិងបងប្អូនស្រីរបស់នាង ឬមីងខាងឪពុករបស់នាង ឬមីងខាងម្តាយរបស់នាងនោះទេ។

## លក្ខខណ្ឌសាសនាឥស្លាមចំពោះប្តី

គេដាក់លក្ខខណ្ឌសម្រាប់ប្តី គឺត្រូវតែជាអ្នកមូស្លីម(កាន់សាសនាឥស្លាម) ហើយនៅក្នុងសាសនាឥស្លាម គឺបានបានហាមឃាត់មិនឱ្យស្ត្រីមូស្លីមរៀបការជាមួយនិងបុរសគ្មានជំនឿឡើយ សូម្បីតែបុរសនោះជាអ្នកកាន់សាសនាអះលីគីតាប ឬមិនមែនក៏ដោយ។ ហើយសាសនាឥស្លាមបានបញ្ជាក់អំពីការទទួលយកអាពាហ៍ពិពាហ៍ ប្រសិនបើបុរសនោះមានពីរលក្ខណៈដូចខាងក្រោមនេះ គឺ៖

- ជាអ្នកប្រកាន់ខ្ជាប់នឹងសាសនា(ឥស្លាម)
- មានសុជីវធម៌ល្អ

អ្នកនាំសារបានមានប្រសាសន៍ថា “ប្រសិនបើមានគេមកស្តីដណ្តឹង(កូនស្រីពួកអ្នក)អំពីពួកអ្នកនៃអ្នកដែលពួកអ្នកពេញចិត្តនឹងសាសនា និងសុជីវធម៌ល្អរបស់គេហើយនោះ ចូរពួកអ្នករៀបការឱ្យគេចុះ”។ (អាត់តៀរមីហ្ស៊ីៈ១០៨៤ អ៊ិពនូម៉ាហ្ជះៈ១៩៦៧)



# > សិទ្ធិរបស់ប្ដីប្រពន្ធ

អល់ឡោះបានដាក់កាតព្វកិច្ចទាំងប្ដីនិងប្រពន្ធនូវសិទ្ធិជាច្រើន និងជម្រុញពួកគេឲ្យធ្វើនូវរាល់កិច្ចការទាំងឡាយណាដែលជួយដល់ការអភិវឌ្ឍទំនាក់ទំនងអាពាហ៍ពិពាហ៍ និងរក្សាការពារទៅលើវា។ ជាការពិតណាស់ ទំនួលខុសត្រូវ គឺស្ថិតនៅលើភាគីទាំងពីរ(ទាំងប្ដី ទាំងប្រពន្ធ)។ ចាំបាច់លើប្ដី និងប្រពន្ធ គឺមិនត្រូវទាមទារនូវអ្វីដែលភាគីម្ខាងទៀតគ្មានលទ្ធភាពផ្ដល់ឲ្យនោះឡើយ។ អល់ឡោះបានមានបន្ទូលថា "ហើយពួកនាងមានសិទ្ធិទៅលើប្ដីដូចសិទ្ធិរបស់ប្ដីទៅលើពួកនាងដោយស្របច្បាប់ដែរ" ។(គម្ពីរគួរអាន ២:២២៨)។ ដូចនេះ ចាំបាច់ត្រូវមានការអធ្យាស្រ័យ និងមានភាពសប្បុរស ដើម្បីទទួលបានភាពងាយស្រួលនៅក្នុងឆាកជីវិត និងកសាងគ្រួសារមួយដែលមានសុភមង្គល។

## សិទ្ធិរបស់ប្រពន្ធ

### 1 ការផ្គត់ផ្គង់ និងទីជម្រក(លំនៅដ្ឋាន)

- ចាំបាច់លើប្ដី ត្រូវផ្គត់ផ្គង់ទៅលើប្រពន្ធរបស់គេនូវចំណីអាហារ ភេសជ្ជៈ សម្លៀកបំពាក់ និងកិច្ចការទាំងឡាយទៀតរបស់នាង។ត្រូវផ្ដល់ឱ្យនាងនូវទីជម្រក(លំនៅដ្ឋាន)ដែលសមរម្យដើម្បីឱ្យនាងអាចស្នាក់នៅក្នុងវា សូម្បីតែនាងជាអ្នកមានក៏ដោយ។
- បរិមាណនៃការផ្គត់ផ្គង់: បរិមាណនៃការផ្គត់ផ្គង់ ត្រូវផ្ដល់ឱ្យសមរម្យទៅតាមចំណូលរបស់ប្ដី ដោយមិនមានការខ្ជះខ្ជាយ និងខ្វះខាត(ត្បិតត្បៀត) ដូចដែលអល់ឡោះបានមានបន្ទូលថា "អ្នកដែលមានទ្រព្យសម្បត្តិច្រើន ចូរឱ្យគេបរិច្ចាគឱ្យបានសមរម្យអំពីទ្រព្យសម្បត្តិរបស់គេ។ រីឯអ្នកដែលទ្រព្យសម្បត្តិរបស់គេមានកំណត់ ចូរឱ្យគេបរិច្ចាគទៅតាមអ្វីដែលអល់ឡោះបានផ្ដល់ឱ្យគេ"។ (គម្ពីរគួរអាន ៦៥:៧)
- ចាំបាច់ក្នុងការផ្គត់ផ្គង់នោះ មិនត្រូវមានការរលើក និងបំបាក់មុខឡើយ ផ្ទុយទៅវិញ ដូចដែលអល់ឡោះបានបញ្ជាក់ប្រាប់ គឺដោយសមរម្យ មានន័យថាដោយល្អប្រសើរ ហើយវាមិនមែនការលើកតម្កើងដល់ស្ត្រីជាប្រពន្ធនោះទេ ប៉ុន្តែជាសិទ្ធិរបស់ប្រពន្ធទៅលើប្ដីរបស់នាងដែលត្រូវតែផ្ដល់ឱ្យនាងនូវសិទ្ធិរបស់នាងដោយសមរម្យ។



> ចាំបាច់លើបុរសត្រូវផ្គត់ផ្គងដល់ប្រពន្ធ និងកូនៗរបស់គេដោយសមរម្យ។

គ្រួសាររបស់អ្នក

- ការផ្តត់ផ្គង់ទៅលើប្រពន្ធនិងគ្រួសារក្នុងសាសនាឥស្លាម គឺទទួលបាននូវផលបុណ្យដ៏ធំធេង។ អ្នកនាំសារបានមានប្រសាសន៍ថា “នៅពេលដែលអ្នកមូស្លីមម្នាក់ផ្គត់ផ្គង់ទ្រព្យសម្បត្តិទៅឱ្យគ្រួសាររបស់គាត់ ដោយរំពឹងចង់បានផលបុណ្យនោះ ទ្រព្យនោះគឺប្រៀបដូចជាទ្រព្យបរិច្ចាគទានសម្រាប់គាត់”។ (ពូខរីៈ៥០៣៦ មូស្លីម ១០០២)។ ហើយអ្នកនាំសារក៏បានមានប្រសាសន៍ទៀតថា “ទ្រព្យសម្បត្តិណាមួយដែលអ្នកបានបរិច្ចាគដើម្បីអល់ឡោះ អ្នកនឹងត្រូវគេផ្តល់ផលបុណ្យ ឱ្យសូម្បីតែចំណីអាហារដែលអ្នកដាក់បញ្ចូលក្នុងមាត់ប្រពន្ធរបស់អ្នកក៏ដោយ”។ (អាល់ពូខរីៈ៥៦ មូស្លីមៈ១៦២៨)។ ជនណាហើយដែលមិនផ្គត់ផ្គង់ទ្រព្យសម្បត្តិ ឬផ្តល់បន្តិចបន្តួចអំពីវា ខណៈដែលគេមានលទ្ធភាពក្នុងការផ្តល់ឲ្យលើសពីនោះ ពិតណាស់គេកំពុងតែប្រព្រឹត្តអំពើបាបកម្មដ៏ធំធេងមួយ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “គ្រប់គ្រាន់ហើយបាបកម្មរបស់បុគ្គលម្នាក់ នៅពេលដែលគាត់បោះបង់ចោលអ្នកដែលគាត់មានកាតព្វកិច្ចផ្គត់ផ្គង់អាហារដល់គេនោះ”។ (អាពូហ្សាវូទៈ១៦៩២)

## 2 រស់នៅប្រកបដោយភាពល្អប្រសើរ

ការរស់នៅប្រកបដោយភាពល្អប្រសើរមានន័យថាៈ សុជីវធម៌ល្អ សុភាពរាបសា សំដីទន់ភ្លន់ និងមានការទទួលខុសត្រូវរាល់កំហុសឆ្គង និងការធ្វេសប្រហែសទាំងឡាយដែលគ្មាននរណាម្នាក់អាចគេចផុតវាបាននោះ។ អល់ឡោះបានមានបន្ទូលថា “ចូរពួកអ្នករួមរស់ជាមួយពួកនាងដោយគុណធម៌។ ប្រសិនបើពួកអ្នកមិនពេញចិត្តពួកនាង(ចូរអត់ធ្មត់) ជួនកាលការមិនពេញចិត្តរបស់ពួកអ្នកលើអ្វីមួយនោះ អល់ឡោះអាចនឹងធ្វើឱ្យវាល្អប្រសើរលើសលប់វិញ”។ (គម្ពីរគួរអាន ៤:១៩)

អ្នកនាំសារបានមានប្រសាសន៍ថា “អ្នកមានជំនឿដែលមានជំនឿពេញលេញជាងគេ គឺអ្នកដែលមានសីលធម៌ល្អជាងគេ ហើយអ្នកដែលល្អជាងគេនៃពួកអ្នក គឺអ្នកដែលធ្វើល្អជាងគេចំពោះភរិយារបស់ពួកអ្នកដោយសីលធម៌ល្អ”។ (អាត់តៀរមីហ្ស៊ីៈ១១៦២)

អ្នកនាំសារបានមានប្រសាសន៍ទៀតថា “អ្នកមានជំនឿដែលមានជំនឿពេញលេញជាងគេ គឺអ្នកដែលមានសីលធម៌ល្អជាងគេ និងមានភាពទន់ភ្លន់ជាងគេជាមួយនឹងភរិយារបស់គេ”។ (អាត់តៀរមីហ្ស៊ីៈ២៦១២ អះម៉ាត់ៈ២៤៦៧៧)

ហើយអ្នកនាំសារក៏បានមានប្រសាសន៍ទៀតថា “អ្នកដែលល្អជាងគេនៃពួកអ្នក គឺអ្នកដែលធ្វើល្អជាងគេចំពោះភរិយារបស់គេ ហើយខ្ញុំជាអ្នកដែលធ្វើល្អជាងគេចំពោះភរិយារបស់ខ្ញុំ”។ (អាត់តៀរមីហ្ស៊ីៈ៣៨៩៥)

ហើយមានមិត្តភក្តិម្នាក់របស់ព្យាការីបានសួរលោកថា “ឱអ្នកនាំសារ! តើសិទ្ធិរបស់ប្រពន្ធមកលើពួកយើង(ជាប្តី)មានអ្វីខ្លះ?” លោកតបថា “អ្នកត្រូវផ្តល់ចំណីអាហារដល់នាងពេលអ្នកទទួលទាន ត្រូវផ្តល់សម្លៀកបំពាក់ដល់នាងនៅពេលអ្នកស្លៀកពាក់ មិនត្រូវវាយមុខ មិនត្រូវជេរប្រមាថ និងមិនត្រូវបំបែកនាងពីទីដំណេកឡើយលើកលែងតែនៅក្នុងផ្ទះ”។ (អាពូហ្សាវូទៈ២១៤២)

## 3 អត់ឱន និងអត់ធ្មត់

ចាំបាច់ត្រូវសង្កេតមើលធម្មជាតិរបស់ស្ត្រីដែលមានភាពខុសគ្នាពីធម្មជាតិរបស់បុរស និងព្យាយាមពិនិត្យមើលពីជីវិតរស់នៅគ្រប់ផ្នែកទាំងអស់របស់នាង។ ជាការពិតណាស់ គ្មាននរណាម្នាក់គេចផុតពីកំហុសឆ្គងនោះទេ។ ដូចនេះ ចាំបាច់លើយើងត្រូវមានការអត់ធ្មត់ និងពិចារណានៅក្នុងផ្លូវវិជ្ជមាន។ អល់ឡោះបានរំលឹកដល់ប្តីប្រពន្ធឲ្យពិចារណានៅក្នុងផ្លូវវិជ្ជមាន ដោយទ្រង់បានមានបន្ទូលថា “ហើយចូរពួកអ្នកកុំភ្លេចនូវអំពើសប្បុរសរវាងពួកអ្នក”។(គម្ពីរគួរអាន ២:២៣៧)។ ហើយអ្នកនាំសារបានមានប្រសាសន៍ថា “អ្នកមានជំនឿមិនត្រូវស្អប់ភរិយារបស់គាត់ជាអ្នកមានជំនឿឡើយ។ ប្រសិនជាគាត់មិនពេញចិត្តនូវចរិតលក្ខណៈ

ណាមួយរបស់នាង គាត់នឹងពេញចិត្តនូវចរិតលក្ខណៈផ្សេងៗទៀតរបស់នាង”។ (មូស្លីមៈ១៤៦៩))

អ្នកនាំសារបានបញ្ជាក់យ៉ាងច្បាស់លើការយកចិត្តទុកដាក់ចំពោះស្ត្រី និងការរួមរស់ជាមួយនាងដោយអំពើល្អ និងសមរម្យ ជាមួយនឹងការប្រុងប្រយ័ត្នទៅលើធម្មជាតិរបស់ស្ត្រីទាំងផ្លូវកាយ និងផ្លូវចិត្ត ដែលមានភាពខុសគ្នាអំពីបុរស ហើយភាពខុសគ្នានេះនិងបំពេញទៅចំពោះគ្រួសារ ហើយចាំបាច់មិនត្រូវឱ្យភាពខុសគ្នានោះជាមូលហេតុនាំឱ្យមានការបែកបាក់ និងលែងលះគ្នាឡើយ ដូចអ្នកនាំសារបានមានប្រសាសន៍ថា “ចូរពួកអ្នកធ្វើល្អចំពោះស្ត្រី។ ការពិត ស្ត្រីត្រូវបានគេបង្កើតពីឆ្អឹងជំនី។ នាងមិនអាចស្ថិតនៅលើផ្លូវតែមួយសម្រាប់អ្នកទេ។ ប្រសិនបើអ្នករីករាយជាមួយនាង អ្នកអាចរីករាយជាមួយនាង ហើយនាងមានភាពវៀចវេរ។ ប្រសិនបើអ្នកពត់នាងអ្នកនឹងធ្វើឱ្យនាងបាក់ ហើយការបាក់នោះគឺការលែងលះ”។ (អាល់ពូខរីៈ៣១៥៣ មូស្លីមៈ១៤៦៨)

## 4 ដេកនៅជាមួយនាង

គប្បីលើបុរសត្រូវដេកនៅជាមួយភរិយារបស់គាត់ ហើយចាំបាច់លើបុរស មិនត្រូវដេកនៅជាមួយនាងតិចជាងមួយថ្ងៃក្នុងចំណោមបួនថ្ងៃឡើយ។ ម្យ៉ាងទៀត ចាំបាច់លើបុរសជាស្វាមីផងដែរ ត្រូវបែងចែករវាងប្រពន្ធទាំងឡាយរបស់គាត់ដោយយុត្តិធម៌ ប្រសិនបើគាត់មានប្រពន្ធលើសពីមួយនាក់។

## 5 ការពារនាង ពីព្រោះនាងជាកិត្តិយស និងជាភាពខ្ពង់ខ្ពស់របស់គាត់

នៅពេលដែលបុរសម្នាក់រៀបការជាមួយស្ត្រីម្នាក់ នាងបានក្លាយជា "កិត្តិយស" របស់គាត់ ដែលចាំបាច់លើគេត្រូវតែការពារកិត្តិយសនេះ ទោះបីជាអាចឈានដល់ស្លាប់ក៏ដោយ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “អ្នកដែលត្រូវគេសម្លាប់ដោយសារការពារគ្រួសាររបស់គាត់គឺជាអ្នកពលី(ស្ហាហ៊ីទ)”។ (អាត់តៀរមីហ្ស៊ីៈ១៤២១ អាពូហ្ទាវូទៈ៤៧៧២)

## 6 មិនត្រូវបញ្ចេញរឿងសម្ងាត់រវាងប្ដីប្រពន្ធឡើយ

ពិតណាស់ គេមិនអនុញ្ញាតឱ្យបុរសនិយាយអំពីរឿងសម្ងាត់ប្រពន្ធរបស់គាត់និងអ្វីដែលកើតឡើងរវាងប្ដីប្រពន្ធ ហើយផ្សព្វផ្សាយនៅក្នុងចំណោមមនុស្សឡើយ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “ពិតណាស់ នៅក្នុងចំណោមមនុស្សដែលស្ថិតនៅក្នុងលំដាប់អាក្រក់បំផុតចំពោះអល់ឡោះនៅថ្ងៃបរលោកនោះគឺ បុរសដែលរួមដំណេកជាមួយស្ត្រីជាភរិយារបស់គាត់ ហើយនាងក៏បានរួមដំណេកជាមួយគាត់វិញដែរ បន្ទាប់មក គាត់ផ្សព្វផ្សាយនូវប្រការអាថ៌កំបាំងរបស់នាង”។ (មូស្លីមៈ១៤៣៧)

## 7 មិនត្រូវរំលោភបំពានទៅលើស្ត្រីឡើយ

សាសនាឥស្លាមបានដាក់ក្បួនច្បាប់មួយចំនួនដើម្បីដោះស្រាយបញ្ហាគ្រួសារ ក្នុងនោះមានដូចជា ៖

- គប្បីដោះស្រាយដោយការសន្ទនាគ្នា ផ្ដល់ដំបូន្មាន និងការប្រៀនប្រដៅដើម្បីកែកំហុស។
- ប្ដីអាចឈប់និយាយទៅកាន់ប្រពន្ធ ប៉ុន្តែមិនត្រូវលើសពីបីថ្ងៃឡើយ។ បន្ទាប់មក គាត់អាចបោះបង់ការរួមដំណេកជាមួយនាង ប៉ុន្តែដោយមិនត្រូវចាកចេញពីផ្ទះឡើយ។
- អាអ៊ីស្ហះបាននិយាយថា “អ្នកនាំសារមិនដែលវាយស្ត្រី ឬខ្ញុំបម្រើណាម្នាក់ឡើយ លើកលែងតែការប្រយុទ្ធក្នុងផ្លូវអល់ឡោះប៉ុណ្ណោះ”។ (មូស្លីមៈ២៣២៧៨)

គ្រួសាររបស់អ្នក

## 8 បង្រៀន និងផ្តល់ដំបូន្មានដល់នាង

ចាំបាច់បុរសជាស្វាមីត្រូវបង្គាប់ប្រើ និងហាមឃាត់ភរិយារបស់គាត់ និងត្រូវយកចិត្តទុកដាក់លើប្រការទាំងឡាយដែលនាំពួកគេទៅកាន់ឋានសួគ៌ និងការពារពួកគេពីភ្លើងឋាននរក តាមរយៈការជួយសម្រួលក្នុងការអនុវត្តនូវបទបញ្ជាទាំងឡាយរបស់អល់ឡោះ និងជម្រុញនាងទៅលើវា ហើយត្រូវរារាំងមិនឱ្យប្រព្រឹត្តនូវទង្វើទាំងឡាយដែលទ្រង់បានហាមឃាត់ និងគេចចេញឱ្យឆ្ងាយអំពីវា។ ហើយចំពោះស្ត្រីវិញក៏ដូចគ្នាដែរ គឺត្រូវយកចិត្តទុកដាក់លើការផ្តល់ដំបូន្មានដល់ប្តីរបស់នាង និងចង្អុលបង្ហាញគាត់ទៅរកផ្លូវដែលល្អ និងអប់រំកូនៗនូវការអប់រំដែលត្រឹមត្រូវ។ អល់ឡោះបានមានបន្ទូលថា "ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកថែរក្សាខ្លួនប្រាណរបស់ពួកអ្នកនិងក្រុមគ្រួសាររបស់ពួកអ្នកឱ្យផុតពីភ្លើងនរក ដែលវត្ថុសម្រាប់ដុតវានោះគឺមនុស្សនិងដុំថ្ម"។ (គម្ពីរគួរអាន ៦៦:៦)។ ហើយអ្នកនាំសារបានមានប្រសាសន៍ថា "ហើយបុរស គឺជាអ្នកគ្រប់គ្រងលើក្រុមគ្រួសាររបស់គាត់ ហើយត្រូវទទួលខុសត្រូវចំពោះអ្វីដែលគាត់គ្រប់គ្រងនោះ"។ (អាល់ពូខរី:២៤១៦ មូស្លីម:១៨២៩)

## 9 ការប្រកាន់ខ្ជាប់នូវលក្ខខណ្ឌរបស់ប្រពន្ធ

ប្រសិនបើស្ត្រីម្នាក់បានដាក់លក្ខខណ្ឌសម្រាប់ខ្លួនរបស់នាងលើកិច្ចការដែលគេអនុញ្ញាតក្នុងពេលរៀបអាពាហ៍ពិពាហ៍ ដូចជាប្រភេទពិសេសនៃលំនៅដ្ឋាន ការផ្គត់ផ្គង់ជីវភាព និងឱ្យប្តីបើបនាង់ជាដើមនោះ ចាំបាច់លើបុរសជាប្តីត្រូវតែបំពេញវា ហើយនេះ គឺជាលក្ខខណ្ឌចាំបាច់ត្រូវតែបំពេញវាជាដាច់ខាត និងត្រូវប្រកាន់ខ្ជាប់នឹងវា ពីព្រោះថា ការរៀបអាពាហ៍ពិពាហ៍រវាងប្តីប្រពន្ធ ស្ថិតក្នុងចំណោមកិច្ចសន្យាដ៏ធំធេងមួយដែលគេចាំបាច់ដាច់ខាតត្រូវតែបំពេញវា ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា "អ្វីដែលពួកអ្នកសាកសមបំពេញវាបំផុតអំពីលក្ខខណ្ឌនោះ គឺអ្វីដែលគេអនុញ្ញាតវាឱ្យពួកអ្នកក្នុងការទំនាក់ទំនងជាមួយការរៀបអាពាហ៍ពិពាហ៍"។ (អាល់ពូខរី:៤៨៥៦ មូស្លីម:១៤១៨)



> ចាំបាច់លើស្វាមី ត្រូវប្រកាន់ខ្ជាប់នឹងលក្ខខណ្ឌរបស់ភរិយាដែលបានរៀបរាប់នៅក្នុងកិច្ចសន្យាអាពាហ៍ពិពាហ៍។

## សិទ្ធិរបស់ប្តី

### 1 ចាំបាច់ត្រូវគោរពដោយសមរម្យ

អល់ឡោះបានផ្តល់ឱ្យបុរសនូវភាពជាអ្នកគ្រប់គ្រងលើស្ត្រី មានន័យថាទទួលខុសត្រូវលើកិច្ចការរបស់នាង ចង្អុលបង្ហាញនាង និងការថែរក្សានាង ដូចជាអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវលើអ្នកក្នុងបន្ទុករបស់គេដែរ ដោយសារតែអល់ឡោះបានផ្តល់នូវលក្ខណៈពិសេស និងឋានៈមួយចំនួនដល់បុរស និងដោយសារតែគេបានដាក់កាតព្វកិច្ចលើបុរសនូវកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ។ អល់ឡោះបានមានបន្ទូលថា "បុរសទាំងឡាយជាអ្នកគ្រប់គ្រងលើស្ត្រី ដោយសារអល់ឡោះបានលើកតម្កើងពួកគេឱ្យមានលក្ខណៈពិសេសជាងគ្នា និងដោយសារតែបុរសមានភារកិច្ចផ្គត់ផ្គង់ទ្រព្យសម្បត្តិរបស់ពួកគេ(ដល់ប្រពន្ធ)"។ (គម្ពីរគួរអាន ៤:៣៤)

### 2 ផ្តល់លទ្ធភាពឱ្យប្តីដើម្បីទទួលបានភាពរីករាយ(ជាមួយខ្លួន)

ក្នុងចំណោមសិទ្ធិរបស់ប្តីទៅលើប្រពន្ធ គឺការផ្តល់លទ្ធភាពឱ្យគាត់អាចទទួលបានភាពរីករាយ និងការរួមដំណេកជាមួយខ្លួន ហើយគប្បីលើភរិយាត្រូវតុបតែងខ្លួន និងរៀបចំខ្លួនសម្រាប់គាត់។ ប្រសិនបើប្រពន្ធបានបដិសេធមិនរួមដំណេកជាមួយស្វាមី(ដោយគ្មានមូលហេតុសមរម្យ) ទេនោះ នាងនឹងធ្លាក់ក្នុងប្រការដែលគេហាមឃាត់ និងបានប្រព្រឹត្តអំពើបាបកម្មដ៏ធំ លើកលែងតែមានមូលហេតុស្របច្បាប់(ដែលអាចបដិសេធបាន)ដូចជា មករដូវ បួស(កាតព្វកិច្ច) មានជំងឺ និងអ្វីដែលស្រដៀងនេះជាដើម។

អ្នកនាំសារមានប្រសាសន៍ថា "នៅពេលដែលបុរសបានហៅប្រពន្ធរបស់គាត់មករួមដំណេកជាមួយគាត់ តែនាងបានបដិសេធ ហើយគាត់ក៏គេងទាំងខឹងចំពោះនាងនោះ ម៉ាឡាអ៊ីកាត់នឹងដាក់បណ្តាសាឱ្យនាងរហូតដល់ភ្លឺ"។ (អាល់ពូខរីៈ៣០៦៥ មូស្លីមៈ១៤៣៦)

### 3 ស្ត្រីមិនត្រូវអនុញ្ញាតឱ្យអ្នកដែលប្តីមិនចូលចិត្តចូលក្នុងផ្ទះឡើយ

ក្នុងចំណោមសិទ្ធិរបស់ប្តីលើប្រពន្ធរបស់គាត់ដែរនោះ គឺមិនត្រូវឱ្យអ្នកដែលប្តីមិនពេញចិត្តចូលផ្ទះរបស់គាត់ឡើយ។ អ្នកនាំសារបានមានប្រសាសន៍ថា "ស្ត្រីមិនអាចបួសស៊ូណាត(បួសស្ម័គ្រចិត្ត)បានឡើយ ខណៈពេលដែលប្តីរបស់នាងនៅមានវត្តមានជាមួយនាងនោះ ហើយនាងក៏មិនត្រូវអនុញ្ញាតឱ្យអ្នកណាម្នាក់ចូលផ្ទះប្តីរបស់នាងឡើយ លើកលែងតែមានការអនុញ្ញាតអំពីប្តីរបស់នាង"។ (អាល់ពូខរីៈ៤៨៩៩)

### 4 ស្ត្រីមិនអាចចេញពីផ្ទះទេ លើកលែងតែមានការអនុញ្ញាតពីប្តីរបស់នាង

ក្នុងចំណោមសិទ្ធិរបស់ប្តីលើប្រពន្ធរបស់គាត់ផងដែរនោះ គឺភរិយាមិនអាចចេញពីផ្ទះឡើយ លើកលែងតែមានការអនុញ្ញាតពីប្តីរបស់នាង ទោះបីជាការអនុញ្ញាតដោយឡែកក្នុងការចេញទៅកន្លែងណាមួយច្បាស់លាស់ ឬការអនុញ្ញាតទូទៅក្នុងការចេញពីផ្ទះទៅកន្លែងធ្វើការរបស់នាង ឬទៅបំពេញកិច្ចការរបស់នាងក៏ដោយ។

### 5 ការបម្រើរបស់ប្រពន្ធចំពោះប្តី

គប្បីលើប្រពន្ធត្រូវបម្រើប្តីរបស់នាងឲ្យបានសមរម្យក្នុងការធ្វើម្ហូបអាហារ និងកិច្ចការផ្ទះទាំងឡាយ។

គ្រួសាររបស់អ្នក

# > ការលែងលះ

>សាសនាឥស្លាមបានជម្រុញឱ្យបន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ ហើយបានបញ្ជាក់យ៉ាងច្បាស់ទៅលើវា ក៏ប៉ុន្តែក៏បានចែងនៅក្នុងច្បាប់ដែលធ្វើឱ្យមានរបៀបរៀបរយលើដំណើរការលែងលះនៅពេលណាដែលប្តីប្រពន្ធទាំងពីរត្រូវការវាផងដែរ។




សាសនាឥស្លាមបានជម្រុញឱ្យស្ថិតនៅលើកិច្ចសន្យាអាពាហ៍ពិពាហ៍ជានិច្ច ហើយបន្តទំនាក់ទំនងអាពាហ៍ពិពាហ៍ឱ្យនៅមានជានិច្ចរវាងប្តីប្រពន្ធទាំងពីររហូតដល់ពួកគេបានស្លាប់។ ហើយអល់ឡោះបានឱ្យឈ្មោះអាពាហ៍ពិពាហ៍ថា ជាសម្ពន្ធ័មេត្រីដ៏មហិមា ហើយសាសនាឥស្លាមមិនអនុញ្ញាតឱ្យកំណត់ពេលបញ្ចប់អាពាហ៍ពិពាហ៍នោះឡើយ។

ក៏ប៉ុន្តែសាសនាឥស្លាមបានជំរុញឱ្យធ្វើដូច្នេះដើម្បីគ្រប់គ្រង។ ពិតណាស់ វាជាច្បាប់សម្រាប់មនុស្សដើម្បីរស់នៅលើផែនដីនេះ។ សម្រាប់ពួកគេមានលក្ខណៈពិសេសរបស់ពួកគេ និងលក្ខណៈធម្មជាតិរបស់ពួកគេដូច្នេះហើយបានជាគេដាក់ច្បាប់លើពួកគេ នូវរបៀបជំរះអំពីកិច្ចសន្យានេះ ប្រសិនបើមានការពិបាកក្នុងការរស់នៅ គ្មានផ្លូវជ្រើសរើស និងបរាជ័យរាល់វិធីសាស្ត្រក្នុងការកែលំអរ គឺត្រូវតែអនុវត្តទៅតាមភាពជាក់ស្តែង និងខណ្ឌចែករវាងពួកគេទាំងបុរស និងស្ត្រី។

អ្វីដែលកើតឡើងច្រើនរវាងប្តីប្រពន្ធគឺមកពីមូលហេតុ ការមិនពេញចិត្ត និងបញ្ហា ដែលជាហេតុធ្វើឱ្យការលែងលះជាប្រការចាំបាច់បំផុត និងជាវិធីសាស្ត្រច្បាស់លាស់ដើម្បីទទួលបានភាពល្អប្រសើរពិត និងមានស្ថេរភាពនៅក្នុងគ្រួសារ និងសង្គមរវាងពួកគេទាំងពីរ ពីព្រោះចំណងអាពាហ៍ពិពាហ៍របៀបនេះ វាមិនបានផ្តល់នូវអត្ថន័យពិតប្រាកដរបស់វានោះទេ ហើយការបែកបាក់រវាងប្តីប្រពន្ធ(ដែលមានសភាពបែបនេះ) បានក្លាយជាប្រការដែលនាំឱ្យមានការខូចខាតតិចជាងការរស់នៅជាមួយគ្នា។

ហេតុនេះហើយបានជាគេអនុញ្ញាតឱ្យមានការលែងលះដែលជាវិធីសាស្ត្រដើម្បីចាកចេញពីស្ថានភាពនេះ ហើយក៏ផ្លាស់ប្តូរពួកគេទាំងពីរនូវការរៀបការផ្សេងទៀត សង្ឃឹមថានឹងទទួលបានជាមួយនឹងអ្នកថ្មីនូវអ្វីដែលអ្នកមុនមិនមាន ហើយបានបញ្ជាក់ដូចនេះដោយបន្ទូលអល់ឡោះថា “ប៉ុន្តែប្រសិនបើគេទាំងពីរបែកបាក់គ្នា(លែងលះគ្នា)វិញនោះ អល់ឡោះនឹងផ្តត់ផ្តង់ដល់គេម្នាក់ៗនូវលាភសក្ការៈដ៏ទូលំទូលាយរបស់ទ្រង់។ អល់ឡោះមហាទូលំទូលាយ មហាគតិបណ្ឌិត”។ (គម្ពីរគួរអាន ៤:១៣០)

ក៏ប៉ុន្តែឥស្លាមបានដាក់ច្បាប់ និងវិន័យជាច្រើនដើម្បីគ្រប់គ្រងលើបញ្ហានេះ ដែលក្នុងនោះមានដូចជា ៖

- ជាគុដើមរបស់វា ការលែងលះគឺនៅក្នុងដៃរបស់បុរស មិនមែននៅក្នុងដៃស្ត្រីទេ។
- ចំពោះស្ត្រី នៅពេលដែលនាងមិនអាចបន្តរួមរស់ជាមួយនឹងប្តីរបស់ខ្លួនបាន ហើយប្តីក៏មិនព្រមលែងលះនាងទៀតនោះ នាងអាចស្នើសុំលែងលះពីចៅក្រម ហើយចៅក្រមអាចលែងលះឱ្យនាងបាន ប្រសិនបើហេតុផលសមរម្យ។
- គេអនុញ្ញាតឱ្យប្តីអាចត្រឡប់ទៅរកប្រពន្ធរបស់ខ្លួនវិញបានបន្ទាប់ពីការលែងលះពីរដងរួច តែប្រសិនបើគេលែងលះនាងជាលើកទីបីហើយនោះ គឺប្តីមិនអាចរៀបការជាមួយនាងបានទេ រហូតទាល់តែនាងបានរៀបការជាមួយបុរសដ៏ទៃទៀតដោយរៀបការពេញលេញ។ ហើយការលែងលះតាមច្បាប់ឥស្លាមនោះគឺបុរសត្រូវលែងលះប្រពន្ធរបស់គាត់នៅក្នុងពេលជ្រះស្អាត ដោយមិនទាន់បានរួមដំណេកជាមួយនាង។

## > សិទ្ធិរបស់ឪពុកម្តាយ





គេចាត់ទុកភាពកតញ្ញូចំពោះឪពុកម្តាយ និងការធ្វើល្អទៅចំពោះគាត់ទាំងពីរជាកិច្ចការដែលល្អប្រសើរបំផុត ហើយទទួលបានផលបុណ្យច្រើនអំពីអល់ឡោះ ហើយពិតណាស់ អល់ឡោះបានភ្ជាប់ការធ្វើល្អចំពោះឪពុកម្តាយជាមួយនឹងការគោរពសក្ការៈទៅចំពោះទ្រង់ និងជំនឿទៅចំពោះទ្រង់។

ហើយបានចាត់ទុកភាពកតញ្ញូ និងការធ្វើល្អទៅចំពោះគាត់ទាំងពីរ ជាមូលហេតុដ៏ចម្បងមួយក្នុងការចូលឋានសួគ៌។ អ្នកនាំសារបានមានប្រសាសន៍ថា “ឪពុកម្តាយ គឺជាទ្វារឋានសួគ៌ដែលល្អជាងគេ។ ហេតុនេះ ប្រសិនបើអ្នកចង់បោះបង់ទ្វារនោះ ឬថែរក្សាវា គឺអាស្រ័យលើអ្នក”។ (អាត់តៀរមីហ្ស៊ី:១៩០០)

- **គ្រោះថ្នាក់នៃការធ្វើអកតញ្ញូចំពោះឪពុកម្តាយ និងធ្វើអាក្រក់ទៅលើគាត់ទាំងពីរ**

ស្ថិតក្នុងចំណោមអំពើបាបដ៏ធំបំផុតដែលច្បាប់ឥស្លាមបានឯកភាពឱ្យហាមឃាត់វា និងឱ្យប្រុងប្រយ័ត្នអំពីវានោះគឺ ការធ្វើអាក្រក់ជាមួយឪពុកម្តាយ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ទៅកាន់មិត្តភក្តិរបស់លោកថា “តើពួកអ្នកចង់ឱ្យខ្ញុំប្រាប់ពីបាបកម្មដ៏ធំបំផុតឬទេ"? ពួកគេបានឆ្លើយថា "ឱអ្នកនាំសារ! ពួកយើងចង់"។ លោកបានមានប្រសាសន៍ថា “គឺការធ្វើស្ហ៊ីរិក(ពហុទេពនិយម)ចំពោះអល់ឡោះ និងការធ្វើអំពើអកតញ្ញូចំពោះឪពុកម្តាយ”។ (អាល់ពូខរី:៥៩១៨)

• ការគោរពប្រតិបត្តិតាមគាត់ទាំងពីរក្រៅពីប្រការដែលប្រឆាំងនឹងអល់ឡោះ

ចាំបាច់ត្រូវគោរពប្រតិបត្តិគាត់ទាំងពីររាល់ប្រការទាំងឡាយណាដែលគាត់ទាំងពីរបានបញ្ជារប្រើ លើកលែងតែវាជាប្រការដែលប្រឆាំងនឹងអល់ឡោះ មិនត្រូវគោរពតាមគាត់ទាំងពីរឡើយ ពីព្រោះគ្មានទេការគោរពធ្វើតាមមនុស្សលោកដែលគេបានបង្កើត ក្នុងប្រការដែលប្រឆាំងនឹងអ្នកអល់ឡោះដែលជាអ្នកបង្កើតនោះទេ។ អល់ឡោះបានមានបន្ទូលថា “ហើយយើងបានបង្គាប់ប្រើមនុស្សលោកឱ្យធ្វើល្អចំពោះឪពុកម្ដាយរបស់គេ តែប្រសិនបើគាត់ទាំងពីរបង្ខំអ្នកឱ្យធ្វើស្ហ៊ីរិកចំពោះយើងនូវអ្វីដែលអ្នកគ្មានចំណេះដឹងនឹងវាទេនោះ ចូរអ្នកកុំប្រតិបត្តិតាមពួកគាត់ទាំងពីរឱ្យសោះ”។ (គម្ពីរគួរអាន ២៩:៨)

• ធ្វើល្អជាមួយគាត់ទាំងពីរ ជាពិសេសក្នុងពេលគាត់ទាំងពីរចាស់ជរា

អល់ឡោះបានមានបន្ទូលថា “ហើយម្ចាស់របស់អ្នកបានបញ្ជាថា ពួកអ្នកមិនត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ ហើយត្រូវតែធ្វើល្អទៅចំពោះឪពុកម្ដាយ។ ប្រសិនបើម្នាក់នៃគាត់ទាំងពីរ ឬគាត់ទាំងពីរមានភាពចាស់ជរានៅជាមួយអ្នក ចូរអ្នកកុំនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសំដីមិនសមរម្យ ឬគំហកដាក់គាត់ទាំងពីរឱ្យសោះ។ តែអ្នកត្រូវនិយាយទៅកាន់គាត់ទាំងពីរនូវពាក្យសម្ដីណាដែលទន់ភ្លន់បំផុត”។ (គម្ពីរគួរអាន ១៧:២៣)

អល់ឡោះបានប្រាប់ថា ពិតណាស់ទ្រង់បានដាក់កាតព្វកិច្ចជាចាំបាច់លើមនុស្សឱ្យគោរពប្រតិបត្តិតាមឪពុកម្ដាយរបស់គេ ហើយមិនត្រូវប្រើពាក្យសំដីមិនសមរម្យ ឬគំហកដាក់គាត់ទាំងពីរឡើយ ជាពិសេស ក្រោយពេលគាត់ទាំងពីរចាស់ជរា និងទន់ខ្សោយ សូម្បីតែនោះគ្រាន់តែជាកាយវិការមិនសមរម្យដោយមិនប្រើសម្ដីនិយាយក៏ដោយ។

• ឪពុកម្ដាយជាអ្នកគ្មានជំនឿ

ចាំបាច់លើជនមូស្លីមត្រូវកតញ្ញូចំពោះឪពុកម្ដាយ គោរពតាមគាត់ និងធ្វើល្អជាមួយគាត់ សូម្បីតែគាត់ជាអ្នកគ្មានជំនឿក៏ដោយ។ អល់ឡោះបានមានបន្ទូលថា “ហើយប្រសិនបើគាត់ទាំងពីរ(ឪពុកម្ដាយ)ព្យាយាមជម្រុញឱ្យអ្នកធ្វើស្ហ៊ីរិកជាមួយយើង(អល់ឡោះ) នូវអ្វីដែលអ្នកមិនបានដឹងវាទេនោះ ចូរអ្នកកុំស្ដាប់បង្គាប់គាត់ទាំងពីរឱ្យសោះ។ តែអ្នកកតញ្ញូចំពោះគាត់ទាំងពីរនៅក្នុងលោកិយនេះដោយអំពើល្អ”។ (គម្ពីរគួរអាន ៣១:១៥)



## > សិទ្ធិរបស់កូនៗ



- ការជ្រើសរើសភរិយាដ៏ល្អម្នាក់ដើម្បីក្លាយជាម្ដាយដ៏ល្អម្នាក់ គឺជាអំណោយដ៏ធំធេងបំផុតដែលឪពុកផ្ដល់ជូនឱ្យកូនៗរបស់គេ។

- ដាក់ឈ្មោះឲ្យពួកគេនូវឈ្មោះដែលល្អ ពិរោះ ពីព្រោះវានឹងក្លាយជាសញ្ញាយ៉ាងជាក់លាក់សម្រាប់កូន

- ត្រូវអប់រំពួកគេឱ្យបានល្អ និងបង្រៀនពួកគេអំពីគោលគ្រឹះនៃសាសនា និងធ្វើឱ្យពួកគេស្រលាញ់ទៅចំពោះវា។ អ្នកនាំសារបានមានប្រសាសន៍ថា “ពួកអ្នកគ្រប់គ្នាសុទ្ធតែជាអ្នកគ្រប់គ្រង ហើយពួកអ្នកនឹងត្រូវទទួលខុសត្រូវនូវអ្វីដែលគេគ្រប់គ្រងនោះ។ មេដឹកនាំ គឺជាអ្នកគ្រប់គ្រងលើមនុស្ស ហើយគាត់ត្រូវទទួលខុសត្រូវចំពោះពួកគេ។ បុរស គឺជាអ្នកគ្រប់គ្រងលើក្រុមគ្រួសាររបស់គាត់ ហើយគាត់ជាអ្នកទទួលខុសត្រូវចំពោះពួកគេ។ ស្ត្រី គឺជាអ្នកគ្រប់គ្រងលើផ្ទះប្ដីរបស់នាង និងកូនៗរបស់គាត់ ហើយនាងជាអ្នកទទួលខុសត្រូវចំពោះពួកគេ។ ហេតុនេះ ពួកអ្នកទាំងអស់គ្នា ជាអ្នកគ្រប់គ្រង ហើយពួកអ្នកទាំងអស់គ្នា នឹងត្រូវទទួលខុសត្រូវចំពោះអ្នកដែលនៅក្រោមការគ្រប់គ្រងរបស់អ្នក”។ (អាល់ពូខរី:២៤១៦ មូស្លីម:១៨២៩)។ ឪពុកម្ដាយត្រូវចាប់ផ្ដើមបង្រៀនកូនៗរបស់ពួកគេទៅលើប្រការណាដែលសំខាន់ជាងគេបំផុតនោះ ហើយប្រការសំខាន់បំផុតដែលត្រូវចាប់ផ្ដើមអប់រំពួកគេមុនគេនោះ គឺអំពីគោលជំនឿដ៏ត្រឹមត្រូវជ្រះស្អាតអំពីស្ហ៊ីរិក(ពហុទេពនិយម) និងប្រការបង្កើតថ្មីក្នុងសាសនា(ពិទអះ)។ បន្ទាប់មក បង្រៀនអំពីការគោរពសក្ការៈ ជាពិសេសការប្រតិបត្តិសឡាត។ បន្ទាប់មកទៀត បង្រៀននិងអប់រំពួកគេអំពីសុជីវធម៌ និងសីលធម៌ដែលគេកោតសសើរ និងរាល់អ្វីដែលមានតម្លៃ និងល្អប្រសើរ។ ហើយទាំងនេះក្នុងគោលបំណងបម្រើឲ្យការគោរពប្រតិបត្តិទៅចំពោះអល់ឡោះ។

- ផ្គត់ផ្គង់ជីវភាព: ចាំបាច់លើឪពុកត្រូវផ្គត់ផ្គង់ប្រាក់ដល់កូនៗទាំងប្រុសទាំងស្រី ហើយមិនអនុញ្ញាតឱ្យគាត់កាត់បន្ថយ ឬបោះបង់ចោលឡើយ។ ប៉ុន្តែ ចាំបាច់លើឪពុកត្រូវផ្គត់ផ្គង់ដល់កូនៗឲ្យបានល្អត្រឹមត្រូវ ទៅតាមសមត្ថភាព និងលទ្ធភាពរបស់គាត់។ អ្នកនាំសារបានមានប្រសាសន៍ថា “គ្រប់គ្រាន់ហើយបាបកម្មរបស់បុគ្គលម្នាក់ នៅពេលដែលគាត់បោះបង់ចោលអ្នកដែលគាត់មានភារកិច្ចផ្គត់ផ្គង់អាហារដល់គេ”។ (អាពូហ្ជាវូទ:១៦៩២)។ ហើយអ្នកនាំសារបានមានប្រសាសន៍ចំពោះការគ្រប់គ្រង និងការផ្គត់ផ្គង់លើកូនស្រីដោយឡែកថា “បុគ្គលណាហើយដែលមានកូនស្រីច្រើននៅក្រោមការគ្រប់គ្រងរបស់គាត់ ហើយគាត់អប់រំពួកនាងឱ្យបានល្អនោះ ពួកនាងនឹងក្លាយជារបាំងការពារគាត់ពីភ្លើងនរក”។ (អាល់ពូខរី:៥៦៤៩ មូស្លីម:២៦២៩)

- មានភាពយុត្តិធម៌រវាងកូនៗទាំងប្រុស ទាំងស្រី ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា “ចូរពួកអ្នកកោតខ្លាចចុះទៅចំពោះអល់ឡោះ ហើយចូរពួកអ្នកផ្តល់ភាពយុត្តិធម៌រវាងកូនៗរបស់ពួកអ្នក”។ (អាល់ពូខរី:២៤៤៧ មូស្លីម:១៦២៣)។ ដូចនេះ គេមិនអនុញ្ញាតឱ្យលើកតម្កើង ឬស្រឡាញ់កូនស្រីជាងកូនប្រុសនោះទេ ហើយក៏មិនអនុញ្ញាតឱ្យលើកតម្កើង ឬស្រឡាញ់កូនប្រុសជាងកូនស្រីនោះដែរ ពីព្រោះធ្វើដូច្នោះនិងនាំឱ្យមានវិនាសកម្ម។ អល់ឡោះមហាដឹងបំផុតអំពីវា។





# សីលធម៌របស់អ្នកនៅក្នុងសាសនាឥស្លាម



# 11

សីលធម៌នៅក្នុងសាសនាឥស្លាមមិនមែនជាប្រការល្អប្រណិត ឬការបំពេញអ្វីមួយទេ ប៉ុន្តែជាផ្នែកមួយនៃការសហការគ្នាមួយដែលភ្ជាប់ទៅនឹងសាសនានៅក្នុងទិដ្ឋភាពទាំងអស់ដែលនៅជិតខ្លួនរបស់គេ។ សម្រាប់សីលធម៌នៅក្នុងសាសនាឥស្លាម វាមានតម្លៃឧត្តុងឧត្តម និងឋានៈខ្ពស់បំផុត ហើយទាំងអស់នោះត្រូវបានបង្ហាញនៅក្នុងបទបញ្ញត្តិ និងច្បាប់ទាំងអស់នៃសាសនាឥស្លាម ហើយគេបានតែងតាំងព្យាការីមូហាំម៉ាត់មក គឺដើម្បីបំពេញសីលធម៌ដ៏ល្អឥតខ្ចោះនេះឯង។

## មាតិកាជំពូក

### ឋានៈរបស់សីលធម៌ក្នុងសាសនាឥស្លាម

- វាគឺជាផ្នែកមួយនៃគោលបំណងសំខាន់បំផុតនៃការតែងតាំងព្យាការី
- សីលធម៌ជាផ្នែកមួយយ៉ាងជិតស្និទ្ធនៃជំនឿ និងការជឿជាក់
- សីលធម៌មានទំនាទំនងជាមួយនឹងការគោរពសក្ការៈគ្រប់ប្រភេទ
- គុណសម្បត្តិដ៏អស្ចារ្យ និងផលបុណ្យយ៉ាងធំធេងដែលអល់ឡោះបានរៀបចំសម្រាប់អ្នកដែលមានសីលធម៌ល្អ

### លក្ខណៈពិសេសនៃសីលធម៌ក្នុងសាសនាឥស្លាម

- សីលធម៌ល្អ គឺមិនមែនសម្រាប់តែប្រភេទមនុស្សមួយចំនួននោះទេ
- សីលធម៌ល្អ គឺមិនមែនសម្រាប់តែមនុស្សនោះទេ
- សីលធម៌ល្អមានគ្រប់វិស័យទាំងអស់នៃជីវិត
- សីលធម៌ល្អមានគ្រប់ករណីទាំងអស់

### រូបភាពក្នុងសម័យកាលព្យាការីរស់នៅ

- ឱនលំទោន
- មេត្តាករុណា
- យុត្តិធម៌
- សប្បុរសធម៌ និងចិត្តទូលាយ

# ឋានៈរបស់សីលធម៌ក្នុងសាសនាឥស្លាម



>ការបំពេញសីលធម៌ល្អ គឺជាគោលដៅដ៏ចម្បងនៃការតែងតាំងព្យាការីមូហាំម៉ាត់។

១ វាគឺជាផ្នែកមួយនៃគោលបំណងសំខាន់បំផុតនៃការតែងតាំងព្យាការីមកកាន់មនុស្សលោក។ អល់ឡោះបានមានបន្ទូលថា "ទ្រង់គឺជាអ្នកដែលបានចាត់តាំងអ្នកនាំសារម្នាក់អំពីពួកគេក្នុងចំណោមពួកអវិជ្ជា ដោយគាត់សូត្រវាក្យខណ្ឌទាំងឡាយរបស់ទ្រង់ឱ្យពួកគេស្តាប់ និងសម្អាតពួកគេ( ពីប្រការស្ហ៊ីរិក )"។ (គម្ពីរគួរអាន ៦២:២)។ អល់ឡោះបានផ្តល់ឱ្យអ្នកដែលមានជំនឿដោយតែងតាំងអ្នកនាំសារម្នាក់ដើម្បីបង្រៀនគួរអានដល់ពួកគេនឹងសំអាតពួកគេ។ ការជម្រះសម្អាតនោះមានន័យថាជម្រះចិត្តពួកគេអំពីប្រការពហុទេពនិយម និងសីលធម៌អាក្រក់ដូចជាការនិយមជ្រុល និងការឈ្នានីស ហើយនិងជម្រះសម្អាតពាក្យសំដី ទង្វើអសីលធម៌ និងទម្លាប់អាក្រក់។ ព្យាការីបានមានប្រសាសន៍យ៉ាងច្បាស់ថា "ពិតប្រាកដណាស់ គេបានចាត់តាំងខ្ញុំមក គឺដើម្បីបំពេញនូវសីលធម៌ដ៏ល្អឥតខ្ចោះ"។ (អាល់ពៃហាគី:២១៣០១)។ ដូចនេះ មួយក្នុងចំណោមហេតុផលចម្បងនៃការតែងតាំងនេះ គឺការលើកតម្កើង និងភាពខ្ពង់ខ្ពស់នៃសីលធម៌បុគ្គល និងសង្គម។

២ សីលធម៌ជាផ្នែកមួយយ៉ាងជិតស្និទ្ធនៃជំនឿ និងការជឿជាក់

នៅពេលដែលគេសួរអ្នកនាំសារថា "តើអ្នកដែលមានជំនឿបែបណាដែលល្អជាងគេនោះ"? លោកបានមានប្រសាសន៍ថា "គឺអ្នកដែលមានសីលធម៌ល្អជាងគេ"។ (អាត់តៀរមីហ្ស៊ី:១១៦២ អាពូហ្ទាវូត:៤៦៨២)

អល់ឡោះបានអោយឈ្មោះជំនឿថា ជាអំពើល្អ ដោយអល់ឡោះបានមានបន្ទូលថា "ការតម្រង់មុខរបស់ពួកអ្នកឆ្ពោះទៅទិសខាងលិចនោះមិនចាត់ទុកជាអំពើល្អឡើយ។ ប៉ុន្តែអំពើល្អនោះគឺអ្នកណាដែលមានជំនឿលើអល់ឡោះ និងថ្ងៃបរលោក បណ្តាម៉ាឡាអ៊ីកាត់របស់ទ្រង់ព្រះគម្ពីទាំងឡាយ និងបណ្តាព្យាការី"។ (គម្ពីរគួរអាន ២:១៧៧)។ អំពើល្អ គឺជាពាក្យទូលំទូលាយដែលក្តោបលើប្រការល្អគ្រប់ប្រភេទអំពីសីលធម៌ ពាក្យសំដី និងកាយវិការ។ ដូច្នេះហើយបានជាអ្នកនាំសារមានប្រសាសន៍ថា "អំពើល្អ គឺសីលធម៌ល្អ"។ (មូស្លីមៈ២៥៥៣)

វាបានបង្ហាញយ៉ាងច្បាស់នៅក្នុងប្រសាសន៍របស់អ្នកនាំសារថា" ជំនឿមានច្រើនជាង៦០ផ្នែក។ លំដាប់ខ្ពស់បំផុតនោះ គឺការពោលពាក្យ( لا إله إلا الله ) គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវមានតែអល់ឡោះ ហើយលំដាប់ក្រោមបំផុតគឺការយកអ្វីដែលបង្កបញ្ហាដល់អ្នកធ្វើដំណើរចេញពីផ្លូវ ហើយការខ្មាស់អៀន ក៏ជាផ្នែកមួយនៃជំនឿដែរ។ (មូស្លីមៈលេខ៣៥)

៣ សីលធម៌មានទំនាក់ទំនងជាមួយនឹងការគោរពសក្ការៈគ្រប់ប្រភេទ

គ្មានទេអល់ឡោះទ្រង់បញ្ជាប្រើឱ្យធ្វើការគោរពសក្ការៈ លើកលែងតែទ្រង់បានណែនាំអំពីគោលដៅរបស់វា គឺសីលធម៌ល្អ ឬផលបុណ្យរបស់វាមកលើខ្លួនឯងផ្ទាល់ ឬសង្គម។ ឧទាហរណ៍ដែលបញ្ជាក់ដូចនេះ គឺមានច្រើន ក្នុងនោះមានដូចជា ៖

សទ្បាត: អល់ឡោះបានមានបន្ទូលថា "ចូរអ្នកប្រតិបត្តិសទ្បាត។ ពិតប្រាកដណាស់ សទ្បាតអាចហាមឃាត់អំពីការប្រព្រឹត្តអសីលធម៌ និងអំពើទុច្ចរិត"។ (គម្ពីរគួរអាន ២៩:៤៥)

ការបរិច្ចាគទាន: អល់ឡោះបានមានបន្ទូលថា "ចូរអ្នក(ព្យាការីមូហាំម៉ាត់)យកការបរិច្ចាគពីទ្រព្យសម្បត្តិរបស់ពួកគេមួយចំនួនដើម្បីជម្រះ និងសំអាត(បាបកម្ម)ពួកគេដោយការបរិច្ចាគនេះ"។ (គម្ពីរគួរអាន ៩:១០៣)។ ការបរិច្ចាគទានពិតប្រាកដនោះ គឺការធ្វើអំពើល្អចំពោះមនុស្សនឹងចូលរួមរំលែកទុក្ខពួកគេ ហើយវាក៏ជាការអប់រំខ្លួន និងជម្រះសម្អាតអំពីសីលធម៌អាក្រក់ផងដែរ។

បួស: អល់ឡោះបានមានបន្ទូលថា "អល់ឡោះបានដាក់កាតព្វកិច្ចបួសមកលើពួកអ្នក ដូចដែលទ្រង់បានដាក់កាតព្វកិច្ចបួសនេះទៅលើពួកអ្នកជំនាន់មុនៗដែរ ដើម្បីឱ្យពួកអ្នកកោតខ្លាចអល់ឡោះ"។ (គម្ពីរគួរអាន ២:១៨៣)។ មានអត្ថន័យថា ការកោតខ្លាចចំពោះអល់ឡោះដោយធ្វើតាមអ្វីដែលទ្រង់បានបង្គាប់បញ្ជាប្រើ និងជៀសឆ្ងាយពីអ្វីដែលទ្រង់បានហាមឃាត់។ អ្នកនាំសារបានមានប្រសាសន៍ថា "នរណាហើយដែលមិនបោះបង់ចោលនូវពាក្យសំដីអាក្រក់ហើយនៅតែធ្វើវានោះ សម្រាប់អល់ឡោះគឺរូបគេគ្មានបានផលប្រយោជន៍អ្វីអំពីការបោះបង់ចំណីអាហារ និងភេសជ្ជៈរបស់គេនោះទេ"។ (អាល់ពូខរី:១៨០៤)។ នរណាហើយដែលការបួសរបស់គេមិនបានជះឥទ្ធិពលអ្វីដល់ខ្លួនរបស់គេ និងសីលធម៌របស់គេជាមួយមនុស្សទេនោះ ពិតណាស់ រូបគេមិនបានទៅដល់គោលដៅពិតប្រាកដនៃការបួសឡើយ។

## ៤ គុណសម្បត្តិដ៏អស្ចារ្យនិងផលបុណ្យយ៉ាងធំធេងដែលអល់ឡោះបានរៀបចំសម្រាប់អ្នកដែលមានសីលធម៌ល្អ

មានភស្តុតាងជាច្រើនអំពីគម្ពីរគួរអាន និងប្រសាសន៍របស់ព្យាការីដែលទាក់ទងនឹងវា ដូចជា ៖

- វាគឺជាទង្វើកុសលដែលធ្ងន់ជាងគេនៅលើជញ្ជីងនៅថ្ងៃបរលោក: ព្យាការីបានមានប្រសាសន៍ថា "គ្មានអ្វីមួយដែលមានទម្ងន់លើជញ្ជីង(នៅថ្ងៃបរលោក)ធ្ងន់ជាងសីលធម៌ល្អនោះឡើយ។ សម្រាប់អ្នកដែលមានសីលធម៌ល្អអាចនឹងឈានទៅដល់ឋានៈរបស់អ្នកបួស និងអ្នកសទ្បាត។ (អាត់តៀរមីហ្ស៊ី:២០០៣)
- វាជាមូលហេតុដ៏ចម្បងមួយដែលនាំឱ្យបានចូលឋានសួគ៌

ព្យាការីបានមានប្រសាសន៍ថា "ប្រការដែលធ្វើឱ្យមនុស្សចូលឋានសួគ៌ច្រើនជាងគេ គឺការកោតខ្លាចអល់ឡោះ និងសីលធម៌ល្អ"។ (អាត់តៀរមីហ្ស៊ី:២០០៤ អ៊ិពនូម៉ាហ្ជះ:៤២៤៦)

- អ្នកដែលមានសីលធម៌ល្អ ជាមនុស្សដែលមានឋានៈជិតទៅចំពោះអ្នកនាំសារបំផុតនៅថ្ងៃបរលោក

ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា "ពិតប្រាកដណាស់ អ្នកដែលខ្ញុំស្រលាញ់ជាងគេបំផុតក្នុងចំណោមពួកអ្នក និងនៅជិតខ្ញុំជាងគេនៅថ្ងៃបរលោកនោះ គឺអ្នកដែលមានសីលធម៌ល្អជាងគេក្នុងចំណោមពួកអ្នក"។ (អាត់តៀរមីហ្ស៊ី:២០១៨)

- រូបគេនឹងបាននៅក្នុងឋានសួគ៌លំដាប់ខ្ពស់ជាងគេដោយមានការធានា និងការបញ្ជាក់ពីអ្នកនាំសារ

ព្យាការីបានមានប្រសាសន៍ថា "ខ្ញុំជាអ្នកធានានូវផ្ទះមួយនៅក្នុងឋានសួគ៌លំដាប់ទាបជាងគេសម្រាប់ជនណាហើយដែលបោះបង់ចោលការឈ្លោះប្រកែកគ្នា សូម្បីតែគាត់ត្រូវក៏ដោយ។ ខ្ញុំក៏ធានានូវផ្ទះមួយនៅចំកណ្តាលនៃឋានសួគ៌សម្រាប់អ្នកដែលបោះបង់ការភូតកុហក សូម្បីតែនៅក្នុងការលេងសើចក៏ដោយ។ ហើយខ្ញុំក៏ធានានូវផ្ទះមួយទៀតនៅក្នុងឋានសួគ៌លំដាប់ខ្ពស់ជាងគេ សម្រាប់អ្នកដែលមានសីលធម៌ល្អ"។ (អាពូហ្ទាវូទ:៤៨០០)

# លក្ខណៈពិសេសនៃសីលធម៌ក្នុងសាសនាឥស្លាម

គេកត់សម្គាល់សីលធម៌នៅក្នុងសាសនាឥស្លាមដោយលក្ខណៈពិសេស និងចំនុចសំខាន់មួយចំនួនដែលមានតែនៅក្នុងសាសនាដ៏ឧត្តុងឧត្តមនេះមួយគត់ ដូចជា ៖

## ១. សីលធម៌ល្អ គឺមិនមែនសម្រាប់តែប្រភេទមនុស្សមួយចំនួននោះទេ

អល់ឡោះបានបង្កើតមនុស្សដោយមានមុខមាត់ ពណ៌សម្បុរ និងភាសាខុសៗគ្នា ហើយក៏បានដាក់ពួកគេនៅលើជញ្ជីងរបស់អល់ឡោះដោយមានលក្ខណៈស្មើភាពគ្នា ដោយមិនឱ្យមាននរណាម្នាក់អំពីពួកគេល្អជាងនរណាម្នាក់ឡើយ លើកលែងតែសេចក្តីជំនឿ ការកោតខ្លាច និងអំពើល្អរបស់ពួកគេប៉ុណ្ណោះ ដូចដែលអល់ឡោះបានមានបន្ទូលថា "មនុស្សលោកទាំងឡាយ! ពិតប្រាកដណាស់ យើងបានបង្កើតពួកអ្នកពីបុរសនិងស្ត្រី ហើយយើងធ្វើអោយពួកអ្នកមានជនជាតិនិងកុលសម្ព័ន្ធជាច្រើន ដើម្បីឱ្យពួកអ្នកស្គាល់គ្នាទៅវិញទៅមក។ ពិតប្រាកដណាស់ អ្នកដែលថ្កុំថ្កើងជាងគេចំពោះអល់ឡោះក្នុងចំណោមពួកអ្នក គឺអ្នកដែលកោតខ្លាចអល់ឡោះជាងគេក្នុងចំណោមពួកអ្នក"។ (គម្ពីរគួរអាន ៤៩:១៣)

សីលធម៌ល្អ បញ្ជាក់ពីទំនាក់ទំនងរវាងអ្នកមូស្លីម និងមនុស្សដទៃទៀតដោយមិនមានភាពខុសគ្នាឡើយរវាងអ្នកមាននិងអ្នកក្រ ឬអ្នកឋានៈខ្ពង់ខ្ពស់និងអ្នកមានឋានៈតូចទាប ឬអ្នកស្បែកខ្មៅនិងអ្នកស្បែកស ឬជនជាតិអារ៉ាប់និងជនជាតិដទៃទៀតនោះឡើយ។

សីលធម៌ជាមួយនឹងអ្នកមិនមែនមូស្លីម

អល់ឡោះបានប្រើឱ្យធ្វើអំពើល្អជាមួយនឹងអ្វីគ្រប់យ៉ាងទាំងអស់។ ភាពយុត្តិធម៌ សប្បុរសធម៌ និងក្តីមេត្តាករុណា គឺជាសីលធម៌របស់អ្នកមូស្លីម ដែលតំណាងឱ្យរូបគេក្នុងឥរិយាបទ និងពាក្យសំដីរបស់គេជាមួយនឹងអ្នកមូស្លីម និងអ្នកមិនមែនមូស្លីម ហើយចាំបាច់ត្រូវតែថែរក្សាសីលធម៌ល្អនោះដោយសារវាជាមាគ៌ាសម្រាប់អំពាវនាវអ្នកមិនមែនមូស្លីមឱ្យចូលក្នុងសាសនាដ៏ថ្កុំថ្កើងនេះ។ អល់ឡោះបានមានបន្ទូលថា "អល់ឡោះមិនហាមឃាត់ពួកអ្នកក្នុងការធ្វើល្អ និងផ្តល់ភាពយុត្តិធម៌ចំពោះពួកដែលមិនបានធ្វើសង្គ្រាមប្រឆាំងនឹងពួកអ្នកនៅក្នុងសាសនា និងមិនបានបណ្តេញពួកអ្នកចេញពីលំនៅដ្ឋានរបស់ពួកអ្នកឡើយ។ ពិតប្រាកដណាស់ អល់ឡោះស្រលាញ់បណ្តាអ្នកដែលប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌"។ (គម្ពីរគួរអាន ៦០:៨)



អ្នកមូស្លីមធ្វើការទំនាក់ទំនងដោយសីលធម៌ល្អជាមួយនឹងមនុស្សគ្រប់រូប បើទោះបីជាជាតិសាសន៍ ឬសាសនាខុសគ្នាក៏ដោយ

ប៉ុន្តែ អល់ឡោះបានហាមឃាត់ពួកយើងមិនឱ្យគាំទ្រអ្នកដែលមិនមែនមូស្លីម និងស្រលាញ់អ្វីដែលពួកគេកំពុងប្រព្រឹត្តអំពីការប្រឆាំង និងការស្អីរកើឡើយ ដូចដែលអល់ឡោះបានមានបន្ទូលថា "ពិតប្រាកដណាស់ អល់ឡោះបានហាមឃាត់ពួកអ្នកមិនឱ្យបង្កើតមិត្តភាពជាមួយពួកដែលបានធ្វើសង្គ្រាមប្រឆាំងនឹងពួកអ្នកនៅក្នុងសាសនា និងបានបណ្តេញពួកអ្នកចេញពីលំនៅដ្ឋានរបស់ពួកអ្នក ហើយពួកគេជួយអ្នកដទៃបណ្តេញពួកអ្នកទៀត។ អ្នកណាហើយដែលយកពួកគេធ្វើជាមិត្តនោះ អ្នកទាំងនោះគឺជាអ្នកបំពាន"។ (គម្ពីរគួរអាន ៦០:៩)

## ២. សីលធម៌ល្អ គឺមិនមែនសម្រាប់តែមនុស្សនោះទេ

សីលធម៌ជាមួយនឹងសត្វពាហនៈ

អ្នកនាំសារបានប្រាប់យើងអំពីស្ត្រីម្នាក់បានចូលឋាននរកដោយសារគាត់ឃុំឃាំងឆ្មាមួយក្បាល ហូតទាល់តែស្លាប់ដោយសារការស្រេកឃ្លាន។ ផ្ទុយពីនេះ គាត់បានប្រាប់យើងអំពីបុរសម្នាក់ដែលអល់ឡោះបានជម្រះចោលនូវបាបកម្មរបស់គាត់ ដោយគាត់បានផ្តល់ទឹកដល់សត្វឆ្កែនៅពេលដែលវាស្រេកទឹកខ្លាំង។ ព្យាការីបានមានប្រសាសន៍ថា "ស្ត្រីម្នាក់បានចូលឋាននរកដោយសារឆ្មាមួយក្បាល ដោយសារតែនាងបានឃុំឃាំងវាទុកដោយមិនឱ្យចំណីវាស៊ី ហើយក៏មិនដោះលែងវាឱ្យដើររកចំណីនៅលើផែនដីដោយខ្លួនឯងដែរ"។ (អាល់ពូខរី:៣១៤០ មូស្លីម:២៦១៩)

ហើយព្យាការីមានប្រសាសន៍ផងដែរថា "នៅពេលដែលបុរសម្នាក់កំពុងដើរតាមផ្លូវមួយ ស្រាប់តែគាត់ស្រេកទឹកយ៉ាងខ្លាំង។ ពេលនោះគាត់ក៏បានឃើញអណ្តូងមួយ ហើយគាត់ក៏បានចុះទៅផឹកទឹកអណ្តូងនោះ បន្ទាប់មកគាត់ក៏បានចេញមកវិញ។ ខណៈពេលនោះ គាត់បានឃើញសត្វឆ្កែមួយក្បាលកំពុងតែយកអណ្តាតរបស់វាលិទ្ធដីភក់ដោយការស្រេកទឹកខ្លាំង។ បុរសម្នាក់នោះក៏បានគិតថា ឆ្កែនេះកំពុងតែស្រេកទឹកខ្លាំងដូចខ្ញុំមុននេះអញ្ចឹង ហើយគាត់ក៏បានចុះទៅក្នុងអណ្តូងម្តងទៀត និងបានដួសទឹកដាក់ពេញស្បែកជើង បន្ទាប់មកខាំវានឹងមាត់របស់គាត់ រហូតឡើងផុតពីអណ្តូង ហើយក៏យកឱ្យឆ្កែនោះផឹក។ អល់ឡោះបានថ្លែងអំណរគុណទៅចំពោះបុរសនោះ និងបានអភ័យទោសឱ្យគាត់។ ពួកគេបានសួរថា "ឱអ្នកនាំសារ! តើពួកយើងធ្វើល្អចំពោះសត្វពាហនៈបានទទួលផលបុណ្យដែរឬ"? លោកបានឆ្លើយថា "រាល់ការជួយសត្វទាំងអស់ដែលមានជីវិត គឺបានទទួលផលបុណ្យ"។ (អាល់ពូខរី:៥៦៦៣ មូស្លីម:២២៤៤)

សីលធម៌ដើម្បីការពារបរិស្ថាន

សាសនាឥស្លាមបានប្រើឱ្យយើងកសាងនៅលើផែនដីនេះ មានន័យថាធ្វើការងារ អភិវឌ្ឍ បង្កើនផលិតផល និងកសាងអារ្យធម៌ ជាមួយនឹងការការពារនិងថែរក្សាទៅលើឧបការគុណនេះ និងហាមឃាត់មិនឱ្យមានការបំផ្លាញ និងរំលោភបំពាន ឬខ្ជះខ្ជាយក្នុងការធ្វើអាជីវកម្មលើធនធានទាំងនោះឡើយ សូម្បីតែការបំផ្លាញនោះគឺដោយសារតែមនុស្ស សត្វ ឬរុក្ខជាតិក៏ដោយ។ ពិតប្រាកដណាស់ វាជាការងារដែលសាសនាឥស្លាមប្រានចោល និងស្អប់ខ្ពើមជាទីបំផុត ហើយអល់ឡោះមិនស្រឡាញ់ការបំផ្លាញនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត ដូចដែលអល់ឡោះបានមានបន្ទូលថា "ហើយអល់ឡោះមិនស្រលាញ់អំពើវិនាសកម្មឡើយ"។ (គម្ពីរគួរអាន ២:២០៥)

ហើយការព្រួយបារម្ភអំពីបញ្ហានេះបានឈានទៅដល់ការផ្តែផ្តាំរបស់ព្យាការីមូហាំម៉ាត់មកលើអ្នកមូស្លីមទាំងអស់ឱ្យប្រព្រឹត្តតែអំពើល្អ និងចូលរួមក្នុងការដាំដុះលើផែនដី សូម្បីតែនៅក្នុងកាលៈទេសៈលំបាកបំផុត ឬក្នុងគ្រាដ៏វេទនាណាក៏ដោយ។ លោកបានមានប្រសាសន៍ថា "ប្រសិនបើថ្ងៃបរលោកបានមកដល់ ហើយនៅក្នុងដៃរបស់ពួកអ្នកមានកូនរុក្ខជាតិ ប្រសិនបើអ្នកអាចដាំវាមុនថ្ងៃបរលោកកើតឡើងនោះ ចូរអ្នកដាំវាចុះ"។ (អះម៉ាត់:១២៩៨១)

## ៣. សីលធម៌ល្អមានគ្រប់វិស័យទាំងអស់នៃជីវិត

### គ្រួសារ

សាសនាឥស្លាមបានបញ្ជាក់ពីសារៈសំខាន់នៃសីលធម៌ក្នុងវិស័យនៃគ្រួសាររវាងសមាជិកគ្រួសារទាំងអស់ ហើយព្យាការីបានមានប្រសាសន៍ថា "អ្នកដែលល្អជាងគេក្នុងចំណោមពួកអ្នកគឺអ្នកដែលបានធ្វើល្អជាងគេចំពោះភរិយារបស់ពួកអ្នក ហើយខ្ញុំជាអ្នកធ្វើល្អជាងគេចំពោះភរិយាយរបស់ខ្ញុំ"។ (អាត់តៀរមីហ្ស៊ីៈ៣៨៩៥)

- ពិតណាស់អ្នកនាំសារ គឺជាមនុស្សដែលល្អជាងគេបំផុត។ លោកបានជួយធ្វើកិច្ចការផ្ទះ និងជួយសម្រួលការងារដល់គ្រួសាររបស់លោកមិនថាក្មេងឬចាស់ ដូចដែលភរិយារបស់លោក គឺលោកស្រី អាអ៊ីស្ហះ បានរាយការណ៍មកថា "លោកតែងជួយកិច្ចការគ្រួសាររបស់លោក"។ (អាល់ពូខរីៈ៥០៤៨)។ មានន័យថាលោកបានជួយពួកគេ និងធ្វើរាល់កិច្ចការផ្ទះដែលគ្រួសារលោកបានធ្វើ។
- ហើយពេលខ្លះ លោកក៏លេងសើចជាមួយក្រុមគ្រួសាររបស់លោកផងដែរ ដូចដែលភរិយារបស់លោក គឺលោកស្រីអាអ៊ីស្ហះបានរាយការណ៍មកថា "ខ្ញុំបានរួមដំណើរជាមួយនឹងអ្នកនាំសារ ក្នុងការធ្វើដំណើរមួយរបស់លោកនៅពេលដែលខ្ញុំនៅក្មេង និងស្គម។ លោកបានសុំឱ្យមនុស្សធ្វើដំណើរទៅមុន ពួកគេក៏បានធ្វើដំណើរទៅមុន បន្ទាប់មកលោកក៏បាននិយាយមកកាន់ខ្ញុំថា "សូមអញ្ជើញមកនេះ ខ្ញុំនឹងទៅឱ្យដល់មុនអ្នក"។ខ្ញុំបានចេញដំណើរយ៉ាងលឿនហើយខ្ញុំបានទៅដល់មុនលោក។ហើយលោកមិនបាននិយាយពីហេតុការណ៍នេះទៀតទេ។ ក្រោយពេលដែលខ្ញុំបានឡើងទម្ងន់ ហើយខ្ញុំបានភ្លេចអំពីហេតុការណ៍នោះ ខ្ញុំបានអមដំណើរជាមួយលោកម្តងទៀត នៅក្នុងការធ្វើដំណើរមួយរបស់លោក។ លោកបានសុំឱ្យមនុស្សធ្វើដំណើរទៅមុន។ ពួកគេក៏បានធ្វើដំណើរទៅមុន។ បន្ទាប់មកលោកក៏បាននិយាយមកកាន់ខ្ញុំថា "សូមអញ្ជើញមកនេះ ខ្ញុំនឹងទៅឱ្យដល់មុនអ្នក"។ ខ្ញុំបានធ្វើដំណើយ៉ាងលឿនមុនលោក ប៉ុន្តែលោកបានទៅដល់មុនខ្ញុំ។ ពេលនោះ លោកក៏បានសើចហើយនិយាយថា "នេះ គឺដើម្បីធ្វើឱ្យអ្នកដឹងចំពោះការបរាជ័យពីមុនរបស់ខ្ញុំ"។

### ពាណិជ្ជកម្ម

ដោយសារសេចក្តីស្រឡាញ់របស់មនុស្សចំពោះទ្រព្យសម្បត្តិ ទើបធ្វើឱ្យមនុស្សចង់បានហួសហេតុ និងធ្វើឱ្យពួកគេធ្លាក់ចូលទៅក្នុងប្រការហាមឃាត់។ សាសនាឥស្លាមបានមកដល់ដើម្បីបញ្ជាក់ពីសារៈសំខាន់នៃការគ្រប់គ្រងវាដោយប្រើសីលធម៌ល្អ ហើយខ្លះៗនៃការអះអាងទាំងនេះមានដូចជា៖

- ឥស្លាមបានហាមឃាត់មិនឱ្យមានការគេងបន្លំ ឬរំលោភបំពាននៅលើភ្នែកជញ្ជីងឡើយ ហើយក៏បានព្រមានដល់អ្នកដែលបានធ្វើទង្វើនេះ នឹងទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរបំផុត ដូចដែលអល់ឡោះបានមានបន្ទូលថា "ភាពវិនាសអន្តរាយគឺសម្រាប់ពួកអ្នកដែលគេងបន្លំ។ ជាពួកដែលទាមទារចង់បានគ្រប់ចំនួននៅពេលដែលពួកគេថ្លឹងវាស់ ឬវាល់ពីអ្នកដទៃ តែនៅពេលដែលពួកគេវាស់ឬវាល់ ឬថ្លឹងឱ្យអ្នកដទៃវិញ គឺពួកគេធ្វើឱ្យខ្វះ"។ (គម្ពីរគួរអាន ៨៣ៈ១-៣)
- ជម្រុញឲ្យមានការអធ្យាស្រ័យ និងភាពទន់ភ្លន់ក្នុងការលក់និងទិញៈ ព្យាការីបានមានប្រសាសន៍ថា "អល់ឡោះអាណិតស្រលាញ់បុរសម្នាក់ដែលអធ្យាស្រ័យក្នុងពេលលក់ ពេលទិញ និងពេលទារបំណុល"។ (អាល់ពូខរីៈ១៩៧០)

### ឧស្សាហកម្ម

សាសនាឥស្លាមបានបញ្ជាក់ចំពោះឧស្សាហករនូវសីលធម៌ជាច្រើនដូចជា ៖

- ត្រូវធ្វើកិច្ចការឱ្យល្អឥតខ្ចោះ និងបញ្ចេញផលិតផលឲ្យបានល្អប្រណិត ដូចដែលព្យាការីបានមានប្រសាសន៍ថា "ពិតប្រាកដណាស់ អល់ឡោះស្រលាញ់ទៅចំពោះនរណាម្នាក់ក្នុងចំណោមពួកអ្នកដែលធ្វើកិច្ចការបានយ៉ាងល្អឥតខ្ចោះ"។ (អាពូយ៉ាក់ឡាៈ៤៣៨៦ អាល់ពៃហាគី នៅក្នុងហ្សុកអាពូល អ៊ីម៉ានៈ៥៣១៣)

- ប្រកាន់ខ្ជាប់ពេលវេលាដែលបានកំណត់ជាមួយនឹងអ្នកដទៃ៖ ព្យាការីបានមានប្រសាសន៍ថា "សញ្ញាសម្គាល់ពួកពុតត្បុត(មូណាហ្វីក)មាន៣"មួយក្នុងចំនោមនោះគឺ "នៅពេលសន្យា គឺគេមិនបំពេញតាមសន្យា"។ (អាល់ពូខរ៍:៣៣)

## ៤. សីលធម៌ល្អមានគ្រប់ករណីទាំងអស់

សាសនាឥស្លាមគ្មានករណីលើកលែងក្នុងផ្នែកសីលធម៌ឡើយ។ ជនមូស្លីមត្រូវបានកំណត់ឱ្យអនុវត្តតាមក្បួនច្បាប់របស់អល់ឡោះ និងការអនុលោមតាមសីលធម៌ល្អ ទោះបីជានៅក្នុងពេលធ្វើសង្គ្រាម ឬក្នុងកាលៈទេសៈលំបាកយ៉ាងណាក៏ដោយ សម្រាប់គោលដៅ និងគោលបំណងដែលត្រឹមត្រូវមិនបង្ហាញអំពីភាពត្រឹមត្រូវនៃមធ្យោបាយអាក្រក់ ឬមិនបិទបាំងអំពីប្រការខុសឆ្គងនិងប្រការវង្វេងឡើយ។ ដោយសារបែបនេះហើយទើបសាសនាឥស្លាមបានដាក់ក្បួនច្បាប់សម្រាប់កាត់ក្តីអ្នកមូស្លីម និងការរៀបចំរាល់សកម្មភាពរបស់ពួកគេ សូម្បីតែនៅពេលដែលមានការឈ្លានពាននិងពេលមានសង្គ្រាមក៏ដោយ គឺដើម្បីកុំឱ្យការងារនោះឈានទៅរកការខឹងសម្បារ និងការប្រកាន់ពូជសាសន៍ ហើយនិងកុំឱ្យមានការឈ្នានីស ភាពសាហាវឃោរឃៅ និងអាត្មានិយម។

## សីលធម៌ឥស្លាមក្នុងពេលធ្វើសង្គ្រាម

### ១. ឥស្លាមប្រើឱ្យមានភាពយុត្តិធម៌ជាមួយនឹងសត្រូវ និងហាមឃាត់មិនឱ្យធ្វើប្រការអយុត្តិធម៌ និងរំលោភបំពានទៅលើពួកគេឡើយ

ដូចអល់ឡោះបានមានបន្ទូលថា "ហើយចូរកុំបណ្តោយឱ្យការស្អប់ខ្ពើមរបស់ក្រុមមួយធ្វើឱ្យពួកអ្នកប្រព្រឹត្តអំពើអយុត្តិធម៌ឱ្យសោះ។ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវភាពយុត្តិធម៌ ព្រោះវាជិតបំផុតក្នុងការកោតខ្លាចអល់ឡោះ"។ (គម្ពីរគួរអាន ៥:៨)។ មានន័យថា ចូរពួកអ្នកកុំធ្វើឱ្យការស្អប់ខ្ពើមរបស់ពួកអ្នកទៅលើសត្រូវរបស់ពួកអ្នក បញ្ឆោឱ្យអ្នកធ្វើការរំលោភបំពាន និងធ្វើប្រការអយុត្តិធម៌ទៅលើសត្រូវរបស់ពួកអ្នកឲ្យសោះ ប៉ុន្តែចាំបាច់ពួកអ្នកត្រូវតែប្រកាន់ខ្ជាប់នឹងភាពយុត្តិធម៌នៅក្នុងពាក្យសំដីនិងទង្វើរបស់ពួកអ្នក។

### ២. ហាមឃាត់មិនឱ្យក្បត់សន្យា និងបោកប្រាស់ជាមួយនឹងខ្មាំងសត្រូវ

ការក្បត់សន្យានិងការបោកប្រាស់ ជាប្រការដែលត្រូវបានគេហាមឃាត់(ហារ៉ាំ)សូម្បីតែជាមួយសត្រូវក៏ដោយ ដូចដែលអល់ឡោះបានមានបន្ទូលថា "ពិតប្រាកដណាស់ អល់ឡោះមិនចូលចិត្តពួកដែលក្បត់កិច្ចសន្យាឡើយ"។ (គម្ពីរគួរអាន ៨:៥៨)

### ៣. ហាមឃាត់មិនឱ្យធ្វើទារុណកម្ម ឬប្រដូចនឹងសាកសព៖ គេបានហាមឃាត់មិនឱ្យប្រដូចទៅនឹងសាកសពទេ ដូចដែលអ្នកនាំសារបានមានប្រសាសន៍ថា "ចូរពួកអ្នកកុំប្រដូច"។ (មូស្លីម:១៧៣១)

### ៤.ហាមឃាត់លើការសម្លាប់ជនស៊ីវិលដែលមិនបានចូលរួមក្នុងសង្គ្រាម បង្កវិនាសកម្មនៅលើផែនដី និងបរិស្ថាន

អាពូហ្ពាកើរ អាសស៊ីទ្ទីក ដែលជាមេដឹកនាំឥស្លាមហើយជាមនុស្សដែលល្អបំផុតក្នុងចំណោមមិត្តភក្តិរបស់ព្យាការីបានផ្តែផ្តាំទៅចំពោះលោក អូសាម៉ាស កូន ហ្សៃទ ខណៈពេលដែលគាត់ត្រូវបានគេតែងតាំងធ្វើជាមេទ័ពទៅឯប្រទេសស្ហាមថា "ចូរពួកអ្នកកុំសម្លាប់កូនក្មេង មនុស្សចាស់ និងស្ត្រី ហើយមិនត្រូវដកដើមល្មើនិងដុតវាចោលទេហើយមិនត្រូវកាប់ដើមឈើណាដែលផ្តល់ផ្លែផ្កាឡើយ។ មិនត្រូវសម្លាប់សត្វពពែ សត្វគោ ឬសត្វអូដ្ឋឡើយ លើកលែងតែសម្រាប់បរិភោគ។ ហើយនឹងមានមួយក្រុមដែលនឹងចាកចេញពីលំនៅឋានរបស់ពួកគេ។ ចូរអំពាវនាវពួកគេកុំឱ្យពួកគេចាកចេញទៀត"។ (អិពនូអាសាកៀរ:២/៥០)

# រូបភាពក្នុងសម័យកាលព្យាការីរស់នៅ

ព្យាការីមូហាំម៉ាត់ គឺជាគំរូនៃសីលធម៌ដ៏ល្អឥតខ្ចោះរបស់មនុស្សជាតិ។ ដូចនេះហើយទើបគម្ពីរគួរអានបានរៀបរាប់អំពីលក្ខណៈសីលធម៌ដ៏អស្ចារ្យរបស់លោក ហើយភរិយារបស់លោកក៏បានរៀបរាប់ពីលក្ខណៈសីលធម៌របស់លោក ដោយបាននិយាយថា "សីលធម៌របស់លោក គឺគម្ពីរគួរអាន" មានន័យថា គំរូនៃការអនុវត្តជាក់ស្តែងរបស់លោក គឺគម្ពីរគួរអាន និងសីលធម៌ដែលមាននៅក្នុងគម្ពីរគួរអាន។



> ព្យាការីមូហាំម៉ាត់គឺជាមនុស្សដែលមានសីលធម៌ដ៏ល្អបំផុត

## ការឱនលំទោន

- អ្នកនាំសារមិនបានអនុញ្ញាតឱ្យនរណាម្នាក់ក្រោកឈរឡើងក្នុងន័យលើកតម្កើងលោកនោះទេ ផ្ទុយទៅវិញ លោកបានហាមឃាត់មិត្តភក្តិរបស់លោកមិនឱ្យធ្វើដូចនោះទេ។ មិត្តភក្តិរបស់លោក ទោះបីជាពួកគេស្រលាញ់ព្យាការីខ្លាំងយ៉ាងណាក៏ដោយ ក៏ពួកគេមិននាំគ្នាក្រោកឈរឡើងនៅពេលដែលពួកគេបានឃើញព្យាការីមកដល់នោះដែរ ដោយពួកគេបានដឹងថា ព្យាការីមិនចូលចិត្តបែបនេះនោះទេ។ (អះម៉ាត់:១២៣៤៥ អាល់ពើសហ្សៃរ:៦៦៣៧)
- លោក អាទី កូន ហាទីម បានទៅជួបព្យាការីមុនពេលគាត់ចូលឥស្លាម។ គាត់ជាអ្នកដែលមានមុខមានមាត់ម្នាក់របស់ជនជាតិអារ៉ាប់។ គាត់ចង់ដឹងអំពីការពិតនៃការអំពាវនាវរបស់ព្យាការី។ អាទីបាននិយាយថា "ខ្ញុំបានទៅជួបលោក(ព្យាការីមូហាំម៉ាត់) ពេលនោះនៅជាមួយនឹងលោក គឺមានស្ត្រីម្នាក់ ឬកូនក្មេងម្នាក់ (គាត់បានរំលឹកថា ពួកគេនៅជិតនឹងព្យាការីមូហាំម៉ាត់) ហើយខ្ញុំក៏បានដឹងដែរថា លោកមិនមែនជាស្តេចដែលអស្ចារ្យ ឬព្រះចៅអធិរាជអ្វីនោះទេ"។ (អះម៉ាត់:១៩៣៨១)។ ការឱនលំទោន ជាសីលធម៌របស់បណ្តាព្យាការីទាំងអស់។
- លោកអង្គុយជាមួយមិត្តភក្តិរបស់លោកដូចជាម្នាក់ក្នុងចំណោមពួកគេ ដោយលោកមិនបានអង្គុយកន្លែងពិសេសណាដើម្បីឱ្យខុសប្លែកពីអ្នកដទៃដែលនៅជុំវិញលោកឡើយ រហូតដល់អ្នកចំឡែកដែលមិនដែលស្គាល់លោកសោះ នៅពេលដែលមកចូលរួមជាមួយលោក គឺគេមិនអាចកំណត់បានថា ម្នាក់ណាជាលោក ម្នាក់ណាជាមិត្តភក្តិលោកទេ ហើយគេក៏បានសួរថា តើម្នាក់ណាជាមូហាំម៉ាត់? (អាល់ពូខរី:៦៣)
- លោក អាណាស កូន ម៉ាលិក បាននិយាយថា "ទាសករណាម្នាក់ក្នុងចំណោមទាសករដែលរស់នៅក្នុងទីកដីម៉ាទីណះ ដែលបានកាន់ដៃរបស់ព្យាការីមូហាំម៉ាត់ ពិតណាស់លោកនឹងយកនាងទៅគ្រប់ទីកន្លែងដែលនាងប្រាថ្នា"។ (អាល់ពូខរី:៥៧២៤)។ អត្ថន័យរបស់ "នរណាហើយដែលបានកាន់ដៃព្យាការី" គឺបានន័យថា ភាពសប្បុរស និងការចង្អុលបង្ហាញរបស់លោក គឺមានទាំងចំពោះកូនក្មេងនិងអ្នកទន់ខ្សោយ។ វាបានបង្ហាញឲ្យឃើញពីភាពឱនលំទោនទាំងស្រុងរបស់លោក ដោយគេបានរៀបរាប់អំពីស្ត្រីមិនមែនបុរស និងជាទាសករមិនមែនអ្នកមានសេរីភាព ដោយនាងអាចចាប់យកវាពេលដែលនាងត្រូវការដើម្បីដោះស្រាយបញ្ហារបស់នាង។

- ព្យាការីបានមានប្រសាសន៍ថា "មិនបានចូលឋានសួគ៌ឡើយ ជនណាហើយដែលមានក្នុងចិត្តរបស់គេនោះនូវភាពក្រអឺតក្រទម សូម្បីតែប៉ុនលំអងធូលីក៏ដោយ"។ (មូស្លីម លេខ៩១)

## ការអាណិតស្រលាញ់

- ព្យាការីបានមានប្រសាសន៍ថា "ពួកអ្នកដែលអាណិតស្រលាញ់គេ អល់ឡោះនឹងអាណិតស្រលាញ់ចំពោះពួកគេវិញ។ ចូរពួកអ្នកអាណិតស្រលាញ់អ្នកដែលនៅលើផែនដី នោះអ្នកដែលនៅលើមេឃនឹងអាណិតស្រលាញ់ពួកអ្នកវិញ"។ (អាត់តៀរមីហ្ស៊ីៈ១៩២៤ អាពូហ្ទាវូទៈ៤៩៤១)

ការអាណិតស្រលាញ់របស់ព្យាការីមូហាំម៉ាត់មានច្រើនផ្នែកដូចជា ៖

### ការអាណិតស្រលាញ់របស់លោកទៅចំពោះកូនក្មេង

- មានបុរសជនបទម្នាក់បានមកជួបព្យាការីមូហាំម៉ាត់ ហើយបាននិយាយទៅកាន់លោកថា "ពួកអ្នកថើបកូនៗរបស់ពួកអ្នកឬ? ពួកយើងមិនដែលបានថើបពួកគេសោះឡើយ"។ ព្យាការីក៏បានតបទៅវិញថា "ខ្ញុំមិនអាចជួយពួកអ្នកបានឡើយ ប្រសិនបើអល់ឡោះបានដកក្តីអាណិតស្រលាញ់ចេញពីចិត្តរបស់ពួកអ្នកនោះ"។ (អាល់ពូខរីៈ៥៦៥២ មូស្លីមៈ២៣១៧)។ មានម្នាក់ទៀតបានឃើញព្យាការីថើប ហូសេន កូន អាលី ហើយក៏បាននិយាយថា "ខ្ញុំមានកូនដល់ទៅ១០នាក់ តែខ្ញុំមិនដែលបានថើបពួកគេម្នាក់ណាឡើយ"។ ព្យាការីក៏បានមានប្រសាសន៍ថា "នរណាហើយដែលមិនអាណិតស្រលាញ់គេទេនោះ គេក៏មិនអាណិតស្រលាញ់គាត់វិញដែរ)។ (មូស្លីមៈ២៣១៨)
- ពេលមួយ ព្យាការីបានពរចៅស្រីរបស់លោក អាម៉ាម៉ះ កូន ហ្សៃណាប់ ខណៈពេលដែលលោកកំពុងសឡាត។ នៅពេលដែលលោកស៊ូជោទ លោកដាក់នាងចុះ ហើយនៅពេលដែលលោកក្រោកឈរវិញ លោកពរនាងឡើង។ (អាល់ពូខរីៈ៤៩៤ មូស្លីមៈ៥៤៣)
- នៅពេលដែលលោកសឡាត ហើយបានលឺសម្លេងក្មេងយំ គឺលោកប្រញាប់ប្រញាល់ និងសូត្រខ្លីៗនៅក្នុងសឡាតនោះ។ អំពីអាពូកីតាហ្ទះ ពិតណាស់ ព្យាការីបានមានប្រសាសន៍ថា "ជាការពិតណាស់ ពេលខ្លះខ្ញុំសឡាត ហើយខ្ញុំចង់សឡាតឱ្យបានយូរ ប៉ុន្តែខ្ញុំបានលឺសម្លេងក្មេងយំ ខ្ញុំក៏សឡាតខ្លីវិញ ដោយខ្ញុំមិនចង់បង្កការលំបាកដល់ម្តាយរបស់គេ"។ (អាល់ពូខរីៈ៦៧៥ មូស្លីមៈ៤៧០)





>ព្យាការីមូហាំម៉ាត់បានចាត់ទុកអ្នកដែលធ្វើល្អជាមួយស្ត្រីមេម៉ាយនិងអ្នកក្រីក្រ ដូចជាអ្នកដែលទៅធ្វើសង្គ្រាមក្នុងផ្លូវអល់ឡោះ។

## ការអាណិតស្រលាញ់របស់លោកទៅចំពោះស្ត្រី

ព្យាការីមូហាំម៉ាត់បានជម្រុញឱ្យថែរក្សាក្មេងស្រីនិងមានចិត្តសប្បុរសទៅចំពោះពួកនាង ហើយគាត់បានមានប្រសាសន៍ថា "បុគ្គលណាដែលត្រូវបានគេសាកល្បងដោយឱ្យមានកូនស្រីច្រើន ហើយគាត់បានធ្វើល្អចំពោះកូនៗទាំងនោះ ពួកនាងគឺជារនាំងសម្រាប់ការពារគាត់ពីភ្លើងឋាននរក។

(អាល់ពូខរី:៥៦៤៩ មូស្លីម:២៦២៩)

ប៉ុន្តែ លោកបានសង្កត់ធ្ងន់ក្នុងការផ្តែផ្តាំឱ្យធ្វើល្អជាមួយប្រពន្ធ និងមានការចាប់អារម្មណ៍ក្នុងកិច្ចការរបស់ពួកនាង ហើយយកចិត្តទុកដាក់លើបញ្ហារបស់ពួកនាង ហើយលោកក៏បានប្រើឱ្យអ្នកមូស្លីមផ្តែផ្តាំគ្នាទៅវិញទៅមកអំពីបញ្ហានេះផងដែរ ដោយលោកបានមានប្រសាសន៍ថា "ចូរពួកអ្នកធ្វើល្អទៅចំពោះស្ត្រី)។ (អាល់ពូខរី:៤៨៩០)

ហើយព្យាការីមូហាំម៉ាត់បានបង្ហាញនូវគំរូដ៏អស្ចារ្យនៃភាពទន់ភ្លន់ជាមួយនឹងសមាជិកគ្រួសាររបស់លោក។ នៅពេលលោកអង្គុយនៅក្បែរសត្វអូដ្ឋរបស់លោក លោកបានដាក់ជង្គង់របស់លោកសម្រាប់ឱ្យសហ្វីយ៉ាស់ ដាក់ជើងរបស់នាងនៅលើជង្គង់របស់លោក ដើម្បីឡើងទៅលើសត្វអូដ្ឋ។

(អាល់ពូខរី:២១២០)

នៅពេលណាដែលកូនស្រីរបស់លោក គឺហ្វាទីម៉ះ បានចូលមកលេងលោកនោះ លោកបានទទួលស្វាគមន៍នាងដោយចាប់ដៃរបស់នាង ហើយថើបនាង និងផ្តល់ឱ្យនាងអង្គុយកន្លែងដែល

លោកបានអង្គុយ។ (អាពូហ្ទាវូទ:៥២១៧)

## ■ ការអាណិតស្រលាញ់របស់លោកជាមួយនឹងអ្នកទន់ខ្សោយ

- ដូច្នេះហើយបានជាព្យាការី ជម្រុញមនុស្សលើការថែរក្សាក្មេងកំព្រា ដោយលោកបានមានប្រសាសន៍ថា "ខ្ញុំ និងអ្នកថែរក្សាក្មេងកំព្រា នឹងស្ថិតនៅក្នុងឋានសួគ៌ក្បែរគ្នាដូចនេះ" គាត់បានបង្ហាញម្រាមដៃចង្អុលនឹងម្រាមដៃកណ្ដាល ហើយញែកវាចេញពីគ្នាបន្តិច។ (អាល់ពូខរី:៤៩៩៨)
- លោកចាត់ទុកអ្នកដែលជួយដល់ស្ត្រីមេម៉ាយនិងជនក្រីក្រ ប្រៀបដូចជាអ្នកដែលច្បាំងក្នុងផ្លូវអល់ឡោះ ហើយក៏ដូចជាអ្នកដែលបួសនៅពេលថ្ងៃ និងសឡាតនៅពេលយប់។

(អាល់ពូខរី:៥៦៦១ មូស្លីម:២៩៨២)

- លោកបានចាត់ទុកការផ្ដល់ក្ដីសប្បុរសចំពោះអ្នកដែលទន់ខ្សោយ និងផ្ដល់ជូនពួកគេនូវសិទ្ធិរបស់ពួកគេ គឺជាមូលហេតុក្នុងការទទួលបានលាភសក្ការៈ និងជំនួយលើខ្មាំងសត្រូវ។ ព្យាការីបានមានប្រសាសន៍ថា "ចូរពួកអ្នកស្វែងរកអ្នកទន់ខ្សោយឱ្យខ្ញុំ។ ការពិតពួកអ្នកត្រូវបានគេជួយ និងត្រូវបាន



> នៅពេលដែលព្យាការីបានឃើញបក្សីក្នុងភាពខ្វះខ្វែងនិងចលនារបស់វានៅក្នុងការស្វែងរកកូនៗរបស់វា ដែលសហាហ្ពះ មួយចំនួនបានយកវាទៅ ហើយគាត់បានមានប្រសាសន៍ថា: (តើនរណាធ្វើឱ្យមានការភ័យខ្វល់នេះដល់ម្ដាយរបស់វា)ចូរត្រឡប់ពួកគេទៅឱ្យម្ដាយរបស់ពួកគេវិញ

គេផ្តល់លាភសក្ការៈ ដោយសារអ្នកទន់ខ្សោយក្នុងចំណោមពួកអ្នក"។ (អាពូហ្សាវូទ:២៥៩៤)

### ការអាណិតស្រលាញ់របស់លោកចំពោះសត្វធាតុ

- ពិតណាស់ ព្យាការីបានជម្រុញឱ្យមនុស្សមានក្តីសប្បុរសចំពោះសត្វធាតុទាំងឡាយ។ មិនត្រូវប្រើប្រាស់ពួកវាលើសពីសមត្ថភាពរបស់វាឡើយ និងមិនត្រូវធ្វើបាបពួកវានោះទេ។ ព្យាការីបានមានប្រសាសន៍ថា "ពិតណាស់ អល់ឡោះបានដាក់បទបញ្ញាឱ្យធ្វើល្អចំពោះអ្វីៗទាំងអស់។ ហេតុនេះ នៅពេលដែលពួកអ្នកសម្លាប់សត្វ(ដែលបង្ករគ្រោះថ្នាក់) ចូរពួកអ្នកសម្លាប់ដោយវិធីសាស្រ្តដ៏ល្អ ហើយនៅពេលណាពួកអ្នកសម្លេះសត្វ(ដើម្បីទទួលទាន) ចូរពួកអ្នកសម្លេះដោយវិធីសាស្រ្តដ៏ល្អ។ ចូរឱ្យពួកអ្នកសំលៀងកាំបិតរបស់ពួកអ្នកឱ្យមុត ហើយធ្វើយ៉ាងណាឱ្យសត្វនោះស្លាប់ដោយងាយស្រួលបំផុត"។ (មូស្លីម:១៩៥៥)
- មិត្តភក្តិម្នាក់របស់ព្យាការីបាននិយាយថា: ព្យាការីបានឃើញកន្លែងសំបុកស្រមោចមួយកន្លែងដែលត្រូវបានពួកយើងដុត លោកក៏បានមានប្រសាសន៍ថា "តើអ្នកណាជាអ្នកដុតនេះ"? ពួកយើងបានឆ្លើយថា "គឺពួកយើងជាអ្នកដុត"។ លោកក៏មានប្រសាសន៍ថា "ជាការពិតណាស់ គ្មាននរណាម្នាក់មានសិទ្ធិប្រើភ្លើងសម្រាប់ដាក់ទណ្ឌកម្មឡើយ លើកលែងតែម្ចាស់របស់ភ្លើង(អល់ឡោះ)ប៉ុណ្ណោះ"។ (អាពូហ្សាវូទ:២៦៧៥)

## យុត្តិធម៌

- ពិតណាស់ ព្យាការីមូហាំម៉ាត់ គឺជាមនុស្សដែលមានភាពយុត្តិធម៌បំផុត។ លោកអនុវត្តច្បាប់របស់អល់ឡោះ សូម្បីតែជាមួយញាតិសន្តានក៏ដោយ ដោយប្រណិបត្តិតាមបទបញ្ជារបស់អល់ឡោះ "ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវភាពយុត្តិធម៌ ដូចជាការធ្វើសាក្សីចំពោះអល់ឡោះ សូម្បីតែ(ធ្វើសាក្សី)លើខ្លួនឯង ឬឪពុកម្តាយ និងញាតិសន្តានក៏ដោយ"។ (គម្ពីរគួរអាន ៤:១៣៥)
- នៅពេលដែលមិត្តភក្តិរបស់ព្យាការីមួយចំនួនបានមកសុំឱ្យលោកជួយធ្វើអន្តរាគម៍ ដោយមិនឱ្យដាក់ទណ្ឌកម្មទៅលើនារីម្នាក់ដែលមានឋានៈខ្ពស់នៅក្នុងកុលសម្ព័ន្ធ ដោយនាងបានលួចគេ។ ព្យាការីក៏បានមានប្រសាសន៍ថា(ខ្ញុំសូមស្បថនឹងអ្នកដែលជីវិតរបស់ខ្ញុំស្ថិតនៅលើដៃរបស់ទ្រង់ថា ប្រសិនបើ ហ្វាតីម៉ាស់ កូន មូហាំម៉ាត់ (កូនស្រីខ្ញុំ) បានលួចគេ ខ្ញុំនឹងកាត់ដៃរបស់នាង"។

(អាល់ពូខរី:៤០៥៣ មូស្លីម:១៦៨៨)

- នៅពេលដែលគេហាមឃាត់មនុស្សទៅលើការយកការប្រាក់ អ្នកដែលលោកចាប់ផ្តើមដំបូងគេគឺជាអ្នកដែលនៅជិតព្យាការីបំផុត។ ដូចនេះ លោកបានរំលាយចោលមុនគេ គឺឪពុកមារបស់លោក អាល់អាប់ហ្ពាស។ ព្យាការីបានមានប្រសាសន៍ថា "ការប្រាក់ដែលខ្ញុំបានរំលាយចោលមុនគេបង្អស់ក្នុងចំណោមពួកយើងនោះ គឺការប្រាក់របស់ អាប់ហ្ពាស កូនរបស់អាប់ទុលមូតល់ឡឹប។ ពិតប្រាកដណាស់



>ព្យាការីមូហាំម៉ាត់ជាមនុស្សដែលមានភាពយុត្តិធម៌បំផុតមិនថាជាមួយនឹងសាច់ញាតិ ឬក៏សត្រូវឡើយ។

វាត្រូវបានគេរំលាយចោលទាំងអស់)។

(មូស្លីម:១២១៨)

- ផ្តល់ភាពស្មើគ្នានៅក្នុងសង្គម និងលើកតម្កើងវា ដោយទាមទារកម្មសិទ្ធិរបស់អ្នកទន់ខ្សោយពីអ្នកដែលមានអំណាចដោយគ្មានការភ័យខ្លាច ឬស្ទាក់ស្ទើរ។ ព្យាការីបានមានប្រសាសន៍ថា "គ្មានការជ្រះស្អាតទេចំពោះក្រុមណាហើយដែលមិនបានផ្តល់ឱ្យអ្នកទន់ខ្សោយនូវកម្មសិទ្ធិរបស់គេ ដោយគ្មានការស្ទាក់ស្ទើរនោះ"។(អ៊ិពនូម៉ាហ្ជះ:២៤២៦)

## សេចក្តីសប្បុរស និងមានចិត្តទូលាយ

- ជាការពិតណាស់ ព្យាការីជាមនុស្សដែលមានចិត្តសប្បុរសបំផុត ហើយពេលដែលលោកមានចិត្តសប្បុរសបំផុតនោះ គឺនៅក្នុងខែរ៉ម៉ាហ្ទន នៅពេលដែល ទេវជីព្រីល មកជួបលោក។ ហើយ ជីព្រីលបានមកជួបលោកជារៀងរាល់យប់ក្នុងខែរ៉ម៉ាហ្ទនរហូតដល់ចប់ហើយបង្រៀនលោកនូវគម្ពីរគួរអាន។ ពេលដែលលោកបានជួប ជីព្រីល លោករួសរាន់បំផុតចំពោះភាពសប្បុរសធម៌ ជាងខ្យល់ដែលបក់នាំអ្វីៗទៅទៀត។ (អាល់ពូខរី:១៨០៣ មូស្លីម:២៣០៨)
- គេមិនបានសុំអ្វីម៉្យាងអំពីលោកឡើយ លើកលែងតែលោកផ្តល់ឱ្យទាំងអស់។ មានបុរសម្នាក់បានមកជួបលោក លោកក៏បានផ្តល់ឱ្យបុរសនោះនូវសត្វពពែពាសពេញចន្លោះភ្នំទាំងពីរ។ ពេលបុរសនោះត្រឡប់ទៅជួបក្រុមរបស់គេវិញ បុរសនោះក៏បាននិយាយថា "ឱក្រុមរបស់យើង! ចូរពួកអ្នកចូលឥស្លាមចុះ! ពិតណាស់ មូហាំម៉ាត់ បានធ្វើការបរិច្ចាគដោយមិនខ្លាចក្រឡើយ"។ (មូស្លីម ២៣១២)
- មានគេយកប្រាក់ ៨០ពាន់ទៀរហាំ(លុយអារ៉ាប់សម័យដើម)មកឱ្យលោក ហើយបានដាក់ចំនួនទឹកប្រាក់នោះនៅលើគ្រែ បន្ទាប់មកលោកក៏បានបែងចែកប្រាក់ទាំងនោះ ហើយគ្មានអ្នកសុំណាម្នាក់ងាកចេញឡើយលើកលែងតែប្រាក់នោះអស់។ (អាល់ហាគីម ៈ:៥៤២៣)
- មានបុរសម្នាក់មកជួបលោកហើយក៏បានសុំលោក លោកក៏បានមានប្រសាសន៍ថា "ខ្ញុំគ្មានអ្វីនោះទេ ក៏ប៉ុន្តែ អ្នកមកតាមខ្ញុំមក ប្រសិនបើយើងបានទទួលអ្វីម៉្យាងយើងនឹងផ្តល់វាឱ្យអ្នក(មានន័យថា យើងនឹងទិញអ្វីដែលអ្នកត្រូវការហើយវាគឺជាការទូទាត់របស់ខ្ញុំ)"។ ពេលនោះ អ៊ូមើរ បាននិយាយថា "ឱអ្នកនាំសារ! អល់ឡោះមិនបានធ្វើឱ្យវាចាំបាច់សម្រាប់លោកដើម្បីធ្វើអ្វីមួយដែលហួសពីសមត្ថភាពរបស់លោកឡើយ"។ ពេលនោះ ព្យាការីក៏មានការអន់ចិត្តនឹងសំដីនេះ ហើយបុរសនោះក៏បាននិយាយថា "ចូរអ្នកបរិច្ចាកទានចុះ ហើយអ្នកកុំខ្លាចភាពក្រីក្រ អល់ឡោះមិនធ្វើឱ្យទ្រព្យសម្បត្តិរបស់អ្នកថយចុះឡើយ"។ ពេលនោះ ព្យាការីក៏បានញញឹម ហើយមុខរបស់គាត់ពោរពេញដោយសេចក្តីសប្បាយរីករាយ។ (អាល់អាហាទីសអាល់មូខតើរ៉ោះ:៨៨)
- ពេលដែលព្យាការីត្រឡប់មកពីសមរភូមិ ហ៊ូណៃន ពួកកុលសម្ព័ន្ធ ហ្គារ៉ាប៊ី ដែលទើបចូលឥស្លាមថ្មីបានមកទាមទារពីព្យាការីនូវចំណែករបស់ពួកគេអំពីជ័យភ័ណ្ឌសង្គ្រាម។ ពួកគេបានរុំព័ទ្ធជុំវិញលោក ហើយនាំលោកទៅកន្លែងដើមឈើ ហើយពួកគេក៏បានចាប់កន្ត្រាក់យកអាវធំរបស់លោក។ ព្យាការីក៏បានក្រោកឈរហើយមានប្រសាសន៍ថា "សូមឱ្យអាវធំរបស់ខ្ញុំត្រឡប់មកវិញមក។ ប្រសិនបើខ្ញុំមានសត្វអូដ្ឋជាច្រើនដូចជាដើមឈើ (នៅជុំវិញនេះ) ខ្ញុំនឹងចែកឱ្យពួកអ្នកទាំងអស់គ្នា ដើម្បីឱ្យ អ្ន ក ដឹ ង ផងដែរថា ខ្ញុំមិនមែនកំណាញ់ឬបោកបញ្ឆោតឬកំសាកឡើយ"។

ពិតណាស់ ព្យាការីមូហាំម៉ាត់បានធ្វើជាគំរូដ៏អស្ចារ្យនៃសីលធម៌ល្អដែលមានគ្រប់វិស័យទាំងអស់នៃជីវិត។



# ជីវិតថ្មីរបស់អ្នក

# 12

ពិតណាស់ ខណៈពេលដែលមនុស្សបានចូលសាសនាឥស្លាម វាជាឱកាសដ៏អស្ចារ្យបំផុតនៃជីវិតរបស់គេ។ វាជាការប្រសូត្រដ៏ពិតប្រាកដរបស់គេ ដែលបន្ទាប់ពីការប្រសូត្រ( ចូលឥស្លាម ) របស់គេនេះទៅ គឺគេនឹងបានដឹងអំពីមូលហេតុនៃការមានវត្តមានរបស់គេនៅក្នុងជីវិតនេះ និងថាតើត្រូវធ្វើដូចម្តេចដើម្បីមានជីវិត និងការរស់នៅឲ្យបានស្របទៅនឹងច្បាប់សាសនាឥស្លាមដែលពោរពេញទៅដោយភាពអច្ឆរិយនេះ។

## មាតិកាជំពូក


តើធ្វើដូចម្តេចដើម្បីចូលសាសនាឥស្លាម?

ការសារភាពកំហុស( តាវហ្ពាត់ )

ថ្លែងអំណរគុណចំពោះឧបការគុណនៃការចង្អុលបង្ហាញ នឹងការសារភាពកំហុស

- ការអំពាវនាវទៅកាន់សាសនាឥស្លាម
- ឧត្តមភាពនៃការអំពាវនាវទៅកាន់អល់ឡោះ
- របៀបអំពាវនាវដែលត្រឹមត្រូវ

ការអំពាវនាវក្រុមគ្រួសារ

ការចូលឥស្លាមរបស់កូនក្មេង

ការផ្លាស់ប្តូរឈ្មោះបន្ទាប់ពីចូលឥស្លាម

លក្ខណៈនៃភាពស្អាតស្អំ ( ស៊ូណានុលហ្វីតរ៉ោះ )

## > តើធ្វើដូចម្តេចដើម្បីចូលសាសនាឥស្លាម?

ដើម្បីចូលក្នុងសាសនាឥស្លាមចាំបាច់ត្រូវពោលពាក្យសច្ចាចំនួនពីរ ជាមួយនឹងការយល់ពីអត្ថន័យរបស់វា និងជឿជាក់នឹងវា ព្រមទាំងអនុវត្តតាមភស្តុតាងរបស់វា ហើយពាក្យសច្ចាទាំងពីរនោះគឺ ៖

1 أشهد أن لا إله إلا الله (អានថា អាស្ហាហាទូ អាល់ឡើ អ៊ីឡើហ៊ី អ៊ិលលល់ឡោះ) ខ្ញុំសូមធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិត លើកលែងតែអល់ឡោះ (មានន័យថា ខ្ញុំសូមសច្ចា និងជឿជាក់ថាគ្មានទេព្រះជាម្ចាស់ដ៏ពិតលើកលែងតែអល់ឡោះតែមួយគត់ហើយខ្ញុំគោរពសក្ការៈចំពោះទ្រង់តែមួយគត់ដោយខ្ញុំមិនធ្វើស្ហ៊ីរិក(ពហុទេពនិយម)ជាមួយនឹងទ្រង់ឡើយ)។

2 وأشهد أن محمداً رسول الله (អានថា វ៉ាអាស្ហាហាទូ អាន់ណា មូហាំម៉ាហ្ទាន់ រ៉ស៊ូលុលឡោះ) ហើយខ្ញុំសូមសច្ចាទៀតថា មូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ ( មានន័យថា ខ្ញុំធ្វើសច្ចាថា ព្យាការីមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះមកកាន់មនុស្សទាំងអស់ គោរពប្រតិបត្តិតាមបទបញ្ជាទាំងឡាយរបស់លោក ជៀសវាងប្រការទាំងឡាយដែលលោកហាមឃាត់ ហើយខ្ញុំគោរពសក្ការៈទៅចំពោះអល់ឡោះដោយអនុវត្តតាមច្បាប់របស់លោក និងអ្វីដែលលោកបាននាំមក)។ (មើលក្នុងទំព័រ ៤២-៥០)

### ការងូតទឹកសម្រាប់អ្នកចូលឥស្លាមថ្មី

ពិតណាស់ ខណៈពេលដែលមនុស្សបានចូលសាសនាឥស្លាម វាគឺជាឱកាសដ៏អស្ចារ្យបំផុតនៃជីវិតរបស់គេ។ វាជាការប្រសូត្រដ៏ពិតប្រាកដរបស់គេ ដែលបន្ទាប់ពីការប្រសូត្រ(ចូលឥស្លាម)របស់គេនេះទៅគឺគេនឹងបានដឹងអំពីមូលហេតុនៃការមានវត្តមានរបស់គេនៅក្នុងជីវិតនេះ។ ហើយគេក៏បានបង្គាប់ប្រើនៅពេលចូលសាសនាឥស្លាមនេះផងដែរ គឺត្រូវងូតទឹក និងស្រោចទឹកឱ្យសប់ពេញខ្លួនប្រាណ ប្រៀបដូចជាគេបានសម្អាតចិត្តរបស់គាត់ពីប្រការអំពើពហុទេពនិយម និងប្រការអាក្រក់ទាំងឡាយ។ គប្បីត្រូវសំអាតខ្លួនប្រាណរបស់គេ ដោយការងូតទឹកសម្អាតកាយ។

ហើយព្យាការី លោកបានប្រើសហការីម្នាក់របស់លោកឱ្យគាត់ទៅងូតទឹក នៅពេលដែលរូបគេចង់ចូលសាសនាឥស្លាម។

(អាល់ពៃហើគី:៨៣៧)



## > ការសារភាពកំហុស ( តាវហ្បាត់ )

ការទទួលសារភាពកំហុសគឺជាការត្រឡប់ទៅរកអល់ឡោះ។ រាល់ៗបុគ្គលដែលបានប្រព្រឹត្តអំពើអាក្រក់ ឬប្រឆាំងនឹងទ្រង់ ហើយបានវិលត្រឡប់ទៅរកអល់ឡោះវិញដោយភាពស្មោះស្ម័គ្រនឹងទ្រង់ចេញពីចិត្តរបស់គេ នោះហើយគឺជាការទទួលសារភាពកំហុសទៅចំពោះអល់ឡោះ។

ជនមូស្លីមគ្រប់រូបចាំបាច់ត្រូវទទួលសារភាពកំហុស និងសុំការអភ័យទោសនៅគ្រប់ដំណាក់កាលនៃជីវិតរបស់គាត់ ដោយសារតែមនុស្ស ជាធម្មតាតែងតែធ្វើខុស ហើយរាល់ពេលដែលគេប្រព្រឹត្តខុសច្បាប់បានចែងឱ្យរូបគេសុំការអភ័យទោសពីអល់ឡោះ និងទទួលសារភាពកំហុសទៅចំពោះទ្រង់។

### តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីឱ្យការទទួលសារភាពកំហុសបានត្រឹមត្រូវ?

ការទទួលសារភាពកំហុសអំពីបាបកម្មទាំងអស់ដូចជា ការប្រឆាំងនឹងអល់ឡោះ និងអំពើពហុទេពនិយមជាដើមនោះ ចាំបាច់ត្រូវបង្គ្រប់រាល់លក្ខខណ្ឌទាំងអស់ដើម្បីឱ្យការសារភាពកំហុសនោះត្រូវបានអល់ឡោះទទួលយក និងត្រឹមត្រូវ។ លក្ខខណ្ឌទាំងនោះមានដូចជា ៖

### 1 ត្រូវបញ្ឈប់ការប្រព្រឹត្តអំពើបាបកម្ម

ការទទួលសារភាពកំហុស គឺមិនត្រឹមត្រូវទេបើការប្រព្រឹត្តអំពើបាបកម្មនៅតែបន្តក្នុងពេលដែលគេទទួលសារភាពកំហុសនោះ។ រីឯការត្រឡប់ទៅប្រព្រឹត្តអំពើបាបកម្មបន្ទាប់ពីការទទួលកំហុសបានត្រឹមត្រូវហើយនោះ ការទទួលសារភាពកំហុសពីមុននោះមិនត្រូវបានខូចខាតនោះទេ ក៏ប៉ុន្តែចាំបាច់លើគេ ត្រូវធ្វើការសារភាពកំហុសសារជាថ្មី។

### 2 សោកស្តាយចំពោះអំពើបាបកម្មដែលបានប្រព្រឹត្តកន្លងផុតមក

មិនចាត់ទុកការសារភាពកំហុសដ៏ត្រឹមត្រូវនោះទេ លើកលែងតែប្រព្រឹត្តទៅដោយមានអារម្មណ៍សោកស្តាយ ទុក្ខព្រួយ និងការសុំអភ័យទោសពីអល់ឡោះចំពោះអំពើបាបដែលបានប្រព្រឹត្តកន្លងមក។ គេមិនរាប់ជាការសោកស្តាយឡើយ បើគ្រាន់តែគេបាននិយាយអំពីអំពើបាបពីអតីតកាលរបស់គេ ដោយមិនមានអារម្មណ៍សោកស្តាយទេនោះ។ ដូចនេះហើយបានជាអ្នកនាំសារបានមានប្រសាសន៍ថា "ការសោកស្តាយ គឺជាការទទួលសារភាពកំហុស"។ (អ៊ិពនូម៉ាហ្ជះ:៤២៥២)

### 3 ប្តេជ្ញាចិត្តមិនវិលត្រឡប់ទៅប្រព្រឹត្តវាម្តងទៀត

ការទទួលសារភាពកំហុសមិនទាន់ត្រឹមត្រូវនោះទេ ដរាបណាបុគ្គលនោះនៅតែមានបំណងត្រឡប់ទៅប្រព្រឹត្តអំពើបាបក្រោយអំពីការទទួលសារភាពកំហុសហើយនោះ។

### ផែនការដើម្បីសម្រេចការប្តេជ្ញាចិត្ត

- វាជាការសន្យាជាមួយនឹងខ្លួនឯងថា នឹងមិនវិលត្រឡប់ទៅប្រព្រឹត្តអំពើដែលបានធ្វើកន្លងមក ទោះបីជាមានឱកាសមួយប៉ព្រិចភ្នែកក្នុងកាលៈទេសៈ និងឧបសគ្គណាក៏ដោយ។ ពិតប្រាកដណាស់ព្យាការីបានមានប្រសាសន៍ថា "បីប្រការ ជនណាហើយមានបីប្រការនេះនឹងទទួលបាននូវរសជាតិនៃជំនឿ (ដោយលោកបានលើកឡើងនៅក្នុងនោះគឺ) ការស្អប់ខ្ពើមមិនចង់វិលត្រឡប់ទៅរកភាពគ្មានជំនឿវិញបន្ទាប់ពីអល់ឡោះបានរំដោះគេពីវាហើយនោះ បីដូចជាគេស្អប់ខ្ពើមមិនចង់ឱ្យគេបោះបញ្ចូលទៅក្នុងភ្លើងនរកដូច្នោះដែរ"។ (អាល់ពូខរី:២១ មូស្លីម:៤៣)
- ចេញឱ្យឆ្ងាយពីមនុស្ស ឬទីកន្លែងដែលធ្វើឱ្យជំនឿរបស់គេចុះខ្សោយ និងល្បួងរូបគេឱ្យប្រព្រឹត្តអំពើបាប។
- បង្កើននូវការបួងសួង ( សុំឌូអា ) ទៅចំពោះអល់ឡោះ ឱ្យរូបគេមានភាពនឹងនរក្នុងសាសនារបស់គេ

(សាសនាឥស្លាម) រហូតដល់ស្លាប់ ទោះបីជានៅក្នុងទ្រង់ទ្រាយ និងភាសាណាមួយក៏ដោយ។ ក្នុងនោះដែរ ដូចមាននៅក្នុងគម្ពីរគួរអាន និងប្រសាសន៍របស់ព្យាការី គឺ ៖

- ឱម្ចាស់របស់ពួកយើង! សូមទ្រង់មេត្តាកុំបង្វែចិត្តរបស់ពួកយើង ក្រោយពេលដែលទ្រង់បានចង្អុលបង្ហាញដល់ពួកយើងហើយនោះឲ្យសោះ។ (គម្ពីរគួរអាន ៣:៨)
- ឱអ្នកដែលបង្វែដួងចិត្ត ! សូមទ្រង់ធ្វើអោយចិត្តរបស់ខ្ញុំនៅនឹងនរក្នុងសាសនារបស់ទ្រង់ផងចុះ។ (អាត់តៀរមីហ្ស៊ីៈ២១៤០)

## តើមានអ្វីកើតឡើងបន្ទាប់ពីការទទួលសារភាពកំហុស(តាវហ្ពាត់)?

នៅពេលដែលមនុស្សម្នាក់បានសារភាពកំហុសនិងផ្លាស់ប្តូរចិត្ត ពិតប្រាកដណាស់ អល់ឡោះនឹងអភ័យទោសនូវបាបកម្មវាទាំងអស់ទោះបីជាបាបកម្មនោះធំធេងយ៉ាងណាក៏ដោយ។ ក្តីមេត្តាករុណារបស់អល់ឡោះទូលំទូលាយលើរាល់អ្វីៗទាំងអស់ ដូចដែលអល់ឡោះបានមានបន្ទូលថា "ចូរអ្នក(ព្យាការីមូហាំម៉ាត់)ពោលថា ឱខ្ញុំបម្រើទាំងឡាយរបស់យើងដែលបានបំពានលើខ្លួនឯង! ចូរពួកអ្នកកុំអស់សង្ឃឹមចំពោះក្តីមេត្តាករុណារបស់អល់ឡោះឱ្យសោះ។ ពិតប្រាកដណាស់ អល់ឡោះនឹងអភ័យទោសនូវរាល់ទោសកំហុសទាំងអស់។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាអភ័យទោស មហាអាណិតស្រឡាញ់"។ (គម្ពីរគួរអាន ៣៩:៥៣)

ជនមូស្លីមបន្ទាប់ពីបានទទួលសារភាពកំហុសដោយស្មោះស្ម័គ្រ ត្រឹមត្រូវរួចមក គឺរូបគេគ្មានបាបកម្មអ្វីនៅជាប់នឹងខ្លួនគេទៀតនោះទេ។ ជាការពិតណាស់ អល់ឡោះបានប្រទានរង្វាន់ដល់បណ្តាអ្នកដែលសច្ចៈ និងបណ្តាអ្នកដែលគោរពប្រតិបត្តិ និងបណ្តាអ្នកដែលសោកស្តាយដែលមានការសោកស្តាយពិតប្រាកដ(ចំពោះបាបកម្មរបស់ខ្លួន)នូវរង្វាន់ដ៏អស្ចារ្យ ដោយផ្លាស់ប្តូរអំពើអាក្រក់របស់ពួកគេទៅជាអំពើល្អវិញ។ អល់ឡោះបានមានបន្ទូលថា "លើកលែងតែអ្នកណាដែលបានសារភាពកំហុស និងមានជំនឿ ព្រមទាំងបានសាងនូវអំពើល្អត្រឹមត្រូវ គឺអ្នកទាំងនោះហើយដែលអល់ឡោះនឹងប្តូរអំពើអាក្រក់របស់ពួកគេទៅជាអំពើល្អវិញ។ ហើយអល់ឡោះមហាអភ័យទោស មហាអាណិតស្រលាញ់"។ (គម្ពីរគួរអាន ២៥:៧០)

ជនណាហើយដែលស្ថិតនៅក្នុងស្ថានភាពនេះ ចូរខិតខំប្រឹងប្រែងក្នុងការថែទាំការសារភាពកំហុសនោះ និងខិតខំព្យាយាមឱ្យកាន់តែខ្លាំងក្លាដើម្បីជៀសវាងពីការធ្លាក់ចូលក្នុងអន្ទាក់របស់ស្ហៃតនដែលនាំឱ្យមានការបរាជ័យ។

## រសជាតិនៃជំនឿ

ជនណាហើយដែលក្តីស្រលាញ់របស់គេចំពោះអល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ ធំធេងជាងក្តីស្រឡាញ់របស់គេចំពោះអ្វីៗទាំងអស់នោះ គឺរូបគេនឹងក្លាយជាអ្នកដែលស្រលាញ់អ្នកដទៃទៅតាមកម្រិតដែលបុគ្គលនោះបញ្ជិតខ្លួនពួកគេទៅចំពោះអល់ឡោះ និងភាពត្រឹមត្រូវនៃសាសនារបស់ពួកគេ និងឥស្លាមរបស់ពួកគេ។ រូបគេនឹងក្លាយជាអ្នកដែលស្អប់ខ្ពើមការត្រឡប់ទៅរកអ្វីដែលគាត់បានធ្វើកាលពីមុននៃភាពគ្មានជំនឿ ការធ្វើស្ទីរិក(ពហុទេពនិយម) និងការវង្វេង(ចេញពីផ្លូវពិត) ដូចដែលរូបគេមិនពេញចិត្តឲ្យគេដុតក្នុងភ្លើងនរកដូច្នោះដែរ។ នៅក្នុងពេលនោះ រូបគេនឹងទទួលបានសម្រាប់ជំនឿនោះនូវភាពផ្អែមល្ហែម និងរសជាតិនៃជំនឿនៅក្នុងចិត្តរបស់គេ ដូចដែលគេទទួលបានភាពជិតស្និតទៅចំពោះអល់ឡោះ និងទំនុកចិត្ត និងសុភមង្គលក្នុងការគោរពតាមច្បាប់របស់អល់ឡោះ និងឧបការគុណរបស់អល់ឡោះមកលើគេដោយបានចង្អុលបង្ហាញផ្លូវត្រឹមត្រូវដែរ។ អ្នកនាំសារបានមានប្រសាសន៍ថា "បីប្រការ ជនណាមានបីប្រការនេះ គេនឹងទទួលបានរសជាតិនៃជំនឿ គឺការស្រលាញ់អល់ឡោះនិងអ្នកនាំសាររបស់ទ្រង់ជាងអ្នកដទៃ ស្រលាញ់រាប់អានបុគ្គលណាម្នាក់គឺគ្មានដើម្បីអ្វីក្រៅពីអល់ឡោះ និងការស្អប់ខ្ពើមមិនចង់វិលត្រឡប់ទៅជាអ្នកគ្មានជំនឿវិញបន្ទាប់ពីអល់ឡោះបានរំដោះគេ(ពីភាពគ្មានជំនឿ) បីដូចជាគេស្អប់ខ្ពើមមិនចង់អោយគេបោះបញ្ចូលក្នុងនរក"។ (អាល់ពូខរីៈ២១ មូស្លីមៈ៤៣)

## > ការថ្លែងអំណរគុណនៅចំពោះឧបការគុណនៃការចង្អុលបង្ហាញ និងការទទួលសារភាពកំហុស

ក្នុងចំណោមសកម្មភាពដ៏ធំធេងដែលជនមូស្លីមត្រូវធ្វើដើម្បីថ្លែងអំណរគុណចំពោះឧបការគុណរបស់អល់ឡោះដែលបានឱ្យរូបគេទទួលសារភាពកំហុស និងទទួលបានការចង្អុលបង្ហាញនោះគឺ៖



### 1 ប្រកាន់ខ្ជាប់នឹងសាសនា ហើយអត់ធ្មត់នឹងប្រការលំបាកក្នុងវា

ជនណាហើយដែលមានទ្រព្យសម្បត្តិវិសេសវិសាល គឺគេនឹងប្រុងប្រយ័ត្នក្នុងការថែរក្សាវាមិនឱ្យវាធ្លាក់ទៅក្នុងដៃពួកអ្នករំលោភបំពាន និងពពួកចោរការពារវាពីអ្វីគ្រប់យ៉ាងដែលប៉ះពាល់ដល់វា។ សាសនាឥស្លាម គឺជាអំណោយទានដ៏ធំធេងបំផុតសម្រាប់មនុស្សលោកទាំងអស់ ហើយវាមិនមែនគ្រាន់តែជាការផ្តល់ដល់គេនូវផ្នត់គំនិតមួយ ឬចំណង់ចំណូលចិត្តដែលមនុស្សចង់អនុវត្តន៍នៅពេលណាក៏បាននោះទេ ប៉ុន្តែសាសនាមានវិធានការរាល់អ្វីទាំងអស់ក្នុងជីវិតរបស់គេ ទាំងសកម្មភាពរបស់គេ និងភាពស្ងាត់ស្ងៀមរបស់គេ។ ដូច្នេះ អល់ឡោះបានមានបន្ទូលទៅកាន់អ្នកនាំសាររបស់ទ្រង់ដោយប្រើឱ្យគាត់ប្រកាន់ឲ្យបានខ្ជាប់ខ្លួននឹងសាសនាឥស្លាម និងគម្ពីរគួរអានហើយមិនត្រូវបោះបង់វាជាដាច់ខាតពីព្រោះគាត់ស្ថិតនៅលើមាគ៌ាដ៏ត្រឹមត្រូវ "ចូរអ្នកកាន់ឱ្យបានខ្ជាប់ខ្លួននូវអ្វី(គម្ពីរគួរអាន)ដែលគេបានបញ្ចុះឱ្យអ្នក។ ពិតប្រាកដណាស់ អ្នកកំពុងស្ថិតនៅលើផ្លូវដ៏ត្រឹមត្រូវ)។ (គម្ពីរគួរអាន ៤៣:៤៣)

ចាំបាច់ជនមូស្លីមមិនគួរមានការព្រួយបារម្ភណ៍ប្រសិនបើរូបគេបានជួបប្រទះការសាកល្បងណាមួយបន្ទាប់ ពីគេបានចូលឥស្លាមហើយនោះទេ ព្រោះនេះ គឺជាផែនការរបស់អល់ឡោះដើម្បីសាកល្បង។ មានអ្នកដែលល្អប្រសើរជាងពួកយើងជាច្រើន តែពួកគេត្រូវបានអល់ឡោះសាកល្បងនូវការលំបាកយ៉ាងធ្ងន់ធ្ងរ តែពួកគេបានអត់ធ្មត់ និងពុះពាររាល់ឧបសគ្គ។ ពួកគេនោះ គឺជាបណ្តាព្យាការី(អ្នកនាំសារ)ទាំងឡាយរបស់អល់ឡោះដែលអល់ឡោះបានប្រាប់យើងអំពីរឿងរ៉ាវរបស់ពួកគាត់។ ហេតុអ្វីបានជាពួកគាត់ជួបប្រទះទុក្ខលំបាកជាច្រើនលើសលប់ពីសំណាក់សាច់ញាតិខ្លួនឯង មុននឹងអ្នកដែលមិនមែនជាសាច់ញាតិ ប៉ុន្តែពួកគាត់មិនបានបាក់ទឹកចិត្តនូវអ្វីដែលបានកើតឡើងចំពោះពួកគាត់ក្នុងមាគ៌ារបស់អល់ឡោះឡើយ ហើយពួកគាត់មិនមានការផ្លាស់ប្តូរ និងមិនមានការប្រែប្រួលឡើយ។ វាគឺជាការសាកល្បងអំពីអល់ឡោះដើម្បីដឹងអំពីសេចក្តីជំនឿដ៏ស្មោះត្រង់របស់អ្នក និងការជឿជាក់យ៉ាងមុតមាំរបស់អ្នក។ ចូរស្ថិតនៅលើកិច្ចព្រមព្រៀងនៃការសាកល្បងនេះ ហើយកាន់ឱ្យខ្ជាប់ខ្លួននឹងសាសនានេះ។ ចូរបួងសួងទៅចំពោះអល់ឡោះ ដូចដែលព្យាការីមូហាំម៉ាត់បានបួងសួងដោយគាត់បានបួងសួងថា «يا مقلب القلوب ثبت قلبي على دينك» (យ៉ាមូកល់ លីហ្គាល់ គូលូប សាប់ពីត គល់ពី អាឡើ ទីនីក) មានន័យថា "ឱអ្នកដែលបង្វែរដួងចិត្ត ! សូមទ្រង់ធ្វើអោយចិត្តរបស់ខ្ញុំនៅនឹងនរក្នុងសាសនារបស់ទ្រង់ផងចុះ"។ (អាត់តៀតរមីហ្ស៊ីៈ២១៤០)។ នៅក្នុងន័យនេះដែរ អល់ឡោះបានមានបន្ទូលថា "តើមនុស្សលោកគិតថា ពួកគេត្រូវគេបណ្តោយឱ្យនិយាយថា ពួកយើងបានជឿហើយដោយពួកគេមិនត្រូវបានគេសាកល្បងឬ? ហើយជាការពិតណាស់ យើងបានសាកល្បងអ្នកជំនាន់មុនពួកគេរួចមកហើយ។ ហើយអល់ឡោះដឹងបំផុតបណ្តាអ្នកដែលទៀងត្រង់ និងដឹងបំផុតចំពោះពួកដែលភូតកុហក"។

(គម្ពីរគួរអាន ២៩:២-៣)

## 2 ឧស្សាហ៍ព្យាយាមក្នុងការអំពាវនាវមនុស្សទៅរកឥស្លាមដោយគតិបណ្ឌិត និងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អ

វាគឺជាមាគ៌ាដ៏អស្ចារ្យក្នុងការថ្លែងអំណរគុណទៅចំពោះឧបការគុណនៃសាសនាឥស្លាមដែលបានផ្តល់ឱ្យមនុស្ស ក៏ដូចជាវាជាមូលហេតុដ៏អស្ចារ្យដែលធ្វើឱ្យមានការនឹងនរនៅក្នុងសាសនារបស់អល់ឡោះ។ ជនណាហើយដែលបានរួចផុតជីវិតពីជំងឺដ៏គ្រោះថ្នាក់ ហើយជម្រះរាងកាយរបស់គេពីជំងឺដែលមើលមិនជាយូរមកហើយដែលនៅជាប់ជាមួយនឹងគេ ហើយបានបំផ្លាញពេលវេលាទាំងថ្ងៃទាំងយប់របស់គេ ហើយបន្ទាប់មកក៏បានរកឃើញវិធីសាស្ត្រសម្រាប់ការព្យាបាលជំងឺនោះ ពិតណាស់មនុស្សនឹងយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយវាទៅឱ្យមនុស្សដទៃទៀត និងជាពិសេសរវាងក្រុមគ្រួសារនិងសាច់ញាតិនៃមនុស្សដែលគាត់ស្រឡាញ់។ហើយវាគឺជាអ្វីដែលនឹងត្រូវបានបកស្រាយដូចខាងក្រោម ៖

# > ការអំពាវនាវទៅកាន់សាសនាឥស្លាម

### គុណសម្បត្តិនៃការអំពាវនាវទៅរកអល់ឡោះ

ការអំពាវនាវទៅរកអល់ឡោះ គឺជាកិច្ចការដ៏ល្អប្រសើរមួយ និងជាការបញ្ចិតខ្លួនដ៏អស្ចារ្យទៅចំពោះអល់ឡោះ ហើយក៏មានការសរសើរនៅក្នុងគម្ពីរគួរអាន និងប្រសាសន៍របស់ព្យាការីទៅលើវាផងដែរ ៖

1 ការអំពាវនាវទៅរកអល់ឡោះវាគឺជាមាគ៌ាដែលនាំទៅរកភាពជោគជ័យ និងជ័យជំនះទាំងនៅលើលោកិយ និងថ្ងៃបរលោក។ អល់ឡោះបានមានបន្ទូលថា "ហើយចូរឱ្យមានក្រុមមួយក្នុងចំណោមពួកអ្នក អំពាវនាវទៅរកផ្លូវល្អ និងប្រើគ្នាឱ្យធ្វើប្រការដែលត្រឹមត្រូវ(តាមច្បាប់ឥស្លាម) និងហាមឃាត់គ្នាអំពីប្រការអាក្រក់។ ហើយអ្នកទាំងនោះគឺជាអ្នកដែលជោគជ័យ"។ (គម្ពីរគួរអាន ៣:១០៤)

2 ពាក្យសំដីរបស់អ្នកអំពាវនាវ គឺជាពាក្យសំដីដែលល្អប្រសើរបំផុត និងជាពាក្យសំដីដែលអល់ឡោះស្រលាញ់ជាងគេ ដូចដែលអល់ឡោះបានមានបន្ទូលសរសើរទៅចំពោះពាក្យសំដីរបស់អ្នកអំពាវនាវថា "ហើយគ្មានអ្នកណាម្នាក់ដែលមានពាក្យសំដីល្អប្រសើរជាងអ្នកដែលបានអំពាវនាវទៅចំពោះអល់ឡោះ និងបានសាងអំពើល្អត្រឹមត្រូវ ព្រមទាំងបាននិយាយថា ពិតណាស់ ខ្ញុំជាមនុស្សម្នាក់ក្នុងចំណោមអ្នកមូស្លីមទាំងឡាយនោះឡើយ"។ (គម្ពីរគួរអាន ៤១:៣៣)។ គ្មានពាក្យសំដីណាដែលល្អប្រសើរជាងពាក្យសំដីរបស់អ្នកដែលអំពាវនាវគេទៅរកសាសនាឥស្លាមនោះឡើយ ហើយវាជាការណែនាំមនុស្ស និងការនាំផ្លូវពួកគេទៅរកការគោរពសក្ការៈចំពោះម្ចាស់របស់ពួកគេ អ្នកបង្កើតពួកគេ អ្នកគ្រប់គ្រងពួកគេ អ្នកបញ្ចេញពួកគេពីភាពងងឹត ប្រការស្ទីរិក ទៅរកភាពមានពន្លឺ មានជំនឿ។

3 ការអំពាវនាវ គឺជាការអនុវត្តទៅតាមបទបញ្ជារបស់អល់ឡោះ ដូចដែលអល់ឡោះបានមានបន្ទូលថា "ចូរអ្នក(ព្យាការីមូហាំម៉ាត់)អំពាវនាវ(មនុស្សលោក)ទៅកាន់មាគ៌ានៃម្ចាស់របស់អ្នកដោយគតិបណ្ឌិត និងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អចុះ ហើយចូរអ្នកជជែកជាមួយពួកគេតាមមធ្យោបាយណាដែលល្អបំផុត)។ (គម្ពីរគួរអាន ១៦:១២៥)។ ហើយចាំបាច់សម្រាប់អ្នកដែលអំពាវនាវទៅរកសាសនាឥស្លាមនោះ ត្រូវអំពាវនាវដោយគតិបណ្ឌិត ហើយនិងចាត់ចែងកិច្ចការឱ្យចំកន្លែងរបស់វានិងដឹងអំពីស្ថានភាពអ្នកដែលត្រូវអំពាវនាវ និងអ្វីដែលសាកសមសម្រាប់ពួកគេ ហើយនិងអ្វីដែលពួកគេត្រូវការវា ដោយការប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អ ហើយនិងសន្ទនាជាមួយពួកគេតាមមាគ៌ាដែលល្អបំផុត និងភាពទន់ភ្លន់ និងបញ្ចិតខ្លួន ដើម្បីចង្អុលបង្ហាញភាពត្រឹមត្រូវដល់ពួកគេ។

4 ពិតណាស់ការអំពាវនាវ គឺជាកាតព្វកិច្ចរបស់បណ្ដាអ្នកនាំសារគ្រប់រូប អ្នកដែលសំខាន់ជាងគេនោះ គឺអ្នកនាំសាររបស់ពួកយើង ព្យាការីមូហាំម៉ាត់ ដែលអល់ឡោះបានបញ្ជូនគាត់មក ដើម្បីធ្វើជាសាក្សីទៅលើមនុស្សលោក និងជាអ្នកផ្ដល់ដំណឹងរីករាយសម្រាប់អ្នកដែលមានជំនឿ អំពីឋានសួគ៌និងផលបុណ្យ និងជាអ្នកដាស់តឿនព្រមានសម្រាប់ពួកដែលគ្មានជំនឿនិងអ្នកដែលប្រឆាំង អំពីឋាននរក និងទណ្ឌកម្ម។ ហើយលោក ក៏ជាអ្នកអំពាវនាវទៅកាន់អល់ឡោះ និងផ្សព្វផ្សាយពន្លឺទៅដល់មនុស្សជាតិទាំងអស់ផងដែរ។ អល់ឡោះបានមានបន្ទូលថា "ឱព្យាការី(ព្យាការីមូហាំម៉ាត់)! ពិតប្រាកដណាស់ យើងបានបញ្ជូនអ្នកធ្វើជាសាក្សី និងជាអ្នកផ្ដល់ដំណឹងរីករាយ ហើយនិងជាអ្នកដាស់តឿនព្រមាន។ ហើយក៏ជាអ្នកអំពាវនាវ(មនុស្សលោក)ទៅកាន់អល់ឡោះដោយការអនុញ្ញាតរបស់ទ្រង់ និងជាពន្លឺដើម្បីបំភ្លឺ។ ហើយចូរអ្នកផ្ដល់ដំណឹងរីករាយដល់បណ្ដាអ្នកមានជំនឿថា ពិតណាស់ សម្រាប់ពួកគេគឺទទួលបានការប្រោសប្រទានដ៏ធំធេងពីអល់ឡោះ"។ (គម្ពីរគួរអាន ៣៣:៤៥-៤៧)

5 ការអំពាវនាវ គឺជាទ្វានៃអំពើល្អដែលមិនចេះដាច់ឡើយ។ សម្រាប់បុគ្គលណាម្នាក់ដែលទទួលយកការអំពាវនាវរបស់អ្នក ហើយទទួលបានការចង្អុលបង្ហាញដោយដៃរបស់អ្នក ពិតណាស់សម្រាប់អ្នកនឹងទទួលបានផលបុណ្យដូចជារូបគេដែរ ដោយការសឡាតរបស់គេ ការគោរពសក្ការៈរបស់គេ និងការបង្រៀនរបស់គេទៅចំពោះមនុស្ស។ នេះជាផលបុណ្យដ៏អស្ចារ្យដែលអល់ឡោះបានផ្ដល់ដល់អ្នកអំពាវនាវ។ ព្យាការីបានមានប្រសាសន៍ថា "បុគ្គលណាចង្អុលបង្ហាញផ្លូវល្អដល់គេ គាត់នឹងទទួលផលបុណ្យដូចផលបុណ្យអ្នកដែលអនុវត្តតាមគាត់ ដោយគេមិនកាត់បន្ថយផលបុណ្យរបស់អ្នកដែលអនុវត្តតាមគាត់បន្តិចណាឡើយ)។

(មូស្លីមៈ ២៦៧៤)

6 ផលបុណ្យអ្នកដែលអំពាវនាវទៅរកអល់ឡោះល្អប្រសើរជាងទ្រព្យសម្បត្តិទាំងអស់ដែលមានលើលោកិយនេះ ហើយផលបុណ្យអ្នកអំពាវនាវគឺនៅលើអល់ឡោះ ដោយគេមិនយកពីនរណាម្នាក់ឡើយ។ ដូច្នេះហើយ ទើបផលបុណ្យរបស់វា គឺធំធេង។ ពិតណាស់ ម្ចាស់ដ៏មហាសប្បុរស ទ្រង់មិនផ្ដល់ឱ្យអ្នកណាដែលទ្រង់ស្រលាញ់នោះទេ លើកលែងតែជារបស់ដែលអស្ចារ្យ ដូចអល់ឡោះបានមានបន្ទូលថា "ប៉ុន្ដែ ប្រសិនបើពួកអ្នកបានបែរចេញ(ពីការអំពាវនាវរបស់ខ្ញុំ) ខ្ញុំពិតជាមិនស្នើសុំកម្រៃពីពួកអ្នកឡើយ។ កម្រៃរបស់ខ្ញុំ គឺកម្រៃពីអល់ឡោះតែមួយគត់ ហើយខ្ញុំត្រូវបានគេបង្គាប់ឱ្យក្លាយជាអ្នកដែលស្ថិតក្នុងចំណោមអ្នកមូស្លីម"។ (គម្ពីរគួរអាន ១០:៧២)។ ហើយព្យាការីក៏បានមានប្រសាសន៍ដែរថា "ប្រសិនបើអល់ឡោះចង្អុលបង្ហាញនរណាម្នាក់(ឱ្យចូលឥស្លាម)តាមរយៈអ្នកនោះ គឺវាល្អប្រសើរសម្រាប់អ្នក ជាងសត្វអូដ្ឋពណ៌ក្រហមទៅទៀត"។ (អាល់ពូខរីៈ២៨៤៧ មូស្លីមៈ២៤០៦)

## របៀបអំពាវនាវដែលត្រឹមត្រូវ

អល់ឡោះបានរៀបរាប់ពីរបៀបនៃការអំពាវនាវដែលត្រឹមត្រូវ និងលក្ខណៈសម្បត្តិមួយចំនួនដែលមានភាពខុសប្លែកពីគេ ដែលមានដូចខាងក្រោម ៖

### 1 ការចេះដឹងច្បាស់លាស់ និងចំណេះដឹង

ចាំបាច់ទៅលើអ្នកអំពាវនាវ គឺត្រូវតែជាអ្នកមានចំនេះដឹងនឹងអ្វីដែលគាត់អំពាវនាវទៅរកនោះ និងស្គាល់អ្វីដែលគាត់កំពុងនិយាយ ដូចអល់ឡោះបានមានបន្ទូលថា "ចូរអ្នក(ព្យាការីមូហាំម៉ាត់) ពោលថា នេះជាមាគ៌ារបស់ខ្ញុំ ដែលខ្ញុំអំពាវនាវទៅកាន់អល់ឡោះ ដោយមានការចេះដឹងច្បាស់លាស់ ខ្ញុំ និងអ្នកដែលបានដើរតាមខ្ញុំ(ត្រូវអំពាវនាវអ្នកផ្សេងទៀតទៅកាន់អល់ឡោះ)"។(គម្ពីរគួរអាន ១២:១០៨)

មានន័យថា ឱព្យាការី! ចូរអ្នកពោលចុះថា នេះគឺជាមាគ៌ារបស់ខ្ញុំ និងការចង្អុលបង្ហាញរបស់ខ្ញុំ។ ខ្ញុំអំពាវនាវទៅកាន់អល់ឡោះ ដោយមានចំណេះដឹង និងការដឹងច្បាស់លាស់។ ហើយវាជាមាគ៌ាអ្នកដែលបានដើរតាមខ្ញុំនៃអ្នកអំពាវនាវ។

ហើយការអំពាវនាវទៅកាន់អល់ឡោះ មិនចាំបាច់សម្រាប់តែអ្នកមូស្លីមដែលមានចំណេះដឹងច្រើននោះទេ។ នៅពេលណាដែលគេបានដឹងពីច្បាប់អ្វីមួយ ចាំបាច់គេត្រូវតែអំពាវនាវទៅកាន់វា។ ហើយនៅពេលដែលអ្នកដឹងថា ការគោរពសក្ការៈគឺសម្រាប់តែអល់ឡោះម្នាក់គត់ ចាំបាច់ត្រូវតែផ្សព្វផ្សាយវាទៅកាន់មនុស្ស ហើយនៅពេលដែលអ្នកដឹងអំពីប្រការល្អរបស់សាសនាឥស្លាម ចាំបាច់អ្នកត្រូវតែផ្សព្វផ្សាយវាទៅកាន់មនុស្ស សូម្បីតែវានោះមួយឃ្លាអំពីគម្ពីរគួរអានក៏ដោយ ដូចព្យាការីបានមានប្រសាសន៍ថា "ចូរពួកអ្នកផ្សព្វផ្សាយអំពីខ្ញុំ ទោះបីជាមួយប្រយោគក៏ដោយ"។ (អាល់ពូខរី:៣២៧៤)

ពិតណាស់ បណ្ដាមិត្តភក្ដិព្យាការី ដែលបានចូលឥស្លាមដោយដៃរបស់ព្យាការីផ្ទាល់ ពួកគេបានរៀនពីគោលការណ៍នៃសាសនាឥស្លាមនិងគោលគ្រឹះរបស់វានៅក្នុងពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ។ បន្ទាប់មកពួកគេក៏ត្រឡប់ទៅរកក្រុមរបស់ពួកគេ ហើយក៏អំពាវនាវពួកគេឱ្យចូលឥស្លាម ហើយពួកគេក៏មានការចាប់អារម្មណ៍ចង់ចូលឥស្លាម។ ហើយដោយសារសីលធម៌ល្អរបស់ពួកគាត់ ធ្វើឱ្យមនុស្សមានចំណាប់អារម្មណ៍ក្នុងការចូលសាសនាឥស្លាម។

## 2 អំពាវនាវដោយគតិបណ្ឌិត

អល់ឡោះបានមានបន្ទូលថា "ចូរអ្នក(ព្យាការីមូហាំម៉ាត់)អំពាវនាវ(មនុស្សលោក)ទៅកាន់មាគ៌ានៃម្ចាស់របស់អ្នកដោយគតិបណ្ឌិត និងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អចុះ ហើយចូរអ្នកជជែកជាមួយពួកគេតាមមធ្យោបាយណាដែលល្អបំផុត"។ (គម្ពីរគួរអាន ១៦:១២៥)។ គតិបណ្ឌិត គឺសកម្មភាពដែលចាំបាច់ត្រូវធ្វើទៅតាមវិធីសាស្ត្រដែលសមរម្យ ជាមួយនឹងការជ្រើសរើសពេលវេលា និងទីកន្លែងសមរម្យ។

មនុស្សមានលក្ខណៈខុសគ្នារវាងធម្មជាតិរបស់ពួកគេ និងកូនសោរបេះដូងរបស់ពួកគេ និងខុសគ្នានៅក្នុងសមត្ថភាពរបស់ពួកគេក្នុងការយល់ដឹង និងការទទួលយក។ សម្រាប់អ្នកអំពាវនាវត្រូវតែជ្រើសរើសវិធីសាស្ត្រដែលសមស្របសម្រាប់ពួកគេ ដោយការឆក់យកឱកាសមានឥទ្ធិពលបំផុតនៅក្នុងជីវិតរបស់ពួកគេ។

ទាំងនោះត្រូវធ្វើដោយភាពទន់ភ្លន់ និងប្រៀនប្រដៅតាមវិធីសាស្ត្រដ៏ល្អ និងចិត្តមេត្តាករុណា និងក្ដីអាណិតស្រលាញ់ចំពោះអ្នកដែលយើងអំពាវនាវ និងការពិភាក្សាស្ងប់ស្ងាត់ និងមានតុល្យភាពដែលមិនធ្វើឱ្យមានការឈឺចាប់ និងការជម្រុញឱ្យស្អប់។ ដូច្នេះហើយទើបអល់ឡោះជាម្ចាស់បានផ្ដល់ឱ្យអ្នកនាំសាររបស់ទ្រង់នូវភាពទន់ភ្លន់ និងអធ្យាស្រ័យជាមួយមនុស្ស។ ហើយពិតណាស់ ប្រសិនបើគាត់មានអាកប្បកិរិយាកោងកាច និងរឹងរូសវិញនោះ មនុស្សនឹងចាកចេញពីគាត់មិនខានឡើយ ដូចដែលអល់ឡោះបានមានបន្ទូលថា "ដោយសារមានក្ដីអាណិតស្រលាញ់ពីអល់ឡោះ អ្នក(ព្យាការីមូហាំម៉ាត់)បានធ្វើទន់ភ្លន់ចំពោះមនុស្ស។ តែបើអ្នកមានអាកប្បកិរិយាកោងកាចនិងរឹងរូសវិញនោះ គឺពួកគេនឹងចាកចេញពីអ្នកជាមិនខាន"។ (គម្ពីរគួរអាន ៣:១៥៩)

## ការអំពាវនាវក្រុមគ្រួសារ

ជាការចាំបាច់សម្រាប់អ្នកដែលអល់ឡោះបានប្រទានផលបុណ្យដល់គាត់ឱ្យបានចូលក្នុងសាសនាឥស្លាម ត្រូវមានការព្យាយាមក្នុងការអំពាវនាវក្រុមគ្រួសារ និងសាច់ញាតិរបស់គាត់ ដោយសារពួកគេគឺជាមនុស្សដែលនៅជិត និងជាអ្នកដែលគាត់ស្រឡាញ់បំផុត ដោយការអត់ធ្មត់នៅលើអ្វីដែលគាត់បានចូលរួមជាមួយពួកគេ និងស្វែងរកគ្រប់វិធីសាស្ត្រទៅលើវានោះ ដូចអល់ឡោះបានមានបន្ទូលថា "ហើយចូរអ្នក( ព្យាការីមូហាំម៉ាត់ )បង្គាប់ឱ្យក្រុមគ្រួសាររបស់អ្នកប្រតិបត្តិសឡាត និងអត់ធ្មត់ចំពោះវា"។ ( គម្ពីរគួរអាន ២០:១៣២ )

ពិតណាស់ មានអ្នកអំពាវនាវមួយចំនួន ត្រូវបានគេទទួលយកការអំពាវនាវរបស់គាត់នៃអ្នកដែលនៅឆ្ងាយពីគាត់ ហើយមិនមានឡើយអ្នកដែលនៅជិតគាត់បំផុតនោះ។ នេះជាការឈឺចាប់ និង ជារឿងសោកសង្វេក។ ក៏ប៉ុន្តែអ្នកអំពាវនាវដែលទទួលបានជោគជ័យ គឺអ្នកដែលខិតខំនិងព្យាយាមស្វែងរកមូលហេតុ ប្រើវិធីសាស្ត្រនិងបច្ចេកទេសនានា និងបួងសួងដល់អល់ឡោះសុំការចង្អុលបង្ហាញត្រឹមត្រូវដល់ពួកគេ ហើយគេមិនអស់សង្ឃឹម សូម្បីស្ថិតនៅក្នុងកាលៈទេសៈដ៏ខ្មៅងងឹតក៏ដោយ។

ដូចដែលអ្នកនាំសារបានធ្វើជាមួយនឹងឪពុកមាររបស់គាត់ អាពូ តឡឹប ជាអ្នកដែលតែងតែជួយនិងការពារគាត់ប្រឈមមុខជាមួយនឹងកុលសម្ព័ន្ធ គូរ៉ស្ហ ក៏ប៉ុន្តែគាត់មិនបានចូលឥស្លាមឡើយ។ ហើយអ្នកនាំសារនៅតែបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអំពាវនាវរបស់គាត់រហូតដល់ពេលចុងក្រោយនៃជីវិតរបស់គាត់ ហើយព្យាការីបានមានប្រសាសន៍ថា "ឱ!ឪពុកមាររបស់ខ្ញុំ! ចូរអ្នកពោលថា ឡាអ៊ីឡាហាអ៊ិលឡល់ឡោះ ( គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវ មានតែអល់ឡោះមួយគត់ )។ តាមរយៈពាក្យនេះ ខ្ញុំប្រហែលជាអាចជួយអន្តរាគមន៍ដល់អ្នកនៅពេលជួបជាមួយអល់ឡោះបាន"។ ( អាល់ពូខរី:៣៦៧១ មូស្លីម:២៤ )។ក៏ប៉ុន្តែ គាត់មិនបានទទួលយកការអំពាវនាវរបស់ព្យាការីនោះទេ ហើយក៏បានស្លាប់នៅលើភាពគ្មានជំនឿ។ ពេលនោះអល់ឡោះបានបញ្ចុះបន្ទូលរបស់ទ្រង់ថា "ពិតប្រាកដណាស់អ្នក( ព្យាការីមូហាំម៉ាត់ )មិនអាចចង្អុលបង្ហាញចំពោះអ្នកណាដែលអ្នកស្រលាញ់បានឡើយ ក៏ប៉ុន្តែអល់ឡោះអាចចង្អុលបង្ហាញចំពោះអ្នកណាដែលទ្រង់មានចេតនា។ ហើយទ្រង់ដឹងបំផុតចំពោះបណ្ដាអ្នកដែលបានទទួលការចង្អុលបង្ហាញ"។ ( គម្ពីរគួរអាន ២៨:៥៧ )។ សម្រាប់អ្នកអំពាវនាវ ត្រូវខិតខំប្រើប្រាស់សមត្ថភាពរបស់ខ្លួន និងផ្សព្វផ្សាយសាសនា និងចង្អុលបង្ហាញមនុស្សទៅកាន់ប្រការល្អ ក៏ប៉ុន្តែចិត្តគឺនៅក្នុងដៃរបស់អល់ឡោះ។ ទ្រង់ចង្អុលបង្ហាញចំពោះអ្នកណាដែលទ្រង់មានចេតនាទៅកាន់មាគ៌ាដ៏ត្រឹមត្រូវ។



ការចូលឥស្លាមរបស់កូនក្មេង

មនុស្សទាំងអស់ត្រូវបានបង្កើតនៅលើភាពស្អាតស្អំ និងសាសនាឥស្លាម។ ចំណែកឯសាសនាដទៃទៀតបានកើតឡើងនៅលើវាដោយសារតែការបង្រៀនរបស់ឪពុកម្ដាយពួកគេ និងការអប់រំពួកគេ។ អ្នកនាំសារបានមានប្រសាសន៍ថាៈ "គ្មានទេទារកបានកើតមក លើកលែងតែកើតនៅលើភាពស្អាតស្អំ (ស្ថិតនៅលើសាសនាឥស្លាម) ប៉ុន្តែគឺឪពុកម្ដាយរបស់គេទេដែលធ្វើឱ្យរូបគេក្លាយជាអ្នកកាន់សាសនាយូដា ឬកាន់សាសនាគ្រឹស្ត ឬកាន់សាសនាគោរពអគ្គី"។(អាល់ពូខរីៈ១២៩២ មូស្លីមៈ២៦៥៨)

ក៏ប៉ុន្តែ ចំពោះកុមារដែលគ្មានជំនឿហើយបានស្លាប់ ពិតណាស់យើងកំណត់ជាមួយពួកគេនឹងច្បាប់អ្នកគ្មានជំនឿនៅក្នុងលោកិយនេះ ហើយអល់ឡោះទ្រង់ដឹងការសម្ងាត់និងការលាក់បាំង ហើយម្ចាស់របស់អ្នកទ្រង់មិនបំពានទៅលើជនណាម្នាក់ឡើយ។ គេនឹងសាកល្បង(ធ្វើតេស្ត)ពួកគេនៅថ្ងៃបរលោក។ ជនណាហើយដែលធ្វើតាម នឹងបានចូលឋានសួគ៌ ហើយជនណាហើយដែលប្រឆាំងនឹងបានចូលឋាននរក។

នៅពេលដែលមានគេមកសួរអ្នកនាំសារអំពីកូនៗរបស់ពួកអ្នកគ្មានជំនឿ គាត់បានមានប្រសាសន៍ថា "អល់ឡោះជាម្ចាស់ នៅពេលដែលទ្រង់បង្កើតពួកគេ ទ្រង់មហាដឹងនូវអ្វីដែលពួកគេនឹងប្រព្រឹត្ត"។ (អាល់ពូខរីៈ១៣១៧)

## ក៏ប៉ុន្តែ តើនៅពេលណាទើបយើងអាចកាត់ក្ដីថា កុមារដែលគ្មានជំនឿជាអ្នកមានជំនឿវិញនៅក្នុងលោកិយនេះ?

ដើម្បីបញ្ជាក់អំពីឥស្លាមរបស់កុមារ មានករណីជាច្រើនខុសៗគ្នា រួមមាន ៖

1. នៅពេលដែលឪពុកម្ដាយចូលឥស្លាមទាំងពីរ ឬម្នាក់ក្នុងចំណោមគេទាំងពីរចូលឥស្លាម ពិតណាស់ កុមារនឹងតាមម្នាក់ក្នុងចំណោមពួកគេដែលមានសាសនាល្អ។

2. នៅពេលដែលកុមារដឹងខុសត្រូវ តែគេមិនទាន់ពេញវ័យ(គ្រប់អាយុ)បានចូលឥស្លាម សូម្បីតែឪពុកម្ដាយរបស់គេមិនចូលឥស្លាមក៏ដោយ។ ហើយពិតណាស់មានក្មេងសាសន៍យូដាម្នាក់ដែលបម្រើអ្នកនាំសារ គេបានឈឺ។ ព្យាការីក៏បានទៅសួរសុខទុក្ខគេ ហើយបានអង្គុយត្រង់កន្លែងក្បាលរបស់គេ ហើយក៏មានប្រសាសន៍ទៅកាន់គេថា "សូមអ្នកចូលឥស្លាម"។ ពេលនោះ ក្មេងនោះក៏បានសម្លឹងមើលទៅឪពុករបស់គេ ដែលនៅជាមួយគេដែរនោះ។ ពេលនោះ ឪពុករបស់ក្មេងនោះ ក៏បាននិយាយទៅកាន់កូនគាត់ថា "ចូរឯង(ចូលឥស្លាម) តាមឪពុករបស់ អាល់កសឹម(ព្យាការី)ចុះ"។ ពេលនោះ ក្មេងនោះក៏បានចូលឥស្លាម។ ព្យាការីក៏បានចាកចេញហើយលោកក៏បានមានប្រសាសន៍ថា "រាល់ការសរសើរទាំងឡាយ គឺសម្រាប់អល់ឡោះដែលបានរំដោះរូបគេអំពីឋាននរក"។ (អាល់ពូខរីៈ១២៩០)

តើឪពុកម្ដាយរបស់គេ ឬម្នាក់ក្នុងចំណោមពួកគេបានចូលឥស្លាមឬទេ ?

ទេ | បាទ

ចាប់កំណត់ថាគេជាមូស្លីម ហើយទំនាក់ទំនងជាមួយគេនឹងច្បាប់អ្នកមូស្លីម ។

តើគេចូលឥស្លាមដោយឯករាជ្យអំពីគ្រួសាររបស់គេទេ ?

ទេ | បាទ

ច្បាប់កំណត់ថាគេជាមូស្លីមត្រឹមត្រូវនៅក្នុងលោកិយ បើសិនជាគេដឹងខុសត្រូវ យល់អ្វីដែលគេនិយាយ ។ ដូច្នេះ វានឹងផ្ដល់ផលប្រយោជន៍ដល់គេ និងការពារគេនៅថ្ងៃបរលោក ដោយមានការឯកភាពអំពីអ្នកមូស្លីមទាំងអស់ ។

កុមារដែលគ្មានជំនឿហើយបានស្លាប់ ពិតណាស់យើងកំណត់ជាមួយពួកគេនឹងច្បាប់អ្នកគ្មានជំនឿ នៅក្នុងលោកិយនេះ ហើយអល់ឡោះទ្រង់ដឹងការសម្ងាត់និងការលាក់បាំង ។ ហើយម្ចាស់របស់អ្នក ទ្រង់មិនបំពានទៅលើជនណាម្នាក់ឡើយ ។ ហើយទ្រង់នឹងប្រឡង(ធ្វើតេស្ត)ពួកគេ នឹងសាកល្បងពួកគេនៅថ្ងៃបរលោក ។ ជនណាហើយដែលធ្វើតាម នឹងបានចូលឋានសួគ៌ ហើយជនណាដែលប្រឆាំង នឹងបានចូលឋាននរក ។



## > តើគេគប្បីផ្លាស់ប្តូរឈ្មោះ បន្ទាប់ពីចាប់ចូលសាសនាឥស្លាមដែរឬទេ?




ជាតុដើមវា គឺអ្នកមូស្លីមរក្សាទុកឈ្មោះរបស់គេក្រោយអំពីចូលឥស្លាមដោយមិនផ្លាស់ប្តូរឡើយ។ ហើយការផ្លាស់ប្តូរឈ្មោះ ពុំត្រូវបានគេដឹង(អនុវត្ត)នៅក្នុងសម័យកាលមិត្តភក្តិរបស់ព្យាការីឡើយ។ ពិតណាស់មនុស្សបានចូលឥស្លាម ហើយក៏ស្ថិតនៅលើឈ្មោះរបស់ពួកគេ ដែលមិនមែនជាឈ្មោះតាមភាសាអារ៉ាប់ដដែល លើកលែងតែវាមានអត្ថន័យអាក្រក់ ទើបគេផ្លាស់ប្តូរវាដោយមូលហេតុវាមានអត្ថន័យអាក្រក់។

### ហើយចាំបាច់ត្រូវផ្លាស់ប្តូរឈ្មោះក្នុងករណីដែលមានដូចខាងក្រោមនេះ

**1** ប្រសិនបើវាបង្ហាញពីភាពជាខ្ញុំបម្រើទៅចំពោះអ្វីផ្សេងអំពីអល់ឡោះ ឬមានអត្ថន័យដែលផ្ទុយពីជំនឿ

ដូចជាឈ្មោះថា អាប់ទុលម៉ាសៀហ (ខ្ញុំរបស់អាល់ម៉ាសៀហ) អាប់ទុនណាពី (ខ្ញុំរបស់ព្យាការី) ឬឈ្មោះដែលចូលក្នុងអត្ថន័យនេះ ឬឈ្មោះមានអត្ថន័យផ្ទុយអំពីជំនឿដូចជាឈ្មោះ សានូហ្វះ ដែលមានន័យថា "បុត្ររបស់អល់ឡោះ"ជាដើម។ អល់ឡោះមហាខ្ពង់ខ្ពស់បំផុតលើសអ្វីៗទាំងអស់។

ឬក៏ដាក់ឈ្មោះទាំងឡាយណាដែលជាឈ្មោះផ្ទាល់របស់អល់ឡោះដែលសម្រាប់តែទ្រង់ ឬលក្ខណៈសម្បត្តិរបស់ទ្រង់ ៖

ដូចជា ការឱ្យលក្ខណៈអ្វីម៉្យាងទៅខ្ញុំបម្រើរបស់អល់ឡោះដែលជាលក្ខណៈមានសម្រាប់តែទ្រង់ ដូចជាដាក់ឈ្មោះថា ម៉ាលីគុលមូលូក (ស្តេចនៃស្តេចទាំងអស់)ជាដើម។

## 2 ឈ្មោះនោះបានបង្ហាញពីអត្ថន័យអាក្រក់ ដែលមានការស្អប់ខ្ពើម ពីធម្មជាតិ និងមនុស្សជាតិជាមួយគ្នាផងដែរ

ហើយអល់ឡោះបានដាក់បម្រាមលើយើងនូវអ្វីដែលអាក្រក់មិនថាចំណីអាហារ ភេសជ្ជៈ និងគ្រប់កិច្ចការទាំងអស់នៅក្នុងជីវិត។ ដូចនេះ មិនត្រូវដាក់ឈ្មោះដែលមានអត្ថន័យអាក្រក់ឬបង្ហាញទៅលើអ្វីដែលអាក្រក់ ក្រោយអំពីឥស្លាមឡើយ។ អល់ឡោះបានមានបន្ទូលថា "ការដាក់ងារមិនល្អក្រោយពីមានជំនឿហើយនោះ គឺអាក្រក់បំផុត"។ (គម្ពីរគួរអាន ៤៩:១១)

### ប្រការដែលគប្បីក្នុងការផ្លាស់ប្តូរឈ្មោះ

ប្រសិនបើឈ្មោះថ្មីនោះ គឺជាឈ្មោះដែលអល់ឡោះស្រលាញ់ ដូចជាផ្លាស់ប្តូរឈ្មោះទៅជាអាប់ទុលឡោះ (ខ្ញុំបម្រើរបស់អល់ឡោះ) និងអាប់ទុលរ៉ោះម៉ាន (ខ្ញុំបម្រើរបស់ម្ចាស់មហាសប្បុរស) និងអ្វីដែលសំដៅលើភាពជាខ្ញុំបម្រើរបស់អល់ឡោះ គឺសុទ្ធតែជាឈ្មោះដែលគេអនុញ្ញាត ក៏ប៉ុន្តែទាំងអស់នោះ វាមិនមានទំនាក់ទំនងអ្វីជាមួយនឹងការចូលឥស្លាមរបស់គេឡើយ។

- ហើយសម្រាប់គេផងដែរអាចផ្លាស់ប្តូរឈ្មោះរបស់គេតែម្តង សូម្បីតែគ្មានមូលហេតុអ្វីក៏ដោយ ដូចជាការផ្លាស់ប្តូរឈ្មោះរបស់គាត់ដែលមិនមែនជាភាសាអារ៉ាប់ ឱ្យទៅជាឈ្មោះជាភាសាអារ៉ាប់។ ក៏ប៉ុន្តែទាំងនោះ វាមិនមែនជាប្រការដែលគេជម្រុញឲ្យធ្វើនោះទេ ហើយក៏មិនមានទំនាក់ទំនងអ្វីនឹងការចូលឥស្លាមរបស់គេដែរ។

តើអត្ថន័យនៃឈ្មោះ វាមានអត្ថន័យផ្ទុយអំពីសាសនា ឬជំនឿដែរឬទេ?

ទេ | បាទ

ចាំបាច់ត្រូវតែផ្លាស់ប្តូរឈ្មោះដែលមានអត្ថន័យបែបនេះ

តើឈ្មោះនោះចង្អុលបង្ហាញទៅលើសាសនាដែលផ្សេងពីអ្នកឥស្លាម ឬមានភាពល្បីល្បាញរវាងសាសនាដទៃ ដែលមិនមែនជាអ្នកមូស្លីមដែរឬទេ?

ទេ | បាទ

ចាំបាច់ត្រូវតែផ្លាស់ប្តូរវាដើម្បីទប់ស្កាត់ការបង្កភាពរឹករេះ ហើយជៀសឱ្យឆ្ងាយអំពីការប្រដូចនោះ

តើវាមានអត្ថន័យអាក្រក់ដែលធ្វើឱ្យមនុស្សមិនពេញចិត្តដែរឬទេ?

ទេ | បាទ

គប្បីផ្លាស់ប្តូរវាទៅជាឈ្មោះដែលមានអត្ថន័យល្អដើម្បីឱ្យស្របជាមួយនឹងការចូលឥស្លាមរបស់បុគ្គលម្នាក់នោះ។

បើសិនជាវាមិនមានអត្ថន័យអ្វីម៉្យាងដូចខាងលើទេ មិនចាំបាច់ផ្លាស់ប្តូរវាទេ។ ពិតណាស់អ្នកមូស្លីមជាច្រើនបានស្ថិតនៅលើឈ្មោះដើមរបស់ពួកគេដែលមិនមែនឈ្មោះជាភាសាអារ៉ាប់ដោយមិនបានផ្លាស់ប្តូរឡើយក្នុងពេលដែលឥស្លាមបានរីកសុះសាយដំបូង។

# > លក្ខណៈនៃភាពស្អាតស្អំ ( ស៊ូណានុលហ្វីតរ៉ោះ )

> សាសនាឥស្លាមចង់ឱ្យអ្នកមូស្លីមមានរាងកាយស្រស់ស្អាតបំផុត។



## តើលក្ខណៈនៃភាពស្អាតស្អំ( ស៊ូណានុលហ្វីតរ៉ោះ )មានអត្ថន័យដូចម្តេច ?

លក្ខណៈនៃភាពស្អាតស្អំ( ស៊ូណានុលហ្វីតរ៉ោះ ) វាជាលក្ខណៈដែលអល់ឡោះបង្កើតមនុស្សនៅលើវា ហើយអ្នកមូស្លីមពេញលក្ខណៈដោយអនុវត្តវា ហើយនិងធ្វើឱ្យមានលក្ខណៈសម្បត្តិល្អប្រសើរ និងរាងកាយស្រស់ស្អាតបំផុត។ ដូច្នោះពិតណាស់ ឥស្លាមយកចិត្តទុកដាក់លើផ្នែកស្រស់ស្អាត និងពេញលក្ខណៈចំពោះអ្នកមូស្លីម ដោយរួមបញ្ចូលសម្រាប់គាត់នូវភាពស្អាតស្អំទាំងខាងក្រៅ និងខាងក្នុង។

អ្នកនាំសារបានមានប្រសាសន៍ថា "ភាពស្អាតស្អំមានប្រាំយ៉ាង គឺការកាត់ស្បែកចុងលិង្គ ការកោររោមប្រដាប់ភេទ កាត់ពុកមាត់ ការកាត់ក្រចក និងការដករោមក្លៀក"។ (អាល់ពូខរី:៥៥៥២ មូស្លីម:២៥៧ )

ការកាត់ស្បែកចុងលិង្គ: គឺការយកចេញនៃស្បែកដែលនៅខាងចុងនៃលិង្គ( ស្បែកដែលគ្របក្បាលលិង្គ ) ហើយជាធម្មតាគេធ្វើវានោះនៅក្នុងពេលសម្រាលកូនដំបូង។

ហើយវាជាប្រការគប្បី និងជាលក្ខណៈនៃភាពស្អាតស្អំ( ស៊ូណានុលហ្វីតរ៉ោះ )សម្រាប់បុរស។ ហើយវាមានអត្ថប្រយោជន៍សម្រាប់សុខភាពជាច្រើន ក៏ប៉ុន្តែវាមិនមែនជាលក្ខខណ្ឌសម្រាប់ចូលឥស្លាមនោះទេ ហើយមិនទទួលផលបាបនោះទេសម្រាប់ជនមូស្លីមដែលមិនបានកាត់ស្បែកចុងលិង្គ ដោយមូលហេតុគាត់ខ្លាច ឬមូលហេតុអ្វីផ្សេង។

ការកោររោមប្រដាប់ភេទ: ការយកចេញនៃសក់រុំប( រោម )នៅប្រដាប់ភេទដោយការកោរ ឬដោយវិធីសាស្ត្រផ្សេងទៀត។

កាត់ពុកមាត់: ការរក្សាទុកពុកមាត់ជាប្រការអន្តរាគ្រោះមិនមែនជាប្រការគប្បីទេ ក៏ប៉ុន្តែអ្នកមូស្លីមប្រសិនបើចង់ទុកវា គាត់មិនត្រូវទុកវែងពេកទេ ហើយត្រូវកំណត់ពេលកាត់ ឬតម្រឹមឲ្យបានខ្លី។

ថែរក្សាពុកចង្ការ: សាសនាឥស្លាមជំរុញឱ្យថែរក្សាពុកចង្ការ។ ហើយវាគឺសក់(រោម)ដុះនៅលើចង្កា និងថ្ពាល់ថ្គាម។

ការថែរក្សាវា គឺមានន័យថា ការទុកវាដោយមិនកោរវាចោល ដោយអនុវត្តតាម ស៊ុណ្ណះ(លំអាន) របស់ព្យាការីមូហាំម៉ាត់

កាត់ក្រចកដៃ: ចាំបាច់សម្រាប់អ្នកមូស្លីមតាមដានក្រចកដៃរបស់គេដោយកាត់ឱ្យខ្លី កុំឱ្យវាក្លាយជាកន្លែងកខ្វក់ និងស្មោគគ្រោក។

ការដករោមឃ្លៀក: ចាំបាច់លើជនមូស្លីមជម្រះចេញនូវរោមដែលនៅកន្លែងឃ្លៀក ដោយដកវា ឬដោយវិធីជម្រះផ្សេងទៀត ដើម្បីការពារមិនឱ្យមានក្លិនអាក្រក់ចេញពីវាមកក្រៅ។



## ជាទីបញ្ចប់




### តើជំហានបន្តគិតធ្វើយ៉ាងដូចម្តេច ?

ដោយអ្នកបានបញ្ចប់ការអានសៀវភៅនេះ ប្រាកដណាស់អ្នកបានបំពេញនូវជំហានទី១ក្នុងការស្គាល់នូវអ្វីដែលអ្នកត្រូវការវានៅក្នុងកិច្ចការសាសនារបស់អ្នក ហើយអ្វីនៅសល់នោះ គឺចាំបាច់លើអ្នកត្រូវយកចិត្តទុកដាក់អនុវត្តតាមអ្វីដែលអ្នកបានរៀនសូត្ររួច ហើយធ្វើឲ្យវាជារឿងជាក់ស្តែងក្នុងឆាកជីវិតរបស់អ្នក ព្រោះថាការចេះដឹងដោយគ្មានការអនុវត្តទេនោះ នឹងក្លាយទៅជាមហន្តរាយដល់រូបគេវិញនៅថ្ងៃបរលោក។

ម្យ៉ាងទៀត កាតព្វកិច្ចលើអ្នកត្រូវប្រឹងប្រែងក្នុងការរៀនសូត្រកិច្ចការដែលអ្នកមានសេចក្តីត្រូវការចំពោះវាតាមរយៈប្រភពដែលអាចជឿបានដែលអ្នកមិនបានប្រទះវានៅក្នុងសៀវភៅនេះទេនោះ។

ហើយជនមូស្លីម ទោះបីជំនឿរបស់គេខ្លាំងក្លាដល់កម្រិតណាក៏ដោយ ក៏រូបគេនៅតែត្រូវការបន្ថែមទៀតនូវការចង្អុលបង្ហាញ។ ហេតុដូចនេះហើយ ទើបនៅក្នុងជំពូកអាល់ហ្វាទីហះ(ជំពូកទីមួយនៃគម្ពីរគួរអាន) ដែលជាជំពូកធំធេងជាងគេនៅក្នុងគម្ពីររបស់អល់ឡោះ និងក៏ជាជំពូកដែល អ្នកមូស្លីមសូត្រវាឡើងវិញប្រចាំថ្ងៃនៅក្នុងរាល់សឡាតរបស់គេជាច្រើនដងនោះ គឺមានវាក្យខណ្ឌ "សូមទ្រង់មេត្តាចង្អុលបង្ហាញដល់ពួកយើងនូវផ្លូវដែលត្រឹមត្រូវផងចុះ"។ (គម្ពីរគួរអាន ១:៥)

### ចូរពួកអ្នកគោរពកោតខ្លាចទៅចំពោះអល់ឡោះទៅតាមលទ្ធភាពរបស់ពួកអ្នក

នៅក្នុងសៀវភៅនេះ លោកអ្នកនឹងមិនបានជួបប្រទះទេ ហើយក៏មិនមានឃើញនៅក្នុងសៀវភៅផ្សេងទៀតដែរនូវចម្លើយពិស្តារអំពីរាល់ស្ថានភាព និងហេតុការណ៍ដែលនឹងជួបវា។ ដូច្នេះជាមួយនឹងការសាកសួរអ្នកចេះដឹង ក៏អ្នកត្រូវប្រឹងប្រែងដើម្បីគោរពកោតខ្លាចចំពោះអល់ឡោះទៅតាមលទ្ធភាពរបស់អ្នកនៅក្នុងរឿងរ៉ាវដែលកើតឡើងជាបន្តបន្ទាប់ ហើយនិងព្រឹត្តិការណ៍ថ្មីនិងសេចក្តីលម្អិតនៃទំនាក់ទំនងប្រចាំថ្ងៃដែលអ្នកមិនអាចត្រលប់ទៅរកពួកអ្នកចេះដឹងបាន ដោយជឿជាក់លើបន្ទូលដ៏ថ្កុំថ្កើងរបស់អល់ឡោះដែលទ្រង់បានមានបន្ទូលថា "ចូរពួកអ្នកកោតខ្លាចអល់ឡោះតាមទៅតាមលទ្ធភាពរបស់ពួកអ្នក"។ (គម្ពីរគួរអាន ៦៤:)

### ចូរអ្នកយកចិត្តទុកដាក់គិតគូដល់បងប្អូនអ្នកដែលជាអ្នកមូស្លិម ហើយចូរអ្នកចូលទៅឲ្យបានជិតដិតនឹងពួកគេ

ចូរអ្នកនៅក្បែរបងប្អូនឥស្លាមរបស់អ្នក និងទៅកន្លែងមជ្ឈមណ្ឌលឥស្លាមឲ្យបានញឹកញាប់

ហើយសូមអ្នករស់នៅជាមួយពួកគេ រួមចំណែកជាមួយពួកគេក្នុងការសប្បាយរបស់ពួកគេ និង ទុក្ខព្រួយរបស់ពួកគេ ហើយប្រាកដណាស់ អល់ទ្បោះបានបង្គាប់ប្រើព្យាការីមូហាំម៉ាត់ ខណៈដែលគាត់គឺជាមនុស្សម្នាក់ដែលមានជំនឿជឿជាក់ដ៏អស្ចារ្យបំផុត អល់ទ្បោះប្រើឲ្យគាត់ស៊ូទ្រាំ និងប្រឹងប្រែងក្នុងការសេពគប់ពួកអ្នកសាងអំពើល្អ ដូចដែលទ្រង់បានមានព្រះបន្ទូលថា "ចូរអ្នកខ្លួនឯងអត់ធ្មត់ជាមួយនឹងបណ្ដាអ្នកដែលគោរពសក្ការៈចំពោះម្ចាស់របស់ពួកគេទាំងព្រឹកទាំងល្ងាច ដោយពួកគេចង់បានការយល់ព្រមពីទ្រង់"។ គម្ពីរគួរអាន ១៨:២៨

ម៉្យាងទៀត ព្យាការីមូហាំម៉ាត់បានព្រមានមិនឲ្យឃ្លាតឆ្ងាយអំពីក្រុមអ្នកមូស្លីមនោះទេ ព្រោះថា វាជាមូលហេតុដែលអាចនាំឲ្យវង្វេង ហើយនិងប្រាស់ចាក ប្រៀបបីដូចជាសត្វពពែដែលឃ្លាតឆ្ងាយអំពីក្រុមរបស់វានឹងអាចទទួលរងគ្រោះថ្នាក់ធំបំផុតពីសំណាក់សត្វខ្លា។

អ្នកនាំសារបានមានប្រសាសន៍ថា "ចាំបាច់លើពួកអ្នកត្រូវស្ថិតនៅជាមួយក្រុមអ្នកមូស្លីម។ ជាការពិតណាស់ សត្វខ្លាវាស៊ីសត្វពពែណាដែលបែកចេញពីហ្វូង"។

ដូចនេះ ជាទូទៅកាលណាជនមូស្លីមបញ្ជិតខ្លួននឹងបងប្អូន(រួមសាសនា) របស់គេ និងនៅជាប់លាប់ជាមួយពួកគេនោះ វាគឺជាមូលហេតុដ៏ធំធេងដែលនាំមកនូវផលល្អ ទទួលបានការបង្ហាញផ្លូវ និងស្នេហភាពសាសនាក្នុងចិត្តរបស់គេ។

ចុះយ៉ាងណាទៅវិញ ចំពោះអ្នកដែលទើបចាប់ផ្ដើមដំណើររបស់គេ ហើយត្រូវការអ្នកដែលលួងលោមគេ និងយកចិត្តទុកដាក់ចំពោះគេទៀតនោះ?

សូមឲ្យអល់ទ្បោះជាម្ចាស់ចង្អុលបង្ហាញដល់អ្នក ហើយធ្វើឲ្យអ្នកនៅឋិតថេរនៅលើសាសនាឥស្លាម និងប្រទានដល់អ្នកនូវឧបការគុណទាំងខាងផ្លូវកាយ និងផ្លូវចិត្តរបស់អ្នក៕




دليل المسلم الجديد

The New Muslim **Guide**

**Guide** du converti musulman

ለአዲስ ሰለምቴዎች መመሪያ

**Ang Gabay** Para sa Bagong Muslim

**Vodič** novom muslimanu

新改宗者のためのガイドブック

**La guida del nuovo musulmano**

**새내기 무슬림을 위한 지침서**

**Handbuch für den neuen Muslim**

नव मुस्लिम मार्गदर्शिका

**Guia para o novo muçulmano**

新穆斯林指南

**Руководство** для принявшего ислам

**Guía para el Nuevo Musulmán**

U.K -Birmingham
B11 1AR
Tel : +441214399144

K . S . A
Tel : +966114486000

www.newmuslimguide.com
www.guide-muslim.com
info@modern-guide.com

Cambodian

គោលជំនឿរបស់អ្នក



អនាម័យរបស់អ្នក



ការសឡាតរបស់អ្នក



ការបួសរបស់អ្នក



ហ្សាកាត់របស់អ្នក



ការធ្វើ
ធម្មយាត្រាហាជ្ជីរបស់អ្នក



ប្រតិបត្តិការ
ហិរញ្ញវត្ថុរបស់អ្នក



ចំណីអាហាររបស់អ្នក
និងភេសជ្ជៈរបស់អ្នក



សម្លៀកបំពាក់
របស់អ្នក



គ្រួសាររបស់អ្នក



សីលធម៌របស់អ្នក
នៅក្នុងសាសនាឥស្លាម



ជីវិតថ្មីរបស់អ្នក



# មគ្គុទេសក៍មូស្លីមថ្មី

ហើយមគ្គុទេសក៍ដែលត្រូវបានធ្វើជារូបភាពនេះ វានឹងផ្តល់ឲ្យអ្នក (សម្រាប់អ្នកកាន់សាសនាឥស្លាមថ្មី ) ជាជំហានទី១ និងជាកម្រិតមូលដ្ឋានក្នុងការយល់ដឹងពីសាសនាដ៏ធំធេងនេះ ដែលជាការប្រទានមួយធំបំផុតសម្រាប់មនុស្សលោក នៅគ្រប់ទិដ្ឋភាពទាំងអស់នៃឆាកជីវិតដែលអ្នកកំពុងរស់នៅ និងដែលអ្នកកំពុងត្រូវការចំពោះវា។ ដូច្នេះដែរ មគ្គុទ្ទេសក៍នេះ វានឹងឆ្លើយតបទៅលើសំណួរបន្ទាន់ជាច្រើនរបស់អ្នក ហើយវាជួយគាំទ្រអ្នកក្នុងការប្រឈមនឹងការពិតដែលនៅជុំវិញខ្លួនអ្នកតាមរចនាបទច្បាស់លាស់ ងាយស្រួល ហើយ និងទទួលបានព័ត៌មានជាក់លាក់ និងត្រូវបានចងក្រងឡើងដោយអនុលោមទៅតាមព្រះគម្ពីរគួរអាន និងស៊ុណ្ណះ(ឈំអាន)របស់ព្យាការីមូហាំម៉ាត់ ហើយដោយសារសៀវភៅជាមគ្គុទ្ទេសក៍ដ៏ពិស្តារដែលគួឲ្យចាប់អារម្មណ៍សម្រាប់អាននេះ វាក៏ជាឯកសារយោងដែលអ្នកអាចត្រលប់ទៅរកព័ត៌មានពិស្តាររបស់វាយ៉ាងងាយស្រួលបំផុតរៀងរាល់ពេលដែលអ្នកប្រឈមនឹងបញ្ហា ឬក៏អ្នកត្រូវការយល់ដឹងអំពីក្បួនច្បាប់របស់អល់ឡោះនៅក្នុងរឿងអ្វីមួយ។

www.newmuslimguide.com

MODERN GUIDE
Tel: +441214399144
uk@modern-guide.com

NEW MUSLIM GUIDE